# វិបស្សនានយ

## ភាគ ១

ព្រះសោភណមហាថេរ (មហាស៊ីសយាដ័រ) រចនា



ប្រមូលរៀបរៀងប្រែដោយ

ភិក្ខុអមរាភិវំស : ថោន សីលា

ភិក្ខុសិក្ខានន្ទ : ឈី សារាឌី

ពុទ្ធសករាជ ២៥៥១

៥០០០ឆ្នាំ

WWW.5000-YEARS.ORG



ឯកសារនេះបាន ទាញចេញពី គេហទំព័រ

www.5000-years.org

## គន្ថារម្ភកថា

ព្រះពុទ្ធវចនៈទាំងអស់ មាន ៨៤០០០ ព្រះធម្មក្ខន្ធ ចែកជាព្រះវិន័យមាន ២១០០០ ព្រះធម្មក្ខន្ធ ចែកជាព្រះសូត្រមាន ២១០០០ ព្រះធម្មក្ខន្ធ និងព្រះអភិធម្មមាន ៤២០០០ ព្រះធម្មក្ខន្ធ បើពោលដោយសិក្ខាមាន៣យ៉ាងគឺ អធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខាតែដែលអាចចូលដល់សីល សមាធិនិងបញ្ញាបាន អាស្រ័យធុរៈ ២ យ៉ាងទៀត គឺ គន្ថធុរៈ និងវិបស្សនាធុរៈ ក្នុងសម័យមួយព្រះចក្ខុបាលត្ថេរ ( នាមដើមមហាបាល ) ក្រោយពីបានឧបសម្បទាហើយ មិនយូរប៉ុន្មាន ក៏ចូលទៅរកព្រះបរមសាស្តា ហើយទូលសួរអំពីធុរៈក្នុងព្រះសាសនា ។ បន្ទាប់មកព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងឆ្លើយតបបញ្ហារបស់ចក្ខុបាលត្ថេរថា

គន្ថធុរំ វិបស្សនាធុរន្តិ ទ្វេយេវ ធុរានិ ភិក្ខុ ។

"ម្នាលភិក្ខុ ( ក្នុងសាសនានេះ ) ធុរៈមាន ២ យ៉ាងប៉ុណ្ណោះ គឺគន្ថធុរៈ និងវិបស្សនាធុរៈ" ។

ការរៀនយកនិកាយមួយក្តី និកាយពីរក្តី ឬក៏ចេះចាំព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកទាំងអស់ក្តី តាមសមគួរដល់បញ្ញារបស់ខ្លួន ហើយទ្រទ្រង់ទុក សម្តែង ឆ្លើយ ព្រះពុទ្ធវចនៈនេះឯង ឈ្មោះថា "គន្ថធុរៈ" ។

ចំណែកឯការចាប់ផ្តើមប្រារព្ធសេចក្តីព្យាយាម កំណត់ដឹងរូបធម៌នាមធម៌ក្នុងអត្តភាពនេះ ញុំាងវិបស្សនាឲ្យកើតឡើងដោយអំណាចនៃការធ្វើឲ្យជាប់តគ្នានូវសីល សមាធិ និងបញ្ញាប្រេចក្សច្បាស់នូវត្រៃលក្ខណ៍ ហើយកាន់យកនូវវិវេកធម៌ជាអារម្មណ៍ មានចិត្តបង្អោនទៅកាន់ព្រះនិព្វានរឿយៗ នេះឈ្មោះថា "វិបស្សនាធុរៈ" ។ ( ខុ. ធ. យមកវគ្គ )

ពេលនេះ យើងខ្ញុំព្រះករុណាទាំងឡាយបានរៀបចំប្រែនូវគម្ពីរមួយដែលមានឈ្មោះថា វិបស្សនាន័យដែលមានការរចនាដ៏វិចិត្ររបស់ព្រះថេរៈ ព្រះនាមសោភណមហាថេរៈ ជនជាតិភូមា ( មហាស៊ីសយាដ័រ ) ក្នុងរជ្ជកាលប្រហែល ៦០ ឆ្នាំមុន ។ ខ្ញុំព្រះករុណាទាំងឡាយបានសិក្សាស្រាវជ្រាវនូវគម្ពីរក្បួនច្បាប់ព្រះពុទ្ធសាសនា ថែមទាំងបានសម្លឹងឃើញនូវអត្ថប្រយោជន៍

នៃព្រះពុទ្ធវចនៈមានតម្លៃកាត់ថ្លៃមិនបាន ដែលព្រះបរមសាស្ដាកសាងអភិនីហារបារមីអស់ ២០ អសង្ខេយ្យ និងកម្រៃមួយសែនមហាកប្បដើម្បីឲ្យបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដោយគោលបំណងរបស់ព្រះអង្គ គឺចង់ឲ្យសត្វលោករួចផុតអំពីសេចក្ដីទុក្ខ ក្នុងសង្សារសាគរ គឺសមុទ្រនៃសង្សារវដ្ដ ។

ក្រោយអំពីការត្រាស់ដឹងរបស់ព្រះអង្គហើយទ្រង់ត្រាស់ប្រកាសសម្ដែងនូវព្រះនិព្វានដែលជាសន្តិបទហើយបើកទ្វារនៃសង្សារវដ្ដ ឯទ្វារនោះវិញមិនទាន់បិទនៅឡើយទេ សូម្បីព្រះអង្គបរិនិព្វានទៅហើយក៏ដោយ តែទ្វារនោះនៅបើករហូត ។

ខ្ញុំព្រះករុណាជ្រះថ្លាក្នុងការសិក្សាស្រាវជ្រាវគម្ពីរព្រះត្រៃបិដក អដ្ឋកថា និងដីកា តែដោយឡែកក្នុងពេលនេះខ្ញុំព្រះករុណាទាំងឡាយបានរៀបចំប្រែគម្ពីរវិបស្សនាន័យនេះមកជាខេមរភាសាអស់រយៈពេល២៦ ថ្ងៃ គឺចាប់ផ្ដើមពីថ្ងៃ ១២ កើត ខែបុស្សដល់ថ្ងៃ ៨ កើតខែមាឃ ក្នុងពុទ្ធសករាជ ២៥៥១បានចប់សព្វគ្រប់ហើយ សង្ឃឹមថា បករណ៍នេះ នឹងអាចកាត់បង់នូវសេចក្ដីសង្ស័យ នឹងមតិខុះ ៗ ផងដែរ ម្យ៉ាងទៀត ខ្ញុំព្រះករុណាទាំង

ឡាយសង្ឃឹមរំពៃថា ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងញាតិ ញោមពុទ្ធបរិស័ទទាំងអស់ និងជួយកែតម្រូវនូវសេចក្ដីខុស ឆ្គាំឆ្គងនូវអក្ខរៈ ព្យញ្ជនៈ ទាំងអស់ដែលភ្លាំងភ្លាតពុំខាន ដោយឡែកមួយទៀត សៀវភៅនេះមានការគាំទ្រទទួលស្គាល់អំពីសំណាក់មជ្ឈដ្ឋានសកលលោក មានសំណាក់ព្រះសាសនាប្រទេសកូមា ថៃជាដើម ជាពិសេសគឺ សំណាក់រៀនព្រះបរិយត្តិធម៌ស្ទឹងក្រញូង ស្រុកសំឡូត ខេត្តបាត់ដំបង...។

ឆាយមញ្ញស្ស កុព្វន្តិ ទិដ្ឋន្តិ សយមាតបេ
ផលានិបិ បរស្សេវ រុក្ខា សប្បុរិសា ឥវ ។

មហាព្រឹក្សាជាម្លប់ឲ្យដល់អ្នកដទៃ តែខ្លួនឯងវិញនោះត្រូវអត់ធន់ចំពោះកំដៅថ្ងៃដ៏ខ្លាំងក្លា ឯដើមឈើនោះវិញ រមែងញ៉ាំងផលដើម្បីអ្នកដទៃដោយពិត សប្បុរសទាំងឡាយ រមែងប្រព្រឹត្តខ្លួនដូចដើមឈើ ។ សូមអនុមោទនា........!!!

# រតនប្បណាម

ពុទ្ធោ សុសុទ្ធោ ករុណាមហណ្ណវោ
យោច្ចន្តសុទ្ធព្វរញាណលោចនោ
លោកស្ស បាបូបកិលេសឃាតកោ
វន្ទាមិ ពុទ្ធំ អហមាទរេន តំ ;

ធម្មោ បទីបោ វិយ តស្ស សត្ថុនោ
យោ បគ្គបាកាមតភេទភិន្នកោ
លោកុត្តរោ យោ ច តទត្ថទីបនោ
វន្ទាមិ ធម្មំ អហមាទរេន តំ ;

សង្ឃោ សុខេត្តាភ្យតិខេត្តសញ្ញិតោ
យោ ទិដ្ឋិសន្តោ សុគតានុពោធកោ
លោលប្បហីនោ អរិយោ សុមេធសោ
វន្ទាមិ សង្ឃំ អហមាទរេន តំ ;

ឥច្ចេវមេកន្តភិបូជនេយ្យកំ
វត្ថុត្តយំ វន្ទយតាភិសង្ខតំ

បុញ្ញំ មយា យំ មម សព្វបទ្ទវំ
មា ហោន្តុ វេ តស្ស បភាវសិទ្ធិយា ។

ព្រះសម្ពុទ្ធម្ចាស់អង្គឯណា ទ្រង់គុណថ្លៃថ្លាល្អម៉ត់ហ្មង គឺវិសុទ្ធិគុណស្អាតកន្លង ករុណាគុណផង ជ្រៅទូលាយ ។ ដូចកល់អន្លង់ជារជំឯក ល្ងង់ល្ងើយអនេកផុតអធិប្បាយ ទាំងបញ្ញាគុណរុងរឿងឆ្ងាយ ប្រសើរសុសសាយសព្វលើសលប់ ។ ទ្រង់សម្លាប់ចោលគ្រឿងសៅហ្មង បាបកម្មចាំចង់សត្វក្នុងភព ដោយការព្យាយាមមិនឈរឈប់ រាល់ថ្ងៃរាល់យប់សព្វវេលា ។ យើងខ្ញុំបង្គំព្រះពុទ្ធនោះ ល្បីកេរ្តិ៍ឈ្មោះផុតភពភា ដោយការគោរពដ៏ថ្លៃថ្លា ចិត្តកាយវាចាទាំងបីពិត ។

ព្រះធម៌នៃអង្គព្រះសាស្ដា រុងរឿងក្លៃថ្លាល្អវិចិត្រ ដូចកល់ប្រទីបខ្ពាត់ងងឹតទ្រោលបំភ្លឺជុតឆ្ងាយក្ដីណា ។ ជាធម៌ផ្នែកផ្សេងដោយប្រភេទមគ្គផលទាំងប៉ែតប្រាំបីឃ្លាជាលោកុត្តរច្នេងលោកា បំភ្លឺប្រាជ្ញាណែប្រយោជន៍ ។ ធម៌ណាដែលខ្ញុំថ្លែងអធិប្បាយ បន្ទៃប្រស្រាយជ្រៅលន្ទោច ខ្ញុំសូមបង្គំផ្ចង់ចិត្តស្រោចមិនរួញរាញោចចាកធម៌នោះ ។

ព្រះសង្ឃអង្គណាជាស្រែបុណ្យ ល្អល្អះលើសលន់ច្រើន ជាន់ស្មោះ សញ្ញាជាប្រែឥតចន្លោះ ប្រសើរចំពោះរបស់ជន ។ មានការយល់ត្រូវសន្ដានស្ងប់ ជ្រាបធម៌ផងសព្វមិនមោហន្ធ តាមផ្លូវព្រះសុគតម្ចាស់ទិព្វតន់ លះការទោបទន់ក្ដីឡេះឡោះ ។ ជាអរិយសង្ឃ ទ្រង់ប្រាជ្ញាគឺស្វាងជ្រះថ្លាផ្ទះសាយសុសទម្លាយ កិលេសឥតមានមោះមន្ទិលពព្រះក្នុងសន្ដាន ។ ខ្ញុំសូមវន្ទា ព្រះសង្ឃនោះ ទ្វារបីចំពោះក្រាបប្រួញប្រាណ គោរពកោត ក្រែងសង្ឃប៉ុន្មានដែលបានទិព្វានផុតទុក្ខភ័យ ។ បុណ្យដែល យើងខ្ញុំបានតាក់តែងវន្ទា ចាប៉ែងវត្ថុត្រ័យដែលគួរបូជាពល់ សម័យជាឯកឥតន័យណាដូចនេះ ។ អន្តរាយទាំងពួងរបស់ខ្ញុំ សូមឲ្យជោរទុំជ្រះរបេះកុំមានដល់ខ្ញុំ អ្នកសំណេះសំណាល ពោលគុណទាំងបីឡើយ ។ សូមសម្រេចដោយកម្លាំងដែល យើងខ្ញុំតាំងយ៉ាងនេះហើយចំពោះត្រ័យរ័ត្នម្ចាស់គ្រាណាត្រើយ សូមបានសះស្បើយគ្រានេះឯង ។

( បុរាណភាសិត )

# ជីវប្រវត្តិសង្ខេប

ព្រះសោភណមហាថេរៈ ( មហាស៊ីសយាដ័រ )

អគ្គមហាបណ្ឌិត...៊

១. ជាតិភូមិ ព្រះសោភណមហាថេរៈ ( មហាស៊ីសយាដ័រ )

២. នាមដើមថា តាក់វិន កើតនៅថ្ងៃសុក្រទី ២៩ ខែកក្កដាត្រូវនឹងថ្ងៃ ៣ កេដ ខែ ៨ វេលាម៉ោង ០៣.០០នាទី ក្នុងភូមិ សិកគុន បេញទៅ ១១២៦៣ គ.ម. អំពីខេត្ត ជវេភោ ដែលធ្លាប់ជាទីក្រុងចាស់នៅ

ភាគខាងជើងនៃប្រទេសភូមា ។

បិតានិងមាតា គឺនាយកាន់ប៉ៃនិង នាងអុក លោកមានបងប្អូនរួមបិតា មាតា ៧ នាក់គឺ ៖

១. នាយតិន ដល់អាយុ ២៨ ឆ្នាំស្លាប់

២. ព្រះសោភណមហាថេរៈ

៣. នាងខិន ដល់អាយុ ១៦ ឆ្នាំស្លាប់

៤. ទាយមិន ដល់អាយុ ២០ឆ្នាំផ្ដាយស្លាប់ ។

៥. ទាយបះយិន ដល់អាយុ ២០ឆ្នាំផ្ដាយស្លាប់ ។

៦. នាងសិន ដល់អាយុ ២៨ ឆ្នាំស្លាប់ ។

៧. នាងសាប់ មានបុត្រប្រុស ៣ បុត្រស្រី ៣ ដល់អាយុ ៥០ ស្លាប់ ។

២. **បព្វជ្ជា** បព្វជ្ជាជាសាមណេរកាល ព.ស.២៤៥៩ អាយុ ១២ ឆ្នាំ ក្នុងវត្ត **បយិនមនា** មានព្រះអទិច្ចៈជាព្រះឧបជ្ឈាយ៍ ដោយមានឆាយាថា **សោភណៈ** ប្រែថា " អ្នកល្អក្នុងព្រះសាសនា ( ជនជាតិភូមា មិនទិយមប្រើឈ្មោះដើម ដែលមាតាបិតាដាក់ តែប្រើ ឆាយាជាភាសាបាលី ក្រោយអំពីបានបព្វជ្ជាហើយ ) ។

៣. **ឧបសម្បទា** លោកបានឧបសម្បទាជាភិក្ខុក្នុងថ្ងៃទី ២៦ ខែ វិច្ឆិកា ព.ស. ២៤៦៦ ត្រូវនឹងថ្ងៃច័ន្ទ ៤ រោជ ខែ ១២ កាលអាយុ ១៩ ឆ្នាំ និង ៤ ខែ ដោយមានព្រះសុមេធាថេរៈ ជាព្រះឧបជ្ឈាយាចារ្យ និង ព្រះទិម្មលៈ ជាអ្នកសូត្រកម្មវាចា ។

៤. ការសិក្សា លោកបានសិក្សាព្រះបរិយត្តិធម៌វត្តកំណើត និងវត្តដទៃច្រើនវត្តទៀតផង រហូតប្រឡងជាប់ទាំង ៣ ថ្នាក់គឺ ថ្នាក់បឋមវែ ( ថ្នាក់ដំបូង ) បឋមឡាត់ ( ថ្នាក់កណ្តាល ) បឋមជី ( ថ្នាក់ខ្ពស់ ) ដោយប្រឡងបានថ្នាក់បឋមជីក្នុង ព.ស.២៤៧០ ក្នុងសម័យនោះ ការប្រឡងបរិយត្តិធម៌មានត្រឹមតែ ៣ ថ្នាក់ ។ ក្រោយអំពីនោះ ទើបទៅសិក្សាបន្តនៅខេត្តម៉ាន់ដីលេ កាលមានអាយុ ២៤ ឆ្នាំ ក្នុង ព.ស. ២៤៧១ តមកក្នុងព.ស.២៤៧២ បានទៅស្នាក់នៅក្នុងវត្ត តងវ៉ៃក្វេ ខេត្តម៉ងឡាំយៃ តាមពាក្យអារាធនារបស់ពៅរពិការវត្ត តងវ៉ៃក្វេ ដែលជាអ្នកស្រុករបស់ ដើម្បីរៀនបរិយត្តិធម៌ក្នុងសំណាក់បន្តមកទៀត ២ ឆ្នាំ ក្នុង ព.ស. ២៤៨៣ រដ្ឋបាលបានផ្តើមការបោតប្រឡងថ្នាក់ធម្មចរិយៈ ( ថ្នាក់គ្រូបង្រៀនធម៌ ) ឡើងតាមសមាគមឯកជន ខេត្តយ៉ាងកុង ឈ្មោះថា បេតិយង្គៈសមាគមឯកជនខេត្តម៉ាន់ដីលេឈ្មោះថា សក្យសីហៈ ពេលនោះលោកបានចូលប្រឡងថ្នាក់ថ្មីនេះ ទីងអាចប្រឡជាប់ ៨ គម្ពីរជាវិជ្ជាការ ៣ គម្ពីរ គឺ ព្រះវិន័យ ( មហាវគ្គ និងសមន្តប្បាសាទិកា ) ព្រះសូត្រ( សីលក្ខន្ធវគ្គ និងអដ្ឋកថាសីលក្ខន្ធវគ្គ ) ព្រះអភិធម្ម

(ធម្មសង្គណី និងអដ្ឋសាលិនី ) ព្រមដោយគម្ពីរដទៃ ៥ គម្ពីរទៀត មានគម្ពីរមហាវគ្គ និងអដ្ឋកថាជាដើម ទើបបានទទួលគុណវុឌ្ឍិជាសាសនធជៈ សិរិបវរធម្មាចរិយៈ ក្នុងព.ស. ២៤៨៣ ។

៥. ការបដិបត្តិ កាលឧបសម្បទាបាន ៨ ព្រះវស្សា ក្នុងថ្ងៃ ៧ កើត ខែ ២ ព.ស.២៤៧៤ លោកបានការអនុញ្ញាតអំពី ចៅអធិការវត្តតង់វៃក្លេ ដើម្បីទៅចំរើនវិបស្សនា ដោយមានភិក្ខុរួមដំណើរទៅបដិបត្តិធម៌ មួយរូបទៀតដែលឧបសម្បទាបាន ៦ ព្រះវស្សា ឈ្មោះថា តេជវន្តៈ លោកជ្រើសខ្លួនជាសិស្សរបស់ព្រះនារទៈ ( ជនជាតិកូមាហៅ លោកថា មិនករវិនជេតវិនស្យ៉ាជ័រ ) វត្តមិនករវិនជេតវិន ខេត្ត តៈថោង ដែលមានកិត្តិស័ព្ទល្បីខ្ចរខ្ចាយទូទាំងប្រទេសថា ជាអ្នកទ្រទ្រង់បរិយត្តិធម៌ និងបដិបត្តិ លោកមកដល់វត្តនេះក្នុងថ្ងៃ ៥ កើត ខែ ៣ ព.ស. ២៤៧៤ លោកបានបដិបត្តិកន្លែងនោះអស់រយៈពេល ៤ ខែ ។

៦. ឋានៈ

ក. ការងារប្រក្រតី ព.ស. ២៤៧៤ ជាអ្នកមើលការខុសត្រូវ

វត្តតងវៃក្លៃ ពោលគឺក្រោយអំពីលោកទៅបដិបត្តិធម៌បាន ៤ ខែ ចៅអធិការវត្ត មានវ័យ ៧៨ ឆ្នាំ បានអាពាធធ្ងន់ដោយរោគជរា ទើបបញ្ជូនទូរលេខសូមឲ្យលោកត្រឡប់មកវត្ត កាលលោកត្រឡប់ទៅបំរើបានត្រឹមតែ ៧ ថ្ងៃ ចៅអធិការក៏មរណភាព លោកទើបទទួលតំណែងជាអ្នកមើលការខុសត្រូវក្នុងវត្ត ។

ព.ស.២៤៧៥ ជាចៅអធិការវត្តតងវៃក្លៃ ខេត្តម៉ងឡាំយៃ ។

ព.ស. ២៤៨៤ ជាចៅអធិការវត្តមហាស៊ី ( វត្តស្គរធំ ) ក្នុងស្រុក សិកគុងជវរោ ។ ពាក្យថា មហាស៊ី ប្រែថា "ស្គរធំ" តមកទើបបានសន្មតិនាមតាមឈ្មោះវត្តថា មហាស៊ីសយាដូ "ព្រះគ្រូវត្តស្គរធំ" ។

ព.ស.២៤៩០ ជាចៅអធិការសំណាក់មហាស៊ី ខេត្តយ៉ាងកុង តាមពាក្យអារាធនារបស់សមាគមសាសនានុគ្រោះ ដែលមានប្រធានគឺនាយតៃន ជាគហបតិធំទីងបានទទួលតំណែងជាមន្ត្រី អំពីរដ្ឋបាលអង់គ្លេសដែលបានមកគ្រប់គ្រងប្រទេសភូមាក្នុងសម័យនោះ។

ខ. ការងារគន្ថធុរៈ

ព.ស. ២៤៩៣ រួមគណៈតែងបទានុក្រមព្រះត្រៃបិដកបាលីភូមា ក្នុងពួកស្រៈ ៨ សម្លេង ។

ព.ស. ២៤៩៧- ២៤៩៩ ជាអ្នកសាកសួរទូវព្រះត្រៃបិដក ( សង្គីតិបុច្ឆកៈ ) ក្នុងសម័យសង្គាយនាគ្រាទី ៦ ( ឆដ្ឋសង្គាយនា ) ដែលផ្តើមក្នុងថ្ងៃពេញបូណ៌មីខែ ៦ ព.ស. ២៤៩៧ ទីងសម្រេចក្នុងថ្ងៃពេញបូណ៌មីខែ ១០ ព.ស. ២៤៩៩ និងជាអ្នករួមគណៈត្រួតជម្រះព្រះត្រៃបិដក ៥ អង្គ ដែលហៅថា **ឱសានសោធកៈ** ។

ព.ស. ២៤៩៩-២៥០២ រួមគណៈត្រួតជម្រះគម្ពីរអដ្ឋកថាក្នុងសម័យអដ្ឋកថាសង្គាយនាចាប់ផ្តើមក្នុងថ្ងៃ ៩ កេដ ខែ ១ ព.ស. ២៤៩៩ ទីងសម្រេចក្នុងថ្ងៃ ៦ កេដ ខែ ៣ ព.ស. ២៥០២ ។

ព.ស. ២៥០៣-២៥០៤ រួមគណៈត្រួតជម្រះដីកាក្នុងសម័យសង្គាយនាដែលផ្តើមក្នុងថ្ងៃ ៣ កេដខែ ១២ ព.ស. ២៥០៣ ទីងសម្រេចក្នុងថ្ងៃ ១២ កេដ ខែ ៣ ព.ស. ២៥០៤ ។

គ. **ការនាំវិបស្សនាធុរៈ**

លោកបង្រៀនកម្មដ្ឋានតាំងអំពីមកស្នាក់នៅវត្តមហាស៊ី ខេត្តជវកោ រហូតប្តូរពីសំណាក់មហាស៊ីមកខេត្តយ៉ាំងកុង រហូតដល់អស់ជីវិត ។

សំណាក់សាខានៃមហាស៊ី បើកបង្រៀនដោយវិបស្សនាចារ្យសិស្សរបស់លោក មានប្រហែល ៣០០ កន្លែងទូទាំងប្រទេស មានបញ្ជីរាយឈ្មោះអ្នកបដិបត្តិ ដែលបានស្នាក់នៅចំរើនវិបស្សនាកន្លែង សំណាក់មហាស៊ី ក្នុងសម័យដែលលោកនៅមានជីវិតប្រហែល ៧០០,០០០ នាក់ ។

**ឃ. ការងារវិជ្ជាការ ( រៀបចំសៀវភៅ )**

ព.ស. ២៤៨១ គន្លងផ្លូវនៃវិបស្សនា

ព.ស. ២៤៨៧ វិបស្សនានយ

ព.ស. ២៤៩៣ មហាសតិបដ្ឋានសូត្រនិស្សយៈ

ព.ស. ២៤៩៩ វិសុទ្ធិញាណកថា (បាលី)

ព.ស. ២៥១០ វិសុទ្ធិមគ្គនិទានកថា (បាលី)

ព.ស. ២៥០៩-២៥១០ វិសុទ្ធិមគ្គមហាដីកានិស្សយ(៤ក្បាល)

ព.ស. ២៥១៤-២៥១៧ វិសុទ្ធិមគ្គប្រែ (៤ ក្បាល)

ក្រោយអំពីនោះនៅមានធម្មទេសនា ដែលជាប់ទាក់ទងជាមួយនឹងការចំរើនវិបស្សនាកាវនាដែលបានទទួលការអោត់កាស្សេតនឹងបោះពុម្ពជាសៀវភៅទៀតប្រហែលជា ៧០ ក្បាល ដូចជាធម្មទេសនាពោជ្ឈង្គៈជាដើមដោយចំណែកធំៗ បានទទួលប្រែជាភាសាអង់គ្លេសទុកហើយ ។

ង.ការផ្សព្វផ្សាយវិបស្សនាកាវនាក្នុងប្រទេសផ្សេងៗ

ព.ស. ២៤៩៤ ទៅប្រទេសថៃ គោល័មបៀ នឹងវៀតណាម

ព.ស. ២៤៩៦ ទៅប្រទេសឥណ្ឌា និង ស្រីលង្កា

ព.ស. ២៥០២ ទៅប្រទេសឥណ្ឌា និង ស្រីលង្កា

ព.ស. ២៥២២ ទៅប្រទេសអាមេរិក ហាវ៉ៃ អង់គ្លេស និងសហភាពអឺរុប

ព.ស. ២៥២៣ ទៅប្រទេសអង់គ្លេស ស្រីលង្កា សិង្ហបូរី

ម៉ាលេស៊ី និងថៃ

ព.ស. ២៥២៤ ទៅប្រទេសឥណ្ឌា និងនេប៉ាល

៧. សមណសក្តិ

ព.ស. ២៤៩៤ បានទទួលតំណែង អគ្គមហាបណ្ឌិត ។

៨. ការអស់ទៅនៃជីវិត

ថ្ងៃទី ៤ ខែសីហា ពុទ្ធសករាជ ២៥២៥ លោកមានអាការថប់ដង្ហើមទីងមរណភាព ដោយរោគខ្យាយបេះដូង ដែលកម្រើកយ៉ាងរហ័ស រួមអាយុ ៧៨ ឆ្នាំ ជីវប្រវត្តិដោយសង្ខេបរបស់លោកបានទទួលចារិកទុកក្នុងសៀវភៅ Whoûs Who in the Word ឈ្មោះសៀវភៅ ជីវប្រវត្តិ ដែលចារិកប្រវត្តិរបស់បុគ្គលដ៏សំខាន់ៗក្នុងលោកដែលស្លាប់បាត់បង់ជីវិតហើយ ។

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ

ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោតិ។

សង្ខារទាំងឡាយមិនទៀងហ្ន៎ មានកិរិយាកើតឡើងនិងការសូន្យ

ទៅវិញជាធម្មតា កិរិយាផ្ចាប់នូវសង្ខារទាំងនោះបាន ទើបនាំមក

នូវសេចក្តីសុខ ។ មហាបរិនិព្វានសូត្រ.៣២៧

ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា

អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី

អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់

នៅខាងមុខ ។ មហាបរិនិព្វានសូត្រ. ២៥៦

បរេ សទ្ធិដ្ឋិបរាមាសី អាធានគ្គាហី ទុប្បដិ និស្សគ្គី

ភវិស្សន្តិ មយមេត្ថ អសទ្ធិដ្ឋិបរាមាសី អនាធានគ្គាហី

សុប្បដិនិស្សគ្គី ភវិស្សាមាតិ សល្លេខោ ករណីយោ ។

“អ្នកទាំងឡាយ គប្បីជុសខាត់ខ្ទង់ក្នុងសេចក្តីនេះថា ពួកជនដទៃ

សូម្បីនឹងជាមនុស្សប្រកាន់មាំ ក្នុងការយើញរបស់ខ្លួន ប្រកាន់មាំ

ដ៏ក្រៃលែង នឹងលះបង់ក្រោបានដោយលំបាក តែពួកយើងនឹងមិន

ជាអ្នកប្រកាន់មាំ ក្នុងការយើញរបស់ខ្លួន មិនប្រកាន់មាំដ៏ក្រៃលែង

ហើយទីផលៈភក្ដីបានដោយឆាយ"ៗ វិសុទ្ធិមគ្គ. ១. ៣៩

ន សីលព្វតមត្តេន ពាហុសច្ចេន វា បនអថ វា
សមាធិលាភេន វិវិត្តសយនេន វា ៗ
ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំភិក្ខុ
វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ ៗ

"ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់នូវការអស់អាសវៈទេ កុំអាល ទុកចិត្ត ដោយគុណត្រឹមតែសីលនិងវត្ត ឬដោយភាពជាអ្នកចេះ ដឹងច្រើន មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុង ទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណោះថា អាត្មាអញពាល់ ត្រូវនូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វដូច្នេះឡើយ" ៗ

ខុ. ខុ. ធម្មបទវគ្គ ៥២. ៧៨ ៗ

# អក្សរសង្ខេបឈ្មោះគម្ពីរ ៈ

( ព្រះត្រៃបិដក=ភាគ, វគ្គ, ទំព័រ, អដ្ឋកថានិងដីកា= ភាគ,ទំព័រ )

## ព្រះត្រៃបិដក

| | |
|---|---|
| វិ. មហាវិ. | វិនយបិដក មហាវិភង្គ |
| វិ. ភិក្ខុនី. | វិនយបិដក ភិក្ខុវិភង្គ |
| វិ. មហា. | វិនយបិដក មហាវគ្គ |
| វិ. ចុល្ល. | វិនយបិដក ចុល្លវគ្គ |

## ព្រះសុត្តន្តបិដក

| | |
|---|---|
| ទី. សី. | ទីឃនិកាយ សីលក្ខន្ធវគ្គ |
| ទី. មហា. | ទីឃនិកាយ មហាវគ្គ |
| ទី. បា. | ទីឃនិកាយ បាដិកវគ្គ |
| ម. មូ. | មជ្ឈិមនិកាយ មូលបណ្ណាសក |
| ម. ម. | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក |
| ម. ឧ. | មជ្ឈិមនិកាយ ឧបរិបណ្ណាសក |
| សំ. ស. | សំយុត្តនិកាយ សគាថវគ្គ |
| សំ. និ. | សំយុត្តនិកាយ និទានវគ្គ |
| សំ. ខ. | សំយុត្តនិកាយ ខន្ធវគ្គ |
| សំ. សឡា. | សំយុត្តនិកាយ សឡាយតនវគ្គ |
| សំ. មហា. | សំយុត្តនិកាយ មហាវគ្គ |

| | |
|---|---|
| អំ. ឯក. | អង្គុត្តរនិកាយ ឯកនិបាត |
| អំ. ទុក. | អង្គុត្តរនិកាយ ទុកនិបាត |
| អំ. តិក. | អង្គុត្តរនិកាយ តិកនិបាត |
| អំ. ចតុក្ក. | អង្គុត្តរនិកាយ ឯកនិបាត |
| អំ. បញ្ចក. | អង្គុត្តរនិកាយ បញ្ចកនិបាត |
| អំ. ឆក្ក. | អង្គុត្តរនិកាយ ឆក្កនិបាត |
| អំ. សត្តក. | អង្គុត្តរនិកាយ សត្តកនិបាត |
| អំ. អដ្ឋក. | អង្គុត្តរនិកាយ អដ្ឋកនិបាត |
| អំ. នវក. | អង្គុត្តរនិកាយ នវកនិបាត |
| អំ. ទសក. | អង្គុត្តរនិកាយ ទសកនិបាត |
| អំ. ឯកាទក. | អង្គុត្តរនិកាយ ឯកាទសកនិបាត |
| ខុ. ខុ. | ខុទ្ទកនិកាយ ខុទ្ទកនិបាត |
| ខុ. ធ. | ខុទ្ទកនិកាយ ធម្មបទ |
| ខុ. ឧ. | ខុទ្ទកនិកាយ ឧទាន |
| ខុ. ឥតិ. | ខុទ្ទកនិកាយ ឥតិវុត្តកៈ |
| ខុ. សុ. | ខុទ្ទកនិកាយ សុត្តនិបាត |
| ខុ. វិ. | ខុទ្ទកនិកាយ វិមានវត្ថុ |
| ខុ. បេ. | ខុទ្ទកនិកាយ បេតវត្ថុ |
| ខុ. ថេរ. | ខុទ្ទកនិកាយ ថេរគាថា |

| | |
|---|---|
| ខុ. ថេរី. | ខុទ្ទកនិកាយ ថេរីគាថា |
| ខុ. ជា. | ខុទ្ទកនិកាយ ជាតក |
| ខុ. មហា. | ខុទ្ទកនិកាយ មហានិទ្ទេស |
| ខុ. ចូឡ. | ខុទ្ទកនិកាយ ចូឡនិទ្ទេស |
| ខុ. បដិ. | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ខុ. អប. | ខុទ្ទកនិកាយ អបទាន |
| ខុ. ពុទ្ធ. | ខុទ្ទកនិកាយ ពុទ្ធវង្ស |
| ខុ. ចរិយា. | ខុទ្ទកនិកាយ ចរិយាបិដក |
| នេត្តិ. | នេត្តិបករណ៍ |
| មិលិន្ទ. | មិលិន្ទបញ្ហា |

ព្រះអភិធម្មបិដក

| | |
|---|---|
| អភិ. ធ. | អភិធម្មបិដក ធម្មសង្គណី |
| អភិ. វិ. | អភិធម្មបិដក វិភង្គ |
| អភិ. ធា. | អភិធម្មបិដក ធាតុកថា |
| អភិ. បុ. | អភិធម្មបិដក បុគ្គលប្បញ្ញត្តិ |
| អភិ. ក. | អភិធម្មបិដក កថាវត្ថុ |
| អភិ. យ. | អភិធម្មបិដក យមកៈ |
| អភិ. ប. | អភិធម្មបិដក បដ្ឋាន |

គម្ពីរអដ្ឋកថា

| | |
|---|---|
| វិ. អ. | វិនយបិដក អដ្ឋកថា |
| ទី. អ. | ទីឃនិកាយ អដ្ឋកថា |
| ម. អ. | មជ្ឈិមនិកាយ អដ្ឋកថា |
| សំ. អ. | សំយុត្តនិកាយ អដ្ឋកថា |
| អំ. អ. | អង្គុត្តរនិកាយ អដ្ឋកថា |
| ខុ. អ. | ខុទ្ទកនិកាយ អដ្ឋកថា |
| ធម្ម. អ. | ធម្មបទ អដ្ឋកថា |
| ឧទាន. អ. | ឧទាន អដ្ឋកថា |
| ឥតិវុត្ត. អ. | ឥតិវុត្តក អដ្ឋកថា |
| សុត្តនិ. អ. | សុត្តនិបាត អដ្ឋកថា |
| វិមាន. អ. | វិមានវត្ថុ អដ្ឋកថា |
| បេត្ត. អ. | បេត្តវត្ថុ អដ្ឋកថា |
| ថេរ. អ. | ថេរគាថា អដ្ឋកថា |
| ថេរី. អ. | ថេរីគាថា អដ្ឋកថា |
| ជា. អ. | ជាតក អដ្ឋកថា |
| មហានិ. អ. | មហានិទ្ទេស អដ្ឋកថា |
| ចូឡនិ. អ. | ចូឡនិទ្ទេស អដ្ឋកថា |
| បដិសំ. អ. | បដិសម្ភិទា អដ្ឋកថា |
| អប. អ. | អបទាន អដ្ឋកថា |

| | |
|---|---|
| ពុទ្ធវំ. អ. | ពុទ្ធវំស អដ្ឋកថា |
| ចរិយា. អ. | ចរិយាបិដក អដ្ឋកថា |
| នេត្តិ. អ. | នេត្តិ អដ្ឋកថា |
| វិសុទ្ធិ. | វិសុទ្ធិមគ្គ |
| អភិ. អ. | អភិធម្មបិដក អដ្ឋកថា |
| សង្គហ. | អភិធម្មត្ថសង្គហ |

គម្ពីរដីកា

| | |
|---|---|
| វជិរ. | វជិរពុទ្ធិ |
| សារត្ថ. | សារត្ថទីបនី |
| វិមតិ. | វិមតិវិនោទនី |
| កង្ខា. ដី. | កង្ខាវិតរណីដីកា |
| កង្ខា. នវដី. | កង្ខាវិតរណីអភិនវដីកា |
| ទី. ដី. | ទីឃនិកាយដីកា |
| សី. ដី. | សីលក្ខន្ធវគ្គ អភិនវដីកា |
| ម. ដី. | មជ្ឈិមនិកាយ ដីកា |
| សំ. ដី | សំយុត្តនិកាយ ដីកា |
| អំ. ដី. | អង្គុត្តរនិកាយ ដីកា |
| វិសុទ្ធិ. ដី. | វិសុទ្ធិមហាដីកា |
| មណិមញ្ជូ. | មណិសារមញ្ជូសា , ខុទ្ទ. ដី. ខុទ្ទសិក្ខាដីកា |

# មាតិកាធម៌

លំដាប់ធម៌. ទំព័រ

គន្ថារម្ភកថា ---------------------------------- [២]
វេទនប្បណាម---------------------------------- [៦]
ជីវប្រវត្តិសង្ខេប---------------------------------- [៩]
អក្សរសង្ខេបឈ្មោះគម្ពីរ. ---------------------- [២០]

## I បរិច្ឆេទទី ១

សីលវិសុទ្ធិ........................................................ ៣
សីលរបស់ភិក្ខុ........................................................ ៣
ការពិចារណាវមែងសម្រេចដោយការចំរើនវិបស្សនា............ ១៨
ឥន្ទ្រិយសំវរសីល............................................ ១៩
សំវរធម៌ និងអសំវរធម៌...................................... ២២
ការចំរើនសំវរធម៌ដោយការរំងាប់ចិត្តជាដើម....................... ២៩
សរុបសីលរបស់ភិក្ខុ............................................ ៣៩
សីលរបស់គ្រហស្ថ............................................. ៤០

អន្តរាយ ៥ យ៉ាង ........................................ ៤៤
រឿងសន្តតិមហាមាត្យ ........................................ ៤៩
រឿងអ្នកស្ងួចត្រីបានសម្រេចធម៌ ........................................ ៥៥
រឿងចោរម្នាក់ ........................................ ៥៦
ស្តេចសក្យៈ ឈ្មោះ សរណានិ ........................................ ៥៨
ការចម្រើនសមថៈជាបាទរបស់វិបស្សនា ........................................ ៦៦
រឿងមនុស្សសម្លាប់ចោរ ........................................ ៦៩
ហេតុនៃការមិនបានសម្រេចធម៌ក្នុងបច្ចុប្បន្នជាតិ ........................................ ៧៣
ការលះកិលេសជាសីល ........................................ ៧៧
ការវៀរចាកឈ្មោះជាសីល ........................................ ៨០
ចេតនាឈ្មោះជាសីល ........................................ ៨២
ការសង្រួមឈ្មោះជាសីល ........................................ ៨២
ការមិនកន្លងល្មើសឈ្មោះជាសីល ........................................ ៨២
ការចំរើនភាវនាសំខាន់ជាងការពិ-
ចារណាប្រយោជន៍របស់បច្ច័យ ........................................ ៨៧
ការតាំងនៅក្នុងសីលហើយចម្រើនសមាធិ និងបញ្ញា ........................................ ៩៣

ពុទ្ធបរិស័ទគួររក្សាសីលជានិច្ច....................................៩៨

## II បរិច្ឆេទទី ២

ចិត្តវិសុទ្ធិ....................................................................១០១
សមាធិ៣ ប្រភេទ..........................................................១០១
ចិត្តវិសុទ្ធិរបស់សមថយានិកនិងវិបស្សនាយានិក..................១១៥
វិធីចម្រើនមគ្គ ២ ប្រការ..................................................១១២
វិបស្សនាញាណ ៣ លំដាប់...............................................១១៩
គ្រឿងរាំងផ្លូវរួចផុត ៨ ប្រការ..........................................១២៨
កាមច្ឆន្ទះ....................................................................១២៩
ព្យាបាទះ......................................................................១៣៥
ថីនមិទ្ធះ......................................................................១៣៧
ឧទ្ធច្ចកុក្កុច្ចះ..............................................................១៣៩
វិចិកិច្ឆា.......................................................................១៤១
អវិជ្ជា..........................................................................១៤៧
ការមិនត្រេកអរក្នុងភាវនា..............................................១៥១

អកុសលធម៌ទាំងពួង..........................................................១៥៥
គួរស្វែងរកប្រយោជន៍ខ្លួនជាគោល..........................................១៥៨
វិធីលះសេចក្តីរវើរវាយ ៥ ប្រការ.............................................១៦៨
ការប្រើសមថៈគ្របសង្កត់សេចក្តីរវើរវាយ...........................១៦៩
ការពិចារណាទោសនៃសេចក្តីរវើរវាយ..............................១៧១
ការកំណត់ដឹងមួយខណៈ.....................................................១៧២
ការកំណត់ដឹងមូលហេតុនៃការរវើរវាយ..............................១៧៤
ការកំណត់ដឹងបែបផ្តោតអារម្មណ៍.......................................១៧៤
ឧបសគ្គរបស់សមាធិ ៦ ប្រការ...........................................១៧៦
ការគិតដល់អតីតកាល.........................................................១៧៧
ការសង្ឃឹមអនាគតកាល.......................................................១៧៨
ការរួញរា..........................................................................១៨០
ការព្យាយាមដ៏ក្រៃលែង.....................................................១៩៧
ការប្រាថ្នាដ៏ក្រៃលែង........................................................១៩៩
ការទម្រន់.........................................................................២០០
ការតាំងមាំក្នុងអារម្មណ៍ ៤ ប្រការ........................................២០១

## III បរិច្ឆេទទី ៣

អារម្មណ៍របស់វិបស្សនាភាវនា ............ ២០៤
បញ្ញត្តិ និងបរមត្ថ ............ ២០៥
ការទទួលដឹងបរមត្ថ ............ ២១៤
អារម្មណ៍របស់វិបស្សនា ............ ២២៥
ការកំណត់ដឹងទាន់បច្ចុប្បន្ន ............ ២៤០
ការចម្រើនវិបស្សនារបស់សមថយានិក ............ ២៦៤
ការចម្រើនអានាបានៈទាំងសមថៈនិងវិបស្សនា ............ ២៧០
ការតាមដឹងរូបនាមតែម្យ៉ាង ............ ២៧៥
រឿងការបានបន្ទុះព្រះអរហត្តផលដោយមិន-
បានទទួលដឹងរូបនាមទាំងអស់ ............ ២៧៩
ការប្រែចក្សច្បាស់របស់ព្រះសារីបុត្រ-
និង ព្រះមោគ្គល្លាន ............ ២៨៤

## IV បរិច្ឆេទទី ៤

គន្លងផ្លូវក្នុងការចម្រើនវិបស្សនាភាវនា ............ ២៩៩

ការតាមដឹងក្នុងខណៈឃើញ........................................៣០២
ការតាមដឹងក្នុងខណៈឮ........................................ ៣១៦
ការតាមដឹងក្នុងខណៈស្រូបក្លិន........................................ ៣១៨
ការតាមដឹងក្នុងខណៈភ្លក្សរស........................................៣២០
ការតាមដឹងក្នុងខណៈប៉ះខ្លួន........................................៣២២
ការតាមដឹងក្នុងខណៈទឹកគិត........................................៣២៤
ការតាមដឹងមនោទ្វារ........................................៣២៧
ការតាមដឹងធម្មារម្មណ៍........................................៣២៩
ការតាមដឹងមនោវិញ្ញាណ........................................៣៣២
ការតាមដឹងផស្សៈផ្លូវមនោទ្វារ........................................ ៣៣៣
ការតាមដឹងវេទនាដែលកើតអំពីផស្សៈផ្លូវមនោទ្វារ..............៣៣៣
ការតាមដឹងសញ្ញាខន្ធ........................................៣៣៦
ការតាមដឹងសង្ខារខន្ធ........................................៣៣៦
វិបស្សនាមិនមែនជាការយល់ចូលចិត្តដោយ-
គ្រាន់តែការស្តាប់ឬការពិចារណា........................................៣៤០
រឿងព្រះពោដ្ឋិលៈ........................................ ៣៧០

ការប្រាកដរបស់រូបនិងនាម..........................................៣៧៥
វិធីតាមដឹងខ្យល់ដង្ហើមចេញចូល..........................................៣៨៦
ការតាមដឹងធាតុ ៤..........................................៣៨៩
សេចក្ដីវិនិច្ឆ័យការបដិបត្តិបែបខ្យល់ប៉ោង ស្រក..........................................៣៩៣
កាយានុបស្សនា ( ការតាមដឹងកងរូប )..........................................៣៩៧
ពួកឥរិយាបថ..........................................៣៩៧
ពួកសម្បជញ្ញៈ..........................................៤១៣
វេទនានុបស្សនា..........................................៤២៨
អានិសង្សនៃការតាមដឹងវេទនា..........................................៤៤៤
ចិត្តានុបស្សនា..........................................៤៤៦
ធម្មានុបស្សនា..........................................៤៥៤
ពួកនីវរណៈ..........................................៤៥៤
ពួកឧបាទានក្ខន្ធ..........................................៤៦៧
ពួកអាយតនៈ និងពួកធាតុ..........................................៤៧២
ពួកសំយោជនៈ..........................................៤៧៧
ពួកពោជ្ឈង្គៈ..........................................៤៨២

ពួកអរិយសច្ចៈ.......................................................................៤៨៨
អានិសង្សនៃការចម្រើនកម្មដ្ឋាន............................................៤៣៧
លេខយោងឈ្មោះគម្ពីរ.......................................................៥៤៤
ឈ្មោះអ្នកចូលរួមបោះពុម្ពសៀវភៅធម៌............................៥៦៦

# វិបស្សនាន័យ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការដល់ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ព្រះអង្គនោះ ។

## ពាក្យផ្តើមគម្ពីរ

អហោ ពុទ្ធោ អហោ ធម្មោ អហោ សង្ឃោ អនុត្តរោ
ឥតិ ចិត្តំ បហំសេត្វា វិបស្សិត្វា តទា គតេ ។
វិបស្សនានយំ កស្សំ សីឃំ មគ្គាទិបាបកំ
ទិដ្ឋេ ធម្មេ សាធូនំ យថាវុត្តំ វិបស្សតន្តិ ។

“ព្រះពុទ្ធជាម្ចាស់ ជាព្រះបរមសាស្តាព្រះអង្គខ្ពង់ខ្ពស់គួរអស្ចារ្យ ព្រះធម៌ជាពាក្យប្រៀនប្រដៅ ដ៏ខ្ពង់ខ្ពស់គួរអស្ចារ្យ ព្រះសង្ឃជាព្រះអរិយបុគ្គលអ្នកខ្ពង់ខ្ពស់គួរអស្ចារ្យ ខ្ញុំម្ចាស់កំណត់ដឹងចិត្តដែលរីករាយ នឹងរូបដែលកើតរួមជាមួយចិត្តក្នុងកាលនោះហើយ នឹងតែងគម្ពីរវិបស្សនាន័យ ដែលញ៉ាំងសប្បុរស អ្នកកំណត់ដឹងតាមន័យ

ដែលពោលទុក ឲ្យបន្ទុះមគ្គផល និងព្រះនិព្វានក្នុងបច្ចុប្បន្នជាតិ ដោយឆាប់រហ័ស” ។

យោគា វេ ជាយតេ ភូរិ អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ ។

“ប្រាជ្ញា រមែងកើតពីការប្រកប សេចក្ដីវិនាសប្រាជ្ញា រមែងកើតពីការមិនប្រកប អ្នកមានប្រាជ្ញា ដឹងការប្រកប នឹងការមិនប្រកប ទាំងពីរនេះថា ជាគន្លងនៃសេចក្ដីចម្រើននឹងសេចក្ដីវិនាស ហើយប្រាជ្ញាចម្រើនឡើង ដោយប្រការណា គួរដំកល់ខ្លួនទុក ដោយប្រការនោះ” ។ បិដកខ្មែរ ៥២. ៨០

# បរិច្ឆេទទី ១

## សីលវិសុទ្ធិ

គម្ពីរវិសុទ្ធិមគ្គអធិប្បាយលក្ខណៈរបស់សីលវិសុទ្ធិថា

សីលវិសុទ្ធិ នាម សុបរិសុទ្ធំ បាតិមោក្ខសំវរាទិ ចតុព្វិធំ សីលំ។

"សីល ៤ យ៉ាង មានការសង្រួមក្នុងព្រះបាតិមោក្ខជាដើម ដែលបរិសុទ្ធល្អ ឈ្មោះថា សីលវិសុទ្ធិ" ។

ពិតហើយ ព្រះអដ្ឋកថាចារ្យ ពោលរឿងនេះ ដោយសំដៅដល់សីលរបស់ភិក្ខុជាគោល សេចក្តីបរិសុទ្ធិរបស់សីល ទើបញែកចេញជាចំណែកភិក្ខុ និងឃរាវាស សីលរបស់ភិក្ខុនោះ មានសេចក្តីល្អិតសុខុមច្រើន ក្នុងទីនេះ នឹងពោលជាលំនាំផ្លូវដោយសង្ខេប ។

## សីលរបស់ភិក្ខុ

សីលរបស់ភិក្ខុមាន ៤ យ៉ាង គឺ បាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល

ទីងអធិប្បាយដូចតទៅនេះ

បាតិមោក្ខសំវរសីល គឺ ការសង្រួមកាយវាចា មិនឲ្យល្មើស សិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុក នឹងយុំគ្រងរក្សាសីល ឲ្យផុតអំពីទុក្ខភ័យផ្សេងៗ ក្នុងបច្ចុប្បន្នភពនឹងភពតទៅ ។

ការជម្រះសីលខនេះឲ្យផូរផង់ គប្បីជ្រាបតាមព្រះបាលីថា

អនុមត្តេសុ វជ្ជេសុ ភយទស្សាវី ។

សមាទាយ សិក្ខតិ សិក្ខាបទេសុ[២] ។

"ភិក្ខុមានប្រក្រតី ឃើញភ័យក្នុងទោសមានប្រមាណតិចរមែង សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ" ។

ភិក្ខុគប្បីសង្រួមខ្លួន មិនឲ្យត្រូវអាបត្តិ ដោយពាក្យត្រិះរិះថា សូម្បីអាបត្តិតូច គឺទុក្កដ និងទុព្ភាសិត ក៏រាំងមិនឲ្យបន្ទុះមគ្គផល ទាំងបញ្ជូនផលឲ្យទៅកើតក្នុងអបាយភូមិ អាបត្តិពួកនេះទើបជាទោស ដែលគួរខ្លាច កាលត្រូវអាបត្តិហើយ ក៏គួរសម្តែងអាបត្តិ ដោយរួសរាន់ ដូចជាក្មេង ដែលចាប់ពាល់ត្រូវភ្លើង ហើយប្រញាប់ប្រញាល់ ប្រលែង ដោយការចូលបរិវាស នៅមានត្ត លះវត្ថុដែលជារបស់

និស្សគ្គិយ៍ ឬបានទទួលដោយមិនប្រកបដោយធម៌ ហើយសម្តែងអាបត្តិចេញ សីលរបស់ភិក្ខុអ្នកត្រូវអាបត្តិ ហើយសម្តែងតាមវិធីក្នុងព្រះវិន័យ និងសង្រួមមិនឲ្យត្រូវអាបត្តិទៀត ក្រោយអំពីនោះ ចាត់ជាសីលសង្រួមគឺ បាតិមោក្ខបានបរិសុទ្ធ ។

**ឥន្ទ្រិយសំវរសីល** គឺ ការសង្រួមឥន្ទ្រិយ៍ មិនឲ្យកិលេសរួបរឹតផ្លូវទ្វារទាំង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយនិងចិត្ត សេចក្តីនេះ មានន័យពិស្តារ និងពោលដល់ក្នុងពេលខាងមុខ ។

**អាជីវបារិសុទ្ធិសីល** គឺ ការស្វែងរកចិញ្ចឹមជីវិតបរិសុទ្ធដោយការស្វែងរកបច្ច័យ ៤ បានដល់ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជៈ ដោយប្រកបតាមធម៌ និងគេចចេញអំពីការស្វែងរកដោយមិនប្រកបតាមធម៌ ដូចជាការសូមគ្រហស្ថ ដែលមិនមែនជាញាតិ និងមិនបានបវារណាជាដើម អង្គធម៌បានដល់វីរិយៈ សេចក្តីព្យាយាមដែលស្វែងរកបច្ច័យដោយត្រឹមត្រូវតាមធម៌ ដែលប្រាកដសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គថា

បច្ចយបរិយេសនវាយាមោ[៣] ។

"សេចក្ដីព្យាយាមក្នុងការស្វែងរកបច្ច័យ" ។

ភិក្ខុអ្នកស្វែងរកបច្ច័យ មិនប្រកបដោយធម៌ រមែងត្រូវអាបត្តិច្រើនយ៉ាងតាំងអំពីបារាជិក សង្ឃាទិសេស ថុល្លច្ច័យ និងទុក្កដ ភាគច្រើនជាអាបត្តិទុក្កដ សូម្បីក្នុងខណៈ ដែលបរិភោគបច្ច័យ ដែលបានមកមិនប្រកបដោយធម៌នោះ ក៏នឹងត្រូវអាបត្តិទុក្កដដូចគ្នា ។ ការត្រូវអាបត្តិដូចនេះហើយ សីលដែលសន្សំមកក្នុងបាតិមោក្ខ របស់ភិក្ខុក៏មិនបរិសុទ្ធ ។ ចាត់ជាអន្តរាយ ចំពោះការទៅកាន់ឋានសួគ៌ និងការបន្ទុះមគ្គផល ភិក្ខុអ្នកត្រូវអាបត្តិ ត្រូវសម្ដែងអាបត្តិតាមវិធីដែលពោលមកហើយ សីលទើបបរិសុទ្ធបានទៀត និងរួចផុតអំពីអន្តរាយខាងដើម ភិក្ខុទើបគួររក្សាសីល ដែលជាប់ទាក់ទងជាមួយការស្វែងរកចិញ្ចឹមជីវិតផង ។

**បច្ចយសន្និស្សិតសីល** គឺ សីលដែលអាស្រ័យបច្ច័យ សំដៅដល់ការពិចារណាប្រយោជន៍ នៃការប្រើប្រាស់បច្ច័យ ៤ ថា យើងដណ្ដប់ចីវរដើម្បីកំចាត់សេចក្ដីរងារ សេចក្ដីក្ដៅ ។ល។ ភិក្ខុគប្បីពិចារណាប្រយោជន៍ របស់បច្ច័យ ៤ ដើម្បីឲ្យសីលនេះបរិសុទ្ធ ក្នុងខណៈបរិភោគអាហារ គួរពិចារណា គ្រប់ពុំនូតបាយ ឬ អាច

ពិចារណា ក្រោយបរិភោគហើយ មុនដល់អរុណរះឡើងថ្មី ប្រសិនបើភ្លេចពិចារណា ចូលដល់អរុណរះឡើង ចាត់ជាអ្នកបរិភោគជំពាក់បំណុល ( ឥណបរិភោគ ) ដូចដែលពោលទុក ក្នុងគម្ពីរអដ្ឋកថា ។

ពាក្យថា ឥណបរិភោគ ( អ្នកបរិភោគជំពាក់បំណុល ) នេះមិនមែនសំដៅយក ភិក្ខុត្រូវទៅសងបំណុលឲ្យដល់ទាយក ក្នុងភពខាងមុខ តែសំដៅដល់ការបរិភោគ ដូចជាជំពាក់បំណុល ពោលគឺ ទានដែលថ្វាយដល់ភិក្ខុអ្នកទ្រទ្រង់សីលរាប់ថា មានសេចក្ដីបរិសុទ្ធនៃទក្ខិណា ( ទក្ខិណាវិសុទ្ធិ ) បញ្ចូនផលទីងឲ្យផលទានមានអានិសង្សច្រើន តែភិក្ខុអ្នកបរិភោគបច្ច័យ ៤ ដោយមិនបានពិចារណារមែងទីងមានសីលមិនផូរផង់ ផលទានរបស់ទាយក ទើបមិនមានអានិសង្សច្រើន ភិក្ខុនោះ ដូចជាជំពាក់បំណុល ផលទានដល់ទាយក ទើបពោលថា ជាអ្នកបរិភោគជំពាក់បំណុល ។

ដូចសាធកៈ ( គ្រឿងអាង ) ក្នុងគម្ពីរមហាដីកាថា

ឥណវសេន បរិភោគោ ឥណបរិភោគោ ។ បដិគ្គាហកតោ ទក្ខិណាវិសុទ្ធិយា អភាវតោ ឥណំ គហេត្វា បរិភោគោ វិយាតិ

អត្ថោ[៥] ។

"ការបរិភោគ ដោយភាពជាបំណុល ឈ្មោះថា ការបរិភោគជំពាក់បំណុល សំដៅដល់ការបរិភោគ ដូចជាជំពាក់បំណុល ព្រោះមិនមានការបរិសុទ្ធនៃទក្ខិណា" ។

**យថា ឥណាយិកោ អត្តនោ រុចិយា គន្តុំ ន លភតិ, ឯវំ ឥណបរិភោគយុត្តោ លោកតោ និស្សរិតុំ ន លភតិ[៦] ។**

"អ្នកជំពាក់បំណុល រមែងនឹងដើរទៅណាមកណា តាមសេចក្តីត្រូវការរបស់ខ្លួនមិនបានយ៉ាងណា ភិក្ខុអ្នកបរិភោគជំពាក់បំណុល នឹងរួចផុតទៅអំពីលោកមិនបានដូច្នោះ" ។

ភិក្ខុអ្នកលះការពិចារណា ប្រយោជន៍នៃបច្ច័យ ៤ នឹងមានការជាប់ជំពាក់ក្នុងបច្ច័យពួកនោះ នឹងអាចទៅកើតក្នុងទុគតិភូមិបាន ។ ព្រះដីកាចារ្យ ទើបពោលថា "ភិក្ខុអ្នកបរិភោគជំពាក់បំណុល នឹងរួចផុតអំពីលោកនេះ ទៅមិនបានទេ" ។

គប្បីជ្រាបសេចក្តីនេះ តាមរឿងរបស់ព្រះតិស្សៈ ដែលមានមកក្នុងធម្មបទ ក្នុងសម័យពុទ្ធកាល មានភិក្ខុមួយរូប ឈ្មោះថា តិស្សៈ

មានការជាប់ជំពាក់ក្នុងចីវរ កាលស្លាប់ហើយ ទៅកើតជាប្រែតនៅនឹងចីវរ កាលពួកភិក្ខុ នឹងបែងចែកចីវររបស់លោក ប្រែតក៏ស្រែកហាមថា កុំកុំចីវររបស់ខ្ញុំ ព្រះពុទ្ធអង្គទ្រង់បានឮសំឡេងនោះដោយទិព្វសោត ទើបទ្រង់ត្រិះរិះថា ប្រសិនបើភិក្ខុចែកចីវរនឹងធ្វើឲ្យប្រែតខឹង ហើយទៅកើតក្នុងអបាយភូមិ ព្រះអង្គទើបឲ្យពន្យាការចែកចីវរនោះ រហូតដល់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៧ ហើយ ប្រែតក៏ស្លាប់ ហើយទៅកើតក្នុងឋានសួគ៌ជាន់តុសិត ព្រះអង្គទើបឲ្យចែកចីវរបាន ។

រឿងដែលប្រែតស្លាប់ហើយ ទៅកើតក្នុងឋានសួគ៌នេះ ធ្វើឲ្យដឹងថា ប្រសិនបើភិក្ខុមិនមានការជាប់ជំពាក់ ក្នុងបរិក្ខារ ក៏អាចទៅកើតក្នុងឋានសួគ៌បាន ក្រោយអំពីអស់ជីវិត បើព្រះពុទ្ធអង្គមិនបានឲ្យពន្យាថ្ងៃចែកចីវរ ប្រែតក៏នឹងធ្លាក់ទៅក្នុងនរក ជាពិតប្រាកដ នឹងឃើញបានថា ការជាប់ជំពាក់ក្នុងបរិក្ខារ ជាអន្តរាយយ៉ាងធំព្រះពុទ្ធអង្គទ្រង់សំឡឹងឃើញសេចក្ដីនេះ ទើបត្រាស់ព្រះគាថាថា

អយសាវ មលំ សមុដ្ឋិតំ តទុដ្ឋាយ តមេវ ខាទតិ
ឯវំ អតិធោនចារិនំ សានិ កម្មានិ នយន្តិ ទុគ្គតឹ ។

"ព្រោះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង" ។

ក្នុងរឿងនេះ មានកន្លែងខ្លះពោលថា "ភិក្ខុអ្នកជំពាក់បំណុលក្នុងការបរិភោគ នឹងត្រូវសងបំណុលឲ្យដល់ទាយក នឹងមិនអាចសម្រេចមគ្គផលក្នុងភពនេះបាន" ការយល់ឃើញនេះ មិនប្រាកដក្នុងព្រះត្រៃបិដកនិងព្រះអដ្ឋកថា សូម្បីព្រះដីកាចារ្យ ក៏មិនបាន អធិប្បាយទុកតាមន័យនេះ នឹងមានសេចក្ដីមិនសមគួរទៀតផង ព្រោះប្រសិនបើជាការពិត ភិក្ខុអ្នកជំពាក់បំណុល ក្នុងការបរិភោគក៏នឹងមានទោសច្រើនជាងអ្នកត្រូវអាបត្តិបារាជិកទៅទៀត ។ ដោយហេតុដែលបុគ្គលនោះអាចបន្ទុះមគ្គផលបាន ដូចការតាំងនៅក្នុងភាពជាគ្រហស្ថ ឬសាមណេរ ដូចពោលទុកក្នុងគម្ពីរអដ្ឋកថា នៃអង្គុត្តរនិកាយថា

***ឥមំ បន ទេសនំ សុត្វា ជាតសំវេគា ហនំ ជហិត្វា សាមណេរភូមិយំ ឋិតា ទស សីលានិ បូរេត្វា យោនិសោមនសិការ***

យុត្តប្បយុត្តា គេចិ សោតាបន្នា, កេចិ សកទាគាមិនោ, កេចិ អនាគាមិនោ អហេសុំ ។ កេចិ ទេវលោកេ នព្វត្តិំសុ ។ ឯវំ បារាជិកាបន្នានម្បិ សផលា អហោសិ ។

"ភិក្ខុ ៦០ រូបអ្នកត្រូវអាបត្តិបារាជិកពួកនោះ កាលស្តាប់ព្រះធម៌ទេសនា អគ្គិខន្ធោបមសូត្រនេះហើយកើតសេចក្តីស្លុតចិត្ត លះបង់សីល មកតាំងនៅក្នុងឋានៈជាសាមណេរ ហើយញ៉ាំងសីល ១០ ឲ្យពេញបរិបូណ៌ ព្យាយាមប្រកបក្នុងយោនិសោមនសិការ ភិក្ខុរូបខ្លះបានជាសោតាបន្ន ភិក្ខុរូបខ្លះ បានជាសកទាគាមី ភិក្ខុរូបខ្លះ បានជាអនាគាមី ភិក្ខុរូបខ្លះ បានទៅកើតក្នុងទេវលោក ព្រះធម៌ទេសនាមានប្រយោជន៍ សូម្បីដល់បុគ្គល អ្នកត្រូវអាបត្តិបារាជិកហើយយ៉ាងនេះ" ។

តាមពិត ព្រះអង្គទ្រង់ជ្រាបថា ភិក្ខុ ៦០ រូបពួកនោះ ត្រូវអាបត្តិបារាជិក ទើបស្តេចចេញចារិកដើម្បីសម្តែងព្រះសូត្រនេះ ក្នុងគម្ពីរអដ្ឋកថា បានពោលថា ព្រះអង្គទ្រង់សម្តែង ព្រះសូត្រនេះក្នុងរវាងផ្លូវដែលស្តេចទៅ ទើបធ្វើឲ្យដឹងថាភិក្ខុពួកនោះ កាលត្រូវអាបត្តិ ក៏តាំង

នៅក្នុងភាវៈជាភិក្ខុរហូតមួយរយៈ ទឹងសូម្បីភិក្ខុអ្នកត្រូវអាបត្តិបារាជិក ក៏អាចបន្ទុះមគ្គផលបាន កាលបើលះបង់ភេទបព្វជិត ដូច្នោះ ភិក្ខុអ្នកមានសីលបរិសុទ្ធ តែមិនបានពិចារណាបច្ច័យ ៤ ទើបចាក់ធ្លុះមគ្គផលបាន ។ ក្រៅអំពីនេះ ទេសនាដែលព្រះអង្គទ្រង់សម្តែងឲ្យពិចារណាបច្ច័យ ៤នេះ ជាសុត្តន្តទេសនា មិនមែនការបង្គាប់បញ្ញត្តវិព្រះវិន័យ ដូច្នេះ ការមិនបានពិចារណាបច្ច័យ ទើបមិនមែនជាការកន្លងល្មើសតាមព្រះវិន័យ ទឹងមិនមែនជាការកន្លងល្មើស ដោយប្រការដទៃ ដែលត្រូវហាមសម្រាប់ ការទៅកាន់ឋានសួគ៌ជាដើម ការភ្លេចពិចារណាបច្ច័យ ៤ ទើបមិនជាទោសធ្ងន់ ។

ក្នុងគម្ពីរអដ្ឋកថា បានពិន័យអាបត្តិ ដល់ភិក្ខុដែលបរិភោគថ្នាំ ដោយមិនបានពិចារណា ដោយសំដៅដល់ការបរិភោគនូវថ្នាំ ក្នុងលក្ខណៈ ដែលជាអាហារ មិនមែនបរិភោគកាលមានហេតុត្រូវតាមរោគនោះៗ ព្រោះព្រះអង្គ ទ្រង់អនុញ្ញាតការបរិភោគថ្នាំ កាលមានរោគប៉ុណ្ណោះ ដូច្នេះ ការមិនបានពិចារណាបច្ច័យ ៤ ទើបមិនមែនជាហេតុ នៃការត្រូវអាបត្តិ ដូចសាធកៈ ក្នុងព្រះវិនយបិដកថា

យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ

អាហារត្ថាយ ជិគ្គណ្ហាតិ ។ អាបត្តិ ទុក្កដស្ស ។

អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស[៩] ។

"ភិក្ខុរមែងទទួលយាមកាលិក សត្តាហកាលិក និងយាវជីវិក ដើម្បីជាអាហារត្រូវអាបត្តិទុក្កដ នឹងត្រូវអាបត្តិទុក្កដ ក្នុងខណៈដែលលេបចូលគ្រប់ៗ ខណៈ" ។

សេចក្ដីសំខាន់ ដែលដាច់មិនបាន គឺការយល់ដឹងនឹងពិចារណាយ៉ាងត្រឹមត្រូវសន្មតិថា ក្នុងវេលាព្រឹកកាលអរុណរះឡើងហើយ ភិក្ខុសំគាល់ថា អរុណមិនទាន់រះឡើង ឬសំគាល់ថាផុតអំពីថ្ងៃត្រង់ ទើបបរិភោគអាហារដែលជា យាវកាលិក ចាត់ថាមានចេតនាកន្លងល្មើសសិក្ខាបទ ទើបត្រូវអាបត្តិតាមព្រះបាលីថា

កាលេ វិកាលសញ្ញី អាបត្តិ ទុក្កដស្ស[១០] ។

"ភិក្ខុសំគាល់កាល ថាជាវិកាល ត្រូវអាបត្តិទុក្កដ" ។

ដោយហេតុនេះ កាលដែលភិក្ខុបរិភោគថ្នាំ ដែលមិនបានពិចារណា ត្រូវអាត្តិទុក្កដ ទើបសំដៅដល់ការកន្លងល្មើសសិក្ខាបទ

មិនមែនសំដៅដល់ការភ្លេចពិចារណាបច្ច័យ ដូចគម្ពីរដីកាទាំងឡាយពោលថា "សូម្បីភិក្ខុភ្លេចសតិ បរិភោគបច្ច័យ ៤ តែមានសតិពិចារណាមុនអរុណរះឡើង ឈ្មោះថា សីលនេះបរិសុទ្ធ"[១១] ។

[វត្ថុដែលព្រះអង្គទ្រង់អនុញ្ញាត ឲ្យភិក្ខុទទួលប្រគេន ទឹងឆាន់បានមាន ៤ យ៉ាង គឺ

១. **យាវកាលិក** គឺអាហារសំរាប់ទំពារស៊ី ឆាន់បានតាំងអំពីពេលអរុណរះឡើង ជាដើមទៅរហូតដល់ថ្ងៃត្រង់ ។

២. **យាមកាលិក** គឺទឹកបានៈ ឆាន់បានតាំងអំពីថ្ងៃត្រង់ជាដើមទៅរហូតដល់អរុណរះនៃថ្ងៃថ្មី ។

៣. *សត្តាហកាលិក* គឺ ភេសជ្ជៈ ៥ យ៉ាង បានដល់ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ឆាន់បានក្នុងរវាង ៧ ថ្ងៃ ក្រោយអំពីការទទួលប្រគេនហើយ ។

៤. *យាវជីវិក* គឺ ថ្នាំឆាន់កែរោគ ដោយមិនមានកំណត់] ។

ម្យ៉ាងទៀត ការយល់ឃើញខាងដើម នៅជំទាស់ជាមួយមតិរបស់ថេរវាទ ដែលមានក្នុងគម្ពីរអដ្ឋកថាទៀតផង ដូចព្រះបាលីថា

**តិបិដកចូឡនាគត្ថេរោ បនាហ "បាតិមោក្ខសំវរោ សីលំ ។**

ឥតរានិ តីណិ សីលន្តិ វុត្តដ្ឋានំ នាម នត្ថីតិ វត្វា តំ អននុជានន្តោ អាហ ឥន្ទ្រិយសំវរោ នាម ឆទ្វាររក្ខណមត្តមេវ ។ អាជីវបារិសុទ្ធិ ធម្មេន សមេន បច្ចយុប្បត្តិមត្តំ ។ បច្ចយសន្និស្សិតំ បដិលទ្ធបច្ចយេ ឥទមត្ថិតំ បច្ចវេក្ខិត្វា បរិភុញ្ជនមត្តំ ។ និប្បរិយាយេន បាតិមោក្ខសំវរោវ សីលំ ។ យស្ស សោ ភិន្នោ, អយំ ឆិន្នសីសោ វិយ បុរិសោ ហត្ថបាទេ សេសានិ រក្ខិស្សតីតិ ន វត្តព្វោ ។ យស្ស បន អរោគោ, អយំ អច្ឆិន្នសីសោ វិយ បុរិសោ ជីវិតំ សេសានិ បុន បាកតិកានិ កត្វា រក្ខិតុំ សមត្ថោតិ[១២]" ។

"ចំណែកព្រះចូឡនាគ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា ( ការសង្រួមក្នុងបាតិមោក្ខជាដើមថាជាសីល តែមិនប្រាកដក្នុងគម្ពីរ ដែលពោលថា សីលដែលនៅសល់ ៣ យ៉ាង ជាសីល ) ហើយ ពោលជំទាស់ការយល់ឃើញខាងដើមថា ( ធម្មតានៃការសង្រួមឥន្ទ្រីយ៍ជា ការឃុំគ្រងទ្វារទាំង ៦ សេចក្តីផូរផង់ក្នុងការចិញ្ចឹមជីវិត ក៏ត្រឹមតែ ជាការស្វែងរកបច្ច័យប្រកបដោយធម៌ ចំណែកសីលដែលអាស្រ័យ

បច្ច័យ ក៏ត្រឹមតែជាការបរិភោគ ដោយពិចារណាដល់ប្រយោជន៍របស់បច្ច័យ ដែលបានទទួលហើយ ការសង្រួមក្នុងព្រះបាតិមោក្ខ ទើបជាសីលដោយត្រង់ សីលរបស់ភិក្ខុណាដាច់ហើយ ភិក្ខុនេះមិនគួរពោលថា នឹងរក្សាដៃជើងទុកបាន ដូចជាបុរសអ្នកមានក្បាលដាច់ហើយ តែសីលរបស់ភិក្ខុណាមិនធ្វេសប្រហែស ភិក្ខុនេះឈ្មោះថា អាចរក្សាជីវិតទុកបាន ដោយធ្វើដៃជើងឲ្យជាប្រក្រតី ដូចជាបុរសអ្នកមានសីសៈ មិនដាច់ដូច្នោះ )" ។

ព្រះចូឡនាគ កើតមុនព្រះពុទ្ធឃោសាចារ្យ ជាកាលយូរជាង លោកជាអ្នកទ្រទ្រង់ព្រះត្រៃបិដក នឹងជាទីគោរពរាប់អាននៃព្រះអដ្ឋកថាចារ្យនិងដីកាចារ្យ ការឃើញរបស់លោកទើបគួរកាន់យកលើកដំកើង លោកមានការយល់ឃើញថា កាលបាតិមោក្ខសំវរសីលតាំងនៅ សូម្បីសីលដទៃនឹងសៅហ្មងទៅ ក៏អាចកែវិញបាន កាលបើសីលទាំង ៤ យ៉ាងបរិសុទ្ធ ក៏ឈ្មោះថា អ្នកមានសីលបរិសុទ្ធ អាចសម្រេចមគ្គផលបាន ។

ដូច្នោះ សេចក្តីយល់ឃើញថា "ភិក្ខុអ្នកជំពាក់បំណុលក្នុងការ

បរិភោគ មិនអាចសម្រេចមគ្គផលក្នុងភពនេះបាន" ទើបជំទាស់ជាមួយនឹងសាធក: ដែលនាំមកសម្តែងទុកខាងដើម ព្រោះបច្ចយសន្និស្សិតសីល អាចកែបានដូចសីលដទៃ វៀរលែងតែសម្រាប់បាតិមោក្ខសំវរសីល ។

ការពិចារណាប្រយោជន៍របស់បច្ច័យ ៤ នេះ អដ្ឋធម៌ គឺបញ្ញារាប់បញ្ចូលក្នុងបញ្ញាសិក្ខា មិនរាប់ចូលក្នុងសីលសិក្ខា សូម្បីក្នុងព្រះសូត្រនិងព្រះអភិធម្ម បាននពោលដល់សីលខនេះ ដោយពាក្យថា **បច្ចវេក្ខណា** ( ការពិចារណា ), **ភោជនេ មត្តញ្ញូ** ( អ្នកដឹងប្រមាណក្នុងការបរិភោគ ), **ភោជនេ មត្តញ្ញុតា** ( ការៈជាអ្នកដឹងប្រមាណក្នុងការបរិភោគ ) និង **បដិសេវនាបហាតព្វអាសវៈ** ( កិលេសដែលគប្បីលះបង់ដោយការពិចារណា ) និងមិនបានពោលទុកដោយត្រង់ក្នុងសីល ។

ក្រៅអំពីនេះ ការពិចារណាដូចពោលមក រមែងប្រព្រឹត្តទៅដើម្បីមិនឲ្យកើតកិលេស ក្នុងខណៈបរិភោគបច្ច័យ ៤ ពេលដែលពិចារណា ទើបគួរប្រកបដោយបញ្ញា ដែលដឹងច្បាស់នូវ

ប្រយោជន៍ ចំពោះការអាស្រ័យបច្ច័យ ៤ យ៉ាងពិតប្រាកដ មិនមែនត្រឹមតែជាការបញ្ចេញ សំឡេងស្វាធ្យាយ ឬ ធ្វើវិធីនយកម្ម ដូចជាការអធិដ្ឋាន ឬវិកប្បនា ដើម្បីឲ្យប្រើប្រាស់ចីវរបានដោយងាយស្រួល ។

## ការពិចារណាមែងសម្រេចដោយការចំរើនវិបស្សនា

អ្នកដែលចម្រើនវិបស្សនាដោយកំណត់ធាតុ ៤ ឬ វត្ថុបដិកោល ក្នុងខណៈទទួលបច្ច័យ ៤ ឬ ប្រើប្រាស់បច្ច័យពួកនោះ សូម្បីនឹងមិនបានពិចារណា ប្រយោជន៍របស់បច្ច័យ ក៏ដូចជាមួយការពិចារណានោះឯង ( រឿងនេះនឹងប្រាកដដោយពិស្តារក្នុងសីលរបស់គ្រហស្ថ ) ដូចមានសាធកៈសម្តែងថា

បដិលាភកាលេបិ ហិ ធាតុវសេន វា បដិក្កូលវសេន វា បច្ចវេក្ខិត្វា ឋបិតានិ ចីវរាទីនិ តតោ ឧត្តរិ បរិភុញ្ជន្តស្ស អនវជ្ជោវ បរិភោគោ ។ តថា បរិភោគកាលេបិ[១៣]។

“ចីវរជាដើម ដែលពិចារណាដោយសភាពត្រឹមតែជាធាតុ ឬ ដោយត្រឹមតែជារបស់បដិកូល ក្នុងពេលដែលទទួលទុកហើយ

កាលភិក្ខុប្រើប្រាស់ក្នុងកាលជាខាងក្រោយនោះ ការប្រើប្រាស់រមែងមិនមានទោសឡើយ សូម្បីកាលពិចារណា ក្នុងពេលប្រើប្រាស់ក៏ដូចគ្នា" ។

សរុបសេចក្ដីមក ការពិចារណាប្រយោជន៍របស់បច្ច័យ ៤ ឬការបរិភោគនោះដោយកំណត់ដឹងថា ត្រឹមតែជាធាតុ ឬវត្ថុបដិកូលចាត់ជាបច្ចយសន្និស្សិតសីល ភិក្ខុអ្នកពិចារណាដូច្នេះ ឈ្មោះថា ជាអ្នកមានបច្ចយសន្និស្សិតសីលបរិសុទ្ធ ។

## ឥន្ទ្រិយសំវរសីល

កាលមានសតិសង្រួមឥន្ទ្រីយ៍ ដើម្បីមិនឲ្យកើតកិលេស ក្នុងខណៈដែលវិញ្ញាណ ៦ គឺ ចិត្តដែលឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ នឹងនឹកគិតរឿងរ៉ាវផ្សេងៗ កំពុងទទួលដឹងអារម្មណ៍ ៦ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ដែលមកប្រាកដក្នុងផ្លូវទ្វារទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ឈ្មោះថា ឥន្ទ្រិយសំវរសីល ក្នុងទីនេះនឹងអធិប្បាយ ការសង្រួមឥន្ទ្រិយ៍ក្នុងផ្លូវចក្ខុទ្វារ ការសង្រួមក្នុងទ្វារដទៃ ក៏មានន័យដូចគ្នា ។

ព្រះអង្គទ្រង់ត្រាស់ទុកជាប់ទាក់ទងក្នុងរឿងនេះថា

**ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី**[១៤] ។

"ភិក្ខុឃើញរូបដោយចក្ខុហើយ មិនកាន់យករូបរាងសណ្ឋាន មិនកាន់យក ( និមិត្តនិងអនុព្យញ្ជនៈ ) អវយវៈតូចធំ" ។

គម្ពីរអដ្ឋកថាអធិប្បាយសេចក្តីនេះថា

**ទិដ្ឋមត្តេយេវ សណ្ឋាតិ**[១៥] ។

"រមែងតាំងចិត្តទុកក្នុងសភាវៈឃើញប៉ុណ្ណោះ"គម្ពីរដីកា[១៦]បាន អធិប្បាយថា

ភិក្ខុគួរញ៉ាំងចិត្តដែលទទួលដឹង សភាវៈឃើញប៉ុណ្ណោះឲ្យកើតឡើង មិនគួរធ្វើទុកក្នុងចិត្តចំពោះការស្អាត ឬមិនស្អាតនៃវត្ថុដែលឃើញ ដោយស្របតាមព្រះបាលីថា

**ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ**[១៧] ។

"កាលឃើញ ទីងត្រឹមតែជាការឃើញ" ។

ក្នុងខណៈ ដែលជួបប្រទះវិសភាគារម្មណ៍ បើបុគ្គលទទួលដឹងរូបរាងសណ្ឋាន ឬ អវយវៈតូចធំរបស់បុរស ឬ ស្ត្រីភេទផ្សេងគ្នា

កិលេស គឺ រាគៈរមែងកើតឡើង ទើបមិនគួរធ្វើទុកក្នុងចិត្ត ចំពោះរូបរាងសណ្ឋាន ឬ អវយវៈតូចធំដូចជាមុខ ភ្នែក ច្រមុះ ព្រមទាំងអាកប្បកិរិយា ញញឹម សើច និយាយ សំឡេងជាដើមៗ តែគួរមើលអាការៈ ៣២ ដែលមានពិតតាមការសន្មតិ គឺ សក់ រោម ក្រចក ធ្មេញ ស្បែក សសៃ ។ល។ ឬកំណត់ដឹងត្រឹមតែជាមហាភូតរូប និងឧបាទាយរូប ដែលមានពិតតាមបរមត្ថ ដូចគម្ពីរអដ្ឋកថាពោលថា

**យំ តត្ថ ភូតំ, តទេវ គណ្ហាតិ[១៨] ។**

"ភិក្ខុរមែងកាន់យករូប ដែលមានពិត ក្នុងរូបទាំងនោះ" ។

ក្នុងទីនេះនឹងពោលដល់ការកើតវិថីចិត្ត ដែលមានការសង្រួមឥន្រ្ទិយ៍ ឬខ្វះការសង្រួមឥន្រ្ទិយ៍ តាមគម្ពីរអដ្ឋកថា[១៩] សម្តែងទុកពោលគឺ ពណ៌ផ្សេងៗ ( រូបារម្មណ៍ ) ប្រាកដផ្លូវចក្ខុទ្វារ អាវជ្ជនចិត្ត ( បញ្ចទ្វារាវជ្ជនចិត្ត ) ពិចារណារូបារម្មណ៍នោះឯងកើតឡើងហើយក៏រលត់ទៅ បញ្ចទ្វារាវជ្ជនចិត្តដែលរលត់ទៅហើយ ក្នុងលំដាប់នោះចក្ខុវិញ្ញាណចិត្ត អ្នកឃើញរូបារម្មណ៍ សម្បដិច្ឆន្នចិត្ត ដែលប្រដូចជាមួយអ្នកទទួលរូបារម្មណ៍ សន្តីរណចិត្ត ដែលប្រដូចជាមួយអ្នក

ពិចារណារូបារម្មណ៍ រេាដ្ឋពូទចិត្ត ដែលប្រដូចជាមួយអ្នកកាត់ក្តី រូបារម្មណ៍ ចិត្តពួកនេះ រមែងកើតឡើងតាមលំដាប់ៗ ហើយក៏រលត់ទៅតាមៗគ្នាទៅ ។ ក្រោយអំពីវោដ្ឋពូទចិត្តរលត់ទៅហើយ កាមជវនដួងណានិមួយដែលមានយោនិសោមនសិការៈជាដើម ជាបច្ច័យ រមែងកើតឡើងច្រើនខណៈ ( ៦ ឬ ៧ ខណៈ ) ។

បើសំវរធម៌ គឺ សីល សតិ បញ្ញា ខន្តិ និងវីរិយៈ កើតឡើងក្នុងជវនចិត្តផ្លូវចក្ខុទ្វារ ការសង្រួមឥន្ទ្រីយ៍ រមែងប្រាកដផ្លូវចក្ខុទ្វារ ភិក្ខុនោះ ឈ្មោះថា មានឥន្ទ្រិយសំវរសីលបរិសុទ្ធ ។ ក្នុងករណីផ្ទុយគ្នានេះ ប្រសិនបើអសំវរធម៌ គឺ ការមិនមានសីល ការភ្លេចសតិ ការវង្វេង ការមិនអត់ធន់ និងការទំរាន់ កើតឡើងក្នុងជវនចិត្ត ការសង្រួមឥន្ទ្រីយ៍ រមែងមិនប្រាកដផ្លូវចក្ខុទ្វារ ភិក្ខុនោះឈ្មោះថា មានឥន្ទ្រិយសំវរសីលបែកធ្លាយ ។

## សំវរធម៌ និងអសំវរធម៌

ក្នុងបណ្តាសំវរធម៌ ៥ យ៉ាងដំបូង គឺ បាតិមោក្ខសំវរៈ សំដៅដល់ ការសង្រួមក្នុងព្រះបាតិមោក្ខ ដូចគម្ពីរអដ្ឋកថាពោលថា

ឥមិនា បាតិមោក្ខសំវរេន ឧបេតោ ហោតិ សមុបេតោតិ

អយំ បាតិមោក្ខសំវរោ[២០] ។

"សំវរៈនេះគឺ ( ភិក្ខុជាអ្នកចូលដល់ហើយ ដល់ព្រមហើយ ដោយបាតិមោក្ខសំវរសីលនេះ ) ឈ្មោះថា បាតិមោក្ខសំវរៈ" ។

ការមិនមានសីល គឺ ការវិបត្តិនៃបាតិមោក្ខសីល ជាការត្រូវអាបត្តិ ព្រោះកន្លងល្មើសសិក្ខាបទផ្លូវកាយ និងវាចា តែការមិនមានសីលក្នុងរឿងនេះ កើតផ្លូវមនោទ្វារ មិនមែនកើតផ្លូវទ្វារ ៥ ព្រោះជាវីតិក្កមកិលេសផ្លូវចិត្ត ចំណែកអសំវរធម៌ ៤ យ៉ាងដទៃកើតឡើងផ្លូវទ្វារទាំង ៦ សេចក្តីនេះ ពោលទុកក្នុងគម្ពីរមូលដីកា[២១] និងវិសុទ្ធិមគ្គមហាដីកា[២២] ។

សំវរៈប្រភេទទី ២ គឺ សតិសំវរៈ ចាត់ជាឥន្ទ្រិយសំវរសីល យ៉ាងពិតប្រាកដ អត្ថធម៌គឺ សតិចេតសិក ដែលឃុំគ្រងមិនឲ្យកើតកិលេសផ្លូវទ្វារទាំង ៦ តាមសាធកៈ ក្នុងគម្ពីរអដ្ឋកថាពោលថា

**រក្ខតិ ចក្ខុន្ទ្រិយំ ។ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតីតិ អយំ សតិសំវរោ[២៣] ។**

"សំវរៈនេះ គឺ ( ភិក្ខុរមែងរក្សាឥន្ទ្រិយ៍ គឺចក្ខុរមែងដល់នូវ

ការសង្រួមក្នុងឥន្ទ្រីយ៍គឺចក្ខុ ) ឈ្មោះថា សតិសំវរៈ" ។

ចំណែកការមិនមានសតិជាការភ្លេចកំណត់ដឹងទាន់សភាវធម៌ដែលមកប្រាកដផ្លូវទ្វារទាំង ៦ អង្គធម៌ គឺលោភចេតសិកដែលហៅថា អភិជ្ឈា ( ការលោភ ) និងទោមនស្ស ( ក្នុងគម្ពីរដីកាសម្តែងថា ជាមោហៈទៀតផង ) សមពិតដូចព្រះបាលីថា

ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ[២៤] ។

"អកុសលធម៌ដែលលាមកគឺ សេចក្តីលោភ និងទោមនស្ស រមែងមិនសង្រួមចក្ខុន្ទ្រីយ៍" ។

សំវរៈប្រភេទទី ៣ គឺ ញាណសំវរៈ អង្គធម៌គឺ បញ្ញាដែលជាអរិយមគ្គ ដែលលះក្រសែបាបបានដល់តណ្ហា ទិដ្ឋិ អវិជ្ជា ។ល។ ដោយដាច់ខាត សមពិតដូចសាធកៈថា

យានិ សោតានិ លោកស្មឹ សតិ តេសំ និវារណំ ( អជិតាតិ ភគវា ) សោតានំ សំវរំ ព្រូមិ បញ្ញាយេតេ បិធីយរេ"តិ អយំ ញាណសំវរោ[២៥] ។

"សំវរៈនេះ គឺ [ព្រះមានព្រះភាគត្រាស់ថា] ( ម្នាលអជិតៈ ក្រសែពួកណាមាននៅក្នុងលោក សតិជាគ្រឿងរាំងក្រសែពួកនោះ តថាគតពោលសតិថា ជាគ្រឿងរាំងក្រសែក្រសែពួកនោះ រមែងត្រូវកាត់ផ្តាច់ដោយបញ្ញា ) ឈ្មោះថា ញាណសំវរៈ" ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ[២៦]ពោលថា សូម្បីបច្ចយសន្និស្សិតសីលក៏ចាត់ចូលក្នុងញាណសំវរៈ និងវិបស្សនាញាណ ក៏គួររាប់ថា ជាញាណសំវរៈដូចគ្នា ព្រោះការរាំងក្រសែកិលេស ដែលជាអារម្មណានុស្ស័យ ( កិលេសដែលដេកសម្ងំនៅក្នុងអារម្មណ៍ដែលមិនបានកំណត់ដឹង ) ជាដើមមក ដោយតទង្គប្បហាន ព្រោះអំណាចនៃវិបស្សនាមានកម្លាំងច្រើន ការបិទរាំងកិលេស ដោយការពិចារណាប្រយោជន៍ ក្នុងការប្រើប្រាស់បច្ច័យ ៤ ដូចគម្ពីរមហានិទ្ទេសសម្តែងថា

*សព្វេ សង្ខារា អនិច្ចាតិ ជានតោ បស្សតោ បញ្ញាយេត សោតា បិធិយ្យន្តិ*[២៧] ។

"ភិក្ខុកាលប្រចាក់ច្បាស់នូវសង្ខារទាំងពួងថា មិនទៀងរមែង

បិទកំផែងក្រសែពួកនោះដោយបញ្ញា” ។

ពោលដោយសរុប ញាណសំវរៈ សំដៅដល់ បច្ចយសន្និស្សិ-តសីល វិបស្សនាញាណនិងបញ្ញាដែលជាអរិយមគ្គ ចំណែកសេចក្ដីវាងវៃ អន្តធម៌ គឺមោហចេតសិក ដែលផ្ដុំយគ្នាជាមួយបញ្ញាទាំង ៣ នោះ ។

សំវរៈប្រភេទទី ៤ គឺ ខន្តិសំវរៈ សេចក្ដីអត់ធន់មិនឲ្យកើតការទាស់ចិត្ត ក្នុងខណៈជួបជាមួយការត្រជាក់ ការក្ដៅ ការស្រេកឃ្លាន រហូតការពោលត្រូវដែលអត់ធន់បានដោយលំបាក និងពាក្យតិះដៀលដោយអន្តធម៌គឺ ទោសចេតសិក សមពិតដូចសាធកៈថា

**យោ បនាយំ ខមោ ហោតិ សីតស្ស ឧណ្ហស្សាតិអាទិនា នយេន អាគតោ ។ អយំ ខន្តិសំវរោ នាម**[២៨] ។

“ម្យ៉ាងទៀត សំវរៈ ដែលមកដោយន័យជាដើមថា ( ភិក្ខុអ្នកអត់ធន់ចំពោះការត្រជាក់ ជាអ្នកអត់ធន់ចំពោះការក្ដៅ )នេះ ឈ្មោះថា ខន្តិសំវរៈ” ។

សំវរៈប្រភេទទី ៥ គឺវីរិយសំវរៈ សេចក្ដីព្យាយាមដើម្បីលះបង់

នូវកាមវិតក្កៈជាដើម សមពិតដូចសាធកៈថា

យោ ចាយំ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតីតិអាទិនា នយេន អាគតោ, អយំ វីរិយសំវរោ នាម[២៩] ។

"ម្យ៉ាងទៀត សំវរៈដែលមកដោយន័យជាដើមថា ( ភិក្ខុមិនព្រមឲ្យកាមវិតក្កៈដែលកើតឡើងហើយតាំងនៅខាងក្នុង ) ឈ្មោះថាវីរិយសំវរៈ" ។

វីរិយសំវរៈនេះ អត្ថធម៌ គឺវីរិយចេតសិក ដែលរាប់ថាជាសម្មប្បធាន ដូចសេចក្ដីក្នុងព្រះបាលីថា

អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ ចិត្តំ បគ្គណ្ហាតិ បទហតិ[៣០] ។

"ភិក្ខុរមែងញុំាងឆន្ទៈ ឲ្យកើតឡើង រមែងព្យាយាមប្រកបចិត្ត រមែងព្យាយាមដើម្បីមិនឲ្យកើតអកុសលធម៌ដ៏លាមកដែលនៅមិនទាន់កើតមិនឲ្យកើតឡើង" ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ[៣១] ពោលថា សូម្បីអាជីវបារិសុទ្ធិសីល ក៏រាប់

ចូលវីរិយសំវរៈ ក្នុងករណីដុយគ្នានេះ ការខ្វិលច្រអូសដែលជាអកុសលចិត្តុប្បាទ ដែលមានថីនមិទ្ធៈជាប្រធាន រាប់ថាជាសំវរធម៌ប្រភេទចុងក្រោយ ។

ក្នុងបណ្ដាសំវរធម៌ ៥ យ៉ាងនេះ សីលសំវរៈ ចាត់ជាការសង្រួមក្នុងព្រះបាតិមោក្ខដោយត្រង់ សូម្បីបច្ចយសន្និស្សិតសីល ដែលរាប់ចូលក្នុងញាណសំវរៈ និងអាជីវបារិសុទ្ធិសីល ដែលរាប់ចូលក្នុងវីរិយសំវរៈ ហើយក៏រាប់បញ្ចូលជាសីលទី២ និងទី ៣ ដោយហេតុនេះ ទើបមិនរាប់ឥន្ទ្រិយសំវរសីល ចូលក្នុងសីល ៣ ខាងដើម ព្រោះបើរាប់ ចូលដូច្នោះ ក៏នឹងមានសីលតែម្យ៉ាងប៉ុណ្ណោះ មិនមាន ៤ យ៉ាងតាមដែលពោលមកហើយ ។

ម្យ៉ាងទៀត ឥន្ទ្រីយ៍សំវរសីល រមែងបរិសុទ្ធដោយសំវរៈ ៤ យ៉ាង ក្រៅអំពីបាតិមោក្ខសំវរសីល និងក្នុងសំវរៈ ៤ យ៉ាងពួកនោះ ញាណសំវរៈ មិនអាចកើតឡើងមុនការបដិបត្តិធម៌ ព្រោះចាត់ជាវិបស្សនាញាណ និងមគ្គញ្ញាណ ដែលជាផលនៃការចំរើនវិបស្សនា ចំណែកសំវរៈ ៣ យ៉ាងទៀត គឺសតិសំវរៈ ខន្តិសំវរៈ និងវីរិយសំវរៈ

ជាធម៌សំខាន់ក្នុងការចំរើនឥន្ទ្រិយសំវរសីល ។

## ការចំរើនសំវរធម៌ដោយការរម្ងាប់ចិត្តជាដើម

វិធីចំរើនសំវរៈទាំង ៣ យ៉ាងនោះ ពោលទុកក្នុងគម្ពីរអដ្ឋសាលិនីជា

តស្ស ឥមិនា និយមិតវសេន សមុទាចារវសេន

អាកុជិតវសេន ច កុសលំ នាម ជាតំ ហោតិ[៣២] ។

"ដែលឈ្មោះថា កុសល រមែងកើតឡើងដល់បុគ្គលនោះ ដោយការរម្ងាប់ចិត្ត ការរវាំងប្រយ័ត្នចិត្ត ការទម្លាប់ និងការពិចារណាដោយបញ្ញា" ។

ការរម្ងាប់ចិត្ត គឺការអប់រំចិត្តក្នុងអារម្មណ៍ ដែលជាកុសលរឿយៗ ដោយត្រិះរិះក្នុងការធ្វើកុសល និងគេចចេញអំពីអកុសល ពោលគឺ ការធ្វើ និយាយ ឬគិតវត្ថុដែលជាកុសល អត់ធន់មិនឲ្យកើតសេចក្តីថ្នាំងថ្នាក់ និងមិនធ្វើនិយាយ ឬគិតវត្ថុដែលជាអកុសលសូម្បីក្នុងខណៈ ដែលជួបជាមួយអារម្មណ៍ដែលពេញចិត្ត ឬមិនពេញចិត្ត ក៏មិនបានធ្វើទុកក្នុងចិត្ត ហេតុដល់ការកើតអកុសលចិត្ត

ដូចអ្នកដែលត្រិះរិះថា ទើបនឹងឲ្យទាន គឺ គួរមានសទ្ធាក្នុងទានមិនបាន គិតដល់ការប្រើប្រាស់ទ្រព្យដើម្បីវត្ថុដទៃ ឬការជួបជាមួយអនិដ្ឋា-រម្មណ៍ ក៏អត់ធន់ មិនសម្ដែងអាកប្បកិរិយា មិនពេញចិត្តដូច្នេះជាដើម ។

ការអប់រំចិត្ត គឺការកែប្រែចិត្តដែលកើតអកុសលឲ្យជាកុសល ដូចកាលភិក្ខុជួបជាមួយវិសភាគារម្មណ៍ដែលស្អាត រមែងកើតការពេញចិត្តក្នុងខណៈនោះ គប្បីអប់រំថា ស្ត្រីល្មមជាម្ដាយ ក៏ទុកដូចជាម្ដាយ ស្ត្រីល្មមជាបងស្រី ក៏ទុកដូចជាបងស្រី ស្ត្រីល្មមជាប្អូន ក៏ទុកដូចជាប្អូនស្រី មានមេត្តាចិត្តនិងករុណាដូចញាតិបងប្អូន ឬមិនគប្បីកាន់យកចំពោះរូបរាងសណ្ឋាន ដែលធ្វើឲ្យកើតការរវើរវាយ តែទៅធ្វើកិច្ចកម្មយ៉ាងដទៃដែលជាសមណៈកិច្ច ដូចជាការទន្ទេញ ស្វាធ្យាយព្រះបរិត្ត សាកសួរធម៌ជួយប្រយោជន៍ដើម្បីឲ្យព្រហ្មចរិយធម៌ និងវត្តតូចធំក្នុងវត្តជាដើម ឬភិក្ខុអាចចំរើនវត្ថុដែលមិនស្អាតក្នុងរាងកាយដូចជា ទឹកភ្នែក អាចម៍ភ្នែក ទឹកមូត ស្លេស្ម ឧច្ចារៈ បស្សាវៈ ក្នុងស្ត្រីដែលបានជួបដែលហៅថា មូលបរិញ្ញា-ន័យ ( ន័យដែលកំណត់ហេតុដើម ) ក្រៅអំពីនេះ នៅអាចទូន្មាន

ចិត្ត ដោយបដិសន្ធានន័យ គឺន័យពិចារណាដោយសេចក្ដីជាកិលេស ដែលត្រាច់មក កិលេសដែលកើតមួយខណៈៗ ឬពិចារណាបែកខន្ធ អាយតនៈ ធាតុ និងបច្ច័យ ដែលពោលទុក ក្នុងអដ្ឋកថារបស់ មហាសតិប្បដ្ឋានសូត្រ[៣៣] ។

ការប្រាប់ គឺសន្សំកុសលជានិច្ច ដោយការសិក្សាបរិយត្តិធម៌ អានគម្ពីរ ស្វាធ្យាយគម្ពីរ បង្រៀនគម្ពីរ ធ្វើសេនាសនវត្ត សម្ដែងធម៌ សន្ទនាធម៌ ស្ដាប់ធម៌ និងសមាទានធុតង្គជាដើម ។ កាលភិក្ខុសន្សំ កុសលយ៉ាងនេះ កុសលចិត្ត រមែងនឹងកើតផ្លូវទ្វារ ទាំង ៦ ជានិច្ច ចំណែកអកុសលចិត្ត នឹងមិនមានឱកាសកើតឡើង ។

ការពិចារណាដោយបញ្ញា គឺការមានយោនិសោមនសិការគ្រប់ ខណៈ ដែលជួបជាមួយអារម្មណ៍ទាំង ៦ ដើម្បីឲ្យកុសលចិត្តកើត ឡើងជានិច្ច ដូច្នេះ ប្រសិនបើត្រូវគេតិះដៀល ដោយប្រាសចាក ការពិត ក៏គួរត្រិះរិះថា គេនិយាយតិះដៀល ដោយមិនបានដឹងដល់ ហេតុការណ៍ ការតិះដៀលរបស់អ្នកដទៃជារឿងធម្មតា នៃអ្នកដែល មិនបានសង្រួមខ្លួន បើគេដឹងការពិតជាខាងក្រោយ ក៏នឹងមិន

សប្បាយចិត្ត ។ ឥឡូវនេះ យើងត្រូវគេតិះដៀល ក៏ព្រោះយើងធ្លាប់តិះដៀលអ្នកដទៃមកក្នុងកាលមុន ការសងបំណុលកម្ម ក៏ជាធម្មតារបស់មនុស្សទូរទៅជាដើម ។

ន័យម្យ៉ាងទៀត គប្បីពិចារណាថា ការត្រូវគេតិះដៀល ជាលោកធម៌ ដែលកើតជាមួយមនុស្សគ្រប់រូប សូម្បីព្រះមានព្រះភាគ ក៏ធ្លាប់ត្រូវគេតិះដៀលដូចគ្នា ទឹងចាំបាច់ពោលទៅថ្វី ក្នុងខ្លួនយើងនោះ ការប្រឈមមុខ ជាមួយលោកធម៌ ហើយមិនសប្បាយចិត្ត នោះជាធម្មតារបស់មនុស្សដែលមិនបានអប់រំចិត្ត តែការអត់ធន់ ចំពោះលោកធម៌ ជាគុណធម៌របស់សប្បុរសប៉ុណ្ណោះ ។ យើងនឹងទៅតាមផ្លូវរបស់សប្បុរស ព្រះអង្គបានត្រាស់បង្រៀនសាវ័កថា សូម្បីនឹងត្រូវអ្នកដទៃប្រើរណាកាត់អារដងខ្លួន ក៏គួរអត់ធន់ មិនគួរមានចិត្តប្រទូសរាយបុគ្គលនោះ ហេតុអ្វីទើបយើងប្រព្រឹត្តតាមពាក្យប្រៀនប្រដៅ របស់ព្រះបរមសាស្ដារមិនបាន ។

ន័យម្យ៉ាងទៀត គប្បីពិចារណាថា អ្នកនិយាយតិះដៀលនោះត្រឹមតែជាចិត្តជរូប ( គឺវិញ្ញត្តិរូប ) ដែលកើតអំពីចិត្តុប្បាទ ដែលមាន

ទោសៈជាប្រធាន បុគ្គលនោះត្រឹមតែជារូបនាម ខន្ធ ៥ ប៉ុណ្ណោះ ដោយបរមត្ថ មិនមានបុគ្គល អ្នកនិយាយតិះដៀល និងរូបនាមទាំងនោះ ក៏កើតរលត់ជានិច្ច ក្នុងខណៈដែលគេនិយាយតិះដៀល ប្រសិនបើយើង ត្រូវក្រោធគេ ក៏នឹងចាត់ថា ក្រោធរូបនាមថ្មី ដែលកើតតអំពីរូបនាមចាស់ ដូចជាការក្រោធមាតាបិតា ហើយទៅប្រទូសរាយបុត្រាបុត្រីរបស់គេ សូម្បីខ្លួនឯង ក៏ត្រឹមតែជាខន្ធ ៥ ដែលប្រជុំគ្នាប៉ុណ្ណោះ កាលខន្ធចាស់បែកធ្លាយទៅហើយ ខន្ធថ្មីរមែងកើតឡើង មិនមែនបុគ្គល យើង គេ តាមពិត មានត្រឹមតែសភាវធម៌ ។

ការពិចារណា ដោយបញ្ញានេះ អាចធ្វើបានច្រើនវិធីដើម្បីឲ្យកើតកុសល ដែលចាត់ជាយោនិសោមនសិការ រឿងនេះ នឹងប្រាកដតទៅ ក្នុងធម្មានុបស្សនា ពួកនីវរណបព្វៈទី ៤ ។

ដោយហេតុនេះ បុគ្គលគប្បីញុំាងកុសលចិត្តឲ្យកើតផ្លូវទ្វារ ៦ ហើយរក្សាឥន្ទ្រិយសំវរសីល ដោយការបិទបាំងចិត្ត មិនឲ្យកើតអកុសល អ្នកដែលបិទចិត្តបានយ៉ាងនេះ រមែងនៅមានសតិ ញុំាងឲ្យ

កើតកុសលចិត្តជានិច្ច ក្នុងខណៈជួបជាមួយអារម្មណ៍ទាំង ៦ សតិក្នុងទីនេះ ឈ្មោះថា សតិសំវរៈ សូម្បីក្នុងខណៈដែលកើតអកុសលចិត្តខ្លះ ក៏គប្បីតាំងចិត្តថា នឹងមិនគិតដូច្នេះទៀត ឥន្ទ្រិយសំវរៈ មែនបរិសុទ្ធដោយការតាំងចិត្ត ដូចការបរិសុទ្ធអំពីអាបត្តិ កាលសម្តែងអាបត្តិហើយ ។

ក្រៅពីនេះ ការអត់ធន់ ចំពោះអនិដ្ឋារម្មណ៍ បានដោយមិនថ្នាំងថ្នាក់ចិត្ត ឬ ក្រោធ ឈ្មោះថា ខន្តិសំវរៈ និងសេចក្តីព្យាយាមដើម្បីមិនឲ្យកើតកាមវិតក្កៈ ( សេចក្តីត្រិះរិះក្នុងកាមគុណអារម្មណ៍ ) ព្យាបាទវិតក្កៈ ( សេចក្តីត្រិះរិះក្នុងការព្យាបាទ ) និងវិហឹសាវិតក្កៈ ( សេចក្តីត្រិះរិះក្នុងការបៀតបៀន ) ឈ្មោះថាវីរិយសំវរៈ ។

ដូចន័យដែលពោលមកនេះ ជាគន្លងផ្លូវដ៏ល្អដើម្បីហ្វឹកហាត់ចិត្តឲ្យកើតកុសលចិត្តជានិច្ច មើលទៅហាក់បីដូចជាធ្វើបានងាយ តែកាលបដិបត្តិតាមវិញ ទើបដឹងថាលំបាក ព្រោះចិត្តដែលមិនបានអប់រំដោយភាវនា មានសភាពលំបាក សូម្បីយើងតាំងចិត្តនឹងមិនគិតដល់វត្ថុអាក្រក់ ចិត្តក៏នៅតែរំពឹងគិតដល់អារម្មណ៍នោះ សេចក្តីនេះ

ជាធម្មតារបស់ចិត្ត ដែលមិនបានអប់រំមកល្អដោយភាវនា ។

អ្នកខ្លះពោលថា "អ្នកដែលចំរើនភាវនា ត្រូវជម្រះសីល ៤ យ៉ាងឲ្យបរិសុទ្ធជាមុន" អ្នកខ្លះក៏ពោលថា "សូម្បីទីងមិនបានចំរើនភាវនា ក៏អាចជម្រះសីលនេះឲ្យបរិសុទ្ធបាន" ។

ការឃើញខាងដើម ជំទាស់ជាមួយពាក្យអធិប្បាយ ក្នុងគម្ពីរអដ្ឋកថា និងដីកាដែលពោលដល់ការមិនកើតកិលេសផ្លូវទាំង ៦ ដោយទទួលដឹងត្រឹមសភាវៈឃើញ ។ល។ ប៉ុណ្ណោះ នឹងអ្នកដែលមិនបានចំរើនភាវនា នឹងហាមចិត្តមិនឲ្យកើតកិលេស កាលកើតវិញ្ញាណចិត្ត ក្នុងខណៈដែលអារម្មណ៍ ៦ ប្រាកដផ្លូវទ្វារ ៦ បានយ៉ាងណា សូម្បីអ្នកចំរើនវិបស្សនាមានកម្លាំង ក៏ហៅថា ពលវិបស្សកៈ ( អ្នកសម្រេចកន្ត្រញាណជាដើមទៅ ) កិលេសក៏អាចកើតឡើងបានក្នុងពេលខ្លះ មនុស្សសាមញ្ញធម្មតា ទើបមិនអាចហាមចិត្ត អំពីកិលេសបានរហូត ព្រោះកិលេសដែលលះដោយឥន្ទ្រិយសំវរមិនមែនជា វីតិក្កមកិលេស ដែលជាការកន្លងល្មើសផ្លូវកាយ និងវាចា តែជាបរិយុដ្ឋានកិលេស និងអនុស្សយកិលេស ដែលត្រូវលះដោយ

សមាធិ និងបញ្ញាតាមលំដាប់ ។

ម្យ៉ាងទៀត ឥន្ទ្រិយសំវរសីល ជាសីលដោយបរិយាយ មិនមែនជាសីលដោយត្រង់ ដូចជាបាតិមោក្ខសំវរសីល សូម្បីអង្គធម៌នៃឥន្ទ្រិយសំវរសីល ដែលជាសតិ បញ្ញា ខន្តិ និងវីរិយៈ រាប់បញ្ចូលជាសមាធិសិក្ខា និងបញ្ញាសិក្ខាដោយត្រង់ ចាត់ចូលក្នុងភាវនា ក៏ឃើញបានថា អង្គធម៌នៃញាណសំវរៈ គឺ មគ្គញាណ ដូចដែលពោលទុកក្នុងគម្ពីរចូឡនិទ្ទេស[៣៤]និងអដ្ឋកថាសុត្តនិបាត[៣៥]។

ចិត្តដែលអប់រំល្អហើយដោយភាវនា នឹងមានសេចក្ដីល្អិតសុខុម នឹងស្ថិតនៅក្នុងអារម្មណ៍ដែលតាំងចិត្តទុក សេចក្ដីនេះ ជាធម្មតារបស់ចិត្ត ដែលអប់រំល្អហើយ ដូច្នោះ ឥន្ទ្រិយសំវរសីល ទើបបរិសុទ្ធបានដោយភាវនាដ៏ក្រៃលែង មានកម្លាំងខ្លាំងត្រឹមណា សីលក្នុងខនេះ ក៏បរិសុទ្ធក្រៃលែងត្រឹមនោះ កាលភាវនាមានកម្លាំងច្រើនពេញបរិបូណ៌ហើយ សីលនេះក៏បរិសុទ្ធ តាមដែលពោលទុកក្នុងគម្ពីអដ្ឋកថានិងដីកា ។

ក្នុងគម្ពីវិសុទ្ធិមគ្គ បានពោលថា ភិក្ខុគប្បីប្រព្រឹត្ត ដូចព្រះ

មហាតិស្សត្ថេរ លោកចំរើនអសុភការនាក្នុងអដ្ឋិកសញ្ញា បានឃើញស្ត្រីម្នាក់សើច ក៏ចំរើនអសុភការនាក្នុងធ្មេញ ដែលឃើញហើយបានសម្រេចបឋមជ្ឈាន លោកចំរើនវិបស្សនា ដែលមានបឋមជ្ឈានក្នុងកាលជាទីបំផុត បានសម្រេចនូវអរហត្តផល ក្នុងខណៈនោះ ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គថា

តស្ស តន្ទដ្ឋិកំ ទិស្វា បុព្វសញ្ញំ អនុស្សរិ
តត្ថេវ សោ ឋិតោ ថេរោ អរហត្តំ អបាបុណិ[៣៦] ។

"ព្រះថេរៈនោះឈរហើយ ឃើញឆ្អឹងធ្មេញរបស់ស្ត្រីនោះ ក៏រលឹកដល់សញ្ញាចាស់ ទើបសម្រេចព្រះអរហត្តផលក្នុងទីនោះឯង" ។

ពាក្យថា **បុព្វសញ្ញំ អនុស្សរិ** ( រលឹកដល់សញ្ញាចាស់ ) សំដៅថា ព្រះថេរៈជាអ្នកចំរើនអដ្ឋិកសញ្ញា ( សេចក្តីសម្គាល់ថាជាឆ្អឹង ) យ៉ាងស្ទាត់ជំនាញ ។

អ្នកដែលត្រូវការទីងពិចារណា ដូចនេះត្រូវចំរើនការនាឲ្យមានការស្ទាត់ជំនាញ ដូចជាព្រះថេរៈទើបនឹងជួបផលសម្រេចដ៏ខ្ពង់ខ្ពស់

បាន តែអ្នកមិនធ្លាប់អប់រំភាវនាមកមុន រមែងមិនអាចនឹងពិចារណាបាន ដូចជាអ្នកដែលអប់រំភាវនាល្អហើយ ការពិត អ្នកដែលមានបារមីពេញបរិបូណ៌ហើយ នឹងអាចពិចារណាយ៉ាងនោះបាន តែការពិចារណាថាជាអសុភរបស់គេ ក៏រាប់ថាជាភាវនា ដូច្នោះ ឥន្ទ្រិយសំវរសីល ទើបមិនអាចបរិបូណ៌បាន ដោយប្រាសចាកភាវនា ។

ដោយហេតុដូចពោលមកនេះ សេចក្ដីក្នុងគម្ពីរអដ្ឋកថានិងដីកាដែលពោលនេះ អាចរាំងមិនឲ្យកើតកិលេសផ្លូវទ្វារ ៦ ទើបសំដៅដល់ការឃុំគ្រងចិត្ត ដោយភាវនាដោយពិតប្រាកដយ៉ាងណាក៏ដោយអ្នកដែលមិនបានចំរើនភាវនា កាលដែលត្រូវការនឹងសង្រួមឥន្ទ្រិយ៍ ក៏ធ្វើតាមន័យដែលពោលមកហើយនោះ តែប្រសិនបើត្រូវការនឹងឲ្យន្ទ្រិយសំវរសីលបរិសុទ្ធ ក៏ត្រូវព្យាយាមចំរើនភាវនា នឹងមិនគួរគិតកន្លល់ថា ឥន្ទ្រិយសំវរៈនៅមិនទាន់បរិសុទ្ធ កាលសំវរធម៌ប្រាកដឡើង ក្នុងចិត្តុប្បាទ ក្នុងខណៈបដិបត្តិធម៌ហើយ ក៏យល់ចូលចិត្តថា ឥន្ទ្រិយសំវរសីលបរិសុទ្ធបរិបូណ៌ពិតប្រាកដ ។

## សីលរបស់ភិក្ខុ

ភិក្ខុគប្បីរក្សាបាតិមោក្ខសំវរសីល និងអាជីវបារិសុទ្ធិសីលឲ្យបរិសុទ្ធមុន កាលសីលទាំង ២យ៉ាងនេះវិបត្តិ ក៏នឹងត្រូវអាបត្តិនិងចាត់ថា ជាអន្តរាយព្រោះជាការកន្លងល្មើស ខបញ្ញត្តិរបស់ព្រះពុទ្ធជាម្ចាស់ ( អាណាវីតិក្កមន្តរាយ ) ម្យ៉ាងទៀត ក្នុងសីលទាំង ២ យ៉ាងនេះ បាតិមោក្ខសំវរសីលជាប្រធាន ព្រោះកាលសីលប្រភេទនេះបរិសុទ្ធ អាជីវបារិសុទ្ធិសីលក៏បរិសុទ្ធដូចគ្នា ពោលគឺការស្វែងរកចិញ្ចឹមជីវិតវិបត្តិទៅ ភិក្ខុរមែងត្រូវអាបត្តិ និងបាតិមោក-សំវរសីល ក៏បែកធ្លាយ ភិក្ខុត្រូវការទឹងជម្រះបាតិមោកសំវរសីលឲ្យបរិសុទ្ធ គួរគេចចេញអំពីមិច្ឆាជីវគ្រប់ប្រភេទ ដូចជាឲ្យផ្កាឈើឲ្យផ្លែឈើ ទាយជោគជតាជាដើម ហើយរកចិញ្ចឹមជីវិតដោយបច្ច័យ ៤ ដែលស្វែងរកបានត្រូវតាមធម៌ តាមវិន័យ ។

ចំណែកឥន្ទ្រិយសំវរសីល និងបច្ចយសន្និស្សិតសីល បើមានការឧស្សាហៈត្រូវការចំរើនកុសល ក៏គួររក្សាឲ្យបរិសុទ្ធបរិបូណ៌ ព្រោះជួយមិនឲ្យកើតសេចក្តីក្តៅក្រហាយចិត្ត ( អវិប្បដិសារ ) ជាដើម

យ៉ាងណាក៏ដោយ សូម្បីសីលទាំង ២ យ៉ាងនៅមិនទាន់បរិសុទ្ធ ក៏មិនមានអន្តរាយយ៉ាងណាម្យ៉ាង តែក៏មិនគួរធ្វេសប្រហែស គួរព្យាយាមចំរើនភាវនាដើម្បីឲ្យសីលទាំង ២ យ៉ាងខាងក្រោយឲ្យបរិសុទ្ធ បន្ទាប់អំពីការដែលបានរក្សាសីល ២ យ៉ាងដំបូងហើយ សីលទាំង ៤ យ៉ាងនេះ នឹងកើតឡើងក្នុងក្រសែចិត្ត ដែលចំរើនភាវនាមានសេចក្តីបរិសុទ្ធបរិបូណ៌ដោយប្រការទាំងពួង រឿងនេះនឹងប្រាកដតទៅក្នុងខាងចុង របស់សីលគ្រហស្ថដែល នឹងពោលតទៅ ។

## សីលរបស់គ្រហស្ថ

សីលរបស់គ្រហស្ថមិនពិស្តារ ដូចជាសីលរបស់ភិក្ខុ ត្រឹមតែរក្សាបញ្ចសីល ឬ អាជីវដ្ឋមកសីល ( សីលមានការចិញ្ចឹមជីវិតជាទី៨ ) ក៏ចាត់ជាអ្នកមានសីលបរិសុទ្ធហើយ សូម្បីបញ្ចសីល និងអាជីវដ្ឋមកសីល នឹងមានសិក្ខាបទខ្លះ ផ្សេងគ្នា តែទាំងពីរយ៉ាងនេះ ក៏ជាសីលវិសុទ្ធិដូចគ្នា ព្រោះមានការរក្សា និងវៀរចាកដូចគ្នា ។

អ្នកដែលរក្សាបញ្ចសីលនោះ កាលនឹងរក្សាឲ្យបរិសុទ្ធបរិបូណ៌

ក៏មិនត្រឹមតែរក្សាសិក្ខាបទ ៥ទេ សេចក្តីដែលប្រាកដ ដោយត្រង់ប៉ុណ្ណោះ តែនៅត្រូវវៀរចាកវចីទុច្ចរិត ៣ ទៀត គឺ បិសុណវាចា ( ពាក្យស៊កសៀត ) ផរុសវាចា ( ពាក្យដ៏គ្រោតគ្រាត ) និងសម្ផប្បលាប ( និយាយពាក្យរោយរាយឥតប្រយោជន៍ ) ទាំង ៣ នេះរាប់ចូលក្នុងមុសាវាទ ដោយភាពជាវចីទុច្ចរិតដូចគ្នា និងបុគ្គលនោះ នឹងត្រូវវៀរចាកមិច្ឆាជីវៈ ទៀតផង ។ អ្នកដែលរក្សាអាជីវដ្ឋមកសីល ក៏ត្រូវវៀរចាកអំពីការផឹកសុរា ដែលរាប់បញ្ចូលក្នុងកាមេសុមិច្ឆាចារ ព្រោះជាការប្រព្រឹត្តខុសក្នុងកាមគុណ គឺរសារម្មណ៍ដូចគ្នា ដូច្នោះ និច្ចសីលនិងអាជីវដ្ឋមកសីល ទើបមិនផ្សេងគ្នា ។

ចំណែកបាតិមោក្ខសំវរសីលរបស់គ្រហស្ថ គឺការវៀរចាកកាយទុច្ចរិត ៣ និងវចីទុច្ចរិត ៤ ដែលមិនជាប់ទាក់ទងជាមួយការចិញ្ចឹមជីវិតក្នុងបញ្ចសីលនិងអាជីវដ្ឋមកសីល និងអាជីវបារិសុទ្ធសីលរបស់គ្រហស្ថ គឺ ការវៀរចាកចំពោះកាយទុច្ចរិត ៣ និងវចីទុច្ចរិត ៤ ដែលជាប់ទាក់ទងជាមួយនឹងការចិញ្ចឹមជីវិត ។

សីលរបស់គ្រហស្ថ ដែលជាប់ទាក់ទងជាមួយការចិញ្ចឹមជីវិត ខណៈធ្វើ និងក្នុងខណៈប្រើប្រាស់បច្ច័យ ដែលបានទទួលដោយ មច្ឆាជីវៈ ព្រោះការកន្លងល្មើសខបញ្ញត្តិ របស់ព្រះពុទ្ធជាម្ចាស់ តែកាលគ្រហស្ថ ដែលប្រកបមិច្ឆាជីវៈ អាជីវបារិសុទ្ធិសីលរបស់ គេរមែងវិបត្តិទៅ ក្នុងខណៈកន្លងល្មើសផ្លូវកាយទុច្ចរិត និងវចីទុច្ចរិត ប៉ុណ្ណោះ មិនរាប់ថាជាមិច្ឆាជីវៈ ក្នុងខណៈប្រើប្រាស់បច្ច័យដូចពោល ព្រោះមិនបានធ្វើបាបណាៗ ក្នុងខណៈបរិភោគប្រើប្រាស់ និងមិន កន្លងល្មើសខបញ្ញត្តិ របស់ព្រះពុទ្ធជាម្ចាស់ដូចជាភិក្ខុ ព្រោះដូច្នោះ គ្រហស្ថដែលបានទទួលវត្ថុ ដែលស្វែងរក ដោយមច្ឆាជីវៈ ទើបមិន ចាំបាច់ត្រូវលះវត្ថុពួកនោះ និងបើមិនធ្វើមិច្ឆាជីវៈ ផ្លូវកាយ ឬ វាចា ទៀត អាជីវបារិសុទ្ធិសីលរបស់គេ ក៏បរិសុទ្ធដូចមុន ។

ឥន្ទ្រិយសំវរសីល កើតឡើងបានដោយលំបាក ដល់ភិក្ខុអ្នកមិនចំរើន ភាវនា ទើបមិនត្រូវពោលដល់ករណី ក្នុងគ្រហស្ថដោយទូទៅ ចំណែកបច្ចយសន្និស្សិតសីល និងជាប់ទាក់ទងជាមួយបព្វជិត ប៉ុណ្ណោះ ព្រោះគ្រហស្ថមិនមានការបរិភោគជំពាក់បំណុល ចំពោះ ការប្រើប្រាស់បច្ច័យ ដោយមិនបានពិចារណា ។ តែសីលខនេះជា

ទេសនាជាប់ទាក់ទងដោយព្រះសូត្រថា ការពិចារណាប្រយោជន៍របស់បច្ច័យ ទើបជាហេតុឲ្យកើតកុសលចិត្តនិងធ្វើឲ្យ អកុសលស្ងួចស្ងើង គ្រហស្ថអាចប្រព្រឹត្តសីលខនេះបានដូចគ្នា និងសីលទាំង ៤ ប្រភេទនឹងបរិបូណ៌បានក្នុងខណៈចំរើនភាវនា តែម្យ៉ាង ។

អ្នកខ្លះសំគាល់ថា ត្រូវរក្សាសីលឲ្យបរិសុទ្ធអស់កាលយូររាប់ខែ ឬរាប់ឆ្នាំសិន ទើបនឹងចំរើនភាវនា ដើម្បីឲ្យកើតសមាធិ និងបញ្ញា ការយល់ឃើញដូចពោលមកនេះ ត្រឹមតែជាអត្តនោមតិប៉ុណ្ណោះ ព្រោះមិនប្រាកដក្នុងព្រះបាលី ព្រះអដ្ឋកថា និងដីកា ថាត្រូវរក្សាសីលឲ្យបរិសុទ្ធយ៉ាងយូរត្រឹមណា ទើបនឹងចំរើនភាវនាបាន ។ សេចក្តីថា ប្រសិនបើភិក្ខុ ធ្វើបាតិមោក្ខសំវរសីលឲ្យបែកធ្លាយក៏ឈ្មោះថា ជាអាណាវីតិក្កមន្តរាយ ភិក្ខុទើបគួរប្រព្រឹត្តសីលឲ្យបរិសុទ្ធមុនសិន តែមិនបានបញ្ជាក់ថា ត្រូវយូរត្រឹណា ទើបគួរចំរើនភាវនា ដូច្នោះ រាប់អំពីខណៈដែលភិក្ខុប្រព្រឹត្តសីលរបស់ខ្លួនឲ្យបរិសុទ្ធហើយ ក៏គួរចំរើនភាវនាបានគ្រប់ពេល សូម្បីគ្រហស្ថក៏ដូចគ្នា ចំណែកអ្នកដែលមានបារមីពេញបរិបូណ៌ហើយ អាចកើតនូវសមាធិវិបស្សនា និងមគ្គផលបាន តាំងអំពីពេលនោះ ។ សីល

៥ របស់គ្រហស្ថនោះ ជាសីលប្រចាំ ដែលមាននៅក្នុងលោកជានិច្ច មិនថាទីងមានសាសនា មិនមានក៏ដោយ អ្នកដែលរក្សាសីល ៥ រមែងនឹងមានតាមសមគួរ ចំណែកអ្នកដែលរក្សា សីល ៥ រមែងនឹងចំរើនកុសលបានទទួលអានិសង្សរបស់សីលនោះៗ ។

ប្រយោជន៍ និងទោសនៃការរក្សាសីល ៥ មិនបានកើតឡើង ជាមួយខបញ្ញត្តិរបស់ព្រះពុទ្ធជាម្ចាស់ទេ តែជាសភាវៈប្រក្រតី ដែលមានប្រចាំក្នុងលោក ដូច្នោះអ្នកដែលមិនបានរក្សាបញ្ចសីល មុននឹងបដិបត្តិធម៌ ទើបមិនមែនជាអន្តរាយដែលហាមមគ្គផល បើការខុសត្រូវរបស់គេមិនមែនជាអនន្តរិយកម្ម ៥ ការប្រទូសរាយនាងភិក្ខុនី នឹងការពោលតិះដៀលព្រះអរិយបុគ្គល បើគេធ្វើអនន្តរិយកម្មជាដើមនោះហើយ សូម្បីនឹងជាបព្វជិត ឬគ្រហស្ថ ក៏មិនអាចសម្រេចមគ្គផលបានក្នុងជាតិនេះទេ ។

## អន្តរាយ ៥ យ៉ាង

ធម៌ដែលជាអន្តរាយ ចំពោះការសម្រេចមគ្គផលមាន ៥ យ៉ាង គឺ៖

១.   កម្មន្តរាយ   អន្តរាយគឺ កម្ម សំដៅដល់ មាតុឃាត ( សម្លាប់មាតា ) បិតុឃាត ( សម្លាប់បិតា ) អរហន្តឃាត ( សម្លាប់ព្រះអរហន្ត ) លោហិតុប្បាទ ( ធ្វើលោហិតព្រះសម្មាសម្ពុទ្ធឲ្យពុះពង ) និង សង្ឃភេទ ( ទំលាយសង្ឃឲ្យបែកគ្នា ) ដោយកម្មចុងក្រោយជាប់ទាក់ទងជាមួយភិក្ខុប៉ុណ្ណោះ កម្មពួកនេះឈ្មោះថា អនន្តរិយកម្ម គឺកម្មដែលឲ្យផលទៅកើតក្នុងអបាយភូមិ បន្ទាប់អំពីអស់ជីវិតហើយ កម្មទាំង ៥ យ៉ាងនេះ រារាំងការទៅកើតក្នុងឋានសួគ៌ និងបន្ទុះនិព្វាន  ចំណែកឯកម្មមួយប្រភេទទៀត គឺ ភិក្ខុនីទូសកៈ ( ប្រទូសរាយនាងភិក្ខុនី ) រារាំងចំពោះការ បន្ទុះមគ្គ ។

២. កិលេសន្តរាយ អន្តរាយ គឺ កិលេស សំដៅដល់ មិច្ឆាទិដ្ឋិ ៣ ប្រការ បានដល់អកិរិយទិដ្ឋិ គឺការយល់ឃើញខុសថា មិនមានបុណ្យបាប សូម្បីនឹងធ្វើយ៉ាងណា ក៏មិនមានកម្មល្អ ឬ កម្មអាក្រក់ និងមិនបញ្ចូនផលជាគុណ ឬ ទោស ។ នត្ថិកទិដ្ឋិ គឺការយល់ឃើញខុសថា ពួកសត្វស្លាប់ហើយសូន្យ មិនមានភពថ្មី មិនមានផលរបស់បុណ្យបាប ក្នុងភពតទៅ និងអហេតុកទិដ្ឋិ គឺការយល់ឃើញខុសថា មិនមានកម្មល្អ ឬអាក្រក់ ដែលជាហេតុឲ្យ

កើតគុណទោស សត្វដែលជាសុខ ឬទុក្ខគ្រប់យ៉ាង ក៏ប្រាសចាកហេតុបច្ច័យ ។ ការយល់ឃើញខុសទាំង ៣ ប្រការពួកនេះ រមែងញ៉ាំងផលឲ្យទៅកើតក្នុងនរក ក្រោយអំពីអស់ជីវិតហើយ ទើបឈ្មោះថា និយតមិច្ឆាទិដ្ឋិ គឺការយល់ឃើញខុសដែលទៀងតែនឹងទៅកាន់នរក ជាកិលេសរាំងការចូលដល់សួគ៌ និងនិព្វាន ។

ក្នុងបណ្ដាការឃើញ ដូចដែលពោលមកនេះ អហេតុកទិដ្ឋិ បដិសេធនូវហេតុថា កម្មមិនមាន, នត្ថិកទិដ្ឋិ បដិសេធផលថា ផលកម្ម មិនមាន, ចំណែកអកិរិយទិដ្ឋិ បដិសេធទាំងហេតុនិងផល យ៉ាងណាក៏ដោយ កាលបដិសេធហេតុ ក៏ចាត់ថា បដិសេធផលនឹង កាលបដិសេធផល ក៏ជាការបដិសេធហេតុ ការឃើញខុសទាំង ៣ ប្រការ ទើបមានដូចគ្នា ដោយជំទាស់ថា បាបបុណ្យមិនមានពិតផល របស់បាបបុណ្យ ក៏មិនមានពិត ។

៣. វិបាកន្តរាយ អន្តរាយ គឺ វិបាកសំដៅដល់ បដិសន្ធិចិត្ត ដែលជាអហេតុកបដិសន្ធិ ( បដិសន្ធិដែលមិនមានហេតុ ៣ គឺ អលោភហេតុ អទោសហេតុនិងអមោហហេតុ ) និងទ្វិហេតុកបដិសន្ធិ

( បដិសន្ធិដែលមានហេតុ ២ គឺ អលោភហេតុ និងអទោសហេតុ ) បុគ្គលអ្នកប្រកបដោយបដិសន្ធិប្រភេទនេះ មិនអាចបានសម្រេចមគ្គផលក្នុងជាតិនេះទេ ព្រោះប្រាសចាកបញ្ញាក្នុងខណៈបដិសន្ធិ បើធ្វើកុសលទុក ក៏កើតជាមនុស្ស ឬទេវតាបាន អន្តរាយប្រភេទនេះទើបហាមការសម្រេចមគ្គផល ឈាន និងអភិញ្ញា មិនហាមការទៅកាន់ឋានសួគ៌ ។

៤. អរិយូបវាទន្តរាយ អន្តរាយ គឺ ការពោលតិះដៀលនូវព្រះអរិយបុគ្គល សំដៅដល់ ការនិយាយតិះដៀល ចំពោះព្រះអរិយបុគ្គលដើម្បីឲ្យលោកខូចឈ្មោះ អាប់យស ឬសីលធម៌ សូម្បីទីងដឹងថា លោកជាព្រះអរិយបុគ្គល ឬមិនដឹងក៏ដោយ អន្តរាយប្រភេទ. នេះ ហាមមិនឲ្យទៅកាន់ឋានសួគ៌និងនិព្វាន ប្រសិនបើសូមខមាទោសហើយ ក៏រួចផុតអំពីអន្តរាយនេះបាន ។

៥. អាណាវីតិក្កមន្តរាយ អន្តរាយគឺ ការកន្លងល្មើសនូវបញ្ញត្តិរបស់ព្រះពុទ្ធជាម្ចាស់ សំដៅដល់ ការត្រូវអាបត្តិយ៉ាងណានិមួយក្នុងអាបត្តិទាំង ៧ កងរបស់ភិក្ខុគឺ បារាជិក សង្ឃាទិសេស ថុល្លច្ច័យ បាចិត្តិយ បដិទេសនិយ ទុក្កដ និងទុព្ភាសិត អន្តរាយ ប្រភេទនេះ

ហាមនូវការទៅកាន់ឋានសួគ៌ និងនិព្វាន តែបើជម្រះទោសតាម វិនយកម្មហើយ ក៏រួចផុតអំពីអន្តរាយ ប្រភេទនេះបាន ដូចគម្ពីរ អដ្ឋកថា ពោលថា

**តេបិ យាវ ភិក្ខុភាវំ វា បដិជានាតិ ន វុដ្ឋាតិ**
**វា ន ទេសេតិ, តាវទេវ ។ ន តោ បរំ[៣៧] ។**

“កងអាបត្តិពួកនោះ រមែងធ្វើអន្តរាយ ដរាបដែលនៅប្តេជ្ញានូវភាពជាភិក្ខុ ឬនៅមិនទាន់បានចេញអំពីអាបត្តិធ្ងន់ ឬនៅមិនបានសម្តែងអាបត្តិស្រាល តែមិនធ្វើអន្តរាយក្នុងខាងក្រោយពីនោះ” ។ ទឹងឃើញបានថា ការទ្រុស្តសីលរបស់គ្រហស្ថទូទៅមិនមែនជាអន្តរាយ ចំពោះការសម្រេចមគ្គផល ព្រោះមិនមែនជាធម៌ដែលចាត់ចូលក្នុងអន្តរាយ ៥ ខាងដើមទេ ដូច្នោះ អ្នកដែលមិនបានរក្សាសីលមុនចំរើនភាវនា ទើបសម្រេចមគ្គផលបាន ក្នុងខណៈស្តាប់ធម៌ ទឹងកំណត់ដឹងសភាវធម៌ ដែលប្រាកដច្បាស់ ក្នុងខណៈនោះ ដូចក្នុងរឿងសន្តតិមហាមាត្យ រឿងមនុស្សស្ទូចត្រី ឈ្មោះអរិយៈ រឿងចោរម្នាក់ ដែលមានក្នុងអដ្ឋកថាធម្មបទ និងរឿងស្តេចសក្យ ឈ្មោះ

សរណាទិ ។

# រឿងសន្តតិមហាមាត្យ

ក្នុងសម័យពុទ្ធកាល អាមាត្យនៃព្រះបាទកោសល្យ ឈ្មោះ សន្តតិមហាមាត្យ បានច្បាំងឈ្នះសឹកសត្រូវ ទើបបានទទួលព្រះបរមរាជានុញ្ញាតិឲ្យសោភជ ៧ ថ្ងៃ គេមានសេចក្តីសុខក្អឹតក្អឹន ដោយការផឹកសុរា នឹងសប្បាយរីករាយជាមួយនាងរបាំ កាលគេទៅដល់កំពង់ទឹកព្រមជាមួយបរិវារក្នុងថ្ងៃទី ៧ ជួបព្រះមានព្រះភាគ ហើយសម្តែងសេចក្តីគោរពបើខ្នងដំរី ព្រះអង្គទ្រង់ព្យាករណ៍ថា "គេនឹងបានស្តាប់មួយគាថា ហើយសម្រេចអរហត្តផលក្នុងថ្ងៃនេះ ហើយនឹងបរិនិព្វានក្នុងភេទជាគ្រហស្ថ" ។ ចំណែកឯពួកតិរ្ថិយ៍ បានឮព្រះពុទ្ធព្យាករណ៍នោះ ក៏ត្រិះរិះថា "អ្នកដែលស្រវឹងសុរានឹងស្តាប់ធម៌ ហើយសម្រេចធម៌ក្នុងថ្ងៃនេះយ៉ាងណា ពួកយើងនឹងចោទនូវព្រះសមណគោតមដោយមុសាវាទ" បន្ទាប់អំពីនោះ ក្នុងវេលាល្ងាចស្ត្រីអ្នករបាំម្នាក់ ដែលជាទីស្រឡាញ់របស់ សន្តតិមហាមាត្យអស់ជីវិតយ៉ាងលឿន ក្នុងខណៈនោះឯង គេសោយសោកយ៉ាងខ្លាំង ទើបចូលទៅគាល់ព្រះអង្គ ដើម្បីរំលត់សេចក្តីសោកនោះ

ព្រះអង្គ ទ្រង់ត្រាស់សម្ដែងគាថាថា

យំ បុព្វេ តំ វិសោសេហិ  បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ  ឧបសន្តោ ចរិស្សសិ[៣៤]។

“ កិលេសជាតណាកើតឡើង ( ព្រោះប្រារព្ធ ) សង្ខារជា អតីត អ្នកចូរធ្វើកិលេសនោះ ឲ្យរីងស្ងួតទៅ កិលេសគ្រឿងកង្វល់ ( មានរាគៈជាដើមកើតឡើងព្រោះប្រារព្ធ ) សង្ខារដែលនឹងមានទៅខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់ក្នុងធម៌ជាកណ្ដាល ( មានរូបជាដើមដែលជាបច្ចុប្បន្ន ) អ្នកនឹងទៅជាបុគ្គលស្ងប់” ។

សន្តតិមហាមាត្យ ស្ដាប់ព្រះគាថានេះហើយ សម្រេចធម៌ជាព្រះអរហន្តបន្ទាប់ពីនោះ បានហោះឡើងទៅលើអាកាស ៧ ដូរត្នោត ហើយបរិនិព្វានក្នុងភេទជាគ្រហស្ថ ក្នុងរឿងនេះពោលទុក ក្នុងអដ្ឋកថាធម្មបទជាដើម ។

ជាការពិតហើយ ក្នុងរឿងនេះដែលមហាមាត្យ បានសម្រេចធម៌

ក្នុងខណៈស្តាប់ធម៌ ឬក្នុងរឿងដទៃទំនងដូចគ្នានោះ ការស្តាប់ធម៌តែម្យ៉ាង ដោយមិនបានកំណត់ដឹងរូបនាមក្នុងបច្ចុប្បន្នខណៈ រមែងមិនអាចធ្វើឲ្យសម្រេចធម៌បានទេ ។ ជនពួកនោះត្រូវកំណត់ដឹងរូបនាមក្នុងខណៈនោះហើយ សម្រេចវិបស្សនាញាណផ្សេងៗ ជាព្រះសោតាបន្ន, ព្រះសកទាគាមី, ព្រះអនាគាមី និងព្រះអរហន្ត ដូចសេចក្តីក្នុងអដ្ឋកថា នៃមហាសតិប្បដ្ឋានសូត្រថា

**យស្មា បន កាយវេទនាចិត្តធម្មេសុ កញ្ចិ ធម្មំ អនាមសិត្វា ភាវនា នាម នត្ថិ ។ តស្មា តេបិ ឥមិនាវ មគ្គេន សោកបរិទេវេ សមតិក្កន្តាតិ វេទិតព្វា** ៣៩ ។

“ម្យ៉ាងទៀត ដែលឈ្មោះថា ភាវនារមែងមិនមាន ដោយការមិនបានកំណត់ដឹងធម៌យ៉ាងណានិមួយ ក្នុងកងរូប វេទនា ចិត្ត និងសភាវធម៌ ។ ដូច្នោះ គួរជ្រាបថា សូម្បីសន្តតិមហាមាត្យ និងនាងបដាចារា ពួកនោះបានកន្លងផុត សេចក្តីសោយសោក និងសេចក្តីកន្ទក់កន្ទេញដោយផ្លូវ គឺសតិប្បដ្ឋាននេះ”។ តាមសេចក្តីក្នុងគម្ពីរសន្តតិមហាមាត្យ បានសម្រេចធម៌ជាព្រះអរហន្ត នាងបដាចារា

បានសម្រេចជាព្រះសោតាបន្ន អ្នកទាំងពីរត្រូវគំណត់ដឹងយ៉ាង ណាមួយ ក្នុងកងរូប វេទនា ចិត្ត និងសភាវធម៌តាមវិធីនៃការចំរើន សតិប្បដ្ឋាន ទើបអាចសម្រេចធម៌ កន្លងផុតសេចក្តីសោយសោក និងការកន្ទក់កន្ទេញបានទាំងអស់ មិនមានសេសសល់ដោយព្រះ ធម្មឱសថ គឺសតិប្បដ្ឋាន ។

ដោយហេតុ ដែលសន្តតិមហាមាត្យ ស្រវឹងសុរារហូត ៧ ថ្ងៃ ចូលដល់ពេលជិតនឹងបានស្តាប់ព្រះធម៌ទេសនា សម្តែងថា សូម្បី គ្រហស្ថអ្នកមិនបានរក្សាសីលមកមុន នឹងបដិបត្តិធម៌ ក៏អាចសម្រេច ធម៌បាន មិនគួរគប្បីពោលថា គេជា បច្ឆិមភវិកៈ ( អ្នកកើតជាតិចុង ក្រោយ ) ទើបបន្ទុះធម៌បានដូច្នេះ ។ ព្រោះសូម្បីតែភិក្ខុដែលជា បច្ឆិមភវិកៈ ក៏មិនអាចសម្រេចធម៌បាន បើនៅមានសីលមិនបរិសុទ្ធ ព្រោះការមានសីលធ្វេសប្រហែសរមែងនឹងរាំងចំពោះការសម្រេច មគ្គផល ដូចដែលព្រះអង្គទ្រង់សម្តែង ការសង្រួម ការរក្សាសីល ដល់ព្រះឧត្តិយៈ ដែលជាបច្ឆិមភវិកៈថា

តស្មាតិហ ត្វំ ឧត្តិយ អាទិមេវ វិសោធេហិ កុសលេសុ

ធម្មសុ ។ កោ ចាទិ កុសលានំ ធម្មានំ ។ សីលញ្ច សុវិសុទ្ធំ ។ ទិដ្ឋិ ច ឧជុកា ។ យតោ ខោ តេ ឧត្តិយ សីលញ្ច សុវិសុទ្ធំ ភវិស្សតិ ទិដ្ឋិ ច ឧជុកា, តតោ ត្វំ ឧត្តិយ សីលំ និស្សាយ សីលេ បតិដ្ឋាយ ចត្តារោ សតិប្បដ្ឋានេ ភាវេយ្យាសិ[៤០] ។

"ម្នាលឧត្តិយៈ ព្រោះហេតុនោះ អ្នកគប្បីជម្រះខាងដើមនៃកុសលធម៌ទាំងឡាយ អ្វីដែលជាខាងដើម នៃកុសលធម៌ទាំងឡាយ សីលដែលបរិសុទ្ធល្អ និងការយល់ដ៏ត្រឹមត្រូវ គឺជាខាងដើមនៃកុសលធម៌ទាំងឡាយ ម្នាលឧត្តិយៈ កាលសីលរបស់អ្នកបរិសុទ្ធល្អ និងការយល់ឃើញត្រឹមត្រូវហើយ តអំពីនោះអ្នកអាស្រ័យសីលតាំងនៅក្នុងសីលហើយ គប្បីចំរើនសតិប្បដ្ឋាន ៤"។

សូម្បីក្នុងព្រះបាលី ទីងត្រាស់ដោយសាមញ្ញទូទៅថា សីលដោយមិនបានបញ្ជាក់ថា ជាសីលប្រភេទណា តែគួរគប្បីជ្រាបថា គឺជាបាតិមោក្ខសំវរសីលនោះ ដូចដែលបានអធិប្បាយទុកក្នុងឈានវិភង្គ[៤១] និងដីកាថ្មីរបស់ កង្ខាវិតរណី[៤២] ។

ព្រះអង្គទ្រង់ត្រាស់ទូន្មានឲ្យឧត្តិយៈ រក្សាសីលឲ្យបរិសុទ្ធមុន

ហើយ ទើបឲ្យចំរើនសតិប្បដ្ឋាន ៤ តែមិនបានបញ្ជាក់ថា ត្រូវរក្សាសីលត្រឹមណាទេ ក្រៅអំពីនេះទៅត្រាស់ថា ឲ្យចំរើនសតិប្បដ្ឋាន ៤ យ៉ាងណាទិមួយ ដោយហេតុនេះ អ្នកបដិបត្តិ ទើបគួរគប្បីចំរើនសតិប្បដ្ឋានទាំង ៤ យ៉ាងតាមសមគួរ ។

ព្រះឧត្តិយៈ បានបដិបត្តិតាមដែលព្រះពុទ្ធអង្គទ្រង់ណែនាំហើយ ទើបបានសម្រេចជាព្រះអរហន្តមិនយឺតយូរ រឿងនេះ ប្រាកដក្នុងព្រះបាលីដូចគ្នា លោកទើបចាត់ថា ជាបច្ចិមកវិកៈ តែព្រោះសីលមិនបរិសុទ្ធ ទើបសម្រេចធម៌មិនបាន ព្រះអង្គទើបត្រាស់ឲ្យលោកសម្រួមនឹងរក្សាសីលមកមុន សម្បទិយតមិច្ឆាទិដ្ឋិ ក៏ជាអន្តរាយចំពោះការសម្រេចធម៌ ព្រះពុទ្ធអង្គ ទើបត្រាស់សម្តែងឲ្យលោកធ្វើការយល់ត្រូវ រឿងសន្តតិមហាមាត្យ និងឧត្តិយៈនេះ សម្តែងថា ការមានសីលបែកធ្លាយ ជាអន្តរាយចំពោះបច្ចិមកវិកៈ សំដៅចំពោះតែភិក្ខុប៉ុណ្ណោះ មិនជាប់ទាក់ទងជាមួយគ្រហស្ថឡើយ ។

# រឿងបុរសស្ទូចត្រីបានសម្រេចធម៌

ថ្ងៃមួយ ព្រះមានព្រះភាគ ទ្រង់ឃើញឧបនិស្ស័យ ក្នុងការសម្រេចធម៌ របស់បុរសស្ទូចត្រី ឈ្មោះ អរិយៈ ទើបស្តេចទៅបិណ្ឌបាត្រជិតទ្វារក្រុងផ្លូវទិសខាងជើង ហើយស្តេចត្រឡប់មកព្រមជាមួយពួកភិក្ខុ ខណៈនោះ បុរសស្ទូចត្រីឃើញព្រះមានព្រះភាគព្រមជាមួយភិក្ខុ ទើបដាក់សន្ទូចចុះ ហើយឈរត្រង់ម្ខាង ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សួរថា អ្នកឈ្មោះអ្វី ?

បុរសនោះ ឆ្លើយថា ខ្ញុំព្រះអង្គឈ្មោះ អរិយៈ ( អ្នកប្រសើរ ) ព្រះមានព្រះភាគត្រាស់ទៀតថា អ្នកដែលនៅបៀតបៀនអ្នកដទៃមិនមែនឈ្មោះថា ជាអរិយៈទេ ព្រោះអរិយៈ មិនបៀតបៀនទណាៗទេ ហើយទ្រង់ត្រាស់ព្រះគាថាពន្លនេះថា

**ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ**

**អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ[៤៣] ។**

“បុគ្គលបៀតបៀនសត្វទាំងឡាយ ដោយហេតុណា មិនបានឈ្មោះថា ជាអរិយៈ ដោយហេតុនោះទេ បុគ្គលដែលតថាគតហៅ

ថា អរិយៈ ព្រោះមិនបៀតបៀនសត្វទាំងពួង ។

ក្នុងទីបំផុត នៃការសម្តែងព្រះធម៌ទេសនា បុរសស្ទូចត្រីនោះបានសម្រេចធម៌ ជាព្រះសោតាបន្ន ដូចដែលពោលទុកក្នុងព្រះអដ្ឋកថាធម្មបទ[៤៤] ។

## រឿងចោរម្នាក់

ក្នុងសម័យមួយ កាលព្រះសម្មាសម្ពុទ្ធទ្រង់កំពុងតែសម្តែងនូវធម៌ក្នុងវត្តជេតពនក្នុងក្រុងសាវត្ថី មានចោរពីរនាក់ ដែលនៅក្នុងចំណោមពុទ្ធបរិស័ទ ចោរម្នាក់តាំងចិត្តស្តាប់ធម៌ ហើយបានសម្រេចជាព្រះសោតាបន្ន ចោរម្នាក់ទៀត រវល់តែលួចហោប៉ៅអ្នកដទៃបានប្រាក់ត្រឹម ៥ មាសកៈ កាលត្រឡប់មកដល់ផ្ទះវិញ ចោរដែលបានប្រាក់ច្រើន ពោលចំអកសំឡាញ់ថា ឯងធ្វើខ្លួនជាមនុស្សល្អ ឯងនឹងមិនមានប្រាក់ទិញបាយស៊ី ចំណែកឯបុរសដែលជាព្រះសោតាបន្នបុគ្គល បែរជាមានគំនិតគិតថា សំឡាញ់មិនមានបញ្ញាទើបគិតថា ខ្លួនឯងជាមនុស្សឆ្លាត ក្រោយអំពីនោះ បានទៅក្រាបទូលរឿងនេះ ចំពោះព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់គាថានេះថា

យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី ស វេ "ពាលោ"តិ វុច្ចតិ[៤៥] ។

"អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថា ជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថា ជាពាល នោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថា ជាមនុស្សពាលដោយពិត" ។

បុគ្គលពាល ដែលដឹងខ្លួនឯងថា ពាល រមែងនឹងទទួលស្តាប់ពាក្យណែនាំរបស់អ្នកដទៃ អាចនឹងក្លាយជាបណ្ឌិតបាន តែបុគ្គលពាល ដែលអួតខ្លួនថាជាបណ្ឌិត ក៏រាប់ថាជាមនុស្សពាលដោយពិតប្រាកដ ព្រោះការគិតខុសថា ខ្លួនជាបណ្ឌិត ទើបមិនទទួលស្តាប់ពាក្យណែនាំរបស់បុគ្គលដទៃ បុគ្គលដូចដែលពោលមកនេះ រមែងមិនអាចជួបប្រទះសេចក្តីចំរើនខាងមុខ ថែមទាំងមិនអាចក្លាយជាបណ្ឌិតបាន ។

## ស្ដេចសក្យៈ ឈ្មោះថា សរណានិ

បានទទួលព្យាករណ៍ អំពីព្រះមានព្រះភាគ កាលគេជិតអស់ជីវិតហើយថា គេជាព្រះសោតាបន្ន អ្នករួចផុតអំពីអបាយភូមិ ៤ ក្នុងខណៈនោះ ស្ដេចសក្យៈទាំងឡាយ នាំគ្នាពោលតិះដៀលថា

*អច្ឆរិយំ វត ភោ ។ អព្ភុតំ វត ភោ ។ ឯត្ថ ទានិ កោ ន សោតាបន្នោ ភវិស្សតិ ។ យត្រ ហិ នាម សរណានិ សក្កោ កាលង្កតោ, សោ ភគវតា ព្យាកតោ "សោតាបន្នោ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ"តិ ។ សរណានិ សក្កោ សិក្ខាទុព្ពល្យមាបាទិ ។ មជ្ជបានំ អបាយីតិ[៤៦] ។*

"លោកអ្នកដ៏ចំរើនទាំងឡាយ គួរអស្ចារ្យណាស់ហ្ន៎ មិនដែលធ្លាប់មានមកក្នុងកាលមុន នរណាទៅក្នុងបណ្ដាជនពួកនេះនឹងមិនមែនជាព្រះសោតាបន្ន ក្នុងលោកនេះ ស្ដេចសក្យៈឈ្មោះ សរណានិស្លាប់ហើយ បានទទួលព្យាករណ៍ អំពីសំណាក់នៃព្រះមានព្រះភាគថា "គេជាព្រះសោតាបន្ន មិនធ្លាក់អបាយ ទៀងតែនឹងបានមគ្គជាន់ខ្ពស់មានការត្រាស់ដឹងនៅខាងមុខ" ស្ដេចសក្យៈឈ្មោះ សរណានិ

អ្នកគ្មានសទ្ធាក្នុងការប្រព្រឹត្តសិក្ខា ជាអ្នកផឹកសុរាហើយ" ។

សរណានិ សក្កោ សិក្ខាយ អបរិបូរការីតិ[៤៧] ។

"ស្តេចសក្យៈឈ្មោះ សរណានិ ជាអ្នកមិនបានប្រព្រឹត្តសិក្ខាឲ្យបរិបូណ៌" ។

រឿងដែលស្តេចសក្យៈទាំងឡាយពោលតិះដៀលនូវព្រះមានព្រះភាគនេះ ស្តេចមហានាមជាអ្នកក្រាបទូលឲ្យទ្រង់ជ្រាប ក្នុងខណៈនោះព្រះអង្គទ្រង់អធិប្បាយរឿងនេះ ដោយចែកបុគ្គលទុកច្រើនប្រភេទដែលប្រាកដក្នុងគម្ពីរសំយុត្តនិកាយទុតិយសរណានិសក្កសូត្រ[៤៨] ។

ក្រៅអំពីនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឧបមាថា គ្រាប់ពូជដែលស្អុយហើយ នឹងបានទទួលការដុះចេញក្នុងស្រែដែលមានថ្មនិងដន្តត់ឈើច្រើន រមែងមិនចំរើនលូតលាស់ទៅជាដើមឈើយ៉ាងណា ការបដិបត្តិធម៌ ដោយមិនត្រូវវិធី ក៏មិនអាចបញ្ចូនផលឲ្យសម្រេចមគ្គផល និព្វានបាន ដូច្នោះ តែចំពោះពូជដែលល្អមិនស្អុយបានទទួលការបណ្តុះទុកក្នុងស្រែដែលល្អ រមែងនឹងចំរើនលូតលាស់បានដោយឆាប់រហ័សយ៉ាងណា ការបដិបត្តិធម៌ ដែលត្រឹមត្រូវ

តាមវិធី កំញ៉ាំងផលឲ្យសម្រេចធម៌បានដោយឆាប់រហ័ស ដូច្នោះ ស្ដេចសក្យៈឈ្មោះ សរណានិ បានបដិបត្តិធម៌យ៉ាងត្រឹមត្រូវ ហេតុអ្វីទើងមិនអាចសម្រេចធម៌បាន ព្រះសម្មាសម្ពុទ្ធទើបមានព្រះពុទ្ធតម្រាស់ថា

**កិមង្គំ បន សរណានិ សក្កំ ។ សរណានិ មហានាម សក្កោ មរណកាលេ សិក្ខាយ បរិបូរការីតិ[៤៩] ។**

"ទើងចាំបាច់ពោលទៅថ្វី ដល់ស្ដេចសក្យសរណានិ ម្នាលមហានាម ស្ដេចសក្យសរណានិ ជាអ្នកប្រព្រឹត្តសិក្ខាបរិបូណ៌ក្នុងពេលជិតស្លាប់" ។ ទើងឃើញបានថា ស្ដេចសក្យសរណានិ មិនបានរក្សាសីលមកពីមុន តែមករក្សាក្នុងខណៈជិតអស់ជីវិត ហើយសម្រេចធម៌ជាព្រះសោតាបន្ន លោកទើបមានសីលសិក្ខាបរិសុទ្ធក្នុងខណៈនោះ ដូចគ្នាជាមួយទើងបុរសស្ដូចត្រីដែលឈ្មោះ អរិយៈនិងចោរម្នាក់ដែលពោលមកហើយ ក៏មិនបានមានសីលបរិសុទ្ធមុនពេលដែលបានស្ដាប់ធម៌ ហើយក៏បានសម្រេចជាព្រះសោតាបន្ន ពួកគេមិនមែនបច្ចិមភវិកៈ ព្រោះនៅជាសោតាបន្ន ដោយហេតុនេះ

ទើបមិនគួរពោលថា បច្ចិមភវិកៈប៉ុណ្ណោះ ជាអ្នកសម្រេចធម៌បាន ដោយប្រាសចាកសីល អ្នកខ្លះពោលថា "បុគ្គលទាំងនោះ ជាឧគ្ឃដិតញ្ញូ ឬ វិបចិតញ្ញូ ទើបសម្រេចធម៌បាន ដោយមិនត្រូវរក្សាសីលមកពីមុន តែអ្នកដែលជានេយ្យៈ ត្រូវរក្សាសីលមកមុនជាយូរ" តែការយល់ឃើញនោះ ក៏ត្រឹមតែជាអត្តនោមតិ មិនធ្លាប់ឃើញក្នុងព្រះបាលី អដ្ឋកថា និងដីកា មានសេចក្តីជាប់ទាក់ទងជាមួយនេយ្យបុគ្គល ក្នុងព្រះបាលីថា

*កតមោ ច បុគ្គលោ នេយ្យោ ។ យស្ស បុគ្គលស្ស ឧទ្ទេសតោ បរិបុច្ឆតោ យោនិសោមនសិករោតោ កល្យាណមិត្តេ សេវតោ ភជតោ បយិរុបាសតោ ឯវំ អនុបុព្វេន ធម្មាភិសមយោ ហោតិ ។ អយំ វុច្ចតិ បុគ្គលោ នេយ្យោ*[៥០] ។

"បុគ្គលណា ឈ្មោះថា នេយ្យៈ បុគ្គលណា រៀនទូវកម្មដ្ឋានសាកសួរ ធ្វើទុកក្នុងចិត្តដោយបញ្ញា សេពគប់កល្យាណមិត្ត ការត្រាស់ដឹងធម៌ រមែងមានដល់គេ តាមលំដាប់យ៉ាងនេះ បុគ្គលនេះឈ្មោះថា នេយ្យៈ" ។

ក្នុងព្រះបាលីនេះ បានត្រាស់ដល់ខាងដើម នៃការបដិបត្តិធម៌ថា គួររៀនកម្មដ្ឋាន សាកសួរសេចក្ដីសង្ស័យ ធ្វើទុកក្នុងចិត្តដោយបញ្ញា ទទួលដឹងសភាវធម៌ តាមសេចក្ដីពិត ដោយមិនមានសម្មតិបញ្ញត្តិ និងតួខ្លួនព្រមទាំងគួរគប់រកវិបស្សនាចារ្យ អ្នកអាចដោះសេចក្ដីសង្ស័យ នឹងប្រាប់ឥន្ទ្រិយ៍ឲ្យចាស់ក្លាឡើង ។ ក្នុងព្រះបាលីនេះ មិនបានពោលដល់ការធ្វើសីលឲ្យបរិសុទ្ធ មុននឹងចំរើនកម្មដ្ឋានម្យ៉ាងទៀត ក្នុងអដ្ឋកថារបស់នេត្តិបករណ៍ពោលថា

**ឧគ្ឃដិតញ្ញុស្ស សមថបុព្វង្គមា វិបស្សនា សប្បាយា ។ នេយ្យស្ស វិបស្សនាបុព្វង្គមោ សមថោ ។ វិបច្ចិតញ្ញុស្ស សមថវិបស្សនា យុគនទ្ធា ។ ឧគ្ឃដិតញ្ញុស្ស អធិបញ្ញាសិក្ខា ។ វិបច្ចិតញ្ញុស្ស អធិចិត្តសិក្ខា ច អធិបញ្ញាសិក្ខា ច ។ នេយ្យស្ស អធិសីលសិក្ខា ច អធិចិត្តសិក្ខា ច អធិបញ្ញាសិក្ខា ច[៤១] ។**

"វិបស្សនាដែលមានសមថៈ ជាប្រធាន សមគួរដល់ឧគ្ឃដិតញ្ញូ សមថៈ ដែលមានវិបស្សនាជាប្រធាន សមគួរដល់នេយ្យៈ សមថៈ និងវិបស្សនា ដែលប្រកបរួមគ្នាសមគួរដល់វិបច្ចិតញ្ញូ ។

អធិបញ្ញាសិក្ខា សមគួរដល់ឧគ្ឃដិតញ្ញូ អធិចិត្តសិក្ខា និង

អធិបញ្ញាសិក្ខា សមគួរដល់វិបច្ចិតញ្ញូ អធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខា សមគួរដល់នេយ្យៈ" ។

[អ្នកដែលអាចសម្រេចធម៌ ក្នុងព្រះសាសនានេះ ហៅថា វេនេយ្យបុគ្គលមាន ៣ ជំពូកគឺ

១. ឧគ្ឃដិតញ្ញូ អ្នកសម្រេចធម៌ឆាប់រហ័ស ដោយគ្រាន់តែស្ដាប់ឧទ្ទេសគឺមាតិកា ។

២. វិបច្ចិតញ្ញូ អ្នកសម្រេចធម៌យូរ ដោយការស្ដាប់និទ្ទេស គឺការអធិប្បាយសេចក្ដីដោយសង្ខេប ។

៣. នេយ្យៈ អ្នកអាចសម្រេចធម៌បាន ដោយការស្ដាប់បដិនិទ្ទេស គឺអធិប្បាយដោយពិស្ដារ និងខិតខំព្យាយាមបដិបត្តិធម៌ ដោយយោនិសោមនសិការ និងសេពគប់នូវកល្យាណមិត្ត] ។

បន្ទាប់ពីនេះ លោកសម្ដែងធម៌ ដែលសមគួរដល់បុគ្គលទាំង ៣ ជំពូក តែមិនបានបំណងនឹងសម្ដែងដល់បុគ្គលដូចពោលត្រូវប្រព្រឹត្តសិក្ខានោះៗ ឲ្យបរិបូណ៌ ពាក្យថា "អធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខា សំដៅដល់នេយ្យៈ" ទើបមិនបានសំដៅថា នេយ្យៈ ត្រូវរក្សាសីលឲ្យបរិសុទ្ធ នឹងសម្រេចនូវឈាន

មុនសិន ទើបអាចនឹងចម្រើនវិបស្សនាបាន មិនដូច្នោះហើយ អ្នកដែលជា វិបច្ចិតញ្ញូ និងនេយ្យៈទាំងអស់ ក៏ត្រូវសម្រេចឈាន ដែលជាអធិចិត្តសិក្ខាមុន ៗ តាមពិតទៅ មិនមែនជាដូច្នោះ ក្រៅអំពីនេះ មិនគួរពោលថា ភិក្ខុដែលជាឧគ្ឃដិតញ្ញូ និងវិបច្ចិតញ្ញូ សូម្បីត្រូវអាបត្តិ ក៏មិនជាអាណាវីតិក្កម្មន្តរាយ ដោយអាងថាក្នុងទីនេះមិនបានពោលថា សីលសិក្ខា សំដៅដល់បុគ្គលពួកនោះ ពីព្រោះអាបត្តិទាំងអស់ដែលត្រូវដោយចេតនា ជាអាណាវីតិក្កម្មន្តរាយ ដូច្នោះ លោកពោលថា សិក្ខា ៣ សំដៅដល់ នេយ្យបុគ្គល ព្រោះសីល និងសមថភាវនារបស់គេ រមែងនឹងនាំទ្រដល់វិបស្សនា និងមគ្គបញ្ញាជាពិសេស ។

អ្នកដែលជាឧគ្ឃដិតញ្ញូនោះ អាចញ៉ាំងវិបស្សនា និងមគ្គបញ្ញា ឲ្យកើតឡើងទាន់ពេល កាលស្តាប់ធម៌ដោយសង្ខេប គេទើបមិនមានឱកាសចំរើនសមថៈឈាន ទាំងមិនចាំបាច់ត្រូវចូលឈានដើម្បីឲ្យជាផ្លូវនាំទៅកាន់វិបស្សនា។ ម្យ៉ាងទៀត ឧគ្ឃដិតញ្ញូ និងវិបច្ចិតញ្ញូ ក៏មិនចាំបាច់ត្រូវពិចារណាសីលរបស់ខ្លួន ដើម្បីឲ្យកើតបាមោជ្ជៈ

ព្រោះពួកគេសម្រេចធម៌ ក្នុងខណៈស្ដាប់ព្រះធម៌ទេសនា បាន ដោយការកំណត់ដឹងបីតិបាមោជ្ជៈជាដើម ដែលកើតអំពីការជ្រះថ្លា ក្នុងអ្នកសម្ដែងធម៌ ឬធម៌ដែលកំពុងស្ដាប់ ដូច្នោះ លោកទើបមិន ពោលថា សីល និងសមថភាវនាជំនួយដល់ឧគ្ឃដិតញ្ញូ សីលជា ឧបការៈដល់វិបច្ចិតញ្ញូ ។

នេយ្យបុគ្គលជាអ្នកដែលបដិបត្តិធម៌ អស់កាលយូរ ខណៈ ខ្លះ កាលពិចារណាសីលរបស់ខ្លួនហើយដឹងច្បាស់ថា មិនបរិសុទ្ធ ក៏នឹងកើតសេចក្ដីក្ដៅក្រហាយចិត្ត សូម្បីថា ក្នុងខណៈបដិបត្តិធម៌ និងរក្សាសីល ក៏កើតការក្ដៅក្រហាយចិត្តដល់រឿងអតីតកាល បាន និងបើកែខ្មែមិនបាន ក៏នឹងជាឧបសគ្គចំពោះការចំរើនវិបស្សនា ចំណែកអ្នកដែលមានសីលបរិសុទ្ធអស់កាលយូរ ឬ តាំងអំពីចាប់ ផ្ដើមចូលកម្មដ្ឋានជាដើមមក ដឹងថា សីលរបស់ខ្លួនមិនសៅហ្មង ក៏កើតបីតិបាមោជ្ជៈ សេចក្ដីស្ងប់ ( បស្សទ្ធិ ) សេចក្ដីសុខចិត្ត និង សមាធិ ព្រមទាំងវិបស្សនាបញ្ញា តមកសីលដែលបរិសុទ្ធអស់ កាលយូរ ឬតាំងអំពីចាប់ផ្ដើមចំរើនកម្មដ្ឋាន ទើបឧបការៈ ដល់ នេយ្យបុគ្គលជាពិសេស ។

## ការចំរើនសមថៈជាបាទរបស់វិបស្សនា

ក្នុងគម្ពីរអដ្ឋកថា ពោលដល់ការចំរើនសមថៈ ជាបាទរបស់វិបស្សនាថា

យស្ស ហិ សមាធិបិ តរុណោ វិបស្សនាបិ ។ តស្ស វិបស្សនំ បដ្ឋបេត្វា អតិចិរំ និសិន្នស្ស កាយោ កិលមតិ ។ អន្តោ អគ្គិ វិយ ឧដ្ឋហតិ ។ កច្ឆេហិ សេទា មុច្ចន្តិ ។ មត្ថកតោ ឧសុមវដ្ដិ វិយ ឧដ្ឋហតិ ។ ចិត្តំ ហញ្ញតិ វិហញ្ញតិ វិប្ផន្ទតិ ។ សោ បុន សមាបត្តឹ សមាបជ្ជិត្វា តំ បរិទមេត្វា មុទុកំ កត្វា សមស្សាសេត្វា បុន វិបស្សនំ បដ្ឋបេតិ ។ តស្ស បុន អតិចិរំ និសិន្នស្ស តថេវ ហោតិ ។ សោ បុន សមាបត្តឹ សមាបជ្ជិត្វា តថេវ ករោតិ ។ វិបស្សនាយ ហិ ពហូបការា សមាបត្តិ[៤២] ។

“ពិតហើយ បុគ្គលណាមានសមាធិ និងវិបស្សនាមិនចាស់ក្លា កាលលោកអង្គុយចំរើនវិបស្សនាយូរ រាងកាយរមែងលំបាក ដូចភ្លើងកំពុងដុតខាងក្នុង ញើសហូរចេញអំពីរន្ធក្លៀក ដូចមានផ្សែងចេញអំពីក្បាល ចិត្តរមែងលំបាក កាលចូលសមាបត្តិនោះទៀត គ្រប់គ្រង

ការលំបាកកាយ និងចិត្តនោះហើយ នឹងធ្វើឲ្យងាយស្រួលហើយ ចំរើនវិបស្សនាទៀត កាលលោកអង្គុយយូរទៀត សភាវៈយ៉ាងនោះ រមែងកើតឡើង លោករមែងចូលសមាបត្តិទៀតធ្វើដូចមុន សេចក្ដីពិតការចូលសមាបត្តិមានឧបការៈច្រើនដល់វិបស្សនា" ។

សេចក្ដីខាងដើមនេះសម្ដែងថា នេយ្យបុគ្គលអ្នកសម្រេចសមថឈានមុនហើយចម្រើនវិបស្សនា អាចចូលឈានសមាបត្តិក្នុងខណៈដែលកើតការលំបាកកាយនិងចិត្ត ហើយទើបចម្រើននូវវិបស្សនាតទៅ ការបដិបត្តិដូច្នេះ នឹងធ្វើឲ្យសមាធិ និងបញ្ញា ក្នុងវិបស្សនាចាស់ក្លាឡើងតាមលំដាប់ កាលសមាធិ និងបញ្ញាចាស់ក្លា ការលំបាកកាយ និងចិត្ត រមែងមិនកើតឡើង អាចអង្គុយកំណត់បានបន្តបន្ទាប់គ្នារហូតយប់និងថ្ងៃ សមថឈានទើបមានឧបការៈដល់នេយ្យបុគ្គលដោយពិសេសយ៉ាងនេះ ។

ក្នុងបច្ចុប្បន្ន ព្រះយោគីបុគ្គល អ្នកនឹងចម្រើនវិបស្សនាមុន អាចជួបប្រទះជាមួយការលំបាកកាយនិងចិត្ត តែប្រសិនបើកំណត់ដឹងសភាវធម៌ជាប់បន្តគ្នា ធ្វើឲ្យសមាធិ និងបញ្ញាចាស់ក្លាហើយ

ក៏អាចផុតអំពីសេចក្ដីលំបាកនោះទៅបាន ។

ដោយហេតុដូចដែលពោលមកនេះ សីលនិងសមថភាវនាជាធម៌ដែលមានឧបការៈដល់នេយ្យបុគ្គលជាពិសេស លោកទើបពោលទុកក្នុងគម្ពីរ នេត្តិអដ្ឋកថា ខាងដើមថា សិក្ខា ៣ ឧបការៈដល់នេយ្យបុគ្គល តែលោកមិនបានពោលទុកដោយត្រង់ និងសម្ដែងថា គេត្រូវតែចម្រើននូវសិក្ខា ៣ អស់កាលយូរសិន ទើបសម្រេចធម៌បានទេ ។

ស្ដេចសក្យសរណានិ ចាត់ថាជានេយ្យបុគ្គល ដែលសម្រេចធម៌ជាព្រះសោតាបន្ន ដោយការចម្រើនវិបស្សនា ក្នុងខណៈជិតអស់ជីវិត មិនរាប់ថាជា ឧគ្ឃដិតញ្ញូ វិបច្ចិតញ្ញូ ព្រោះមិនប្រាកដក្នុងព្រះបាលី ឬ អដ្ឋកថា ថាបានសម្រេចធម៌ដូច្នេះ នេយ្យបុគ្គលទើបមិនចាំបាច់ត្រូវរក្សាសីលឲ្យបរិសុទ្ធអស់កាលយូរសិន ទើបនឹងសម្រេចធម៌បាន ។

# រឿងពេជ្ឈឃាតសម្លាប់ចោរ

ក្នុងគម្ពីរអដ្ឋកថាធម្មបទ មានរឿងរបស់មនុស្សសម្លាប់ចោរម្នាក់ អ្នកមិនបានរក្សាសីលមកពីមុន ហើយសម្រេចវិបស្សនាជាន់ខ្ពស់ ក្នុងពេលជិតអស់ជីវិត ដោយពោលទុកដូចតទៅនេះ ក្នុងសម័យពុទ្ធកាល មានមនុស្សសម្លាប់ចោរពុកមាត់ក្រហម ឈ្មោះ តម្ពទាឋិកៈ នៅក្នុងក្រុងរាជគ្រឹះ បានទទួលការតែងតាំងអំពីព្រះរាជាឲ្យសម្លាប់ចោររហូត ៥៥ ឆ្នាំ កាលគ្រប់កំណត់ហើយ ក៏រួចផុតអំពីនាទីនេះ ក្នុងថ្ងៃដែលរួចផុតអំពីតំណែង គេត្រូវការទទួលទានអាហារ ដែលមិនធ្លាប់ទទួលមកពីមុន ទើបដាក់បាយាសលាយទឹកដោះ គេប្រើប្រាស់ចូលគ្នាថ្មីៗ ស្លៀកសំពត់ថ្មីហើយអង្គុយរងចាំបរិភោគនូវបាយបាយាស ។

ខណៈនោះ ព្រះសារីបុត្របាននិមន្តមកប្រោសដោយឈរទទួលបិណ្ឌបាត្រមុខទ្វារផ្ទះ គេឃើញហើយកើតបីតិត្រេកអរ និមន្តព្រះថេរៈចូលមកអង្គុយក្នុងផ្ទះ និងអង្គាសបាយាសនោះ ព្រះថេរៈឆាន់ហើយបានសម្ដែងធម៌ តែគេរវល់គិតដល់រឿងដែលសម្លាប់មនុស្សអស់

៥៥ ឆ្នាំកន្លងមកហើយ មិនអាចស្ងប់ចិត្តទទួលស្ដាប់ធម៌ទេសនាបាន ព្រះថេរៈទើបសួរថា លោកធ្វើបាបតាមសេចក្ដីត្រូវការរបស់ខ្លួន ឬ មានអ្នកដទៃប្រើឲ្យធ្វើ? គេប្រាប់ថា ព្រះរាជាបញ្ជាឲ្យធ្វើ ព្រះថេរៈត្រឡប់សួរថា កាលដែលត្រូវគេប្រើដូច្នេះ អ្នកនឹងមានបាបឬ ? មួយរំពេចនោះ គេទើបគិតថា ខ្លួនមិនមានបាប តែអ្នកប្រើឲ្យធ្វើទើបមានបាប ធ្វើឲ្យគេអាចស្ងប់ចិត្តទទួលស្ដាប់ព្រះធម៌ទេសនា នឹងបានសម្រេចសង្ខារុបេក្ខាញាណ ដែលជាញាណខ្ពស់បំផុតនៃបុថុជ្ជន ដូចសេចក្ដីក្នុងអដ្ឋកថាធម្មបទថា

សោ ថេរ អនុមោទនំ កថេន្តេ ឯកគ្គចិត្តោ
ហុត្វា ធម្មំ សុណន្តោ សោតាបត្តិមគ្គស្ស
ឱរតោ អនុលោមិកំ ខន្តិ និព្វត្តេសិ[៥៣] ។

“កាលព្រះថេរៈ កំពុងអនុមោទនា គេមានចិត្តតាំងមាំស្ដាប់ធម៌បានសម្រេចវិបស្សនាញាណដែលស្របតាមមគ្គញាណ ក្នុងជាន់ទាបចាប់ពីសោតាបត្តិមគ្គ” ។

( ក្នុងកន្លែងខ្លះ វិបស្សនាញាណទូទៅហៅថា អនុលោមិកខន្តិ

តែក្នុងទីនេះ សំដៅដល់ សង្ខារុបេក្ខាញាណ ដែលនៅជិតមគ្គញាណ តាមឋានៈ) ។

កាលបានស្ដាប់ធម៌ហើយគេបានជូនដំណើរព្រះថេរៈ វាងផ្លូវដើរត្រឡប់វិញ ត្រូវនាងយក្ខិនីដែលចងពៀរ ក្លែងភេទជាមេគោជល់ស្លាប់ ទើបទៅកើតក្នុងសួគ៌ជាន់តុសិត ភិក្ខុទាំងឡាយជ្រាបរឿងនោះហើយ សន្ទនាគ្នាក្នុងធម្មសភាថា គេធ្វើបាបរហូត ៥៥ឆ្នាំ ថ្ងៃនេះ ផុតអំពីនាទី បានថ្វាយអាហារចំពោះព្រះសារីបុត្រ ហើយអស់ជីវិត ទៅកើតក្នុងភពណា ព្រះមានព្រះភាគទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ព្រះគាថាថា

សុភាសិតំ សុណិត្វាន    នគរេ ចោរឃាតកោ

អនុលោមខន្តិំ លទ្ធាន    មោទតិ តិទិវង្គតោ[៥៤] ។

"អ្នកសម្លាប់ចោរក្នុងនគរ បានស្ដាប់វាចាដែលពោលទុកល្អហើយ សម្រេចញាណដែលស្របតាមមគ្គញាណ ហើយទៅកាន់សួគ៌ រមែងរីករាយ" ។

ភិក្ខុទាំងឡាយក្រាបទូលថា ក្នុងកាលកន្លងមកគេបានធ្វើបាប

ច្រើនណាស់ តែអនុមោទនាកថា ត្រឹមបន្តិចបន្តួចក៏បញ្ជូនផលឲ្យសម្រេចវិបស្សនាជាន់ខ្ពស់បានយ៉ាងណា ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកកុំពិចារណាធម៌របស់តថាគតថា តិច ឬច្រើន ដោយហោចទៅសូម្បីវាចាត្រឹមតែមួយមាត់ ដែលពោលទុកល្អហើយ ក៏មានផលច្រើនបាន ហើយត្រាស់ព្រះគាថានេះថា

សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា

ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ[៥៥] ។

"បើវាចា សូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះសូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង" ។

អ្នកសម្លាប់ចោរតាមរឿងនេះ មិនអាចសម្រេចមគ្គផលបាន ទើបមិនមែនជានេយ្យបុគ្គល នឹងឃ្លាតឆ្ងាយអំពី ឧគ្ឃដិតញ្ញូ និងវិបច្ចិតញ្ញូ តែសូម្បី គេនឹងមិនបានរក្សាសីលមករហូត ៥៥ ឆ្នាំ ក៏នៅបន្ទុះសង្ខារុបេក្ខាញាណក្នុងពេលជិតអស់ជីវិតបាន តែចំពោះការ

ធុះធ្លាយសីលរបស់គ្រហស្ថ មុននឹងបដិបត្តិធម៌ ទើបមិនបានរាំង ផលការបដិបត្តិយ៉ាងណានិមួយ ។

## ហេតុនៃការមិនបានសម្រេចធម៌ក្នុងបច្ចុប្បន្ន

ការមិនបានសម្រេចធម៌ក្នុងបច្ចុប្បន្នជាតិមាន ២ យ៉ាង[៥៦] គឺ

១. ការគប់រកមិត្តអាក្រក់ ( បាបមិត្តតា )

២. ការមិនបានស្តាប់ធម៌និងចំរើនភាវនា ( កិរិយបរិហានិ )

ព្រះបាទអជាតសត្តុសេពគប់មិត្តអាក្រក់ គឺភិក្ខុទេវទត្ត បានធ្វើនូវ បិតុឃាត ព្រះអង្គទើបមិនអាចបានសម្រេចមគ្គផល ព្រោះកម្មដែល សម្លាប់បិតាជាកម្មន្តរាយិកកម្ម និងសូម្បីវិបស្សនាញាណ ដែលមាន ឧទ្ទយព្វយញ្ញាណជាដើម ក៏មិនអាចកើតដល់បុគ្គលនោះដូច្នោះ ។

[ ឧទ្ទយព្វយញ្ញាណ គឺ ញាណដែលដឹងនូវការកើតឡើង និង រលត់ទៅជាវិបស្សនាញាណលំដាប់ទី ៤ ក្នុងវិបស្សនាញាណ ១៦ ] ។

ក្រៅអំពីនេះ អ្នកដែលមានឧបនិស្ស័យបច្ច័យ ល្មមនឹងសម្រេច ធម៌បាន តែបើមិនបានបដិបត្តិធម៌ ក៏មិនអាចសម្រេចធម៌បានដូចគ្នា

ក្នុងមជ្ឈិមនិកាយកនុរសូត្រ[៣] មានរឿងរបស់នាយបេស្ស: ដែលមិនបានស្ដាប់ធម៌រហូតចប់ តែក្រោកត្រឡប់ទៅមុន ទើបមិនអាចបានសម្រេចធម៌ដោយការស្ដាប់ និងកំណត់ដឹងសភាវធម៌ ក្នុងខណៈនោះ សូម្បីក្នុងសម័យបច្ចុប្បន្ន អ្នកដែលអាចនឹងសម្រេចមគ្គផលបាន តែបើមិនបានបដិបត្តិធម៌ទេ ឬមានពេលបដិបត្តិធម៌តិច ក៏ថយចុះអំពីមគ្គផល ដោយការមិនបដិបត្តិធម៌នោះឯង ។

ក្នុងសម័យមួយ ព្រះសារីបុត្រ សម្ដែងនូវសមថភាវនាដល់ព្រាហ្មណ៍ធនញ្ជានី អ្នកកំពុងសោយសោកដោយមិនបានសម្ដែងវិបស្សនា ព្រាហ្មណ៍ចំរើនសមថភាវនា ហើយអស់ជីវិតទៅកើតក្នុងព្រហ្មលោក បើព្រះសារីបុត្រសម្ដែងវិបស្សនាភាវនា គេក៏អាចសម្រេចមគ្គផលបានក្នុងជាតិនោះ ការមិនសម្រេចធម៌មានហេតុមកអំពីការមិនបានស្ដាប់ធម៌ ដោយហេតុនេះ ព្រះអង្គទើបរំពឹងដល់ព្រះសារីបុត្រ ហើយប្រាប់ឲ្យទៅតាមសម្ដែងធម៌ក្នុងព្រហ្មលោក ព្រះថេរៈតាមទៅសម្ដែងអរិយសច្ច: ៤ រហូតដល់បានសម្រេចធម៌ សូម្បីបុគ្គលចំនួនច្រើនក្នុងបច្ចុប្បន្ន ក៏មិនអាចសម្រេចធម៌បាន

ព្រោះមិនបានស្ដាប់វិបស្សនាភាវនា តួយ៉ាងដូចជាព្រាហ្មណ៍នោះ ។

ដោយប្រការដូចដែលពោលមកនេះ ភាវៈជាបច្ឆិមកវិកៈ ឧគ្ឃដិតញ្ញូ ឬវិបច្ចិតញ្ញូ ទើបមិនមែនជាសារៈសំខាន់ កាលបើមានសីលបែកធ្លាយហាមការសម្រេចមគ្គផលសម្រាប់ភិក្ខុ តែមិនហាមសម្រាប់គ្រហស្ថគ្រប់យ៉ាង សូម្បីគ្រហស្ថដែលមានសីលមិនបរិសុទ្ធ ក៏មិនអាចកើតវិបស្សនាញាណ និង មគ្គញាណបានទេ ព្រោះសីលវិសុទ្ធិជាមូលដ្ឋាននៃវិសុទ្ធិដទៃៗ ចំណែកសីលវិសុទ្ធិរបស់សន្តតិមហាមាត្យជាដើម កើតអំពីការត្រិះរិះថានឹងមិនធ្វើខុសសីលយ៉ាងនោះទៀត ក្នុងខណៈមុននឹងស្ដាប់ធម៌ ឬកំពុងស្ដាប់ធម៌ ។

ន័យម្យ៉ាងទៀត សីលកើតអំពីភាវនាចិត្តដែលកំណត់ដឹងទាន់សភាវធម៌បច្ចុប្បន្ន តាមគោលនៃវិបស្សនា ដូចសាធកៈក្នុងគម្ពីរបដិសម្ភិទាមគ្គថា

ញាណេន អវិជ្ជាយ អនិច្ចានុបស្សនាយ និច្ចសញ្ញាយ បហានំ សីលំ, វេរមណិ សីលំ, ចេតនា សីលំ, សំវរោ សីលំ, អវីតិក្កមោ សីលំ ។ ឯវរូបានិ សីលានិ ចិត្តស្ស អវិប្បដិសារាយ

សំវត្តតិ ។ បាមោជ្ជាយ បីតិយា បស្សទ្ធិយា សោមនស្សាយ សំវត្តតិ ។ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យោ តត្ថ សំវរដ្ឋោ, អយំ អធិសីលសិក្ខា ។ យោ តត្ថ អវិក្ខេបដ្ឋោ, អយំ អធិចិត្តសិក្ខា ។ យោ តត្ថ ទស្សនដ្ឋោ, អយំ អធិបញ្ញាសិក្ខា[៤៨] ។

"ការលះអវិជ្ជាដោយញាណ [ ដែលជានាមរូបបរិច្ឆេទញាណ និងបច្ចយបរិគ្គហញាណ] និងលះនិច្ចសញ្ញា ( ការសំគាល់ថាទៀង ) ដោយញាណដែលឃើញច្បាស់ថា មិនទៀង [ មានសម្មសនញាណជាដើម] ឈ្មោះថា សីល ការវៀរចាកឈ្មោះថា សីល ចេតនាឈ្មោះថា សីល ការសង្រួមឈ្មោះថា សីល ការមិនកន្លងល្មើសឈ្មោះថា សីល សីលទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីការមិនក្តៅក្រហាយនៃចិត្ត ដើម្បីបាមោជ្ជៈ បីតិ សេចក្តីស្ងប់ សេចក្តីសោមនស្ស សេចក្តីនឿយណាយ កំណាត់ដឹងដោយពិតប្រាកដ ការរលត់ សេចក្តីស្ងប់រម្ងាប់ ការដឹងដ៏ក្រៃលែង ការប្រេចក្សច្បាស់ និងព្រះនិព្វាន សភាវៈដែលសង្រួមនេះ ក្នុងវិបស្សនាចិត្តឈ្មោះថា អធិសីលសិក្ខា, សភាវៈដែលមិនជំទាស់ក្នុងវិបស្សនាចិត្តនោះ

ឈ្មោះថា អធិចិត្តសិក្ខា, សភាវៈដែលប្រចក្សច្បាស់ក្នុងវិបស្សនាចិត្ត នោះឈ្មោះថា អធិបញ្ញាសិក្ខា" ។

## ការលះកិលេសជាសីល

អ្នកបដិបត្តិរមែងលះបង់អវិជ្ជាដែលយល់ខុសថា ជាបុគ្គល ជាយើង ជារបស់យើង ( បបញ្ចធម៌ ) ដោយវិបស្សនាញាណ ដែលដឹងច្បាស់ថា មានត្រឹមតែរូបនាមប៉ុណ្ណោះ មិនមានសម្មតិបញ្ញត្តិណាៗ និងគប្បីលះបង់អវិជ្ជាដែលយល់ខុសថា ពួកសត្វកើតឡើងឯងៗ ដោយមិនមានកម្មជាបច្ច័យ ឬកើតអំពីការនិម្មិតរបស់ព្រហ្ម, ព្រះជាម្ចាស់ដោយវិបស្សនាញាណ ដែលដឹងច្បាស់ថា មានត្រឹមតែហេតុនិងផលកើតឡើងជាប់បន្តគ្នា ក្រៅពីនេះ ក៏នៅត្រូវលះកិលេសដែលប្រកាន់មាំថា មានតួខ្លួនទៀតក្នុងរូបដែលកំពុងកំណត់ដឹងដោយវិបស្សនាញាណ ដែលប្រចក្សច្បាស់ថា មិនទៀងដូច្នេះជាដើម ។

ការលះកិលេសសំដៅដល់ការរំលត់កិលេស ដែលកើតឡើងដោយការឃើញយ៉ាងត្រឹមត្រូវ ដូចជាកាពង់ងឹតអន្តរធានទៅ កាល

ដែលជួបជាមួយនឹងពន្លឺ និងសំដៅដល់ការមិនឲ្យកិលេសកើតឡើងទៀតក្នុងឱកាសតទៅកាលកិលេស មិនមានឱកាសកើតឡើង ដូច្នេះ កុសលចិត្តដែលប្រកបដោយវិបស្សនាញាណ រមែងនឹងកើតឡើងយ៉ាងបន្តបន្ទាប់ ។

នឹងឃើញបានថា ការកើតឡើងរបស់អកុសលចិត្ត ក្នុងចំណែកជាខាងក្រោយមានអណ្ដូងកើតអំពីការលះកិលេសដោយវិបស្សនា ទាំងកុសលចិត្ត ដែលកើតអំពីការលះកិលេស ក៏នឹងតាំងនៅមាំបានយូរ ដោយមិនប្រែប្រួលទៅជាអកុសល ដូច្នេះ ការលះកិលេសទើបជាទីតាំងរបស់កុសលចិត្តតៗមកនិងធ្វើឲ្យកុសលចិត្ត ដូចដែលពោលមកនេះតាំងមាំ ព្រះសារីបុត្រទើបពោលថា **បហានំ សីលំ** ( ការលះឈ្មោះថាសីល ) ព្រោះជាទីតាំងរបស់កុសលធម៌ នឹងធ្វើឲ្យកុសលធម៌តាំងនៅមាំ សូម្បីពាក្យថា **វេរមណិ សីលំ** ( ការវៀរចាកឈ្មោះថា សីល ) ក៏មានន័យដូចគ្នា ។

[ គម្ពីរវិសុទ្ធិមគ្គ សម្ដែងសេចក្ដីរបស់សីល ២ ប្រការគឺ

១. **សមាធាន** តាំងទុកល្អ សំដៅដល់ការតាំងកាយកម្មជាដើមទុកល្អមិនបែកធ្លាយ ។

២. ឧបធារណៈ ចូលទៅទ្រទ្រង់ទុក សំដៅដល់ការដែលអាស្រ័យកុសលធម៌ ដែលសំខាន់ខ្ពង់ខ្ពស់ឡើងទៅដោយជាបាទឲ្យកើតសមាធិនិងបញ្ញា ។

មានសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គនោះថា

កេនដ្ឋេន សីលន្តិ សីលនដ្ឋេន សីលំ ។ កិមិទំ សីលនំ នាម ។ សមាធានំ វា កាយកម្មាទីនំ សុសីល្យវសេន អវិប្បកិណ្ណតាតិ អត្ថោ ។ ឧបធារណំ វា កុសលានំ ធម្មានំ បតិដ្ឋានវសេន អាធារណភាវោតិ អត្ថោ ។ ឯតទេវ ហេត្ថ អត្ថទ្វយំ សទ្ទលក្ខណវិទូ អនុជានន្តិ[៤៩]។

"សួរថា : ឈ្មោះថា សីល ព្រោះមានសភាវៈអ្វី ?

ឆ្លើយថា : ព្រោះមានសភាវៈតាំងទុកល្អ នឹងចូលទៅទ្រទ្រង់ទុក ។

សួរថា : សភាវៈតាំងទុកល្អ នឹងចូលទៅទ្រទ្រង់ទុកគឺអ្វី ?

ឆ្លើយថា : សភាវៈតាំងទុលល្អ និងចូលទៅទ្រទ្រង់ទុក គឺ ការតាំងកាយកម្មជាដើមល្អដោយភាពជាអ្នកមានសីល សំដៅដល់ការមិនឲ្យកាយកម្មជាដើមរាត់រាយ ឬការចូលទៅទ្រទ្រង់ទុក សេចក្តីថា ដែលជាទីតាំងនៃកុសលធម៌ ដោយភាវៈជាការដែលទទួលរ៉ាប់រង ដោយពិតប្រាកដ ហើយ អ្នកចេះវេយ្យាករណ៍ទាំងឡាយអនុញ្ញាតអត្ថពីរយ៉ាងនេះប៉ុណ្ណោះ" ។

អត្ថខាងដើមនេះ ពោលតាមស័ព្ទដើមរបស់សីល ជាតុ ប្រាកដក្នុងសទ្ទនីតិបករណ៍ ( ធាតុមាលាទំព័រ ២១៨-២១៩ ) ថា សមាធានៈ (តាំងទុកល្អ ) និងឧបធារណៈ ( ចូលទៅទ្រទ្រង់ទុក ) ។

ម្យ៉ាងទៀត នេត្តិបករណ៍ (ទំព័រ ១៩០) ពោលដល់សីល ៥ ប្រភេទ គឺ

១. បកតិសីល សីលដោយប្រក្រតី គឺសីលដែលប្រព្រឹត្ត ជាប្រចាំដោយមិនបានសមាទាន ។

២. សមាទានសីល សីលដោយការសមាទាន គឺសីលដែលទទួលយកអំពីព្រះភិក្ខុ ឬសមាទានចំពោះមុខព្រះពុទ្ធរូប ។

៣. ចិត្តបសាទៈ សីលដែលកើតអំពីការជ្រះថ្លា ។

៤. សមថៈ សីលដែលកើតអំពីសមថៈ ។

៥. វិបស្សនា សីលដែលកើតអំពីវិបស្សនា]។

## ការវៀរចាកឈ្មោះថា សីល

ពិតហើយ វិរតិចេតសិកមិនកើតឡើងព្រមគ្នាក្នុងវិបស្សនាចិត្ត តែវិបស្សនាចិត្ត ក៏ជាបដិបក្ខចំពោះទុច្ចរិត និងទុរាជីវៈ ( ការចិញ្ចឹមជីវិតខុស ) ទាំងអស់ ទើបគេចចេញអំពីវត្ថុទាំងនោះ ដោយតទង្គបហាន ដូចក្នុងខណៈដែលកើតមគ្គចិត្ត ដែលទទួលយក

ព្រះនិព្វានជាអារម្មណ៍ សូម្បីទីធ៍មិនមានការវៀរចាក ដោយទទួលយកទុច្ចរិត និងទុកជីវ:ជាអារម្មណ៍ ក៏ចាត់ថាគេចចេញក្នុងខណៈនោះ ព្រោះលះបាបនោះបានដោយសមុច្ឆេទបហាន ។

ក្នុងខណៈដែលអ្នកបដិបត្តិធម៌ កើតនូវវិបស្សនាញាណ មាននាមរូបបរិច្ឆេទញាណជាដើម កិលេសដែលប្រកាន់មាំថា ជាបុគ្គល ជាយើង របស់យើង និងប្រកាន់មាំថា ពួកសត្វកើតឡើងឯងៗ ដោយមិនមានហេតុបច្ច័យ ឬប្រកាន់មាំថា ទៀង ជាសុខ ជាអត្តា រមែងនឹងមិនកើតឡើង ក្នុងរូបនាមដែលកំពុងកំណត់ដឹង សេចក្តីនេះជាការលះអារម្មណានុស្ស័យ គឺអានុស្ស័យដែលដេកត្រាំនៅក្នុងអារម្មណ៍ដែលរលត់សតិកំណត់ដឹង កាលបើដូច្នេះ ការត្រិះរិះថាជាបុគ្គល ជាយើង របស់យើង ដែលជាបរិយុដ្ឋានកិលេស ក៏មិនកើតឡើង នឹងកាលមិនមានការត្រិះរិះដូចពោល ការកន្លងនូវបាណាតិបាតកម្មជាដើម ដោយការប្រកាន់ភ្ជាប់ក្នុងត្លួខនដែលជាវីតិក្កមកិលេសរមែងមិនកើតឡើង នឹងឃើញបានថា គ្រប់ខណៈដែលកំណត់ដឹងរូបនាម ជាការវៀរចាកនូវកិលេស តាំងអំពីអនុស្ស័យកិលេស រហូតដល់វីតិក្កមកិលេស លោកទើបពោលថា

វេរមណិ សីលំ ( ការវៀរចាក ឈ្មោះថា សីល ) ។

## ចេតនាឈ្មោះថា សីល

ចេតនាដែលជាការតាំងចិត្តកំណត់ដឹងទាន់សភាវធម៌ រមែងកើតឡើងក្នុងគ្រប់ៗខណៈ ដែលចំរើនភាវនា ចេតនាដែលកើតដល់បុគ្គលទូទៅ អ្នកមិនបានសង្រួមឥន្ទ្រីយ៍ តែងតែឧបត្ថម្ភឲ្យធ្វើអកុសល កាលកើតក្នុងអ្នកបដិបត្តិដែលមានសទ្ធា ឆន្ទៈ និងវិរិយៈចាស់ក្លា រមែងនឹងឧបត្ថម្ភឲ្យតាំងចិត្តចំរើនភាវនា ប្រសិនបើសទ្ធា ឆន្ទៈ និងវិរិយៈអន់ខ្សោយ កម្លាំងចេតនា ក៏បណ្តាយឲ្យអន់ខ្សោយកម្លាំងទៅផង ដូច្នោះ ចេតនាទើបធ្វើឲ្យកុសលធម៌តាំងមាំ នឹងជាទីតាំង របស់កុសលធម៌កាន់តែចំរើនឡើង ។

## ការសង្រួមឈ្មោះថា សីល

សំវរៈ ៥ យ៉ាង ដែលពោលទុកក្នុងឥន្ទ្រិយសំវរៈឈ្មោះថា សំវរសីល អ្នកដែលចំរើនវិបស្សនា រមែងរាំងមិនឲ្យកើតអកុសល ដោយសំវរៈ ៥ ដែលកើតឡើងជានិច្ចក្នុងវិបស្សនាចិត្ត ការសង្រួមនេះ អង្គធម៌បានដល់ សតិ បញ្ញា ខន្តិ និងវិរិយៈ ។

# ការមិនកន្លងល្មើសឈ្មោះថា សីល

ចិត្តដែលប្រកបដោយសតិ ដែលកំណត់ដឹងតាមសភាវៈពិតរមែងនឹងមិនលាយឡំដោយមោហៈជាដើម ព្រោះមិនបើកឱកាសឲ្យអកុសលកើតឡើង ដូចចេតនាក្នុងការធ្វើបាណាតិបាត ឈ្មោះថាកន្លងល្មើសកម្មនោះ តែចិត្តដែលមានចេតនាវៀរចាកបាណាតិបាតរមែងឈ្មោះថា មិនកន្លងល្មើស ក្នុងករណីជាមួយគ្នាចិត្តដែលខ្វះសតិដឹងទាន់សភាវធម៌ឈ្មោះថា កន្លងល្មើសកិលេស ព្រោះបើកឱកាសឲ្យកិលេសដែលជាអនុស័យ បរិយុដ្ឋាន ឬវីតិក្កម តែចិត្តដែលប្រកបដោយសតិឈ្មោះថា មិនកន្លងល្មើសកិលេស ព្រោះមិនបើកឱកាសឲ្យកិលេសកើតឡើង ដូច្នោះ កាលបើមិនកន្លងល្មើសអង្គធម៌បានដល់ វិបស្សនាចិត្តទើបឈ្មោះថា សីល ។

ក្នុងបណ្ដាសីលទាំង ៥ យ៉ាងនេះ ចេតនានិងការសង្រួមមានអង្គដោយត្រង់ ការលះកិលេសជាការកំចាត់កិលេសដែលកើតឡើងហើយ នឹងមិនបើកឱកាសឲ្យកិលេសថ្មីកើតឡើង ចំណែកការវៀរចាក និងការមិនកន្លងល្មើសអង្គធម៌ គឺវិបស្សនាចិត្តដូចសាធកៈក្នុង

គម្ពីរវិសុទ្ធិមគ្គថា

វេរមណិវសេន អវីតិក្កមវសេន

ចេតសោ បវត្តិសព្ភាវំ សន្ធាយ វុត្តា[៦០] ។

"សេចក្ដីនេះ ពោលទុកសំដៅដល់ការប្រព្រឹត្តទៅរបស់ចិត្តដោយជាប់ទាក់ទងដោយការវៀរចាក និងដោយការមិនកន្លងល្មើស" ។

ទោះបីយ៉ាងណាក៏ដោយ វិបស្សនាចិត្តដូចដែលពោលមកនេះ ជាចិត្តដទៃដែលមិនមែនចេតនា និងសំវរៈ ដែលចាត់ជាសីល ដូចដែលពោលមកហើយខាងដើម ។

ក្រៅអំពីនេះ សូម្បីការវៀរចាក និងការមិនកន្លងល្មើសអង្គធម៌ដូចគ្នា តែមានលក្ខណៈផ្សេងគ្នាគឺការវៀរចាកជាការចៀសវាងអំពីកិលេសដែលជាអនុស័យ បរិយុដ្ឋាន និងវីតិក្កមៈ ចំណែកការមិនកន្លងល្មើស ជាការមិនបើកឱកាសឲ្យកិលេសកើតឡើងក្នុងក្រសែចិត្តរបស់ខ្លួន ។

ក្នុងសេចក្ដីដែលស្រង់អំពីគម្ពីរបដិសម្ភិទាមគ្គនោះ ពាក្យថា

យោ តត្ថ សំវរដ្ឋោ ( សភាវៈដែលសង្រួមនេះ ក្នុងវិបស្សនាចិត្ត នោះ ឈ្មោះថា អធិសីលសិក្ខា ) ជាដើម ។

សេចក្តីថា ការលះបង់, ការវៀរចាក, ចេតនា, និងការមិនកន្លង ល្មើសទាំង ៤ យ៉ាងនេះ ជាសីលដែលហៅថា **សំវរសីល** ។

សតិដែលកាន់យករូបនាមជាអារម្មណ៍ទុកយ៉ាងកៀកកិត ឈ្មោះថា **សតិសំវរៈ**។

បញ្ញាដែលប្រចក្សច្បាស់រូបនាមយ៉ាងពិតប្រាកដ ឈ្មោះថា **ញាណសំវរៈ** ។

អទោសចេតសិកដែលមិនប្រទូស្សរាយអារម្មណ៍ដែលមកប្រាកដ ឈ្មោះថា **ខន្តិសំវរៈ** ។

សេចក្តីព្យាយាមក្នុងការកំណត់ដឹងឈ្មោះថា**វីរិយសំវរៈ** ។ សំវរៈពួកនេះ រមែងប្រាកដយ៉ាងបរិបូណ៌ក្នុងវិបស្សនាចិត្តដឹងទាន់ សភាវធម៌ ឈ្មោះថា **អធិសីលសិក្ខា** ។

មយ៉ាងទៀត ការពោលដល់បញ្ញា សតិ និងវីរិយៈថាជាសីលក្នុង

រឿងនេះជាការពោលដោយបរិយាយ ការពិតបញ្ញារាប់ចូលក្នុងបញ្ញាខន្ធ សតិ និងវិរិយៈរាប់ចូលក្នុងសមាធិខន្ធដោយត្រង់ក្រៅអំពីនេះ បាតិមោក្ខសំវរសីលជាដើម រមែងបរិសុទ្ធក្នុងវិបស្សនាប៉ុណ្ណោះ និងបាតិមោក្ខសំវរសីលព្រមទាំងអាជីវបារិសុទ្ធិសីល រមែងបរិបូណ៌ដោយសីល ៤ យ៉ាងគឺ ការលះ, ការវៀរចាក, ចេតនា និងការមិនកន្លងល្មើស ព្រោះកិលេសទាំងអស់ដែលជា អនុស័យ បរិយុដ្ឋាន និងវីតិក្កមៈមិនមានឱកាសកើតឡើងដោយការលះជាដើម ទើបមិនអាចកន្លងល្មើសផ្លូវកាយ ឬវាចាបានទេ ។

សំវរៈពួកនេះ គឺ សតិ បញ្ញា ខន្តិ និងវិរិយៈ ជាឥន្ទ្រិយសំវរសីលដោយត្រង់ បញ្ញាដែលកើតឡើងក្នុងខណៈពិចារណាប្រយោជន៍របស់បច្ច័យ ៤ រមែងធ្វើឲ្យបច្ចយសន្និស្សិតសីលបរិបូណ៌ ពីព្រោះការពិចារណាតាមព្រះពុទ្ធតម្រាសនោះ មានប្រយោជន៍ដើម្បីបិទរាំងមិនឲ្យកិលេសកើតឡើង ។ ការពិចារណាដូចដែលពោលមកនេះ អាចលះកិលេសថ្នាក់បរិយុដ្ឋាន និងវីតិក្កមៈ មិនអាចលះ កិលេសបានទេ តែវិបស្សនាញាណអាចលះបង់អនុស័យកិលេសបានដែល

ជាប់ទាក់ទងដោយបច្ច័យទាំងនោះ ដោយហេតុនេះ ញាណសំវរៈ ទើបធ្វើឲ្យបច្ចយសន្និស្សិតសីលបរិសុទ្ធបរិបូណ៌បាន ។

## ការចំរើនភាវនាសំខាន់ជាងការពិចារណាប្រយោជន៍របស់បច្ច័យ

អ្នកខ្លះយល់ថា ការពិចារណាប្រយោជន៍របស់បច្ច័យសំខាន់ជាងភាវនា ទើបមិនព្រមទទួលពាក្យអធិប្បាយខាងដើម ការពិតការចំរើនសមថភាវនា ឬវិបស្សនាភាវនាមានគុណតម្លៃប្រសើរជាងការពិចារណាប្រយោជន៍របស់បច្ច័យ ព្រះពុទ្ធជាម្ចាស់ត្រាស់ដល់ការចំរើនភាវនាត្រឹមមួយផ្ទាត់ក្រចកដៃថា វាប្រសើរជាងការពិចារណា ដូច្នេះ សូម្បីភិក្ខុចំរើនភាវនា តែមិនបានពិចារណាក៏មិនមានទោស ដូចព្រះពុទ្ធវចនៈ ក្នុងគម្ពីរអង្គុត្តរនិកាយថា

**អច្ឆរាសង្ឃាតមត្តម្បិ ចេ ភិក្ខវេ ភិក្ខុ មេត្តាចិត្តំ អាសេវតិ ភាវេតិ មនសិការោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ ឱវាទបតិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ ។ កោ បន វាទោ យេ នំ ពហុលីករោន្តិ**[៦១] ។

“ម្នាលភិក្ខុទាំងឡាយ បើភិក្ខុធ្វើទុកក្នុងចិត្ត ដោយយោនិសោ-

មនសិការ ចំរើនមេត្តាចិត្ត សូម្បីត្រឹមមួយផ្ទាត់ក្រចក ភិក្ខុនេះឈ្មោះថា កំពុងប្រកបដោយឈាន ជាអ្នកធ្វើស្តាប់បដិបត្តិតាមពាក្យទូន្មានរបស់ព្រះសាស្តា រមែងបរិភោគដុំបាយរបស់អ្នកស្រុកដោយមិនឥតប្រយោជន៍ ទីងចាំបាច់ពោលទៅថ្វី ដល់ភិក្ខុអ្នកមានប្រក្រតីចំរើនមេត្តាចិត្តដ៏ច្រើននោះ" ។

អច្ឆរាសង្ឃាតមត្តម្បិ ចេ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ, វេទនាសុ វេទនានុបស្សី វិហរតិ, ចិត្តេ ចិត្តានុបស្សី វិហរតិ, ធម្មេសុ ធម្មានុបស្សី វិហរតិ អាសេវតិ ភាវេតិ មនសិករោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ ឱវាទបតិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ ។ កោ បន វាទោ យេ នំ ពហុលីករោន្តិ[៦២] ។

"ម្នាលភិក្ខុទាំងឡាយ បើភិក្ខុតាមដឹងកាយក្នុងកាយ ( គឺរូប ) តាមដឹងនូវវេទនាក្នុងវេទនា តាមដឹងនូវចិត្តក្នុងចិត្ត តាមដឹងនូវធម៌ក្នុងធម៌ សូម្បីព្យាយាមត្រឹមមួយផ្ទាត់ក្រចកដៃ មានសេចក្តីព្យាយាមមានបញ្ញាដឹងដ៏ក្រៃលែងមានសតិរំលត់បង់អភិជ្ឈា និងទោមនស្ស

ក្នុងលោកចេញបាន ភិក្ខុនេះ ឈ្មោះថា កំពុងប្រកបដោយឈាន ជាអ្នកជឿស្តាប់បដិបត្តិតាមពាក្យទូន្មានរបស់ព្រះសាស្តា រមែងបរិភោគដុំបាយរបស់អ្នកស្រុក ដោយមិនឥតប្រយោជន៍ ទីងចាំបាច់ពោលទៅថ្វី ដល់ភិក្ខុអ្នកមានប្រក្រតីចំរើនសតិប្បដ្ឋាន ៤ ដ៏ច្រើននោះ" ។

ក្នុងព្រះសូត្រដំបូង ដែលពោលដល់ការចំរើនមេត្តាភាវនា ព្រះបរមសាស្តា ទ្រង់បំណងដល់មេត្តាចិត្តរបស់មនុស្សទូទៅ ដែលនៅមិនទាន់បានសម្រេច ជាឧបចារសមាធិ និងអប្បនាសមាធិ ដូចក្នុងគម្ពីរអដ្ឋកថាពោលថា

**មេត្តាយ សព្វបុព្វភាគោ នាម នេវ អប្បនា**
**ន ឧបចារោ, សត្តានំ ហិតផរណមត្តមេវ**[៦៣] ។

"ឈ្មោះថា ចំណែកខាងដើមទាំងអស់ របស់មេត្តាជាការពង្រីកសេចក្តីប្រាថ្នាល្អដល់ពួកសត្វប៉ុណ្ណោះ នៅមិនមែនជាឧបចារៈ ឬអប្បនា" ។

ដូចដែលព្រះសូត្រសម្តែងថា ភិក្ខុណាចំរើននូវមេត្តាភាវនា

សមថការនាយ៉ាងណានិមួយ ឬវិបស្សនា មានកាយានុបស្សនាជាដើម ត្រឹមមួយផ្ទាត់ក្រចកដៃ ភិក្ខុនោះ ជាអ្នកបដិបត្តិតាមពាក្យទូន្មានរបស់ព្រះបរមសាស្តា រាប់ថាជាព្រះសេក្ខៈដោយបរិយាយ ការបរិភោគដុំបាយរបស់ភិក្ខុនោះ មានប្រយោជន៍ ដល់អ្នកស្រុក ជាការបរិភោគដូចអ្នកមិនជំពាក់បំណុល ( អាណណ្យបរិភោគៈ ) បរិភោគដោយភាពជាទាយាទ ( ទាយជ្ជបរិភោគ ) និងបរិភោគដោយភាពជាម្ចាស់របស់ ( សាមិបរិភោគ ) ចំណែកភិក្ខុអ្នកចំរើនការនារឿយៗ រមែងមានប្រយោជន៍ដល់ខ្លួនឯង និងអ្នកស្រុកដោយពិត ដូចគម្ពីរអដ្ឋកថាពោលថា

កុញ្ចតីតិ ចត្តារោ បរិភោគា ថេយ្យបរិភោគោ ឥណទាយជ្ជសាមិបរិភោគោ ។បេ។ តត្ថ ឥមស្ស ភិក្ខុនោ អយំ រដ្ឋបិណ្ឌបរិភោគោ ទ្វីហិ ការណេហិ អមោឃោ ហោតិ ។ អច្ឆរាសង្ឃាតមត្តម្បិ មេត្តាចិត្តំ អាសេវន្តោ ភិក្ខុ រដ្ឋបិណ្ឌស្ស សាមិកោ ហុត្វា អនណោ ហុត្វា ទាយាទោ ហុត្វា បរិភុញ្ជតីតិបិស្ស អមោឃោ រដ្ឋបិណ្ឌបរិភោគោ ។ អច្ឆរាសង្ឃាតមត្តម្បិ មេត្តំ អាសេវន្តស្ស

ភិក្ខុនោ ទិន្នទានំ មហគ្គិយំ ហោតិ មហប្ផលំ មហានិសំសំ មហាជុតិកំ មហាវិប្ផារន្តិ បិស្ស អមោឃោ រដ្ឋបិណ្ឌបរិភោគោ ។ យេ បន ឥមំ មេត្តាចិត្តំ ពហុលំ អាសេវន្តិ ភាវេន្តិ បុនប្បុនំ ករោន្តិ, តេ អមោឃំ រដ្ឋបិណ្ឌំ បរិភុញ្ជន្តីតិ ឯត្ថ វត្តព្វមេវ កឹ ។ ឯវរូបា ហិ ភិក្ខូ រដ្ឋបិណ្ឌស្ស សាមិនោ អនណា ទាយាទា ហុត្វា បរិភុញ្ជន្តិ[៦៤] ។

“ពាក្យថា ភុញ្ជតិ សំដៅដល់ ការបរិភោគមាន ៤ យ៉ាង គឺ ការបរិភោគដូចជាការលួច ការបរិភោគដោយជាប់បំណុល ការបរិភោគដោយភាពជាទាយាទ និងការបរិភោគដោយភាពជាម្ចាស់ទ្រព្យ ក្នុងបណ្ដាការបរិភោគទាំងនោះ ការបរិភោគដុំបាយរបស់អ្នកស្រុក រមែងមិនមានទូវប្រយោជន៍ដល់ភិក្ខុនេះ ដោយហេតុពីរប្រការ ភិក្ខុអ្នកចំរើនមេត្តាចិត្ត ត្រឹមមួយផ្ទាត់ក្រចកដៃ រមែងបរិភោគដូចជាម្ចាស់ទ្រព្យ មិនមានបំណុល និងជាទាយាទ ដូច្នោះ ការបរិភោគរបស់លោក ទើបមិនឥតប្រយោជន៍ ទីងទានដែលថ្វាយដល់ភិក្ខុអ្នកចំរើនមេត្តាចិត្ត ក៏មានប្រយោជន៍ច្រើន មានផលានិសង្ស ច្រើន មានភាពរុងរឿងទូលំទូលាយច្រើន ដូច្នោះ ការបរិភោគ

របស់លោក ទើបមិនឥតប្រយោជន៍ នឹងចាំបាច់ពោលទៅថ្វី ដល់ភិក្ខុអ្នកចំរើនមេត្តាចិត្តជាប់ជានិច្ចនោះ ព្រោះភិក្ខុពួកនេះរមែងបរិភោគដោយភាពជាម្ចាស់ជុំបាយនៃអ្នកស្រុក ជាអ្នកមិនមានបំណុល នឹងជាទាយាទ"ៗ

ភិក្ខុអ្នកចំរើនមេត្តា ត្រឹមមួយផ្ទាត់ក្រចក ក្នុងខណៈបរិភោគ ឈ្មោះថា បរិភោគដោយមិនសូន្យទទេ ( **អមោឃបរិភោគ** ) ព្រោះធ្វើប្រយោជន៍ដល់ខ្លួន និងអ្នកថ្វាយទាន ការធ្វើប្រយោជន៍ដល់ខ្លួនគឺការចំរើនកុសលដែលជាប់ដោយមេត្តាភាវនា និងធ្វើឲ្យជាការបរិភោគក្នុងភាពជាម្ចាស់ ក្នុងវត្ថុដែលបានទទួលថ្វាយ ( **សាមិបរិភោគ** ) ការបរិភោគមិនមានបំណុល ( **អាណណ្យបរិភោគ** ) និងការបរិភោគដោយភាពជាទាយាទ ( **ទាយជ្ជបរិភោគ** ) ចំណែកឯប្រយោជន៍ដល់អ្នកថ្វាយ គឺភិក្ខុអ្នកចំរើនមេត្តាចាត់ថា ជាទក្ខិណេយ្យបុគ្គល ទី ៨ អ្នកបដិបត្តិដើម្បីសម្រេចសោតាបត្តិផល ។

សូម្បីថា លោកនឹងពោលទុកដល់មេត្តាភាវនាទុកតែប៉ុណ្ណឹង ក្នុងគម្ពីរអដ្ឋកថា តែសេចក្តីនេះនៅគ្រប់គ្រាន់ដល់ភាវនាដទៃ ឈាន-

សមាបត្តិ និងវិបស្សនាភាវនាមានកាយានុបស្សនាជាដើមទៀតផង កាលដែលលោកមិនបានពោលដល់ភាវនាដទៃ ក៏ព្រោះនៅក្នុងបរិបទនៃការពោលដល់មេត្តា ក្នុងមេត្តាសូត្រនោះឯង ។

ដោយហេតុដូចដែលពោលមកនេះ បច្ចុយសន្និស្សិតសីលរមែងចម្រើនបានដោយការចំរើនវិបស្សនាភាវនា ។

## ការតាំងនៅក្នុងសីលហើយចំរើនសមាធិ និងបញ្ញា

គ្រហស្ថអ្នករក្សាសីលអស់កាលយូរ ឬមិនរក្សាសីលមកមុន កាលមកចំរើនវិបស្សនាភាវនា ក៏ចាត់ថាជាអ្នកមានសីលទាំង ៤ យ៉ាងបរិសុទ្ធ បរិបូណ៌ដោយវិបស្សនាចិត្ត ។ មួយ៉ាងទៀត ការកពួនសមាធិ និងបញ្ញារបស់អ្នកបដិបត្តិនោះឡើងជាមួយសីលគ្រាដំបូង (បុព្វភាគសីល) ដោយភាពជាឧបនិស្សយបច្ច័យ និងសីលដែលកើតរួមគ្នា ( សហជាតសីល ) ដោយភាពជានិស្សយបច្ច័យ ។

សីលដែលរក្សាមកយូរ ឬសីលដែលសមាទានមុនបដិបត្តិធម៌ ហៅថា ជាឧបនិស្សយបច្ច័យ ( បច្ច័យដែលជាទីអាស្រ័យដ៏មានកម្លាំង ) ព្រោះជាទីអាស្រ័យរបស់សមាធិ និងបញ្ញា នៅក្នុង

វិបស្សនាញាណ និងមគ្គញាណ ចំណែកសីលដែលកើតឡើងក្នុងវិបស្សនាចិត្ត និងមគ្គចិត្តជាទីអាស្រ័យរបស់សមាធិ និងបញ្ញាក្នុងចិត្តពួកនោះ ហៅថាសហជាតនិស្សយបច្ច័យ (បច្ច័យជាទីអាស្រ័យដែលកើតរួមគ្នា ) ។

អ្នកបដិបត្តិរមែងតាំងនៅក្នុងសីលដែលជាសហជាតនិស្សយ-បច្ច័យ ក្នុងចិត្តុប្បាទដែលរលឹកដឹងសភាវធម៌គ្រាដំបូងហើយ ចំរើនសមាធិ និង បញ្ញា តែក្នុងចិត្តុប្បាទទី ២ ជាដើមទៅ រមែងតាំងនៅក្នុងសីលដែលជាឧបនិស្សយបច្ច័យ និងនិស្សយបច្ច័យ ហើយចំរើនសមាធិ និងបញ្ញា ក្នុងវិបស្សនាញាណ និងមគ្គញាណ ដូចសេចក្តីក្នុងគម្ពីរមហាដីកាថា

បតិដ្ឋាយាតិ ទុវិធា បតិដ្ឋា និស្សយូបនិស្សយភេទតោ ។ តត្ថ ឧបនិស្សយបតិដ្ឋា លោកិយា, ឥតរា លោកុត្តរា អភិន្ទិត្វា គហណេ ។ ភិន្ទិត្វា បន គហណេ យថា លោកិយចិត្តុប្បាទេសុ សហជាតានំ បុរិមបច្ឆិមានញ្ច វសេន និស្សយូបនិស្សយបតិដ្ឋាយ សម្ភវតិ ឯវំ លោកុត្តរេសុ ហេដ្ឋិមមគ្គផលសីលវសេន

ឧបនិស្សយបតិដ្ឋាបិ សម្ភវតិ ។ បតិដ្ឋាយាតិ ច បទស្ស យទា ឧបនិស្សយបតិដ្ឋា អធិប្បេតា, តទា សទ្ធិំ ឧបនិស្សាយាតិអាទីសុ វិយ បុរិមកាលកិរិយាវសេន អត្ថោ វេទិតព្វោ ។ តេនាហ "បុព្វេ ខោ បទស្ស កាយកម្មំ វចីកម្មំ អាជីវោ សុបរិសុទ្ធោ ហោតីតិ ។ យទា បន និស្សយបតិដ្ឋា អធិប្បេតា, តទា "ចក្ខុញ្ច បដិច្ចាតិអាទីសុ វិយ សមានកាលកិរិយាវសេន អត្ថោ វេទិតព្វោ[៥] ។

"ពាក្យថា បតិដ្ឋាយ (តាំងនៅក្នុងសីល) ការតាំងនៅមាន ២ យ៉ាង ដោយចែកតាមនិស្សយបច្ច័យ និងឧបនិស្សយបច្ច័យ ក្នុងការតាំងនៅទាំងពីរនោះ កាលមិនញែក [មគ្គចិត្តជា ៤] ក៏កាន់យកថា ការតាំងនៅដោយឧបនិស្សយបច្ច័យជាលោកិយ: ការតាំងនៅដទៃជាលោកុត្តរ: តែកាលញែកពិចារណា [យ៉ាងនោះ] សូម្បីការតាំងនៅដោយឧបនិស្សយបច្ច័យ ដោយភាពជាមគ្គសីល និងផលសីលខាងក្រោម រមែងកើតក្នុងលោកុត្តរសីលទាំងឡាយកាលការតាំងនៅដោយនិស្សយបច្ច័យ និងឧបនិស្សយបច្ច័យដោយអំណាចនៃសីល សមាធិ និងបញ្ញាដែលកើតរួមគ្នា នឹងដោយអំណាចរបស់សីល

ដែលកើតមុន នឹងសមាធិព្រមទាំងបញ្ញាដែលកើតខាងក្រោយក្នុង

លោកុត្តរចិត្ត" ។

ម្យ៉ាងទៀត បទថា **បតិដ្ឋាយ** បានដល់ការតាំងនៅដោយភាពជា

ឧបនិស្សយបច្ច័យ គប្បីជ្រាបសេចក្តី [របស់ត្វាបច្ច័យ] ដោយភាព

ជា បុព្វកាលកិរិយា ដូចពាក្យថា **សទ្ធំ ឧបនិស្សាយ** ( អាស្រ័យ

សទ្ធាហើយ ) ជាដើម សមពិតដូចជាព្រះពុទ្ធតម្រាស់ថា ( កាយកម្ម

វចីកម្មនិងការស្វែងរកចិញ្ចឹមជីវិតរបស់ភិក្ខុនោះបរិសុទ្ធល្អហើយមុន )

តែកាលពោលដល់ការតាំងនៅដោយនិស្សយបច្ច័យ គប្បីជ្រាប

សេចក្តី [របស់ត្វាបច្ច័យ] ដោយភាពជាសមានកាលកិរិយា ដូច

ពាក្យថា **ចក្ខុញ្ច បដិច្ច** ( អាស្រ័យចក្ខុបសាទ )"។

[តាមគោលភាសាបាលី ត្វាបច្ច័យក្នុងពាក្យថា **បតិដ្ឋាយ** ( បតិ-

បុព្វបទ+ ឋាធាតុ + ត្វាបច្ច័យ ផ្លាស់ ត្វា ជា យ ) ប្រើក្នុងសេចក្តី ២

យ៉ាងគឺ៖

១. បុព្វកាលកិរិយា គឺកិរិយាដែលកើតឡើងមុនកិរិយាក្រោយតាម

ន័យនេះ បតិដ្ឋាយ ប្រែថា " តាំងនៅហើយ " ជាការតាំងនៅដោយ

ឧបនិស្សយបច្ច័យ ។

២. សមានកាលកិរិយា កិរិយាដែលស្មើគ្នាជាមួយកិរិយាក្រោយ តាមន័យនេះ បតិដ្ឋាយៈ ប្រែថា " តាំងនៅ" ជាការតាំងនៅ ដោយនិស្សយ-បច្ច័យ ។

ដោយហេតុនេះ គាថាដំបូងក្នុងគម្ពីរវិសុទ្ធិមគ្គ ទើបមានពាក្យប្រែ ២ ន័យដូច្នេះ

សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ[៦៦] ។

"ភិក្ខុជាអ្នកខ្លាច មានសេចក្តីព្យាយាម មានបញ្ញាឈ្លៀវឈ្លាស តាំងនៅក្នុងសីលហើយអប់រំចិត្ត និងបញ្ញានោះ គប្បីកាប់ធ្លាព្រៃក្រាស់បាន ( ន័យទី ១ )" ។

"ភិក្ខុជាអ្នកខ្លាច មានសេចក្តីព្យាយាម មានបញ្ញាឈ្លៀវឈ្លាស តាំងនៅក្នុងសីលអប់រំចិត្ត និងបញ្ញានោះ គប្បីកាប់ធ្លាព្រៃក្រាស់បាន ( ន័យ ទី ២ )"] ។

## ពុទ្ធបរិស័ទគប្បីរក្សាសីលជានិច្ច

ការពោលដល់សេចក្ដីបរិសុទ្ធនៃសីលដោយភាវនា ដូចដែលបានអធិប្បាយមកហើយ នេះបំណងនឹងបដិសេធការយល់ខុសថា បុគ្គលត្រូវរក្សាសីលមកមុនអស់កាលយូរ ទើបអាចចំរើនភាវនាបាន មិនអាចរក្សាសីលក្រោយការចំរើនភាវនា ការអធិប្បាយដូច្នេះមានប្រយោជន៍ ដើម្បីមិនឲ្យមនុស្សទូទៅបាត់បង់ទំនុកចិត្ត ក្នុងភាវនាដែលគួរបដិបត្តិ មិនមែនពោលទុក ដោយមិនបានគោរពក្នុងសីលទេ ពិតហើយ សីលជាខបដិបត្តិដ៏ប្រសើរក្នុងពួកសត្វ ដែលធ្លាក់ទៅកាន់អបាយភូមិសោយទុក្ខវេទនាសែនធ្ងន់ធ្ងរ ៩៩ នាក់ក្នុងចំណោម ១០០ នាក់គួរនឹងធ្លាក់នរក ព្រោះដាច់សីល ចំណែកអ្នកដែលទៅក្នុងមនុស្សភូមិ ឬស្ថានសួគ៌ ក៏កើតដោយអំណាចអានុភាពរបស់សីលជាចំនួនច្រើនគួរនឹងកើន ៥០ នាក់ក្នុងចំណោម ១០០ នាក់សូម្បីអ្នកដែលសម្រេចធម៌ជាព្រះអរិយបុគ្គល ក៏រមែងរក្សាសីលមកមុនអស់កាលយូរ អ្នកដែលសម្រេចធម៌បាន ដូចសន្តតិមហាមាត្យមានតិចតួច ។

ដោយហេតុនេះ មនុស្សគ្រប់គ្នា គប្បីរក្សាសីលឲ្យដូចជាការរក្សាជីវិតរបស់ខ្លួន កុំប្រមាទដោយគិតថា នឹងរក្សាសីលក្នុងកាលជាខាងក្រោយ ព្រោះអ្នកនៅដោយសេចក្ដីប្រមាទ មិនបានរក្សាសីលអាចអស់ជីវិតភ្លាមហើយទៅកើតក្នុងអបាយភូមិបាន អ្នកត្រូវការចំរើនភាវនា ដើម្បីឲ្យសម្រេចធម៌ក្នុងជាតិនេះ ទើបត្រូវព្យាយាមរក្សាសីល មិនឲ្យធ្វេសប្រហែស ។

អ្នករក្សាសីលដោយប្រក្រតីហើយ មុននឹងចំរើនភាវនាគួរសមាទានបញ្ចសីល ឬអាជីវដ្ឋមកសីលទៀត ដើម្បីឲ្យសីលជាឧបការៈដល់សមាធិ និងបញ្ញា ក្នុងខណៈដែលបដិបត្តិធម៌ ។ ម្យ៉ាងទៀត អ្នកដែលចូលបដិបត្តិធម៌ ក្នុងព្រះសូត្រអប់រំឲ្យចំរើនវិបស្សនាតាំងអំពី ៧ ថ្ងៃជាដើមទៅ គួរលះសេចក្ដីកង្វល់ក្នុងក្រុមគ្រួសារ តួនាទីការងារ ។ល។ ហើយរក្សាសីល ៨ ឬសីល ១០ តាមសមគួរ ។

សីលដែលបុគ្គលសមាទាន ប្រព្រឹត្តល្អហើយរមែងរីករាយត្រេកអរថា សីលរបស់យើងបរិសុទ្ធល្អ ហើយឲ្យកើតនូវសេចក្ដីបាមោជ្ជៈ បីតិត្រេកអរ ការស្ងប់កាយស្ងប់ចិត្ត សេចក្ដីសោមនស្ស

ការតាំងមាំនៃចិត្ត និងយថាភូតញ្ញាណ គឺបញ្ញាដែលប្រចក្សច្បាស់រូបនាមតាមសេចក្តីពិតដូច្នេះជាដើម ។

ចប់បរិច្ឆេទទី ១

# បរិច្ឆេទទី ២

## ចិត្តវិសុទ្ធិ

ចិត្តវិសុទ្ធិគឺ សេចក្តីបរិសុទ្ធនៃចិត្ត សូម្បីពាក្យនេះ នឹងពោលដល់ចិត្ត ក៏សំដៅដល់សមាធិដែលកើតរួមជាមួយចិត្ត ព្រោះកាលសមថសមាធិ និងវិបស្សនាសមាធិ មានកម្លាំងចាស់ក្លា នីវរណៈ ៥ ដែលរុកគួនចិត្ត រមែងមិនកើតឡើង នឹងមានត្រឹមតែសមាធិ ដែលពិតប្រាកដនៅក្នុងសមថារម្មណ៍ ឬ វិបស្សនារម្មណ៍ កើតឡើងបន្តគ្នា សមាធិដូចបានពោលខាងលើ ជាចិត្តវិសុទ្ធិ យ៉ាងពិតប្រាកដ ចិត្តដែលមានសមាធិកើតរួមនោះ រមែងនឹងបរិសុទ្ធអំពីនីវរណៈ ដោយកម្លាំងរបស់សមាធិ ។

## សមាធិ ៣ ប្រភេទ

សមាធិដែលចូលដល់លំដាប់ចិត្តវិសុទ្ធិមាន ៣ ប្រភេទគឺ

១. ឧបចារសមាធិ សមាធិជិតឈាន, សមាធិដែលជិតនឹងអែបក្នុងអារម្មណ៍ ។

២. អប្បនាសមាធិ សមាធិអែបណែបក្នុងអារម្មណ៍

៣. ខណិកសមាធិ សមាធិមួយខណៈ មួយប្រាវៈ ។

[ សមាធិ ២ ប្រការដំបូងគឺ ឧបចារសមាធិ និងអប្បនាសមាធិ ពោលទុកតាមសមថយានិក អ្នកចម្រើនសមថៈ ហើយអាស្រ័យសមថៈ ជាបាទរបស់វិបស្សនា សមាធិពួកនេះមានក្នុងគម្ពីរវិសុទ្ធិមគ្គ ថា

**ទុវិធោ ហិ សមាធិ ឧបចារសមាធិ អប្បនាសមាធិ ច ទ្វីហាការេហិ ចិត្តំ សមាធិយតិ ឧបចារភូមិយំ វា បដិលាភភូមិយំ ។ តត្ថ ឧបចារភូមិយំ នីវរណប្បហានេន ចិត្តំ សមាហិតំ ហោតិ ។ បដិលាភភូមិយំ អង្គបាតុភាវេន[១] ។**

"ដោយពិតហើយ សមាធិ ២ ប្រការគឺ ឧបចារសមាធិ និង អប្បនាសមាធិ ចិត្តរមែងតាំងមាំដោយអាការៈ ២ យ៉ាង ក្នុងឋានៈនៃ ឧបចារសមាធិ ឬក្នុងពេលដែលសម្រេចអប្បនាសមាធិ ក្នុងបណ្ដាសមាធិ ពួកនោះ ចិត្តរមែងតាំងមាំដោយការលះនីវរណៈ ក្នុងឋានៈនៃឧបចារសមាធិ និងតាំងមាំដោយការប្រាកដនៃអង្គឈាន ក្នុងពេលដែលសម្រេច អប្បនាសមាធិ" ។

ចំណែកខណិកសមាធិ ពោលទុកតាមវិបស្សនាយានិក អ្នកដែល ចំរើនវិបស្សនាដោយត្រង់ ជួបក្នុងគម្ពីរវិសុទ្ធិមគ្គ ដែលសម្ដែងសមាធិ

ទាំង ៣ ប្រភេទថា

**សុខំ គម្ភីរំ គណ្ហន្តំ បរិបាកំ គច្ឆន្តំ តិវិធំ សមាធឹ បរិបូរេតិ ខណិកសមាធឹ ឧបចារសមាធឹ អប្បនាសមាធិន្តិ**(២) ។

"សេចក្តីសុខដែលចំរើនចាស់ក្លា រមែងញ៉ាំងសមាធិ ៣ ឲ្យបរិបូណ៌ គឺ ខណិកសមាធិ ឧបចារសមាធិ និងអប្បនាសមាធិ" ។

សូម្បីគម្ពីរដីកាបរមត្ថមញ្ជូសាក៏បញ្ជាក់ដល់ខណិកសមាធិ ដែលកើតឡើងដល់អ្នកចំរើនវិបស្សនាជាគោលថា

**សមថំ អនុប្បាទេត្វាតិ អវធារណេន ឧបចារសមាធឹ និវត្តេតិ, ន ខណិកសមាធឹ, ន ហិ ខណិកសមាធឹ វិនា វិបស្សនា សម្ភវតិ**(៣) ។

"ព្រះអដ្ឋកថាចារ្យហាមឧបចារសមាធិ ដោយពាក្យបដិសេធ ថា សមថំ អនុប្បាទេត្វា ( មិនញ៉ាំងសមថៈឲ្យកើតឡើង ) តែមិនហាម ខណិកសមាធិ ព្រោះវិបស្សនា រមែងមិនកើតឡើងដោយប្រាសចាក ខណិកសមាធិទេ"] ។

ឧបចារសមាធិ ជាកាមាវចរសមាធិ ដែលកើតឡើងដល់អ្នក ចំរើនសមថភាវនា អ្នកដែលសម្រេចនូវបដិភាគនិមិត្ត ក្នុងខណៈ

ដែលប្រាសចាកនីវរណៈធម៌ហើយ ឬអាចទទួលដឹងព្រះពុទ្ធគុណជាដើមបានយ៉ាងច្បាស់លាស់ សំដៅដល់សមាធិក្នុងកសិណ ១០ អសុភ ១០ កាយគតានុស្សតិ អានាបានៈ ព្រហ្មវិហារ ៤ និងអារុប្បកម្មដ្ឋាន ៤ ដោយត្រង់ ទាំងសំដៅដល់អនុស្សតិ ៨ បដិកូលសញ្ញា និងធាតុវវត្ថានដោយអម ព្រោះកម្មដ្ឋាន ១០ យ៉ាងពួកនេះធ្វើឲ្យសម្រេចដល់សភាវៈដែលប្រាសចាកនីវរណៈបាន តែមិនអាចធ្វើឲ្យសំរេចឈានបាន ទើបចាត់ជា ឧបចារសមាធិដោយអម ។

អប្បនាសមាធិ ជាសមាធិដែលនែបនិត្យ ក្នុងកសិណារម្មណ៍ជាដើម ដែលកំពុងសំឡឹងមើល សំដៅដល់សមាបត្តិ ៨ ឬ ៩ គឺ រូបឈាន ៤ និង អរូបឈាន ៤ រាប់តាមចតុក្កន័យ ឬ រូបឈាន ៥ និងអរូបឈាន ៤ រាប់តាមបញ្ចកន័យ ។

ខណិកសមាធិ ជាសមាធិដែលកើតមួយខណៈៗ កាលកំពុងកំណត់ដឹងសភាវធម៌ រមែងប្រាកដឡើង កាលចិត្តតាំងមាំក្នុងអារម្មណ៍បច្ចុប្បន្ន ដែលជារូបនាមជាបន្តបន្ទាប់ប្រាសចាកនីវរណៈក្នុងខណៈដែលឥន្ទ្រីយ៍ ៥ គឺ សទ្ធាវីរិយៈ សតិ សមាធិ និងបញ្ញា

មានកម្លាំងស្មើគ្នាដល់អ្នកចំរើនវិបស្សនាភាវនា ។

## ចិត្តវិសុទ្ធិរបស់សមាធិយានិក និងវិបស្សនាយានិក

អ្នកដែលចំរើនវិបស្សនា ដោយអាស្រ័យឧបចារសមាធិ ឬ អប្បនាសមាធិ ឈ្មោះថា សមថយានិក គឺ អ្នកធ្វើដំណើរទៅកាន់មគ្គផល និងនិព្វាន ដោយសមថយាន សមាធិទាំង ២ យ៉ាងនោះ ទើបជាចិត្តវិសុទ្ធិដែលជាទីអាស្រ័យរបស់សមថយានិក ។

ចំណែកអ្នកដែលចំរើនវិបស្សនាតែម្យ៉ាង ដោយមិនអាស្រ័យសមថៈទាំង ២ យ៉ាងនោះ ឈ្មោះថា សុទ្ធវិបស្សនាយានិក គឺ អ្នកធ្វើដំណើរទៅកាន់មគ្គផល និងនិព្វានដោយវិបស្សនាសុទ្ធៗ បុគ្គលប្រភេទនេះ មានខណិកសមាធិតែម្យ៉ាង ជាចិត្តវិសុទ្ធិ ។

សេចក្តីដែលពោលមកនេះ ស្របគ្នាជាមួយសាធកៈថា

**ចិត្តវិសុទ្ធិ នាម សឧបចារា អដ្ឋ សមាបត្តិយោ[៤] ។**

“សមាបត្តិ ៨ ព្រមទាំងឧបចារសមាធិឈ្មោះថា ចិត្តវិសុទ្ធិ” ។

ក្នុងទីនេះ លោកមិនបានពោលខណិកសមាធិ ព្រោះត្រូវការនឹងបញ្ជាក់ដល់ការចំរើនភាវនារបស់សមថយានិក ឬ ត្រូវការនឹងសម្តែង

ចិត្តវិសុទ្ធិ ដែលបុគ្គលចម្រើនបានមុននឹងកើតវិបស្សនាញាណ ។

ម្យ៉ាងទៀត ខណិកសមាធិ រមែងកើតឡើងក្នុងវិបស្សនាចិត្តប៉ុណ្ណោះ មិនកើតឡើងក្នុងខាងដើមនៃការបដិបត្តិ តែដែលរាប់រួមខណិកសមាធិនេះ ទុកក្នុងឧបចារសមាធិ ព្រោះស្រដៀងជាមួយឧបចារសមាធិ ដែលប្រាសចាកនីវរណៈ ដូចគ្នានឹងកម្មដ្ឋាន ១២ យ៉ាងមានអនុស្សតិកម្មដ្ឋានជាដើម ដែលរាប់ថា ជាឧបចារសមាធិដូចគ្នា ដូចសេចក្តីក្នុងអដ្ឋកថារបស់មហាសតិប្បដ្ឋានសូត្រថា

**សេសានិ ទ្វាទសាបិ ឧបចារកម្មដ្ឋានានេវ[៥] ។**

"កម្មដ្ឋាន ១២ យ៉ាងដែលសល់ ឈ្មោះថា កម្មដ្ឋានដែលបន្កឲ្យកើតឧបចារសមាធិនោះពិត" ។

កាលកាន់យកសេចក្តីដូច្នេះ សេចក្តីក្នុងគម្ពីរផ្សេង ៗ រមែងស្របគ្នា ដូចសាធកៈក្នុងគម្ពីរវិសុទ្ធិមគ្គមហាដីកាថា

**សមថោវ យានំ សមថយានំ ។ តំ ឯតស្ស អត្ថីតិសមថយានិកោ ។ ឈានេ ឈានូបចារេ វា បតិដ្ឋាយ វិបស្សនំ អនុយុញ្ជន្តស្សេតំ នាមំ ។ សមថយានិកស្ស សមថមុខេន**

វិបស្សនាភិនិវេសោ ។ វិបស្សនាយានិកស្ស បន សមថំ អនិស្សាយាតិ អាហ សុទ្ធវិបស្សនាយានិកោតិ ។ សមថភាវ-នាយអនិស្សិតវិបស្សនាយានវាតិ អត្ថោ ៦ ។

"សមថៈតែម្យ៉ាងជាយាន ឈ្មោះថា សមថយានៗ នោះ មានដល់បុគ្គលណា បុគ្គលនោះ ឈ្មោះថា សមថយានិក ពាក្យនេះអាចហៅអ្នកដែលចំរើនវិបស្សនា ដែលតាំងនៅក្នុងឈាន ឬ សមាធិជិតឈាន ការចំរើនវិបស្សនាដោយមានសមថៈជាបាទ រមែងមានដល់សមថយានិក តែវិបស្សនាយានិក មិនចាំបាច់អាស្រ័យសមថៈទេ ដូច្នេះ ព្រះអដ្ឋកថាចារ្យទើបពោលថា **សុទ្ធវិបស្សនាយានិកោ** ( អ្នកមានត្រឹមតែវិបស្សនាជាយាន ) បានដល់អ្នកមានយាន គឺ វិបស្សនា ដែលមិនចាំបាច់អាស្រ័យសមថភាវនា" ។

សេចក្តីខាងដើមនេះ សំដែងថា អ្នកចម្រើនវិបស្សនាដោយអាស្រ័យសមាធិបន្ទាប់ពីឧបចារៈនិងអប្បនា ឈ្មោះថា សមថយានិក ចំណែកអ្នកចម្រើនវិបស្សនា ដោយមិនចាំបាច់អាស្រ័យសមាធិទាំង ២ យ៉ាងនោះ ឈ្មោះថា សុទ្ធវិបស្សនាយានិក ដូចពាក្យថា

ទេវទត្តោ ទិវា ន កុត្តោ ចូឡោ ។

( ទេវទត្តមិនបានចង្អាន់ពេលថ្ងៃ តែលោកជាមនុស្សជាត់ ) ។

ពាក្យនេះ សំដៅដល់ការបានចង្អាន់ពេលយប់ដោយបរិយាយ ដូច្នេះ សុទ្ធវិបស្សនាយានិក ទើបអាស្រ័យខណិកសមាធិជាគោល ក្នុងការចំរើនវិបស្សនា គម្ពីរវិសុទ្ធិមគ្គមហាដីកា ពោលដល់សមាធិ ប្រភេទនេះថា

សមថយានិកស្ស ហិ ឧបចារប្បនាភេទំ សមាធឹ ឥតរស្ស ខណិកសមាធឹ ឧភយេសម្បិ វិមោក្ខមុខត្តយំ វិនា ន កទាចិបិ លោកុត្តរាធិគមោ សម្ភវតិ ។ តេនាហ សមាធិញ្ចេវ វិបស្សនញ្ច ភាវយមានោតិ[៧] ។

"ពិតហើយ ការសម្រេចលោកុត្តរធម៌ រមែងមិនមានដល់ សមថយានិក ដោយប្រាសចាកសមាធិ ដែលចែកជាឧបចារៈ និង អប្បនា ការសម្រេចលោកុត្តរធម៌ រមែងមិនមានដល់វិបស្សនាយានិក ដោយប្រាសចាកខណិកសមាធិ និងការសម្រេចលោកុត្តរធម៌ រមែងមិនមានដល់បុគ្គលទាំង ២ ដោយប្រាសចាកផ្លូវកាន់វិមោក្ខ ៣

( អនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ) ដូច្នោះលោកទើបពោលថា សមាធិញ្ច វិបស្សនញ្ច ភាវយមានោ ( អប់រំសមាធិ និងវិបស្សនា )" ។

ម្យ៉ាងទៀត ដើម្បីឲ្យយល់ចូលចិត្តក្នុងរឿងនេះយ៉ាងជាក់ច្បាស់ ទើងនាំសេចក្ដីអំពីគម្ពីរអដ្ឋកថា មកអធិប្បាយរួមគ្នាជាមួយពាក្យអធិប្បាយរបស់ព្រះដីកាចារ្យ ពោលគឺ ក្នុងគម្ពីរវិសុទ្ធិមគ្គមានគាថាផ្ដើមថា

សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ^៩ ។

"ភិក្ខុជាអ្នកខ្ជាត មានសេចក្ដីព្យាយាម មានបញ្ញាឈ្លៀវឈ្លាសតាំងនៅក្នុងសីលហើយ អប់រំចិត្តនិងបញ្ញានោះ គប្បីកាប់ធ្លារព្រៃក្រាស់នេះបាន" ។

ព្រះតម្រាស់ថា ចិត្តំ បញ្ញញ្ច ភាវយំ ( អប់រំចិត្តនិងបញ្ញា ) សម្ដែងនូវវិធីបដិបត្តិដើម្បីកាប់ធ្លារព្រៃក្រាស់ គឺ តណ្ហា ពាក្យថា "ចិត្ត" ក្នុងទីនេះសំដៅដល់សមាធិ ចំណែកពាក្យថា "បញ្ញា"

សំដៅដល់ វិបស្សនាបញ្ញា ដូចគម្ពីរអដ្ឋកថា អធិប្បាយថា

ចិត្តំ បញ្ញញ្ច ភាវយន្តិ សមាធិញ្ចេវ ភាវយមានោ ។ ចិត្តសី-
លេន ហេតុ សមាធិ និទ្ទិដ្ឋោ ។ បញ្ញានាមេន ច វិបស្សនាតិ ។

“បាទគាថាថា **ចិត្តំ បញ្ញញ្ច ភាវយំ** ( អប់រំចិត្តនិងបញ្ញា )
សេចក្តីថា អប់រំសមាធិ និងវិបស្សនា ដោយពិតហើយ សមាធិ
សម្តែងទុកដោយមានចិត្តជាប្រធាន និងវិបស្សនាបញ្ញា ក៏សម្តែងទុក
ដោយឈ្មោះថា បញ្ញា” ។

សេចក្តីនេះ មានន័យថា អ្នកចំរើនសមាធិ និងវិបស្សនា រមែង
នឹងកាប់ច្ការព្រៃក្រាស់ គឺ តណ្ហាបាន ពោលគឺ ជាព្រះអរហន្តអ្នក
ប្រាសចាកតណ្ហា ដោយគ្មានសេសសល់ ។

ពាក្យអធិប្បាយ ក្នុងគម្ពីរអដ្ឋកថានេះ លោកមិនបានបញ្ជាក់ថា
បុគ្គលណា គួរចំរើនសមាធិប្រភេទណា នឹងហេតុណា ទើបគួរចំរើន
សមាធិ និងបញ្ញារួមចូលគ្នា ដូច្នេះ គម្ពីរដីកាទើបអធិប្បាយដោយ
ចែកជាសមថយានិក និងសុទ្ធវិបស្សនាយានិក ដូចដែលបាននាំមក
បែងចែកទុកហើយ ។

ក្រៅអំពីនេះ ព្រះដីកាចារ្យ ក៏នៅបានអធិប្បាយបំពេញថែម ថា សមថយានិកត្រូវចំរើនឧបចារសមាធិឬអប្បនាសមាធិយ៉ាងណា និមួយ ទើបនឹងសម្រេចមគ្គផលបាន ចំណែកវិបស្សនាយានិក ត្រូវចំរើនខណិកសមាធិប៉ុណ្ណោះ ទើបសម្រេចធម៌បាននិងបុគ្គល ទាំងពីរប្រភេទ ត្រូវចំរើនអនុបស្សនា ៣ ដែលហៅថា វិមោក្ខមុខ ( ផ្លូវកាន់វិមោក្ខ ) ទើបសម្រេចធម៌បានដោយប្រការដូច្នេះ អ្នក បដិបត្តិគប្បីចំរើនសមាធិ ៣ យ៉ាង និងអនុបស្សនា ៣ យ៉ាងតាម សមគួរ ទើបនឹងសម្រេចធម៌ និងកាប់ច្ការព្រៃស្អុក គឺតណ្ហាបាន បើមិនចំរើនសមាធិ និងវិបស្សនា ដូចដែលពោលមកនេះទេ ក៏មិន អាចសម្រេចមគ្គផល និងកាប់ច្ការតណ្ហាបាន ដូចព្រះអដ្ឋកថាចារ្យ ពោលថា

សមាធិញ្ច វិបស្សនញ្ច ការយមានោ

( អប់រំសមាធិ និងវិបស្សនា ) ។

## វិធីចំរើនមគ្គ ២ ប្រការ

តាមសេចក្ដីក្នុងគម្ពីរមេឃកាដីកានេះសម្ដែងថា វិបស្សនាយានិក មិនចាំបាច់ត្រូវចំរើនឧបចារសមាធិ ឬអប្បនាសមាធិ ចំរើនត្រឹមតែខណិកសមាធិប៉ុណ្ណោះ និងខណិកសមាធិ ក៏អាចធ្វើឲ្យកើតចិត្តវិសុទ្ធិរហូតចូលដល់សម្រេចមគ្គផលបាន ។ សូមនាំសាធក: អំពីអដ្ឋកថា របស់មូលបណ្ណាសក: ធម្មទាយាទសូត្រមកសម្ដែងទុកក្នុងទីនេះ

*ភាវនានយោតិ កោចិ សមថបុព្វង្គមំ វិបស្សនំ ភាវេតិ ។ កោចិ វិបស្សនាបុព្វង្គមំ សមថំ ។ កថំ ។ ឥធេកច្ចោ បឋមំ ឧបចារសមាធឹ វា អប្បនាសមាធឹ វា ឧប្បាទេតិ ។ អយំ សមថោ ។ សោ តញ្ច តំសម្បយុត្តេ ច ធម្មេ អនិច្ចាទីហិ វិបស្សតិ ។ អយំ វិបស្សនា។ ឥតិ បឋមំ បច្ឆា វិបស្សនា ។ តេន វុច្ចតិ សមថបុព្វង្គមំ ភាវេតីតិ។ តស្ស សមថបុព្វង្គមំ វិបស្សនំ ភាវយតោ មគ្គោ សញ្ជាយតិ*[10]។

"ពាក្យថា *ភាវនានយោ* ( វិធីចំរើនភាវនា ) សេចក្ដីថា ព្រះយោគីពួកខ្លះ ចំរើនវិបស្សនា ដោយមានសមថ:ជាបាទ អ្នកខ្លះចំរើន

សមថៈ ដោយមានវិបស្សនាជាបុរេ" ។

សួរថា : ចំរើនយ៉ាងណា ?

ឆ្លើយថា: បុគ្គលពួកខ្លះ ក្នុងព្រះសាសនានេះ រមែងបដិបត្តិឲ្យកើតខណិកសមាធិ ឬ ឧបចារសមាធិជាមុនសិន សមាធិទាំងពីរនេះឈ្មោះថា សមថៈ គេរមែងកំណត់ដឹងសមាធិ ឬធម៌[ គឺចិត និងចេតសិក] ដែលកើតព្រមគ្នាជាមួយសមាធិនោះ ដោយសភាពមិនទៀងជាដើម បញ្ញាដែលកំណត់ដឹងនេះ ឈ្មោះថា វិបស្សនា កាលគេកំពុងចំរើនដូច្នេះ សមថៈរមែងកើតមុន វិបស្សនារមែងកើតជាខាងក្រោយ ដូច្នេះ លោកទើបពោលថា ( ចំរើនវិបស្សនាដោយមានសមថៈជាបុរេ ) កាលគេចំរើនវិបស្សនា ដោយមានសមថៈជាបុរេមគ្គរមែងកើតឡើង " ។

វិធីចំរើនភាវនា ដែលពោលទុកខាងដើម ជាន័យដំបូង ដែលពោលដល់ សមថយានិក ដូចគម្ពីរដីកាអធិប្បាយថា

**បឋមោ សមថយានិកស្ស វសេន វុត្តោ[១១] ។**

"ន័យដំបូងពោលទុកដោយជាប់ទាក់ទិនដោយសមថយានិក" ។

ពាក្យពោលដែលថា "គេរមែងកំណត់សមាធិ ឬធម៌[ គឺចិត្តនិងចេតសិក] ដែលកើតព្រមគ្នាជាមួយនឹងសមាធិនោះ ដោយសភាពមិនទៀងជាដើម" សម្តែងវិធីការចំរើនវិបស្សនារបស់សមថយានិកថា គេគួរកំណត់ដឹងសមថៈ ឬចិត្តចេតសិក មានបីតិចេតសិកជាដើម ដែលកើតព្រមជាមួយសមាធិ ។

សូម្បីពាក្យពោលថា "ដោយសភាពមិនទៀងជាដើម" នឹងបញ្ជាក់ដល់វិបស្សនាញាណតាំងអំពីសម្មសនញាណជាដើមទៅ ដោយភាពជាត្រៃលក្ខណ៍ ចំណែកវិបស្សនាញាណពីរយ៉ាងដំបូង គឺនាមរូបបរិច្ឆេទញាណ ( បញ្ញាដែលកំណត់ដឹងការចែករូបនិងនាម ) និងបច្ចយបរិគ្គហញាណ ( បញ្ញាដែលកំណត់ដឹងហេតុបច្ច័យរបស់នាម ) ក៏បានទទួលការពោលទុកដោយបរិយាយ ។ ពិតមែនហើយញាណទាំងពីរនេះ មិនបានកើតមុនពេលដែលចំរើនភាវនា សូម្បីអនិច្ចានុបស្សនាជាដើម ក៏កើតឡើងមិនបានដោយប្រាសចាកញាណខាងដើម សេចក្តីថាសមថយានិកបានចំរើនសមថៈហើយកំណត់ដឹងរូបនាមដោយញាណទាំងពីរនេះ បន្ទាប់អំពីនោះទើបកំណត់ដឹង

ដោយភាពមិនទៀងជាដើម ។ ដូច្នេះ ពាក្យនេះទើបជាសំនួនភាសាម្យ៉ាងដែលហៅថា បធាននន័យ គឺសំនួនដែលពោលដល់វត្ថុដែលជាប្រធាន តែបំណងឲ្យដល់វត្ថុដទៃៗ ដែលមិនមែនជាប្រធាននៅក្នុងទីនេះ ជាការពោលដល់វត្ថុដែលជាប្រធានគឺ អនិច្ចានុបស្សនាជាដើម តែចេតនាបំណងរួបរួមដល់ញាណទាំងពីរខាងដើមទៀតផង ។ ដូចពាក្យថា រាជា អាគច្ឆតិ ( ព្រះរាជាស្តេចយាងមក ) ដែលសំដៅដល់ការស្តេចយាងមកនៃព្រះរាជានិងរាជបរិវារដទៃៗ បើកាន់យកថា អនិច្ចានុបស្សនាជាដើម កើតបានមុនវិបស្សនាញាណពីរយ៉ាងដំបូង ក៏នឹងជំទាស់ជាមួយគម្ពីរបដិសម្ភិទាមគ្គ និងគម្ពីរដទៃៗ[១២] ដែលបានពោលដល់វិបស្សនាញាណ ពួកនោះជាលំដាប់ដំបូង ។

ចំណែកវិបស្សនាយានិកមានវិធីបដិបត្តិដូចតទៅនេះ

ឥធ បនេកច្ចោ វុត្តប្បការំ សមថំ អនុប្បាទេត្វាវ បញ្ចុប្បាទានក្ខន្ធេ អនិច្ចាទីហិ វិបស្សតិ ។ អយំ វិបស្សនា ។ តស្ស វិបស្សនាបរិបូរិយា តត្ថ ជាតានំ ធម្មានំ វោសគ្គារម្មណតោ ឧប្បជ្ជតិ

ចិត្តស្ស ឯកគ្គតា ។ អយំ សមថោ ឥតិ បឋមំ វិបស្សនា, បច្ឆា សមថោ ។ តេន វុច្ចតិ វិបស្សនាបុព្វង្គមំ សមថំ ភាវេតីតិ ។ តស្ស វិបស្សនាបុព្វង្គមំ សមថំ ភាវយតោ មគ្គោ សញ្ជាយតិ ។ សោ តំ មគ្គំ ភាវេតិ ពហុលីករោតិ ។ តស្ស តំ មគ្គំ អាសេវតោ ភាវយតោ ពហុលីករោតោ បហីយន្តិ ។ អនុសយា ព្យន្តី ហោន្តិ[១៣]។

“ចំណែកព្រះយោគីពួកខ្លះ ក្នុងព្រះសាសនានេះ មិនបានចំរើន សមថៈ តាមប្រភេទដែលពោលទុកហើយ រមែងកំណត់ដឹង ឧបាទានក្ខន្ធ ៥ ដោយសភាពមិនទៀងជាដើម បញ្ញានេះ ឈ្មោះថា វិបស្សនា កាលមានសេចក្ដីបរិបូណ៌នៃវិបស្សនាសមាធិ ដែលធ្វើចិត្ត ឲ្យមានអារម្មណ៍តែមួយ [សម្មាសមាធិមគ្គ] រមែងកើតឡើងដល់គេ ព្រោះធម៌[គឺចិត្តនិងចេតសិក]ដែលកើតឡើងក្នុងវិបស្សនាចិត្តនោះ លះបង់អារម្មណ៍ខាងក្រៅចេញបាន សមាធិនេះ ឈ្មោះថា សមថៈ ដោយប្រការដូច្នេះ ។ វិបស្សនារមែងកើតមុន សមថៈរមែងកើតក្នុង ពេលខាងក្រោយ ដូច្នេះទើបពោលថា ( ចំរើនសមថៈ ដោយមាន វិបស្សនាជាមុខ ) កាលគេចំរើនសមថៈ ដែលមានវិបស្សនាជាមុខ

មគ្គរមែងកើតឡើង គេសេពចំរើនអប់រំមគ្គនោះ កាលគេកំពុងសេព ចំរើនអប់រំមគ្គនោះ រមែងបេះបង់សំយោជនៈបាន អនុស័យក៏រមែងអស់ទៅ" ។

ព្រះដីកាចារ្យអធិប្បាយទុកក្នុងគម្ពីរដីកា[១៤]ថា វិបស្សនាយានិក មិនបានចំរើនសមថកម្មដ្ឋាន បានបន្ទុះឧបចារសមាធិ ឬអប្បនាសមាធិមកមុន តែចាប់ផ្ដើមចំរើនខណិកសមាធិជាលំដាប់ដំបូង នឹងញ៉ាំងឲ្យកើតនាមរូបបរិច្ឆេទញាណ និងបច្ចយបរិគ្គហញាណ ដែលសម្ដែងទុកដោយបធាននយ័ ហើយទើបកំណត់ដឹងរូបនាមដោយសភាពមិនទៀង ។ល។ តាំងតែអំពីសម្មសនញាណជាដើមទៅ ។

ក្រៅអំពីនេះ លោកបានអធិប្បាយបំពេញសេចក្ដីថា កាលវិប-ស្សនាចាស់ក្លាហើយសមថៈ គឺសមាធិទើបកើតឡើងបានវិបស្សនាដែលចាស់ក្លា គឺវុដ្ឋានគាមិនីវិបស្សនា ចំណែកសមថៈ ក្នុងទីនេះគឺមគ្គសមាធិ តែក្នុងសមថបុព្វង្គមនយ័ ( នយ័ដែលមានសមថៈកើតមុន ) សមថៈដែលកើតមុន និងវិបស្សនាដែលកើតខាងក្រោយជាលោកិយធម៌ដូចគ្នាយ៉ាងណា សូម្បីក្នុងវិបស្សនាបុព្វង្គមនយ័

( ន័យដែលមានវិបស្សនាកើតមុន ) វិបស្សនាដែលកើតមុន និងសមថៈដែលកើតក្នុងពេលខាងក្រោយ ក៏គួរជាលោកិយធម៌ដូចគ្នាដូច្នោះ ដោយហេតុនេះ សមថៈក្នុងទីនេះ ទើបគួរជាខណិកសមាធិដែលប្រកបជាមួយវិបស្សនាញាណ សូម្បីគម្ពីរអដ្ឋកថាអង្គុត្តរនិកាយក៏ពោលថា

*វិបស្សនំ បុព្វង្គមំ បុរេចារិកំ កត្វា សមថំ ភាវេតិ ។ បកតិយា វិបស្សនាលាភី វិបស្សនាយ ឋត្វា សមាធឹ ឧប្បាទេតីតិ អត្ថោ*[៥] ។

"អ្នកបំពេញព្យាយាម ធ្វើវិបស្សនាឲ្យជាខាងដើម គឺ ធ្វើឲ្យកើតឡើងមុនហើយចម្រើនសមាធិ បានសេចក្តីថា អ្នកសម្រេចវិបស្សនាញាណដោយប្រក្រតី និងតាំងនៅក្នុងវិបស្សនាហើយទើបកើតសមាធិ " ។

## វិបស្សនាញាណ ៣ លំដាប់

ម្យ៉ាងទៀត វិបស្សនាញាណបែងចេញជា ៣ លំដាប់គឺ

១. ញាណថ្នាក់ខ្ពស់ សំដៅដល់ភង្គញាណជាដើមទៅ ខណិក-សមាធិ ដែលប្រកបដោយញាណ នេះជាសមាធិចាស់ក្លា ដូច

សេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គ[១៦]ថា **វយលក្ខនោបដ្ឋានេកត្ត** ( ការតាំងមាំដែលប្រាកដដោយលក្ខណៈរលត់ទៅ ) និងសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គ[១៧]ដែលសម្តែងរឿងភង្គញាណ ។

២. ញាណថ្នាក់កណ្តាល សំដៅដល់ ឧទយព្វយញ្ញាណ ខណិកសមាធិដែលប្រកបដោយញាណនេះ ជាសមាធិថ្នាក់កណ្តាល ដូចគម្ពីរវិសុទ្ធិមគ្គ[១៨]ពោលដល់ញាណនេះថា **តរុណវិបស្សនា** ( វិបស្សនាដែលនៅមិនទាន់ចាស់ក្លា ) នឹងពោលដល់អ្នកដែលចូលដល់ព្រមដោយញាណនេះថា **អារទ្ធវិបស្សកៈ** ( អ្នកប្រារព្ធវិបស្សនា ) ទាំងស្របជាមួយព្រះបាលី[១៩] ដែលពោលដល់អង្គគុណរបស់អ្នកបដិបត្តិ ( បធានិយង្គៈ ) ៥ប្រការ ក្នុងសេចក្តីទីបំផុតថា ជាអ្នកតាមឃើញការកើតឡើងនិងរលត់ទៅ ជាការពិតហើយ ញាណនេះជាវិបស្សនាញាណជាន់ដំបូងក្នុងញាណដែលចាស់ក្លាបរិបូណ៌ ។

៣. ញាណថ្នាក់ក្រោម សំដៅដល់ នាមរូបបរិច្ឆេទញាណ និងបច្ចយបរិគ្គហញាណ ខណិកសមាធិដែលប្រកបដោយញាណនេះ ជាសមាធិជាន់ទាប តែយ៉ាងណាក៏ដោយ នីវរណៈ ៥ យ៉ាង រមែងមិនកើតឡើងក្នុងខណៈដែលកំណត់ដឹងសភាវធម៌ ក្នុងខណៈ

នោះ វិបស្សនាចិត្តនឹងបរិសុទ្ធប្រាសចាកនីវរណៈ ។ ញាណទាំងពីរនេះ ទើបកើតឡើងឃើញច្បាស់សភាវលក្ខណៈ គឺ លក្ខណៈចំពោះនៃរូបនាមបាន ស្ទើរខណិកសមាធិក្នុងញាណលំដាប់នេះ ក៏មានកម្លាំង ប្រៀបដូចជាមួយឧបចារសមាធិដូចគ្នា បើមិនដូច្នោះ ក៏មិនអាចឃើញ ច្បាស់រូបនាមតាមសេចក្ដីពិត សមាធិនេះ ទើបចាត់ជាចិត្តវិសុទ្ធិ ដែលឧបការៈដល់ញាណទាំងពីរនោះ ដូចសេចក្ដីថា

យោ តត្ថ អវិក្ខេបដ្ឋោ, អយំ អធិចិត្តសិក្ខា[២០] ។

"សភាពដែលមិនរាករេក្នុងវិបស្សនាចិត្ត ដែលប្រកបជាមួយនាមរូបបរិច្ឆេទញាណ និងបច្ចយបរិគ្គហញាណនោះ ឈ្មោះថា អធិចិត្តសិក្ខា" ។

យំ នាមរូបរិច្ឆេទាទីសុ វិបស្សនាញាណេសុ បដិបក្ខភាវតោ ទីបាលោកេនេវ តមស្ស តេន តេន វិបស្សនាញាណេន តស្ស តស្ស អនត្ថស្ស បហានំ ។ សេយ្យថីទំ ។ នាមរូបវវត្ថានេន សក្កាយទិដ្ឋិយា បច្ចយបរិគ្គហេន អហេតុវិសមហេតុទិដ្ឋីនំ ។បេ។ គោត្រភុនា សង្ខារនិមិត្តគ្គាហស្ស បហានំ ។ ឯតំ តទង្គប្បហានំ

នាម[២១]។

"ក្នុងបណ្ដាវិបស្សនាញាណ មាននាមរូបបរិច្ឆេទញាណជាដើម ការលះបង់ទោសនោះ ៗ រមែងមានដោយវិបស្សនាញាណនោះ ៗ ព្រោះជាបដិបក្ខនឹងគ្នា ដូចការកំចាត់ភាពងងឹតដោយពន្លឺប្រទីបពោល គឺ ការលះសក្កាយទិដ្ឋិ ដោយការកំណត់ដឹងរូបនាម ការលះទិដ្ឋិដែលយល់ថាមិនមានហេតុ ឬយល់ថាមានហេតុដែលមិនសមគួរ ដោយការកំណត់ដឹងបច្ច័យ ។ល។ ការលះសេចក្ដីប្រកាន់មាំក្នុងអារម្មណ៍ដែលជាសង្ខារធម៌ដោយគោត្រភូទាំងអស់នេះ ឈ្មោះថា តទង្គបហាន ( ការលះដោយហេតុ គឺ វិបស្សនានោះ ៗ )" ។

កាលខណិកសមាធិចាស់ក្លាឡើងៗ ការតាំងមាំនៃចិត្តដូចជាឈានក្នុងសមថភាវនា រមែងកើតឡើង សូម្បីអារម្មណ៍ដែលជារូបនាម នឹងផ្លាស់ប្ដូរទៅតាមសភាវៈប្រាកដច្បាស់ការតាំងមាំក៏ស្ថិតនៅយ៉ាងនោះ លំដាប់ចិត្តដែលកើតមុន និងលំដាប់ចិត្តដែលកើតក្នុងពេលខាងក្រោយមានកម្លាំងស្មើគ្នា សមាធិដូចពោលមកនេះ ផ្សេងគ្នាអំពីឈានក្នុងសមថភាវនា គឺឈានក្នុងសមថភាវនាទទួលដឹងអារម្ម-

ណ៍បញ្ញត្តិតែម្យ៉ាងមិនប្រាកដសភាពជារូបនាមទាំងប្រាសចាកសភាវៈ របស់ត្រៃលក្ខណ៍ តែសមាធិរបស់វិបស្សនាទទួលដឹងអារម្មណ៍ បច្ចុប្បន្ន ដែលផ្លាស់ប្តូរទៅខ្វះ ទាំងប្រាកដសភាពជារូបនាមកាល ញាណចាស់ក្លាឡើង ក៏នឹងប្រចក្សព្រះត្រៃលក្ខណ៍ ដែលឃើញច្បាស់ នូវសភាវៈកើតរលត់ជាដើម ។ ដូចសេចក្តីក្នុងគម្ពីរមហាដីកាថា

**ខណិកចិត្តេកគ្គតាតិ ខណមត្តដ្ឋិតិកោ សមាធិ ។ សោបិ ហិ អារម្មណេ និរន្តរំ ឯកាការេន បវត្តមានោ បដិបក្ខេន អនភិភូតោ អប្បិតោ វិយ ចិត្តំ និច្ចលំ ឋបេតិ**[២] ។

“ពាក្យថា **ខណិកចិត្តេកគ្គតា** ( ការតាំងនៅនៃចិត្តមួយខណៈ ) មានសេចក្តីថា សមាធិដែលតាំងនៅមួយខណៈ ដោយពិតហើយ សមាធិនោះត្រាច់ទៅក្នុងអារម្មណ៍ ដោយអាការៈតែម្យ៉ាងជាប់បន្ត មិនត្រូវនីវរណៈ ដែលជាបដិបក្ខគ្របសង្កត់ រមែងតាំងចិត្តទុកមាំ ដូចឈានសមាធិ ដែលឈានចុះហើយ”។

សេចក្តីខាងដើម ជាពាក្យអធិប្បាយ ដែលព្រះដីកាចារ្យគាំទ្រ សេចក្តីក្នុងគម្ពីរអដ្ឋកថារបស់មហាសតិប្បដ្ឋានសូត្រ ដែលពោលថា

វិបស្សនាចិត្តតាំងមាំបានដោយខណិកសមាធិ ក្នុងកាលចំរើនអានាបានៈថា **ចិត្តំ សមាទហតោ** ( អ្នកតាំងចិត្តទុកមាំ )[២៣] ដោយបង្ហាញឲ្យឃើញថា ក្រៅអំពីសមាធិដែលជាឧបចារៈ និងអប្បនាហើយ សូម្បីវិបស្សនាខណិកសមាធិក៏អាចតាំងចិត្តទុកមាំបានដូចគ្នា ។

ពាក្យថា **អារម្មណេ និរន្តរំ ឯកាការេន បវត្តមានោ** ( ត្រាច់ទៅក្នុងអារម្មណ៍ដោយអាការៈតែម្យ៉ាងជាប់តគ្នា )សម្ដែងថា កាលខណិកសមាធិមានកម្លាំងស្មើគ្នាជាមួយឧបចារសមាធិ នីវរណៈ ៥ នោះ មិនអាចកើតឡើងទេ ការកំណត់ដឹងរមែងប្រព្រឹត្តទៅយ៉ាងបន្តបន្ទាប់ជានិច្ច ។

ពាក្យថា **បដិបក្ខេន អនភិភូតោ អប្បិតោ វិយ ចិត្តំ និច្ចលំ ឋបេតិ** ( មិនត្រូវនីវរណៈ ដែលជាបដិបក្ខគ្របសង្កត់ រមែងតម្កល់ចិត្តទុកមាំដូចឈានសមាធិដែលឈានចុះហើយ ) សេចក្ដីថា ខណិកសមាធិ ដែលកើតព្រមជាមួយឧទយព្វយញ្ញាណ និងភង្គញាណជាដើមទៅមានកម្លាំងច្រើនជាងខណិកសមាធិក្នុងញាណ

ដើមៗ ដោយមានកម្លាំងស្មើនឹងអប្បនាសមាធិ ក្នុងសមថការទា ខណិកសមាធិនេះមិនត្រូវនីវរណៈរុករាន នឹងអាចឲ្យចិត្តតាំងមាំ ដូចជាអប្បនាសមាធិដែរ ។

សរុបសេចក្តីមក វិបស្សនាយានិក មិនចំរើនឧបចារសមាធិ ឬអប្បនាសមាធិចាប់ផ្តើមចំរើនវិបស្សនាដោយកំណត់ដឹងសភាវធម៌ដែលជារូបនាមបានទាន់ពេល តមកវិបស្សនាញាណរមែងកើតឡើង កាលវិបស្សនាញាណចាស់ក្លាឡើង តាំងតែអំពីឧទ្ទយ-ព្វយញ្ញាណជាដើមទៅ ហើយសមាធិក៏នឹងតាំងនៅមាំជាងខាងដើម ។ សេចក្តីដែលសម្តែងដល់សមថបុព្វង្គមន័យ និងវិបស្ស-នាបុព្វង្គមន័យដែលឃើញក្នុងគម្ពីរអដ្ឋកថា ដូចដែលពោល មកនេះស្របគ្នាជាមួយសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គថា

រូបំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា ។ រូបំ ទុក្ខតោ អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា ។ តត្ថ ជាតានំ ធម្មានំ ច វោសគ្គា-រម្មណតា ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ។ ឥតិ បឋមំ វិបស្សនា, បច្ឆា សមថោ ។ តេន វុច្ចតិ វិបស្សនាបុព្វង្គមំ សមថំ

កាវេតិតិ[២៤] ។

"ឈ្មោះថា វិបស្សនា ព្រោះជាសភាវៈឃើញរូបថា ជារបស់មិនទៀង ព្រោះជាសភាពឃើញរូបថា ជាទុក្ខ មិនមែនតួខ្លួន ការលះអារម្មណ៍ខាងក្រៅ ការមានអារម្មណ៍តែមួយនៃចិត្ត ការមិនរាករនៃធម៌ [គឺចិត្ត និងចេតសិក] ដែលកើតក្នុងវិបស្សនាចិត្តនោះ ឈ្មោះថា សមថៈដោយប្រការ ដូច្នេះ វិបស្សនារមែងកើតមុន ឯសមថៈរមែងក្នុងពេលខាងក្រោយ ទើបពោលថា ( ចំរើន សមថៈ ដោយមានវិបស្សនាជាបុរេ )"។

ក្រៅអំពីសមថបុព្វង្គមន័យ និងវិបស្សនាបុព្វង្គមន័យហើយ ក្នុងគម្ពីរបដិសម្ភិទាមគ្គ[២៥]នៅពោលដល់យុគនទ្ធន័យ គឺ ន័យប្រកបចូលគ្នាជាគូ និងធម្មុទ្ធច្ចបហានន័យ គឺន័យដែលលះបង់សេចក្តីរវើរវាយក្នុងសភាវធម៌ ន័យទាំងពីរនេះរាប់ក្នុងសមថ-បុព្វង្គមន័យនិងវិបស្សនាបុព្វង្គមន័យដូចគ្នា ក្នុងគម្ពីរអដ្ឋកថា ទើបសម្តែងទុកត្រឹមតែពីរន័យប៉ុណ្ណោះ ។

យុគនទ្ធន័យ ប្រែថា "ន័យប្រកបចូលគ្នាជាគូ" សំដៅដល់

អ្នកបដិបត្តិអ្នកបន្ទះឈានបានចំរើនសមថៈ និងវិបស្សនាផ្គួបចូលគ្នាទៅតាមលំដាប់ឈាន ដោយចូលបឋមជ្ឈានហើយចំរើនវិបស្សនាកំណត់ដឹងឈានចិត្ត ក្រោយអំពីនោះទើបចូលទុតិយជ្ឈាន ហើយកំណត់ដឹងឈានចិត្តទៀត គេចូលឈានតាមលំដាប់ព្រមជាមួយការចំរើនវិបស្សនា កាលចេញអំពីឈាននោះៗ រហូតបន្ទះមគ្គ ន័យនេះរាប់ចូលក្នុងសមថបុព្វង្គមន័យ ព្រោះចំរើនវិបស្សនាដោយមានសមថៈជាបាទ ។

ធម្មុទ្ធច្ចបហានន័យ ប្រែតាមស័ព្ទថា "ន័យលះសេចក្ដីសង្ស័យក្នុងសភាវធម៌" សំដៅដល់កាលវិបស្សនូបកិលេស គឺ ឱភាស (ពន្លឺ) ជាដើម កើតឡើងក្នុងខណៈបន្ទះឧទ្ទយព្វយញ្ញាណដល់សមថយានិក ឬវិបស្សនាយានិកខណៈនោះ អ្នកបដិបត្តិអាចយល់ខុសថា ឱភាសជាដើមនោះជាគុណធម៌វិសេស គឺ មគ្គផលនិងសំគាល់ថា ខ្លួននោះបានសម្រេចមគ្គផល ហើយការសំគាល់ដូច្នេះជាសេចក្ដីរវើរវាយក្នុងសភាវធម៌ កាលកើតសេចក្ដីរវើរវាយយ៉ាងនេះរូបនាមដែលធ្លាប់ប្រាកដច្បាស់ ក៏មិនប្រាកដច្បាស់ការកំណត់ដឹង

រមែងជាប់មិនដាច់បន្តគ្នា ក្នុងខណៈនោះ អ្នកបដិបត្តិមិនគួរធ្វើទុកក្នុងចិត្តចំពោះឱកាសជាដើម តែគួរកំណត់ដឹងរូបនាមដូចដើមវិញ កាលកំណត់ដូច្នេះ សេចក្ដីរវើរវាយក្នុងសភាវធម៌ នឹងអន្តរធានទៅ ។ រូបនាមរមែងប្រាកដច្បាស់ដូចគ្រាមុន ការកំណត់ដឹង និងតាំងនៅមាំក្នុងរូបនាមដែលជាអារម្មណ៍ខាងក្នុងប៉ុណ្ណោះ ក្រៅអំពីនោះ វិបស្សនាញាណរមែងចាស់ក្លាតាមលំដាប់រហូតដល់សម្រេចមគ្គញាណ នយដូចដែលពោលនេះ រាប់ចូលក្នុងសមថបុព្វង្គមនយ និងវិបស្សនាបុព្វង្គមនយទាំងពីរយ៉ាង ព្រោះជាប់ទាក់ទងដោយសមថយានិក និងវិបស្សនាយានិក ព្រះអដ្ឋកថាចារ្យ ទើបពោលដល់ការនានយទុកពីរប្រការប៉ុណ្ណោះ ។

ដោយហេតុនេះ វិបស្សនាយានិក ទើបមិនចាំបាច់ត្រូវចំរើនសមថភាវនា ដើម្បីឲ្យកើតចិត្តវិសុទ្ធិ តែគួរចំរើនវិបស្សនាបានគ្រប់ពេល និងខណិកសមាធិដែលកើតឡើងកាលវិបស្សនាញាណចាស់ក្លា ក៏ជាចិត្តវិសុទ្ធិរបស់បុគ្គលនោះ ។

## គ្រឿងរារាំងផ្លូវរួចផុតទុក្ខ ៨ ប្រការ

ដោយហេតុដូចដែលគម្ពីរនេះ ណែនាំការចំរើនវិបស្សនារបស់វិបស្សនាយានិក ឥឡូវនេះនឹងសម្តែងដល់គ្រឿងរាំងផ្លូវរួចផុត ៨ ប្រការ ដែលឧបត្ថម្ភគាំទ្រដល់អ្នកចំរើនខណិកសមាធិដែលប្រកបជាមួយវិបស្សនាញាណ គ្រឿងរាំងផ្លូវរួចផុតទុក្ខពួកនោះ គឺ

១. កាមច្ឆន្ទៈ ( សេចក្តីត្រេកអរពេញចិត្តក្នុងកាម ) ។

២. ព្យាបាទៈ ( សេចក្តីមិនពេញចិត្តការក្រោធ ការចងគំនុំ )។

៣. ថីនមិទ្ធៈ ( ការងងុយងោកងក់ ) ។

៤. ឧទ្ធច្ចកុក្កុច្ចៈ ( សេចក្តីរាយមាយក្តៅក្រហាយចិត្ត ) ។

៥. វិចិកិច្ឆា ( សេចក្តីសង្ស័យ ) ។

៦. អវិជ្ជា ( សេចក្តីមិនដឹង ) ។

៧. អរតិ ( សេចក្តីមិនត្រេកអរ[ក្នុងការនៅ])។

៨. អកុសលធម៌ទាំងពួង ។

មានសេចក្តីក្នុងគម្ពីរ អាធាបានកថា នៃគម្ពីរបដិសម្ភិទាមគ្គ តាមលំដាប់ ដូច្នេះ ៖

## ១. កាមច្ឆន្ទៈ

នេក្ខម្មំ អរិយានំ និយ្យានំ ។ តេន ច នេក្ខម្មេន អរិយា និយ្យន្តិ ។ កាមច្ឆន្ទោ និយ្យានាវរណំ ។ តេន ច កាមច្ឆន្ទេន និវុតត្តា នេក្ខម្មំ អរិយានំ និយ្យានំ នប្បជានាតីតិ កាមច្ឆន្ទោ និយ្យានាវរណំ[២៦] ។

"វិបស្សនាកុសល ជាផ្លូវរួចផុតចាកទុក្ខ របស់ព្រះអរិយៈទាំងឡាយ ព្រោះព្រះអរិយៈរមែងរួចផុតទុក្ខ ដោយវិបស្សនាកុសលនោះ កាមច្ឆន្ទៈជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គលរមែងមិនដឹងវិបស្សនាកុសលថាជាផ្លូវរួចផុតចាកទុក្ខ របស់ព្រះអរិយៈបន្ទាប់អំពីត្រូវកាមច្ឆន្ទៈនោះបិទរាំងខ្ទប់ ដូច្នេះ កាមច្ឆន្ទៈទើបជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ" ។

ពាក្យថា **នេក្ខម្មៈ** ប្រើក្នុងសេចក្ដីច្រើនយ៉ាង តាមឱកាស គឺការចេញបួស, បឋមជ្ឈាន, ព្រះនិព្វាន, វិបស្សនាញាណ និងកុសលធម៌ទាំងអស់ ដូចសេចក្ដីក្នុងគម្ពីរអដ្ឋកថាថា

បព្វជ្ជា បឋមំ ឈានំ     និព្វានញ្ច វិបស្សនា

សព្វេបិ កុសលា ធម្មា នេក្ខម្មន្តិ ပវុច្ចរេ[២៧] ។

"ការចេញបួស បឋមជ្ឈាន ព្រះនិព្វាន វិបស្សនាញាណ និងកុសលធម៌ទាំងអស់ លោកហៅថា នេក្ខម្មៈ" ។

ទោះយ៉ាងណាក៏ដោយ ក្នុងទីនេះសំដៅដល់វិបស្សនាកុសល តាមដែលប្រាកដ នៅក្នុងរឿងជាប់ទាក់ទងជាមួយនឹងការចំរើនវិបស្សនា ។

អ្នកដែលមិនបានកំណត់ដឹងរូបនាម ដែលប្រាកដផ្លូវទ្វារទាំង ៦ តាមសភាវៈពិត រមែងមិនយល់ថាវត្ថុនោះត្រឹមតែជារូបនាម មិនយល់ថាមានហេតុផលជាប់បន្តគ្នា ទាំងមិនយល់ថាជាសភាពមិនទៀង ជាទុក្ខ និងមិនមែនជារបស់ខ្លួន កាលមិនយល់ដូចដែលពោលមកនេះធ្វើឲ្យកើតសេចក្តីប្រាថ្នា ពេញចិត្តចំពោះអារម្មណ៍ដែលកំពុងជួបប្រទះ ឬអារម្មណ៍ដទៃដែលប្រហាក់ប្រហែលគ្នា អ្នកដែលចំរើនវិបស្សនាកំណត់ដឹងសភាវធម៌ គេរមែងយល់ថា មានត្រឹមតែរូបនាម មានហេតុផលជាប់បន្តគ្នា នឹងយល់ថា ជាសភាវៈមិនទៀង ជាទុក្ខ មិនមែនរបស់ខ្លួន ការយល់ចូលចិត្តដូចពោលមក

នេះធ្វើឲ្យអស់សេចក្ដីប្រាថ្នា សេចក្ដីពេញចិត្តចំពោះអារម្មណ៍ ដែលកំពុងជួបប្រទះ ឬអារម្មណ៍ដទៃដែលប្រហាក់ប្រហែលគ្នា ព្រោះដូច្នោះ វិបស្សនាកុសលទើបជាផ្លូវរួចផុតពីវដ្ដសង្សាររបស់ព្រះអរិយៈទាំងឡាយ ។

ចំណែកការពេញចិត្តក្នុងកាម ដែលហៅថាកាមច្ឆន្ទៈ ជាគ្រឿងបិទបាំងវិបស្សនាកុសល ពោលគឺមនុស្សគ្រប់គ្នា មានតួនាទីក្នុងការស្វែងរកចិញ្ចឹមជីវិតរបស់ខ្លួន ឬជាប់ទាក់ទងដោយស្វាមី ភរិយា បុត្រាបុត្រី ញាតិ មិត្ត សិស្ស អាចារ្យ ។ល។ កាមច្ឆន្ទៈ ដែលត្រូវការសេចក្ដីសុខ រមែងនាំឲ្យបុគ្គលធ្វើតួនាទីពួកនោះខ្វល់ខ្វាយក្នុងកិច្ចដែលជាប់ទាក់ទងជាមួយភារៈតួនាទី ដោយស្វែងរកវត្ថុដែលនៅមិនទាន់មាន ឬមិនបាននឹងរក្សាវត្ថុដែលមាន ឬទីលំនៅដែលកំពុងគ្រប់គ្រង ដូច្នេះ ពួកមនុស្សទើបមិនមានពេលដើម្បីការចំរើនវិបស្សនា សូម្បីខណៈខ្លះ គិតនឹងមកបដិបត្តិធម៌ ក៏មិនអាចធ្វើបានតាមបំណង ។

ក្រៅអំពីនេះ ពួកមនុស្សដែលពេញចិត្តនឹងគិតយ៉ាងឥស្សរៈ

បណ្តោយឲ្យភាពពាយមាយគ្របសង្កត់ចិត្ត ដោយប្រាសចាកការសង្រួមចិត្តឲ្យនៅជាមួយសភាវធម៌តាមសេចក្តីពិត ទាំងពេញចិត្តក្នុងការធ្វើ ឬនិយាយតាមចិត្តរបស់ខ្លួន ខណៈខ្លះ សូម្បីគិតថាត្រូវការបដិបត្តិធម៌ ក៏កង្វល់ថា សេចក្តីសុខផ្លូវកាយនិងចិត្តដែលកំពុងប្រទះក្នុងខណៈនោះ នឹងត្រូវអស់ទៅ ទើបមិនអាចមកចំរើនវិបស្សនាបាន កាលមិនបានចំរើនវិបស្សនា ក៏មិនកើតវិបស្សនាញាណ ដែលឃើញច្បាស់ត្រៃលក្ខណ៍ តាមសភាវៈពិត អ្នកខ្លះក៏ត្រូវការនឹងសោយសុខក្នុងជាតិខាងមុខ ពេញចិត្តនឹងការត្រាច់រង្គត់ទៅក្នុងវដ្តសង្សារ ទើបមិនបានចំរើនវិបស្សនាដើម្បីការរួចផុតចាកទុក្ខ នឹងឃើញបានថា ការមិនរួចផុតអំពីវដ្តៈ មានដោយសារហេតុមកអំពីកាមច្ឆន្ទៈៗ ទើបជាគ្រឿងរាំងមិនកើតវិបស្សនាកុសល ។

សូម្បីក្នុងខណៈចំរើនវិបស្សនាភាវនា កាមច្ឆន្ទៈ ក៏បិទរាំងវិបស្សនាកុសលបានដូចគ្នាពោលគឺខណៈខ្លះ កាមច្ឆន្ទៈ យ៉ាងគ្រោតគ្រាត ដែលត្រូវការកាមគុណក៏ប្រាកដឡើងដូចគ្នាជាមួយពេលដែលមិនទាន់បដិបត្តិធម៌ អ្នកខ្លះកាមច្ឆន្ទៈដ៏ល្អិតក៏កើតឡើង

ដោយពេញចិត្តការចំរើនសតិ ដែលកំពុងប្រព្រឹត្តទៅយ៉ាងរាបល្អ ប្រាសចាកសេចក្ដីរាយមាយចិត្ត ឬពេញចិត្តសភាវធម៌ដែលប្រាកដយ៉ាងច្បាស់ធ្វើឲ្យអាឡោះអាល័យដល់វត្ថុនោះជាទិច្ចត្រូវការប្រាប់ឲ្យអ្នកដទៃដឹង នឹងប្រាថ្នាឲ្យបុគ្គលជិតដិតបានមកបដិបត្តិធម៌ផង ឬធ្វើឲ្យកើតសេចក្ដីសង្ឃឹមនៅខាងមុខតទៅដែលជាញាណជាន់ខ្ពស់ជាងញាណដំបូង ឬមគ្គផល និងនិព្វាន ។ ពិតហើយ ការប្រាថ្នាព្រះនិព្វាន អាចជាឆន្ទៈ ដែលប្រកបជាមួយកុសលចិត្ត ឬលោភៈក៏បាន ព្រោះបុថុជ្ជនមិនអាចទទួលយក ព្រះនិព្វានជាអារម្មណ៍ដោយត្រង់បានទេ ត្រឹមតែទទួលដឹងដោយការអនុមានប៉ុណ្ណោះ មានសាធកៈដែលពោលដល់ការប្រាថ្នាខាងដើម ជាលោភៈ ដូចតទៅនេះ:

អនុត្តរេសុ វិមោក្ខេសុ បិហំ ឧបដ្ឋាបេតិ[28] ។

"បុគ្គលរមែងតាំងសេចក្ដីប្រាថ្នាទុកក្នុងអរហត្តផលដ៏កំពូល" ។

អនុសុតិលទ្ធំ បទ បរិកប្បសិទ្ធំ

អរហត្តំ ឧទ្ទិស្ស បត្ថនំ ឋបេតិ[29] ។

"បុគ្គលរមែងតាំងសេចក្តីប្រាថ្នា ដល់អរហត្តផល ដែលសំរេចដោយការត្រិះរិះ ដែលបានទទួលមកអំពីការស្តាប់" ។

អនុស្សវិបលាទ្ធ បទ អនុត្តរវិមោក្ខ ឧទ្ទិស្ស បិហំ

ឧប្បាទេន្តោ តត្ថ បិហំ ឧបដ្ឋាបេតីតិ អត្ថោ[៣០] ។

"សេចក្តីនេះ គឺអ្នកកើតការប្រាថ្នាដល់អរហត្តផលដ៏កំពូលដែលបានទទួលមកអំពីការស្តាប់ឈ្មោះថា រមែងតាំងសេចក្តីប្រាថ្នាទុកក្នុងអរហត្តផលនោះ" ។

នឹងឃើញបានថា កាមច្ឆន្ទៈធ្វើឲ្យវិបស្សនាចិត្តដាច់មិនជាប់បន្តគ្នាអ្នកខ្វះចំរើនវិបស្សនាចូលដល់មានសមាធិ និងបញ្ញាចាស់ក្លាល្អមសមគួរ កាលកើតកាមច្ឆន្ទៈដូច្នេះ នឹងវិនាសចាកសមាធិនិងបញ្ញានោះ ទាំងអាចកើតការខូចចិត្តជាប់តាមមកទៀតផង ។

ដោយហេតុដែលពោលមកនេះ ក្នុងគម្ពីរបដិសម្ភិទាមគ្គខាងដើមទើបពោលថា "កាមច្ឆន្ទៈជាគ្រឿងរារាំងផ្លូវរួចផុត ព្រោះបុគ្គលរមែងមិនដឹងច្បាស់វិបស្សនាកុសលថាជាផ្លូវរួចផុតចាកទុក្ខ របស់

ព្រះអរិយៈ” ។

ពាក្យថា “មិនដឹងច្បាស់” សំដៅដល់ ការមិនដឹងច្បាស់ដោយការទាបញ្ញាដែលកើតឡើងក្នុងក្រសែចិត្តរបស់ខ្លួន មិនមែនសំដៅដល់ ការមិនដឹងច្បាស់ដោយបញ្ញាអំពីការស្ដាប់ទេ ព្រោះដូច្នោះកាមច្ឆន្ទៈ ទើបជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខទាំងទៅចាត់ជានីវរណៈទៀតផង ដូចគម្ពីរបដិសម្ភិទាមគ្គពោលថា

កេនដ្ឋេន នីវរណា ។ និយ្យានាវរណដ្ឋេន នីវរណា[៣១]។

“សួរថា : ឈ្មោះថា នីវរណៈ ព្រោះជាសភាពអ្វី ?

ឆ្លើយថា : ឈ្មោះថា នីវរណៈ ព្រោះជាសភាពរាំងផ្លូវរួចផុតចាកទុក្ខ” ។

## ២. ព្យាបាទៈ

អព្យាបាទោ អរិយានំ និយ្យានំ ។ តេន ច អព្យាបាទេន អរិយា និយ្យន្តិ ។ ព្យាបាទោ និយ្យានាវរណំ ។ តេន ច ព្យាបាទេន និវុតត្តា អព្យាបាទំ អរិយានំ និយ្យានំ នប្បជានាតីតិ

ព្យាបាទោ និយ្យានាវរណំ ៣២។

“ការមិនក្រោធ ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ព្រោះព្រះអរិយៈ រមែងរួចផុតចាកទុក្ខដោយការមិនក្រោធនោះ សេចក្ដីក្រោធជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គលរមែងមិនឃើញច្បាស់ សេចក្ដីមិនក្រោធថា ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈ ពីព្រោះត្រូវសេចក្ដីក្រោធនោះបិទបាំងទុក្ខ ដូច្នេះ សេចក្ដីក្រោធទើបជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ” ។

ក្នុងខណៈចម្រើនវិបស្សនា អ្នកបដិបត្តិអាចទទួលអារម្មណ៍ដែលមិនគួរពេញចិត្ត ឬទុក្ខវេទនាដែលខ្លាំងក្លា ឬការបដិបត្តិមិនឈានទៅមុខ នោះគប្បីកំចាត់សេចក្ដីមិនពេញចិត្ត ហើយចំរើនវិបស្សនាតទៅសេចក្ដីមិនក្រោធនេះទើបជាផ្លូវរួចផុតចាកទុក្ខ ។

សេចក្ដីក្រោធដែលកើតឡើងអំពីបុគ្គល ឬរឿងណាៗ ក៏ដោយធ្វើឲ្យអ្នកបដិបត្តិមិនអាចចំរើនសតិទទួលដឹងសភាវធម៌បាន សេចក្ដីក្រោធ ទើបជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ ដោយហេតុដូចដែលពោលមកនេះ ប្រសិនបើកើតសេចក្ដីមិនពេញចិត្ត កាលអាឡោះ

អាល័យអ្នកដែលមិនចូលចិត្ត អ្នកដែលធ្លាប់ឈ្លោះរិះគន់ទាស់ទែងគ្នា ឬកាលជួបជាមួយទុក្ខវេទនាដ៏ខ្លាំងក្លា ឬព្រោះឃើញនិងបានឮវត្ថុដែលរំខានការបដិបត្តិធម៌ ក៏គួរកំណត់ឲ្យដឹងសភាពមិនពេញចិត្តនោះ រហូតដល់បាត់ទៅ បើអ្នកបដិបត្តិកំណត់ដឹងមួយដងហើយនៅមិនបាត់ទៅ ក៏គួរកំណត់ដឹងតទៅរហូតចូលដល់សភាពមិនពេញចិត្តនោះបាត់ទៅ ។

## ៣. ថីនមិទ្ធៈ

អាលោកសញ្ញា អរិយានំ និយ្យានំ ។ តាយ ច អាលោកសញ្ញាយ អរិយា និយ្យន្តិ ។ ថីនមិទ្ធំ និយ្យានាវរណំ ។ តេន ច ថីនមិទ្ធេន និវុតត្តា អាលោកសញ្ញំ អរិយានំ និយ្យានំ នប្បជានាតីតិ ថីនមិទ្ធំ និយ្យានាវរណំ[៣៣] ។

"ការធ្វើទុកក្នុងចិត្តនូវពន្លឺ ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ព្រោះព្រះអរិយៈ រមែងរួចផុតចាកទុក្ខ ក្នុងពន្លឺនោះ ថីនមិទ្ធៈ ជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គលរមែងមិនដឹងច្បាស់ថា ការធ្វើទុកក្នុងចិត្តនូវពន្លឺថា ជាផ្លូវរួចផុតចាកទុក្ខ របស់

ព្រះអរិយៈ ពីព្រោះត្រូវថីនមិទ្ធៈបិទបាំងទុក ដូច្នោះ ថីនមិទ្ធៈ ទើបជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ” ។

ការធ្វើទុកក្នុងចិត្តនូវពន្លឺ គឺការធ្វើទុកក្នុងចិត្តនូវពន្លឺព្រះអាទិត្យ ព្រះច័ន្ទ ឬពន្លឺកើតអំពីការចំរើនអាលោកកសិណ កាលមានការធ្វើទុកក្នុងចិត្តដូច្នេះ ថីនមិទ្ធៈដែលជាគ្រឿងងងុយងោកងក់ រមែងមិនកើតឡើងបាន ការធ្វើទុកក្នុងចិត្តនូវពន្លឺ ទើបជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈ ។

ក្រៅអំពីនេះ ការធ្វើទុកក្នុងចិត្ត ដោយការកំណត់ដឹងរូបនាមឲ្យប្រាកដច្បាស់ ក៏ចាត់ថា ជាការធ្វើទុកក្នុងចិត្តនូវពន្លឺដូចគ្នា កាលអ្នកបដិបត្តិ ចំរើនសតិកំណត់ដឹងយ៉ាងប្រចក្សច្បាស់ ការងងុយ ឬការទម្រន់ រមែងមិនកើតឡើង អ្នកខ្លះប្រាសចាកការងងុយរហូតដល់អាចចំរើនសតិបានរហូតថ្ងៃនិងយប់ ។

ការងងុយជាហេតុឲ្យងោកក្បាល និងចង់ដេក សូម្បីការទម្រន់ដែលសញ្ជប់សញ្ជឹងមិនមានការងងុយ ក៏ចាត់ថា ជាថីនមិទ្ធៈដូចគ្នា ថីនមិទ្ធៈនេះ ជាគ្រឿងរារាំងការធ្វើទុកក្នុងចិត្តនូវពន្លឺ អ្នកបដិបត្តិគួរ

ចំរើនសតិកំណត់ដឹងនូវបទនីឲ្យច្បាស់លាស់ហើយលះបីនមិទ្ធៈ ។

## ៤. ការចេះទោយរាយមាយ

អវិក្ខេបោ អរិយានំ និយ្យានំ ។ តាយ ច អវិក្ខេបេន អរិយា និយ្យន្តិ ។ ឧទ្ធច្ចំ និយ្យានាវរណំ ។ តេន ច ឧទ្ធច្ចេន និវុតត្តា អវិក្ខេបំ អរិយានំ និយ្យានំ នប្បជានាតីតិ ឧទ្ធច្ចំ និយ្យានាវរណំ[៣៤]។

"សេចក្តីមិនរវើរវាយ ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ព្រោះព្រះអរិយៈមែងរួចផុតចាកទុក្ខ ដោយសេចក្តីមិនរវើរវាយនោះ សេចក្តីរវើរវាយជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គល រមែងមិនដឹងច្បាស់នូវសេចក្តីមិនរវើរវាយថា ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈ ពីព្រោះត្រូវសេចក្តីរវើរវាយនោះបិទបាំងទុក ដូច្នោះ សេចក្តីរវើរវាយ ទើបជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ" ។

សេចក្តីមិនរវើរវាយក្នុងទីនេះ សំដៅដល់ខណិកសមាធិ ដែលតាំងមាំក្នុងរូបនាម ដែលអ្នកបដិបត្តិកំពុងកំណត់ដឹងក្នុងបច្ចុប្បន្នខណៈ កាលសមាធិមានកម្លាំងច្រើនឡើង ចិត្តដែលកំណត់ដឹងរមែង

នឹងជាប់តាមទទួលដឹងអារម្មណ៍ ដែលបានយ៉ាងជាប់រហ័ស ដូចកាលដាក់របស់ធ្ងន់ទុកលើផែនដី របស់ធ្ងន់ក៏នឹងឈប់មួយកន្លែង មិនកកិលឃ្លាត ឬដូចការជោតលាំពែងស្រួចទុកលើផែនដីថ្មមៗ លំពែងស្រួចរមែងជាប់នឹងផែនដី ឬដូចជាការគប់ដីស្អិតទៅលើជញ្ជាំងឥដ្ឋ ដីស្អិតនឹងជាប់ជញ្ជាំងពិតប្រាកដ អ្នកបដិបត្តិ រមែងនឹងសម្រេចមគ្គផលបានដោយខណិកសមាធិ ដែលមិនរាយមាយខណិកសមាធិនេះ ទើបជាផ្លូវរួចផុតអំពីវដ្ដៈ របស់ព្រះអរិយៈទាំងឡាយ ។

ក្នុងខណៈខ្លះ ដែលអ្នកបដិបត្តិកំពុងចំរើនវិបស្សនា ចិត្តក៏អាចរវើរវាយរាយមាយចេញអំពីសភាវធម៌បច្ចុប្បន្ន អាឡោះអាល័យទៅក្នុងអតីតៈឬអនាគត បើសេចក្ដីរវើរវាយមានកម្លាំងតិច ចិត្តក៏នឹងរាយមាយតិច ប្រសិនបើសេចក្ដីរវើរវាយមានកម្លាំងច្រើន ចិត្តក៏នឹងរាយមាយច្រើន គ្រាខ្លះការរវើរវាយ ដែលជាប់ទាក់ទងជាមួយនឹងការបដិបត្តិ ក៏អាចកើតឡើងបានខ្លះ ដូចជាការពិចារណាវិធីបដិបត្តិរបស់ខ្លួនថា ត្រឹមត្រូវទេ ? ចិត្តអាចទទួលដឹងអារម្មណ៍ដែលប្រាកដច្បាស់ឬទេ ? ឬគួរកំណត់ដឹងយ៉ាងណា កាលចិត្តរវើរវាយ

រាយមាយយ៉ាងនេះ សមាធិរមែងមិនកើតឡើង សូម្បីសមាធិ ដែលកើតឡើងហើយ ក៏មិនតាំងនៅមាំក្នុងអារម្មណ៍កម្មដ្ឋាន សេចក្តីរវើរវាយ ទើបជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ ដោយហេតុនេះ អ្នកបដិបត្តិ ទើបគួរកំណត់ដឹងសេចក្តីរវើរវាយឲ្យទាន់សភាវៈ រហូតដល់បាត់ទៅ ហើយមកកំណត់ដឹងសភាវធម៌ដូចដើម ។

## ៥. វិចិកិច្ឆា

ធម្មវិត្ថានំ អរិយានំ និយ្យានំ ។ តេន ច ធម្មវិត្ថានេន អរិយា និយ្យន្តិ ។ វិចិកិច្ឆា និយ្យានាវរណំ ។ តាយ ច វិចិកិច្ឆាយ និវុតត្តា ធម្មវិត្ថានំ អរិយានំ និយ្យានំ នប្បជានាតីតិ វិចិកិច្ឆា និយ្យានាវរណំ[៣៥] ។

“ការយល់ចូលចិត្តធម៌ [ថាជាកុសលឬអកុសល] ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ព្រោះព្រះអរិយៈ រមែងរួចផុតចាកទុក្ខដោយការយល់ចូលចិត្តធម៌នោះ សេចក្តីសង្ស័យជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គលរមែងមិនដឹងច្បាស់ការយល់ចូលចិត្តក្នុងធម៌ ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈ ពីព្រោះ

ត្រូវសេចក្ដីសង្ស័យនោះបិទបាំងទុក ដូច្នោះ សេចក្ដីសង្ស័យ ទើបជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ” ។

ការយល់ចូលចិត្តថា ធម៌ជាកុសលឬអកុសល ជាគ្រឿងលះបង់នូវអកុសលនឹងចំរើនកុសលរហូតដល់រួចផុតអំពីវដ្ដៈ និងចាក់ធ្លុះព្រះនិព្វាន ការយល់ចូលចិត្តក្នុងធម៌ដូចពោលមកនេះ ទើបជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈ ក្នុងករណីដូយគ្នានេះ សេចក្ដីសង្ស័យដែលហៅថា វិចិកិច្ឆា សង្ស័យថាធម៌នេះ ជាកុសលឬអកុសល ជាគ្រឿងបិទរាំងការយល់ចូលចិត្តខាងដើម ព្រោះអ្នកដែលសង្ស័យ រមែងមិនអាចលះបង់អកុសល នឹងចំរើនកុសលបានទេ ។

ក្នុងរឿងនៃវិបស្សនាកម្មដ្ឋាននេះ ការយល់ចូលចិត្ត ដូចដែលពោល ជាការដឹងច្បាស់ ជាវិបស្សនាកុសល ឬកុសលដែលឧបត្ថម្ភដល់វិបស្សនាញាណ ចាត់ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ រឿងការយល់ចូលចិត្តក្នុងខនេះ នឹងពោលទុកដោយពិស្ដារតទៅក្នុងបរិច្ឆេទទី ៣ និងទី ៤ ។

ពិតហើយ ការកំណត់ដឹងនូវរូបនាម ដែលជាបច្ចុប្បន្នខណៈ ( បច្ចុប្បន្នដែលកើតឡើងពិត ) និងសន្តតិបច្ចុប្បន្ន ( បច្ចុប្បន្នដែលជាប់មកពីអតីតៈទើបនឹងរលត់ទៅ ) ចាត់ជាវិបស្សនាយ៉ាងពិតប្រាកដ កាលវិបស្សនាញាណចាស់ក្លាហើយ សូម្បីធម៌ទាំងអស់ដែលជាអតីតៈ អនាគត និងធម៌ខាងក្រៅ ដែលនឹងបានដឹងច្បាស់ដោយប្រចក្ស ក៏ត្រឹមតែ ជាការអនុមានដឹងបានដូចជាវិបស្សនាកុសល ។ ចំណែកការគិតរវើរវាយដទៃអំពីនេះ មិនមែនជាវិបស្សនាកុសល អ្នកបដិបត្តិដែលយល់ដូច្នេះ ហើយចំរើនវិបស្សនាយ៉ាងត្រឹមត្រូវ រមែងសម្រេចធម៌ជាព្រះអរិយបុគ្គល រួចផុតអំពីវដ្តសង្សារបាន ក្រៅអំពីនេះ សូម្បីការពិចារណាកុសល បានដល់សីលធុតង្គ និងសមថភាវនាតាមសមគួរ ក៏ជាសេចក្តីយល់ចូលចិត្ត ដែលឧបត្ថម្ភដល់វិបស្សនាញាណដូចគ្នា ។

សេចក្តីសង្ស័យ ក្នុងការបដិបត្តិធម៌ ការកំណត់ដឹងរូបនាមបច្ចុប្បន្នជាកុសល ឬមិនមែនកុសលនោះ ជាអន្តរាយចំពោះការបដិបត្តិធម៌យ៉ាងក្រៃលែង នឹងបន្ទំឲ្យជឿថា ជាបញ្ញាដែលពិចារណា

យ៉ាងស្មើគ្នាតាមហេតុផលទាំងពីរចំណែក ដូចអដ្ឋកថារបស់គម្ពីរនេត្តិបករណ៍ពោលថា

**ឧភយបក្ខសន្តីរណមុខេន វិចិកិច្ឆា វេញ្ចតិ[៣៦] ។**

"សេចក្តីសង្ស័យ រមែងបន្ទំដោយលក្ខណៈ ដែលពិចារណាទាំងពីរចំណែកជាគោល" ។

សេចក្តីសង្ស័យនេះ រមែងមិនកើតដល់អ្នកដែលអស់ការស្វែងយល់ដែលជាប់ទាក់ទងជាមួយការបដិបត្តិបុគ្គលនោះ រមែងជឿស្តាប់វិបស្សនាចារ្យអ្នកណែនាំ និងបដិបត្តិតាមដោយតឹងរឹងបំផុត បើមិនមានបុគ្គលអ្នកណែនាំគេក៏មិនអាចបដិបត្តិបាន ។ ចំណែកអ្នកដែលមានការដឹងល្អ សូម្បីមិនមានអ្នកណែនាំ គេក៏អាចបដិបត្តិបាន តែអាចកើតសេចក្តីសង្ស័យក្នុងខណៈខ្លះ ដោយវត្ថុដែលធ្លាប់សិក្សា ដូចអ្នកទៅក្នុងផ្លូវដែលមិនធ្លាប់ទៅ ក៏អាចវង្វេងផ្លូវថា ផ្លូវណាត្រូវ ក្នុងវម្មិកសូត្រទើបពោលដល់សេចក្តីសង្ស័យថា ដូចជា ផ្លូវបែកជាពីរ[៣៧] ក្នុងព្រះសូត្រនេះ ព្រះអង្គទ្រង់ត្រាស់ប្រៀបអ្នកបដិបត្តិដូចមនុស្សដើរផ្លូវ ពោលគឺមនុស្សដើរផ្លូវដែលមានទ្រព្យ បានធ្វើដំណើរមកដល់ផ្លូវបែកជាពីរហើយ សម្រេចចិត្តមិនបានថា គួរទៅផ្លូវណា

ខណៈនោះ ចោរដើរតាមមកទាន់ហើយប្លន់ទ្រព្យ ប្រទូសរ៉ាយគេ កាលដែលអ្នកបដិបត្តិកើតសេចក្ដីសង្ស័យ ជាប់ទាក់ទងជាមួយនឹងការចម្រើនវិបស្សនា ហើយមិនអាចកំណត់ដឹង សភាវធម៌តទៅក៏ដូចជាមួយការកំពុងឈប់ឈរកន្លែងផ្លូវបែកជាពីរ កាលធ្លាក់ក្នុងអំណាចរបស់កិលេសហើយ មិនអាចរួចផុតអំពីវដ្ដៈទេ ដូចជាកាលដែលបុរសដើរផ្លូវធ្លាក់នៅក្នុងកណ្ដាប់ដៃរបស់ចោរ ។

## សេចក្ដីសង្ស័យ ដែលជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ មាន ៨ ប្រការគឺ

១. សេចក្ដីសង្ស័យក្នុងព្រះពុទ្ធ ។

២. សេចក្ដីសង្ស័យក្នុងព្រះធម៌ ។

៣. សេចក្ដីសង្ស័យក្នុងព្រះសង្ឃ ។

៤. សេចក្ដីសង្ស័យក្នុងត្រៃសិក្ខា គឺ សីល សមាធិ និងបញ្ញា

៥. សេចក្ដីសង្ស័យក្នុងខន្ធអតីតៈ ។

៦. សេចក្ដីសង្ស័យក្នុងខន្ធអនាគត ។

៧. សេចក្ដីសង្ស័យក្នុងខន្ធបច្ចុប្បន្ន ។

៨. សេចក្តីសង្ស័យក្នុងបដិច្ចសមុប្បាទ ។

ក្នុងបច្ចុប្បន្ន អ្នកបដិបត្តិអាចសង្ស័យក្នុងវិបស្សនាចារ្យថា បង្រៀនត្រឹមត្រូវឬមិនសង្ស័យក្នុងការត្រឹមត្រូវនៃវិធីបដិបត្តិ សង្ស័យក្នុងបុគ្គលអ្នកបដិបត្តិថា ប្រទះការឈានទៅមុខក្នុងការបដិបត្តិឬទេ? និងសង្ស័យក្នុងការបដិបត្តិរបស់ខ្លួនថា ត្រឹមត្រូវឬទេ? ដោយហេតុនេះ អ្នកបដិបត្តិគួរកំចាត់សេចក្តីសង្ស័យ ក្នុងរឿងពួកនេះ ហើយតាំងចិត្តចម្រើនវិបស្សនា និងធ្វើឲ្យសម្រេចមគ្គផលដោយឆាប់រហ័ស ដូច្នេះ គម្ពីរនេះទើបពោលដល់សីលវិសុទ្ធិជាដើម ព្រមដោយគោលការចំរើនវិបស្សនាដ៏ល្អិតល្អន់ទាំងនេះ ដើម្បីឲ្យអ្នកបដិបត្តិកើតការយល់ចូលចិត្តយ៉ាងជាក់ច្បាស់ ប្រាសចាកសេចក្តីសង្ស័យ ដែលជាគ្រឿងបិទបាំងវិបស្សនា ។

អ្នកបដិបត្តិកំណត់ដឹងសភាវធម៌ ដែលមានការដើរ ការឈរ ការអង្គុយ ការដេក ការលោត ការបត់ ។ល។ តាមន័យ ដែលនឹងពោលតទៅក្នុងបរិច្ឆេទទី ៥ ឈ្មោះថា ជាអ្នកចំរើនកុសលយ៉ាងពិតប្រាកដ ព្រោះក្នុងខណៈនោះ គេកើតបញ្ញាឃើញច្បាស់រូបធម៌ ដែល

ជាការដើរជាដើម ទាំងកើតសភាវធម៌ដទៃៗ គឺសតិដែលកំណត់ដឹងយ៉ាងបន្តបន្ទាប់ សទ្ធាដែលជឿមាំធ្វើឲ្យចិត្តផូរផង់ ការមិនលោភនិងការមិនក្រោធ ដូច្នេះ ជាដើម ធម៌ដែលជាបញ្ញា សតិ សទ្ធា អលោភៈ និងអទោសៈជាដើមនោះ ជាកុសលធម៌ដែលប្រាសចាកទោសដោយពិត នឹងឃើញបានថា កាលចំរើនវិបស្សនាការនា រមែងញ៉ាំងឲ្យកើតកុសលធម៌យ៉ាងនេះ ដូចគ្នាជាមួយការចំរើនសមថភាវនាក្នុងការបរិកម្មកសិណថា "បឋវី បឋវី" ឬ"ដី ៗ" រមែងញ៉ាំងឲ្យកើតសមថៈកុសលគ្រប់ៗ ខណៈដែលកំណត់ដឹងបឋវីកសិណជាអារម្មណ៍ ។

## ៦. អវិជ្ជា

*ឈានំ អរិយានំ និយ្យានំ ។ តេន ច ឈានេន អរិយា និយ្យន្តិ ។ អវិជ្ជា និយ្យានាវរណំ ។ តាយ ច អវិជ្ជាយ និវុតត្តា ឈានំ អរិយានំ និយ្យានំ នប្បជានាតីត អវិជ្ជា និយ្យានាវរណំ*(៣៨) ។

"ការដឹងច្បាស់ ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ព្រោះព្រះអរិយៈ រមែងរួចផុតចាកទុក្ខ ដោយការដឹងច្បាស់នោះ

ការមិនដឹងជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គលរមែងមិនដឹងការឃើញច្បាស់ជាផ្លូវរួចផុតចាកទុក្ខ របស់ព្រះអរិយៈ ពីព្រោះត្រូវសេចក្តីមិនដឹងនោះបិទបាំងទុក ដូច្នោះ ការមិនដឹងទើបជាគ្រឿងរារាំងផ្លូវរួចផុតចាកទុក្ខ" ។

ក្នុងគម្ពីរមហាដីកា[៣៩] អធិប្បាយថា ការឃើញច្បាស់ក្នុងរឿងនេះ គឺនាមរូបបរិច្ឆេទញាណ និងបច្ចយបរិគ្គហញាណ ចំណែកការមិនដឹងដែលហៅថា អវិជ្ជា គឺការសំគាល់ថា ជាតួខ្លួន បុគ្គល យើង របស់យើង ឬជាការយល់ខុសថា មានព្រះជាម្ចាស់ ជាអ្នកនិម្មិតពួកសត្វ ។ ទោះបីយ៉ាងណាក៏ដោយ ការឃើញច្បាស់ អាចសំដៅដល់វិបស្សនាញាណទាំងអស់ព្រមទាំងមគ្គញាណ នឹងការមិនដឹង ក៏សំដៅដល់មោហៈ ដែលមានសភាពផ្ទុយគ្នាជាមួយវិបស្សនាញាណទាំងអស់ ព្រោះពោលនៅក្នុងរឿងតែមួយជាមួយវិបស្សនា ។ អ្នកដែលចំរើនសតិកំណត់រូបនាមក្នុងបច្ចុប្បន្នខណៈ រមែងកើតបញ្ញាឃើញច្បាស់ជាគ្រាដំបូងថា មានត្រឹមតែរូបធម៌ប៉ុណ្ណោះ ដែលទទួលដឹងអារម្មណ៍មិនបាន ឬឃើញថា នាមធម៌ដែលទទួលដឹង

អារម្មណ៍បានដូចស្រមោលដែលជាប់តាមខ្លួន មិនមានតួខ្លួន បុគ្គល យើង របស់យើង តមកឃើញច្បាស់នូវហេតុ និងផលរបស់ រូបនាមថា រូបនាមកើតអំពីហេតុបច្ច័យយ៉ាងនេះ កាលមានហេតុ បច្ច័យពួកនេះ រូបនាមទើបកើតឡើងបាន នឹងមានផលដែលកើត អំពីហេតុបច្ច័យប៉ុណ្ណោះ មិនមានព្រះជាម្ចាស់ អ្នកនិម្មិតពួកសត្វ ។ បន្ទាប់ពីនោះ អ្នកបដិបត្តិនឹងកើតបញ្ញាឃើញច្បាស់ត្រៃលក្ខណ៍ថា រូបនាមមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ក្រោយអំពីនោះ នឹង ឃើញច្បាស់សភាវៈ កើតរលត់យ៉ាងលឿនរហ័សរបស់រូបនាម ព្រមទាំងសភាវៈរលត់ទៅតែម្យ៉ាងរបស់រូបនាម ដូចនេះជាដើម បញ្ញា ឃើញច្បាស់ គឺវិបស្សនាញាណ ទើបជាផ្លូវរួចផុតអំពីវដ្តៈរបស់ ព្រះអរិយៈទាំងឡាយ ។

អ្នកដែលខ្វះសតិ មិនបានកំណត់ដឹងរូបនាមតាមសភាវៈពិត រមែងមិនដឹងច្បាស់ថា ទាំងអស់មានត្រឹមតែរូបនាមប៉ុណ្ណោះ ដោយ ប្រាសចាកតួខ្លួន មិនដឹងថា រូបនាមជាផលដែលកើតអំពីហេតុ បច្ច័យ មិនដឹងត្រៃលក្ខណ៍ មិនដឹងការកើតរលត់យ៉ាងលឿនរហ័ស របស់រូបនាម និងមិនដឹងសភាវៈរលត់ទៅតែម្យ៉ាងរបស់រូបនាម

ទើបសំគាល់រូបនាមថា ជាតួខ្លួន ជាបុគ្គល និងយល់ខុសថា ពួកសត្វកើតឡើងឯងៗ តាមធម្មជាតិដោយមិនមានហេតុបច្ច័យ ឬកើតឡើងអំពីការនិម្មិត្ត របស់ព្រះជាម្ចាស់ ទាំងសំគាល់ខុសទៀតថា មានតួខ្លួន ជាបស់ទៀង ជាសុខ បង្គាប់បញ្ជាបាន ដែលស្ថិតនៅជានិច្ច មិនផ្លាស់ប្តូរប្រែប្រួល ដូច្នេះ ការមិនដឹង ទើបជាគ្រឿងបិទបាំងផ្លូវរួចផុតអំពីវដ្តៈ ។

ការឃើញច្បាស់ ជាឈ្មោះរបស់ញាណ ឬវិជ្ជា ចំណែកការមិនឃើញច្បាស់ ជាឈ្មោះរបស់មោហៈ ឬអវិជ្ជា ការមិនឃើញច្បាស់ គឺ ការឃើញខុសអំពីសភាវធម៌ រមែងកើតគ្របសង្កត់អ្នកដែលមិនបានបដិបត្តិធម៌ជានិច្ច សូម្បីក្នុងខណៈផ្តើមបដិបត្តិធម៌ អវិជ្ជាក៏រមែងកើតឡើងជានិច្ច ធ្វើឲ្យអ្នកបដិបត្តិទទួលដឹងរូបរាងសណ្ឋានពេលជួបនិងឃើញរូបារម្មណ៍ រមែងដឹងបញ្ញត្តិមុនថា "យើងឃើញ" ឬ"ឃើញវត្ថុនោះ វត្ថុនេះ"ដោយមិនបានទទួលដឹងសភាវៈឃើញឬត្រឹមតែពណ៌ដែលកំពុងឃើញដោយមិនមានសណ្ឋាន ការពោលថា អវិជ្ជា គឺការមិនដឹង សំដៅដល់ ការមិនដឹងច្បាស់សភាវធម៌តាមសេចក្តីពិត តែអវិជ្ជាមានសភាពដឹងបញ្ញត្តិតាមប្រក្រតី ដូច

គម្ពីរអដ្ឋកថាពោលថា “អវិជ្ជា មាននាទីបិទបាំងសភាវធម៌របស់អារម្មណ៍តាមសេចក្ដីពិត[៤០]” ។

### ៧. អរតិ សេចក្ដីមិនត្រេកអរក្នុងភាវនា

បាមុជ្ជំ អរិយានំ និយ្យានំ ។ តេន ច បាមុជ្ជេន អរិយា និយ្យន្តិ ។ អរតិ និយ្យានាវរណំ ។ តាយ ច អរតិយា និវុតត្តា អរិយានំ និយ្យានំ នប្បជានាតីតិ អរតិ និយ្យានាវរណំ[៤១] ។

“សេចក្ដីបាមោជ្ជៈ ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ព្រោះព្រះអរិយៈទាំងឡាយ រមែងរួចផុតដោយសេចក្ដីបាមោជ្ជៈនោះ ការមិនត្រេកអរក្នុងភាវនា ជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គលរមែងមិនដឹងច្បាស់សេចក្ដីបាមោជ្ជៈ ថាជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈ ពីព្រោះត្រូវសេចក្ដីមិនត្រេកអរក្នុងភាវនានោះបិទបាំងទុក ដូចនោះ ការមិនក្រេតអរក្នុងភាវនា ទើបជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ” ។

ក្នុងគម្ពីរមហាដីកា[៤២] ពោលថា សេចក្ដីបាមោជ្ជៈ ជាហេតុកើត

នៃឈាន សេចក្ដីនោះ ពោលទុកក្នុងឱកាស ដែលសម្ដែងរឿងសមថភាវនា តែសេចក្ដីបាមោជ្ជៈ នៅជាដែនកើតនៃបីតិជាដើមក្នុងវិបស្សនាភាវនាទៀតផង ដូចព្រះពុទ្ធវចនៈ ដែលត្រាស់ដល់បីតិ បស្សទ្ធិ សុខៈ សមាធិ និង យថាភូតញ្ញាណថា កើតអំពីសេចក្ដីបាមោជ្ជៈ[៨៣] ក្នុងទីនេះទើបពោលដល់សេចក្ដីបាមោជ្ជៈ ដែលជាប់ទាក់ទងជាមួយនឹងវិបស្សនាភាវនា ។ អ្នកបដិបត្តិកំណត់ដឹងសភាវធម៌បានយ៉ាងជាក់ច្បាស់ រមែងកើតសេចក្ដីរីករាយត្រេកអរក្នុងការបដិបត្តិ សេចក្ដីរីករាយនេះ ឈ្មោះថា បាមោជ្ជៈ និងកាលអ្នកបដិបត្តិចំរើនវិបស្សនាតទៅ ដោយសេចក្ដីបាមោជ្ជៈនេះ រមែងរួចផុតអំពីវដ្ដសង្សារបាន សេចក្ដីបាមោជ្ជៈ ទើបជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ។

សេចក្ដីបាមោជ្ជៈ រមែងកើតឡើងងាយ ដល់អ្នកដែលមានសភាពមិនសុខុម និងកើតការលំបាកដល់អ្នកដែលមានសភាពសុខុម ដូចក្មេងទទួលកាន់កហាបណៈ ក៏ពេញចិត្តតែអ្នកដែលសុខុម រមែងកើតបាមោជ្ជៈបាន ដូចជាការសម្រេចនូវឧទ្ទយព្វយញ្ញាណជាដើមទៅ ដូចព្រះពុទ្ធវចនៈក្នុងគម្ពីរធម្មបទថា

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ

លភតិ បីតិបាមោជ្ជំ អមតន្តំ វិជានតំ[៤៤] ។

"កាលភិក្ខុឃើញច្បាស់ការកើតឡើង និងរលត់ទៅនៃខន្ធ ហើយ រមែងបានបីតិបាមោជ្ជៈ ដែលជារបស់អមតៈសម្រាប់លោកអ្នកដឹងទាំងឡាយ" ។

សេចក្ដីបាមោជ្ជៈដូចពោល នឹងប្រាកដច្បាស់ដល់អ្នកដែលមានសតិ សមាធិ និងបញ្ញាចាស់ក្លាតាមសេចក្ដីដែលនឹងពោលតទៅក្នុងបរិច្ឆេទទី ៥ អ្នកបដិបត្តិ ទើបមិនចាំបាច់ត្រូវព្យាយាមដើម្បីឲ្យកើតបាមោជ្ជៈ ទោះបីយ៉ាងណាក៏ដោយ ក្នុងខណៈខ្លះ ដែលកំណត់ដឹងបានមិនល្អ ហើយកើតសេចក្ដីធុញទ្រាន់ គប្បីរលឹកដល់គុណរបស់ព្រះរតនៈត្រៃ ប្រយោជន៍នៃការចំរើនវិបស្សនា សេចក្ដីផូរផង់នៃសីលតាំងអំពីចាប់ផ្ដើមមកបដិបត្តិធម៌ ក្នុងសំណាក់កម្មដ្ឋាន និងភាពប្រសើរនៃវិបស្សនា ដែលប្រាសចាកកិលេសលាយឡំ ដូចនេះជាដើម ឬកំណត់ដឹងការធុញទ្រាន់រហូតដល់អស់ទៅ ហើយបន្តឲ្យកើតបាមោជ្ជៈ ដើម្បីកំចាត់ការធុញទ្រាន់ ។

ការផុញទ្រាន់ក្នុងការចំរើនវិបស្សនា ឈ្មោះថា ការមិនត្រេក-អរក្នុងភាវនា មានបុគ្គលច្រើនសន្ធឹកសន្ធាប់មិនអាចបដិបត្តិធម៌បាន ព្រោះត្រូវការផុញទ្រាន់គ្របសង្កត់ អ្នកដែលអាចបដិបត្តិធម៌អស់កាលយូរមានចំនួនតិចណាស់ មនុស្សទូទៅទើបរិលស្វាប់រិលកើតយ៉ាងនេះ ដូចព្រះពុទ្ធវចនៈក្នុងគម្ពីរធម្មបទថា

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ

សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ[៤៥] ។

"សត្វលោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ ( នូវខន្ធាទិលោកនេះដោយអំណាចអនិច្ចលក្ខណៈជាដើម ) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប ( ដែលជាប់សំណាញ់របស់ព្រានហើយ ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ" ។

ក្នុងគម្ពីរអដ្ឋកថា[៤៦] អធិប្បាយពាក្យថា "មនុស្សតិចនឹងទៅកាន់ឋានសួគ៌"សំដៅដល់មនុស្សតិចនឹងទៅកាន់ឋានសួគ៌ និងនិព្វានពាក្យនេះ ទើបសំដៅដល់ការបាក់ដុះព្រះនិព្វានទៀតផង ។

អ្នកដែលកំពុងចំរើនវិបស្សនានោះ ខណៈខ្លះ អាចកំណត់ដឹងទាន់សភាវធម៌បច្ចុប្បន្នបានមិនច្បាស់លាស់ ឬអាចមិនសម្រេចនូវវិបស្សនាញាណលំដាប់ខ្ពស់ជាងខាងដើម ធ្វើឲ្យកើតការធុញទ្រាន់ក្នុងភាវនា កាលកើតសភាវៈដូចពោល ភាពរីករាយត្រេកអរក្នុងភាវនានឹងអន្តរធានទៅ ញុំាំងផលឲ្យមិនអាចបដិបត្តិធម៌តទៅ កាលបើដូច្នេះ គេរមែងរួចផុតអំពីវដ្តសង្សារមិនបាន ភាវៈមិនត្រេកអរក្នុងភាវនា ទើបជាគ្រឿងរាំងផ្លូវរួចផុតបាកទុក្ខ ។

## ៨. អកុសលធម៌ធាំងពួង

សព្វេបិ កុសលា ធម្មា អរិយានំ និយ្យានំ ។ តេហិ ច កុសលេហិ ធម្មេហិ អរិយា និយ្យន្តិ ។ សព្វេបិ អកុសលា ធម្មា និយ្យានាវរណំ ។ តេហិ ច អកុសលេហិ ធម្មេហិ និវុត្តា សព្វេ-បិកុសលេ ធម្មេ អរិយានំ និយ្យាន នប្បជានាតីតិ សព្វេបិ អកុសលា ធម្មា និយ្យានាវរណំ[៤៧] ។

"កុសលធម៌ទាំងពួង ជាផ្លូវរួចផុតបាកទុក្ខរបស់ព្រះអរិយៈ

ទាំងឡាយ ព្រោះព្រះអរិយៈទាំងឡាយ រមែងរួចផុតចាកទុក្ខ ដោយកុសលធម៌នោះ អកុសលធម៌ទាំងពួង ជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ ព្រោះបុគ្គលរមែងមិនដឹងកុសលធម៌ថា ជាផ្លូវរួចផុតរបស់ព្រះអរិយៈ ពីព្រោះត្រូវអកុសលធម៌នោះបិទបាំងទុក ដូចនោះ អកុសលធម៌ទាំងពួង ទើបជាគ្រឿងរាំងផ្លូវរួចផុតចាកទុក្ខ " ។

កុសលធម៌ទាំងអស់មានទាន សីល ភាវនា និងការខ្វល់ខ្វាយជាដើម ជាផ្លូវរួចផុតចាកទុក្ខរបស់ព្រះអរិយៈទាំងឡាយ ដែលឈ្មោះជាកុសលដែលមិនគួរធ្វើមិនមានទេ គ្រប់យ៉ាងជាផ្លូវនៃការរួចផុតចាកទុក្ខទាំងអស់ ដោយស្របតាមចិត្តដែលតាំងទុកល្អ ដើម្បីការរួចផុតចាកទុក្ខ ។

ដូចមានព្រះពុទ្ធវចនៈសម្តែងថា

សម្មា បណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ[៤៩]។

"ចិត្តដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះឲ្យប្រសើរជាងហេតុនោះបាន" ។

សោ វត ភិក្ខុ សម្មា បណិហិតាយ ទិដ្ឋិយា សម្មា បណិ-

ហិតាយ មគ្គភាវនាយ អវិជ្ជំ ភេច្ឆតិ, វិជ្ជំ ឧប្បាទេស្សតិ, និព្វានំ សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតី”តិ[៤៩] ។

“ភិក្ខុនោះ ទម្លាយអវិជ្ជា និងញ៉ាំងវិជ្ជាឲ្យកើតឡើងនឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយការឃើញដែលតាំងទុកល្អ ដោយការអប់រំមគ្គដែលតាំងទុកល្អ សេចក្ដីនោះ ជាឋានៈដែលមានពិត” ។

ទោះបីយ៉ាងណាក៏ដោយ ការចំរើនវិបស្សនាជាកុសលជាន់ខ្ពស់ ដែលជាផ្លូវរួចផុតចាកទុក្ខយ៉ាងពិតប្រាកដ អ្នកបដិបត្តិទើបគួរចំរើនវិបស្សនាជាប់បន្តគ្នាជានិច្ច ព្រោះវិបស្សនាភាវនា ជាកុសលថ្នាក់ខ្ពស់ ក្នុងបណ្ដាលោកិយកុសល ដែលធ្វើឲ្យអ្នកបដិបត្តិទទួលនូវព្រះនិព្វានជាអារម្មណ៍ ដោយមគ្គញាណ ក្នុងខណៈដែលវិបស្សនាចាស់ក្លាពេញបរិបូណ៌ ដូច្នោះ កាលកំពុងចំរើនវិបស្សនា អ្នកបដិបត្តិ ទើបមិនគួរធ្វើទុកក្នុងចិត្តចំពោះការចំរើនកុសលដទៃ ។ សូមលើករឿងព្រះអត្ថទត្ថថេរៈ មកជាតួយ៉ាងក្នុងទីនេះ ។

# គួរស្វែងរកប្រយោជន៍ខ្លួនជាគោល

ក្នុងពេលដែលព្រះមានព្រះភាគ ស្តេចជិតរំលត់ខន្ធបរិនិព្វាន មានភិក្ខុមួយអង្គត្រិះរិះថា ព្រះអង្គនឹងបរិនិព្វានក្នុង ៤ ខែទៀតខាងមុខ តែចំពោះសមណកិច្ចរបស់យើង នៅមិនទាន់ស្រេចអស់ យើងនឹងព្យាយាមបដិបត្តិធម៌ឲ្យសម្រេចជាព្រះអរហន្ត កាលព្រះអង្គកំពុងនៅមានព្រះជន្ម ទើបបានចំរើនសមណធម៌ ដែលជាប្រយោជន៍ខ្លួន មិនបានចូលរួមប្រជុំប្រឹក្សាកិច្ចផ្សេងៗជាមួយភិក្ខុដទៃពួកភិក្ខុ ទើបហៅលោកថា ព្រះអត្តទត្ថៈ ប្រែថា អ្នកស្វែងរកតែប្រយោជន៍ខ្លួន ខណៈនោះ ភិក្ខុជាបុថុជ្ជនអង្គខ្លះ មិនពេញចិត្ត ទើបក្រាបទូលព្រះមានព្រះភាគថា ភិក្ខុអង្គនោះមិនបានជ្រះថ្លានឹងព្រះអង្គ ទើបមិនមកប្រជុំប្រឹក្សាកិច្ចជាប់ទាក់ទងជាមួយការបរិនិព្វានរបស់ព្រះអង្គ ព្រះមានព្រះភាគបានត្រាស់ហៅព្រះអត្តទត្ថៈមកសួរកាលទ្រង់ជ្រាបសេចក្តីនោះ ហើយបានត្រាស់អនុមោទនាសាធុការ ហើយទ្រង់ទូន្មានពួកភិក្ខុដូចសេចក្តីក្នុងអដ្ឋកថាធម្មបទថា

សត្ថា តស្ស សាធុការំ កត្វា ភិក្ខវេ យស្ស មយិ សិនេហោ

អត្ថិ ។ តេន អត្តទត្ថេន វិយ ភវិតុំ វដ្ដតិ ។ ន ហិ ភិក្ខវេ គន្ធាទីហិ បូជេន្តា មំ បូជេន្តិ ។ ធម្មានុធម្មបដិបត្តិយា បន មំ បូជេន្តិ។ តស្មា អញ្ញេនបិ អត្តទត្ថេន សទិសេនេវ ភវិតព្វន្តិ[៥០]។

"ព្រះបរមសាស្តា ទ្រង់ធ្វើសាធុការដល់ភិក្ខុនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានសេចក្តីជ្រះថ្លាក្នុងតថាគត លោកគួរដូចជាព្រះអត្តទត្ថៈ ព្រោះអ្នកបូជាដោយគ្រឿងក្រអូបជាដើមមិនឈ្មោះថា បូជាតថាគតទេ តែអ្នកបូជាដោយការបដិបត្តិធម៌ដ៏សមគួរដល់លោកុត្តរធម៌ ឈ្មោះថា រមែងបូជាតថាគត ដូច្នេះ សូម្បីភិក្ខុអង្គដទៃ ក៏គួរធ្វើដូចជា ព្រះអត្តទត្ថៈ" ។

បន្ទាប់អំពីនោះ ព្រះអង្គត្រាស់គាថានេះថា

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា[៥១] ។

"បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃសូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន ( នោះ )" ។

បើនិយាយតាមផ្លូវលោក អ្នកដែលស្វែងរកប្រាក់ ឲ្យអ្នកដទៃបានទាំងរយទាំងពាន់ តែបើប្រយោជន៍ខ្លួនបាត់បង់ ក៏មិនគួរស្វែងរកប្រាក់ឲ្យអ្នកដទៃទេ សូម្បីតាមផ្លូវធម៌ ក៏ដូចគ្នា អ្នកដែលអាចបង្រៀនឲ្យអ្នកដទៃសម្រេចអរហត្តផលបាន ក៏មិនគួរលះប្រយោជន៍ខ្លួនដែលសូម្បីត្រឹមតែជាសោតាបត្តិផល ព្រោះប្រយោជន៍របស់អ្នកដទៃធ្វើឲ្យខ្លួននៅជាសុខមិនបាន ដូច្នោះ ទើបបដិបត្តិធម៌ស្វែងរកប្រយោជន៍ខ្លួនជាគោល សូម្បីក្នុងបណ្តាប្រយោជន៍ខ្លួន ដែលមានច្រើនយ៉ាង ក៏គួរលះបង់ប្រយោជន៍ដែលមិនសំខាន់ ស្វែងរកធ្វើប្រយោជន៍ ដែលសំខាន់ គឺការសម្រេចធម៌ជាន់ខ្ពស់ ដូចគម្ពីរអដ្ឋកថាពោលថា

អត្តទត្ថំ ន ហាបយេតិ កិញ្ចាបិ នាម សង្ឃស្ស ឧប្បន្នំ ចេតិយប្បដិសង្ខរណាទិកិច្ចំ វា ឧបជ្ឈាយាទិវត្តំ វា ន ហាបេតព្វំ ។ អាភិសមាចារិកវត្តញ្ហិ បូរេន្តោយេវ អរិយផលាទីនិ សច្ឆិករោតិ ។ តស្មា អយម្បិ អត្តទត្ថោយេវ ។ យោ បន អច្ចារទ្ធវិបស្សកោ អជ្ជ វា សុវេ វា បដិវេធំ បត្ថយមានោ វិចរតិ ។ តេន ឧបជ្ឈាយាទីនិបិ ហាបេត្វា អត្តនោ កិច្ចមេវ កាតព្វំ[៥២] ។

"ពាក្យថា **អត្ថទត្តំ ន ហាបយេ** មានសេចក្តីថា ធម្មតា ភិក្ខុមិនគប្បីបោះបង់ចោលកិច្ច មានការបដិសង្ខរណៈ ( ជួសជុល ) ព្រះចេតិយ៍ជាដើមដែលកើតឡើងដល់សង្ឃ ឬ ការធ្វើឧបជ្ឈាយវត្តជាដើម ព្រោះអ្នកដែលបំពេញអភិសមាចារិកវត្ត រមែងនឹងធ្វើឲ្យជាក់ច្បាស់អរិយផលជាដើមបាន ដូចនោះ សូម្បីកិច្ចខាងដើម ក៏ឈ្មោះថា ប្រយោជន៍ខ្លួនដោយពិត តែភិក្ខុណាប្រារព្ធវិបស្សនាតឹងរ៉ឹងរមែងត្រាច់ទៅប្រាថ្នាការបាក់ធ្លុះរហូតក្នុងថ្ងៃនេះ ឬព្រឹកនេះ ភិក្ខុនោះសូម្បីបោះបង់ឧបជ្ឈាយវត្តជាដើមក៏គប្បីធ្វើកិច្ចរបស់ខ្លួនប៉ុណ្ណោះ"។

សេចក្តីពិតហើយ ភិក្ខុជាសទ្ធិវិហារិក គួរនឹងធ្វើឧបជ្ឈាយវត្តជាដើម អ្នកមិនធ្វើនឹងត្រូវអាបត្តិទុក្កដ ព្រោះបែកធ្លាយវត្ត ( វត្តភេទទុក្កដ ) ទាំងបាតិមោក្ខសំវរសីលក៏សៅហ្មង ធ្វើឲ្យអន្តរាយចំពោះសួគ៌ និងនិព្វាន ដូច្នោះក៏ដោយ ភិក្ខុអាចចំរើនវិបស្សនា ដោយមិនបាច់ធ្វើឧបជ្ឈាយវត្ត ដោយមិនបាច់សូមអនុញ្ញាតិព្រះឧបជ្ឈាយ៍មុនសិន នឹងចាំបាច់ពោលទៅថ្វី ក្នុងសង្ឃកិច្ច មានការធ្វើបដិសង្ខរណៈព្រះចេតីយ៍ជាដើម ។

ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ជិតនឹងរំលត់ខន្ធបរិនិព្វាន ក្នុងសាលវនឧទ្យានរបស់មល្លក្សត្រ ក្នុងក្រុងកុសិនារា ទេវតា និងព្រហ្មចំនួនច្រើនក្នុងម៉ឺនចក្រវាឡ មកបូជាព្រះអង្គ ដោយគ្រឿងក្រអូបនិងតន្ត្រី ព្រះអង្គត្រាស់ដល់ការបូជាទាំងនោះថា

ន ខោ អានន្ទ ឯត្តាវតា តថាគតោ សក្កតោ វា ហោតិគរុកតោ វា មានិតោ វា បូជិតោ វា អបចិតោ វា ។ យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា ធម្មា-នុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី ។ សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ ។ តស្មាតិហានន្ទ ធម្មានុធម្មប្បដិបន្នា វិហរិស្សាម សាមីចិប្បដិបន្នា អនុធម្មចារិនោតិ ។ ឯវញ្ហិ វោ អានន្ទ សិក្ខិតព្វំ[៤៣]។

"ម្នាលអានន្ទ តថាគតមិនបានឈ្មោះថា បរិសទ្យធ្វើសក្ការៈក្តី គោរពក្តី រាប់អានក្តី បូជាក្តី នឹងកោតក្រែងក្តី ដោយហេតុមានប្រមាណប៉ុណ្ណោះឡើយ ម្នាលអានន្ទ បុគ្គលណាមួយ ទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ សមគួរ

ដល់ធម៌ ប្រតិបត្តិដោយសេចក្ដីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថា ធ្វើសក្ការៈ គោរពរាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្ដម ម្នាលអានន្ទ ព្រោះហេតុនោះ បរិសទ្យក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយ នឹងប្រតិបត្តិនូវធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីកោតក្រែង ប្រព្រឹត្តតាមធម៌ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះ" ។

ក្នុងគម្ពីរអដ្ឋកថា"អធិប្បាយរឿងនេះថា សូម្បីការធ្វើសក្ការៈបូជាព្រះអង្គ ដោយរបស់ក្រអូបជាដើម នឹងជាកុសលធម៌ ដែលជាផ្លូវរួចផុតចាកទុក្ខ តែការបំពេញបារមីមានដល់ ៤ អសង្ខេយ្យកំរៃមួយសែនមហាកប្បរបស់ព្រះអង្គ មានគោលដៅដើម្បីប្រោសនូវពួកវេនេយ្យសត្វឲ្យសំរេចមគ្គផល មិនមែនដើម្បីទទួលការធ្វើសក្ការៈបូជា បើបុគ្គលពេញចិត្តដោយការធ្វើសក្ការៈបូជា ដូច្នោះហើយ មិនបានបំពេញកុសល ដែលធ្វើឲ្យសម្រេចធម៌ដោយត្រង់ គឺ សីល សមាធិ និងបញ្ញា រមែងនឹងបន្ទុះមគ្គផលនិងរួចផុតអំពីវដ្ដទុក្ខក្នុងជាតិបច្ចុប្បន្នមិនបាន ។

ម្យ៉ាងទៀត ការធ្វើសក្ការៈបូជាដូចពោលមកនេះ មិនអាចធ្វើឲ្យព្រះសាសនាតាំងបានយូរ គឺត្រឹមតែការផឹកយាគូមួយគ្រូក ឬសូម្បីការសាងវត្ត ចេតិយ៍ត្រឹមមួយពាន់ ក៏ជាកុសលដល់អ្នកសាងថ្វាយមែនពិត តែមិនមែនជាការបូជាធ្វើឲ្យតម្រង់ព្រះសាសនាបានយូរឡើយ តែចំពោះការបំពេញសីល សមាធិ និងបញ្ញា ជាការបដិបត្តិបូជា មានប្រយោជន៍ដល់អ្នកបូជាយ៉ាងពិតប្រាកដ ថែមទាំងផ្តល់ប្រយោជន៍ឲ្យព្រះសាសនាតាំងមាំ ដោយហេតុនេះ បដិបត្តិបូជា ទើបជាការបូជាដ៏កំពូល ដូចក្នុងធម្មទាយាទសូត្រថា

**ធម្មទាយាទា មេ ភិក្ខវេ ភវថ ។ មា អាមិសទាយាទា ។ អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ មេ សាវកា ធម្មទាយាទា ភវេយ្យុំ ។ នោ អាមិសទាយាទាតិ[៥៥] ។**

"ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរជាធម្មទាយាទរបស់តថាគត កុំជាអាមិសទាយាទ តថាគតមានសេចក្តីករុណាដល់អ្នកថា ( ធ្វើដូចម្តេចហ្ន៎ សាវករបស់តថាគត គប្បីជាធម្មទាយាទ មិនមែនជាអាមិសទាយាទ )" ។

សេចក្តីនេះមានន័យថា បច្ច័យ ៤ គឺចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជៈ ដែលព្រះអង្គទ្រង់អនុញ្ញាតដល់ភិក្ខុទាំងឡាយ ជាអាមិសវត្ថុ ភិក្ខុអ្នកទទួលអាមិសពួកនោះហើយ ពេញចិត្តដោយការបរិភោគប្រើប្រាស់ ដោយមិនមានការព្យាយាមបដិបត្តិធម៌ដើម្បីបន្ទុះមគ្គផលនិងនិព្វាន ឈ្មោះថា អាមិសទាយាទ គឺអ្នកទទួលមរតក ដែលជាអាមិសៈ សូម្បីកុសលទាំងអស់ ដែលធ្វើដោយសង្ឃឹមសេចក្តីសុខក្នុងភព ក៏ចាត់ថាជាអាមិសៈដូចគ្នា ភិក្ខុឬយកវាសអ្នកត្រេកអរកុសលនោះ ឈ្មោះថា អាមិសទាយាទដោយបរិយាយ បុគ្គលដូចពោលមកនេះ បានជួបជាមួយព្រះសាសនាដែលមិនងាយនឹងជួបប្រទះបាន ហើយទទួលយកត្រឹមតែអាមិសៈរមែងមិនអាចរួចផុតអំពីទុក្ខក្នុងវដ្តៈបាន ព្រះអង្គទ្រង់ប្រមើលមើលថា ពួកគេត្រូវជួបជាមួយទុក្ខក្នុងវដ្តៈដ៏យូរអង្វែង ទើបទ្រង់អាណិតពួកសត្វ ដូចមាតាឃើញនូវបុត្រ ដែលនឹងប្រឈមមុខជាមួយនឹងសេចក្តីទុក្ខដ៏ធំក្រៃលែង ក៏កើតសេចក្តីករុណាអាណិត ដូច្នោះ ទើបទ្រង់ទូន្មាន មិនឲ្យសាវកត្រេកអរក្នុងអាមិសៈប៉ុណ្ណោះ ។

ពិតមែនហើយលោកុត្តរធម៌ គឺមគ្គផលនិងនិព្វាន ជាធម្មមរតក

របស់ព្រះអង្គ សូម្បីខបដិបត្តិដែលធ្វើឲ្យបន្ទុះធម៌ពួកនោះបានដល់សីល សមាធិ និងវិបស្សនា ក៏ចាត់ថា ជាធម្មវតកដោយបរិយាយក្រៅអំពីនេះ កុសលទាំងអស់ ដែលធ្វើដើម្បីការសម្រេចនិព្វានបានដល់ ទាន សីលជាដើម ក៏ឈ្មោះថា ធម្មវតកដោយបរិយាយព្រោះជាហេតុនៃការសម្រេចធម៌ ក្នុងអនាគតជាតិ ដូច្នោះ សាវករបស់ព្រះបរមសាស្តា ទើបគប្បីព្យាយាមបដិបត្តិដើម្បីទទួលយកមវតកធម៌ ដោយត្រង់និងដោយបរិយាយ យ៉ាងណាក៏ដោយព្រះអង្គទ្រង់បំណងឲ្យទទួលធម្មវតកដោយត្រង់ ដែលជាមគ្គផលនិងនិព្វាន ព្រមទាំងសីល សមាធិ និងវិបស្សនា ដែលជាហេតុឲ្យសម្រេចធម៌ក្នុងបច្ចុប្បន្នជាតិ ។ ដូចដែលព្រះអង្គទ្រង់ណែនាំព្រះបោដ្ឋិលៈទុក ( រឿងព្រះបោដ្ឋិលៈនឹងពោលក្នុងបរិច្ឆេទទី ៤ ) ពុទ្ធបរិសទ្យ ទើបគួរស្វែងរកការសម្រេចមគ្គផលជាព្រះអរហន្តក្នុងជាតិនេះ ជាគោលដៅនៃជីវិត ដូចព្រះពុទ្ធវចនៈក្នុងគម្ពីរធម្មបទថា

ន សីលព្វតមត្តេន ពាហុសច្ចេន វា បន
អថ វា សមាធិលាភេន វិវិត្តសយនេន វា ។
ផុសាមិ នេក្ខម្មសុខំ អបុថុជ្ជនសេវិតំ

ភិក្ខុ វិស្សាសមាបាទិ អប្បត្តោ អាសវក្ខយំ[៥៦] ។

"ម្នាលភិក្ខុ បើភិក្ខុមិនទាន់ដល់ នូវការអស់អាសវៈទេ កុំអាលទុកចិត្ត ដោយគុណត្រឹមតែសីលនិងវត្ត ឬដោយភាពជាអ្នកចេះដឹងច្រើន មួយទៀត ដោយការបានសមាធិ ឬដោយការដេកក្នុងទីស្ងាត់ ឬក៏ដោយគុណមានប្រមាណប៉ុណ្ណេះថា អាត្មាអញពាល់ត្រូវនូវនេក្ខម្មសុខ ដែលបុថុជ្ជនមិនដែលជួបប្រសព្វ ដូច្នេះឡើយ" ។

ព្រះពុទ្ធតម្រាស់នេះ ត្រាស់ទូន្មានភិក្ខុអ្នកទ្រទ្រង់សីលជាដើមក្នុងភិក្ខុពួកនោះ អ្នកខ្លះត្រិះរិះថា ខ្លួនមានសីលបរិសុទ្ធមិនយូរនឹងបន្ទុះអរហត្តផលបាន ទើបដេកស្ងៀម មិនព្យាយាមបដិបត្តិធម៌ អង្គខ្លះត្រិះរិះថា ខ្លួនកាន់ធុតង្គខ្លះ ជាពហុស្សូតខ្លះ បន្ទុះសមាបត្តិ ៨ ខ្លះ នៅក្នុងព្រៃដ៏ស្ងៀមស្ងាត់ខ្លះ អង្គខ្លះបន្ទុះអនាគាមិផលហើយ ត្រិះរិះថា ខ្លួនអាចសម្រេចអរហត្តផលបានមិនលំបាក ហើយដេកស្ងៀមទៅ ព្រះអង្គទើបត្រាស់ណែនាំថា កុំដេកស្ងៀមរហូតជាងនឹងសម្រេចធម៌ជាព្រះអរហន្ត ។

## វិធីលះសេចក្ដីរវើរវាយ ៥ ប្រការ

សេចក្ដីនេះ នឹងឃើញបានថា ការចំរើនវិបស្សនាភាវនាជាកិច្ចដែលប្រសើរ អ្នកចំរើនវិបស្សនា ឈ្មោះថា បូជាព្រះបរមសាស្ដាដោយការបូជាដ៏ឧត្ដម ទាំងជាធម្មទាយាទ អ្នកទទួលមរតកធម៌ដ៏ប្រសើរ ទាំងជាអ្នកប្រព្រឹត្តតាមពាក្យទូន្មាន ដ៏ប្រសើរនៃព្រះបរមសាស្ដា ដោយហេតុនេះ ក្នុងខណៈដែលចំរើនវិបស្សនា ទើបគួរតាំងចិត្តកំណត់ដឹងយ៉ាងបន្តបន្ទាប់មិនដាច់ តាំងពីខណៈចូលដេករហូតដេកលក់ស៊ប់ ដោយមិនចាំបាច់ត្រូវទៅចំរើនកុសលដទៃ ទោះបីយ៉ាងណាក៏ដោយ ក្នុងខណៈខ្លះ ក៏អាចចំរើនសមថភាវនា ដើម្បីលះកាមវិតក្កៈជាដើមបានដូចគ្នា ។

ក្នុងទីនេះ នឹងពោលដល់សេចក្ដីរវើរវាយ ៥ ប្រការ តាមសេចក្ដីក្នុងគម្ពីរមូលបណ្ណាសកៈ វិតក្កសណ្ឋានសូត្រ[៣]ដោយសង្ខេប គឺ ៖

១. ការប្រើសមថៈគ្របសង្កត់សេចក្ដីរវើរវាយ។

២ . ការពិចារណាទោសរបស់សេចក្ដីរវើរវាយ ។

៣ . ការឈប់កំណត់ដឹងមួយគ្រា ។

៤ . ការកំណត់ដឹងមូលហេតុនៃការរវើរវាយ ។

៥ . ការកំណត់បែបផ្ដោតអារម្មណ៍ ។

គប្បីជ្រាបសេចក្ដីពិស្ដារដូចតទៅនេះ

**ការប្រើសមថៈគ្របសង្កត់សេចក្ដីរវើរវាយ**

កាលកំណត់ដឹងសេចក្ដីត្រេកអរ ដែលកើតឡើងក្នុងបុរសឬស្ត្រី គប្បីចំរើនអសុភភាវនា កាលសេចក្ដីក្រោធកើតឡើង គប្បីចំរើនមេត្តាភាវនា កាលសេចក្ដីលោភក្នុងវត្ថុរបស់របរដែលកើតឡើង គប្បីពិចារណាថា វត្ថុទាំងនោះមិនមានម្ចាស់របស់យ៉ាងពិតប្រាកដ ឬពិចារណាថា ជារបស់ដែលតាំងនៅមួយខណៈ ហើយពិចារណាថា ជារបស់មិនទៀង កាលកើតទោសៈ ក៏គប្បីពិចារណាដោយសេចក្ដីជាធាតុថា មិនមានមនុស្សដែលគួរឲ្យក្រោធ មានត្រឹមធាតុ ៤ ដែលមកប្រជុំគ្នាជាបុគ្គលប៉ុណ្ណោះ កាលកើតមោហៈ ដែលកើត

ព្រមដោយការរើរវាយឬសង្ស័យ គប្បីកំចាត់មោហៈនោះ ដោយការសាកសួរនិងស្តាប់ធម៌ជាដើម ។

ន័យម្យ៉ាងទៀត កាលកើតកិលេសយ៉ាងណានិមួយ ក៏គប្បីកំចាត់ដោយសមថភាវនាដែលខ្លួនជំនាញ រមែងនឹងលះកិលេសបានគ្រប់យ៉ាង ។

ប្រសិនបើចំរើនវិបស្សនាអស់កាលយូរ ហើយកើតសេចក្តីហត់នឿយផ្លូវកាយ និងចិត្ត គប្បីចម្រើនសមថភាវនាដូចពោល ចំណែកអ្នកដែលមិនធ្លាប់ជាមួយការចម្រើនសមថភាវនា ក៏គប្បីចម្រើនសតិកំណត់ដឹងសភាវធម៌ដែលប្រាកដច្បាស់ សូម្បីសេចក្តីក្តៅក្រហាយចិត្ត ដែលកើតដល់ភិក្ខុអ្នកកន្លងល្មើសសីល ក៏គប្បីលះដោយការសម្តែងអាបត្តិជាដើម ។

ម្យ៉ាងទៀត ការពិចារណាដូចនេះស្របជាមួយនឹងអ្នកដែលមានការស្តាប់ ឬអ្នកដែលចំរើនសមថភាវនាយ៉ាងជំនាញហើយ ។

## ការពិចារណាទោសនៃសេចក្ដីរេវីរវាយ

អ្នកបដិបត្តិគប្បីពិចារណាទោសនៃការរេវីរវាយថា បើសេចក្ដីត្រិះរិះក្នុងកាមគុណជាដើមករពូនឡើង អាចធ្វើឲ្យសីលវិបត្តិហើយធ្លាក់ទៅកាន់អបាយភូមិ រាំងការកើតជាមនុស្ស ឬទេវតាជាន់ខ្ពស់ និងជាហេតុឲ្យពួកសត្វមិនអាចរួចផុតអំពីវដ្ដទុក្ខបាន ។ ពិតហើយ ពួកសត្វចូលចិត្តតាមចំណង់ខ្លួនឯង ទើបថែរក្សារាងកាយឲ្យសុខសប្បាយ កាលជាដូច្នេះ រមែងជួបជាមួយទុក្ខជាអនេកប្បការក្នុងសង្សារវដ្ដ មានគាថាមួយ ដែលបោរាណាចារ្យចងក្រងទុកថា

នាហំ ទាសោ ភដោ តុយ្ហំ នាហំ បោសេមិ ទានិ តំ

តូមេវ បោសេន្តោ ទុក្ខំ បត្តោ វដ្ដេ អនប្បកំ ។

“យើងមិនមែនទាសៈ ឬអ្នកធ្វើការងាររបស់ម្ចាស់ ( រាងកាយ ) យើងនឹងមិនថែរក្សាម្ចាស់ទៀតទេ ក្នុងកាលនេះ យើងបានទទួលទុក្ខច្រើនសន្ធឹកសន្ធាប់ក្នុងវដ្ដៈ ព្រោះថែរក្សាម្ចាស់ដោយពិត” ។

គាថានេះ ជាបទចងក្រងរបស់បោរាណាចារ្យប្រទេសភូមាដែលតែងកំណាព្យ ក្នុងគម្ពីរវិសុទ្ធិមគ្គ ជាកម្រងមានសេចក្ដីក្នុងគម្ពីរវិសុទ្ធិ-

មគ្គថា

សចេ បន កតិបាហំ ភេសជ្ជំ ករោតស្សបិ ន វិបសម្មតិ ។ នាហំ ទាសោ, ន ភជកោ ។ តំ យេវ ហិ បោសេន្តោ អនមតគ្គេ សំសារវដ្ដេ ទុក្ខំ បត្តោតិ អត្តភាវំ គរហិត្វា សមណធម្មោ កាតព្វោតិ[៥៨] ។

“ម្យ៉ាងទៀត កាលភិក្ខុឆាន់ថ្នាំពីរបីថ្ងៃហើយរោគមិនស្ងប់ទៅទេ លោកគប្បីតិះដៀលរាងកាយថា ( យើងមិនមែនទាសៈ ឬអ្នកធ្វើការ [របស់ម្ចាស់] យើងបានទទួលទុក្ខក្នុងសង្សារវដ្ដ ដែលមិនប្រាកដខាងដើម ព្រោះថែរក្សាម្ចាស់ដោយពិត ) ហើយចម្រើនសមណធម៌ ]។

## ការឈប់កំណត់ដឹងមួយគ្រា

ក្នុងខណៈខ្លះ សេចក្ដីរើរវាយរាយមាយអាចកើតឡើងជានិច្ច ក្នុងអារម្មណ៍យ៉ាងណានិមួយ ក្នុងខណៈនោះ អ្នកបដិបត្តិមិនគប្បីធ្វើទុកក្នុងចិត្តអារម្មណ៍ដូចពោល ទាំងគួរឈប់ចំរើនសតិកំណត់ដឹងសេចក្ដីរើរវាយនោះ ការឈប់ពិចារណាមួយគ្រានេះ នឹងជួយប្រយោជន៍ដល់អ្នកបដិបត្តិ ដែលមានសេចក្ដីប្រាថ្នាការឈានទៅមុខ ឬមានសេចក្ដីព្យាយាមក្នុងការបដិបត្តិច្រើន រហូតលើសទៅ

ដោយចំពោះអ្នកដែលសំរេចសង្ខារុបេក្ខាញាណហើយ មិនសំរេចមគ្គញាណអាចកើតសភាវៈយ៉ាងនេះ ទើបគួរឈប់ចំរើនវិបស្សនា ២ ម៉ោង ៣ ម៉ោងរហូតកន្លះថ្ងៃ ឬមួយថ្ងៃហើយសន្ទនាប្រាស្រ័យតាមប្រក្រតី ឬទៅថ្វាយបង្គំព្រះចេតីយ៍ ឬងូតទឹក បោកសំលៀកបំពាក់ ឬដេកលក់តាមសប្បាយដូច្នេះជាដើម បន្ទាប់មកទើបចំរើនសតិកំណត់ដឹងសភាវធម៌បច្ចុប្បន្ន ដូចសេចក្តីក្នុងព្រះបាលីថា

**តេន ភិក្ខវេ ភិក្ខុនា អសម្មោសអមនសិការោ អាបជ្ជិតព្វោ**[៥៩]។

“ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីដល់ការមិនអប់រំដឹង និងមិនធ្វើទុកក្នុងចិត្ត” ។

ម្យ៉ាងទៀត ក្នុងគម្ពីរអដ្ឋកថា[៦០]ពោលថា បើសេចក្តីរវើរវាយនៅមិនទាន់បាត់ទៅដោយការមិនធ្វើទុកក្នុងចិត្ត បដិបត្តិយ៉ាងនេះក៏គួរស្វាធ្យាយគម្ពីរអានគម្ពីរ ឬត្រួតពិនិត្យរបស់របរថា វត្ថុនេះ ជាប្រអប់ឈើគូស នេះជាឈើគូស នេះជាដែកដាប់ នេះជាកាំបិទ នេះជាកន្ត្រៃកាត់ក្រចក នេះជាម្ជុល នេះជាចេសជាដើម ឬគួរធ្វើការងារ មានការសាងកុដិកម្មដ្ឋានជាដើម តាមន័យដូចដែល

បោរាណាចារ្យពោលទុក ។

## ការកំណត់ដឹងមូលហេតុនៃការរេរីរវាយ

ក្នុងខណៈខ្លះ អ្នកបដិបត្តិគប្បីពិចារណារកមូលហេតុនៃសេចក្ដីរវើរវាយ ពិតហើយ មុនដែលសេចក្ដីរវើរវាយនឹងកើតឡើង រមែងមានចិត្តដែលត្រូវការនឹងគិតរឿងរ៉ាវផ្សេងៗ កើតឡើងមុន បើអ្នកបដិបត្តិកំណត់ដឹងចិត្ត ដែលលំបាកនឹងគិតបានទាន់ពេល ការគិតក៏នឹងមិនកើតឡើង ឬបើការគិតកើតឡើងហើយ អ្នកបដិបត្តិកំណត់ដឹងហើយការគិតនោះមិនបាត់ទៅព្រោះចិត្តដែលលំបាកនឹងគិតមានកម្លាំងច្រើន ក៏គប្បីកំណត់ដឹងចិត្ត ដែលលំបាកនឹងគិតដូចពោល ។

## ការកំណត់ដឹងបែបផ្តោតអារម្មណ៍

វិធីនេះជាការបដិបត្តិតាមប្រក្រតី តែផ្ដើមការផ្ដោតអារម្មណ៍ឲ្យច្រើនឡើងជាងខាងដើម ដូចសេចក្ដីក្នុងព្រះបាលីថា

**តេន ភិក្ខវេ ភិក្ខុនា ទន្តេកិ ទន្តមាធាយ ជិវ្ហាយ**

តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហិតព្វំ[៦១] ។

“ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីប្រើធ្មេញខាំធ្មេញ ប្រើអណ្តាត ទល់ពិតាន ប្រើចិត្តគ្របសង្កត់ចិត្ត” ។

វិធីនេះសមដល់អ្នកដែលមានការស្តាប់តិច នឹងចំរើនវិបស្សនាមួយខណៈ ដោយមានពេលបដិបត្តិមិនកំណត់ថ្ងៃ ឬកំណត់ខែម្យ៉ាងទៀត វិធីនេះ ហៅថា អប្បណិធាយភាវនា គឺភាវនាដែលមិនតាំងចិត្តទុកក្នុងអារម្មណ៍ដទៃ ចំណែកដែលពោលមកហើយ ៤ វិធីនឹងហៅថា បណិធាយភាវនា គឺ ភាវនាដែលតាំងចិត្តទុកក្នុងអារម្មណ៍ដទៃ ជាវិធីដែលសមគួរដល់អ្នកដែលមានការស្តាប់ច្រើន និងបានចំរើនវិបស្សនាអស់រយៈមួយខែ មួយឆ្នាំ វិធីទាំងពីរនេះមានក្នុងគម្ពីរសំយុត្តនិកាយ[៦២] ។

ក្រៅពីនេះ ក្នុងអដ្ឋកថា របស់សតិប្បដ្ឋានសូត្រជាដើម[៦៣] ពោលដល់ ការពិចារណាដើម្បីលះនីវរណៈ និងការពិចារណាដើម្បីកពូនពោជ្ឈង្គៈជាដើម ចំណែកធំការពិចារណា ពួកនោះរាប់ចូលក្នុងបណិធាយភាវនា ហើយទើបមិនបានពោលទុកក្នុងទីនេះទៀត ។

ដោយហេតុដែលពោលមកនេះ អ្នកដែលចំរើនវិបស្សនាភាវនាយ៉ាងជាប់តគ្នា កាលកើតសេចក្តីរវើរវាយឡើង គប្បីកំណត់ដឹងទាន់សភាវៈរវើរវាយជាគោល តែបើមិនអាចបញ្ឈប់ការគិតរវើរវាយបាន ក៏គប្បីចំរើនសមថភាវនាយ៉ាងណានិមួយ តាមសមគួរ ចំណែកអ្នកដែលមានការស្តាប់តិច គួរសូមពាក្យណែនាំអំពីព្រះវិបស្សនាចារ្យ លោកនឹងបង្ហាញណែនាំ តាមសមគួរដល់បុគ្គល ។

## ឧបសគ្គរបស់សមាធិ ៦ ប្រការ

ព្រះសារីបុត្រពោលដល់ឧបសគ្គរបស់សមាធិ និងវិធីកំចាត់ទុក ៦ ប្រការគឺ

១. ការគិតដល់អតីតកាល ។

២ . ការសង្ឃឹមអនាគតកាល ។

៣ . ការរួញរា ។

៤ . សេចក្តីព្យាយាមដ៏ក្រៃលែង ។

៥ . សេចក្តីប្រាថ្នាដ៏ក្រៃលែង ។

៦ . សេចក្ដីទម្រន់ ។

សេចក្ដីខាងដើមមានពិស្ដារដូចតទៅនេះ

## ការគិតដល់អតីតកាល

អតីតានុធាវនំ ចិត្តំ វិក្ខេបានុបតិតំ ។ តំ វិវជ្ជយិត្វា ឯកដ្ឋានេ សមាទហតិ ។ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ[៦៤] ។

“ចិត្តដែលគិតដល់អតីតៈ រមែងធ្លាក់ទៅក្នុងសេចក្ដីរវើរវាយ ភិក្ខុរមែងគេចចេញអំពីអតីតអារម្មណ៍នោះ ហើយរមែងតាំងចិត្តទុកក្នុងបច្ចុប្បន្នអារម្មណ៍តែម៉្យាង កាលតាំងចិត្តទុកយ៉ាងនេះចិត្តរមែងដល់នូវសេចក្ដីរាយមាយ” ។

វត្ថុដែលធ្លាប់ឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ឬនឹកគិតមកមុន ឈ្មោះថា អតីតារម្មណ៍ ចិត្តដែលនឹកដល់អារម្មណ៍ដែលធ្លាប់ទទួលមកនោះ រមែងធ្លាក់ទៅក្នុងសេចក្ដីរវើរវាយ ដូចជាខណៈដែលចំរើនវិបស្សនាភាវនា អ្នកបដិបត្តិអាចអាល័យដល់វត្ថុដែលធ្លាប់ឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ឬនឹកត្រឡប់

ទៅដល់ថ្ងៃមុន ខែមុន ឬឆ្នាំមុន ឬថាអាល័យដល់ការបដិបត្តិដែលល្អ ឬមិនល្អក្នុងចន្លោះពេលដែលកំពុងបដិបត្តិ ឬថាអាល័យដល់វត្ថុដែលខ្លួនភ្លេចកំណត់ដឹងទាន់ ហើយពិចារណាថាអារម្មណ៍ ដូចដែលពោលថាជារូប ឬនាមប្រាកដច្បាស់ ឬមិនប្រាកដច្បាស់ដូច្នេះជាដើម ព្រោះដូច្នោះ អ្នកបដិបត្តិគួរកំណត់ដឹងអតីតារម្មណ៍ដែលកើតឡើងគ្រប់ៗ ខណៈដែលដឹងខ្លួនហើយ តាំងចិត្តទុកក្នុងបច្ចុប្បន្នអារម្មណ៍ គឺកំណត់ដឹងបច្ចុប្បន្នអារម្មណ៍ ដែលកំពុងកើតឡើងក្នុងបច្ចុប្បន្នខណៈ កាលបើដូច្នេះ ចិត្តរមែងតាំងមាំមិនរាយមាយ ( ដោយហេតុដែលនៅក្នុងរឿងថា ដោយការចំរើនវិបស្សនាភាវនា ដូច្នោះ ពាក្យថា **ឯកគ្គតា** ទើបសំដៅដល់បច្ចុប្បន្នអារម្មណ៍ បើជាប់ទាក់ទងជាមួយការចំរើនសមថភាវនា ពាក្យនេះ សំដៅដល់អារម្មណ៍របស់សមថកម្មដ្ឋាន ) ។

## ការសង្រួមអនាគតកាល

អនាគតប្បដិកង្ខំ ចិត្តំ វិកម្បិតំ ។ តំ វិវជ្ជយិត្វា តត្ថេវ អធិមោចេតិ ។ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ[៦៤] ។

"ចិត្តដែលសង្ឃឹមអនាគតរមែងរាយមាយ ភិក្ខុរមែងគេចចេញអំពីអនាគតអារម្មណ៍នោះ ហើយរមែងធ្វើទុកក្នុងចិត្ត ក្នុងបច្ចុប្បន្នអារម្មណ៍តែម្យ៉ាង កាលធ្វើទុកក្នុងចិត្តយ៉ាងនេះ ចិត្តរមែងមិនដល់ការរាយមាយ" ។

វត្ថុដែលនឹងកើតក្នុងអនាគតដោយការឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ឬនឹកគិត ឈ្មោះថា អនាគតអារម្មណ៍ ចិត្តដែលសង្ឃឹមអារម្មណ៍ដូចពោលមកនេះ រមែងរាយមាយមិនស្ងប់ស្ងៀម ដូចជាការសង្ឃឹមថា នឹងឃើញ ឬបានឮវត្ថុណាក្នុងអនាគត ឬសង្ឃឹមដល់សេចក្ដីចម្រើនឈានមុខក្នុងភពនេះ ឬភពខាងមុខ ឬថាសង្ឃឹមការឈានមុខក្នុងការបដិបត្តិធម៌ ព្រោះដូច្នោះ អ្នកបដិបត្តិគួរកំណត់ដឹងអនាគតអារម្មណ៍ ដែលកើតឡើងគ្រប់ៗ ខណៈ ដែលដឹងខ្លួន ហើយធ្វើទុកក្នុងចិត្តក្នុងបច្ចុប្បន្នអារម្មណ៍ កាលបើដូច្នេះ ចិត្តរមែងតាំងមាំមិនរាយមាយ ។

## ការរួញរា

លីនំ ចិត្តំ កោសជ្ជានុបតិតំ ។ តំ បគ្គណ្ហិត្វា កោសជ្ជំ បជហាតិ ។ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ[៦៦] ។

“ចិត្តដែលរួញរារមែងធ្លាក់ទៅកាន់ការទម្រន់ ភិក្ខុផ្គងចិត្តនោះហើយរមែងលះការទម្រន់ កាលផ្គងចិត្តទុកយ៉ាងនេះ ចិត្តរមែងមិនដល់នូវសេចក្តីរាយមាយ ” ។

ក្នុងខណៈខ្លះ ដែលអ្នកបដិបត្តិកំណត់ដឹងសភាវធម៌ ក្នុងបច្ចុប្បន្នបានមិនជាក់ច្បាស់ឬមិនមានការឈានទៅមុខឡើងជាងដើម អ្នកបដិបត្តិអាចកើតសេចក្តីរួញរាមិនត្រូវការនឹងបដិបត្តិធម៌ ការទម្រន់រមែងកើតឡើងក្នុងខណៈនោះ អ្នកបដិបត្តិគួរកំណត់ដឹងឲ្យទាន់ការទម្រន់ដែលកើតឡើងហើយលះចេញឲ្យបាន បើលះមិនបានដោយការកំណត់ដឹង ក៏គួរផ្គងចិត្តឲ្យមានកម្លាំងចិត្ត មិនអន់ថយ ក្នុងទីនេះនឹងសម្តែងដល់វិធីផ្គងចិត្តចំពោះវីរិយសម្ពោជ្ឈង្គៈ ដែលប្រាកដក្នុងគម្ពីរអដ្ឋកថា លម្អមជាតួយ៉ាង ដូច្នេះ

ពួកសត្វជំពូកខ្លះ ដែលកើតក្នុងនរកមានរាងកាយខ្ពស់ ៣ គាវុត

ស្មើនឹង ១២ គីឡូម៉ែត្រ ( ១ គាវុត=៤ គីឡូម៉ែត្រ, ៤គាវុត= ១ យោជន៍ ឬ ១៦ គីឡូម៉ែត្រ ) នាយនិរយបាលបង្គាប់ឲ្យដេកផ្ងារលើផ្ទៃដែកដែលមានអណ្ដាតភ្លើងឆេះសន្ធោសន្ធៅ ហើយប្រើដុំដែកវែងមួយដូរគ្នាតបោះទម្លាក់ទៅលើបាទដៃស្ដាំ បាទដៃឆ្វេងជើងស្ដាំជើងឆ្វេង និងចង្កេះទាំងឲ្យដេកផ្កាប់ ឬដេកផ្អៀងទាំងពីរខាង ហើយប្រើដុំដែកបោះទម្លាក់ទៅក្នុងរាងកាយទាំង ៥ កន្លែងនោះ ពួកសត្វនរកនៅមិនស្លាប់ដរាបណា កម្មកំពុងតែឲ្យនូវផលពួកគេបានឃើញផ្ទៃដែកដែលមានអណ្ដាតភ្លើងឆេះសន្ធោសន្ធៅ បានឮសំឡេងជេរស្ដីរបស់នាយនិរយបាល និងត្រូវបង្គាប់ឲ្យដេកលើផ្ទៃដែកត្រូវភ្លើងដុត និងត្រូវបោះដុំដែក រមែងបានទទួលសេចក្ដីទុក្ខធ្វើទារុណកម្មផ្លូវកាយនិងចិត្តយ៉ាងធ្ងន់ធ្ងរ ក្នុងខណៈនោះសូម្បីនឹងស្រែកយំសូមការជួយសង្គ្រោះ ក៏មិនមានអ្នកណាអាណិតនៅតែម្នាក់ឯង សោយផលរបស់កម្មអាក្រក់រហូតអស់កាល ដ៏យូរអង្វែង មិនមានឱកាសបានចំរើនវិបស្សនាភាវនាក្នុងខណៈនោះបានទេ ។

ក្រៅអំពីនោះ នាយនិរយបាលប្រើជ្រនីកកោសស្បែកសាច់

របស់សត្វនរក ដែលរំបែមម្រះទៅមកនៅក្នុងដុំដែកដែលជំទុក ឈាម ហូរស្រក់ជាស្ទឹង ហើយក្លាយជាអណ្ដាតភ្លើង ដុតរាងកាយទៀត តមកនាយនិរយបាលនៅធ្វើទារុណកម្មដោយវិធីដទៃៗ ដូចចាប់ ក្បាលព្យួរសំយុង ហើយប្រើកាំបិតធំពន្លះសាច់ចេញមក ជា ចំណិតៗ ចងទុកជាមួយរថដែក ដែលមានអណ្ដាតភ្លើងក្ដៅខ្លាំង ហើយប្រើដុំដែកក្រហមវាយឲ្យដើរឡើងទៅលើភ្នំភ្លើង កាលឡើង ទៅដល់កំពូលភ្នំហើយ ក៏បណ្ដាប់ឲ្យចុះមកដដែលៗ ទៀត តមក ត្រូវបានចាប់បោះចុះទៅក្នុងខ្ទះដែក ដែលមានទឹក ពុះកញ្ជ្រោល ដែលហៅថា លោហកុម្ភី ដូចគ្រាប់បាយក្នុងឆ្នាំងបាយដែលមាន ទឹកក្ដៅលិចចុះដល់បាទខ្ទះអស់វេលា ៣ ម៉ឺនឆ្នាំ ហើយ ៣ ម៉ឺនឆ្នាំ ទើបអណ្ដែតឡើង លើផ្ទៃទឹកត្រូវសោយទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ ។ តមកនាយនិរយបាល រមែងចាប់សត្វនរក ដែលនៅមិនទាន់ស្លាប់ ព្រោះផលកម្មនៅមិនទាន់អស់បោះចូលទៅក្នុងនរក ដែលដូចជា ហិបដែក ៤ ជ្រុង ដែលមានអណ្ដាតភ្លើងឆេះសន្ធោរឡើង ទទឹង បណ្ដោយ និងកំពស់ខាងលើមួយរយយោជន៍ អណ្ដាតភ្លើងក្នុង ជញ្ជាំង ទិសខាងកើតឆេះរោលដុតទម្លុះជញ្ជាំង ទិសខាងលិចចេញ

ទៅមួយរយយោជន៍ អណ្តាតភ្លើងក្នុងជញ្ជាំងទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ផ្ទៃខាងលើ និងផ្ទៃក្រោមក៏ដូចគ្នា សត្វនរកក្នុងហិបដែកនោះ ស្រែកថ្ងូររត់គេចទៅមក សោយទុក្ខវេទនាសែនធ្ងន់ធ្ងរ ។

កាលកន្លងទៅជាយូរទ្វារនរកមួយកន្លែង ក៏បើកចេញសត្វនរក ក៏នាំគ្នារត់មកទ្វារនេះ ខ្លះរត់មកមិនដល់ ខ្លះរត់មកដល់មាត់ទ្វារ ខ្លះរត់ចេញមកខាងក្រៅទ្វារបានទ្វារនរកនោះ ក៏បិទទៀត កាលកន្លងទៅច្រើនសែនឆ្នាំសត្វនរក ដែលរត់ចេញខាងក្រៅទ្វារនឹងធ្លាក់ទៅ ក្នុងនរករណ្តៅលាមកត្រូវដង្កូវយ៉ាងធំប៉ុនកដីរ ឬនាវាកាត់ស៊ីសាច់ឈាមបានទទួលទុក្ខវេទនាសែនធ្ងន់ធ្ងរ ។

កាលផុតអំពីនរករណ្តៅលាមក ហើយសត្វនរករមែងទៅកើតក្នុងនរកផេះក្តៅកំពស់ស្មើដំបូលផ្ទះ ត្រូវផេះក្តៅដុតកំទេចបានទទួលទុក្ខវេទនាសែនធ្ងន់ធ្ងរ ។

កាលផុតអំពីនរកនោះហើយ រមែងទៅកើតក្នុងនរកព្រៃដើមរកា ដែលមានបន្លាប្រវែង ១៦ ធ្នាប់ មានភ្លើងឆេះសន្ធោរសន្ធៅ

នាយនិរយបាលវាយដំឲ្យតោងឡើងនិងចុះពីដើមរការបន្ទាដើមរការ
នឹងសំយុងចុះ កាលសត្វនរកតោងឡើង នឹងងើបចុងឡើងកាល
សត្វនរកតោងចុះ ពួកសត្វនរកដទៃទៀតខ្លាចតោងឡើង នឹងចុះ
ពីដើមរការត្រូវបន្ទារដើមរការចាក់ដោតបានទទួលទុក្ខវេទនាសែន
ធ្ងន់ធ្ងរ ។

កាលផុតអំពីនរកនោះហើយ រមែងទៅកើតក្នុងនរកព្រៃដាវ
ដោយស្លឹកឈើ ជាដាវកាត់ពន្លះយកអវយវៈ ក្នុងរាងកាយល្មម
សត្វនរករត់គេច ក៏មានស្លឹកកាំបិតលេចឡើងលើផ្ទៃរាបកាត់ពន្លះរាង
កាយមានកំផែងដែកយ៉ាងខ្ពស់ ការពារមិនឲ្យគេចផុតទៅបាន ។

កាលផុតអំពីនរកនោះហើយ រមែងទៅកើតក្នុងនរកទឹកជ្រោះ
វល្លិ៍ផ្តៅ ដែលហៅថា **វេតរណី** នរកនោះមានទឹកដែលពុះ
កញ្ជ្រោល វល្លិ៍ និងឈូកក្នុងជ្រោះជាកាំបិត ខាងក្រោមទឹកជ្រោះ
ក៏មានកាំបិតដោតទុកជុំវិញប្រាំង មានវល្លិ៍ផ្តៅ វល្លិ៍ និងស្មៅដ៏រ
មុតដូចកាំបិត សត្វនរកចុះកាន់ជ្រោះ ហើយត្រូវកាំបិតកាត់ពន្លះ
ហើយបណ្តែតទៅតាមទឹកជ្រោះដែលមានទឹកពុះកញ្ជ្រោល ត្រូវវល្លិ៍

និងឈូកក្នុងទឹកជ្រោះកាត់ពន្លះ កាលបណ្តែតទៅដល់មាត់ច្រាំង ក៏ត្រូវល្បីផ្តៅនិងស្មៅដ៏វែកាត់ពន្លះរាងកាយ នាយនិរយបាល ឃើញសត្វនរកដែលកំពុងលិចទឹក ឬអណ្តែតទឹកយ៉ាងនោះ ក៏ប្រើសន្ទូចអូសឡើងមក ហើយសួរថាត្រូវការអ្វី? ពួកគេឆ្លើយថា ចង់បរិភោគបាយ នាយនិរយបាលយកល្អីដែលពេញទៅដោយដុំដែកក្តៅ ពួកនរកនាំគ្នាខ្ទាចបិតមាត់យ៉ាងមាំ នាយនិរយបាលម្នាក់ ក៏យកដង្កាប់គាស់មាត់ឲ្យហាចេញ ម្នាក់ទៀត ចាប់យកដុំដែកក្តៅ ដាក់ចូលទៅក្នុងមាត់ ដុំដែកក្តៅបានដុតរោលមាត់ អណ្តាត ពិតាន កពោះវៀន ហើយហូរចេញផ្លូវទ្វារក្រោម បើសត្វនរកប្រាប់ថា ចង់ផឹកទឹក នាយនិរយបាលក៏នឹងយកទឹកដែលក្តៅបញ្ចូកចូលក្នុងមាត់ ទឹកក្តៅនោះរមែងដុតបំផ្លាញអវយវៈផ្សេង ៗ ហើយហូរចេញផ្លូវទ្វារក្រោមដូចគ្នា កាលសត្វនរកនោះ សោយទុក្ខវេទនាអស់កាលដ៏យូរអង្វែងហើយ កម្មនៅមិនទាន់អស់ ក៏នឹងទៅកើត ក្នុងនរកដទៃទៀត ។

ក្នុងទីនេះ ពោលដល់រឿងនរកទុកដោយសង្ខេប ដែលប្រាកដ

ដោយពិស្ដារ ក្នុងពាលបណ្ឌិតសូត្រ និងទេវទូតសូត្រជាដើម នឹងឃើញបានថា សត្វនរកសោយទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ ក្នុងនរកយ៉ាងនេះ រមែងមិនមានឱកាសចំរើនវិបស្សនាភាវនា ។

សូម្បីអ្នកដែលទៅកើតក្នុងអបាយភូមិដទៃដោយជាសត្វតិរច្ឆាន ប្រេត ឬ អសុរកាយ ត្រូវទទួលផលកម្មតាមសមគួរ ក៏មិនមានឱកាសចំរើនវិបស្សនាភាវនា ដូចត្រីដែលកំពុងជាប់ក្នុងសំណាញ់ ហើយត្រូវសម្លាប់ គោក្របីដែលត្រូវជន្លញចាក់ដោត ត្រូវទាំភារៈក្នុងរថ ឬ រទេះឲ្យកម្រើកទៅ ប្រេតដែលអត់ឃ្លានរហូតកាលយូរកន្លងសម័យរបស់ព្រះពុទ្ធ ២ ព្រះអង្គ ៣ ព្រះអង្គ ឬ ៤ ព្រះអង្គ អសុរកាយដែលនៅក្នុងភូមិស្គមសល់តែស្បែកដណ្ដប់ឆ្អឹង កំពស់ ៧០ ឬ ៨០ ហត្ថ ត្រូវអត់ឃ្លានធន់ចំពោះខ្យល់ កំដៅថ្ងៃជាកាលយូរ ដូច្នេះជាដើម ។

ស្មេធតាបស បានទទួលព្យាករណ៍ អំពីព្រះពុទ្ធទីបង្ករហើយ ក៏បានសន្សំនូវបារមីមានពោធិសម្ភារៈរឿយៗ មករហូតគ្រប់ ៤ អសង្ខេយ្យកម្រៃមួយសែនមហាកប្ប ទើបត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណជាព្រះពុទ្ធព្រះនាម គោតម ជាសាស្ដារបស់ពុទ្ធបរិស័ទក្នុងបច្ចុប្បន្ន រហូត

រយៈពេលដែលបំពេញបារមីមកនេះ ព្រះអង្គបានឱកាសឧបសម្ប័ទ ក្នុងព្រះពុទ្ធសាសនា និងបដិបត្តិវិបស្សនារហូតសម្រេចវិបស្សនាញាណ ទី ១១ ត្រឹម ៩ ជាតិ មានសាធកៈក្នុងអដ្ឋកថានៃគម្ពីរពុទ្ធវង្សថា

១. កាលសោយព្រះជាតិជាស្តេចចក្រពត្តិមានព្រះនាមថា **វិជិតាវី** ទ្រង់ឧបសម្បទា និងបានទទួលព្យាករណ៍អំពីព្រះពុទ្ធ ព្រះនាម កោណ្ឌញ្ញៈ ( ពុទ្ធវំ. អ. ២០០ ) ។

២. កាលសោយព្រះជាតិជាព្រាហ្មណ៍ សុរុចិ បានឧបសម្បទានិងបានទទួលព្យាករណ៍អំពីព្រះពុទ្ធព្រះនាម **មង្គលៈ**( ពុទ្ធវំ.អ.២២០ ) ។

៣. កាលសោយព្រះជាតិជាព្រាហ្មណ៍ **ឧត្តរៈ** បានឧបសម្បទានិងបានទទួលព្យាករណ៍អំពីព្រះពុទ្ធព្រះនាម **សុមេធៈ**( ពុទ្ធវំ.អ. ២៩០ ) ។

៤. កាលសោយព្រះជាតិជាស្តេចចក្រពត្តិ ទ្រង់ឧបសម្បទានិងបានទទួលព្យាករណ៍អំពីព្រះពុទ្ធព្រះនាម **សុជាតៈ**( ពុទ្ធវំ.អ.២៩៦ ) ។

៥. កាលសោយព្រះជាតិ ជាស្តេចចក្រពត្តិ មាននាមថា **វិជិតាវី** ទ្រង់ឧបសម្បទានឹងបានទទួលព្យាករណ៍អំពីព្រះពុទ្ធព្រះនាម **ផុស្សៈ** ( ពុទ្ធវំ. អ. ៣៣៦ ) ។

៦. កាលសោយព្រះជាតិជាក្សត្រ មានព្រះនាមថា សុទស្សនៈ ទ្រង់ឧបសម្បទា នឹងបានទទួលព្យាករណ៍ អំពីព្រះពុទ្ធព្រះនាម វេស្សភូ ( ពុទ្ធវំ.អ. ៣៥៩-៦០ ) ។

៧. កាលសោយព្រះជាតិជាក្សត្រ មានព្រះនាមថា ខេមៈ ទ្រង់ឧបសម្បទា នឹងបានទទួលព្យាករណ៍អំពីព្រះពុទ្ធ កកុសន្ធៈ ( ពុទ្ធវំ.អ. ៣៦៨ ) ។

៨. កាលសោយព្រះជាតិជាក្សត្រ មានព្រះនាមថា បពិត ទ្រង់ឧបសម្បទា នឹងបានទទួលព្យាករណ៍ អំពីព្រះពុទ្ធ កោនាគមនៈ ( ពុទ្ធវំ. អ. ៣៧៤ ) ។

៩. កាលសោយព្រះជាតិជាព្រាហ្មណ៍ ឈ្មោះ ជោតិបាលៈ ទ្រង់ឧបសម្បទា នឹងបានទទួលព្យាករណ៍ អំពីព្រះពុទ្ធ កស្សបៈ ( ពុទ្ធវំ.អ .៣៨២-៨៣ )] ។

លោកអ្នកចំរើនវិបស្សនា ចូរកុំប្រមាទ កុំខ្វិលប្រអូស បើគិតតែប្រមាទ ក៏នឹងរួចផុតអំពីសង្សារវដ្តមិនបាន កាលរួចផុតមិនបាន ក៏អាចទៅកើតក្នុងនរកសោយទុក្ខដ៏ធំក្រៃលែង ដែលធ្លាប់ជួបមកហើយ ក្នុងពេលនោះ សូម្បីនឹងស្រែកយំរៀបរាប់ក៏មិនមាន

ទណាជួយបាន ឥឡូវនេះ យើងបានកើតជាមនុស្សជួបជាមួយព្រះពុទ្ធសាសនា ចាត់ថាជាឱកាសបដិបត្តិធម៌ដ៏ប្រសើរ ចូរកុំបណ្តោយពេលវេលាឲ្យកន្លងទៅ ដោយឥតប្រយោជន៍ គួរបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តា ដែលត្រាស់ដាស់តឿនថា

*ឈាយ ភិក្ខុ មា ច បមាទោ មា តេ កាមគុណេ ភមស្សុ ចិត្តំ មា លោហគុឡំ គិលី បមត្តោ មា កន្ទិ ទុក្ខមិទន្តិ ឌយ្ហមានោ*[៦៧] ។

"ម្នាលភិក្ខុ អ្នកចូរពិនិត្យផង ចូរកុំជាអ្នកប្រមាទផង ចិត្តរបស់អ្នក ចូរកុំវិលទៅរកកាមគុណឡើយ អ្នកចូរកុំប្រមាទ ទំពារស៊ីនូវដុំលោហៈ កុំឲ្យជាអ្នកកាលភ្លើងឆេះហើយកន្ទក់កន្ទេញថា នេះទុក្ខដូច្នេះឡើយ" ។

ព្រះពុទ្ធតម្រាស់ ដែលពោលមកនេះ ជាការពិចារណាភ័យក្នុងអបាយភូមិ អ្នកបដិបត្តិអាចពិចារណាប្រយោជន៍ នៃការចំរើនវិបស្សនាបានខ្លះ ពោលគឺ ការចំរើនវិបស្សនាមានប្រយោជន៍ ដើម្បីឲ្យសម្រេចមគ្គផល និងនិព្វាន រួចផុតអំពីសេចក្តីទុក្ខ ក្នុងអបាយភូមិ

និងសង្សារវដ្ដ ប្រយោជន៍ដូចពោលមិនអាចបង្កើតដោយសេចក្ដីព្យាយាមដែលថោកថយ សូម្បីការស្វែងរកទ្រព្យរាប់ពាន់រាប់ម៉ឺនក៏ត្រូវប្រើសេចក្ដីព្យាយាមច្រើន មនុស្សដែលព្រមលំបាកធ្វើការងារមួយថ្ងៃ ហើយនៅសប្បាយមួយឆ្នាំ រមែងនឹងធ្វើការងារដោយការពេញចិត្តមនុស្សដែលព្រមលំបាក ធ្វើការងារមួយខែ ហើយនៅសប្បាយមួយជីវិតក៏នឹងតាំងចិត្តធ្វើការងារនោះ ក្នុងករណីដូចគ្នានេះ ការព្រមលំបាកខិតខំព្យាយាមចំរើនវិបស្សនាកន្លះខែ មួយខែឬពីរខែជាដើម ហើយរួចផុតអំពីសេចក្ដីទុក្ខ ក្នុងសង្សារវដ្ដទាំងពួង ចាត់ជាកិច្ចដែលមានតម្លៃជាងប្រយោជន៍ផ្លូវលោកយ៉ាងច្រើនសន្ធឹកសន្ធាប់ ដូច្នោះ ទើបគួរចំរើនវិបស្សនាដោយសេចក្ដីមិនប្រមាទ ។

ន័យម្យ៉ាងទៀត អ្នកបដិបត្តិគួរពិចារណាផ្លូវឆ្ពោះទៅរបស់ព្រះអរិយៈទាំងឡាយ ពោលគឺ វិបស្សនាភាវនា មិនមែនជាផ្លូវឆ្ពោះទៅរបស់មនុស្សសាមញ្ញដែលកំពុងប្រមាទខ្ជិលច្រអូស តែជាផ្លូវឆ្ពោះទៅរបស់ព្រះអរិយៈ បានដល់ព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវកទាំងឡាយ អ្នកដែលធ្វើដំណើរទៅតាមផ្លូវនេះ បាន

ឈ្មោះថា ទៅតាមស្នាមព្រះបាទរបស់ព្រះអរិយៈទាំងនោះ ដោយហេតុនេះ ទើបគួរព្យាយាមបដិបត្តិធម៌ ដែលជាផ្លូវឆ្ពោះទៅរបស់ព្រះអរិយៈទាំងឡាយ ។

ន័យម្យ៉ាងទៀត អ្នកបដិបត្តិដែលជាភិក្ខុគួរមានសេចក្ដីគោរពក្នុងដំបាយរបស់អ្នកស្រុក សំដៅសេចក្ដីថា អ្នកស្រុកនាំគ្នាស្វែងរកទ្រព្យដោយការហត់នឿយទាំងយប់ទាំងថ្ងៃ អ្នកខ្លះប្រថុយស្លាប់រកទ្រព្យចិញ្ចឹមជីវិត ពួកគេប្រើប្រាស់ទ្រព្យ ដែលខ្លួនរកមកបានល្មមសមគួរ តែចំណាយទ្រព្យថ្វាយវត្ថុដែលល្អលើសដល់ភិក្ខុ ការចំណាយទ្រព្យឲ្យជាទាន ដូចដែលពោលមិនមែនឲ្យដល់ញាតិមិត្ត មិនមែនជាការតបស្នងឧបការគុណ និងមិនមែនឲ្យទានដោយសង្ឃឹមលាភយស ឬឋានន្តរៈ តែគេពួកគិតថា ភិក្ខុជាអ្នកដល់ព្រមដោយគុណធម៌គឺ សីល សមាធិ និងបញ្ញា ទានដែលថ្វាយដល់ភិក្ខុមានផលច្រើន អាចឲ្យផលជាមនុស្សសម្បត្តិ សួគ៌សម្បត្តិ និងនិព្វានសម្បត្តិបាន ដូចការបណ្ដុះគ្រាប់ពោធិ ទើបឲ្យផលជាដើមពោធិធំក្នុងកាលតទៅ តែបើភិក្ខុអ្នកទទួលទាន មិនដល់ព្រមដោយសីល សមាធិ និង បញ្ញាយ៉ាងពិតប្រាកដ ទានដែលថ្វាយ ក៏មាន

ផលមិនច្រើន ដូច្នោះ ភិក្ខុអ្នកមានសេចក្តីគោរព ក្នុងដុំបាយរបស់អ្នកស្រុក ទើបគួរបំពេញសីល សមាធិ និងវិបស្សនាបញ្ញា ឲ្យបរិបូណ៌ បើជាអ្នកខ្ជិលច្រអូសគិតតែប្រមាទ ក៏ចាត់ថាជាអ្នកមិនគោរពក្នុងដុំបាយរបស់អ្នកស្រុក ដូចសេចក្តីក្នុងអាកង្ខេយ្យសូត្រថា

អាកង្ខេយ្យ ចេ ភិក្ខវេ ភិក្ខុ យេសាហំ ចីវរបិណ្ឌបាត-សេនាសនគិលានបច្ចយភេសជ្ជបរិក្ខារំ បរិភុញ្ជាមិ ។ តេសំ តេ ការា មហប្ផលា អស្សុ មហានិសំសាតិ ។ សីលេស្វេវស្ស បរិបូរការី ។ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ[៦៨]។

“ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា យើងប្រើប្រាស់ចីវរ បិណ្ឌបាត សេនាសនៈ និងថ្នាំរក្សារោគរបស់បុគ្គលណា ទាននោះរបស់បុគ្គលនោះ ចូរមានផលច្រើន មានអានិសង្សច្រើន លោកគប្បីជាអ្នកបំពេញសីលឲ្យបរិបូណ៌ ព្យាយាមចំរើនសមថៈដែលធ្វើឲ្យចិត្តរបស់ខ្លួនស្ងប់ ជាអ្នកមិនប្រាសចាកឈាន ដល់ព្រមដោយវិបស្សនា នៅក្នុងផ្ទះស្ងាត់ចំរើនសមថៈ និងវិបស្សនា ។

តាមន័យនេះ ភិក្ខុគួរពិចារណាថា អ្នកស្រុកជឿកាន់វត្តបដិបត្តិរបស់យើងហើយថ្វាយចីវរ និងបិណ្ឌបាតជាដើម ពួកគេមិនបាន ប្រាថ្នាវត្ថុណា អំពីយើងត្រឹមតែប្រាថ្នាសេចក្ដីសុខ ក្នុងមនុស្ស សួគ៌ និងនិព្វាន យើងបរិភោគប្រើប្រាស់បច្ច័យ ៤ យ៉ាងមិនលំបាក ដោយការត្រជាក់ ការក្ដៅ ការស្រេកឃ្លាន មិនលំបាកក្នុងការស្វែងរកបច្ច័យ ៤ មានឱកាសក្នុងការបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្ដាយ៉ាងឥស្សរៈ អ្នកស្រុកទាំងឡាយ ទើបមានឧបការៈដល់យើង បើយើងគិតតែប្រមាទ ខ្ជិលច្រអូសមិនព្យាយាមចំរើនសីល សមាធិ និងវិបស្សនាបញ្ញឲ្យបរិបូណ៌ អ្នកស្រុកក៏នឹងបានទទួលផល អំពីការឲ្យទានមិនមានផលច្រើន ដោយហេតុនេះ យើងទើបគួរព្យាយាមចំរើនវិបស្សនាដោយការតស៊ូ ។

ភិក្ខុអ្នកអប់រំយ៉ាងនេះ ហើយចំរើនវិបស្សនាដោយសេចក្ដីព្យាយាមដែលមានអង្គ ៤ គឺព្រមឲ្យរាងកាយសល់ត្រឹមតែស្បែកសរសៃ និងឆ្អឹង និងព្រមឲ្យសាច់ឈាម ក្នុងរាងកាយរីងស្ងួតទៅបើមិនសម្រេចធម៌ ក៏នឹងមិនឈប់ នៅតែព្យាយាម រមែងអាចសំរេចធម៌ រហូតដល់អរហត្តផល ដូចព្រះមហាមិត្តៈដែលពោលទុកក្នុងគម្ពីរ

វិសុទ្ធិមគ្គ[៦៩] និងដូចព្រះបិណ្ឌបាតិកតិស្សៈ ដែលពោលទុកក្នុងគម្ពីរអដ្ឋកថារបស់អង្គុត្តរនិកាយ[៧០] សូម្បីក្នុងសំយុត្តនិកាយ ក៏មានព្រះពុទ្ធវចនៈថា

អលមេវ សទ្ធាបព្វជិតេន កុលបុត្តេនវីរិយំ អារភិតុំ ។ កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ ។ សរីរេ ឧបសុស្សតុ មំសលោហិតំ ។ យំ តំ បុរិសថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ។ ន តំ អបាបុណិត្វាវីរិយស្ស សណ្ឋានំ ភវិស្សតីតិ ។បេ។ ន ភិក្ខវេ ហីនេន អគ្គស្ស បត្តិ ហោតិ ។ អគ្គេន ច ភិក្ខវេ អគ្គស្ស បត្តិ ហោតិ ។បេ។ តស្មាតិហ ភិក្ខវេវីរិយំ អារភថ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ ឯវំ នោ អយំ បព្វជ្ជា អវញ្ឈា ភវិស្សតិ សផលា សឧទ្រយា ។ យេសញ្ច មយំ បរិភុញ្ជាម ចីវរបិណ្ឌបាតសេនាសនគិលាន-បច្ចយភេសជ្ជបរិក្ខារំ ។ តេសំ តេ ការា អម្ហេសុ មហប្ផលា ភវិស្សន្តិ មហានិសំសាតិ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ អត្តត្ថំ វា ហិ ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន

សម្បាទេតុំ ។ បត្តំ វា ហិ ភិក្ខវេ សម្បស្សមានេន អលមេវ អប្បមាទេន សម្បាទេតុំ ។ ឱកយត្តំ វា ហិ ភិក្ខវេ សម្បស្ស-មានេន អលមេវ អប្បមាទេន សម្បាទេតុំ[៧១] ។

“កុលបុត្រ អ្នកបួសដោយសទ្ធា គួរប្រារព្ធសេចក្តីព្យាយាម [ដែលមានអង្គ ៤] គឺស្បែក សរសៃ និងឆ្អឹងចូរសល់នៅដោយពិត សាច់និងឈាមក្នុងរាងកាយចូរស្ងួតទៅចុះ កាលបើនៅមិនទាន់សម្រេចមគ្គផលដែលគួរសម្រេច ដោយកម្លាំងព្យាយាមនិងការខិតខំរបស់បុរស ការឈប់ញុំាងសេចក្តីព្យាយាមនឹងមិនមាន. ម្នាលភិក្ខុទាំងឡាយ ការសម្រេចមគ្គផលដ៏ប្រសើររមែងមិនមានដោយឥន្ទ្រិយ៍ ៥ ដែលមានចំនួនតិច តែការសម្រេចមគ្គផលដ៏ប្រសើរ រមែងមានបានដោយឥន្ទ្រិយ៍ ៥ ដែលចាស់ក្លាខ្ពស់បំផុត ដូច្នោះ ពួកអ្នកចូរប្រារព្ធសេចក្តីព្យាយាមដើម្បីសម្រេចធម៌ដែលនៅមិនទាន់បានសម្រេច ដើម្បីឲ្យបានទទួលធម៌ដែលនៅមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលនៅមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

ពួកអ្នកគប្បីយកចិត្តទុកដាក់ដោយប្រការដូច្នេះ ការបួសរបស់ពួកយើងនេះនឹងមិនមែនជាការឥតប្រយោជន៍ មានផល មានតម្លៃម៉្យាងទៀត ពួកយើងប្រើប្រាស់ចីវរ បិណ្ឌបាត្រ សេនាសនៈ និងថ្នាំរក្សារោគរបស់បុគ្គលណា ទាននោះរបស់បុគ្គលនោះ ក្នុងយើងទាំងឡាយ នឹងមានផលច្រើន មានអានិសង្សច្រើន ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីយកចិត្តទុកដាក់យ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឃើញប្រយោជន៍ខ្លួនគួរញ៉ាំងសិក្ខា ៣ ឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទ ភិក្ខុអ្នកឃើញប្រយោជន៍អ្នកដទៃគួរញ៉ាំងសិក្ខា ៣ ឲ្យដល់ព្រមដោយការមិនប្រមាទ ភិក្ខុអ្នកឃើញប្រយោជន៍ទាំងពីរចំណែក គួរញ៉ាំងសិក្ខា ៣ ឲ្យដល់ព្រមដោយការមិនប្រមាទ" ។

ក្រៅអំពីការគោរព ក្នុងដុំបាយរបស់អ្នកស្រុក ដែលពោលមកនេះ អ្នកបដិបត្តិអាចពិចារណាភាពប្រសើរ ដែលបានជាទាយាទអ្នកទទួលមរតក គឺលោកុត្តរធម៌, ពិចារណាភាពប្រសើរនៃព្រះបរមសាស្តាអ្នកណែនាំប្រៀនប្រដៅ, ពិចារណាសេចក្តីព្យាយាម

ដ៏ឧក្រិដ្ឋរបស់ព្រះសោណៈ ឬរលឹងដល់ព្រះពុទ្ធគុណ ធម្មគុណ សង្ឃគុណ ពិចារណាសេចក្ដីផូរផង់នៃសីល ឬស្ដាប់ព្រះសូត្រ ដែលគួរជ្រះថ្លា ដូចដែលប្រាកដក្នុងរឿងបីតិសម្ពោជ្ឈង្គៈ កាលអ្នកបដិបត្តិពិចារណាតាមវិធីទាំងនេះតែម្យ៉ាង ឬច្រើនយ៉ាងរមែងកើតកម្លាំងចិត្តក្នុងការបដិបត្តិធម៌ ក្នុងខណៈនោះ ចិត្តនឹងតាំងមាំអាចកំណត់ដឹងទាន់សភាវៈបច្ចុប្បន្នបាន ។

## សេចក្ដីព្យាយាមដ៏ក្រៃលែង

*អតិបគ្គហិតំ ចិត្តំ ឧទ្ធច្ចានុបតិតំ ។ តំ វិនិគណ្ហិត្វា ឧទ្ធច្ចំ បជហតិ ។ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ*[72] ។

"ចិត្តដែលព្យាយាមដ៏ក្រៃលែង រមែងធ្លាក់ទៅកាន់ការរវើរវាយ ភិក្ខុសំរួលចិត្តនោះហើយ រមែងលះការរវើរវាយ កាលសំរួលចិត្តយ៉ាងនេះចិត្តរមែងមិនដល់ការរវើរវាយ" ។

ក្នុងខណៈខ្លះ អ្នកបដិបត្តិអាចតាំងចិត្តកំណត់រហូតលើសហួសពេកដោយគិតថានឹងទទួលដឹងទាន់សភាវធម៌បច្ចុប្បន្ន ដែលកើតឡើងកាលនោះអាចគិតរវើរវាយថា យើងអាចកំណត់ដឹងទាន់គ្រប់យ៉ាង

ឬទេ ភ្លេចកំណត់ដឹងសភាវធម៌ណាខ្លះ ឬអាចគិតថា យើងព្យាយាមរហូតទីបំផុតនឹងអាចហើយ តែហេតុអ្វីទើបមិនឈានទៅមុខជាងនេះ ការរវើរវាយរបស់ខ្លួនធ្វើឲ្យសតិមិនជាប់បន្តក្នុងបច្ចុប្បន្នអារម្មណ៍ ព្រោះមានការរវើរវាយកំពុងកើតឡើង សេចក្តីព្យាយាមដ៏ក្រៃលែងទើបជាឧបសគ្គមួយប្រការរបស់សមាធិ ។

សេចក្តីរវើរវាយ ដែលពោលដល់ឧបសគ្គរបស់សមាធិ ខ ដំបូង និងខទី ៤ នេះ មានលក្ខណៈផ្សេងគ្នា ពោលគឺ ការរវើរវាយក្នុងខដំបូង ជាការដាស់តឿនចិត្តទៅកាន់អារម្មណ៍ ដ៏ឆ្ងាយដែលកន្លងមកហើយ ចំណែកសេចក្តីរវើរវាយដែលពោលដល់ក្នុងខនេះ ជាការរវើរវាយ ជាប់ទាក់ទងនឹងការកំណត់ ដែលជារឿងជិតខ្លួន ។

កាលអ្នកបដិបត្តិដឹងត្រឹមថា ខ្លួនមានការព្យាយាមហួសពេកគួរសំរួលចិត្តដោយការពិចារណាថា សភាវធម៌ទាំងពួងជាអនត្តា មិននៅក្នុងការបង្គាប់របស់ខ្លួន សូម្បីនឹងព្យាយាមច្រើន ក៏អាចនឹងមិនឈានទៅមុខបាន ព្រោះការឈានទៅមុខក្នុងការបដិបត្តិ រមែងឡើងជាមួយហេតុបច្ច័យដែលនឹងឲ្យផលគឺ វិបស្សនាញាណកើត

ឡើង ដូចនោះ ការកំណត់ដឹងតាមសមគួរ មិនតឹងហួសពេក ការ
ដាស់តឿនចិត្តយ៉ាងនេះ ធ្វើឲ្យវិរិយៈថយចុះបញ្ជូនផលឲ្យចិត្តតាំងមាំ
មានសមាធិយ៉ាងជាប់រហ័ស ។

## សេចក្ដីប្រាថ្នាដ៏ក្រៃលែង

អភិនតំ ចិត្តំ ភគានុបតិតំ ។ តំ សម្បជានោ ហុត្វា ភគំ
បជហតិ ។ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ[៧៣] ។

"ចិត្តដែលប្រាថ្នាដ៏ក្រៃលែង រមែងធ្លាក់ទៅកាន់សេចក្ដីពេញ
ចិត្ត ភិក្ខុដឹងចិត្តនោះហើយ រមែងលះសេចក្ដីពេញចិត្ត កាលលះ
សេចក្ដីពេញចិត្តយ៉ាងនេះ ចិត្តរមែងមិនដល់នៅសេចក្ដីរវើរវាយ" ។

ក្នុងខណៈខ្លះ ដែលអ្នកបដិបត្តិកំណត់ដឹងទាន់សភាវធម៌ បាន
យ៉ាងល្អ អាចកើតសេចក្ដីប្រាថ្នា ដែលនឹងសម្រេចការឈានទៅ
មុខ ដែលបានដល់វិបស្សនាញាណថ្នាក់ខ្ពស់ឡើងទៅ ឬមគ្គផល
សេចក្ដីប្រាថ្នានេះ ជាការពេញចិត្តដែលចាត់ជាលោភៈ ខណៈនោះ
គួរកំណត់ដឹង សេចក្ដីប្រាថ្នាដ៏ក្រៃលែងនោះ កាលអ្នកបដិបត្តិ
កំណត់ដឹងដូច្នេះ រមែងលះលោភៈបានដោយការកំណត់ដឹងទាន់

ពេល ចិត្តក៏នឹងតាំងមាំជាសមាធិក្នុងខណៈនោះ ( វិធីលះកិលេសមានលោភៈជាដើម ដោយការកំណត់ដឹងនឹងពោលដល់បរិច្ឆេទទី ៤ តទៅ ) ។

## ការទម្រន់

អបនតំ ចិត្តំ ព្យាបាទានុបតិតំ ។ តំ សម្បជានោ ហុត្វា ព្យាបាទំ បជហតិ ។ ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ[៧៤] ។

“ចិត្តដែលទម្រន់ រមែងធ្លាក់ទៅកាន់សេចក្តីមិនពេញចិត្ត ភិក្ខុដឹងចិត្តនោះហើយ រមែងលះសេចក្តីមិនពេញចិត្ត កាលលះសេចក្តីមិនពេញចិត្តយ៉ាងនេះ ចិត្តរមែងមិនដល់នៅសេចក្តីរវើរវាយ” ។

អ្នកបដិបត្តិធម៌ច្រើនថ្ងៃ ឬច្រើនខែ អាចកើតការរួញរា កាលមិនជួបការឈានទៅមុខក្នុងការបដិបត្តិ រហូតទាំងគិតនឹងបោះបង់ការបដិបត្តិធម៌ សេចក្តីរួញរាដូចពោល កើតរួមជាមួយការមិនពេញចិត្តចាត់ថា ជាឧបសគ្គដ៏ធំរបស់សមាធិ អ្នកបដិបត្តិគប្បីកំណត់ការរួញរា ដែលធ្វើឲ្យលំបាក នឹងចេញអំពីកម្មដ្ឋាន ដដែលហើយ

ដដែលទៀត រហូតជាងនឹងបាត់ទៅ កាលការរួញរាបាត់ទៅហើយ ចិត្តក៏នឹងស្ងប់រម្ងាប់មានសមាធិ ។

## ការតាំងមាំក្នុងអារម្មណ៍ ៤ ប្រការ

អ្នកបដិបត្តិកំចាត់ឧបសគ្គរបស់សមាធិ ៦ ប្រការ តាមវិធីដែលពោលមកហើយ រមែងមិនអាឡោះអាល័យអតីត មិនរំពឹងដល់អនាគត ប្រាសចាកការស្ទុតចិត្ត មិនព្យាយាមក្រៃលែង ឬប្រាថ្នាក្រៃលែង និងមិនរួញរាអាចដឹងទាន់រូបនាម ក្នុងបច្ចុប្បន្នខណៈបានយ៉ាងជាក់ច្បាស់ ក្នុងខណៈនោះ សមាធិដែលតាំងមាំ រមែងកើតឡើងយ៉ាងបន្តបន្ទាប់ដោយមិនមានកិលេសលាយឡំ ។

ដូចគម្ពីរបដិសម្ភិទាមគ្គ ពោលដល់ការតាំងមាំក្នុងអារម្មណ៍៤ប្រការ ដែលមានវិបស្សនា ៤ ប្រភេទគឺ ៖

១. សេចក្ដីតាំងមាំក្នុងការឲ្យទាន ។

២. សេចក្ដីតាំងមាំក្នុងអារម្មណ៍របស់សមថភាវនា ។

៣. សេចក្ដីតាំងមាំក្នុងសភាវៈរលត់ទៅរបស់រូបនាម

៤. សេចក្តីតាំងមាំក្នុងការរលត់សតិរបស់រូបនាមទាំងអស់ ។ មានសេចក្តីក្នុងគម្ពីរនោះថា

ឥមេហិ ឆហិ ឋានេហិ បរិសុទ្ធំ ចិត្តំ បរិយោទាតំ ឯកត្តគតំ ហោតិ ។ កតមេ តេ ឯកត្តា ។ ទានវោសគ្គុបដ្ឋានេកត្តំ សមថនិមិត្តុបដ្ឋានេកត្តំ វយលក្ខណុបដ្ឋានេកត្តំ និរោធុបដ្ឋានេកត្តំ ។ ទានវោសគ្គុបដ្ឋានេកត្តំ ចាគាធិមុត្តានំសមថនិមិត្តុបដ្ឋានេកត្តំ អធិចិត្តមនុយុត្តានំ វយលក្ខណុបដ្ឋានេកត្តំ វិបស្សកានំ និរោធុបដ្ឋានេកត្តញ្ច អរិយបុគ្គលានំ[៧៥] ។

"ចិត្តដែលបរិសុទ្ធផូរផង់ដោយឋានៈ ៦ ប្រការទាំងនេះ រមែងដល់ការតាំងមាំ ការតាំងមាំទាំងនោះគឺអ្វី? គឺការតាំងមាំដែលប្រាកដដោយការឲ្យទាន ការតាំងមាំដែលប្រាកដដោយអារម្មណ៍ របស់សមថភាវនា ការតាំងមាំដែលប្រាកដដោយសភាវៈរលត់ទៅ និងការតាំងមាំដែលប្រាកដ ដោយសេចក្តីរលត់សូន [នៃសង្ខារទាំងពួង] ។ ការតាំងមាំ ដែលប្រាកដដោយការឲ្យទាន រមែងមានដល់អ្នកបង្អោនចិត្តក្នុងការបរិចាគ ការតាំងមាំ ដែលប្រាកដដោយអារម្មណ៍របស់

សមថភាវនា រមែងមានដល់អ្នកបដិបត្តិសមថភាវនា ការតាំងមាំ ដែលប្រាកដដោយលក្ខណៈរលត់ទៅ រមែងមានដល់អ្នកចម្រើន វិបស្សនាភាវនា ចំណែកការតាំងមាំ ដែលប្រាកដដោយការរលត់ សូន [នៃសង្ខារទាំងពួង] រមែងមានដល់ព្រះអរិយបុគ្គលទាំងឡាយ" ។

សេចក្ដីខាងដើម មានន័យថា ចិត្តរបស់អ្នកដែលកំចាត់ឧបសគ្គ ៦ ប្រការដែលពោលមកហើយនោះ រមែងមិនអាឡោះអាល័យដល់អតីតមិនសង្ស័យអនាគតជាដើម អាចកំណត់ដឹងទាន់សភាវៈដែលជារូបនាមបានយ៉ាងជាក់ច្បាស់ វិបស្សនាចិត្ត ដែលហ្មត់ចត់អំពីនីវរណៈយ៉ាងនេះ រមែងតាំងមាំក្នុងបច្ចុប្បន្នអារម្មណ៍មិនប្រែប្រួលទៅដោយកិលេស ។

ម្យ៉ាងទៀត ក្នុងបណ្ដាការតាំងមាំក្នុងអារម្មណ៍ ៤ ប្រការ សេចក្ដីតាំងមាំ ដែលប្រាកដដោយការឲ្យទាន រមែងមានបានកាលបុគ្គលតាំងចិត្តមាំក្នុងការដែលនឹងឲ្យទានប៉ុណ្ណោះ ជាខណៈ ដែលអារម្មណ៍ដទៃនិងនីវរណៈ មិនកើតឡើងអ្នកដែលចំរើនសមថភាវនា

មានអារម្មណ៍តែមួយគឺ សមថារម្មណ៍ក្នុងខណៈ ដែលសម្រេចឧបចារសមាធិ ឬអប្បនាសមាធិដែលជាចិត្តវិសុទ្ធិរបស់សមថយានិក អ្នកដែលចំរើនវិបស្សនាភាវនាមានអារម្មណ៍តែមួយគឺ រូបនាមតាំងអំពីកើតនាមរូបបរិច្ឆេទញាណជាដើមទៅ តែកាលសម្រេចកង្ខាញាណជាដើមទៅរហូតដល់អនុលោមញាណ ហើយនឹងទទួលដឹងសភាវៈរលត់ទៅរបស់រូបនាមជាគោលដែលជាខណិកសមាធិលំដាប់ខ្ពស់របស់វិបស្សនាយានិក ក្រៅពីនេះ កាលវិបស្សនាចិត្តមានកម្លាំងចាស់ក្លាយ៉ាងខ្ពស់បំផុត ក៏នឹងសម្រេចព្រះនិព្វាន ជាសភាវៈដែលរលត់រូបនាមសង្ខារទាំងអស់ក្នុងខណៈសម្រេចមគ្គផល ។

ចប់បរិច្ឆេទ ទី ២

## បរិច្ឆេទទី ៣

## អារម្មណ៍របស់វិបស្សនាភាវនា

ដោយហេតុដែលគម្ពីរនេះ បញ្ជាក់ការនាំបែងចែកវិបស្សនាភាវនាជាគោលដូច្នោះ ក្នុងបទនេះ ទើបពោលដល់ការផ្សេងគ្នារវាងបញ្ញត្តិនិងបរមត្ថ និងវិធីចំរើនវិបស្សនាភាវនា ដោយការកំណត់ដឹង

អារម្មណ៍របស់វិបស្សនា ដែលជាបរមត្ថដូចតទៅនេះ ។

## បញ្ញត្តិ និង បរមត្ថ

ដូចគម្ពីរអភិធម្មត្ថវិភាវនីពោលថា

**បរមោ ឧត្តមោ អវិបរីតោ អត្ថោ បរមត្ថោ[១] ។**

"សភាវៈប្រសើរ គឺ ខ្ពង់ខ្ពស់ សំដៅដល់ការមិនប្រែប្រួល ឈ្មោះថា បរមត្ថ" ។

ដោយប្រក្រតី វត្ថុដែលមិនមានពិត ដែលខុសអំពីសភាវធម៌ រមែងមិនប្រសើរ តែវត្ថុដែលមានពិតមិនប្រែប្រួលអំពីសភាវៈរបស់ខ្លួន រមែងជាសភាពប្រសើរ ដូចនោះ សភាវធម៌៤ យ៉ាងនោះគឺ ចិត្ត ចេតសិក រូប និងនិព្វាន ដែលមានពិតមិនប្រែប្រួល ទើបឈ្មោះថា បរមត្ថ ឬបរមត្ថធម៌ដោយមានរូបវិគ្រោះ ( ពាក្យកំណត់ន័យ ) តាមសេចក្តីក្នុងគម្ពីរអដ្ឋកថាថា

**បរមោ ឧត្តមោ អត្តបច្ចក្ខោ អត្ថោ បរមត្ថោ[២] ។**

"សភាវៈប្រសើរគឺ ខ្ពង់ខ្ពស់សំដៅដល់ការដឹងបានដោយខ្លួន

ឯង ឈ្មោះថា បរមត្ថ" ។

ខាងដើមសំដៅសេចក្ដីថា វត្ថុដែលស្ដាប់អំពីអ្នកដទៃអាចត្រូវ ឬខុសក៏មាន ទើបមិនហៅវត្ថុនោះ ថាជាបរមត្ថ តែវត្ថុដែលបុគ្គល ទទួលដឹងបានដោយជាក់ច្បាស់ដល់ខ្លួនឯង រមែងនឹងមិនក្លាំងក្លាត់ ដូចនោះ សភាវធម៌ ៤ យ៉ាងខាងដើមទើបឈ្មោះថា បរមត្ថ សូម្បី អដ្ឋកថារបស់គម្ពីរកថាវត្ថុ អធិប្បាយរឿងនេះថា

**សច្ចិកដ្ឋោតិ មាយាមរីចិអាទយោ វិយ**

**អភូតាការេន អគ្គហេតព្វោ ភូតដ្ឋោ ។**

**បរមត្ថោតិ អនុស្សវាទិវសេន អគ្គហេតព្វោ**

**ឧត្តមត្ថោ[៣] ។**

"សភាវៈដែលមិនគួរប្រកាន់ភ្ជាប់ដោយអាការដែលមិនមានពិត ដូចកលមាយានិងថ្ងៃចុះអ័ព្ទជាដើម ឈ្មោះថា សច្ចិកដ្ឋៈ ( សភាវធម៌ ដែលមានពិត ) ។

សភាវៈខ្ពង់ខ្ពស់ដែលមិនប្រកាន់ភ្ជាប់ ដោយជាវត្ថុដែលស្ដាប់

តមក ឈ្មោះថា បរមត្ថ ( សភាវធម៌ប្រសើរ )" ។

"មួយវិញទៀត ឈ្មោះថាសច្ចិកដ្ឋៈ ព្រោះប្រាកដពិតដល់ខ្លួនឯង និង ឈ្មោះថា បរមត្ថ ព្រោះឃើញច្បាស់ដល់ខ្លួនឯង ព្រះមានព្រះភាគត្រាស់ពាក្យនេះទុកដោយសំដៅដល់ធម៌ទាំងនោះ ( ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ៍ ២២ រួមជាបរមត្ថ ៥៧ ប្រការ)" ។

ព្រះអដ្ឋកថាចារ្យ ពោលដល់ធម៌ដែលហៅថា សច្ចិកដ្ឋៈ និង បរមត្ថ ៥៧ ប្រការ ដែលសរុបបានក្នុងធម៌ ៤ ប្រការ គឺ ចិត្ត ចេតសិក រូបនិងនិព្វាន ឬសង្ខេបបានក្នុងធម៌ ២ ប្រការគឺ រូបនិងនាម ក្នុងទីនេះនឹងអធិប្បាយដោយសរុបជារូបនិងនាម ។

អ្នកមាយាកលអាចធ្វើឥដ្ឋ ក្រដាស់ ឬដុំថ្មឲ្យឃើញជាមាសប្រាក់

មនុស្សមើលក៏សំគាល់ថាជាពិត តែមាសប្រាក់ទាំងនោះមិនមានពិត ឈ្លូសដែលរកទឹកផឹកក្នុងវាលរហោស្ថាន ឃើញថ្ងៃចុះអ័ព្ទហើយ គិតថាជាទឹក តែទឹកនោះមិនមានពិត ក្នុងទំនងជាមួយគ្នាវត្ថុបញ្ញត្តិមានរូបរាង សណ្ឋានតាមដែលសន្មតិក្នុងផ្លូវលោកថា ជាបុរស ស្ត្រី ដៃ ជើង ។ល។ ក៏មិនមានពិត ព្រោះជាវត្ថុប្រជុំគ្នារបស់រូបនាម

ប៉ុណ្ណោះមានត្រឹមរូបនាមដែលជាសភាវៈពិត កើតឡើងនិងរលត់ទៅតាមហេតុបច្ច័យ ទើបឈ្មោះថា សច្ចិកដ្ឋៈ ឬ បរមត្ថ ។

ការពិត អ្នកដែលឃើញរូបផ្លូវចក្ខុបសាទ រមែងទទួលពណ៌ដែលកំពុងមានពិត នៅបែកផ្សេងគ្នាអំពីឧបាយកល និងថ្ងៃចុះអ័ព្ទដែលមិនពិត ព្រោះបើមិនមានពណ៌ទើងគប្បីឃើញបានសភាវៈការឃើញរមែងមិនកើតឡើង ដូច្នេះ ពណ៌ដែលឃើញផ្លូវចក្ខុបសាទទើបជាសច្ចិកដ្ឋៈ ឬ បរមត្ថ កាលឃើញពណ៌ហើយ មនុស្សយើងក៏គិតដល់រូបរាងសណ្ឋាន ផ្លូវមនោទ្វារថា វែង ខ្លី មូល សំប៉ែត បីជ្រុង បួនជ្រុង បុរស ស្ត្រី ដៃ ជើង ។ល។ ទើបសំគាល់ថា ឃើញរូបរាងសណ្ឋាន ព្រោះចិត្តដែលឃើញផ្លូវចក្ខុទ្វារ និងចិត្តដែលត្រិះរិះផ្លូវមនោទ្វារកើតរលត់លឿនរហ័សរហូតមនុស្សទូទៅបែងចែកមិនបាន ធ្វើឲ្យយល់ខុសថា ចិត្តដែលឃើញពណ៌ និងចិត្តដែលទទួលរូបរាងសណ្ឋានជាចិត្តតែមួយដូង ដូចគម្ពីរមូលដីកាពោលថា

ចក្ខុវិញ្ញាណស្ស ហិ រូបេ អភិនិបាតមត្តំ កិច្ចំ ។ ន អធិប្បាយសហកុនោ ចលនវិការស្ស គហណំ ។ ចិត្តស្ស បន លហុប-

វិវត្តិតាយ ចក្ខុវិញ្ញាណវីថិយា អនន្តរំ មនោវិញ្ញាណេន វិញ្ញាតម្បិ ចក្ខុនា ទិដ្ឋំ វិយ មញ្ញន្តិ អវិសេសវិទុនោ[៥] ។

"នាទីរបស់ចក្ខុវិញ្ញាណ គឺ ការប្រព្រឹត្តទៅក្នុងពណ៌តែម្យ៉ាង មិនមែនទទួលដឹងការកម្រើក ដែលកើតរួមជាមួយសេចក្តីប្រាថ្នា [របស់អ្នកដទៃ] តែមនុស្សទូទៅ ដែលប្រាសចាកការយល់ដឹង រមែងសំគាល់ថា សូម្បីវត្ថុដែលទទួលដឹងផ្លូវមនោទ្វារតអំពីចក្ខុវិញ្ញាណវិថី ក៏ដូចជាការបានឃើញផ្លូវចក្ខុបសាទ ព្រោះចិត្តផ្លាស់ប្តូរយ៉ាងលឿនរហ័ស" ។

ក្នុងខណៈឃើញ ដូចជាការធ្វើចលនា បុគ្គលរមែងឃើញពណ៌ដោយចក្ខុវិញ្ញាណ ខណៈនោះ នៅមិនទាន់ទទួលដឹងថាជាដៃ ឬជាវត្ថុដែលកម្រើក តែចិត្តកើតរលត់លឿនរហ័ស មនុស្សទូទៅទើបយល់ខុស តាមដែលកំពុងឃើញផ្លូវចក្ខុទ្វារថាដៃកម្រើក ចំណែកអ្នកដែលចំរើនវិបស្សនាជំនាញ ទើងទទួលដឹងត្រឹមតែចិត្តដែលឃើញពណ៌ ចិត្តដែលដឹងថាជាដៃ និងចិត្តដែលដឹងថា កំពុងកម្រើក ជាចិត្តមួយដួងផ្សេងគ្នា ដូចកាលបុគ្គលឃើញភ្លើងធូបដែលគេវី

ជាវេទនាក្នុងពេលយប់តែងតែយល់ថា ខ្លួនឃើញរង្វង់ភ្លើងធូប សេចក្ដីពិត ភ្លើងធូបមិនបានកើតរួមជាមួយភ្លើង តែត្រឹមជាអាការ ដែលត្រូវជារង្វង់មូល ដែលកើតបន្តជាប់គ្នា ចិត្តរបស់យើងក៏ដូចគ្នា កាលចិត្តដួងក្រោយៗ កើតឡើងទទួលដឹងវត្ថុ ដែលឃើញដល់ការកើតឡើងជាប់តគ្នា ក៏ក្លាយជាភាពប្រាកដជារូបរាងសណ្ឋាន ។

ក្រៅអំពីនេះ មនុស្សដែលអានសៀវភៅមិនស្ទាត់ ត្រូវរួមអក្សរ ១ តួហើយពិចារណាប្រកបជាពាក្យ ៗ ទើបនឹងអានយល់បាន ការពិចារណាត្រិះរិះនេះប្រាកដច្បាស់ ព្រោះប្រើពេលយូរ តែមនុស្សដែលអានសៀវភៅស្ទាត់ហើយ នឹងអានបានយល់ភ្លាម ព្រោះការពិចារណាកើតឡើងលឿនយ៉ាងណា សភាវៈឃើញ រមែងញែកចេញអំពីការពិចារណាបានយ៉ាងជាក់ច្បាស់ ក្នុងអារម្មណ៍ដែលមិនធ្លាប់ឃើញ តែការពិចារណា រមែងមិនប្រាកដច្បាស់ក្នុងអារម្មណ៍ដែលមិនធ្លាប់ឃើញ ដូច្នោះ ដោយហេតុនេះ មនុស្សទូទៅទើបសំគាល់ថា ចក្ខុបសាទជា បុរស ស្ត្រី ។

ម្យ៉ាងទៀត ពោលដោយធាតុ រូបរាងសណ្ឋាននៃវត្ថុគ្រប់យ៉ាង

ចាត់ចូលក្នុងក្រុមធាតុទាំង ៤ ចក្ខុវិញ្ញាណចិត្តឃើញពណ៌ផ្លូវចក្ខុបសាទប៉ុណ្ណោះ សូម្បីការប៉ះខ្ទប់ផ្លូវកាយ ក៏ជាការប៉ះខ្ទប់ផោដ្ឋព្វារម្មណ៍ដែលជារូបត្រជាក់ ឬក្តៅជាដើម ដែលប៉ះខ្ទប់បានមិនមែនប៉ះខ្ទប់រូបភពសណ្ឋាន ព្រោះកាលញែកផោដ្ឋព្វារម្មណ៍ចេញអំពីរូបភពសណ្ឋានក៏នឹងមិនមានវត្ថុ ដែលប៉ះខ្ទប់បាន ដូច្នោះរូបភពសណ្ឋានរបស់ បុរស ឬស្ត្រី ទើបជាបញ្ញត្តិ ដែលមិនមានពិត ( **អភូតត្ថ:, អសច្ចិកដ្ឋ:** ) ។

កែវភ្នែករបស់មនុស្សទូទៅមានភាពថ្លា ដែលអាចទទួលដឹងរូបារម្មណ៍បានដែលហៅថា ចក្ខុបសាទ ពណ៌ផ្សេង ៗ ទើបឃើញច្បាស់ខាងមុខចក្ខុបសាទ បើមិនមានចក្ខុបសាទ ក៏នឹងមិនប្រាកដពណ៌ ដូចស្រមោលមុខ រមែងប្រាកដលើកញ្ចក់ មិនប្រាកដទីដទៃ

ចក្ខុបសាទដែលជាភាពថ្លា អាចជះត្រឡប់នូវពណ៌ផ្សេង ៗ ឲ្យចក្ខុវិញ្ញាណឃើញបាន ទើបជាសភាពដែលមានពិតសូម្បីសភាវៈឃើញ ក៏មានពិត និងពណ៌ដែលឃើញ ក៏មានពិត សរុបសេចក្តីមកថា ចក្ខុបសាទ ចក្ខុវិញ្ញាណ និងពណ៌ជាសភាពដែលមានពិត

( **ភូតត្ថៈ, សច្ចិកដ្ឋៈ, បរមត្ថៈ** ) ។

តាមន័យដែលពោលមកខាងដើមនេះ សូម្បីសោតបសាទ សោតវិញ្ញាណ និងសំឡេងជាដើម ក៏ជាសភាពដែលមានពិត តែការស្តាប់តាមគ្នាមក ( **អនុស្សវៈ** ) អាចជាការទទួលដឹងរឿងដែលពិត ឬមិនពិតក៏បាន ទើបមិនឈ្មោះថា **បរមត្ថៈ** វត្ថុដែលខ្លួនទទួលដឹងដោយប្រចក្សប៉ុណ្ណោះ ទើបមានពិត និងបានឈ្មោះថា **បរមត្ថៈ** ក្នុងគម្ពីរអដ្ឋកថា នៅពោលដល់វត្ថុដទៃដែលទទួលដឹងដោយមិនប្រចក្សច្បាស់ដូចជា

- **បរម្បរា** ការកាន់តគ្នាមកតាំងអំពីជំនាន់អាចារ្យ ឬ ជីដូននិងជីតា ។

- **ឥតិកិរ** ពាក្យចចាមអារ៉ាម ។

- **បិដកសម្បទាន** ការអាងក្បួនច្បាប់ ។

- **តក្កហេតុ** ភាវៈជាហេតុជាផល ។

- **នយហេតុ** ការចង្អុរណែនាំ ។

- អាការបរិវិតក្ក ការត្រិះរិះតាមអាការៈ ។

- ទិដ្ឋិនិជ្ឈាន ការស្រេចជាមួយការឃើញ ដែលខ្លួនព្រម ទទួលទុកហើយ ។

ការស្ដាប់ និងការជឿតាមគ្នា ដែលពោលមកនេះ អាចនឹងត្រូវ ឬខុសក៏បាន ព្រះអង្គទើបទ្រង់បដិសេធទុកក្នុងកាមសូត្រ ហើយទ្រង់ ណែនាំឲ្យបដិបត្តិដោយខ្លួនឯងរហូតទាំងទទួលដឹងសភាវធម៌ដែល ប្រាកដលជាខ្លួនយ៉ាងពិតប្រាកដ ។ សភាវធម៌ គឺរូបនាមទាំងពីរយ៉ាង មិនមែននឹងយល់បានជាក់ច្បាស់ ដោយការស្ដាប់ពាក្យប្រាប់តៗ គ្នា មក ។ល។ តែគប្បីយល់បានដោយការបដិបត្តិខ្លួនឯងប៉ុណ្ណោះ ដូចមនុស្សដែលខ្វាក់ភ្នែកអំពីកំណើត សូម្បីអ្នកដទៃនឹងនិយាយ ដល់ពណ៌ផ្សេងៗ ដូចពណ៌ស ពណ៌ក្រហម ពណ៌លឿង ក៏មិន អាចយល់ថា ពណ៌ទាំងនោះផ្សេងគ្នាយ៉ាងណា ឬ កាលទណា និយាយដល់សភាវៈ ការឃើញក៏មិនយល់ថា ការឃើញគឺអ្វី អ្នកខ្លះ មានឃានបសាទបែកធ្លាយ សូម្បីអ្នកដទៃ នឹងនិយាយដល់ក្លិនក្រ អូប ឬក្លិនស្អុយក៏មិនអាចចែកបាន ឬកាលមានអ្នកដទៃនិយាយ

ដល់អាហារ ដែលយើងមិនធ្លាប់ទទួលទាន យើងក៏មិនយល់ក្នុង
រសជាតិនោះ ឬអ្នកដែលមិនធ្លាប់ឈឺក្បាល ឈឺធ្មេញ សូម្បីអ្នក
ណា នឹងនិយាយដល់ ក៏មិនយល់ ក្នុងករណីតែមួយដូចគ្នានេះ
អ្នកដែលមិនធ្លាប់បន្ទះវិបស្សនាញាណ ឈាន ឬមគ្គផល សូម្បី
គម្ពីរនឹងពោលទុក ក៏មិនយល់យ៉ាងពិតប្រាកដ អ្នកបដិបត្តិបន្ទះ
វិបស្សនាញាណបន្ទះឈាន និងព្រះអរិយបុគ្គលប៉ុណ្ណោះ ទើបនឹង
យល់រឿងនោះៗ បានយ៉ាងជាក់ច្បាស់ ការយល់រឿងរបស់រូបនាម
អំពីការសិក្សាឬស្តាប់អំពីអ្នកដទៃត្រឹមជាបញ្ញត្តិដែលជាប់ទាក់ទង
ជាមួយបរមត្ថ មិនមែនសភាវធម៌ដែលជាបរមត្ថពិត ។

## ការទទួលដឹងបរមត្ថ

មនុស្សទូទៅឃើញពណ៌ផ្លូវចក្ខុបសាទពិត សូម្បីចក្ខុបសាទ
និងចក្ខុវិញ្ញាណ ក៏នៅមានពិតក្នុងខណៈឃើញ ដោយហេតុនេះ
ពណ៌ ចក្ខុបសាទ និងចក្ខុវិញ្ញាណទើបជាសភាវៈដែលមានពិត សូម្បី
សំឡេង សោតបសាទ និងសោតវិញ្ញាណ ក៏នៅមានពិតក្នុងខណៈ
បានឮសំឡេង ដូច្នេះជាដើម ។ ម្យ៉ាងទៀត តាមប្រក្រតីបុថុជ្ជន

អាចនឹងទទួលដឹងរូបនាម ដែលជាកាមធម៌បាន ព្រោះសភាវធម៌ទាំងនោះប្រាកដច្បាស់ផ្លូវទ្វារ ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដោយចំពោះក្នុងខណៈចំរើនវិបស្សនានឹងប្រាកដយ៉ាងច្បាស់ អ្នកដែលសម្រេចឈាន រមែងទទួលដឹងឈានធម៌ ដែលជាមហគ្គតធម៌បាន ចំណែកអ្នកដែលសម្រេចធម៌ជាព្រះអរិយបុគ្គល រមែងទទួលដឹងមគ្គ ផល និងនិព្វាន ( លោកុត្តរធម៌ ) ដោយប្រចក្សបាន ដូចនោះ រូបនាមទាំងអស់ទើបជាសភាវៈដែលមាននៅពិត ដែលហៅថា **បរមត្ថ** មិនមែនវត្ថុដែលគិតឡើងឯងដោយការស្តាប់តាមគ្នាមកជាដើម ដូចសាធកៈក្នុងគម្ពីរមូលដីកាថា

**អនុស្សវាទិវសេន គយ្ហមានោ តថាបិ ហោតិ អញ្ញថាបីតិ តាទិសោ ញេយ្យោ ន បរមត្ថោ ។ អត្តបច្ចក្ខោ បន បរមត្ថោតិ ទស្សេន្តោ អាហ "អនុស្សវាទិវសេន អត្តហេតញ្ច ឧត្តមត្ថោតិ ៍ ។**

"ព្រះអដ្ឋកថាចារ្យ កាលនឹងសម្តែងថា ( វត្ថុដែលទទួលដឹងដោយការស្តាប់តគ្នាមកជាដើម អាចនឹងពិត ឬមិនពិតក៏បាន វត្ថុដែលត្រូវទទួលដឹងយ៉ាងនោះ ទើបមិនមែនបរមត្ថ តែវត្ថុដែលប្រចក្ស

ដោយខ្លួនឯងទើបជាបរមត្ថ ) និងពោលដូចនេះថា

**អនុស្សវាទិវាសេន អត្ថហេតញ្ញ ឧត្តមត្ថោតិ**

( សេចក្តីដ៏ខ្ពង់ខ្ពស់បំផុត ដែលទទួលដឹងមិនបាន ដោយការស្តាប់តគ្នាមកជាដើម )" ។

**អវិបរីតភាវតោ ឯវំ បរមោ បធានោ អត្ថោតិ**

**បរមត្ថោ ។ ញាណស្ស បច្ចក្ខតោ ធម្មានំ**

**អនិទ្ទិសិតព្វសភាវោ ។ តេន វុត្តំ "ឧត្តមត្ថោតិ"[៧] ។**

"សេចក្តីដ៏ខ្ពង់ខ្ពស់បំផុតជាប្រធាន ឈ្មោះថា បរមត្ថ ព្រោះជាសភាវៈមិនប្រែប្រួល សំដៅដល់សភាវៈដែលឃើញច្បាស់ដល់[វិបស្សនា]ញាណ និងបុគ្គលដទៃក៏សម្តែងសភាវធម៌ឲ្យជាក់ច្បាស់មិនបាន" ។

សេចក្តីខាងដើម អធិប្បាយបានថា សភាវធម៌រូបនាមដែលមានពិតប្រាកដ មិនប្រែប្រួលអំពីការទទួលដឹងរបស់មនុស្សគ្រប់គ្នា ទើបចាត់ជាសេចក្តីដ៏ខ្ពង់ខ្ពស់បំផុត ឬបរមត្ថ និងជាសភាវៈ

ប្រចក្សដោយចំពោះ ដ៏ក្រៃលែងដល់អ្នកដែលចម្រើនវិបស្សនា រហូតកើតវិបស្សនាញាណ ទាំងមិនមែនជាសភាវៈដែលប្រចក្សដល់អ្នកដែលស្តាប់អំពីបុគ្គលដទៃសំណែនាំថាជា យ៉ាងនេះ យ៉ាងនោះ ។

ពាក្យថា **អនិទ្ទិសិតព្វសភាវោ** ( សម្តែងសភាវៈយ៉ាងជាក់ច្បាស់មិនបាន ) ស្របគ្នាជាមួយគម្ពីរអដ្ឋកថាថា **អនុស្សវាទិវសេន អគ្គហេតព្វោ** ( ទទួលដឹងមិនបានដោយការស្តាប់តគ្នាមកជាដើម ) ដោយព្រះអដ្ឋកថាចារ្យអធិប្បាយថា សភាវៈដែលមិនបានប្រចក្សដល់ខ្លួនត្រឹមតែស្តាប់អំពីបុគ្គលដទៃ មិនមែនបរមត្ថ និងព្រះដីកាចារ្យក៏ពោលថា សភាវៈការអធិប្បាយឲ្យអ្នកដទៃយល់តាមដែលខ្លួនឯងមិនបាន ឈ្មោះថា បរមត្ថ ។

ជាការពិតហើយ ពាក្យអធិប្បាយលក្ខណៈ របស់រូបនាមចាត់ជាបញ្ញត្តិប៉ុណ្ណោះ មិនមែនសភាវៈដែលប្រចក្សដល់អ្នកស្តាប់ ដូចជា ការពោលថា បឋវីធាតុមានលក្ខណៈរឹង ចិត្តមានសភាវៈទទួលដឹងអារម្មណ៍ ផស្សៈមានសភាវៈប៉ះខ្ទប់អារម្មណ៍ ក៏ជាពាក្យបញ្ញត្តិដែលពោលដល់ឈ្មោះ ដែលហៅថា **វិជ្ជមានបញ្ញត្តិ** ( បញ្ញត្តិ

សម្តែងសេចក្តីដែលប្រាកដ ) **អាការបញ្ញត្តិ** ( បញ្ញត្តិសម្តែងអាការ ) ឬបើអធិប្បាយក្នុងលក្ខណៈរបស់រូបរាងសណ្ឋាន ក៏ជាសណ្ឋានបញ្ញត្តិ ( បញ្ញត្តិសម្តែងសណ្ឋាន ) សូម្បីបុថុជ្ជន ដែលធ្លាប់បានស្តាប់មក ក៏អាចពោលដល់លក្ខណៈរបស់មគ្គផល និងនិព្វានបាន តែគេមិនអាចទទួលដឹងនិព្វាន ជាអារម្មណ៍ដោយមគ្គចិត្ត ឬផលចិត្តបាន ព្រោះអ្នកដែលមិនទាន់បន្ទុះគោត្រភូនឹងទទួលដឹងនិព្វានជាអារម្មណ៍មិនបានទេ ដូចអ្នកដែលមិនធ្លាប់ទទួលទាន ផ្លែស្វាយមកពីមុន កាលមានអ្នកដទៃនិយាយថា ផ្លែស្វាយផ្អែម ក៏មិនដឹងថាយ៉ាងណា បន្ទាប់អំពីបានទទួលទានហើយ ទើបយល់ដល់រសផ្អែមនោះបាន ដូច្នេះ លក្ខណៈរបស់មគ្គផល និងនិព្វានដែលបុថុជ្ជនទទួលដឹងត្រឹមតែជាការទទួលដឹងបែបសញ្ញា មិនមែនជាការទទួលដឹងដោយប្រចក្សដោយខ្លួនឯងទេ ។

ម្យ៉ាងទៀត បញ្ញត្តិជាពាក្យនិយាយសំដៅដល់ ( **នាមបញ្ញត្តិ, សទ្ទបញ្ញត្តិ** ) និងជាវត្ថុសន្មតិគ្នាឡើងក្នុងលោក ( **អត្ថបញ្ញត្តិ** ) មានសភាពមិនប្រែប្រួលពីព្រោះមិនមានពិត បញ្ញត្តិទាំងពីរយ៉ាងនោះ

ត្រឹមតែជាវត្ថុដែលនឹងគិតឡើងមកជាអារម្មណ៍ប៉ុណ្ណោះ សាកគិតមើលថា ឈ្មោះនាយក នៅត្រង់រាងកាយចំណែកណា និងផ្លាស់ប្តូរទៅកាលណា នឹងជួបថាឈ្មោះ ដូចពោលមិនបាននៅត្រង់អវយវៈចំណែកណាឡើយ ទាំងមិនបានកើតឡើង នៅជាមួយកាលវេលាឈ្មោះនេះ នឹងប្រាកដឡើង កាលមនុស្សគ្រប់គ្នានឹកដល់នាយ ក ប៉ុណ្ណោះ បើមនុស្សគ្រប់គ្នាភ្លេចគេ ឈ្មោះក៏នឹងបាត់សូន្យទៅ ដូចសុមេធតាបស ដែលបាត់សូន្យទៅ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប តែមកប្រាកដដល់ពុទ្ធបរិសទ្យក្នុងភទ្រកប្បនេះទៀត សូម្បីសាធារណនាមថា បុរស ស្ត្រី ឆ្មាំង សំពត់ជាដើម ក៏មានន័យតែមួយដូចគ្នា គឺជាវត្ថុដែលមិនមានពិត តាំងដោយពាក្យហៅនិងវត្ថុរបស់របរ ពាក្យហៅជាបុគ្គលបញ្ញត្តិ គឺបញ្ញត្តិសំដែងបុគ្គល ចំណែកវត្ថុរបស់របរជាសណ្ឋានបញ្ញត្តិ គឺបញ្ញត្តិសំដែងសណ្ឋាន ។

វត្ថុដែលហៅថា រទេះ ផ្សំឡើងអំពីកង់ កាំ តួខ្នងរទេះ ។ល។ បើញែកផ្នែកតែមួយផ្នែកចេញមក ក៏នឹងមិនសេសសល់រទេះ យ៉ាងណា បើញែករូបនាមចេញអំពីបុគ្គល ដែលយើងសន្មតិគ្នាថា ជាបុរស ស្ត្រី ក៏នឹងមិនមានបុរសឬស្ត្រីឡើយ ដូច្នោះ ក្នុងទំនងដូចគ្នា

នេះ សូម្បីជួរស្រមោច ក៏ត្រឹមតែជាការរួមគ្នួន របស់ស្រមោច ដែលដើរជាប់បន្តគ្នាទៅ បាវខ្សាច់ប្រកបដោយគ្រាប់ខ្សាច់ ដែលកំពុងរួមគ្នា ខ្សែវិញដោយសរសៃផ្ទដូង ក៏គឺសរសៃផ្ទដូងដែលនាំមករួមគ្នា ក្រសែទឹកគឺទឹកដែលហូរមករួមគ្នាមិនដាច់ ឬដើមឈើក៏ជាវត្ថុដែលរួមចំណែកសំខាន់ ដូចជាឫស គល់ដើមឈើ មែកស្លឹកជាដើម ។

ពោលដោយសរុបមក ក្នុងបណ្តាបរមត្ថ ៤ យ៉ាងនោះ ព្រះនិព្វាន ជាអសង្ខតធម៌ ដែលមិនត្រូវបច្ច័យគឺ កម្ម ចិត្ត ឧតុ និងអាហារប្រជុំតាក់តែង ទើបមានសភាវៈទៀងទាត់ប្រាកដមិនប្រែប្រួល ចំណែកបរមត្ថ ៣ យ៉ាងទៀតគឺ ចិត្ត ចេតសិក និងរូប ជាសង្ខតធម៌ ដែលមានបច្ច័យប្រជុំតាក់តែង ទើបមានសភាវៈប្រែប្រួលមិនទៀង កាលញែកចេញជាវត្ថុដែលកើតខាងក្នុងរាងកាយ ( **អជ្ឈត្តសន្តាន** ) និងកើតនៅខាងក្រៅរាងកាយ ( **ពហិទ្ធសន្តាន** ) ទាំងអស់នោះ ប្រកបដោយខណៈកើតឡើង ( **ឧប្បាទខណៈ** ) ខណៈតាំងនៅ ( **ឋិតិខណៈ** ) និងខណៈរលត់ទៅ ( **ភង្គខណៈ** ) ក្នុងអតីត បច្ចុប្បន្ន និង អនាគត ។

ចំណែកបញ្ញត្តិ ដែលជាពាក្យនិយាយ និងវត្ថុសន្មតិគ្នាឡើងក្នុងលោក មិនមែនវត្ថុដែលមាននៅពិត ក្នុងខណៈកើតឡើង តាំងនៅ និងរលត់ទៅក្នុងកាលទាំង ៣ ទាំងមិនមែននិព្វាន ដែលជាអារម្មណ៍របស់មគ្គចិត្ត និងផលចិត្ត ត្រឹមតែជាវត្ថុដែលគិតសន្មតិឡើង ដូចជាពាក្យបាលីថា រូបារម្មណ៍ ឬ ពាក្យប្រែថា "រូបារម្មណ៍" ឬ "ពណ៌" ត្រឹមតែជាវត្ថុដែលយើងគិតឡើងមកឯង មិនមែនកើតហើយកំពុងកើត ឬនឹងកើតឡើងខាងក្នុង និងខាងក្រៅរាងកាយ ទាំងមិនបានតាំងនៅក្នុងទីណានិមួយ ចំណែកការគិតដល់វត្ថុទាំងនោះ ផ្លូវមនោទ្វារចាត់ជានាមបញ្ញត្តិ អាការបញ្ញត្តិ ឬ សណ្ឋានបញ្ញត្តិ តាមសមគួរ ព្រោះវត្ថុទាំងនោះមិនមែនកើតហើយ កំពុងកើត ឬនឹងកើតឡើងតទៅ ទាំងមិនបានតាំងនៅក្នុងទីណា ប្រៀបដូចជាមនុស្សខ្វាចខ្មោច កាលជួបប្រទះវត្ថុដែលគួររន្ធត់ចិត្ត ក៏គិតថាខ្មោចលង ឬមនុស្សដេកលក់យល់សប្តិទៅ ក៏គិតថា ការយល់សប្តិនោះជាការពិត ដូច្នោះ អារម្មណ៍គ្រប់យ៉ាង ដែលប្រាកដឡើងក្នុងចិត្តតាមសញ្ញាសំគាល់ដឹង ចាត់ជាបញ្ញត្តិដែលមិនមានពិត តាមន័យដូចដែលពោលមកនេះ ពាក្យបញ្ញត្តិ ដែលពោលដល់ចក្ខុបសាទ

ចក្ខុវិញ្ញាណ រូបារម្មណ៍ និងសោតបសាទ សោតវិញ្ញាណ សទ្ទា-រម្មណ៍ជាដើម ជាបញ្ញត្តិ ចំណែកសភាវៈដែលចិត្តទទួលដឹងយ៉ាងពិតប្រាកដ ក្នុងបច្ចុប្បន្នខណៈជាបរមត្ថ ។

ម្យ៉ាងទៀត ពាក្យសម្តែងឈ្មោះនៃអាកប្បកិរិយាផ្សេងៗ ដូចជាការដើរ ឈរ អង្គុយ ដេក បត់ លាត ជាបញ្ញត្តិ ដែលហៅថា **វិជ្ជមានបញ្ញត្តិ** គឺបញ្ញត្តិដែលសម្តែងសេចក្តីមានប្រាកដ ព្រោះការនិយាយដល់រូបដែលកើតអំពីចិត្ត ( **ចិត្តជរូប** ) ដែលកើតឡើងអំពីចិត្តដែលត្រូវការដើរជាដើម អង្គធម៌នៃការដើរប្រកបដោយចិត្តចេតសិក និងចិត្តជរូប ដែលប្រព្រឹត្តទៅដោយអាការនោះ ចំណែកសេចក្តីក្នុងពាក្យបញ្ញត្តិថា ដើរ អាចនិយាយដល់ការទទួលដឹងបានពីរលំដាប់ គឺការទទួលដឹងរបស់មនុស្សទូទៅ និងការទទួលដឹងរបស់អ្នកចំរើនវិបស្សនាភាវនា ។

ការទទួលដឹងរបស់មនុស្សទូទៅ សំដៅដល់ការទទួលដឹងតាមប្រក្រតី ដែលមនុស្សទូទៅរមែងទទួលដឹងថា យើងដើរ យើងឈរ យើងអង្គុយ យើងដេក យើងលាត យើងបត់ ។ល។ ដោយមានការ

ដឹងត្រឹមថាមានតួខ្លួន ព្រមដោយរូបរាងសណ្ឋានរបស់ដៃ ជើង រាងកាយ វត្ថុដែលទទួលដឹងនេះជាបុគ្គលបញ្ញត្តិ គឺបញ្ញត្តិសម្តែងបុគ្គល និងសណ្ឋានបញ្ញត្តិ គឺបញ្ញត្តិសម្តែងសណ្ឋាន សូម្បីថាបញ្ញត្តិដែលជាវិជ្ជមានបញ្ញត្តិ និង និយាយដល់វត្ថុដែលមានពិត តែបើមិនមានសតិអប់រំដឹងសភាវធម៌តាមសេចក្តីពិត ក៏យល់ថា មានតួខ្លួន យើង របស់យើង ដូចបញ្ញត្តិដែលសំដៅដល់រូប វេទនា និងបឋវីជាដើម សូម្បីមានមកមុនសម័យពុទ្ធកាល ក៏មិនបានធ្វើឲ្យមនុស្សទូទៅទទួលដឹងសភាវៈរបស់បញ្ញត្តិពួកនេះបាន កាលព្រះអង្គទ្រង់ប្រកាសសច្ចធម៌ហើយ ពុទ្ធបរិស័ទ ទើបយល់និងកំណត់ដឹងបានយ៉ាងត្រឹមត្រូវ ។

ការទទួលដឹងរបស់អ្នកចំរើនវិបស្សនា ជាការទទួលដឹងសភាវៈរបស់រូបដែលកំពុងកម្រើកក្នុងខណៈដើរ និងកាលវិបស្សនា-ញាណចាស់ក្លាឡើង រមែងនឹងទទួលដឹងចិត្តដែលត្រូវការនឹងដើរ ទទួលដឹងរូបដែលកើតហើយរលត់ទៅ ក្នុងមួយខណៈៗ ក្នុងខណៈនោះ អ្នកបដិបត្តិនឹងយល់បានថា ( យើងដើរ ) ត្រឹមតែជាពាក្យដែលប្រើនិយាយគ្នាក្នុងលោក មិនមានខ្លួនយើងដែលកំពុងដើរ

ពិត មានត្រឹមតែចិត្តដែលត្រូវការទីងដើរ និងរូបដែលកម្រើកអំពីខណៈមួយទៅកាន់ខណៈមួយទៀតប៉ុណ្ណោះ សូម្បីក្នុងខណៈ ឈរ បត់ លាតជាដើម អ្នកបដិបត្តិក៏ទឹងទទួលដឹងចិត្តដែលត្រូវការធ្វើឥរិយាបថនោះ ៗ ព្រមដោយរូបដែលកើតឡើង និងការកើតរលត់របស់រូបអំពីមួយខណៈទៅកាន់មួយខណៈទៀត ការទទួលដឹងយ៉ាងនេះ ជាការឃើញយ៉ាងប្រចក្សដោយវិបស្សនាញាណ ។

[ចិត្តដែលត្រូវការទឹងកម្រើកដូចពោល ដែលប្រកបដោយចេតនាគឺ ការតាំងចិត្ត និងឆន្ទៈ គឺសេចក្តីប្រាថ្នា ជាហេតុឲ្យកើតសភាវៈកម្រើក សំណាក់វិបស្សនាកន្លែងខ្លះហៅចិត្តនោះថា "ដើមចិត្ត" តែអ្នកប្រែគិតថា គួរហៅថា "ចិត្តបញ្ជា" នឹងយល់ងាយថា ដូចពាក្យសុភាសិតថា "ចិត្តជាចៅហ្វាយ កាយជាបាវព្រាវ"] ។

ក្រៅពីនេះ បញ្ញត្តិដែលជាពាក្យបាលីថា **ឥត្ថី បុរិស ហត្ថៈ បាទៈ យដៈ** និង**បដៈ** ព្រមទាំងពាក្យប្រែថា ស្ត្រី បុរស ដៃ ជើង ឆ្នាំង សំពត់ជាដើមបានឈ្មោះថា **អវិជ្ជមានបញ្ញត្តិ** គឺ បញ្ញត្តិដែលសម្តែងសេចក្តីដែលមិនមានប្រាកដព្រោះវត្ថុទាំងនេះ ត្រឹមតែជាសំណុំរូប ដែលសម្តែងឲ្យយល់បានថាជា ស្រី ប្រុស ពិតមែន

ហើយ សភាវៈដែលទទួលដឹងបានផ្លូវបសាទ សម្ផស្ស គឺពណ៌ សំឡេង ក្លិន រស និងផស្សៈដែលជាភាពរឹង ទន់ ក្តៅ ត្រជាក់ ធូរ តឹង មិនមែនពាក្យ បញ្ញត្តិថា ស្ត្រី បុរស តែយ៉ាងណា តាមគោល ព្រះអភិធម្ម ការទទួលដឹងពាក្យបញ្ញត្តិ និងសណ្ឋាននោះ កើតឡើង ផ្លូវចិត្តដែលហៅថា មនោទ្វារវិថី ដែលកើតបន្តអំពីបញ្ចទ្វារវិថី គឺវិថីចិត្តដែលកើតផ្លូវបញ្ចទ្វារ ។

មានពាក្យសុភាសិតថា "កាលបើបញ្ញត្តិកើត បរមត្ថរមែងបាត់ទៅ កាលបើបរមត្ថកើតបញ្ញត្តិរមែងបាត់ទៅ" សេចក្តីថា កាលយើងទទួលដឹងថាជាស្ត្រី បុរសតាមបញ្ញត្តិនោះ ៗ បរមត្ថដែលជាពណ៌ សំឡេង ក្លិន ។ល។ រមែងមិនប្រាកដ តែកាលទទួលដឹងសភាវៈថាជារូបនាមបរមត្ថរមែងប្រាកដ និងបញ្ញត្តិរមែងអន្តរធានទៅ ។

## អារម្មណ៍របស់វិបស្សនា

ឥឡូវនេះ នឹងពោលដល់អារម្មណ៍របស់វិបស្សនា អ្នកដែលប្រាថ្នានឹងបដិបត្តិវិបស្សនាភាវនា គប្បីចម្រើនសតិអប់រំដឹងរូបនាមបរមត្ថប៉ុណ្ណោះ មិនគួរដាក់ចិត្តចំពោះបញ្ញត្តិ សូម្បីក្នុងបរមត្ថ ក៏គួរ

កំណត់ដឹងសភាវៈដែលជាលោកិយធម៌ គឺធម៌ចំណែកលោក សំដៅដល់ចិត្ត ចេតសិកនិងរូប មិនគួរកំណត់ដឹងលោកុត្តរធម៌ ព្រោះបុថុជ្ជនមិនអាចយល់សភាវៈដែលពិតប្រាកដរបស់លោកុត្តរធម៌បាន សូម្បីសម្រាប់ព្រះអរិយបុគ្គល ក៏មិនមានប្រយោជន៍ដែលកំណត់ដឹងលោកុត្តរធម៌ដែរ ព្រោះការកំណត់ដឹងលោកិយធម៌នោះមានគោលដៅដើម្បីដកខ្លួនចេញពីកិលេស ដែលប្រកាន់មាំថាជារបស់ទៀង ជាសុខ ជាតួខ្លួន តែកិលេសដែលប្រកាន់មាំ ដូច្នោះមិនមានក្នុងលោកុត្តរធម៌ ដូចនោះ សូម្បីទឹងកំណត់ដឹងលោកុត្តរធម៌ក៏មិនអាចលះកិលេសបាន ដូចជាការកែតម្រូវផែនដីដែលមានទាំងទីទួល និងទីទំនាបឲ្យរាបស្មើគ្នា ជាវត្ថុដែលមានប្រយោជន៍ចំពោះការកែតម្រូវផែនដី ដែលរៀបរយហើយ រមែងនឹងមិនបានប្រយោជន៍តែយ៉ាងណា ដូចសាធកៈដែលពោលដល់បុថុជ្ជននិងព្រះអរិយបុគ្គលថា

លោកុត្តរចិត្តានិ ចន នេវ សុខវិបស្សកស្ស ។

ន សមថយានិកស្ស បរិគ្គហំ គច្ឆន្តិ អនធិគតត្តា[៥] ។

“ចំណែកលោកុត្តរចិត្ត រមែងមិនដល់ការកំណត់ដឹងរបស់អ្នកចម្រើនវិបស្សនាតែម្យ៉ាង និងអ្នកចម្រើនសមថយានិក ព្រោះខ្លួននៅមិនបានសម្រេចលោកុត្តរធម៌” ។

**វិវដ្ដេ នត្ថិ អវិសយត្តា វិសយត្តេបិ ច បយោជនាភាវតោ[៩]។**

“ការចម្រើនកម្មដ្ឋាន រមែងមិនមានក្នុងលោកុត្តរធម៌ ព្រោះមិនមែនជាឋានៈ ដែលទទួលដឹងបាន និងសូម្បីថាជាឋានៈ [ដែលព្រះអរិយបុគ្គលទទួលដឹងបាន] ក៏មិនមានប្រយោជន៍ក្នុងការកំណត់ដឹង” ។

ម្យ៉ាងទៀត វិបស្សនាមាន ២ ប្រការគឺ ៖

១. **បច្ចក្ខវិបស្សនា** វិបស្សនាដែលប្រចក្សយ៉ាងច្បាស់ ។

២. **អនុមានវិបស្សនា** វិបស្សនាដែលអនុមានដឹង ។

**បច្ចក្ខវិបស្សនា** ជាការឃើញរូបនាម តាមសភាវៈពិតក្នុងបច្ចុប្បន្នខណៈ ដូចប៉ះខ្ទប់ដោយដៃ អ្នកបដិបត្តិរមែងដឹង ឃើញសភាវលក្ខណៈ គឺលក្ខណៈវិសេសនៃរូបនាមក្នុងមួយខណៈ ដោយបច្ចក្ខវិបស្សនា ទាំងឃើញត្រៃលក្ខណ៍ដែលហៅថាសាមញ្ញលក្ខណៈ

គឺ លក្ខណៈទូទៅដែលបានដល់ **អនិច្ចំ** ( ការមិនទៀង ) **ទុក្ខំ** ( ភាពជាទុក្ខ ) និង **អនត្តា** ( ភាពមិនមែនខ្លួន ) ដោយហេតុនេះ អ្នកបដិបត្តិទើបគួរចំរើន **បច្ចក្ខវិបស្សនា** តាំងអំពីចាប់ផ្តើមបដិបត្តិធម៌រហូតសម្រេចអនុលោមញាណ ។

កាល**បច្ចក្ខវិបស្សនា**មានកម្លាំងចាស់ក្លាឡើង តាំងពីនាមរូប-បរិច្ឆេទញាណជាដើមទៅ អ្នកបដិបត្តិនឹងអនុមានដឹងរូបនាមដែលមិនបានកំណត់ដឹងក្នុងបច្ចុប្បន្នខណៈ ការអនុមានដឹងយ៉ាងនេះឈ្មោះថា **អនុមានវិបស្សនា** វិបស្សនាប្រភេទនេះអាចទទួលដឹងអារម្មណ៍ដែលជាលោកិយធម៌ទាំងអស់ ដែលកើតខាងក្នុង ខាងក្រៅ ជាអតីតៈ អនាគត ឬបច្ចុប្បន្ន តែមិនអាចឃើញលក្ខណៈវិសេស និងលក្ខណៈទូទៅរបស់នាមរូបយ៉ាងជាក់ច្បាស់ ដូចបច្ចក្ខវិបស្សនាទាំងមិនមែនវិបស្សនាញាណ ដែលត្រូវព្យាយាមធ្វើឲ្យកើតឡើង តែនឹងកើតឡើងឯង ក្នុងខណៈដែលបច្ចក្ខវិបស្សនាចាស់ក្លាហើយ តពីនេះទៅ ខ្ញុំនឹងពោលដល់វិធីនៃការចម្រើនបច្ចក្ខវិបស្សនាជាគោល ។

ក្នុងបណ្តាលោកិយធម៌ អ្នកបដិបត្តិដែលចាប់ផ្តើមចម្រើនឈានភាវនា មិនអាចកំណត់ដឹងអរូបឈានទី ៤ ឈ្មោះនេវសញ្ញានាសញ្ញាយតនៈ ឈានដូចពោលមានសេចក្តីល្អិតសុខុម មិនមានសញ្ញាប្រាកដច្បាស់ សូម្បីរហូតដល់ព្រះសារីបុត្រក៏មិនអាចកំណត់ដឹងសញ្ញាជាដើមដែលលះក្នុងឈាននោះតែម្យ៉ាង ចំណែកអ្នកដែលសម្រេចឈានហើយ រមែងអាចកំណត់ដឹងមហគ្គតធម៌បាន អ្នកដែលនៅមិនទាន់សម្រេចឈាន រមែងមិនអាចកំណត់ដឹងបាន ព្រោះឈានធម៌ មិនធ្លាប់ប្រាកដក្នុងក្រសែចិត្តរបស់ខ្លួន ដូចសាធកៈក្នុងគម្ពីរវិសុទ្ធិមគ្គមហាដីកាថា

**លាភិនោ ឯវ មហគ្គតចិត្តានិ សុបាកដានិ ហោន្តិ**[10] ។

"មហគ្គតចិត្ត រមែងប្រាកដច្បាស់ ដល់អ្នកសម្រេចឈានប៉ុណ្ណោះ" ។

ពាក្យថា "ប៉ុណ្ណោះ" ដែលជាសេចក្តីរបស់ ឯវ សព្ទសម្តែងការបដិសេធថា មហគ្គតចិត្ត រមែងមិនប្រាកដដល់អ្នកដែលមិនបានសម្រេចឈាន ។

ពាក្យថា "ប្រាកដច្បាស់" សំដៅដល់សភាវលក្ខណៈរបស់ឈាន ប្រាកដដល់បញ្ញាដែលដឹងយ៉ាងជាក់ច្បាស់ (បច្ចក្ខញាណ) ។

ពាក្យថា "មិនប្រាកដច្បាស់" សំដៅដល់ការអនុមានដឹងដោយមិនបានទទួលដឹងយ៉ាងជាក់ច្បាស់ ដោយហេតុដូចដែលពោលនេះ អ្នកដែលមិនបានសម្រេចឈាន ទើបគួរកំណត់ដឹងកាមធម៌ប៉ុណ្ណោះ កាលកាមធម៌ប្រាកដច្បាស់ហើយ ក៏អាចអនុមានដឹងមហគ្គតធម៌បាន ។ ម្យ៉ាងទៀត អ្នកចម្រើនវិបស្សនា គួរកំណត់ដឹងទាន់កាមធម៌ដែលជារូបនាមប្រាកដច្បាស់ក្នុងបច្ចុប្បន្នខណៈ មិនគួរអនុមានដឹងរូបនាមដែលមិនប្រាកដច្បាស់យ៉ាងពិត ដូចសេចក្ដីក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា

**យេហិ ច សម្មសនុបគា, តេសុ យេ យស្ស បាកដា ហោន្តិ, សុខេន បរិគ្គហំ គច្ឆន្តិ, តេសុ តេន សម្មសនំ អារភិតព្វំ[១១] ។**

"ក្នុងបណ្ដាធម៌ដែលគួរឃើញច្បាស់ ធម៌ពួកណាប្រាកដច្បាស់ដល់បុគ្គលណា រមែងដល់ភាពជាធម៌ ដែលបុគ្គលកំណត់ដឹងបានដោយងាយស្រួល គេគួរប្រារព្ធការឃើញច្បាស់ក្នុងធម៌ទាំងនោះ" ។

ក្នុងរូប ២៨ ប្រភេទ គួរកំណត់ដឹងរូបបរមត្ថដោយពិត ១៨ យ៉ាង ដែលហៅថា

- រូបរូប រូបដែលមានការអន់ថយទៅ ។

- និប្ផន្នរូប រូបដែលកើតអំពីកម្ម ចិត្ត ឧតុ និងអាហារ ។

- សលក្ខណរូប រូបដែលមានលក្ខណៈរបស់ខ្លួន ដែលជាសង្ខតធម៌ ដែលបានដល់ការកើតឡើង តាំងនៅ និងរលត់ទៅ ។

- សម្មសនរូប រូបដែលគួរឃើញច្បាស់ដោយភាពជាត្រៃលក្ខណ៍ ដោយវិបស្សនាញាណ ។

- សភាវរូប រូបដែលមានសភាវៈរបស់ខ្លួនៗ ។

អ្នកបដិបត្តិមិនកំណត់រូប ១០ ប្រភេទដែលហៅថា អនិប្ផន្នរូប គឺរូបដែលមិនបានកើតពីកម្ម ចិត្ត ឧតុ និងអាហារ ។

រឿងនេះ មានការជាប់ទាក់ទងក្នុងគម្ពីរវិសុទ្ធិមគ្គមហាដីកាថា

រូបរូបានេវ ហិ ឥធ បរិគ្គយហន្តិ ។

ន រូបបរិច្ឆេទវិការលក្ខណានិ[១២] ។

"អ្នកបដិបត្តិគួរកំណត់ដឹងរូបរូបប៉ុណ្ណោះក្នុងរឿងនេះ មិនគួរកំណត់ដឹងអាកាសធាតុ វិការរូប និងលក្ខណរូប" ។

ក្រៅពីនេះ បុថុជ្ជននិងព្រះសេក្ខៈ រមែងមិនអាចកំណត់ដឹងកិរិយាទូន្មានចិត្តរបស់ព្រះអរហន្តបាន បុគ្គលពួកនោះ អ្នកចម្រើនវិបស្សនាភាវនា គួរកំណត់ដឹងរូបនាមដោយបច្ចក្ខវិបស្សនាដូចនេះ

- និប្ផន្នរូប ១៨ គឺ បសាទរូប ៥ វិសយរូប ៧ អាបោធាតុ ១ ភាវរូប ២ ហទយវត្ថុ ១ ជីវិតរូប ១ អាហាររូប ១ ។

- កាមាវចរចិត្ត ៤៥ ដូចគឺ អកុសលចិត្ត ១២ អហេតុកចិត្ត ១៧ ( វៀរហសិតុប្បាទចិត្ត ១ ) កាមាវចរសោភនចិត្ត ១៦ ( វៀរមហាកិរិយាចិត្ត ៨ ) ។

- ចេតសិក ៥២ ដូចដែលកើតរួមគ្នាជាមួយចិត្តពួកនោះ ។

ក្នុងខណៈឃើញពណ៌ផ្លូវចក្ខុទ្វារ រូបនាមដែលបានដល់ចក្ខុបសាទ រូបារម្មណ៍ គឺ ពណ៌ និងចក្ខុវិញ្ញាណ ដែលទទួលដឹងអារម្មណ៍ផ្លូវចក្ខុទ្វារព្រមដោយចិត្ត ( ចក្ខុទ្វារិកចិត្ត ) និងចេតសិក

ដទៃៗ ដែលកើតព្រមជាមួយចក្ខុវិញ្ញាណ រមែងប្រាកដទៅតាមលំដាប់ បានដល់ចិត្ត ៣៥ ដួងគឺ បញ្ចទ្វារាវជ្ជនចិត្ត ១ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ វោដ្ឋព្វនចិត្ត ១ កាមជវន ២០ គឺ អកុសលជវន ១២ មហាកុសលជវន ៨ តទារម្មណចិត្ត ១១ គឺ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ។

ក្នុងខណៈបានឮសំឡេងផ្លូវសោតទ្វារ រូបនាមដែលកើតឡើង គឺសោតបសាទ សទ្ទារម្មណ៍ ( សំឡេង ) និងសោតវិញ្ញាណដែលទទួលដឹងអារម្មណ៍ផ្លូវសោតទ្វារ ព្រមដោយសោតទ្វារិកចិត្ត និងចេតសិកដទៃៗ ដែលកើតព្រមជាមួយសោតវិញ្ញាណ រមែងប្រាកដដោយមានលំដាប់ចិត្ត ៣៥ ដួងខាងដើម ។

ក្នុងខណៈដឹងក្លិនផ្លូវឃានទ្វារ រូបនាមដែលកើតឡើង គឺ ឃានបសាទ គន្ធារម្មណ៍ ( ក្លិន ) និងឃានវិញ្ញាណដែលទទួលដឹងអារម្មណ៍ផ្លូវឃានទ្វារ ព្រមដោយឃានទ្វារិកចិត្ត និងចេតសិកដទៃៗ ដែលកើតព្រមជាមួយនឹងឃានវិញ្ញាណ រមែងប្រាកដដោយមានលំដាប់ចិត្ត ៣៥ ដួងខាងដើម ។

ក្នុងខណៈដឹងក្លិនផ្លូវជិវ្ហាទ្វារ រូបនាមដែលកើតឡើង គឺ ជិវ្ហា-បសាទ រសារម្មណ៍ ( រស ) និងជិវ្ហាវិញ្ញាណដែលទទួលដឹងអារម្មណ៍ផ្លូវជិវ្ហាទ្វារ ព្រមដោយជិវ្ហាទ្វារិកចិត្ត និងចេតសិកដទៃៗ ដែលកើតព្រមជាមួយជិវ្ហាវិញ្ញាណ រមែងប្រាកដដោយមានលំដាប់ចិត្ត ៣៥ ដួងខាងដើម ។

ក្នុងខណៈប៉ះខ្ទប់កាយទ្វារ រូបនាមដែលកើតឡើងគឺកាយបសាទ ផោដ្ឋព្វារម្មណ៍ ( ធាតុដីដែលបានដល់សភាវៈ រឹង-ទន់ ធាតុភ្លើងបានដល់ សភាវៈក្តៅ-ត្រជាក់ ធាតុខ្យល់បានដល់សភាវៈធូរ-តឹង ) និងកាយវិញ្ញាណ ដែលទទួលដឹងអារម្មណ៍ផ្លូវកាយទ្វារ ព្រមដោយកាយទ្វារិកចិត្ត និងចេតសិកដទៃៗ ដែលកើតព្រមជាមួយកាយ-វិញ្ញាណ រមែងប្រាកដដោយមានលំដាប់ចិត្ត ៣៥ ដួងខាងដើម ។

ក្នុងខណៈទទួលដឹងភាពជាស្រី ឬប្រុស ឥត្ថីភាវរូប ដែលសម្តែងពីភាពជាស្រី ឬបុរិសភាវរូបដែលសម្តែងភាពជាប្រុស រមែងកើតឡើងផ្លូវមនោទ្វារ ។

ក្នុងខណៈលេបទឹកមាត់ ស្តោះទឹកមាត់ ឬ ទឹកស្អុកហូរ ទឹក

មូត្រហូរ ញើសហូរ អាបោធាតុដែលមានសភាវៈហូរជ្រាប-កក រមែងកើតឡើងផ្លូវមនោទ្វារ ។

ក្នុងខណៈនឹកគិតពិចារណា ឬកំណត់ដឹងបច្ចុប្បន្នអារម្មណ៍ ហទយវត្ថុ ដែលជារូបអាស្រ័យកើតរបស់ចិត្ត និងចេតសិក រមែងកើតឡើង ចិត្តដែលនឹកគិតពិចារណាកាមធម៌ គឺរូប សំឡេង ក្លិន រស សម្ផស្ស ។ល។ មាន ៣២ ដួងគឺ មនោទ្វារាវជ្ជនចិត្ត ១ កាមជវន ២០ តទារម្មណចិត្ត ១១ ចំណែកចិត្តដែលកំណត់ដឹងសភាវធម៌បច្ចុប្បន្ន គឺ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ តទារម្មណចិត្ត ១១ ។

ម្យ៉ាងទៀត សូម្បីវិបស្សនាជវនចិត្តដែលជាញាណវិប្បយុត្តចិត្ត ក៏មានក្នុងគ្រាខ្លះ ដូចមានសាធកៈថា

**ភាវេន្តោបិ តេសំយេវ អញ្ញតរេន ភាវេតិ**[១៣] ។

"សូម្បីអ្នកចំរើនភាវនា រមែងចំរើនបានដោយមហាកុសលចិត្ត ៨ ដួង ដួងណាមួយនោះ" ។

កទាចិ បរិចយពលេន ញាណវិប្បយុត្តចិត្តេហិបិ សម្មសទំ[១៤] ។

"គ្រាខ្លះការកំណត់ដឹង រមែងមានដោយចិត្តដែលប្រកបដោយបញ្ញា ដោយកម្លាំងនៃការធ្លាប់ឃើញ ( មហាកុសលញាណវិប្ប-យុត្តចិត្ត ៤ )" ។

**បគុណំ សមថវិបស្សនាការទំ អនុយុញ្ជន្តស្ស អន្តរន្តរា ញាណវិប្បយុត្តចិត្តេនាបិ មនសិការោ បវត្តតិ[១៥] ។**

"ការធ្វើទុកក្នុងចិត្ត រមែងប្រព្រឹត្តទៅបានខ្លះ ក្នុងខណៈដល់អ្នកចំរើនសមថការនា និងវិបស្សនាការនាដែលជំនាញ សូម្បីដោយចិត្តដែលមិនប្រកបដោយបញ្ញា" ។

ក្រៅពីនេះ សូម្បីតទាលម្មណចិត្ត រមែងមានដោយកើតឡើងក្នុងលំដាប់បន្ទាប់ពីវិបស្សនាជវនចិត្ត ដែលមានកម្លាំងខ្សោយ ដូចសាធកៈក្នុងគម្ពីរបដ្ឋានថា

**អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។ កុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ[១៦] ។**

"រមែងឃើញថា មិនទៀង ជាទុក្ខ មិនមែនខ្លួន កាលកុសលរលត់ហើយ វិបាកចិត្តរមែងកើតឡើងដោយភាពជាតទារម្មណ៍" ។

អាហាររូបដែលជាឱជា រមែងប្រាកដកាលបរិភោគអាហារហើយមានកម្លាំងថែមឡើង ឬកាលមិនបានបរិភោគអាហារហើយអស់កម្លាំង ។

ជីវិតរូប ដែលមានសភាពតាមរក្សារូបដែលកើតអំពីកម្ម ( **កម្មជរូប** ) ឲ្យប្រព្រឹត្តទៅ រមែងប្រាកដដើម្បីតាមរក្សាបសាទរូប ភាវរូប និងហទយរូប ជាកម្មជរូបដែលកើតឡើងយ៉ាងបន្តបន្ទាប់ ។

ដោយប្រការដូចនេះ អ្នកបដិបត្តិគប្បីចម្រើនវិបស្សនាភាវនាដោយការកំណត់ដឹងរូបនាមដែលប្រាកដច្បាស់ក្នុងបច្ចុប្បន្នខណៈនោះ ៗ តាមសេចក្តីពិត ។

ម្យ៉ាងទៀត សូម្បីអារម្មណ៍របស់វិបស្សនាទីងបានជាអារម្មណ៍ខាងក្នុងនិងខាងក្រៅ ដូចសេចក្តីក្នុងមហាសតិប្បដ្ឋានសូត្រ[១៧] តែអ្នកបដិបត្តិគួរចាប់ផ្តើមពីការកំណត់ដឹងអារម្មណ៍ខាងក្នុង គឺរូបនាមដែលនៅក្នុងរាងកាយ មានប្រវែងមិនលើសពីមួយព្យាម កម្រាស់

មួយចម្អាម ទទឹងត្រឹមមួយហត្ថ កាលវិបស្សនាញាណចាស់ក្លា ហើយ ក៏អាចនឹងទទួលដឹងអារម្មណ៍ខាងក្រៅបានឯង វិធីនេះ ជាវិធី បដិបត្តិនៃសាវកទាំងឡាយ ដូចប្រាកដក្នុងដីការបស់អនុបទសូត្រ ដែលអធិប្បាយរឿងរបស់ព្រះមោគ្គល្លានត្ថេរ អ្នកកំណត់ដឹង សភាវធម៌ចំណែកខ្លះ ហើយបានសម្រេចជាព្រះអរហន្ត មានសេចក្តី ដូច្នេះ

ឯកទេសមេវាតិ សកអត្តភាវេ សង្ខារេ អនវសេសតោ បរិគ្គហេតុញ្ច សម្មសិតុញ្ច អសក្កោន្តំ អត្តនោ អភិនីហារសមុ- ទាគតញាណពលានុរូបំ ឯកទេសមេវ បរិគ្គហេត្វា សម្មសន្តោ[១៨] ។

"ពាក្យថា ឯកទេសមេវ ( ត្រឹមចំណែកខ្លះ ) មានសេចក្តីថា ព្រះថេរៈបានកំណត់ដឹងឃើញត្រឹមចំណែកខ្លះ ដែលខ្លួនមិនអាច កំណត់ដឹង និងឃើញសង្ខារធម៌ក្នុងអត្តភាពរបស់ខ្លួនដោយពិត ប្រាកដតាមកម្លាំងបញ្ញា ដែលបានសន្សំមក" ។

តស្មា សសន្តានគតេ សព្វធម្មេ, បរសន្តានគតេ ច តេសំ សន្តានវិភាគំ អកត្វា ពហិទ្ធាភាវសាមញ្ញតោ សម្មសតិ ។ អយំ

សាវកានំ សម្មសនចារោ[១៩] ។

"ដូច្នោះ ព្រះថេរៈទើបឃើញធម៌ទាំងពួកដែលប្រព្រឹត្តទៅក្នុងក្រសែរូបនាមរបស់ខ្លួន និងឃើញធម៌ដែលប្រព្រឹត្តទៅក្នុងក្រសែរូបនាមរបស់អ្នកដទៃ ដោយសភាពជាធម៌ខាងក្រៅទូទៅ មិនបានធ្វើការចែកក្រសែរូបនាមរបស់បុគ្គលពួកនោះ វិធីនេះ ជាវិធីឃើញនៃសាវកទាំងឡាយ" ។

ដោយហេតុនេះ អ្នកបដិបត្តិទើបមិនគួរស្វែងរក ឬកំណត់ដឹងអារម្មណ៍ខាងក្រៅដូចជា សំឡេងដោយមិនទាក់ចិត្ត ចំពោះសភាវៈបានឮ ដែលជាអារម្មណ៍ខាងក្នុង ព្រោះនឹងធ្វើឲ្យចិត្តរវើរវាយរាយមាយ បណ្តាលឲ្យសមាធិ និងបញ្ញាមិនចំរើនឡើង សូម្បីនឹងបដិបត្តិជាប់តគ្នា ១៥ ថ្ងៃ ឬមួយខែ ក៏មិនអាចជួបការឈានទៅមុខនិងអ្នកដែលមិនកំណត់ដឹងសភាវធម៌បច្ចុប្បន្ន តែបែរត្រឡប់ទៅពិចារណាថាជារូបឬនាម តាមដែលខ្លួនធ្លាប់សិក្សាមក ក៏មិនត្រឹមត្រូវទេ ព្រោះជាការនឹកគិតដោយសញ្ញា មិនមែនជាការចម្រើនសតិរលឹកដឹងយ៉ាងពិតប្រាកដ ដូចនោះ អ្នកបដិបត្តិទើបគួរកំណត់ដឹង

អារម្មណ៍ខាងក្នុងជាគោល និងអាចកំណត់អារម្មណ៍ខាងក្រៅ ដែលមកប្រាកដឯងផ្លូវទ្វារទាំង ៦ បានដូចគ្នា ដូចគម្ពីរវិសុទ្ធិមគ្គមហាដីកាពោលថា

**អជ្ឈត្តំ វា ហិ វិបស្សនាភិនិវេសោ ហោតុ ពហិទ្ធា វា ។ អជ្ឈត្តសិទ្ធិយំ បន លក្ខណតោ សព្វម្បិ នាមរូបំ អនវសេសតោ បរិគ្គហិតមេវ ហោតិ[២០] ។**

“ការចម្រើនវិបស្សនា អាចមានបានទាំងខាងក្នុង ឬខាងក្រៅ តែកាលការកំណត់ដឹងសម្រេចខាងក្នុង ក៏ជាការដែលកំណត់ដឹងរូបនាមទាំងអស់ដោយលក្ខណៈ ដែលជាសភាវលក្ខណៈ និងសាមញ្ញលក្ខណៈ ដោយច្បាស់លាស់” ។

## ការកំណត់ដឹងទាន់បច្ចុប្បន្ន

អ្នកបដិបត្តិធម៌កំណត់ដឹងសភាវធម៌បច្ចុបម្បន្ន ដែលចែកជាខណៈបច្ចុប្បន្ន គឺបច្ចុប្បន្នក្នុងខណៈមួយៗ ដែលកំពុងកើតឡើង សន្តតិបច្ចុប្បន្ន គឺបច្ចុប្បន្នជាប់តគ្នាពីអតីតដែលទើបតែរលត់ទៅ

និងអទ្ធាបច្ចុប្បន្ន គឺបច្ចុប្បន្នដោយរយៈកាលរហូតអស់មួយជីវិត កាលការកំណត់ដឹងបច្ចុប្បន្នមានកម្លាំងចាស់ក្លាហើយ អ្នកបដិបត្តិ នឹងអាចអនុមានដឹងរូបធម៌ ដែលជាអតីតៈ និងអនាគតបានផង ជាការពិតហើយ អតីតជាវត្ថុដែលកន្លងមកហើយ អនាគតក៏នៅមិន ទាន់កើតឡើង យើងមិនអាចទទួលដឹងសភាវធម៌ក្នុងអតីតឬអនាគត បានជាក់ច្បាស់ទេ សាកពិចារណាថា យើងអាចទទួលដឹងវត្ថុ ដែល ធ្លាប់ជួបមកក្នុងកពមុនដែរឬទេ រូបធម៌និងនាមធម៌របស់យើង មាន សភាវៈយ៉ាងណា គឺសម្បុរកាយពណ៌ខ្មៅ ឬស មានចក្ខុបសាទ ជាដើមគ្រប់គ្រាន់ ឬមិនមានឥត្ថីភាវរូប ឬបុរិសភាវរូប, មានចិត្ត និងចេតសិកប្រភេទណាកើតឡើង ឬមានចិត្តប្រភេទណាកើតបន្ត អំពីចិត្តដួងមុន ការពោលដល់កពមុនទើបឆ្ងាយសែនឆ្ងាយ សាក ពិចារណាមើលកពនេះថា ក្នុងថ្ងៃខែឆ្នាំដែលកន្លងមកមានសភាវធម៌ រូបនាមកើតឡើងយ៉ាងណា សូម្បីរូបនាមដែលកើតកន្លងមកហើយ ១ ម៉ោង ១០ នាទី ឬ៥ នាទី ក៏មិនប្រាកដលក្ខណៈវិសេសយ៉ាង ជាក់ច្បាស់ ។

ក្រៅពីនេះ អ្នកបដិបត្តិ មិនគួរកំណត់ដឹងអនាគត ដូចជាក្នុងខណៈលើកជើងស្តាំ យើងមិនអាចដឹងសភាវៈរូបនាម ដែលនឹងកើតឡើងតទៅ ក្នុងខណៈលើកជើងឆ្វេង សូម្បីសំគាល់ថា នឹងកើតកុសលចិត្ត ក៏អាចនឹងកើតអកុសលចិត្តបាន ឬគិតថា គួរកើតសោមនស្ស ក៏អាចកើតទោមនស្សបាន មនុស្សគ្រប់គ្នាមិនអាចដឹងឃើញអនាគតបានទេ សូម្បីនឹងគិតថា ខ្លួនឯងនៅជាសុខ ក៏អាចជួបឧបត្តិហេតុផ្សេងៗ ដូចជាត្រូវអាវុធ ផ្ទះបាក់សង្កត់ ធ្លាក់អំពីទីខ្ពស់ ភ្លើងឆេះ លង់ទឹក ពស់ចឹក មុតបន្លា អ្នកខ្លះសូម្បីជិតនឹងស្លាប់ ក៏នៅសំគាល់ថា ខ្លួនមានអាយុវែង ។

ម្យ៉ាងទៀត សភាវធម៌បច្ចុប្បន្ន ជាវត្ថុដែលកំពុងកើតខាងក្នុងរាងកាយ និងប្រាកដផ្លូវទ្វារទាំង ៦ កាលចំរើនសតិកំណត់ដឹងរូបនាមបច្ចុប្បន្ន ទើបធ្វើឲ្យអ្នកបដិបត្តិអាចឃើញលក្ខណៈវិសេសនិងលក្ខណៈទូទៅយ៉ាងជាក់ច្បាស់ ប្រៀបដូចមនុស្សដែលងើបមើលផ្ទៃមេឃ កាលកើតផ្គរបន្ទោរ គេរមែងឃើញកន្លែងដែលកើតផ្គរបន្ទោរ និងរូបរាងសណ្ឋានរបស់ផ្គរបន្ទោរបានយ៉ាងជាក់

ច្បាស់ ក្នុងករណីដូចគ្នានេះ បើងើបមើលផ្ទៃមាយ កាលផ្ទៃកបន្ទោរ បាត់ទៅហើយ ឬមើលកាលនៅមិនទាន់កើតផ្ទៃកបន្ទោរ គេរមែង មិនឃើញការកើតឡើងពិតរបស់ផ្ទៃកបន្ទោរបាន,ដូចនោះ អ្នកបដិបត្តិ ទើបមិនគួរធ្វើទុកក្នុងចិត្តចំពោះអតីត ឬអនាគត គួរចម្រើនសតិ កំណត់ដឹងសភាវធម៌បច្ចុប្បន្នតាមសេចក្តីពិត ។

ក្រៅអំពីនោះទៅ កិលេសដែលហៅថា អារម្មណានុស័យ គឺ អនុស័យដែលដេកសម្ងំនៅក្នុងអារម្មណ៍រមែងកើតឡើង កាលមិន បានចំរើនសតិដឹងទាន់ តែនឹងមិនកើតឡើងក្នុងអារម្មណ៍ដែលអ្នក បដិបត្តិបានកំណត់ដឹងហើយ ការចំរើនវិបស្សនាក្នុងសភាវធម៌ បច្ចុប្បន្ន ទើបជាការលះកិលេស ដោយតទង្គប្បហាន គឺលះបាន មួយខណៈក្នុងពេលចំរើនសតិកំណត់ដឹង ទាំងនៅជាការលះកម្មវិបាក និងខន្ធដែលជាផលរបស់កិលេសតមក ( នឹងពោលដល់រឿងនេះ ដោយពិស្តារក្នុងបរិច្ឆេទទី ៧ រឿងអនិច្ចានុបស្សនា ) ជាការពិត ហើយ អារម្មណានុស័យ រមែងដេកសម្ងំក្នុងអតីតារម្មណ៍ ដែល បុគ្គលមិនបានកំណត់ដឹង សូម្បីយេនបញ្ញត្តិ គឺបញ្ញត្តិដែលសម្តែងដុំ

ក្រុម ដែលកើតជាប់បន្ទអំពីអតីតធម៌នោះ ក៏ប្រាកដក្នុងក្រសែចិត្ត ដូចថតរូបទុកគ្រប់ខណៈដែលគេរលឹកដល់អតីត ដែលបានឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ឬនឹកគិតរឿងរ៉ាវ ឃនបញ្ញត្តិ រមែងប្រាកដ ធ្វើឲ្យសំគាល់ថា ជាតួខ្លួនដែលទៀងទាត់ ជាសុខ បន្ទាប់បញ្ជាបាន សូម្បីនឹងពិចារណាតាមការដឹងដែលធ្លាប់សិក្សា មកថា មានត្រឹមរូបនាមដែលមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ក៏មិនអាចលះឃនបញ្ញត្តិ ដែលដូចរូបថតបាន នឹងមិនអាចលះកិលេសដែលប្រកាន់មកថាទៀង ជាសុខ បន្ទាប់បញ្ជាបាន ។

តួយ៉ាងដូច ឪពុកម្តាយខ្លះ បង្រៀនក្មេងឲ្យក្លាហានមិនខ្លាចខ្មោច លុះក្មេងធំឡើងក៏មិនខ្លាចខ្មោច សូម្បីឃើញខ្មោចក៏គិតថា ជារបស់ចំឡែក តែឪពុកម្តាយខ្លះ បញ្ជោរក្មេងឲ្យខ្លាចខ្មោច កាលក្មេងធំឡើង ក៏រមែងខ្លាចខ្មោច សូម្បីនឹងមិនធ្លាប់ឃើញ ក៏គិតស្រមើស្រមៃនឹងខ្លាចទៅឯង សូម្បីអ្នកដទៃប្រាប់ថា មិនត្រូវខ្លាចក៏នៅមិនបាត់ខ្លាច ព្រោះធ្លាប់សន្សំការខ្លាចមកមុន ក្នុងករណីដូចគ្នានេះ អ្នកចំរើនសតិកំណត់ដឹងរូបនាម ដោយសេចក្តីជាសភាវធម៌ មិនប្រាកដ

យនបញ្ញត្តិ ក៏មិនកើតកិលេស កាលគិតដល់រូបនាមនោះទៀត តែអ្នកដែលមិនបានចំរើនសតិកំណត់ដឹងទាន់សភាវៈបច្ចុប្បន្ន រមែងកើតកិលេសឡើង កាលនឹកគិតដល់រូបនាមដែលកន្លងមក ព្រោះយនបញ្ញត្តិបានប្រាកដ ឲ្យសំគាល់ថា ជាតួខ្លួន និងប្រកបជាមួយការប្រកាន់មាំ ដែលមាននៅមិនអាចរំដោះចេញបាន សូម្បីអនាគតអារម្មណ៍ដែលបុគ្គលមិនបានកំណត់ដឹង ក៏ជាហេតុកើតនៃអារម្មណានុស័យដូចគ្នា ។

ហេតុនេះ ការតាមដឹងសភាវធម៌បច្ចុប្បន្ន ទើបធ្វើឲ្យអ្នកបដិបត្តិកើតបញ្ញាជាក់ច្បាស់សភាវធម៌ដែលពិតប្រាកដរបស់រូបនាម នឹងអាចលះបង់កិលេសក្នុងខណៈនោះៗ សភាវធម៌បច្ចុប្បន្នទើបជាអារម្មណ៍នៃការចម្រើនសតិបំពេញវិបស្សនាភាវនា ដូចសាធកៈក្នុងគម្ពីរភទ្ទេករត្តសូត្រថា

អតីតំ នាន្វាគមេយ្យ    នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ    អប្បត្តញ្ច អនាគតំ ។
បច្ចុប្បន្នញ្ច យោ ធម្មំ    តត្ថ តត្ថ វិបស្សតិ

អសំហីរំ អសង្កុប្បំ តំ វិទ្វា មនុព្រូហយេ ។
អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។
ឯវំវិហារិមាតាបឹ អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ សន្តោ អាចិក្ខតេ មុនីតិ[២១]។

"បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចខន្ធជាអតីត មិនគប្បីប្រាថ្នានូវបញ្ចក្ខន្ធជាអនាគតទេ ព្រោះថា បញ្ចខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វានដែលមិនរសេមរសោម មិនកម្រើក ហើយគប្បីចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍នៃព្រះនិព្វាននោះ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ

មុនីអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកំដៅកិលេស ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

អតីតកាលដែលពោលដល់ក្នុងព្រះសូត្រនេះ សំដៅដល់វត្ថុដែលកន្លងមកហើយទាំងក្នុងភពមុននិងភពនេះ មិនមែនសំដៅដល់អតីតកាលក្នុងភពមុនប៉ុណ្ណោះ សេចក្ដីពិត អ្នកដែលសម្រេចអភិញ្ញាមានភ្នែកទិព្វ អាចឃើញរឿងរ៉ាវក្នុងអតីតបាន តែព្រះសូត្រនេះពោលដល់បុគ្គលទូទៅ ទើបសំដៅដល់រឿងក្នុងអតីតកាល ដែលកន្លងមកហើយទាំងអស់ ។

១៩ ៥ ដែលកើតរលត់ក្នុងអតីតកាល ដូចចក្ខុបសាទ ពណ៌និងសភាវៈការឃើញជាដើម មិនមានពិតក្នុងបច្ចុប្បន្ន បុគ្គលទើបមិនគួរប្រកាន់ភ្ជាប់ដោយគិតដល់វត្ថុ ដែលរលត់ទៅហើយ ដោយតណ្ហា និងទិដ្ឋិ ការប្រកាន់ភ្ជាប់ដោយតណ្ហា គឺការគិតដល់វត្ថុដែលកន្លងមក ដោយសេចក្ដីត្រេកអរថា ចក្ខុបសាទរបស់យើងនឹងភ្លឺច្បាស់ ក្រសែភ្នែករបស់យើងមើលឃើញបានច្បាស់ កែវភ្នែក

ទឹកមុខ ចិញ្ចើម ប្រមុះ មាត់ និងសម្បុរស្បែកស្រស់ស្អាត ដល់ព្រម ដោយគ្រឿងប្រដាប់តាក់តែង កាលមុនបានធ្លាប់ឃើញមនុស្សដែល មានរូបរាងគួរសេរសើរ ។ល។ ការប្រកាន់ភ្ជាប់ដោយទិដ្ឋិ គឺការគិត ថា ខ្លួនយើងឃើញអ្នកដទៃ សភាវៈឃើញនោះស្ថិតនៅ តាំងអំពី អតីតរហូតដល់បច្ចុប្បន្ន សូម្បីអស់ជីវិតហើយវិញ្ញាណរបស់យើង ក៏ឃ្លាតពីរាងកាយនេះ ទៅកើតក្នុងភពថ្មី ដូច្នេះជាដើម ។

សូម្បីខន្ធ ៥ ដែលនឹងកើតក្នុងអនាគត ក៏មិនមានពិតក្នុង បច្ចុប្បន្ន ត្រឹមតែជាការសង្ឃឹមរបស់យើង ដូចមនុស្សទិញឆ្នោត ហើយគិតថា យើងនឹងធ្វើយ៉ាងណាទើបត្រូវរង្វាន់ អ្នកបដិបត្តិធម៌ ទើបមិនគួរសង្ឃឹមអនាគតថា សូមឲ្យចក្ខុបសាទរបស់យើង ចូរ ភ្លឺច្បាស់ ភ្នែករបស់យើងកុំស្រអាប់ឡើយ យើងចូរមានរូបរាងមុខ មាត់ស្រស់ស្អាតគួរពេចពិលរមិលមើល រហូតទៅហែរហមដោយ ពួកមិត្តដែលស្រស់ស្អាត សូមឲ្យសភាវៈឃើញចូរគង់នៅរហូតទៅ ដូចនេះជាដើម ។

គ្រប់ៗ ខណៈនៃការបដិបត្តិ អ្នកបដិបត្តិគប្បីចម្រើនសតិរលឹក

ដឹងសភាវធម៌បច្ចុប្បន្ន ក្នុងខណៈឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ដើរ ឈរ អង្គុយ ដេក បត់ លាត ដើម្បីដឹងអាការប្រាកដនៃការមិនទៀង ជាទុក្ខ មិនមែនតួខ្លួន អ្នកដែលខ្វះសតិកំណត់ដឹងទាន់ រមែងកើតតណ្ហា សេចក្ដីពេញចិត្តថា ទៀងជាសុខ បន្ទាប់បញ្ហាបាន និងស្រស់ស្អាត ទាំងកើតទិដ្ឋិដែលយល់ខុសថា ជាបុគ្គល យើង របស់យើង ចិត្តរមែងធ្លាក់ទៅក្នុងអំណាចនៃតណ្ហាទិដ្ឋិ និងរមែងកើតការត្រិះរិះ ក្នុងកាមគុណអារម្មណ៍ ( **កាមវិតក្កៈ** ) ថា បុរស ឬស្ត្រីដែលជួបនេះ មានរូបស្អាត និយាយពិរោះ ជាបុត្រធីតារបស់អ្នកនោះ ជាបិតាមាតារបស់អ្នកនេះ មានកិច្ចធុរៈយ៉ាងនេះ មាននិស្ស័យយ៉ាងនេះ ធ្វើអាកប្បកិរិយាយ៉ាងនេះ គ្រាខ្លះក៏ត្រិះរិះឡើងដោយការក្រោធ ( **ព្យាបាទវិតក្កៈ** )ថា អ្នកដែលបានជួបមុខមាត់មិនគួរមើលនិយាយមិនសុភាព និស្ស័យមិនល្អបៀតបៀនយើង ចូរកុំមានអាយុវែងឡើយ គ្រាខ្លះក៏កើតការត្រិះរិះក្នុងការបៀតបៀន ( **វិហិង្សាវិតក្កៈ** )ថា ធ្វើយ៉ាងណាឲ្យគេបានទទួលទុក្ខ តែអ្នកដែលចម្រើនសតិដឹងទាន់សភាវធម៌បច្ចុប្បន្ន រមែងមិនត្រិះរិះក្នុងកាម ក្នុងសេចក្ដីក្រោធ និងក្នុងការបៀតបៀន ដោយ

អំណាចនៃតណ្ហាទិដ្ឋិ វិបស្សនាចិត្តដែលកើតឡើងក្នុងខណៈនោះ ទើបមិនត្រូវអ្វីភពាំង និងធ្វើឲ្យវិបត្តិដោយតណ្ហាទិដ្ឋិពួកនោះ ។

ការចម្រើនវិបស្សនាដែលព្រះកច្ចាយនៈពោលដល់ក្នុងសូត្រនេះ ជាការចម្រើនសតិរលឹកដឹងរូបនាមរឿយៗ ទៅរហូតដល់សម្រេចវិបស្សនាញាណទី ១១ ដែលហៅថា សង្ខារុបេក្ខាញាណ គឺ ញាណប្រងើយ ៗ ក្នុងសង្ខារ ដែលជាញាណខ្ពស់បំផុតរបស់បុថុជ្ជនរហូតដល់អនុលោម, គោត្រភូ, មគ្គញាណ និងផលញាណ។

សួរថា : គម្ពីរវិសុទ្ធិមគ្គ[២២] នាំសេចក្ដីរបស់ព្រះកច្ចាយនៈមកពោលទុកដោយសភាពជាអទ្ធាបច្ចុប្បន្ន គឺបច្ចុប្បន្នដោយរយៈកាលរហូតមួយជីវិតមិនមែនឬ ?

ឆ្លើយថា : សេចក្ដីនេះ លោកសំដៅដល់បច្ចុប្បន្នរហូតមួយជីវិត ដែលតណ្ហាទិដ្ឋិមិនអាចភពាំង និងមិនអាចធ្វើឲ្យវិបត្តិបាន មិនបានសំដៅដល់អ្នកបដិបត្តិគួរកំណត់ដឹងអទ្ធាបច្ចុប្បន្ន ព្រោះអ្នកបដិបត្តិគួរកំណត់ដឹងទាន់សភាវៈបច្ចុប្បន្ន ក្នុងបច្ចុប្បន្នខណៈប៉ុណ្ណោះ មិនមែនកំណត់ដឹងសភាវៈ តាំងអំពីបដិសន្ធិរហូតដល់ចុតិ

នឹងឃើញបានថា ក្នុងព្រះបាលីខាងដើម មានសេចក្តីថា **តត្ថ តត្ថ** ( ក្នុងខណៈនោះ ៗ ) សូម្បីព្រះអដ្ឋកថាចារ្យ ក៏អធិប្បាយទុកថា

**តត្ថ តត្ថាតិ បច្ចុប្បន្នម្បិ ធម្មំ យត្ថ យត្ថេវ សោ ឧប្បន្នោ, តត្ថ តត្ថេវ អនិច្ចានុបស្សនាទីហិ សត្តហិ អនុបស្សនាហិ វិបស្សតិ**[២៣] ។

“ព្រះតម្រាស់ថា **តត្ថ តត្ថ** ( ក្នុងបច្ចុប្បន្នខណៈនោះៗ ) មានសេចក្តីថា សភាវធម៌បច្ចុប្បន្ននោះ កើតឡើងហើយក្នុងខណៈណាៗ អ្នកបដិបត្តិ រមែងកំណត់ដឹងធម៌ ( ខន្ធ៥ ) ដែលសូម្បីជាបច្ចុប្បន្នខណៈនោះ ៗ តែម៉្យាង ដោយការឃើញ ៧ ប្រការមានអនិច្ចានុបស្សនា ( ការឃើញសភាពមិនទៀង ) ជាដើម” ។

បិ ស័ព្ទក្នុងពាក្យថា **បច្ចុប្បន្នម្បិ** ( ដែលសូម្បីជាបច្ចុប្បន្ន ) ធ្វើនាទីសម្ភាវនា គឺលើកឡើងសម្តែងជាពិសេស មានន័យថា រូបនាមទាំងអស់ដែលកើតឡើងតាំងអំពីបដិសន្ធិរហូតដល់ចុតិ ជាអទ្ធានបច្ចុប្បន្នក៏ពិតមែន តែអ្នកបដិបត្តិមិនគួរចម្រើនសតិកំណត់ដឹងរូបនាមទាំងអស់នោះ វត្ថុដែលគួរកំណត់ដឹងមានត្រឹមតែរូបនាមក្នុងបច្ចុប្បន្នខណៈប៉ុណ្ណោះ ។

៦។ ស័ព្ទក្នុង តត្ថ តត្ថ ( ក្នុងខណៈនោះ ៗ តែម្យ៉ាង ) ធ្វើនាទីអវធារណៈ គឺហាមសេចក្តីដទៃ មានន័យថា គួរកំណត់ដឹងនូវបច្ចុប្បន្នដែលកំពុងកើតឡើងពិតៗ មិនគួរកំណត់ដឹងបច្ចុប្បន្នដែលកើតកន្លងទៅហើយ ឬនៅមិនទាន់កើតឡើង ។

ពាក្យថា **អនុបស្សនា** គឺការឃើញច្បាស់ ៧ ប្រការ ពោលគឺ ៖

១. **អនិច្ចានុបស្សនា** ការឃើញច្បាស់សភាពមិនទៀង ។

២. **ទុក្ខានុបស្សនា** ការឃើញសង្ខារទាំងពួងជាទុក្ខ ។

៣. **អនត្តានុបស្សនា** ការឃើញសង្ខារមិនមែនជារបស់ខ្លួន។

៤. **និព្វិទានុបស្សនា** ការឃើញច្បាស់ភាពនឿយណាយ ។

៥. **វិរាគានុបស្សនា** ការឃើញច្បាស់ភាពប្រាសចាកតម្រេក ។

៦. **និរោធានុបស្សនា** ការឃើញច្បាស់សភាវៈរលត់ ។

៧. **បដិនិស្សគ្គានុបស្សនា** ការឃើញច្បាស់ភាពលះបង់ចោល។

រឿងនេះនឹងប្រាកដដោយពិស្តារតទៅក្នុងបរិច្ឆេទទី ៧

សរុបសេចក្ដីថា វត្ថុដែលជាអារម្មណ៍របស់វិបស្សនាភាវនា ជាខណៈបច្ចុប្បន្ន គឺបច្ចុប្បន្នក្នុងខណៈមួយៗ ដែលកំពុងកើតឡើង និងសន្តតិបច្ចុប្បន្ន គឺបច្ចុប្បន្នបន្ទាប់អំពីអតីត ដែលផ្ដើមរលត់ទៅ មិនមែនអទ្ធាបច្ចុប្បន្ន ដែលជារយៈកាលតាំងពីបដិសន្ធិដល់ចុតិ សូម្បីក្នុងរឿងជីងចិត្តរបស់អ្នកដទៃដោយចេតោបរិយញ្ញាណ ដែលគម្ពីរអដ្ឋកថាពោលថា ជាអទ្ធាបច្ចុប្បន្ន ក៏មិនបានសំដៅដល់អទ្ធាបច្ចុប្បន្នតាំងពីបដិសន្ធិដល់ចុតិ តែសំដៅដល់បច្ចុប្បន្នដែលកំពុងកើតឡើងពិត ៗ ដែលកំណត់សំដៅដោយជវនវារៈតែម្យ៉ាង ដូចសេចក្ដីថា

អទ្ធាបច្ចុប្បន្នំ បន ជវនវារេន ទីបេតព្វន្តិ
សំយុត្តដ្ឋកថាយំ វុត្តំ ។ តំ សុដ្ឋុ វុត្តំ[២៤] ។

“ក្នុងអដ្ឋកថានៃសំយុត្តនិកាយពោលថា ចំណែកអទ្ធាបច្ចុប្បន្ន គប្បីសម្ដែងដោយជវនវារៈ ពាក្យនោះលោកពោលទុកល្អហើយ” ។

អទ្ធាបច្ចុប្បន្នំ បន ជវនវារេន ទីបេតព្វំ ។
ន សករេន បច្ចុប្បន្នទ្ធុនាតិ អធិប្បាយោ[២៥] ។

"សំដៅសេចក្តីថា ចំណែកអទ្ធាបច្ចុប្បន្ន គប្បីសម្តែងដោយជវនវារៈ មិនមែនគប្បីសម្តែងដោយរយៈកាល ដែលជាបច្ចុប្បន្នរហូតមួយជីវិត" ។

ម្យ៉ាងទៀត សូម្បីក្នុងសតិប្បដ្ឋានសូត្រ ក៏ពោលដល់បច្ចុប្បន្នដែលកំពុងកើតឡើងពិត ៗ ដូចសេចក្តីដែលប្រាកដដោយភាពជាបច្ចុប្បន្នៈពោលថា

គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ[២៦] ។

"កាលកំពុងដើរ ក៏ដឹងច្បាស់ថា កំពុងដើរ" ។

សុខំ វា វេទនំ វេទយមានោ សុខំ

វេទនំ វេទយាមីតិ បជានាតិ[២៧] ។

"កាលកំពុងសោយវេទនាដែលជាសុខ រមែងដឹងច្បាស់ថាសោយវេទនាដែលជាសុខ" ។

សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ អត្ថិ មេ

អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ[២៨] ។

“រមែងដឹងច្បាស់ដោយកាមច្ឆន្ទៈ ដែលមានទៅខាងក្នុងខ្លួនថា កាមច្ឆន្ទៈកំពុងមានដល់យើងខាងក្នុងខ្លួន” ។

នឹងឃើញថា ក្នុងរឿងនេះ មិនបានត្រាស់ទុកដោយភាពជាអតីត ឬអនាគតថា

- អ្នកដែលដើរហើយ រមែងដឹងច្បាស់ថា ដើរហើយ ។

- អ្នកដែលនឹងដើរ រមែងដឹងច្បាស់ថា នឹងដើរ ។

-អ្នកដែលសោយវេទនាដែលជាសុខហើយ រមែងដឹងច្បាស់ថា សោយវេទនាដែលជាសុខហើយ ។

- អ្នកដែលនឹងសោយវេទនាដែលជាសុខ រមែងដឹងច្បាស់ថា នឹងសោយវេទនាដែលជាសុខ ។

- រមែងដឹងច្បាស់ដល់កាមច្ឆន្ទៈ ដែលមានហើយខាងក្នុងខ្លួនថា កាមច្ឆន្ទៈមានហើយដល់យើងខាងក្នុងខ្លួន ។

- រមែងដឹងច្បាស់ដល់កាមច្ឆន្ទៈ ដែលនឹងមានខាងក្នុងខ្លួនថា កាមច្ឆន្ទៈនឹងមានដល់យើងខាងក្នុងខ្លួន ។

យ៉ាងណាក៏ដោយ មានសេចក្ដីខ្លះ ក្នុងសតិប្បដ្ឋានសូត្រមិនប្រាកដសេចក្ដីជាបច្ចុប្បន្នកាលដូចជា

សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ[២៩] ។

"រមែងដឹងច្បាស់ក្នុងចិត្តដែលមានរាគៈថា ជាចិត្តដែលមានរាគៈ" ។

សេចក្ដីដូចពោលខាងដើម ពោលទុកដោយបញ្ជាក់សេចក្ដីជាបច្ចុប្បន្នកាល ក្នុងគម្ពីរអដ្ឋកថាដូចនេះថា

យស្មឹ យស្មឹ ខណេ យំ យំ ចិត្តំ បវត្តតិ, តំ តំ សល្លក្ខេន្តោ អត្តនោ វា ចិត្តេ បរស្ស វា ចិត្តេ កាលេន វា អត្តនោ កាលេន វា បរស្ស ចិត្តេ ចិត្តានុបស្សី វិហរតិ[៣០] ។

"ចិត្តណាៗ រមែងប្រព្រឹត្តទៅក្នុងខណៈណាៗ ភិក្ខុកំណត់ចិត្តនោះៗ ក្នុងខណៈនោះៗ ឈ្មោះថា អ្នកតាមដឹងចិត្តក្នុងចិត្តរបស់ខ្លួនខ្លះ តាមដឹងចិត្តក្នុងចិត្តរបស់អ្នកដទៃខ្លះ តាមដឹងចិត្តក្នុងចិត្តរបស់ខ្លួនក្នុងគ្រាខ្លះ តាមដឹងចិត្តក្នុងចិត្តរបស់អ្នកដទៃក្នុងគ្រាខ្លះ" ។

តាមសេចក្ដីដែលពោលមកហើយនេះ ការកំណត់ចិត្តដែលកំពុងកើតឡើង ក៏គឺការតាមដឹងចិត្តនោះឯង ដូចនោះ ការកំណត់ ( **សល្លក្ខណា** ) ទើបមានន័យដូចជាមួយការតាមដឹង ( **អនុបស្សី** ) និងការធ្វើទុកក្នុងចិត្ត ( **យោនិសោមនសិការ** ) ។

មានអ្នកមិនបានសង្កេតសេចក្ដីក្នុងគម្ពីរអដ្ឋកថាខាងដើម តែឃើញថា មានការសម្ដែងអត្ថធម៌របស់ចិត្តមានរាគៈជាដើម ដែលពោលទុកក្នុងអដ្ឋកថា ទើបពោលថា ការកំណត់ដឹងចិត្តានុបស្សនាក៏គឺការចែកអត្ថធម៌របស់ចិត្តថា ចិត្តដែលមានរាគៈ គឺលោភមូលចិត្ត ៨ ដួង ចិត្តដែលប្រាសចាករាគៈ គឺ លោកិយកុសលចិត្ត និងអព្យាកតចិត្ត សេចក្ដីពិត ព្រះអដ្ឋកថាចារ្យសម្ដែងអត្ថធម៌របស់ចិត្តទាំងនោះហើយ ពោលដល់វិធីកំណត់ចិត្តានុបស្សនាក្នុងខាងក្រោយដោយប្រយោគដែលនាំមកសម្ដែងទុកខាងដើម ក្រៅពីនេះ ការចែកអត្ថធម៌របស់ចិត្ត ក៏មិនមែនការកំណត់ដឹងចិត្តក្នុងបច្ចុប្បន្នយ៉ាងពិតប្រាកដ ត្រឹមតែជានាមបញ្ញត្តិ គឺ បញ្ញត្តិសម្ដែងឈ្មោះ និងសង្ខ្យាបញ្ញត្តិ គឺ បញ្ញត្តិសម្ដែងចំនួន ។

សូម្បីក្នុងរឿងដឹងចិត្តរបស់អ្នកដទៃ ដោយចេតោបរិយញ្ញាណ ក៏មានសេចក្តីក្នុងព្រះបាលី និងអដ្ឋកថាដូចចិត្តានុបស្សនា បើការចែកចំនួនធម៌របស់ចិត្តតាមមតិ ដែលពោលដល់ខាងដើមនោះត្រឹមត្រូវ អ្នកដែលចែកអត្ថធម៌បាន ក៏រាប់ថា សម្រេចចេតោបរិយញ្ញាណហើយ តែសេចក្តីពិត មិនមែនដូចនោះ ព្រោះអ្នកសម្រេចចេតោបរិយញ្ញាណ ត្រូវកំណត់ដឹងចិត្តរបស់អ្នកដទៃយ៉ាងពិតប្រាកដ ដូចនោះការចម្រើនសតិដឹងទាន់ចិត្តដែលមានរាគៈជាដើម ក្នុងបច្ចុប្បន្នខណៈទើបចាត់ជាចិត្តានុបស្សនា ( តទៅនឹងបានពោលដល់ការកំណត់ដឹងខណៈបច្ចុប្បន្ន ញ៉ាំងឲ្យកើតឧទយព្វយញ្ញាណ និងភង្គញាណ ដោយប្រែចក្សក្នុងបរិច្ឆេទទី ៦ ដែលពោលដល់ឧទយព្វយញ្ញាណ និងភង្គញាណ ដោយអាងសាធកៈអំពីព្រះបាលី អដ្ឋកថានិងដីកា )។

ម្យ៉ាងទៀត មានសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គថា

**យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា, យំ ទូរេ សន្តិកេ វា, សព្វំ រូបំ អនិច្ចតោ វវត្ថេតិ ។ ឯកំ សម្មសនំ[៣១] ។**

"រូបយ៉ាងណាមួយ៉ាង គឺ រូបអតីត រូបអនាគត រូបបច្ចុប្បន្ន រូបខាងក្នុង រូបខាងក្រៅ រូបគ្រោតគ្រាត រូបល្អិត រូបថោកទាប រូបប្រណីត រូបឆ្ងាយ រូបជិត អ្នកបដិបត្តិរមែងកំណត់ដឹងទាំងពួង ដោយភាពមិនទៀង សេចក្ដីនេះ ជាសម្មសនញ្ញាណមួយ៉ាង" ។

សេចក្ដីនេះ ពោលតាមលំដាប់ទេសនា ដែលប្រាកដក្នុងព្រះសូត្រ និងព្រះអភិធម្ម មិនមែនប្រាប់សម្ដែងវិធីចំរើនវិបស្សនាដោយការកំណត់ដឹងរូបអតីតជាដើម សេចក្ដីពិតហើយ សម្មសនញ្ញាណ ដែលពោលដល់ក្នុងទីនេះ ជាអនុមានវិបស្សនា គឺ វិបស្សនាដោយការអនុមាន មិនមែនបច្ចក្ខវិបស្សនា គឺ វិបស្សនាដោយជាក់ច្បាស់ សំដៅសេចក្ដីថា ការចម្រើនវិបស្សនា ជាការកំណត់ដឹងទាន់សភាវធម៌បច្ចុប្បន្ន ដែលកើតឡើងផ្លូវទ្វារទាំង ៦ យ៉ាងបន្តបន្ទាប់ ដើម្បីឲ្យទទួលដឹងសភាវលក្ខណៈគឺលក្ខណៈពិសេស និងសាមញ្ញលក្ខណៈ គឺ លក្ខណៈទូទៅរបស់សភាវធម៌នោះៗ តាមសភាពពិត ។

គប្បីសង្កេតថា លំដាប់ដែលពោលទុកខាងដើមមិនសមដល់ការបដិបត្តិពោលគឺ កាលរូបអតីតកើតឡើងហើយ ក៏ត្រូវកើតរូប

បច្ចុប្បន្នមុនរូបអនាគត មិនមែនកើតរូបអនាគតមុនរូបបច្ចុប្បន្ន បើអ្នកបដិបត្តិកំណត់រូបអតីតហើយ កំណត់រូបអនាគតបន្ទាប់អំពីរូបអតីត ក៏នឹងដាច់ការកំណត់រូបបច្ចុប្បន្នទៅ ដូចក្នុងខណៈឈានជើងស្តាំ បើអ្នកបដិបត្តិកំណត់ដឹងសភាវៈឈានជើងឆ្វេង ដែលនឹងកើតឡើងតទៅហើយ ទើបមកកំណត់សភាវៈឈានជើងស្តាំ ក៏មិនអាចដឹងទាន់បច្ចុប្បន្ន ដែលជាហេតុឲ្យកើតឧទយព្វយញ្ញាណនិងភង្គញាណបាន ដូចនោះ សេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គនេះ ទើបពោលតាមលំដាប់ទេសនា ក្នុងព្រះសូត្រនិងព្រះអភិធម្មប៉ុណ្ណោះ ។

ម្យ៉ាងទៀត ការទទួលដឹងរូបទាំងអស់ដែលជាអតីត អនាគត បច្ចុប្បន្នជាដើម លោកពោលទុកដោយភាពជាអនុមានវិបស្សនា គឺវិបស្សនា ដោយការអនុមានទាំងនេះ ព្រោះអ្នកបដិបត្តិមិនអាចទទួលដឹងរូបដូចពោលព្រមគ្នាក្នុងមួយខណៈយ៉ាងជាក់ច្បាស់បាន អនុមានវិបស្សនាជាញាណដែលប្រាកដ កាលបច្ចក្ខវិបស្សនាចាស់ក្លាហើយ ដោយកើតតាមសមគួរដល់ការស្តាប់ និងបញ្ញាបារមីដែលសន្សំទុកក្នុងបុគ្គលម្នាក់ៗ ក្នុងគម្ពីរបដិសម្ភិទាមគ្គ និងវិសុទ្ធិមគ្គ

ទើបពោលដល់សម្មសនញាណ ដែលទាំងបច្ចក្ខវិបស្សនា និងអនុ-មានវិបស្សនាទុកដោយពិស្តារ អនុមានវិបស្សនានៃសម្មសនញាណអាចកើតឡើងមុននិងក្រោយអំពីឧទយព្វយញ្ញាណ និងភង្គញាណទៀតផង សេចក្ដីនេះ នឹងពោលដល់ក្នុងឱកាសតទៅ ។

អនុមានវិបស្សនានោះ មិនមែនការឃើញរូបនាមតែម្យ៉ាង តែជាការទទួលដឹងរូបនាមទាំងអស់ក្នុងខណៈជាមួយគ្នា ទើបហៅថាកលាបសម្មសនៈ គឺ ការពិចារណាដោយក្រុម, នយវិបស្សនា គឺការឃើញដោយន័យ, នយទស្សនៈ គឺ ការសម្ដែងដោយន័យ និងនយមនសិការៈ គឺ ការធ្វើទុកក្នុងចិត្តដោយន័យ ដូចសាធកៈក្នុងគម្ពីរអដ្ឋកថាថា

**តត្ថ ឯកសង្ខារស្សបិ អនិច្ចតាយ ទិដ្ឋាយ សព្វេ សង្ខារា អនិច្ចាតិ អវសេសេសុ នយតោ មនសិការោ ហោតិ**[៣២] ។

"ក្នុងសេចក្ដីនោះ កាលដឹងការមិនទៀងសូម្បីរបស់សង្ខារតែម្យ៉ាង ការធ្វើទុកក្នុងចិត្តដោយន័យ រមែងមានក្នុងសង្ខារដ៏សេសថា សង្ខារទាំងពួងមិនទៀង" ។

សព្វេ សង្ខារគតិអាទិវចនំ នយតោ ទស្សនំ សន្ធាយ វុត្តំ ។ ន ឯកក្ខណេ អារម្មណតោ[៣៣] ។

"ព្រះតម្រាស់ថា សព្វេ សង្ខារ ( សង្ខារទាំងពួង )ជាដើម ពោលទុកដោយបញ្ជាក់ដល់ការសម្ដែងដោយន័យ មិនបានពោលទុកដោយភាពជាអារម្មណ៍ក្នុងខណៈជាមួយគ្នា" ។

បិ ស័ព្ទក្នុងពាក្យថា ឯកសង្ខារស្សបិ ( សូម្បីរបស់សង្ខារតែម្យ៉ាង ) ធ្វើនាទី គរហា គឺត្រិះរិះ មានន័យថា សូម្បីឃើញភាពមិនទៀងរបស់សង្ខារតែម្យ៉ាង ក៏ឃើញថាសង្ខារទាំងពួង ទើបមិនចាំបាច់ត្រូវពោលដល់ការឃើញភាពមិនទៀងរបស់សង្ខារច្រើន ៗ នោះ ដោយបញ្ជាក់ការឃើញថា សង្ខារទាំងពួងមិនទៀងជាពិតប្រាកដ ។

ពាក្យថា អនិច្ចតាយ ទិដ្ឋាយ ( កាលឃើញភាពមិនទៀង ) សម្ដែងដល់ការឃើញដោយជាក់ច្បាស់ដោយបច្ចក្ខវិបស្សនា ។

ពាក្យថា អវសេសេសុ នយតោ មនសិការោ ហោតិ ( ការធ្វើទុកក្នុងចិត្តដោយន័យ រមែងមានក្នុងសង្ខារដ៏សេសថា សង្ខារ

ទាំងពួងមិនទៀង ) សម្តែងដល់ការអនុមានដឹង ដោយអនុមានវិបស្សនា ។

ពាក្យថា **នយតោ ទស្សនំ សន្ធាយ វុត្តំ** ( ពោលទុកដោយបញ្ជាក់ដល់ការសំដែងដោយន័យ ) មានន័យថា ព្រះតម្រាស់ថា **សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ** ( កាលណាមែនឃើញដោយបញ្ញាថា សង្ខារទាំងពួងមិនទៀង ) **សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ** ( កាលណាមែនឃើញដោយបញ្ញាថា សង្ខារទាំងពួងជាទុក្ខ ) **សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ** ( កាលណាមែនឃើញដោយបញ្ញាថា ធម៌ទាំងពួងមិនមែនតួខ្លួន ) សំដៅដល់ការឃើញសង្ខារយ៉ាងណាម្យ៉ាងថា មិនទៀងដោយជាក់ច្បាស់ ហើយអនុមានដឹងសង្ខារទាំងពួងថា មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ។

នឹងឃើញបានថា អនុមានវិបស្សនាមិនបានកើតឡើងក្នុងខាងដើមនៃការបដិបត្តិ តែនឹងកើតបានកាលបច្ចក្ខវិបស្សនាមានកម្លាំងចាស់ក្លាហើយដោយការឃើញសង្ខារតែមួយ ឬ ច្រើនយ៉ាងថាមិន

ទៀត ដោយកើតរលត់យ៉ាងឆាប់រហ័ស សម្មសនញាណដែលជា វិបស្សនាញាណទី ៣ អាចជាអនុមានវិបស្សនាបានដូចគ្នា មិនមែន ញាណដើម ដែលនឹងគប្បីចម្រើនឲ្យកើតឡើងមុនញាណទី ១ គឺ នាមរូបបរិច្ឆេទញាណ និងញាណទី ២ គឺ បច្ចយបរិគ្គហញាណ ដោយហេតុនេះ ការអាងដល់សម្មសនញាណ ហើយពោលថា អ្នកបដិបត្តិគួរកំណត់ដឹងដល់រូបអតីតជាដើម ទើបមិនសមគួរ ។

## ការចម្រើនវិបស្សនារបស់សមថយានិក

បន្ទាប់អំពីនេះទៅ នឹងពោលដល់វិធីចម្រើនវិបស្សនាភាវនា របស់សមថយានិកបុគ្គលមុនហើយ ទើបសម្តែងវិធីបដិបត្តិសម្រាប់ វិបស្សនាយានិកដោយពិស្តារតទៅ ដោយស្របតាមមហាសតិ- បដ្ឋានសូត្រ និងព្រះសូត្រដទៃ ៗ ដែលជាប់ទាក់ទងជាមួយការ បដិបត្តិ ។

ក្នុងអង្គុត្តរនិកាយ នវកនិបាត ពោលដល់ការបដិបត្តិរបស់ សមថយានិកថា

ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ

សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ យទេវ តត្ថ ហោតិ រូបគតំ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ, តេ ធម្មេ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតិ[៣៤] ។

"ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះសាសនានេះ ស្ងាត់ហើយចាកកាមគុណ ស្ងាត់ហើយចាកអកុសលធម៌ សម្រេចបឋមឈានដែលមានវិតក្កៈ មានវិចារៈ មានបីតិ និងសុខកើតអំពីវិវេក លោករមែងឃើញធម៌ទាំងនោះ គឺរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណក្នុងខណៈកើតបឋមឈាននោះថា មិនទៀង ជាទុក្ខ ដូចរោគ ដូចបូស ដូចបន្លា មិនស្អាត ដូចរោគ ជាសភាពដទៃ[ចាកខ្លួន] នាំបំផ្លាញ សោះសូន្យ មិនមែនខ្លួន" ។

ព្រះបាលីនេះសម្តែងថា ភិក្ខុអ្នកសម្រេចបឋមឈានហើយ គួរចូលបឋមឈាន មុននឹងចម្រើនវិបស្សនា ដើម្បីឲ្យឈានជាបាទ កាលចេញអំពីឈានហើយ ទើបចម្រើនវិបស្សនាតមក សូម្បីការ

ឃើញក៏ត្រឹមការកំណត់ដឹងខន្ធ ៥ ដែលប្រាកដក្នុងបឋមឈាននោះ អ្នកដែលសម្រេចរូបឈានដទៃ ឬអរូបឈាន ក៏គួរបដិបត្តិតាមន័យនេះដូចគ្នា សូម្បីក្នុងព្រះបាលីដទៃក៏ពោលថា អ្នកសម្រេចឈានត្រូវចូលឈានមុនហើយចេញពីឈាន ក្រោយអំពីនោះ ទើបកំណត់ដឹងរូបនាម ដែលប្រាកដក្នុងឈាននោះ ៗ ដោយមិនមានព្រះបាលីដែលពោលដល់ការពិចារណារូបនាមតាមដែលបានសិក្សាមកអំពីគម្ពីរឡើយ ។

លោកអ្នកខ្លះអាងព្រះតម្រាស់ថា អនិច្ចតោ ( ថាមិនទៀង ) ទើបសំគាល់ថា ក្នុងទីនេះ ពោលដល់ការឃើញភាពមិនទៀង ( **អនិច្ចានុបស្សនា** )ជាដើម ដោយសម្មសនញ្ញាណជាដើមទៅដូច្នោះ ទើបអាចពិចារណារូបនាមដោយនាមរូបបរិច្ឆេទញ្ញាណ និងបច្ចយបរិគ្គហញ្ញាណ សេចក្ដីនេះមិនត្រឹមត្រូវ ព្រោះលោកពោលដល់វត្ថុដែលជាគោល សំគាល់ដោយត្រង់ និងរូមវត្ថុដែលមិនសំគាល់ចូលក្នុងសេចក្ដីដទៃទៀតផង ដូចដែលបានពោលទុកហើយក្នុងបរិច្ឆេទទី ២ មានសាធកៈជាប់ទាក់ទងរឿងនេះ ក្នុងគម្ពីរវិសុទ្ធិ-

មគ្គថា

នាមរូបានំ យាថាវទស្សនំ ទិដ្ឋិវិសុទ្ធិ នាម ។ តំ សម្បាទេតុ-កាមេន សមថយានិកេន តាវ ឋបេត្វា នេវសញ្ញានាសញ្ញាយតនំ អវសេសរូបារូបាវចរជ្ឈានានំ អញ្ញតរតោ វុដ្ឋាយ វិតក្កាទីនិ ឈានង្គានិ តំ សម្បយុត្តកា ច ធម្មា លក្ខណរសាទិវសេន បរិគ្គហេតព្វា[៣៤] ។

"ការឃើញរូបនាមតាមសេចក្ដីពិតឈ្មោះថា ទិដ្ឋិវិសុទ្ធិ ( ភាពហ្មត់ចត់នៃការឃើញ ) អ្នកបដិបត្តិផ្នែកសមថយានិក ត្រូវការឲ្យសម្រេចទិដ្ឋិវិសុទ្ធិនោះ គប្បីកំណត់អង្គឈាន មានវិតក្កៈជាដើម និងធម៌[មានផស្សៈ សញ្ញា ចេតនា ចិត្តជាដើម] ដែលប្រកបជាមួយអង្គឈាននោះ ដោយប្រភេទនៃលក្ខណៈ និងនាទីជាដើម កាលចេញអំពីរូបឈាន ឬ អរូបឈានយ៉ាងណាមួយ៉ាង ហើយវៀរនេវសញ្ញានាសញ្ញាយតនឈាន" ។

ពាក្យថា លក្ខណរសាទិវសេន ( ដោយប្រភេទនៃលក្ខណៈនិងនាទីជាដើម ) នោះ មានន័យថា ការកំណត់ដឹងអង្គឈាន និង

សម្បយុត្តធម៌ គឺចិត្តព្រមដោយចេតសិក គឺការកំណត់ សភាវ-លក្ខណៈ ដែលជាលក្ខណៈពិសេសរបស់ធម៌នោះៗ និងនាទីជាដើម មិនមែនការទទួលដឹងឈ្មោះ រូបរាង សណ្ឋាន ឬចំនួន ។

ក្នុងគម្ពីរដីកា[៣៦]ពោលថា លោកវៀរនេវសញ្ញានាសញ្ញាយតនៈទុក ព្រោះអ្នកដែលផ្តើមបដិបត្តិមិនអាចកំណត់ដឹងនេវសញ្ញានាស-ញ្ញាយតនៈបាន បន្ទាប់អំពីមានសញ្ញាល្អិត ក្រៅពីនេះ ហេតុដែលព្រះបាលីមិនសម្តែងដល់ការកំណត់រូបកាលចេញអំពីឈានហើយ ក៏ព្រោះថា នាមធម៌ដែលជាឈានចិត្តុប្បាទ រមែងប្រាកដជាក់ច្បាស់ដល់សមថយានិក ព្រះអង្គទើបត្រាស់បង្រៀនឲ្យកំណត់ដឹងនាមធម៌មុនរូបធម៌ តែបើរូបធម៌ប្រាកដច្បាស់ក្នុងខណៈខ្លះ ក៏អាចកំណត់ដឹងរូបធម៌បានដូចគ្នា ព្រោះព្រះបាលីខាងដើមជាសំនួនភាសាដែលពោលដល់វត្ថុដែលកើតឡើងជាចំណែកធំដែលហៅថា **យេភុយ្យន័យ** ឬជាសំនួនដែលពោលដល់វត្ថុដែលជាប្រធាន ដែលហៅថា **បធានន័យ** ឬព្រោះអ្នកបដិបត្តិមិនអាចកំណត់រូបធម៌ និងនាមធម៌ព្រមគ្នាបាន ទើបទ្រង់លះរូបធម៌ទុកក្នុងភាសានោះ តែទ្រង់បានសម្តែងការ

កំណត់ដឹងបាទយរូប ដែលជាទីអាស្រ័យរបស់ឈានក្នុងពាក្យនិយាយតមក ដូចមានសាធក:ថា

*អរូបេ វិបស្សនាភិនិវេសោ យេភុយ្យេន សមថយានិកស្ស ហោតិ*[៣៧] ។

"ការចម្រើនវិបស្សនាក្នុងនាមធម៌ រមែងមានដល់សមថយានិកជាចំណែកធំ" ។

*ឈានង្គានិ បរិគ្គណ្ហាតិ អរូបមុខេន វិបស្សនំ អភិនិវិសន្តោ*[៣៨]។

-- "អ្នកដែលចំរើនវិបស្សនាដោយមាននាមធម៌ជាគោល រមែងកំណត់ដឹងអង្គឈាន" ។

ពាក្យថា *អរូបមុខេន* ( ដោយមាននាមធម៌ជាគោល ) មានន័យថា កាលកំណត់ដឹងនាមធម៌ជាគោលហើយ សូម្បីនឹងមិនកំណត់ដឹងរូបធម៌ ក៏ចាត់ថា បានកំណត់រូប និងនាមទាំងពីរយ៉ាងបានដោយបរិយាយ សូម្បីវិបស្សនាយានិកអ្នកកំណត់រូបជាគោល ក៏ចាត់ថាបានកំណត់រូបនិងនាមទាំងពីរដោយបរិយាយដូចគ្នា ។ ព្រោះរូបនាមក៏មានលក្ខណ:ទូទៅ គឺ ត្រៃលក្ខណ៍ដូចគ្នា ដូចមានសាធក:ថា

រូបេ វិបស្សនាភិនិវេសោ យេភុយ្យេន វិបស្សនាយានិកស្ស[៣៩] ។

“ការចំរើនវិបស្សនាក្នុងរូបធម៌ រមែងមានដល់វិបស្សនាយានិក ជាចំណែកធំ” ។

អស្សាសបស្សាសេ បរិគ្គណ្ហាតិ រូបមុខេន វិបស្សនំ អភិនិវិសន្តោ, យោ “អស្សាសបស្សាសកម្មិកោ”តិ វុត្តោ[៤០] ។

“អ្នកដែលចម្រើនវិបស្សនាដែលមានរូបធម៌ជាគោល ដែលហៅថា អ្នកចម្រើនខ្យល់ដង្ហើមចេញចូល រមែងកំណត់ដឹងខ្យល់ដង្ហើមចេញចូល” ។

## ការចម្រើនអានាបានៈបានទាំងសមថៈ និងវិបស្សនា

អ្នកខ្លះសំគាល់ថា ការចម្រើនវិបស្សនាត្រូវអាស្រ័យសមថៈជាបាទយ៉ាងពិតប្រាកដ ដោយត្រូវសម្រេចឈានមុនហើយ ទើបមកចម្រើនវិបស្សនាបាន ដោយអាងសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គដែលពោលដល់ការចម្រើនអានាបានៈបែបសមថៈ[៤១] និងអាងសាធកៈអំពីព្រះបាលីថា

សោ ឈានា វុដ្ឋហិត្វា អស្សាសបស្សាសេ វា បរិគ្គណ្ហាតិ ឈានង្គានិ វា[៤២] ។

"ភិក្ខុនោះចេញអំពីឈាននោះហើយ រមែងកំណត់ដឹងខ្យល់ដង្ហើមចេញចូលឬអង្គឈាន" ។

ពិតហើយ សេចក្ដីខាងដើមពោលបញ្ជាក់ដល់បុគ្គលអ្នកសំរេចឈានដោយការចម្រើនអានាបានសតិ ហើយចម្រើនវិបស្សនាដោយការកំណត់ដឹងខ្យល់ដង្ហើមចេញចូល ឬអង្គឈាន មិនបានប្រាថ្នាសម្ដែងថា មិនសម្រេចឈានក៏ចម្រើនវិបស្សនាមិនបាន ព្រោះធម៌ដែលជាកាមាវចរ គួរជាអារម្មណ៍របស់សមថយានិក និងវិបស្សនាយានិកទាំងពីរចំពូក តែបុគ្គលទាំងពីរនេះមានវិធីបដិបត្តិផ្សេងគ្នាពោល គឺ សមថយានិកកំណត់ដឹងសណ្ឋានវែងខ្លីរបស់ខ្យល់ដង្ហើមចេញចូល ដែលចាត់ជាបញ្ញត្តិ ចំណែកវិបស្សនាយានិកកំណត់ដឹងសភាវៈធ្វើចលនារបស់ខ្យល់ដង្ហើមដែលប៉ះខ្ទប់ច្រមុះ ទើបចាត់ជាផោដ្ឋព្វារម្មណ៍ ដែលជាការប៉ះខ្ទប់រវាងវាយោធាតុជាមួយចុងច្រមុះឬបបូរមាត់ខាងលើ ដោយផោដ្ឋព្វារម្មណ៍ រាប់បញ្ចូលក្នុងពួក

ធម្មានុបស្សនា មានសាធកៈក្នុងរឿងនេះពីព្រះបាលីនិងអដ្ឋកថាថា

កាយេសុ កាយញ្ញតរាហំ ភិក្ខវេ ឯវំ

វទាមិ, យទិទំ អស្សាសបស្សាសា[៤៣] ។

"ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ខ្យល់ដង្ហើមចេញចូលជាគំនររូបម្យ៉ាង [វាយោធាតុ] ក្នុងគំនររូបទាំងឡាយ" ។

កាយញ្ញតរន្តិ បឋវីកាយាទីសុ ចតូសុ កាយេសុ អញ្ញតរំ វទាមិ ។ វាយោកាយំ វទាមីតិ អត្ថោ ។ អថ វា ចក្ខាយតនំ ។បេ។ កពឡីការោ អាហារោតិ បញ្ចវីសតិ រូបកោដ្ឋាសា រូបកាយោ នាម, តេសុ អានាបានំ ផោដ្ឋព្វាយតនេ សង្គហិតត្តា កាយញ្ញតរំ ហោតិ ។ តស្មាបិ ឯវមាហ[៤៤] ។

"ពាក្យថា កាយញ្ញតរំ ( គំនររូបម្យ៉ាង ) មានន័យតាមដែលយើងពោលថា ជាគំនររូបម្យ៉ាងក្នុងគំនររូប ៤ កង មានកងបឋវីធាតុជាដើមពោលគឺ ជាគំនរវាយោ ម្យ៉ាងទៀត គំនររូប ២៥ ប្រការគឺ ចក្ខាយតនៈ ។ល។ កពឡីការាហារ ឈ្មោះថា គំនររូបក្នុងបណ្ដាគំនររូបទាំងនោះ ខ្យល់ដង្ហើមចេញចូលគឺជាគំនររូបម្យ៉ាង

ព្រោះរាប់ចូលក្នុងផោដ្ឋព្វាយតនៈ ដូចនោះ ទើបត្រាស់ទុកយ៉ាងនេះ” ។

លោកអធិប្បាយថា ខ្យល់ដង្ហើមចេញចូល ជាគំនររូប គឺ វាយោធាតុ ក្នុងធាតុទាំង ៤ បានដល់ បឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោធាតុ ឬជាគំនររូបគឺ វាយោធាតុ ដែលរាប់ក្នុងផោដ្ឋព្វាយតនៈ ក្នុងរូប ២៥ ប្រការ មានចក្ខាយតនៈជាដើម ( រូប២៥ ប្រការនេះជួបដោយត្រង់ក្នុងគម្ពីរធម្មសង្គណី[៤៥] និងពោលទុកក្នុងអដ្ឋកថារបស់មហាគោបាលសូត្រក្នុង មូលបណ្ណាសកៈ[៤៦] និងគោលបាលសូត្រក្នុងអង្គុត្តរនិកាយ)[៤៧]។

ពិតប្រាកដហើយ ការតាមដឹងខ្យល់ដង្ហើមចេញចូល ពោលទុកក្នុងមហាសតិប្បដ្ឋានសូត្រដោយបញ្ជាក់វិបស្សនាជាគោល នឹងឃើញបានថា ការពោលដល់សេចក្តីកើតរលត់របស់ខ្យល់ដង្ហើម នឹងមិនពាក់ពន្ធដោយតណ្ហាទិដ្ឋិ ព្រមទាំងការមិនប្រកាន់មាំវត្ថុណាមួយក្នុងលោក ដែលជាវិស័យរបស់វិបស្សនាម្យ៉ាង សូម្បីក្នុងគម្ពីរវិសុទ្ធិមគ្គ ក៏ពោលដល់វិបស្សនាន័យនៃអានាបានៈនេះថា

វិបស្សនាយំ បន អបរិគ្គហេ បវត្តោ កាយសង្ខារោ ឱឡារិកោ, មហាភូតបរិគ្គហេ សុខុមោ។ សោបិ ឱឡារិកោ, ឧបាទាយរូបបរិគ្គហេ សុខុមោ ។ សោបិ ឱឡារិកោ, សកលរូបបរិគ្គហេ សុខុមោ ។ សោបិ ឱឡារិកោ, អរូបបរិគ្គហេ សុខុមោ ។ សោបិ ឱឡារិកោ, រូបារូបបរិគ្គហេ សុខុមោ ។ សោបិ ឱឡារិកោ, បច្ចយបរិគ្គហេ សុខុមោ ។ សោបិ ឱឡារិកោ, សប្បច្ចយនាមរូបបរិគ្គហេ សុខុមោ ។ សោបិ ឱឡារិកោ, លក្ខណារម្មណិកវិបស្សនាយ សុខុមោ ។ សោបិ ទុព្វលវិបស្សនាយ ឱឡារិកោ, ពលវវិបស្ស-នាយ សុខុមោ[៤៨] ។

“ចំណែកក្នុងផ្លូវវិបស្សនា គំនរខ្យល់ដែលប្រព្រឹត្តទៅក្នុងផ្នែកដែលនៅមិនបានកំណត់ ក៏នៅគ្រោតគ្រាត ក្នុងផ្នែកដែលកំណត់ដឹងមហាភូតរូបចូលដល់ល្អិតឡើង សូម្បីគំនរខ្យល់ក្នុងផ្នែកដែលកំណត់ដឹងមហាភូតរូបនោះ ក៏រាប់ថា នៅគ្រោតគ្រាត តអំពីរូបដែលបានកំណត់ឧបាទាយរូបទើបល្អិតឡើង គំនរខ្យល់ក្នុងផ្នែកដែលកំណត់ឧបាទាយរូបនោះ ក៏រាប់ថា នៅគ្រោតគ្រាត ដល់ផ្នែកដែល

កំណត់រូបទាំងអស់ ទើបល្អិតឡើង គំនរខ្យល់ក្នុងផ្នែកដែលកំណត់រូបទាំងអស់នោះ ក៏រាប់ថា នៅគ្រោតគ្រាត ដល់ផ្នែកដែលកំណត់ដឹងនាម ទើបល្អិតឡើង គំនរខ្យល់ក្នុងផ្នែកដែលកំណត់ដឹងនាមនោះ ក៏រាប់ថា នៅគ្រោតគ្រាត ដល់ផ្នែកដែលកំណត់ដឹងទាំងរូបទាំងនាម ទើបល្អិតឡើង សូម្បីគំនរខ្យល់ដល់ផ្នែកដែលកំណត់ដឹងទាំងរូបទាំងនាមនោះ ក៏រាប់ថា នៅគ្រោតគ្រាត ដល់ផ្នែកដែលកំណត់បច្ច័យ [របស់រូបនាម]ទើបល្អិតឡើង សូម្បីគំនរខ្យល់ក្នុងផ្នែកឃើញរូបនាមព្រមទាំងបច្ច័យនោះ ក៏រាប់ថា នៅគ្រោតគ្រាត ដល់ផ្នែកដែលជាវិបស្សនាដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ ទើបល្អិតឡើង ក្នុងវិបស្សនាមានកម្លាំងខ្សោយ ក៏រាប់ថា គ្រោតគ្រាត ដល់វិបស្សនាដែលមានកម្លាំងចាស់ក្លា ទើបទើងល្អិត"] ។

## ការតាមដឹងរូបនាមតែម្យ៉ាង

ម្យ៉ាងទៀត អ្នកបដិបត្តិមិនអាចតាមដឹងរូបធម៌ និងនាមធម៌ព្រមគ្នាបាន ព្រោះទាំងពីរយ៉ាងមានលក្ខណៈផ្សេងគ្នា ពោលគឺ រូបមានលក្ខណៈ មិនទទួលដឹងអារម្មណ៍ ចំណែកនាមមានលក្ខណៈទទួល

ដឹងអារម្មណ៍ និងចិត្តក៏ទទួលយកអារម្មណ៍តែម្យ៉ាងក្នុងខណៈតែមួយ មិនអាចទទួលដឹងរឿងពីររឿងក្នុងខណៈជាមួយគ្នាបាន ដូចមានសាធកៈថា

រូបារូបធម្មានំ អច្ចន្តវិធុរតាយ ឯកជ្ឈំ អសម្ភសិតព្វត្តា តថាសម្មសនស្ស ច ឥធ អនធិប្បេតត្តា កាលេន រូបំ សម្មសិតព្វំ ។ កាលេន អរូបន្តិ វុត្តំ[៤៩] ។

“ព្រះអដ្ឋកថាចារ្យពោលថា គួរឃើញរូបក្នុងគ្រាខ្លះ គួរឃើញនាមក្នុងគ្រាខ្លះ ព្រោះមិនអាចឃើញព្រមគ្នា ពីព្រោះរូបធម៌ស្របគ្នាជាមួយនឹងនាមធម៌ដោយពិត និងមិនប្រាថ្នាការឃើញក្នុងរឿងដែលផ្សេងគ្នា” ។

សរុបសេចក្តីថា សមថយានិកគប្បីកំណត់ដឹងអារម្មណ៍ ដែលប្រាកដច្បាស់ កាលចេញអំពីឈានហើយ ដែលបានដល់នាមធម៌គឺឈានចិត្តប្បាទក្នុងបច្ចុប្បន្នខណៈនោះ, ហទយរូបដែលជាទីតាំងរបស់ចិត្ត ឬរូបយ៉ាងណាមួយ៉ាងដែលកើតអំពីចិត្ត ចំណែកវិបស្សនាយានិក គប្បីកំណត់ដឹងរូបនាមក្នុងបច្ចុប្បន្នខណៈនោះ ៗ ត្រឹម

ផ្សេងគ្នាដែលសមថយានិកជាអ្នកសម្រេចឈាន ហើយទើបកំណត់ដឹងឈានជាដើមបាន តែវិបស្សនាយានិកមិនបានសម្រេចឈាន ទើបកំណត់រូបនាមក្នុងខណៈឃើញជាដើម ។

ក្នុងខណៈឃើញជាដើមនោះ វិបស្សនាយានិកគប្បីចំរើនសតិដឹងទាន់សភាវៈការឃើញ ដែលជាចិត្តនិងចេតសិក, រូបដែលជាទីតាំងរបស់នាមធម៌ទាំងនោះ និងពណ៌ដែលបានឃើញ សូម្បីក្នុងខណៈបានឮ ដឹងក្លិន ដឹងរស់ ដឹងផោដ្ឋព្វៈ ក៏មានន័យដូចគ្នានេះ ចំណែកក្នុងខណៈនឹកគិត គប្បីដឹងទាន់សភាវៈគិត ដែលជាចិត្តនិងចេតសិក, រូបដែលជាទីតាំងរបស់នាមធម៌ទាំងនោះ និងរូបដែលកើតអំពីចិត្តដែលកើតរាយមាយ ដោយទទួលដឹងសភាវធម៌ដែលប្រាកដច្បាស់ក្នុងខណៈនោះៗ តាមសមគួរ ដូចសេចក្ដីក្នុងគម្ពីរដីកាថា

ឯកទេសមេវាតិ សកអត្តភាវេ សង្ខារេ អនវសេសតោ បរិគ្គហេតុញ្ច សម្មសិតុញ្ច អសក្កោន្តំ អត្តនោ អភិនីហារសមុ-ទាគតញាណពលានុរូបំ ឯកទេសមេវ បរិគ្គហេត្វា សម្មសន្តោ[៥០]។

"ពាក្យថា ឯកទេសមេវ ( ត្រឹមចំណែកខ្លះ ) មានន័យថា ព្រះថេរៈកំណត់ឃើញត្រឹមចំណែកខ្លះ ដែលខ្លួនមិនអាចកំណត់ដឹង និងឃើញសង្ខារធម៌ក្នុងអត្តភាពរបស់ខ្លួនដោយមិនមានសេសសល់ តាមកម្លាំងបញ្ញាដែលបានសន្សំមក" ។

អស្សាសបស្សាសេ បរិគ្គណ្ហាតិ រូបមុខេន វិបស្សនំ អភិនិវិសន្តោ , យោ "អស្សាសបស្សាសកម្មិកោ"តិ វុត្តោ ។ ឈានង្គានិ បរិគ្គណ្ហាតិ អរូបមុខេន វិបស្សនំ អភិនិវិសន្តោ ។ ឈានង្គានិ បរិគ្គណ្ហាតិ អរូបមុខេន វិបស្សនំ អភិនិវិសន្តោ[៤១] ។

"អ្នកដែលចម្រើនវិបស្សនាដោយមានរូបធម៌ជាគោល ដែលហៅថា អ្នកចម្រើនខ្យល់ដង្ហើមចេញចូល រមែងកំណត់ដឹងខ្យល់ដង្ហើមចេញចូល ចំណែកអ្នកដែលចម្រើនវិបស្សនាដោយមាននាមធម៌ជាគោល រមែងកំណត់ដឹងអង្គឈាន" ។

សេចក្ដីពិតហើយ អ្នកបដិបត្តិមិនអាចទទួលដឹងរូបនាម ២ ឬ៣ យ៉ាង ក្នុងខណៈជាមួយគ្នាបាន ព្រោះរូបនាមតែម្យ៉ាងមានសភាវៈលក្ខណៈផ្សេងគ្នា ដូចបឋវីធាតុមានសភាវៈរឹង-ទន់ អាបោធាតុមាន

សភាវៈហូរ-ជ្រួតជ្រាប ផស្សៈមានសភាវៈប៉ះខ្ទប់អារម្មណ៍ វេទនាមានសភាវៈសោយអារម្មណ៍ និងចិត្តក្នុងមួយខណៈ ក៏ទទួលដឹងអារម្មណ៍តែម្យ៉ាង តែកាលទទួលដឹងរូប ឬនាមយ៉ាងណាម្យ៉ាងដែលប្រាកដច្បាស់ ក៏ចាត់ថា បានទទួលដឹងរូបនាមទាំងអស់ដោយបរិយាយ ព្រោះរាប់ចូលក្នុងសាមញ្ញលក្ខណៈ ដែលជាត្រៃលក្ខណ៍ដូចគ្នា ។

## រឿងការសម្រេចអរហត្តផលដោយមិនបានទទួលដឹងរូបនាមទាំងអស់

អ្នកដែលសម្រេចមគ្គផល មិនចំបាច់ត្រូវឃើញរូបនាមក្នុងលក្ខណៈជាមួយគ្នា និងមិនចាំបាច់ត្រូវឃើញរូបនាមទាំងអស់តាមដែលព្រះត្រៃបិដក និងអដ្ឋកថាពណ៌នាទុក ព្រោះមនុស្សម្នាក់ ៗ មានបារមី និងការសន្សំផ្សេងគ្នា ទើបឃើញដោយញាណដែលសមដល់ខ្លួន ដូចអ្នកមានបញ្ញាចាស់ក្លាដែលហៅថា **មន្ទបុគ្គល** រមែងសម្រេចមគ្គផលដោយការឃើញរូបនាមចំណែកខ្លះប៉ុណ្ណោះ ដូចសេចក្តីក្នុងគម្ពីរអដ្ឋកថាថា

សាវកា ហិ ចតុន្នំ ធាតូនំ ឯកទេសមេវ សម្មសិត្វា និព្វានំ បាបុណន្តិ[៥២] ។

"ដោយពិតហើយ សាវកទាំងឡាយឃើញធាតុ ៤ ត្រឹមតែចំណែកខ្លះហើយ រមែងសម្រេចព្រះនិព្វាន" ។

ក្រៅពីនេះ ក្នុងសឡាយតនសំយុត្ត[៥៣] ពោលដល់ភិក្ខុមួយរូបសួរថា បុគ្គលឃើញយ៉ាងណា បញ្ញាទើបបរិសុទ្ធសម្រេចជាព្រះអរហន្ត និង ពោលដល់ពាក្យឆ្លើយរបស់ព្រះអរហន្ត ៤ រូបដែលពោលដល់ការបដិបត្តិ របស់ខ្លួនទុកផ្សេងគ្នាតាមលំដាប់ថា

យតោ ខោ អាវុសោ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ, ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតិ[៥៤] ។

"លោកអ្នកមានអាយុ កាលណាភិក្ខុឃើញការកើតឡើង និងរលត់ទៅរបស់អាយតនៈ [ខាងក្នុង] ដែលជាហេតុកើតនៃផស្សៈ ៦ កាលនោះ ភិក្ខុរមែងឃើញបានល្អតតខ្ពះ ដោយការដឹងត្រឹមប៉ុណ្ណោះ" ។

យតោ ខោ អាវុសោ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ, ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតិ[៥៥] ។

“លោកអ្នកមានអាយុ កាលណា ភិក្ខុឃើញការកើតឡើង និងរលត់ទៅរបស់ឧបាទានក្ខន្ធ ៥ កាលនោះ ភិក្ខុរមែងឃើញបានល្អឥតខ្ចោះដោយការដឹងត្រឹមប៉ុណ្ណោះ” ។

យតោ ខោ អាវុសោ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ, ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតិ[៥៦] ។

“លោកអ្នកមានអាយុ កាលណា ភិក្ខុឃើញការកើតឡើង និងរលត់ទៅរបស់មហាភូតរូប ៤ កាលនោះ ភិក្ខុរមែងឃើញបានល្អឥតខ្ចោះ ដោយការដឹងត្រឹមប៉ុណ្ណោះ” ។

យតោ ខោ អាវុសោ ភិក្ខុ យំ កិញ្ចិ សមុទយធម្មំ, សព្វំ តំ និរោធធម្មន្តិ យថាភូតំ បជានាតិ, ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតិ[៥៧] ។

“លោកអ្នកដ៏មានអាយុ កាលណា ភិក្ខុដឹងថា ធម៌យ៉ាងណាមួយមានសភាពកើតឡើង ធម៌ទាំងអស់នោះមានសភាពរលត់ទៅ កាលនោះ ភិក្ខុរមែងដឹងបានល្អតខ្ទះដោយការដឹងត្រឹមប៉ុណ្ណោះ” ។

ពាក្យឆ្លើយរបស់ព្រះអរហន្តរូបដំបូង គឺ ការកំណត់ដឹងអាយតនៈខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត មិនបានកំណត់ដឹងអាយតនៈខាងក្រៅ ៦ គឺ រូប សំឡេង ក្លិន រស់ សម្ផស្ស និងធម្មារម្មណ៍ សូម្បីក្នុងអាយតនៈខាងក្នុង ក៏កំណត់ដឹងរូប ៥ យ៉ាងគឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ មិនបានកំណត់ដឹងរូបយ៉ាងដទៃ និងកំណត់ដឹងនាមធម៌ គឺ ចិត្តប៉ុណ្ណោះ មិនកំណត់ដឹងចេតសិក ការកំណត់ដឹងអាយតនៈខាងក្នុងនេះ ចាត់ជាការកំណត់អាយតនៈខាងក្រៅដោយបរិយាយ អ្នកកំណត់ដឹងបានយ៉ាងនេះ ទើបជាអ្នកចំរើនសតិដឹងទាន់រូបនាមទាំងអស់ ពិតមែនហើយ ក្នុងព្រះបាលីពោលដល់ការកំណត់ដោយសង្ខេប និងដោយពិស្ដារ តាមអធ្យាស្រ័យរបស់បុគ្គលអ្នកស្ដាប់ធម៌ក្នុងឱកាសតែមួយ មិនបានសំដៅថា ត្រូវកំណត់ដឹងរូបនាមទាំងអស់ ទើបនឹងសម្រេចធម៌បាន ។

ម្យ៉ាងទៀត ព្រះអរហន្តរូបទី ២ ពោលដល់ការកំណត់ដឹងឧបាទានក្ខន្ធ ៥, ព្រះអរហន្តរូបទី ៣ ពោលដល់ការកំណត់ដឹងមហាភូតរូប ៤, ចំណែកព្រះអរហន្តរូបទី ៤ ពោលដល់រូបនាមទាំងអស់ ពាក្យឆ្លើយព្រះអរហន្តរូបទី ៤ នេះ គ្របដណ្តប់រូបនាមទាំងអស់តាមដែលលោកបដិបត្តិ ។

តាមពិត ភិក្ខុអ្នកសួរបញ្ហាខាងដើមត្រិះរិះថា ត្រូវកំណត់ដឹងរូបនាមទាំងអស់ ទើបទីងសម្រេចធម៌ជាព្រះអរហន្តបានមែនឬទេ តែកាលបានស្តាប់ពាក្យឆ្លើយរបស់ព្រះអរហន្តទាំង ៤ រូប ដែលបែកផ្សេង ៗ គ្នា និងភិក្ខុរូបខ្លះ ក៏មិនបានកំណត់រូបនាមទាំងអស់លោកទើបសង្ស័យហើយ បានសួរបញ្ហាព្រះសម្មាសម្ពុទ្ធ ព្រះអង្គត្រាស់តបថា លោកទាំងនោះ ឆ្លើយតាមដែលខ្លួនឯងបដិបត្តិ ដូចសេចក្តីថា

**យថា យថា អធិមុត្តានំ តេសំ សប្បុរិសានំ ទស្សនំ សុវិសុទ្ធំ ហោតិ, តថា តថា ខោ តេហិ សប្បុរិសេហិ ព្យាកតំ[៥៨] ។**

"ការយល់ឃើញរបស់សប្បុរសទាំងនោះ ដែលជាអ្នកបង្អោន

ទៅដោយប្រការណា ៗ រមែងបរិសុទ្ធល្អ សប្បុរសតាំងនោះពោលឆ្លើយទុកដោយប្រការនោះៗ" ។

## ការឃើញរបស់ព្រះសារីបុត្រនិងព្រះមោគ្គល្លាន

តទៅនឹងពោលការឃើញរបស់ព្រះសារីបុត្រ ដែលប្រាកដក្នុងអនុបទសូត្រថា

សារិបុត្តោ ភិក្ខវេ អឌ្ឍមាសំ អនុបទធម្មវិបស្សនំ វិបស្សតិ ។ តត្រិទំ ភិក្ខវេ សារិបុត្តស្ស អនុបទធម្មវិបស្សនាយ ហោតិ ។ ឥធ ភិក្ខវេ សារិបុត្តោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យេ ច បឋមេ ឈានេ ធម្មា វិតក្កោ ច វិចារោ ច បីតិ ច សុខំ ច ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា ចិត្តំ ឆន្ទោ អធិមោក្ខោ វិរិយំ សតិ ឧបេក្ខា មនសិ- ការោ ។ ត្យស្ស ធម្មា អនុបទវវត្ថិតា ហោន្តិ ។ ត្យស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ ។ វិទិតា ឧបដ្ឋហន្តិ, វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ "ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ, ហុត្វា បដិ-

វេន្តិ”តិ៤៩ ។

“ម្នាលភិក្ខុទាំងឡាយ សារីបុត្រឃើញធម៌ច្បាស់តាមលំដាប់បានត្រឹមកន្លះខែ មានលំដាប់ក្នុងការឃើញធម៌ច្បាស់តាមលំដាប់នោះដូច្នេះ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនេះ សារីបុត្រស្ងាត់អំពីកាមស្ងាត់អំពីអកុសលធម៌ ចូលបឋមឈាន មានវិតក្កៈ មានវិចារៈមានបីតិ និងសុខ កើតអំពីវិវេកធម៌ក្នុងបឋមឈាន ១៦ ប្រការគឺវិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ( សភាវៈមានអារម្មណ៍តែមួយរបស់ចិត្ត, ឯកគ្គតា ) ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈអធិមោក្ខៈវិរិយៈ សតិ ឧបេក្ខា ( តត្រមជ្ឈត្តតា ) មនសិការដែលលោកកំណត់បានតាមលំដាប់ ដែលលោកដឹងច្បាស់ហើយទាំងដែលកើតឡើង តាំងនៅ និងរលត់ទៅ លោកដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនេះ មានសភាវៈពិតប្រាកដយ៉ាងនេះ មិនមានមកពីមុន ហើយរមែងកើតឡើង ហើយរមែងរលត់ទៅ” ។

ព្រះអង្គត្រាស់ដល់បដិបទារបស់ព្រះសារីបុត្រថា លោកចូលបឋមឈានមុនហើយ កំណត់ដឹងធម៌១៦ ដូចមានវិតក្កៈជាដើមដែល

ប្រាកដក្នុងឈានចិត្តុប្បាទ ធម៌ទាំងនោះ ប្រាកដការកើតឡើង តាំងនៅ និងរលត់ទៅ ដែលជាខាងដើម កណ្តាលនិងទីបំផុត លោកទើបដឹងច្បាស់ថា ធម៌ទាំងនេះមិនមានមកមុនទីងចូលបឋមឈាន តែកើតឡើងក្នុងខណៈចូលឈាននេះ ទាំងកាលកើតឡើងហើយ រមែងរលត់ទៅ លោកចូលរូបឈាន និងអរូបឈានហើយ កំណត់ដឹងធម៌ក្នុងឈានតាមន័យនេះ រហូតដល់អកិញ្ចញ្ញាយតនៈ លោកទទួលដឹងអង្គឈានខ្លះម្យ៉ាង ដែលអន្តរធានទៅ និងសទ្ធាជាដើម បង្កើនឲ្យច្រើនឡើងក្នុងឈានជាន់ខ្ពស់ឡើងតាមលំដាប់ កាលបដិបត្តិយ៉ាងនេះគ្រប់ ១៥ ថ្ងៃ ក៏សម្រេចធម៌ជាព្រះអរហន្ត ការបដិបត្តិតាមន័យនេះ ឈ្មោះថា **អនុបទធម្មវិបស្សនា ។**

**អនុបទធម្មវិបស្សនា** គឺការឃើញធម៌តាមលំដាប់សមាបត្តិ និងអង្គឈាន មានន័យថា ការចូលឈានតាមលំដាប់សមាបត្តិ ហើយចេញអំពីឈានមួយៗ ហើយទើបកំណត់ដឹងអង្គឈានព្រមដោយផស្សៈជាដើម ដែលកើតរួមជាមួយអង្គឈាន ដូចក្នុងគម្ពីរអដ្ឋកថាពោលថា

អនុបទធម្មវិបស្សនន្តិ សមាបត្តិវសេន វា ឈានង្គវសេន វា អនុបដិបាដិយា ធម្មវិបស្សនំ វិបស្សតិ[៦០] ។

"ពាក្យថា អនុធម្មវិបស្សនំ ( ការឃើញធម៌តាមលំដាប់ ) មានន័យថា រមែងឃើញធម៌តាមលំដាប់សមាបត្តិនិងអង្គឈាន" ។

ក្នុងរឿងនេះ ព្រះសារីបុត្រមិនបានចូលឈានណាមួយហើយកំណត់ដឹងធម៌ ១៦ យ៉ាងនោះតាមលំដាប់ តែលោកចូលឈានមួយៗ ហើយចេញអំពីឈាន ហើយទើបកំណត់ដឹងធម៌ដូចពោលម្តងមួយគ្រាៗ គ្រប់ ១៦ គ្រា ក្រោយចេញពីឈានមួយៗ ពោលគឺ លោកចូលបឋមឈាន ចេញពីបឋមឈានហើយកំណត់ដឹងវិតក្កៈ តមកចូលបឋមឈានជាលើកទី២ ហើយចេញពីបឋមឈានកំណត់ដឹងវិចារៈដូចនេះជាដើម សេចក្តីនេះ ជ្រាប់បានអំពីគម្ពីរបដិ-សម្ភិទាមគ្គ[៦១] ដែលពោលដល់ការកំណត់ដឹងសភាវៈអារម្មណ៍មួយលើក ៗ ដែលរលត់ទៅហើយទើបកំណត់ដឹង ចិត្តដែលទទួលដឹងអារម្មណ៍ខាងដើម និងក្នុងគម្ពីរវិសុទ្ធិមគ្គ[៦២] ក៏ពោលដល់ការកំណត់ដឹងចិត្តម្តងមួយគ្រាៗថា គប្បីកំណត់ដឹងចិត្តដួងដំបូងដោយចិត្តដួង

ទី ២ កំណត់ដឹងចិត្តដួងទី ២ ដោយចិត្តដួងទី ៣ ដូច្នេះជាដើម ។

ពិតហើយ ព្រះសារីបុត្រមានបញ្ញាច្រើនជាងសាវ័កដទៃ ទើបចំរើនវិបស្សនាដោយការកំណត់ដឹងដោយពិស្តារតាមដែលពោលមកនេះ ធ្វើឲ្យប្រើពេលក្នុងការបដិបត្តិយូរជាងព្រះមោគ្គល្លាន ដែលសម្រេចធម៌ខាងក្នុង ៧ ថ្ងៃ ការចម្រើនវិបស្សនារបស់ព្រះមហាមោគ្គល្លាន ជាការកំណត់ដឹងមិនពិស្តារ បញ្ចូនផលឲ្យសម្រេចធម៌ឆាប់ ដូចសេចក្តីក្នុងគម្ពីរអដ្ឋកថាថា

មហាមោគ្គល្លានត្ថេរោ ហិ សាវកានំ សម្មសនចារំ យដ្ឋិកោដិយា ឧប្បីឡេន្តោ វិយ ឯកទេសមេវ សម្មសន្តោ សត្តទិវសេ វាយមិត្វា អរហត្តំ បត្តោ ។ សារិបុត្តត្ថេរោ ឋបេត្វា ពុទ្ធានំ បច្ចេកពុទ្ធានញ្ច សម្មសនចារំ សាវកានំ សម្មសនចារំ និប្បទេសំ សម្មសិ ។ ឯវំ សម្មសន្តោ អឌ្ឍមាសំ វាយមិត្វា អរហត្តញ្ច កិរ បត្វា អញ្ញាសិ “ឋបេត្វា ពុទ្ធេ ច បច្ចេកពុទ្ធេ ច អញ្ញោ សាវកោ នាម បញ្ញាយ មយា បត្តព្វំ បត្តុំ សមត្ថោ ន ភវិស្សតី”តិ[៦៣] ។

“សេចក្តីពិស្តារថា ព្រះមហាមោគ្គល្លានត្ថេរកំណត់ដឹងអារម្មណ៍

នៃការកំណត់របស់សាវកត្រឹមចំណែកខ្លះ ដូចប្រើចុងឈើច្រត់ទ្រុក ខិតខំព្យាយាមរហូត ៧ថ្ងៃ ទើបសម្រេចអរហត្តផល តែព្រះសារីបុត្រ កំណត់ដឹងអារម្មណ៍នៃការកំណត់របស់សាវកដោយមិនមានសេស សល់ លើកលែងតែអារម្មណ៍នៃការកំណត់របស់ព្រះសម្មាសម្ពុទ្ធ និងព្រះបច្ចេកពុទ្ធ កាលព្រះសារីបុត្រកំណត់ដឹងយ៉ាងនេះ ខិតខំ ព្យាយាមរហូតកន្លះខែហើយ ទើបសម្រេចអរហត្តផល រួចហើយ បានត្រិះរិះថា ( ធម្មតាហើយសាវកដទៃរៀរលែងតែព្រះសម្មាសម្ពុទ្ធ និងព្រះបច្ចេកពុទ្ធ អ្នកដែលអាចសម្រេចធម៌ដូចយើង គប្បីសម្រេច ដោយបញ្ញាទីងមិនមាន )" ។

ពាក្យថា សម្មសនចារ ( អារម្មណ៍របស់ការកំណត់ ) សំដៅ ដល់ធម៌ខាងក្នុងដែលហៅថា អជ្ឈត្តធម៌ ដែលសាវកទទួលដឹង ដោយជាក់ច្បាស់ និងធម៌ខាងក្រៅដែលហៅថា ពហិទ្ធធម៌ ដែល សាវកទទួលដឹងដោយអនុមាន ។

ពាក្យថា យដ្ឋិកោដិយា ឧប្បីឡេន្តោ វិយ ( ដូចប្រើចុងឈើ ច្រត់ទ្រុក ) មានន័យថា តាមប្រក្រតីដូចប្រើចុងឈើច្រត់ទ្រ

ហើយដើរទៅទីកន្លែង ដែលឈើប្រត់ប៉ះខ្ទប់ត្រឹមតែទីចង្អៀត តែទីកន្លែងដទៃអំពីនោះរមែងទូលាយជាងយ៉ាងណា អារម្មណ៍វិបស្សនាដែលព្រះមោគ្គល្លានកំណត់ដឹងក៏មិនច្រើនយ៉ាងនោះ កាលអារម្មណ៍វិបស្សនារបស់ព្រះមហាសាវ័ករូបទី ២ ជាយ៉ាងនេះ អារម្មណ៍វិបស្សនារបស់ព្រះមហាសាវ័ករូបដទៃក៏នឹងតិចចុះ និងអារម្មណ៍វិបស្សនារបស់ព្រះអរហន្តដោយទូទៅ ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន និងបុថុជ្ជន ក៏នឹងតិចចុះទៅតាមលំដាប់ រឿងនេះអនុមានដឹងបានពីសេចក្តីនេះ សូម្បីក្នុងអដ្ឋកថារបស់មជ្ឈិមបណ្ណាសក: កណ្ណកត្ថលសូត្រ[៦៤] ក៏ពោលថា ការព្យាយាមរបស់បុថុជ្ជនជាដើមមិនស្មើគ្នានឹងសេចក្តីព្យាយាមរបស់ព្រះសោតាបន្នជាដើមតាមលំដាប់ថ្នាក់ខ្ពស់ៗ ឡើងទៅ ។

ការកំណត់ដឹងអង្គឈាននិងផស្ស:ជាដើម ដែលកើតព្រមជាមួយអង្គឈានរបស់ព្រះសារីបុត្រនោះ ជាការទទួលដឹងសភាវ:លក្ខណ: គឺ លក្ខណ:ពិសេសរបស់វិតក្ក:ជាដើមតាមសេចក្តីពិត ពោលគឺ កាលលោកកំណត់វិតក្ក: ក៏ដឹងច្បាស់ថា វិតក្ក:មានលក្ខណ:លើកចិត្តចូលទៅកាន់អារម្មណ៍ ( អភិនិរោបនលក្ខណោ

វិតក្កោ ) កាលកំណត់ដឹងវិចារៈ ក៏ដឹងច្បាស់សភាវលក្ខណៈរបស់វិចារៈ ពោលគឺ

- វិចារៈ មានលក្ខណៈស្ទាបអង្អែលនូវអារម្មណ៍ ( **អារម្មណានុមជ្ជនលក្ខណោ** ) ។

- បីតិ មានលក្ខណៈឆ្អែតក្នុងអារម្មណ៍ (**សម្បិយាយនលក្ខណា**)។

- សុខ ( សោមនស្សវេទនា ) មានលក្ខណៈសោយអារម្មណ៍ដែលគួរត្រេកអរ ( **ឥដ្ឋារម្មណានុភាវនលក្ខណា** ) ។

- ឯកគ្គតា មានលក្ខណៈផ្គងចិត្តក្នុងអារម្មណ៍តែមួយ ( **អវិក្ខេបលក្ខណា** ) ។

- ផស្សៈ មានលក្ខណៈប៉ះខ្ទប់អារម្មណ៍ ( **ផុសនលក្ខណោ** ) ។

- វេទនាមានលក្ខណៈសោយអារម្មណ៍ ( **វេទិយនលក្ខណា** )។

- សញ្ញា មានលក្ខណៈសំគាល់ដឹងអារម្មណ៍ ( **សញ្ជាននលក្ខណា** ) ។

- ចេតនា មានលក្ខណៈតាំងចិត្ត ( **ចេតនាភាវលក្ខណា** ) ។

- ចិត្តមានលក្ខណៈដឹងអារម្មណ៍ ( **អារម្មណវិជាននលក្ខណំ** ) ។

- ឆន្ទៈ មានលក្ខណៈត្រូវការនឹងធ្វើ ( **កត្តុកម្យតាលក្ខណោ** ) ។

- អធិមោក្ខមានលក្ខណៈកាត់ចិត្តសំរេច ( **សន្និដ្ឋានលក្ខណោ** ) ។

- វីរិយៈ មានលក្ខណៈខិតខំព្យាយាមគឺ ព្យាយាមក្នុងអារម្មណ៍ ( **ឧស្សាហនលក្ខណំ** ) ។

- សតិ មានលក្ខណៈរលឹកបាន គឺការមិនភ្លេចភ្លាំងអារម្មណ៍ ដែលជាប់ទាក់ទងជាមួយកុសលធម៌ ( **អបិលាបនលក្ខណា** ) ។

- មនសិការ មានលក្ខណៈធ្វើទុកក្នុងចិត្ត គឺ ការនាំចិត្តទៅកាន់អារម្មណ៍ ( **សារណលក្ខណោ** ) ។

ម្យ៉ាងទៀត ការឃើញសេចក្តីកើតឡើង តាំងនៅ និងរលត់ទៅរបស់ធម៌ទាំងនោះ សំដៅដល់ការកើតឧទយព្វយញ្ញាណ គឺ ញាណដឹងការកើតឡើងនិងរលត់ទៅ និងភង្គញាណ គឺ ញាណដឹងការរលត់ទៅដោយទទួលដឹងធម៌ទាំងនោះ ដែលជាខណៈបច្ចុប្បន្ន មិនបានសំដៅសេចក្តីថា ឈានចិត្តអាចដឹងសភាវៈកើតឡើង តាំងនៅ

និងរលត់ទៅក្នុងខណៈចូលឈាន ដូចសាធកៈក្នុងគម្ពីរអដ្ឋកថាថា

យថា ហិ តេនេវ អង្គុលគ្គេន តំ អង្គុលគ្គំ ន សក្កា ផុសិតុំ, ឯវមេវ តេនេវ ចិត្តេន តស្ស ឧប្បាទោ វា ឋិតិ វា ភង្គោ វា ន សក្កា ជានិតុន្តិ ឯវំ តាវ តំឈានតា មោចេតព្វា[៦៥] ។

"បុគ្គលមិនអាចប៉ះខ្ទប់ដោយប្រើចុងម្រាមដៃនិងចុងម្រាមដៃតែមួយជាមួយគ្នាបានយ៉ាងណា ការកើតឡើង តាំងនៅនិងរលត់ទៅរបស់ចិត្តនោះ រមែងមិនអាចទទួលដឹងដោយ[ឈាន]ចិត្តមួយដួងដូចគ្នាបានយ៉ាងនោះ ដោយហេតុនេះ ការទទួលដឹងឈានចិត្តដោយឈានចិត្តនោះ ទើបមិនមានយ៉ាងនេះ" ។

ក្នុងបណ្តាធម៌ ១៦ យ៉ាងដែលប្រាកដក្នុងព្រះបាលីនេះ សុខនិង វេទនាមានអត្ថធម៌តែមួយ គឺ ជាវេទនាចេតសិក ទើបមានចេតសិកទាំងអស់១៥ ដួង យ៉ាងណាក៏ដោយតាមគោលព្រះអភិធម្ម ចេតសិកដែលប្រកបក្នុងបឋមឈានមាន ៣៥ ដួង បើវៀរករុណានិងមុទិតាដែលកើតឡើង ក្នុងគ្រាខ្លះក៏មានចេតសិក ៣៣ ដួង កាលរួមចេតសិក ៣៣ ដួងជាមួយនឹងឈានចិត្ត ក៏ជាធម៌ ៣៤

ប្រការ តែក្នុងព្រះបាលី និងអដ្ឋកថាពោលដល់ការកំណត់ដឹងធម៌ ១៨ ប្រការប៉ុណ្ណោះ មិនបានពោលដល់ធម៌ដ៏សេស ១៩ ប្រការទៀត ក្នុងរឿងនេះ ព្រះដីកាចារ្យ[៦៦] សម្តែងមតិទុក ២ ន័យថា មតិរបស់អាចារ្យពោលថា ធម៌ ១៦ ប្រការទាំងនោះប្រាកដជាក់ច្បាស់ទើបគួរកំណត់ដឹងធម៌ដូចពោលប៉ុណ្ណោះ តែមតិរបស់អាចារ្យដទៃទៀត លោកពោលថា សូម្បីធម៌ ១៩ ប្រការដ៏សេសក៏ប្រាកដច្បាស់ដូចគ្នា ទើបគួរកំណត់ដឹងធម៌ទាំងនោះទៀតផង ។ មានអ្នកសំគាល់ថា ការចម្រើនសតិទាន់សភាវធម៌បច្ចុប្បន្ន មិនមែនការបដិបត្តិធម៌ តែឲ្យពិចារណាត្រិះរិះធម៌តាមដែលបានស្តាប់មក សេចក្តីពិតហើយ ក្នុងព្រះបាលីពោលដល់ការបដិបត្តិធម៌ដោយការចម្រើនសតិតាមដឹងរូបនាមបច្ចុប្បន្នទាំងខាងក្នុងនិងខាងក្រៅ មិនមែនការពិចារណាដោយសញ្ញាដែលចាំបានសំគាល់ដឹង ព្រោះអ្នកពិចារណារមែងមិនអាចទទួលដឹងសភាវលក្ខណៈ គឺ លក្ខណៈពិសេសរបស់រូបនាមដែលប្រាកដច្បាស់យ៉ាងពិតប្រាកដ ត្រឹមតែជាការទទួលដឹងបញ្ញត្តិ ដោយអំណាចរបស់សញ្ញាប៉ុណ្ណោះ ទើបឃើញបានថា នេវសញ្ញានាសញ្ញាយតនឈាន ជាអរូបឈានដ៏ល្អិត សូម្បីព្រះ

សារីបុត្រ ក៏មិនអាចកំណត់ដឹងផស្សៈជាដើមបាន កាលចេញអំពីឈាននេះ ទើបកំណត់ដឹងដោយកលាបសម្មសនន័យ គឺ ន័យពិចារណាជាក្រុម ដូចសេចក្ដីក្នុងអនុបទសូត្រថា

បុន ច បរំ ភិក្ខវេ សារិបុត្តោ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ, សោ តាយ សមាបត្តិយា សតោ វុដ្ឋហសិ, សោ តាយ សមាបត្តិយា សតោ វុដ្ឋហិត្វា យេ ធម្មា អតីតា និរុទ្ធា វិបរិណតា, តេ ធម្មេ សមនុបស្សតិ "ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ, ហុត្វា បដិវេន្តី" តិ[៦៧] ។

"ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៅមានទៀត សារីបុត្រកន្លងអាកិញ្ចញ្ញាយតនឈានដោយមិនមានសេសសល់ហើយ ចូលនេវសញ្ញានាសញ្ញាយតនឈាន លោកជាអ្នកមានសតិចេញអំពីសមាបត្តិនោះ រួចហើយពិចារណាឃើញធម៌ដែលកន្លងហើយ រលត់ហើយ ប្រែប្រួលទៅហើយថា ធម៌ទាំងនេះមានសភាវៈពិតប្រាកដយ៉ាងនេះ មិនមានមកពីមុន ហើយរមែងកើតឡើង កើតឡើងហើយ

រមែងរលត់ទៅ" ។

ព្រះសម្មាសម្ពុទ្ធត្រាស់ដល់ការកំណត់ដឹង ១៦ ប្រការមានផស្សៈជាដើមរបស់ព្រះសារីបុត្រក្នុងបឋមឈានជាដើម ហើយត្រាស់ការកើតឡើង តាំងនៅ និងរលត់ទៅរបស់ធម៌ទាំងនោះតែក្នុងអរូបឈានទី ៤ នេះពោលដោយទូទៅថា "ពិចារណាឃើញធម៌ដែលកន្លងហើយ រលត់ហើយ ប្រែប្រួលទៅហើយ" ដោយឃើញធម៌ដូចពោលព្រមគ្នា មិនបានឃើញម្តងមួយៗ ដូចក្នុងឈានដើម ៗ ព្រោះផស្សៈជាដើមក្នុងអរូបឈាននេះ ល្អិតល្អន់ក្រៃលែង ដូចជាចិត្តដួងខាងចុងបំផុតមុននឹងលក់ស្កប់ ចិត្តដួងខាងចុងបំផុតក្នុងខណៈសន្លប់ និងចុតិចិត្តក្នុងពេលអស់ជីវិត មានត្រឹមព្រះពុទ្ធប៉ុណ្ណោះ អាចកំណត់ដឹងបាន ដូចសេចក្តីក្នុងគម្ពីរអដ្ឋកថាថា

តេ ធម្មេ សមនុបស្សតីតិ យស្មា នេវសញ្ញានាសញ្ញាយតនេ ពុទ្ធានំយេវ អនុបទធម្មវិបស្សនា ហោតិ, ន សាវកានំ, តស្មា ឯត្ថ កលាបវិបស្សនំ ទស្សេន្តោ ឯវមាហ[៦៨] ។

"ព្រះអង្គត្រាស់ថា តេ ធម្មេ សមនុបស្សតីតិ ( ពិចារណា

ឃើញធម៌ទាំងនោះ ) មានន័យថា ការឃើញធម៌តាមលំដាប់សមាបត្តិ និងអង្គឈាន រមែងមានដល់ព្រះពុទ្ធប៉ុណ្ណោះក្នុងនេវសញ្ញានាសញ្ញាយតនៈ ដូចនោះ កាលព្រះសាស្តាទ្រង់សម្តែងការឃើញជាក្រុមក្នុងសេចក្តីនេះ ទើបត្រាស់ទុកយ៉ាងនេះ" ។

តាមសាធកៈ ដែលពោលនេះ ព្រះពុទ្ធអង្គ ក៏ទ្រង់ចម្រើនវិបស្សនាតាមលំដាប់សមាបត្តិ និងអង្គឈានដូចព្រះសារីបុត្រ តែទ្រង់ឃើញអង្គឈានម្តងមួយ ៗ ក្នុងនេវសញ្ញានាសញ្ញាយតនៈដោយល្អិត ដូចនោះ ការបដិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា ទើបមិនមែនការរិះគិតតាមសញ្ញា ដែលចាំបាន សំគាល់ដឹង តែជាការអប់រំចិត្តឲ្យកើតសមាធិ ដើម្បីចម្រើនវិបស្សនាយ៉ាងពិតប្រាកដ ។ ដើម្បីឲ្យអ្នកបដិបត្តិយល់វិបស្សនាន័យដូចពោលមកនេះ ហើយប្រព្រឹត្តតាមពាក្យណែនាំក្នុងសល្លេខសូត្រថា

បរេ សន្ទិដ្ឋិបរាមាសី អាធានគ្គាហី ទុប្បដិនិស្សគ្គី ភវិស្សន្តិ។ មយមេត្ថ អសន្ទិដ្ឋិបរាមាសី អនាធានគ្គាហី សុប្បដិនិស្សគ្គី ភវិស្សាមាតិ សល្លេខោ ករណីយោ[៦៩] ។

"លោកទាំងឡាយគប្បីផ្ដុសខាត់ក្នុងសេចក្ដីនេះថា ជនពួកដទៃ សូម្បីនឹងជាមនុស្សប្រកាន់មាំការឃើញរបស់ខ្លួន ប្រកាន់ភ្ជាប់យ៉ាងមាំ នឹងលះវាត្រីបានដោយលំបាក តែពួកយើងនឹងមិនជាអ្នកប្រកាន់មាំការឃើញរបស់ខ្លួន មិនប្រកាន់ភ្ជាប់យ៉ាងមាំ នឹងលះវាត្រីបានដោយងាយ" ។

ចប់ បរិច្ឆេទទី ៣ ។ ៙

# បរិច្ឆេទទី ៤

## គន្លងផ្លូវក្នុងការចម្រើនវិបស្សនាភាវនា

ការចម្រើនវិបស្សនា ជាការរលឹកដឹងទាន់សភាវធម៌បច្ចុប្បន្ន ដោយអាស្រ័យពាក្យបរិកម្មជាគ្រឿងជួយឲ្យដឹងក្នុងបច្ចុប្បន្នខណៈ ពាក្យអធិប្បាយនោះ សំខាន់ចំពោះការចម្រើនវិបស្សនា ចាត់ជាវិជ្ជមានបញ្ញត្តិ គឺ បញ្ញត្តិសម្តែងសេចក្តីដែលប្រាកដដោយបរមត្ថ ដែលហៅថា តជ្ជាបញ្ញត្តិ សំដៅដល់ បញ្ញត្តិដែលសមរម្យជាមួយសភាវធម៌ ពោលគឺ ឲ្យដឹងដល់សភាវធម៌នោះ បានយ៉ាងជាក់ច្បាស់ ។

សូម្បីការបរិកម្មនឹងធ្វើឲ្យចិត្តទទួលដឹងពាក្យបញ្ញត្តិជាអារម្មណ៍ តែក៏ជួយឲ្យចិត្តផ្តោតអារម្មណ៍ច្រើនឡើងក្នុងវេលាផ្តើមបដិបត្តិធម៌ តពីនោះ នឹងអាចឃើញរូបនាមតាមសភាវៈនោះៗ ដោយភាពមិនទៀងជាដើមបាន កាលវិបស្សនាញាណមានកម្លាំងច្រើនឡើងហើយ ក្នុងខាងក្រោយ អ្នកបដិបត្តិមិនចាំបាច់ត្រូវប្រើពាក្យបរិកម្មតទៅទៀត ព្រោះក្នុងខណៈនោះ នឹងអាចតាមដឹងរូបនាមបានជាក់ច្បាស់

រហូតឃើញការកើតរលត់យ៉ាងឆាប់រហ័សរបស់សភាវធម៌ ដែលកំពុងកំណត់ដឹង ដូចសេចក្ដីក្នុងគម្ពីរវិសុទ្ធិមគ្គមហាដីកាថា

ននុ ច តជ្ជាបណ្ណត្តិវសេន សភាវធម្មោ គយ្ហតីតិ ។ សច្ចំ គយ្ហតិ បុព្វភាគេ ។ ភាវនាយ បន វឌ្ឍមានាយ បញ្ញត្តិំ សមតិក្កមិត្វា សភាវេយេវ ចិត្តំ តិដ្ឋតិ[១] ។

"សួរថា បុគ្គលរមែងទទួលដឹងសភាវធម៌ដោយសារនាមបញ្ញត្តិបានឬ ? ឆ្លើយថា មែនពិត ក្នុងខាងដើមរមែងទទួលដឹងដោយសារនាមបញ្ញត្តិ ( គឺមានពាក្យបរិកម្មច្រាស់គ្នាទៅ ) តែកាលភាវនាចម្រើនឡើង ចិត្តរមែងកន្លងបញ្ញត្តិ ហើយស្ថិតនៅក្នុងសភាវៈតែមួយ ( គឺមិនមានពាក្យបរិកម្មប្រែកបរួម )" ។

ការពិត សេចក្ដីខាងដើមពោលទុកក្នុងរឿងការរលឹកដល់ព្រះពុទ្ធគុណ តែនាំមកប្រើក្នុងការចម្រើនវិបស្សនាភាវនាបាន ព្រោះវិបស្សនា មានអារម្មណ៍ជាសភាវធម៌ដូចព្រះពុទ្ធគុណ និងការរលឹកដល់ព្រះពុទ្ធគុណ ក៏ត្រូវបរិកម្មថា ឥតិបិ សោ ភគវា ជាដើម ដូចគ្នាតែម្យ៉ាង មិនដូច្នោះហើយ ក៏មិនអាចរលឹកដល់ព្រះពុទ្ធគុណ

បាន ។

[ការប្រើពាក្យបរិកម្មថា "ឡើងប៉ុងហ្ន៎ ស្រុតហ្ន៎" នេះលោកម្ចាស់ព្រះធម្មធីរាជមហាមុនី ( ជោកតឈានសិទ្ធិ ប.ធ.៩ ) អាចារ្យធំផ្នែកវិបស្សនាធុរៈ ការិយាល័យកណ្ដាលក្រុមវិបស្សនាធុរៈ វត្តមហាធាតុ ។ គណៈ ៥ ក្រុងទេពមហានគរ បានបញ្ញត្តិប្រើមុនទិន បង្រៀនសិស្សានុសិស្សតមក ។ សេចក្ដីពិត ក្នុងភាសាភូមាប្រើ ពាក្យថា "ប៉ោងបេះដូង ធំបេះដូង" ដែលប្រែជាភាសាថៃថា "កំពុងប៉ោង កំពុងស្រុត" ដោយហេតុដែលភាសាភូមា រមែងប្រកបកិរិយា ត្រួតពាក្យដូចភាសាបាលី ទើបប្រើបេះដូង ( កំពុង ) គួបជាគូ ជាមួយនឹងពាក្យថា ប៉ោងធំដូចនោះ ពាក្យអធិប្បាយនោះ ទើបមាន ពីរពាក្យថា បេះដូចប៉ោងបេះដូងធំ ( កំពុងប៉ោង កំពុងស្រុត ) យ៉ាងណាក៏ដោយ ប្រជាជនថៃទូទាំងប្រទេសធ្លាប់ត្រួតជាមួយពាក្យថា ប៉ោងហ្ន៎ ស្រុតហ្ន៎ អ្នកប្រែទើបគិតថា មិនចាំបាច់ត្រូវប្ដូរជា កំពុងប៉ោង កំពុងស្រុត ។

ពាក្យបរិកម្មនោះ មានប្រយោជន៍ដើម្បីឲ្យចិត្តផ្ដោតអារម្មណ៍ច្រើនឡើង ជាការបន្ថែមវិរិយៈផ្លូវចិត្ត ដើម្បីមិនឲ្យតាមដឹងយ៉ាងរាក់ ៗ ប្រៀបដូចដុំដីស្អិតដែលដាក់ក្នុងជញ្ជាំងដោយកម្លាំងខ្លាំង រមែងប៉ះខ្ជាប់ជញ្ជាំង ហើយជាប់ណែន បើត្រូវចោលដោយកម្លាំងមិនល្មម ក៏អាចធ្លាក់

ទៅមិនដល់ដញ្ហាំង ឬស្ទូម្បីប៉ះខ្ទប់ដញ្ហាំងក៏មិនជាប់ណែន] ។

## ការតាមដឹងក្នុងខណៈឃើញ

អ្នកបដិបត្តិ ចម្រើនវិបស្សនាឃើញរូបនាមតាមសេចក្ដីពិតរមែងទទួលដឹងសភាវៈឃើញ បានឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ នឹកគិត និងរូបដែលជាទីអាស្រ័យរបស់ចិត្ត ព្រមទាំងរូបដែលកើតអំពីចិត្តក្នុងខណៈនោះៗ ចំណែកអ្នកចម្រើនសមថ-ភាវនា គប្បីទទួលដឹងឈានចិត្ត ហទយវត្ថុ និងរូបដែលកើតអំពីឈានចិត្តតាមសមគួរ ។ ម្យ៉ាងទៀត ចិត្តដែលទទួលដឹងសភាវៈឃើញ គឺវិថីចិត្តដែលកើតផ្លូវចក្ខុទ្វារមួយវិថី តាំងអំពីអាវជ្ជនចិត្តទៅរហូតដល់តទារម្មណចិត្ត ត្រឹមជាការទទួលដឹងចំពោះវិថីចិត្តមួយវិថីនៅមិនមែនការទទួលដឹងចិត្តម្ដងមួយដួងៗ សេចក្ដីនេះ នឹងពោលតទៅក្នុងបរិច្ឆេទទី ៦ រឿងកង្ខញាណ ។

ក្នុងខណៈឃើញគប្បីកំណត់ថា“ឃើញហ្ន៎ៗ”ស្ទូម្បីក្នុងពេលបានឮជាដើម ក៏គប្បីកំណត់ថា “បានឮហ្ន៎ៗ” ការកំណត់ថា “ឃើញហ្ន៎ៗ” នេះ សំដៅដល់ចក្ខុបសាទ រូបារម្មណ៍( ពណ៌ ) សភាវៈឃើញការប៉ះ

ខ្ទប់គ្នារវាងពណ៌និងចក្ខុបសាទ និងវេទនាដែលសប្បាយចិត្ត ខូចចិត្ត ឬព្រងើយៗ ពោលដោយសរុបការកំណត់ថា "ឃើញហ្ន៎ៗ" ជាការទទួលដឹងសភាវធម៌ ៥ យ៉ាងតាមសមគួរគឺ ចក្ខុបសាទ រូបារម្មណ៍ ចក្ខុវិញ្ញាណ ផស្សៈផ្លូវភ្នែក ( ចក្ខុសម្ផស្ស ) ឬវេទនាដែលកើតអំពីផស្សៈផ្លូវភ្នែក ( ចក្ខុសម្ផស្សជាវេទនា ) ។

អ្នកដែលចម្រើនវិបស្សនាភាវនា នៅមិនគួរជ្រើសរើសរកអារម្មណ៍កម្មដ្ឋានដែលខ្លួនត្រូវការ គួរតាមដឹងសភាវធម៌ដែលមកប្រាកដយ៉ាងជាក់ច្បាស់ក្នុងបច្ចុប្បន្នខណៈ សូម្បីថា អ្នកបដិបត្តិនឹងមិនមានការជាប់ទាក់ទងជាមួយបរិយត្តិ ក៏អាចទទួលដឹងសភាវធម៌ដែលប្រាកដបាន ដូចកាលតាមដឹងទុក្ខវេទនាថា "ឈឺហ្ន៎" រមែងនឹងទទួលដឹងសភាវធម៌ដូច្នេះ គឺ

- ការប៉ះខ្ទប់ដែលមិនគួរត្រេកអរ ជាលក្ខណៈពិសេសរបស់ទុក្ខវេទនា ( អនិដ្ឋផោដ្ឋព្វានុភវនលក្ខណា ) ។

- ការធ្វើឲ្យចិត្តមិនស្រស់ថ្លា ជានាទីរបស់ទុក្ខវេទនា ( សម្បយុត្តានំ មិលាបនរសា ) ។

- ការចុកចាប់ផ្ទៃកាយ ជាអាការប្រាកដរបស់ទុក្ខវេទនា ( កាយិកាពាធបច្ចុបដ្ឋានា ) ។

-ការជួបគ្នារវាងចិត្តជាមួយផស្សៈដែលមិនល្អ ជាហេតុជិតរបស់ទុក្ខវេទនា ( ផស្សបទដ្ឋានា ) ។

- ពោលដោយលោកូបមា ការទទួលដឹងលក្ខណៈពិសេស ដូចការឃើញពន្លឺរបស់ផ្លេកបន្ទោរ ការទទួលដឹងនាទី ដូចការកំចាត់កាពងងឹត ការទទួលដឹងអាការប្រាកដ ដូចការឃើញសណ្ឋានរបស់ផ្លេកបន្ទោរដែលវែង ខ្លី ត្រង់ឬវៀច ចំណែកការទទួលដឹងហេតុជិត ដូចការឃើញដុំពពកដែលជាស្ថានទីកើតរបស់ផ្លេកបន្ទោរ ។

យ៉ាងណាក៏ដោយ ហេតុជិតរមែងមិនប្រាកដច្បាស់ដល់អ្នកបដិបត្តិក្នុងពេលដែលកើតវិបស្សនាញាណថ្នាក់ដំបូង ដែលហៅថា នាមរូបបរិច្ឆេទញាណ គឺ បញ្ញាចែករូបនាម ព្រោះហេតុជិតជាធម៌ដែលមិនគួរតាមដឹង ព្រោះតែមិនមែនសភាវធម៌ដែលឃើញច្បាស់ក្នុងបច្ចុប្បន្នខណៈ ដូចអ្នកដែលតាមដឹងបឋវីធាតុ គួរទទួលដឹងលក្ខណៈពិសេស នាទី និងអាការៈប្រាកដរបស់បឋវីធាតុ មិន

គួរតាមដឹងហេតុជិតរបស់បឋវីធាតុ គឺ ធាតុ ៣ យ៉ាងដ៏សេស គឺ អាបោធាតុ តេជោធាតុ និងវាយោធាតុ ព្រោះនឹងជាការកំណត់ធាតុដទៃដែលមិនមែនបឋវីធាតុ កាលចក្ខុបសាទប្រាកដច្បាស់ ក៏គួរតាមដឹងចក្ខុបសាទ មិនគួរកំណត់ហេតុជិត គឺ មហាភូតរូប ៤ ( បឋវី អាបោ តេជោ និងវាយោ ) ដែលជាទីអាស្រ័យរបស់ចក្ខុបសាទ កាលផស្សៈប្រាកដច្បាស់ ក៏គួរកំណត់ផស្សៈ មិនគួរកំណត់ហេតុជិត គឺវេទនា កាលវេទនាប្រាកដច្បាស់ក៏គួរកំណត់វេទនា មិនគួរកំណត់ហេតុជិតគឺអារម្មណ៍ ដូចនេះជាដើម ដូចគម្ពីរវិសុទ្ធិមគ្គមហាដីកាពោលថា

**បទដ្ឋានំ បនេត្ថ អញ្ញធម្មតាយ ន ឧទ្ធដំ ។**

"បទដ្ឋានមិនសម្ដែងទុកក្នុងរឿងធាតុនេះ ព្រោះជាធម៌ដទៃផុតអំពីធាតុដែលគប្បីកំណត់ដឹង" ។

ពិតហើយ ការកំណត់ដឹងបទដ្ឋានគឺហេតុជិតរបស់រូបនាម រមែងប្រាកដក្នុងវិបស្សនាញាណទី ២ ឈ្មោះថា បច្ចយបរិគ្គហញ្ញាណ គឺ ញាណកំណត់ដឹងបច្ច័យរបស់រូបនាម មិនប្រាកដក្នុងនាមរូប-

បរិច្ឆេទញាណ ។

ម្យ៉ាងទៀត គម្ពីរអភិធម្មត្ថសង្គហៈគ្រប់ច្បាប់ គឺ ច្បាប់ឆដ្ឋ-សង្គាយនា ច្បាប់សិង្ហល: និងច្បាប់ថៃ មានសេចក្តីថា

**លក្ខណរសបច្ចុបដ្ឋានបទដ្ឋានវសេន**

**នាមរូបបរិគ្គហោ ទិដ្ឋិវិសុទ្ធិ នាម[៣] ។**

"ការកំណត់ដឹងនាមរូបដោយប្រភេទនៃលក្ខណ: រស បច្ចុបដ្ឋាន និងបទដ្ឋាន ឈ្មោះថា ទិដ្ឋិវិសុទ្ធិ" ។

ដោយហេតុដែលគម្ពីរច្បាប់សិង្ហល:សម័យមុនមិនមានបទដ្ឋានក្នុងរឿងនេះ និងគម្ពីរអភិធម្មត្ថវិភាវិនី ដែលតែងក្នុងពុទ្ធសករាជ ១៧០០ ក៏មិនបានពោលដល់បទដ្ឋានទុក ទើបឈ្មោះថា រឿងបទដ្ឋានគង់នឹងមកបន្ថែមខាងក្រោយ ដែលអាចកើតអំពីការចារស្លឹករឹតខុសតាមគ្នាមក ក្រោយពុទ្ធសករាជ ១៧០០ ។

ម្យ៉ាងទៀត សភាវធម៌ដូចលក្ខណ:ជាដើម រមែងប្រាកដច្បាស់ដល់អ្នកបដិបត្តិតែក្នុងមួយខណ: មានន័យថា ខណ:ខ្លះ លក្ខណ:

ពិសេសប្រាកដច្បាស់ ខណៈខ្លះ នាទីប្រាកដច្បាស់ ខណៈខ្លះ អាការប្រាកដច្បាស់ ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គថា

កស្មា បនេត្ថ ឧភយគ្គហណំ ។ បុគ្គលជ្ឈាសយតោ ។ ឯកច្ចស្ស ហិ ធាតុយោ មនសិករោន្តស្ស តា សភាវតោ គហេតព្វំ គច្ឆន្តិ ។ ឯកច្ចស្ស សកិច្ចករណតោ, យោ រសោតិ វុច្ចតិ[៤] ។

"សួរថា : ហេតុណាទើបពោលដល់លក្ខណៈ និងនាទីទាំងពីរយ៉ាងទុកក្នុងរឿងនេះ

ឆ្លើយថា : ជាការពោលទុកតាមអធ្យាស្រ័យរបស់បុគ្គលដោយពិតហើយ កាលអ្នកខ្លះកំណត់ដឹងនូវធាតុ ធាតុទាំងនោះរមែងប្រាកដដោយលក្ខណៈ កាលអ្នកខ្លះកំពុងកំណត់ដឹងនូវធាតុ ធាតុទាំងនោះ រមែងប្រាកដដោយធ្វើនាទីរបស់ខ្លួនដែលហៅថារស" ។

សេចក្តីនេះ មានន័យថា អ្នកដែលចម្រើនធាតុកម្មដ្ឋានដោយតាមដឹងធាតុ ៤ គប្បីកំណត់ដោយលក្ខណៈ ឬនាទីរបស់ធាតុ

យ៉ាងណាមួយ៉ាង មិនគួរតាមដឹងព្រមគ្នាទាំងពីរយ៉ាង តែក្នុងគម្ពីរអដ្ឋកថាពោលដល់ការតាមដឹងទាំងពីរយ៉ាងទុក តាមអធ្យាស្រ័យរបស់បុគ្គល ព្រោះអ្នកខ្លះនឹងប្រាកដដោយលក្ខណៈ និងអ្នកខ្លះក៏មកប្រាកដដោយនាទី ទើបគួរតាមដឹងសភាវៈដែលប្រាកដតែក្នុងមួយខណៈ ។

ក្នុងខណៈកំណត់ថា "ឃើញហ្ន៎" សភាវធម៌ ៥ យ៉ាង គឺចក្ខុបសាទ ពណ៌ ( រូបារម្មណ៍ ) ចក្ខុវិញ្ញាណ ផស្សៈផ្លូវភ្នែកឬវេទនាដែលកើតអំពីផស្សៈផ្លូវភ្នែក រមែងប្រាកដក្នុងខណៈនោះ ៗ តាមសមគួរ ដូចមានសេចក្ដីពិស្ដារតទៅនេះ

ការតាមដឹងចក្ខុបសាទ មានសភាវធម៌ដូចនេះគឺ

- ភាពភ្លឺដែលចាំងឆ្លុះឃើញរូបបាន ជាលក្ខណៈពិសេសរបស់ចក្ខុបសាទ ( **រូបាភិឃាតារហភូតប្បសាទលក្ខណំ** ) ។

- ការនាំចិត្តទៅក្នុងរូបារម្មណ៍ជានាទី ( **រូបេសុ អាវិញ្ឆនរសំ** ) ។

- ការឃើញបានផ្លូវចក្ខុបសាទជាអាការៈប្រាកដ ( **ចក្ខុវិញ្ញា-ណស្ស អាធារភាវបច្ចុបដ្ឋានំ** ) ។

- ការមានដួងភ្នែកជាហេតុជិត ( ទដ្ឋុកាមតានិទានកម្មជភូតបទដ្ឋានំ ) ។

ការតាមដឹងរូបារម្មណ៍ មានសភាវធម៌ដូច្នេះគឺ

- ការប្រាកដឲ្យដឹងផ្ទៃភ្នែក ជាលក្ខណៈពិសេសរបស់រូបារម្មណ៍ ( ចក្ខុបដិហននលក្ខណំ ) ។

- ការត្រូវឃើញជានាទី ( ចក្ខុវិញ្ញាណស្ស វិសយភាវរសំ ) ។

- ការដែលសភាវៈឃើញដំណើរទៅក្នុងចក្ខុបសាទ ជាអាការប្រាកដ ( តស្សេវ គោចរបច្ចុបដ្ឋានំ ) ។

- ការអាស្រ័យមហាភូតរូបជាហេតុជិត( ចក្ខុមហាភូតបទដ្ឋានំ )។

ការទទួលដឹងចក្ខុបសាទ និងរូបារម្មណ៍ ដែលពោលមកនេះស្របជាមួយសេចក្តីក្នុងមហាសតិប្បដ្ឋានសូត្រ និងគម្ពីរអដ្ឋកថាថា

ឥធ ភិក្ខវេ ភិក្ខុ ចក្ខុញ្ច បជានាតិ ។ រូបេ ច បជានាតិ ។ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ, តញ្ច បជានាតិ[៥] ។

“ភិក្ខុក្នុងព្រះសាសនានេះ រមែងដឹងច្បាស់ភ្នែក ដឹងច្បាស់

រូបារម្មណ៍ និងដឹងច្បាស់ភ្នែកនិងរូបារម្មណ៍ទាំងពីរនោះ ដែលជាទីអាស្រ័យកើតនៃសំយោជនៈ" ។

ចក្ខុញ្ច បជានាតីតិ ចក្ខុបសាទំ យាថាវសរសលក្ខណវសេន បជានាតិ ។ រូបេ ច បជានាតីតិ បហិទ្ធា ចតុសមុដ្ឋានិករូបញ្ច យាថាវសរសលក្ខណវសេន បជានាតិ[៦] ។

"ព្រះតម្រាស់ថា ចក្ខុញ្ច បជានាតិ ( រមែងដឹងភ្នែក ) មានន័យថារមែងដឹងច្បាស់ចក្ខុបសាទ ដោយអំណាចតាមលក្ខណៈនិងនាទីយ៉ាងពិតប្រាកដ ។ ព្រះតម្រាស់ថា រូបេ ច បជានាតិ ( រមែងដឹងច្បាស់រូបារម្មណ៍ ) មានន័យថា រមែងដឹងច្បាស់រូបារម្មណ៍ដែលកើតអំពីសមុដ្ឋានទាំង ៤ ដោយអំណាចតាមលក្ខណៈនិងនាទីយ៉ាងពិតប្រាកដ" ។

ការតាមដឹងច្បាស់ចក្ខុវិញ្ញាណ មានសភាវធម៌ដូច្នេះ គឺ

- ការឃើញរូប ជាលក្ខណៈពិសេសរបស់ចក្ខុវិញ្ញាណ ( វិជាននលក្ខណំ ) ។

- ការទទួលពណ៌ជាអារម្មណ៍ ជានាទី ( បុព្វង្គមរសំ ) ។

- ការនាំចិត្តទៅកាន់អារម្មណ៍ ជាអាការប្រាកដ ( **សន្ធានបច្ចុ-បដ្ឋានំ** ) ។

- ចក្ខុបសាទនិងពណ៌ ជាហេតុជិត ( **វត្ថារម្មណបទដ្ឋានំ** )។

ការតាមដឹងផស្សៈផ្លូវភ្នែកមានសភាវធម៌ដូច្នេះគឺ

-ការប៉ះខ្ទប់នឹងពណ៌ ជាលក្ខណៈពិសេសនៃផស្សៈផ្លូវភ្នែក ( **ផុសនលក្ខណោ** ) ។

- ការទំនាក់ទំនងអារម្មណ៍ ជាទាទី ( **សំឃដ្ដនរសោ** ) ។

- ការប្រជុំគ្នារវាងចក្ខុបសាទ ពណ៌និងការឃើញ ជាអាការប្រាកដ ( **សន្និបាតបច្ចុបដ្ឋានោ** ) ។

- អារម្មណ៍ដែលមកប្រាកដ ជាហេតុជិត ( **អាបាថគតវិស-បទដ្ឋានោ** ) ។

ការតាមដឹងសុខវេទនា ដែលកើតអំពីផស្សៈផ្លូវភ្នែក មានសភាវធម៌ដូច្នេះ គឺ

- ការសោយអារម្មណ៍ដែលគួរពេញចិត្ត ជាលក្ខណៈពិសេស

របស់សុខវេទនាដែលកើតអំពីផស្សៈផ្លូវភ្នែក ( ឥដ្ឋារម្មណានុភ-វនលក្ខណា ) ។

- ការធ្វើឲ្យដឹងត្រឹមតែពេញចិត្ត ជានាទីរបស់សុខវេទនា ( ឥដ្ឋាការសម្ភោគរសា ) ។

- ការកើតសេចក្ដីពេញចិត្តផ្លូវចិត្ត ជាអាការប្រាកដ ( ចេតសិកអស្សាទបច្ចុបដ្ឋានា ) ។

- ការស្ងប់ចិត្ត ជាហេតុជិត ( បស្សទ្ធិបទដ្ឋានា ) ។

ការតាមដឹងទុក្ខវេទនា ដែលកើតអំពីផស្សៈផ្លូវភ្នែក មានសភាវធម៌ដូច្នេះ គឺ

- ការសោយអារម្មណ៍ ដែលមិនគួរពេញចិត្ត ជាលក្ខណៈពិសេសរបស់ទុក្ខវេទនាដែលកើតអំពីផស្សៈផ្លូវភ្នែក ( អនិដ្ឋារម្មណានុភវនលក្ខណា ) ។

- ការធ្វើឲ្យដឹងត្រឹមតែជាការមិនពេញចិត្តជានាទី ( អនិដ្ឋការសម្ភោគរសា ) ។

- ការកើតសេចក្តីមិនពេញចិត្តផ្លូវចិត្ត ជាអាការៈប្រាកដ ( **ចេតសិកាពាធបច្ចុបដ្ឋាន** ) ។

- ហទយវត្ថុ ជាហេតុជិត ( **ហទយវត្ថុបទដ្ឋានា** ) ។

ការតាមដឹងឧបេក្ខាវេទន ដែលកើតអំពីផស្សៈផ្លូវភ្នែក មានសភាវធម៌ដូច្នេះ គឺ

- ភាពព្រងើយដែលកើតឡើងក្នុងខណៈឃើញ ជាលក្ខណៈពិសេសរបស់ឧបេក្ខាវេទនាដែលកើតអំពីផស្សៈផ្លូវភ្នែក ( **មជ្ឈត្ត-វេទយិតលក្ខណា** ) ។

- ការធ្វើឲ្យសភាវៈឃើញជាកណ្តាល ជានាទី ( **សម្បយុត្តានំ នាតិឧបព្យូហនមិលាបនរសា** ) ។

- ការកើតភាពស្ងប់ មិនត្រេកអរ មិនពេញចិត្តជាអាការប្រាកដ ( **សន្តភាវបច្ចុបដ្ឋានា** ) ។

- ការមានចិត្តមិនមានបីតិត្រេកអរ ជាហេតុជិត ( **និប្បីតិក-ចិត្តបទដ្ឋានា** ) ។

សម្បីសុខវេទនា និងទុក្ខវេទនា ទើងមិនប្រកបរួមជាមួយនឹងចក្ខុវិញ្ញាណ ដែលប្រកបដោយឧបេក្ខាវេទនាតែម្យ៉ាង តែក្នុងអភិញ្ញេយ្យសូត្រ និងបរិញ្ញេយ្យសូត្រ[7] បានពោលដល់វេទនា ៣ ដែលប្រាកដផ្លូវទ្វារ ៦ ក្នុងទីនេះ ទើបសម្ដែងដល់វេទនាទាំងនោះ ដែលប្រកបជាមួយសម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត ជនវចិត្ត និងតទារម្មណចិត្ត ដែលកើតផ្លូវចក្ខុទ្វារវិថី ។

ម្យ៉ាងទៀត គម្ពីរមូលដីកា និងគម្ពីរវិសុទ្ធិមគ្គមហាដីកា ពោលថា ឧបេក្ខាដែលប្រកបរួមនឹងចិត្ត ដែលឃើញរូបមិនគួរពេញចិត្ត ចាត់ជាទុក្ខវេទនា និងឧបេក្ខាដែលប្រកបរួមនឹងចិត្ត ដែលឃើញរូបគួរពេញចិត្ត ចាត់ជាសុខវេទនាដោយបរិយាយ ដូចសាធកៈក្នុងគម្ពីរទាំងនោះថា

**ឧបេក្ខា បន អកុសលវិបាកភូតា អនិដ្ឋត្តា**

**ទុក្ខេ អវរោធេតព្វា, ឥតរា ឥដ្ឋត្តា សុខេ[8] ។**

“ចំណែកឧបេក្ខាដែលជាផលរបស់អកុសល រមែងរាប់ចូលក្នុងទុក្ខ ព្រោះមិនគួរប្រាថ្នា ចំណែកឧបេក្ខាក្រៅពីនេះ រាប់ចូលក្នុង

សុខ ព្រោះគួរប្រាថ្នា" ។

ក្រៅពីនេះ សម្បីឧបេក្ខាដែលប្រកបរួមនឹងចិត្តដែលឃើញរូបជាកណ្ដាល ដែលមិនគួរត្រេកអរមិនពេញចិត្ត ក៏គួរជាឧបេក្ខាដោយពិត ព្រោះលោកពោលបទសម្ដែងហេតុទុកពីរស័ព្ទ គឺ **អនិដ្ឋតា** ( ព្រោះមិនគួរប្រាថ្នា ) និង **ឥដ្ឋតា** ( ព្រោះគួរប្រាថ្នា ) ។

ពិតហើយ សម្បីចក្ខុវិញ្ញាណ នឹងប្រកបដោយឧបេក្ខាវេទនា តែការត្រេកអរពេញចិត្ត រមែងប្រាកដកាលប៉ះខូប់ពណ៌ សម្លេង ក្លិន រស និងសម្ផស្ស ដែលត្រូវចិត្តហើយកើតការដឹងត្រឹមត្រេកអរ សម្បីការមិនពេញចិត្ត ក៏ប្រាកដកាលការប៉ះខូប់ពណ៌ សម្លេង ក្លិន រស និងសម្ផស្ស ដែលមិនត្រូវចិត្ត នឹងឃើញបានថា ការដឹងត្រឹមត្រេកអរ រមែងប្រាកដកាលបានក្លិនរបស់ប្រអប់មានទឹងអប់ផ្កាឈើក្រអូបជាដើម ឬទទួលទានអាហារ មានរសឆ្ងាញ់ ការដឹងត្រឹមមិនពេញចិត្ត រមែងប្រាកដកាលបានក្លិនរបស់ស្អុយ ទទួលទានអាហារមានរសមិនល្អ ក្រៅពីនេះ សម្បីកាយវិញ្ញាណ នឹងប្រកបដោយសុខវេទនា និងទុក្ខវេទនា តែក្នុងគ្រាខ្លះក៏អាចនឹងដឹង

ត្រឹមផោដ្ឋព្វារម្មណ៍ ក្នុងលក្ខណៈជាកណ្ដាល មិនសុខមិនទុក្ខ តាមន័យនេះ គប្បីរួមផោដ្ឋព្វារម្មណ៍ប្រភេទនេះទុកក្នុងសុខវេទនាថ្នាក់ទាប ។

## ការតាមដឹងក្នុងខណៈបានឮ

ក្នុងខណៈកំណត់ថា "បានឮហ្ន៎" សភាវធម៌ ៥ យ៉ាង គឺ សោតបសាទ សម្លេង ( សទ្ទារម្មណ៍ ) សោតវិញ្ញាណ ផស្សៈផ្លូវត្រចៀក ឬវេទនាដែលកើតពីផស្សៈផ្លូវត្រចៀក រមែងប្រាកដក្នុងខណៈនោះៗ តាមសមគួរ ។

ការតាមដឹងសោតបសាទ មានសភាវធម៌ដូច្នេះ គឺ

- ភាពថ្លាដែលអាចឲ្យបានឮសម្លេងបាន ជាលក្ខណៈពិសេសរបស់សោតបសាទ ( **សទ្ទាភិឃាតារហភូតប្បសាទលក្ខណំ** ) ។

- ការនាំចិត្តទៅក្នុងសទ្ទារម្មណ៍ជានាទី( **សទ្ទេសុអាវិញ្ឆនរសំ** )។

- ការបានឮតាមផ្លូវសោតបសាទ ជាអាការប្រាកដ ( **សោតវិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានំ** ) ។

- ការមានត្រចៀកជាហេតុជិត ( សោតុកាមតានិទានកម្មជ-ភូតបទដ្ឋានំ ) ។

ការតាមដឹងសទ្ទារម្មណ៍ មានសភាវធម៌ដូច្នេះ គឺ

- ការដែលសទ្ទារម្មណ៍មកប្រាកដក្នុងត្រចៀក ជាលក្ខណៈពិសេសរបស់សទ្ទារម្មណ៍ ( សោតបដិហននលក្ខណំ ) ។

- ការត្រូវបានឮជានាទី ( សោតវិញ្ញាណស្ស វិសយភាវរសំ )។

-ការដែលសភាវៈបានដំណើរការទៅក្នុងសោតបសាទជាអាការប្រាកដ ( តស្សេវគោចរបច្ចុបដ្ឋានំ ) ។

- ការអាស្រ័យមហាភូតរូបជាហេតុជិត( ចតុមហាភូតបទដ្ឋានំ )។

ការតាមដឹងសោតវិញ្ញាណ មានសភាវធម៌ដូច្នេះ គឺ

- ការបានឮជាលក្ខណៈពិសេសរបស់សោតវិញ្ញាណ ( វិជ្ជា-ននលក្ខណំ ) ។

- ការទទួលសម្លេងជាអារម្មណ៍ ជានាទី ( បុព្វង្គមរសំ ) ។

- នាំចិត្តទៅកាន់អារម្មណ៍ជាអាការប្រាកដ( សន្ទានបច្ចុបដ្ឋានំ )។

- សោតបសាទនិងសម្លេង ជាហេតុជិត( វត្ថារម្មណបទដ្ឋានំ )។

## ការតាមដឹងក្នុងខណៈស្រូបក្លិន

ក្នុងខណៈកំណត់ថា "ដឹងហ្ន៎" កាលបានក្លិនសភាវធម៌ ៥យ៉ាងគឺ ឃានបសាទ ក្លិន ( គន្ធារម្មណ៍ ) ឃានវិញ្ញាណ ផស្សៈផ្លូវច្រមុះ ឬវេទនាដែលកើតអំពីផស្សៈផ្លូវច្រមុះ រមែងប្រាកដក្នុងខណៈនោះ ៗ តាមសមគួរ ។

ការតាមដឹងឃានបសាទ មានសភាវធម៌ដូច្នេះ គឺ

- ភាពថ្លាដែលស្រូបយកក្លិនបាន ជាលក្ខណៈពិសេសរបស់ ឃានបសាទ ( គន្ធាភិឃាតារហភូតប្បសាទលក្ខណំ ) ។

- ការទាំចិត្តទៅក្នុងគន្ធារម្មណ៍ជានាទី ( គន្ធេសុ អាវិញ្ឆនរសំ )។

- ការបានក្លិនផ្លូវឃានបសាទ ជាអាការប្រាកដ ( ឃានវិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានំ ) ។

- ការមានច្រមុះ ជាហេតុជិត ( ឃាយិតុកាមតានិទានកម្មជភូតបទដ្ឋានំ ) ។

ការតាមដឹងគន្ធារម្មណ៍ មានសភាវធម៌ដូច្នេះ គឺ

- ការដែលគន្ធារម្មណ៍ប្រាកដក្នុងច្រមុះ ជាលក្ខណៈពិសេសរបស់គន្ធារម្មណ៍ ( **ឃានបដិហននលក្ខណំ** ) ។

- ការត្រូវស្រូបយកបាន ជាទាទី ( **ឃានវិញ្ញាណស្សវិសយភាវរសំ** ) ។

- ការដែលសភាវៈបានក្លិន ដំណើរទៅក្នុងឃានបសាទ ជាអាការប្រាកដ ( **តស្សេវ គោចរបច្ចុបដ្ឋានំ** ) ។

- ការអាស្រ័យមហាភូតរូបជាហេតុជិត ( **ចតុមហាភូតបទដ្ឋានំ** ) ។

ការតាមដឹងឃានវិញ្ញាណ មានសភាវធម៌ដូច្នេះ គឺ

- ការបានធំក្លិន ជាលក្ខណៈពិសេសរបស់ឃានវិញ្ញាណ ( **វិជ្ជានននលក្ខណំ** ) ។

- ការទទួលក្លិនជាអារម្មណ៍ ជាទាទី ( **បុព្វង្គមរសំ** ) ។

- ការនាំចិត្តទៅកាន់អារម្មណ៍ ជាអាការប្រាកដ ( **សន្ទានបច្ចុបដ្ឋានំ** ) ។

- ឃានបសាទ និងក្លិន ជាហេតុជិតរបស់ឃានវិញ្ញាណ ( **វត្ថារម្មណបទដ្ឋានំ** ) ។

**ការតាមដឹងក្នុងខណៈភ្លក្សរស**

ក្នុងខណៈកំណត់ថា "ក្លិនហ្ន៎" ឬ "ដឹងហ្ន៎" សភាវធម៌ ៥ យ៉ាង គឺ ជិវ្ហាបសាទ រស ( រសារម្មណ៍ ) ជិវ្ហាវិញ្ញាណ ផស្សៈផ្លូវអណ្តាត ឬវេទនាដែលកើតអំពីផស្សៈផ្លូវអណ្តាត រមែងប្រាកដក្នុងខណៈនោះ ៗ តាមសមគួរ ។

ការតាមដឹងជិវ្ហាបសាទ មានសភាវធម៌ដូច្នេះ គឺ

- ភាពថ្លាដែលធ្វើឲ្យទទួលរសបាន ជាលក្ខណៈពិសេសរបស់ជិវ្ហាបសាទ ( **រសាភិឃាតារហភូតប្បសាទលក្ខណំ** ) ។

- ការនាំចិត្តទៅក្នុងរសារម្មណ៍ជាទាទី (**រសេសុ អាវិញ្ឆនរសំ**)។

- ការបានភ្លក្សរសផ្លូវជិវ្ហាបសាទ ជាអាការប្រាកដ ( **ជិវ្ហាវិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានំ** ) ។

- ការមានអណ្តាត ជាហេតុជិត ( **សាយិតុកាមតានិទានកម្ម-**

**ជក្ខុតបទដ្ឋានំ** ) ។

ការតាមដឹងរសារម្មណ៍ មានសភាវធម៌ដូច្នេះ គឺ

- ការដែលរសារម្មណ៍ប្រាកដក្នុងអណ្តាត ជាលក្ខណៈពិសេសរបស់រសារម្មណ៍ ( **ជិវ្ហាបដិហននលក្ខណំ** ) ។

- ការត្រូវភ្លក្សជានាទី ( **ជិវ្ហាវិញ្ញាណស្ស វិសយភាវរសំ** ) ។

- ការដែលសភាវៈបានកក់រសជំណើរទៅក្នុងជិវ្ហាបសាទ ជាអាការប្រាកដ ( **តស្សេវ គោចរបច្ចុបដ្ឋានំ** ) ។

- ការអាស្រ័យមហាភូតរូបជាហេតុជិត ( **ចតុមហាភូតបទដ្ឋានំ** ) ។

ការតាមដឹងជិវ្ហាវិញ្ញាណ មានសភាវធម៌ដូច្នេះ គឺ

- ការភ្លក្សរសជាលក្ខណៈពិសេសរបស់ជិវ្ហាវិញ្ញាណ ( **វិជាននលក្ខណំ** ) ។

- ការទទួលរសជាអារម្មណ៍ ជានាទី ( **បុព្វង្គមរសំ** ) ។

- ការនាំចិត្តទៅកាន់អារម្មណ៍ ជាអាការប្រាកដ ( **សន្ធានបច្ចុ-**

បដ្ឋានំ ) ។

- ជិវ្ហាបសាទនិងរស ជាហេតុជិត ( **វត្ថារម្មណបទដ្ឋានំ** ) ។

## ការតាមដឹងក្នុងខណៈប៉ះខ្ទប់

ក្នុងខណៈកំណត់ថា "ត្រូវហ្ន៎" សភាវធម៌ ៥ យ៉ាង គឺ កាយ-បសាទ ប៉ះខ្ទប់ ( ផោដ្ឋព្វារម្មណ៍ដែលបានដល់បឋវីធាតុ តេជោធាតុ និងវាយោធាតុ ) កាយវិញ្ញាណ ផស្សៈផ្លូវកាយ ឬវេទនាដែលកើតអំពីផស្សៈផ្លូវកាយ រមែងប្រាកដក្នុងខណៈនោះៗ តាមសមគួរ ។

ការតាមដឹងកាយបសាទ មានសភាវធម៌ដូច្នេះ គឺ

- ភាពថ្លាដែលធ្វើឲ្យទទួលប៉ះខ្ទប់បាន ជាលក្ខណៈពិសេសរបស់កាយបសាទ ( **ផោដ្ឋព្វាភិឃាតារហភូតប្បសាទលក្ខណំ** ) ។

- ការនាំចិត្តទៅក្នុងផោដ្ឋព្វារម្មណ៍ ជានាទី ( **ផោដ្ឋព្វេសុ-អាវិញ្ឆនរសំ** ) ។

- ការបានប៉ះខ្ទប់ផ្លូវកាយបសាទ ជាអាការប្រាកដ ( **កាយវិ-ញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានំ** ) ។

- ការមានរាងកាយ ជាហេតុជិត ( **ផុសិតុកាមតានិទានកម្ម-ជភូតបទដ្ឋានំ** ) ។

ការតាមដឹងផោដ្ឋព្វារម្មណ៍ មានសភាវធម៌ដូច្នេះ គឺ

- ការដែលផោដ្ឋព្វារម្មណ៍ប្រាកដក្នុងកាយ ជាលក្ខណៈវិសេសរបស់ផោដ្ឋព្វារម្មណ៍ ( **កាយបដិហាននលក្ខណំ** ) ។

- ការត្រូវប៉ះខ្ទប់ជានាទី (**កាយវិញ្ញាណស្ស វិសយការសំ**)។

- ការដែលសភាវៈប៉ះខ្ទប់ដំណើរការទៅក្នុងកាយបសាទ ជាអាការប្រាកដ ( **តស្សេវ គោចរបច្ចុបដ្ឋានំ** ) ។

- ការអាស្រ័យមហាភូតរូបជាហេតុជិត(**ចតុមហាភូតបទដ្ឋានំ**)។

ការតាមដឹងកាយវិញ្ញាណ មានសភាវធម៌ដូច្នេះ គឺ ៖

- ការប៉ះខ្ទប់ ជាលក្ខណៈវិសេសរបស់កាយវិញ្ញាណ ( **វិជាននលក្ខណំ** ) ។

- ការទទួលសម្ផស្សជាអារម្មណ៍ ជានាទី ( **បុព្វង្គមរសំ** ) ។

- ការនាំចិត្តទៅកាន់អារម្មណ៍ជាអាការប្រាកដ ( **សន្ធានបច្ចុ-**

បដ្ឋានំ ) ។

- កាយបសាទនិងសម្ផស្សជាហេតុជិត (វត្ថារម្មណបទដ្ឋានំ) ។

## ការតាមដឹងក្នុងខណៈគិត

ខណៈដែលចិត្តកើតផ្លូវមនោទ្វារ និងមានអាការៈដែលហៅផ្សេងគ្នាថា គិត នឹក ពិចារណា រិះគិតយ៉ាងខ្លាំង ធ្វើទុកក្នុងចិត្ត កំណត់ ជាលក្ខណៈរបស់ចិត្តដែលទទួលដឹងអារម្មណ៍ផ្លូវចិត្ត អ្នកបដិបត្តិគួរតាមដឹងសភាវធម៌នោះៗ ថា "គិតហ្ន៎" "ពិចារណាហ្ន៎" "រិះគិតយ៉ាងខ្លាំងហ្ន៎" "ធ្វើទុកក្នុងចិត្តហ្ន៎" "កំណត់ហ្ន៎" ក៏នឹងជាការទទួលដឹងមនោទ្វារ ធម្មារម្មណ៍ មនោវិញ្ញាណ ផស្សៈ និងវេទនាយ៉ាងណាមួយ៉ាង ដែលប្រាកដច្បាស់ក្នុងខណៈនោះ ការទទួលដឹងនេះ ជាការឃើញដោយការកំណត់ដែលហៅថា ញាតបរិញ្ញានិងជាការឃើញភាពមិនទៀង ដែលកើតឡើង និងរលត់ទៅជាដើម ដោយ តីរណបរិញ្ញា និងបហានបរិញ្ញា តាមសមគួរ ដូចមានសាធកៈ ថា

អាវជ្ជនំ ករិត្តោ អមោបេត្វា មនោតិ សហាវជ្ជនេន ករន្តិ ។

**ធម្មាតិ អារម្មណំ ។ មនោវិញ្ញាណន្តិ ជវនវិញ្ញាណំ[៩] ។**

"ពាក្យថា មនោ គឺភវង្គចិត្តព្រមដោយអាវជ្ជនចិត្ត ដោយរួម អាវជ្ជនចិត្តទុកក្នុងភវង្គចិត្ត, ពាក្យថា ធម្មា ប្រែថា អារម្មណ៍, ពាក្យ ថា មនោវិញ្ញាណំ គឺ ជវនចិត្ត" ។

**កម្មជំ អាយតនទ្វារវសេន បាកដំ ហោតិ ។បេ។ មនោទ្វារេ ហទយវត្ថុ កាយភាវទសកវសេន ចេវ ឧតុសមុដ្ឋានាទិវសេន ច ចតុប្បណ្ណាសមេវ[១០] ។**

"កម្មជរូបប្រាកដដោយសភាពជាអាយតនៈ និងទ្វារ ។ល។ ហទយវត្ថុ ក្នុងមនោទ្វារមានរូប ៥៤ យ៉ាង មានកាយទសកកលាប ភាវទសកកលាប និងឧតុជរូបជាដើម" ។

**មនោទ្វារំ នាម សាវជ្ជំ ភវង្គំ ។ តស្ស និស្សយការតោ ហទយវត្ថុំ សន្ធាយ និស្សិតវោហារេន មនោទ្វារេតិ វុត្តំ, យត្ថ មនោទ្វារុបត្តិ[១១] ។**

"ភវង្គចិត្តព្រមដោយអាវជ្ជនចិត្ត ឈ្មោះថា មនោទ្វារ លោក

ពោលថា ( ក្នុងមនោទ្វារ ) ដែលជាទីកើតរបស់មនោទ្វារ ដោយសំនួនដែលពោលដល់វត្ថុដែលអាស្រ័យផង សំដៅយក ហទយវត្ថុ ព្រោះជាទីអាស្រ័យរបស់ហទយវត្ថុនោះ” ។

សាធកៈខាងដើមសម្ដែងថា ភវង្គចិត្តដែលកើតមុនវិថីចិត្ត និងមនោទ្វារាវជ្ជនចិត្ត ដែលផ្ដើមពិចារណាអារម្មណ៍ផ្លូវមនោទ្វារ ឈ្មោះថាមនោទ្វារ សូម្បីហទយវត្ថុដែលជាទីអាស្រ័យរបស់មនោទ្វារា-វជ្ជនចិត្ត និងភវង្គចិត្ត ទាំងនោះក៏បានឈ្មោះថា មនោទ្វារ ដោយឋានូបចារៈ គឺសំនួនដែលពោលដល់វត្ថុដែលអាស្រ័យ តែប្រាថ្នាឲ្យសំដៅដល់ទីតាំង ដែលក្នុងទីនេះ ជាការពោលដល់វត្ថុដែលអាស្រ័យ គឺមនោទ្វារ តែចេតនាសំដៅដល់ទីតាំង គឺហទយវត្ថុ ។

ធម្មារម្មណ៍ដែលជាអារម្មណ៍របស់វិបស្សនាចិត្ត គឺចិត្ត ចេតសិក និងរូបដែលបានដល់ លោកិយចិត្ត លោកិយចេតសិក បសាទរូប ៥ និងសុខុមរូប ១៦ ពោលគឺ អាបោធាតុ ឥត្ថីភាវរូប ( រូបដែលជាហេតុនៃភាពជាស្ត្រី ) បុរិសភាវរូប ( រូបដែលជាហេតុនៃភាពជាបុរស ) ហទយវត្ថុ ជីវិតរូប និងអាហាររូប ។

មនោវិញ្ញាណ គឺអកុសលជវនចិត្ត កាមាវចរកុសលជវនចិត្ត និងតទារម្មណចិត្ត ចំណែកផស្សៈនិងវេទនា ក៏ជាផស្សៈនិងវេទនា ដែលប្រកបជាមួយជវនចិត្តនិងតទារម្មណចិត្ត ។

## ការតាមដឹងមនោទ្វារ

ក្នុងខណៈដែលវិបស្សនាញាណចាស់ក្លាឡើង អ្នកបដិបត្តិអាចដឹងត្រឹមថាការតាមដឹងមិនជាប់គ្នា ដូចកាលកំណត់ថា "គោងហ្នឹងៗ" ខណៈខ្លះអាចមានប្រឡោះក្នុងរវាង ធ្វើឲ្យសំគាល់ថា អារម្មណ៍ដែលទទួលដឹងមិនតជាប់គ្នា ឬចិត្តដែលទទួលដឹងមិនតជាប់គ្នាសេចក្តីពិតហើយ ជាលក្ខណៈរបស់ភវង្គចិត្ត ដែលខណ្ឌឲ្យដាច់ពីគ្នាទៅចន្លោះ ការទទួលដឹង ការដាច់ចន្លោះនេះ ជាការទទួលដឹងភវង្គចិត្ត ។

ក្នុងខណៈខ្លះ អ្នកបដិបត្តិ អាចទទួលដឹងមនោទ្វារាវជ្ជនចិត្តបានដូចមានសភាវៈតទៅនេះ

- ការទទួលដឹងអារម្មណ៍ដំបូង ជាលក្ខណៈវិសេសរបស់មនោទ្វារាវជ្ជនចិត្ត ( បុព្វង្គមលក្ខណំ ) ។

- ការចាប់ផ្ដើមធ្វើទុកក្នុងចិត្ត ជានាទី ( **អាវជ្ជនរសំ** ) ។

- ការសម្ដែងភាពធ្វើទុកក្នុងចិត្ត ជាអាការប្រាកដ ( **តថាភាវបច្ចុបដ្ឋានំ** ) ។

- ការរលត់ទៅនៃកវង្គចិត្តជាហេតុជិត (**ភវង្គកវង្គបទដ្ឋានំ**) ។

ក្រៅពីនេះ ខណៈខ្លះ អ្នកបដិបត្តិ អាចទទួលដឹងហទយវត្ថុ ដោយមានសភាវៈដូចនេះ

- ការជាទីតាំងរបស់ភាពរិះគិតយ៉ាងខ្លាំង និងភាពទឹកគិត ជាលក្ខណៈវិសេសរបស់ហទយវត្ថុ ( **មនោធាតុមនោវិញ្ញាណធាតូនំ និស្សយលក្ខណំ** ) ។

- ការទ្រទ្រង់ទុកនូវភាពរិះគិតយ៉ាងខ្លាំង និងភាពទឹកគិត ជានាទី ( **តាសញ្ញេវធាតូនំ អាធារណរសំ** ) ។

- ការប្រកបផ្ដុំ ការរិះគិតយ៉ាងខ្លាំង និងភាពទឹកគិត ជាអាការប្រាកដ ( **តទុព្វហនបច្ចុបដ្ឋានំ** ) ។

- ការយល់ថា មានរូបជាទីអាស្រ័យទើបកើតហទយវត្ថុ ជា

ហេតុជិត ( **ចតុមហាភូតបទដ្ឋានំ** ) ។

## ការតាមដឹងធម្មារម្មណ៍

ការតាមដឹងចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ និងកាយបសាទ ព្រមដោយអាបោធាតុ និងហទយវត្ថុ បានពោលទុកមុនហើយ ចំណែកសុខុមរូប ១៦ មានសេចក្ដីពិស្ដារដូចតទៅនេះ

ភាវរូបរមែងប្រាកដកាលសម្ដែងការញញឹម ឬនឹងគិតដោយការដឹងត្រឹមថា ខ្លួនជាប្រុស ឬស្រី ដោយមានសភាវៈដូចនេះ

- ភាពជាស្រី ជាលក្ខណៈវិសេសរបស់ឥត្ថីភាវរូប ( **ឥត្ថីភាវលក្ខណំ** ) ។

- ការសម្ដែងថាជាស្រី ជានាទី ( **ឥត្ថីតិ បកាសនរសំ** ) ។

- ការមានសណ្ឋាន ឥរិយាបថ និងការត្រិះរិះដូចស្ត្រីទូទៅ ជាអាការប្រាកដ ( **ឥត្ថិលិង្គាទីនំ ការណភាវបច្ចុបដ្ឋានំ** ) ។

- ការយល់ថា មានរូបជាទីអាស្រ័យទើបកើតហទយវត្ថុ ជា

ហេតុជិត ( **ចតុមហាភូតបទដ្ឋានំ** ) ។

- ភាពជាប្រុស ជាលក្ខណៈវិសេសរបស់បុរិសភាវរូប ( **បុរិ-សភាវលក្ខណំ** ) ។

- ការសម្តែងថាជាប្រុសជានាទី ( **បុរិសោតិ បកាសនរសំ** ) ។

- ការមានសណ្ឋាន ឥរិយាបថ និងការត្រិះរិះដូចប្រុសទូទៅ ជាអាការប្រាកដ ( **បុរិសលិង្គាទីនំ ការណភាវបច្ចុបដ្ឋានំ** ) ។

- ការយល់ថា មានរូបជាទីអាស្រ័យទើបកើតហទយវត្ថុ ជាហេតុជិត ( **ចតុមហាភូតបទដ្ឋានំ** ) ។

ជីវិតរូបជាហេតុនៃការស្ថិតនៅរបស់ចក្ខុបសាទជាដើម ដែលតាមដឹងសភាវៈឃើញ ។ល។ ក្នុងបច្ចុប្បន្នខណៈ ជីវិតរូបនេះ កើតរួមជាមួយបសាទរូប ក្នុងរាងកាយចំណែកផ្សេងៗ ដែលមានបសាទរូបតាមសមគួរ ធ្វើនាទីរក្សាឲ្យចក្ខុបសាទជាដើម ដែលរលត់ទៅហើយ បានកើតឡើងថ្មីជានិច្ច រហូតអស់មួយជីវិត ដោយមានសភាវៈដូច្នេះ

- ការតាមរក្សាចក្ខុបសាទជាដើម ជាលក្ខណៈវិសេសរបស់

ជីវិតរូប ( **សហជាតរូបានុបាលលក្ខណំ** ) ។

- ការធ្វើឲ្យចក្ខុបសាទជាដើម ដំណើរការទៅបាន ជាទាទី ( **តេសំ បវត្តនរសំ** ) ។

- ការទ្រទ្រង់ទុកនូវចក្ខុបសាទជាដើម ជាអាការប្រាកដ ( **តេសញ្ញេវ ឋបនបច្ចុបដ្ឋានំ** ) ។

-ការយល់ថាមានរូប ជាទីអាស្រ័យដែលដំណើរទៅបានទើបកើតជីវិតរូប ជាហេតុជិត ( **យាបយិតព្វបទដ្ឋានំ** ) ។

អាហាររូប រមែងប្រាកដដល់អ្នកដែលកំណត់ដឹងភាពមានកម្លាំងនិងភាពស្រស់ថ្លានៃចិត្តក្រោយអំពីទទួលទានអាហារហើយ ដោយមានសភាវៈដូច្នេះ

- ការជាសារៈសំខាន់នៃអាហារ ជាលក្ខណៈវិសេសរបស់អាហាររូប ( **ឱជាលក្ខណំ** ) ។

- ការធ្វើឲ្យកើតកម្លាំង ជាទាទី ( **រូបាហរណរសំ** ) ។

- ការឧបត្ថម្ភកាយទុកមិនឲ្យទន់ខ្សោយ ជាអាការប្រាកដ

( **កាយុបត្ថម្ភបច្ចុបដ្ឋាន** ) ។

- ការយល់ថា មានអាហារដែលគួរបរិភោគទើបកើតអាហាររូបជាហេតុជិត ( **អជ្ឈោហរិតព្វបទដ្ឋាន** ) ។

ចិត្តនិងចេតសិក ដែលជាធម្មារម្មណ៍ មានសភាវៈផ្សេងគ្នាដោយបានពោលទៅខ្លះ នឹងចំណែកខ្លះ ក៏នឹងនាំមកពោលដល់ក្នុងបទតទៅ ទើបសូមលើកទុកក្នុងរឿងនេះ ។

**ការតាមដឹងមនោវិញ្ញាណ**

ការតាមដឹងមនោវិញ្ញាណ មានសភាវដូច្នេះគឺ

- ការទទួលដឹងអារម្មណ៍ដោយការនឹកគិត ជាលក្ខណៈវិសេសរបស់មនោវិញ្ញាណ ( **វិជាននលក្ខណំ** ) ។

- ការទទួលដឹងដល់អារម្មណ៍ផ្សេងៗ ជានាទី( **បុព្វង្គមរសំ** ) ។

- ការប្រាប្តាទៅកាន់អារម្មណ៍ ជាអាការប្រាកដ ( **សន្ធានបច្ចុបដ្ឋានំ** ) ។

- ការយល់ថា មានរូបដែលអាស្រ័យទើបកើតមនោវិញ្ញាណ

ជាហេតុជិត ( **វត្ថារម្មណាបទដ្ឋានំ** ) ។

**ការតាមដឹងផស្សៈផ្លូវមនោទ្វារ**

ផស្សៈផ្លូវមនោទ្វារ ( មនោសម្ផស្ស ) មានសភាវៈដូច្នេះ

- ការប៉ះខ្ទប់គ្នារវាងចិត្តជាមួយអារម្មណ៍ ជាលក្ខណៈវិសេស របស់មនោសម្ផស្ស ( **ផុសនលក្ខណោ** ) ។

- ការទំនាក់ទំនងអារម្មណ៍ ជានាទី ( **សង្ឃដ្ដនរសោ** ) ។

- ការប្រជុំគ្នារបស់ហទយវត្ថុ ការទើកគិត និងអារម្មណ៍ ជាអាការប្រាកដ ( **សន្និបាតបច្ចុបដ្ឋានោ** ) ។

- អារម្មណ៍ដែលមកប្រាកដ ជាហេតុជិត ( **អាបាថគតវិសយបទដ្ឋានោ** ) ។

**ការតាមដឹងវេទនាដែលកើតអំពីផស្សៈផ្លូវមនោទ្វារ**

វេទនាដែលកើតអំពីផស្សៈផ្លូវមនោទ្វារ ( មនោសម្ផស្សជាវេទនា ) បែកចេញជាសុខវេទនា ដែលកើតអំពីផស្សៈផ្លូវមនោទ្វារមានសភាវៈដូច្នេះ គឺ ៖

- ការសោយអារម្មណ៍ដែលគួរពេញចិត្ត ជាលក្ខណៈវិសេសរបស់សុខវេទនា ដែលកើតអំពីផស្សៈផ្លូវមនោទ្វារ ( ឥដ្ឋារម្មណានុភវនលក្ខណា ) ។

- ការធ្វើឲ្យដឹងត្រឹមតែជាការពេញចិត្តជានាទី ( ឥដ្ឋាការសម្ភោគរសា ) ។

- ការពេញចិត្តដែលកើតផ្លូវចិត្តជាអាការប្រាកដ ( ចេតសិកអស្សាទបច្ចុបដ្ឋានា ) ។

- ការស្ងប់ចិត្ត ជាហេតុជិត ( បស្សទ្ធិបទដ្ឋានា ) ។

ទុក្ខវេទនាដែលកើតអំពីផស្សៈផ្លូវមនោទ្វារ មានសភាវៈដូច្នេះ

- ការសោយអារម្មណ៍ ដែលមិនគួរពេញចិត្ត ជាលក្ខណៈវិសេសរបស់ទុក្ខវេទនា ដែលកើតអំពីផស្សៈផ្លូវមនោទ្វារ ( អនិដ្ឋារម្មណានុភវនលក្ខណា ) ។

- ការធ្វើឲ្យដឹងត្រឹមតែជាការមិនពេញចិត្ត ជានាទី ( អនិដ្ឋាការសម្ភោគរសា ) ។

- ការមិនពេញចិត្តដែលកើតផ្លូវចិត្ត ជាអាការប្រាកដ ( **ចេតសិកាពាធបច្ចុបដ្ឋានា** ) ។

- ហទយវត្ថុ ជាហេតុជិត ( **ហទយវត្ថុបទដ្ឋានា** ) ។

ឧបេក្ខាវេទនាដែលកើតអំពីផស្សៈផ្លូវមនោទ្វារ មានសភាវៈដូច្នេះ គឺ ៖

- ភាពព្រងើយដែលកើតឡើងក្នុងខណៈឃើញ ជាលក្ខណៈវិសេសរបស់ឧបេក្ខាវេទនា ដែលកើតអំពីផស្សៈផ្លូវមនោទ្វារ ( **មជ្ឈត្តវេទយិតលក្ខណា** ) ។

- ការធ្វើឲ្យសភាវៈឃើញជាកណ្តាល ជានាទី ( **សម្បយុត្តានំនាតិឧព្រូហនមិលាបនរសា** ) ។

- ការកើតភាពស្ងប់មិនត្រេកអរ មិនពេញចិត្តយ៉ាងខ្លាំង ជាអាការប្រាកដ ( **សន្តភាវបច្ចុបដ្ឋានា** ) ។

- ការមានចិត្តមិនមានបីតិត្រេកអរ ជាហេតុជិត ( **និប្បីតិកចិត្តបទដ្ឋានា** ) ។

## ការតាមដឹងសញ្ញាខន្ធ

សញ្ញា គឺការចាំបាន សំគាល់ដឹងអារម្មណ៍ដែលប៉ះខ្ទប់ផ្លូវទ្វារទាំង ៦ សញ្ញានេះ រមែងប្រាកដច្បាស់ក្នុងខណៈប៉ះខ្ទប់អារម្មណ៍ថ្មី ឬបានស្តាប់ ពាក្យបង្ហាញណែនាំដែលខ្វះពេញចិត្ត ដូចមានសភាវៈទាំងនេះ គឺ

- ការសំគាល់ដឹងអារម្មណ៍ ជាលក្ខណៈវិសេសរបស់សញ្ញា ( សញ្ញានខលក្ខណា ) ។

- ការធ្វើនាទីជាហេតុឲ្យចាំបាន ជានាទី ( បុនសញ្ញានខបច្ចយនិមិត្តករណរសា ) ។

- ការគោងយកនូវអារម្មណ៍ដែលប៉ះខ្ទប់ ជាអាការប្រាកដ ( យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុបដ្ឋានា ) ។

- អារម្មណ៍ដែលប្រាកដ ជាហេតុជិត ( យថាឧបដ្ឋិតវិសយបទដ្ឋានា ) ។

## ការតាមដឹងសង្ខារខន្ធ

ចេតសិក ៥០ ដួង វៀរវេទនានិងសញ្ញា ឈ្មោះថា សង្ខារខន្ធ សំដៅដល់កងចេតសិក ដែលប្រកបរួមគ្នាជាមួយចិត្តក្នុងខណៈ ឃើញ ឮ ធុំ ដើរ ឈរ អង្គុយ ដេក បត់ លាតជាដើម ដោយហេតុដែលចេតនាចេតសិកជាប្រធានក្នុងចេតសិកទាំងនេះ ដូចនោះ ទីងពោលដល់ការតាមដឹងចេតនាក្នុងទីនេះ ដូចតទៅ

ចេតនា គឺការតាំងចិត្ត ដែលមានសភាវៈបបួលចិត្ត និងចេតសិក ដែលកើតរួមជាមួយខ្លួនទុកក្នុងអារម្មណ៍ ដូចប្រធានការងារ ដែលធ្វើការងារខ្លួនឯងហើយ បបួលអ្នកដទៃឲ្យធ្វើការងាររួមផង ដោយមានសភាវៈដូច្នេះ

- ការបបួលឲ្យចិត្ត និងចេតសិកបន្តអារម្មណ៍ ជាលក្ខណៈវិសេសរបស់ចេតនា ( **ចេតនាភាវលក្ខណា** ) ។

-ការខ្វល់ខ្វាយឲ្យប្រព្រឹត្តទៅដូចនោះជានាទី (**អាយូហនរសា**)។

- ការចាត់ការឲ្យជាទីតាំងចិត្តដូចការបង្គាប់ថា ចូរស្លាប់ក្នុងការសម្លាប់សត្វឬដូចចូរយក, ចូរជាសុខក្នុងការឲ្យទាន ជាអាការប្រាកដ ( **សំវិធានបច្ចុបដ្ឋានា** ) ។

- ការធ្វើទុកក្នុងចិត្តដោយភាពឆ្លាត ឬមិនឆ្លាត ជាហេតុជិត ( មនសិការបទដ្ឋាន ) ។

សរុបសេចក្ដីថា ក្នុងខណៈកំណត់ថា"ឃើញហ្ន៎" ធម៌ ៥ យ៉ាង គឺចក្ខុបសាទ រូបារម្មណ៍គឺពណ៌ ចក្ខុវិញ្ញាណ ផស្សៈផ្ទុវក្អែក ឬ វេទនាដែលកើតអំពីផស្សៈផ្ទុវក្អែក រមែងប្រាកដក្នុងខណៈនោះៗ សូម្បីក្នុងការកំណត់ថា"បានឮហ្ន៎" ជាដើមក៏មានន័យដូចគ្នា អ្នកបដិបត្តិដែលតាមដឹងយ៉ាងនេះ រមែងនឹងទទួលដឹងលក្ខណៈ នាទី បច្ចុបដ្ឋាន និងបទដ្ឋាន តាមសមគួរដល់អធ្យាស្រ័យរបស់បុគ្គលម្នាក់ៗ ដូចសេចក្ដីក្នុងអភិញ្ញេយ្យសូត្រ និង បរិញ្ញេយ្យសូត្រថា

**ចក្ខុំ ភិក្ខវេ អភិញ្ញេយ្យំ ។ រូបា អភិញ្ញេយ្យា ។ ចក្ខុវិញ្ញាណំ អភិញ្ញេយ្យំ ។ ចក្ខុសម្ផស្សោ អភិញ្ញេយ្យោ ។ យមិទំ ចក្ខុ-សម្ផស្សបច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា, តម្បិ អភិញ្ញេយ្យំ[១២] ។**

"ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីដឹងចក្ខុបសាទចំពោះមុខ គប្បីដឹងរូបារម្មណ៍ចំពោះមុខ គប្បីដឹងចក្ខុវិញ្ញាណចំពោះមុខ គប្បីដឹង

ការប៉ះខ្ទប់គ្នានៃចក្ខុបសាទចំពោះមុខ នឹងគប្បីដឹងចំពោះមុខដល់ការដឹងត្រឹមជាសុខទុក្ខ ឬមិនសុខមិនទុក្ខ ដែលកើតអំពីហេតុ គឺប៉ះខ្ទប់ជាមួយចក្ខុបសាទ" ។

*ចក្ខុំ ភិក្ខវេ អភិញ្ញេយ្យំ ។ រូបា អភិញ្ញេយ្យា ។ ចក្ខុវិញ្ញាណំ បរិញ្ញេយ្យំ ។ ចក្ខុសម្ផស្សោ បរិញ្ញេយ្យោ ។ យមិទំ ចក្ខុសម្ផស្សបច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា, តម្បិ បរិញ្ញេយ្យំ*[១៣] ។

"ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីកំណត់ដឹងចក្ខុបសាទ គប្បីកំណត់ដឹងរូបារម្មណ៍ គប្បីកំណត់ដឹងចក្ខុវិញ្ញាណ គប្បីកំណត់ដឹងការប៉ះខ្ទប់គ្នានៃចក្ខុបសាទ និងគប្បីកំណត់ដឹងដល់ការដឹងត្រឹមតែជាសុខទុក្ខ ឬមិនសុខមិនទុក្ខ ដែលកើតអំពីហេតុ គឺប៉ះខ្ទប់ជាមួយចក្ខុបសាទ" ។

### វិបស្សនាមិនមែនការយល់ដោយការស្តាប់ ឬការពិចារណា

ការចំរើនវិបស្សនា ជាការតាមដឹងសភាវធម៌ គឺរូបនាមតាម

ការពិត ដើម្បីឲ្យទទួលដឹងសភាវលក្ខណៈជាដើម មិនមែនការយល់ដោយការស្តាប់ ដែលហៅថា សុតមយបញ្ញា ឬយល់ដោយការពិចារណា ដែលហៅថា ចិន្តាមយបញ្ញា ទើងឃើញបានថា ព្រះពុទ្ធអង្គត្រាស់ពាក្យថា អភិញ្ញេយ្យ ដែលប្រើក្នុងសេចក្តីថា "គប្បីដឹងចំពោះមុខ" ឬ "គប្បីដឹងដោយបញ្ញាវិសេស" ដោយអភិឧបសគ្គ ប្រើក្នុងសេចក្តីថា "ចំពោះមុខ" ឬ "វិសេស" ដូចមានសាធកៈថា

សភាវធម្មានំ លក្ខណសល្លក្ខណតោ
ញេយ្យអភិមុខា បញ្ញា អភិញ្ញា បញ្ញា[១៤] ។

"បញ្ញាដែលដឹងចំពោះមុខ ចំពោះរូបនាមដែលគួរដឹង ព្រោះកំណត់លក្ខណៈរបស់សភាវធម៌ឈ្មោះថា អភិញ្ញាបញ្ញា ( បញ្ញាដឹងចំពោះមុខ )" ។

អបិ ច សុតមយាយ, ចិន្តាមយាយ, ឯកច្ចភាវនាមយាយ ច អភិវិសិដ្ឋាយ បញ្ញាយ ញាតា អភិញ្ញាតា[១៥] ។

"ម្យ៉ាងទៀត ធម៌ដែលដឹងបានដោយបញ្ញាដ៏វិសេស ជាបញ្ញា

ដែលកើតអំពីការស្តាប់ បញ្ញាដែលកើតអំពីការត្រិះរិះ និងបញ្ញាដែលកើតអំពី[សមថ]ភាវនាខ្លះម្យ៉ាង ឈ្មោះថា ធម៌ដែលដឹងដោយបញ្ញាវិសេស" ។

ការតាមដឹងចក្ខុបសាទ និងធម្មារម្មណ៍ជាដើម ក្នុងព្រះសូត្រខាងដើមនោះ ជាព្រះទេសនាដែលត្រាស់ទុកជាលំដាប់ប៉ុណ្ណោះ មិនមែនមានន័យថា ឲ្យតាមដឹងទាំង ៥ យ៉ាងតាមលំដាប់ ព្រោះចិត្តកើតរលត់ឆាប់រហ័ស រហូតទាំងកំណត់ដឹងតាមលំដាប់មិនបាន និងការកំណត់ទាំង ៥ យ៉ាង ក៏មិនស្រួបជាមួយសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គ[១៦] ដែលពោលដល់ការកើតភង្គញាណ ដោយឃើញការរលត់របស់អារម្មណ៍ ហើយទទួលដឹងការរលត់របស់ចិត្ត ដែលឃើញអារម្មណ៍នោះ ដូចនោះ ទើបគួរតាមដឹងសភាវៈដែលជាក់ច្បាស់យ៉ាងណាម្យ៉ាង ក្នុង៥ យ៉ាងទាំងនោះតាមសមគួរ កាលតាមដឹងសភាវធម៌យ៉ាងណាម្យ៉ាងហើយ សូម្បីសភាវៈយ៉ាងដទៃ ក៏រាប់ចូលក្នុងសភាវៈនោះដោយបរិយាយ ព្រោះជាត្រៃលក្ខណ៍ដូចគ្នា ។

ម្យ៉ាងទៀត ក្នុងពាហិយសូត្រ មានព្រះពុទ្ធវចននេះថា

តស្មាតិហ ពាហិយ ឯវំ សិក្ខិតព្វំ ។ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ, សុតេ សុតមត្តំ ភវិស្សតិ, មុតេ មុតមត្តំ ភវិស្សតិ, វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ, ឯវញ្ហិ តេ ពាហិយ សិក្ខិតព្វំ[១៧] ។

"ម្នាលពាហិយៈ ព្រោះហេតុនោះឯង អ្នកគប្បីសិក្សាយ៉ាងនេះថា កាលឃើញ នឹងត្រឹមតែជាការឃើញ កាលបានឮ នឹងត្រឹមតែជាការបានឮ កាលដឹងអារម្មណ៍ផ្លូវច្រមុះ អណ្ដាត កាយ នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវច្រមុះ អណ្ដាត កាយ កាលដឹងអារម្មណ៍ផ្លូវចិត្ត នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវចិត្ត ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះ" ។

ព្រះតម្រាស់ថា សិក្ខិតព្វំ ( គប្បីសិក្សា ) សំដៅដល់ការបដិបត្តិ ដោយការបំពេញត្រៃសិក្ខា គឺសីលសិក្ខា សមាធិសិក្ខា និងបញ្ញាសិក្ខាឲ្យបរិបូណ៌ មិនមែនជាការសិក្សារៀនសូត្រព្រះបរិយត្តិដូចសាធកៈក្នុងគម្ពីរអដ្ឋកថាថា

សិក្ខិតព្វន្តិ អធិសីលសិក្ខាទីនំ តិស្សន្នម្បិ សិក្ខានំ វសេន សិក្ខនំ កាតព្វំ[១៨] ។

“ព្រះតម្រាស់ថា **សិក្ខិតព្វំ** ( គប្បីសិក្សា ) គឺគប្បីធ្វើការសិក្សាជាប់ទាក់ទងដោយសិក្ខាទាំង ៣ មានអធិសីលសិក្ខាជាដើម”។

**ឯវំ ឥមាយ បដិបទាយ តយា ពាហិយ តិស្សន្នំ សិក្ខានំ អនុបវត្តនវសេន សិក្ខិតព្វំ**[១៩] ។

“ម្នាលពាហិយៈ អ្នកគប្បីសិក្សាដោយការប្រព្រឹត្តត្រៃសិក្ខាដោយបដិបទានេះយ៉ាងនេះ” ។

## ២ការតាមដឹងក្នុងខណៈឃើញជាដើម

អ្នកបដិបត្តិកំណត់ថា “ឃើញហ្ន៎” ក្នុងខណៈឃើញ កាលវិបស្សនាញាណដែលឃើញរូបនាម នឹងកំណត់ដឹងបច្ច័យ ដែលហៅថា ញាតបរិញ្ញា គឺការឃើញដោយការកំណត់ដឹងកើតឡើងហើយ តអំពីនោះនឹងទទួលដឹងថា សភាវធម៌ ៥ យ៉ាងទាំងនោះកើតឡើងហើយរលត់ទៅ កាលវិបស្សនាញាណចាស់ក្លាឡើងក៏នឹងទទួលដឹងការកើតរលត់យ៉ាងឆាប់រហ័សរបស់សភាវធម៌ធ្វើឲ្យយល់ត្រៃលក្ខណ៍ថា មិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ។

ការយល់ក្នុងត្រៃលក្ខណ៍នោះ មានប្រយោជន៍ដើម្បីដោះស្រាយ

ការឃើញខុសថា ទៀង ជាសុខ និងមានតួខ្លួន ទើងឃើញបានថា កិលេសដែលស្រឡាញ់ ឬស្អប់ ដែលកើតឡើងក្នុងខណៈឃើញ រមែងកើតអំពីវត្ថុដែលធ្លាប់ជួបមកពីមុន ទាំងនោះដូចការស្រឡាញ់ ឬការស្អប់របស់មនុស្សទូទៅ រមែងកើតអំពីការជួបជាមួយមនុស្ស ដែលស្រឡាញ់ឬស្អប់ ឬកើតអំពីការបានឮមនុស្សដទៃនិយាយដល់ ទើបទើងកើតការដឹងត្រឹមស្រឡាញ់ ឬស្អប់ឡើងបាន បើមិនធ្លាប់ ជួប ឬមិនបានឮ ក៏ទើងមិនដឹងថាមានបុគ្គលនោះនៅក្នុងលោក ទើបរមែងប្រាសចាកការស្រឡាញ់ ឬស្អប់យ៉ាងពិតប្រាកដ ក្នុង ករណីជាមួយគ្នា បើមនុស្សទូទៅជួបវត្ថុដែលមិនធ្លាប់ជួប ក៏ទើងមិន កើតកិលេសនោះៗ ព្រោះមិនធ្លាប់ប្រាកដក្នុងក្រសែចិត្តរបស់ខ្លួន គប្បីជ្រាបសេចក្ដីនេះ តាមព្រះពុទ្ធតម្រាស់ដែលត្រាស់ដល់ព្រះ មាលុក្យបុត្រថា

តំ កឹ មញ្ញសិ មាលុក្យបុត្ត យេ តេ ចក្ខុវិញ្ញេយ្យា រូបា អទិដ្ឋា អទិដ្ឋបុព្វា ។ ន ច បស្សសិ ។ ន ច តេ ហោតិ បស្សេយ្យន្តិ ។ អត្ថិ តេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វា[២០] ។

"ម្នាលមាលុក្យបុត្រ អ្នកសំគាល់សេចក្ដីនោះ យ៉ាងណា រូបដែលគប្បីឃើញដោយចក្ខុពួកណា អ្នកមិនឃើញហើយទាំងមិនធ្លាប់ឃើញហើយ រមែងមិនឃើញក្នុងឥឡូវនេះផង និងការត្រិះរិះថាយើងនឹងឃើញ ក៏មិនបានមានដល់អ្នកផង អ្នកមានការពេញចិត្តមានការកំណាត់ដឹង ឬមានការស្រឡាញ់ក្នុងរូបទាំងនោះឬ?" ។

ព្រះមាលុក្យបុត្រទូលឆ្លើយថា

**នោ ហេតំ ភន្តេ**[៧១] ។

"មិនមានទេ ព្រះអង្គ" ។

ព្រះតម្រាស់នេះប្រាប្ញាសម្ដែងថា អ្នកបដិបត្តិគប្បីចំរើនវិបស្សនាឃើញរូបារម្មណ៍ ដែលធ្លាប់ឃើញមកពីមុនហើយ លះកិលេសដែលកើតឡើងក្នុងខណៈឃើញ ដូចជាមួយកិលេសដែលមិនកើតឡើងក្នុងរូបដែលមិនធ្លាប់ឃើញមកពីមុន ពិតហើយក្នុងខណៈឃើញនោះ កិលេសរមែងពេញចិត្ត ឬមិនពេញចិត្តក្នុងរូបដែលឃើញនិងរួមទាំងអវយវៈតូចធំទៀតផង កិលេសដូចពោលនេះរមែងនាំទៅកាន់ការប្រកាន់ភ្ជាប់ឧបាទាន ដែលជាហេតុឲ្យកើតភព

ប្តីតទៅ ។

ក្រៅពីនេះមានសេចក្តីដែលត្រាស់សម្តែងដល់សទ្ធារម្មណ៍ ជាដើមតទៅក្នុងមាលុក្យបុត្តសូត្រនោះ[២២]ថា

"សម្លេងដែលគប្បីដឹង ច្បាស់ដោយត្រចៀកពួកណា អ្នកមិនបានស្តាប់ហើយ ទាំងមិនធ្លាប់បានស្តាប់ហើយ រមែងមិនបានស្តាប់ក្នុងឥឡូវនេះផង និងការត្រិះរិះថា យើងនឹងបានស្តាប់ក៏មិនបានមានដល់អ្នកផង អ្នកមានការពេញចិត្ត មានការកំណត់ដឹង ឬមានការស្រឡាញ់ក្នុងសម្លេងទាំងនោះឬ? " ។

"មិនមានទេ ព្រះអង្គ" ។

"ក្លិនដែលគប្បីដឹងច្បាស់ដោយច្រមុះពួកណា អ្នកមិនបានស្រូបយកហើយ ទាំងមិនធ្លាប់បានស្រូបយកហើយ រមែងមិនបានស្រូបយកក្នុងកាលឥឡូវនេះផង និងការត្រិះរិះថាយើងនឹងបានស្រូបយកក៏មិនបានមានដល់អ្នកផង អ្នកមានការពេញចិត្ត មានការកំណត់ដឹង ឬមានការស្រឡាញ់ក្នុងក្លិនទាំងនោះឬ? " ។

"មិនមានទេ ព្រះអង្គ" ។

“រសដែលគប្បីដឹងច្បាស់ដោយអណ្តាតពួកណា អ្នកមិនបានភ្លក្សហើយ ទាំងមិនធ្លាប់បានភ្លក្សហើយ រមែងមិនបានភ្លក្សក្នុងកាលឥឡូវនេះផង និងការត្រិះរិះថា យើងនឹងបានភ្លក្ស ក៏មិនបានមានដល់អ្នកផង អ្នកមានការពេញចិត្ត មានការកំណត់ដឹង ឬមានការស្រឡាញ់ក្នុងរសទាំងនោះឬ?” ។

“មិនមានទេ ព្រះអង្គ” ។

“ផោដ្ឋព្វៈដែលគប្បីដឹងច្បាស់ដោយកាយពួកណា អ្នកមិនបានពាល់ត្រូវហើយ ទាំងមិនធ្លាប់បានពាល់ត្រូវហើយ រមែងមិនបានពាល់ត្រូវក្នុងកាលឥឡូវនេះផង និងការត្រិះរិះថា យើងនឹងបានពាល់ត្រូវ ក៏មិនបានមានដល់អ្នកផង អ្នកមានការពេញចិត្ត មានការកំណត់ដឹង ឬមានការស្រឡាញ់ក្នុងផោដ្ឋព្វៈទាំងនោះឬ?” ។

“មិនមានទេ ព្រះអង្គ” ។

“ធម្មារម្មណ៍ដែលគប្បីដឹងច្បាស់ដោយចិត្តពួកណា អ្នកមិនបានដឹងហើយ ទាំងមិនធ្លាប់បានដឹងហើយ រមែងមិនបានដឹងក្នុងកាលឥឡូវនេះផង និងការត្រិះរិះថាយើងនឹងបានដឹង ក៏មិនបានមាន

ដល់អ្នកផងអ្នកមានការពេញចិត្ត មានការកំណត់ដឹង ឬមានការស្រឡាញ់ក្នុងធម្មារម្មណ៍ទាំងនោះឬ? ” ។

“មិនមានទេ ព្រះអង្គ” ។

ក្រោយពីនោះ ព្រះពុទ្ធអង្គបានត្រាស់ការចម្រើនវិបស្សនា ដោយសង្ខេបថា

ឯត្ថ ច តេ មាលុក្យបុត្ត ទិដ្ឋសុតមុតវិញ្ញាតេសុ ធម្មាសុ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ, សុតេ សុតមត្តំ ភវិស្សតិ, មុតេ មុតមត្តំ ភវិស្សតិ, វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ ។ យតោ ខោ តេ មាលុក្យបុត្ត ទិដ្ឋសុតមុតវិញ្ញាតេសុ ធម្មាសុ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ, សុតេ សុតមត្តំ ភវិស្សតិ, មុតេ មុតមត្តំ ភវិស្សតិ, វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ ។ តតោ ត្វំ មាលុក្យបុត្ត ន តេន ។ យតោ ត្វំ មាលុក្យបុត្ត ន តេន, តតោ ត្វំ មាលុក្យបុត្ត ន តត្ថ ។ យតោ ត្វំ មាលុក្យបុត្ត ន តត្ថ, តតោ ត្វំ មាលុក្យបុត្ត នេវិធ ន ហុរំ ន ឧភយមន្តរេន ។ ឯសេវន្តោ ទុក្ខស្ស[23] ។

“ម្នាលមាលុក្យបុត្រ ក៏ក្នុងសភាវធម៌ទាំងនោះ គឺរូបដែលឃើញ

សម្លេងដែលបានឮ អារម្មណ៍ដែលបានទទួលដឹង និងធម៌ដែលនឹងគប្បីទទួលដឹង កាលឃើញនឹងត្រឹមតែជាការបានឃើញ កាលបានឮនឹងត្រឹមតែជាការបានឮ កាលដឹងអារម្មណ៍ផ្លូវច្រមុះ អណ្តាត កាយ នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវច្រមុះ អណ្តាត កាយ កាលដឹងអារម្មណ៍ផ្លូវចិត្ត នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវចិត្ត ។

ម្នាលមាលុក្យបុត្រ ក្នុងសភាវធម៌ គឺរូបដែលឃើញ សម្លេងដែលបានឮ អារម្មណ៍ដែលបានទទួលដឹង និងធម៌ដែលនឹងគប្បីទទួលដឹង កាលឃើញនឹងត្រឹមតែជាការបានឃើញ កាលបានឮនឹងត្រឹមតែជាការបានឮ កាលដឹងអារម្មណ៍ផ្លូវច្រមុះ អណ្តាត កាយ នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវច្រមុះ អណ្តាត កាយ កាលដឹងអារម្មណ៍ផ្លូវចិត្ត នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវចិត្ត ក្នុងកាលណា ក្នុងកាលនោះ អ្នកនឹងមិនកើតកិលេស ដែលជាប់ដោយសភាវធម៌ទាំងនោះ ។

អ្នកនឹងមិនកើតកិលេសដែលជាប់ដោយសភាវធម៌ទាំងនោះ ក្នុងកាលណា អ្នកនឹងមិនជាប់ជំពាក់ក្នុងសភាវធម៌ទាំងនោះ ក្នុង

កាលនោះ ។

ម្នាលមាលុក្យបុត្រ អ្នកនឹងមិនមានក្នុងលោកនេះ មិនមានក្នុងលោកដទៃ មិនមានក្នុងលោកទាំងពីរ នេះឯងជាទីបំផុតនៃទុក្ខ" ។

សេចក្តីខាងដើមមានន័យថា ក្នុងខណៈឃើញរូប គប្បីទទួលដឹងត្រឹមសភាវៈឃើញប៉ុណ្ណោះ កុំពិចារណាក្នុងវត្ថុដែលឃើញហេតុនាំឲ្យកិលេសដែលស្រឡាញ់ឬស្អប់កើតឡើង កាលតាមដឹងសភាវៈឃើញតែម៉្យាង រូបដែលជួបឃើញ ក៏នឹងប្រាកដត្រឹមតែជាពណ៌ ដោយមិនប្រាកដជារូបរាងសណ្ឋាន និងប្រាកដសភាពដែលមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ដោយការឃើញភាពកើតឡើងនិងរលត់ទៅ រូបដែលឃើញនោះដូចជាមួយរូបដែលមិនបានឃើញ រមែងមិនជាប់ជំពាក់ឲ្យកើតកិលេសតទៅថា ឃើញអ្នកនោះ អ្នកនេះ និងគេជាមនុស្សគួរស្រឡាញ់ ឬគួរស្អប់ ការមិនកើតកិលេសក្នុងខណៈនេះ ឈ្មោះថា លះកិលេសបានដោយ **តទង្គបហាន** គឺលះមួយគ្រា ដោយការកំណត់ដឹង និងមិនមានអារម្មណានុស័យដេកត្រាំក្នុងអារម្មណ៍ដែលឃើញនោះ ។

បុគ្គលដូចពោលនេះ មានត្រាស់ទុកក្នុង**ខន្ធវគ្គសំយុត្ត**[២៤] ថា **តទង្គនិព្វុត**( អ្នកលះកិលេសបានមួយគ្រា ដោយការកំណត់ដឹង ) គេរមែងមិនត្រេកអរជាប់ជំពាក់ ឬមិនពេញចិត្ត ចំពោះរូបដែលបានជួប បានឃើញ ទាំងប្រាសចាកការឃើញខុសថា ទៀង ជាសុខ បង្គាប់បញ្ជាបាន បញ្ញាដែលកើតដល់គេ អាចលះបង់សញ្ញាថាទៀងជាដើមបាន ឈ្មោះថា **បហានបរិញ្ញា** គឺការឃើញដោយការលះនិច្ចសញ្ញាជាដើម តមកកាលវិបស្សនាញាណចាស់ក្លាឡើង នឹងដឹងច្បាស់ដល់ការកើតរលត់របស់សភាវៈឃើញ ឬរូបដែលបានឃើញ តអំពីនោះ ក៏នឹងដឹងច្បាស់ក្នុងការរលត់របស់សភាវៈឃើញ និងរូបដែលឃើញរួមទាំងសង្ខារទាំងអស់ បញ្ញានេះជា **បហានបរិញ្ញា** ក្នុងលំដាប់មគ្គ តមកផលចិត្តរមែងកើតឡើង តអំពីមគ្គចិត្ត ដោយទទួលដឹងព្រះនិព្វានជាអារម្មណ៍ ដូចមគ្គចិត្តគ្រាសម្រេចមគ្គផលជាន់ខ្ពស់ គឺអរហត្តមគ្គនិងអរហត្តផល កិលេសទាំងពួងរមែងអស់ទៅដោយមិនមានសេសសល់ ។

សូម្បីក្នុងការបានឮ ដឹងក្លិន ភ្លក្សរស ប៉ះខ្ទប់ ឬនឹកគិតរឿងរ៉ាវ

ក៏គប្បីតាមដឹងត្រឹមតែសភាវៈបានឮជាដើម ក្នុងខណៈនោះៗ តាមសមគួរដល់ការចម្រើនវិបស្សនា តាមន័យនេះនឹងជួយធ្វើឲ្យចំរើនសីល សមាធិ និងបញ្ញាដែលកើតរួមជាមួយវិបស្សនា ឲ្យចាស់ក្លារហូតទាំងបន្ទុះសីល សមាធិ និងបញ្ញាលំដាប់មគ្គផលតទៅ ។

ព្រះពុទ្ធតម្រាស់នេះ ត្រាស់សម្ដែងគោលនៃការចម្រើនវិបស្សនាទុកដោយត្រង់ ដូចសាធកៈក្នុងគម្ពីរអដ្ឋកថាថា

**ឥតិ ភគវា ពាហិយស្ស សង្ខិត្តរុចិតាយ ឆហិ វិញ្ញាណកាយេហិ សទ្ធឹ ឆឡារម្មណភេទភិន្នំ វិបស្សនាយ វិសយំ ទិដ្ឋាទីហិ ចតូហិ កោដ្ឋាសេហិ វិភជិត្វា តត្ថស្ស ញាតតីរណបរិញ្ញំ ទស្សេតិ[២៤] ។**

“ព្រះមានព្រះភាគ ទ្រង់ចែកអារម្មណ៍របស់វិបស្សនាដែលផ្សេងគ្នាជាអារម្មណ៍ ៦ យ៉ាង ព្រមទាំងកងវិញ្ញាណ ៦ ជា ៤ ចំណែក មានការឃើញជាដើម ព្រោះព្រះពាហិយៈ ជាអ្នកចូលចិត្តសេចក្ដីសង្ខេប ហើយទ្រង់សម្ដែង ញាតបរិញ្ញា ( ការឃើញដោយការកំណត់ដឹង ) និង **តីរណបរិញ្ញា** ( ការឃើញដោយការ

ពិចារណា ) ក្នុងរឿងនោះដល់គេ" ។

**យេហ្ថិមាហិ វិសុទ្ធីហិ សទ្ធិ សារន្ធបេនេវ វិបស្សនា កថិតា**[២៦] ។

"ព្រះអង្គត្រាស់ការចម្រើនវិបស្សនា ដោយសង្ខេបព្រមដោយវិសុទ្ធិថ្នាក់ទាប" ។

ម្យ៉ាងទៀត ក្នុងមាលុក្យបុត្តសូត្រនោះ ព្រះតម្រាស់ថា **ឯត្ថ ច ។បេ។ ភវិស្សតិ** ( ម្នាលមាលុក្យបុត្រ ក៏ក្នុងសភាវធម៌ទាំងនោះ គឺរូបដែលបានឃើញ សម្លេងដែលបានឮ អារម្មណ៍ដែលបានទទួលដឹង និងធម៌ដែលនឹងគប្បីទទួលដឹង កាលឃើញនឹងត្រឹមតែជាការបានឃើញ កាលបានឮនឹងត្រឹមតែជាការបានឮ កាលដឹងអារម្មណ៍ផ្លូវច្រមុះ អណ្តាត កាយ នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវច្រមុះ អណ្តាត កាយ កាលដឹងអារម្មណ៍ផ្លូវចិត្ត នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវចិត្ត ) ជាចំណែកដែលសម្តែងវិធីចំរើនវិបស្សនាភាវនា ។

ព្រះតម្រាស់ថា **យតោ ខោ ។បេ។ ន តេន** ( ម្នាលមាលុក្យបុត្រ ក្នុងសភាវធម៌ គឺរូបដែលបានឃើញ សម្លេងដែលបានឮ អារម្មណ៍ដែលបានទទួលដឹង និងធម៌ដែលនឹងគប្បីទទួលដឹង កាលឃើញ

នឹងត្រឹមតែជាការបានឃើញ កាលបានឮនឹងត្រឹមតែជាការបានឮ កាលដឹងអារម្មណ៍ផ្លូវច្រមុះ អណ្ដាត កាយ នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវច្រមុះ អណ្ដាត កាយ កាលដឹងអារម្មណ៍ផ្លូវចិត្ត នឹងត្រឹមតែជាការដឹងអារម្មណ៍ផ្លូវចិត្ត ក្នុងកាលណា ក្នុងកាលនោះ អ្នកនឹងមិនកើតកិលេស ដែលជាប់ដោយសភាវធម៌ទាំងនោះ ) ជាចំណែកដែលសម្ដែងការសម្រេចមគ្គ ។

ព្រះតម្រាស់ថា **យតោ ត្វំ ។បេ។ ន តត្ថ** ( អ្នកនឹងមិនកើតកិលេស ដែលជាប់ដោយសភាវធម៌ទាំងនោះ ក្នុងកាលណា អ្នកនឹងមិនជាប់ជំពាក់ក្នុងសភាវធម៌ទាំងនោះ ក្នុងកាលនោះ ) ជាចំណែកដែលសម្ដែងការសម្រេចផល ។

ព្រះតម្រាស់ថា **យតោ ត្វំ ។បេ។ ឯសេវន្តោ ទុក្ខស្ស** ( ម្នាលមាលុក្យបុត្រ អ្នកនឹងមិនមានក្នុងលោកនេះ មិនមានក្នុងលោកដទៃ មិនមានក្នុងលោកទាំងពីរនេះឯង ជាទីបំផុតនៃទុក្ខ ) ជាចំណែកដែលសម្ដែងការសម្រេចព្រះនិព្វាន មានន័យថា ព្រះអរហន្តអ្នកសម្រេចអរហត្តផលហើយ ជាអ្នកប្រាសចាកការជាប់ជំពាក់ក្នុង

រូបនាមទាំងអស់ ទើបឈ្មោះថា មិនស្ថិតនៅក្នុងលោកនេះ និងកាល បរិនិព្វានហើយក៏នឹងមិនមានរូបនាមថ្មីកើតឡើង លោកទើបមិន ស្ថិតនៅក្នុងលោកខាងមុខ ការមិនកើតរូបនាមថ្មី ក្នុងលោកទាំង ពីរលក្ខណៈយ៉ាងនេះ ជាការរលត់ទុក្ខ កិលេសនិងទុក្ខក្នុងវដ្តសង្សារ ដែលហៅថា អនុបាទិសេសនិព្វាន គឺការរលត់ដោយមិនមានខន្ធ សេសសល់ ។

កាលព្រះមាលុក្យបុត្ត បានស្តាប់ព្រះធម្មទេសនានេះហើយ បានក្រាបទូលការយល់របស់ខ្លួនដល់ព្រះបរមសាស្តាថា

រូបំ ទិស្វា សតិ មុដ្ឋា បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ តញ្ច អជ្ឈោស តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា អនេកា រូបសម្ភវា
អភិជ្ឈា ច វិហេសា ច ចិត្តមស្សូបហញ្ញតិ
ឯវំ អចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ[២៧] ។

“កាលបុគ្គលឃើញរូបហើយ ធ្វើទុកក្នុងចិត្តដល់រូបនិមិត្ត ដែល

គួរស្រឡាញ់ សតិភ្លេចទៅហើយ គេមានចិត្តកំណាត់ដឹងស្រឡាញ់ សោយអារម្មណ៍នោះ ទាំងមានការជាប់ចិត្តក្នុងអារម្មណ៍នោះ វេទនាដែលកើតអំពីរូប សេចក្ដីល្មោភ និងការប្រទូសរាយ រមែងទ្វេឡើងជាការច្រើន ចិត្តរបស់គេរមែងត្រូវកគូនឲ្យក្ដៅក្រហាយ កាលគេសន្សំទុក្ខយ៉ាងនេះ បណ្ឌិតពោលថា នៅឆ្ងាយព្រះនិព្វាន ។

ពាក្យថា **រូបំ ទិស្វា សតិ មុដ្ឋា បិយំ និមិត្តំ មនសិករោតោ** ( កាលបុគ្គលឃើញរូបហើយធ្វើទុកក្នុងចិត្ត ដល់រូបនិមិត្ត ដែលគួរស្រឡាញ់ ភ្លេចសតិទៅហើយ ) មានន័យថា គេភ្លេចសតិមិនបានចម្រើនវិបស្សនាដែលទទួលដឹងសភាវធម៌ តាមសេចក្ដីពិតតែទៅទទួលដឹងរូបកងសណ្ឋាន ទើបមិនទទួលដឹងសភាវៈឃើញ ឬត្រឹមតែរូបដែលឃើញ និងមិនដឹងច្បាស់ ការមិនទៀង ជាទុក្ខ និងមិនមែនតួខ្លួន ។

ពាក្យថា **សារត្តចិត្តោ វេទេតិ** ( គេមានចិត្តកំណាត់ស្រឡាញ់ សោយអារម្មណ៍នោះ ) មានន័យថា គេពេញចិត្តវត្ថុ ដែលឃើញដោយសេចក្ដីលោភ មិនពេញចិត្តដោយសេចក្ដីក្រោធ ឬព្រងើយ

ដោយការវង្វេង ព្រះមាលុក្យបុត្រ ពោលដល់ការលោកតែម្យ៉ាង ដោយនិទស្សនន័យ គឺសំនួនដែលពោលល្មមជាតួយ៉ាង តែប្រាថ្នាឲ្យសំដៅដល់សេចក្ដីក្រោធ និងការវង្វេងទៀតផង ។

ពាក្យថា ឯវំ អចិនតោ ទុក្ខំ អារា និព្វាន វុច្ចតិ ( កាលគេសន្សំទុក្ខយ៉ាងនេះ បណ្ឌិតពោលថា នៅឆ្ងាយព្រះនិព្វាន ) មានន័យថា កាលគេមិនបានតាមដឹងសភាវៈឃើញ ក្នុងខណៈឃើញរមែងកើតកិលេសដែលដឹងត្រឹមលោក ក្រោធ វង្វេង វេទនាដែលជាប់ដោយវត្ថុដែលឃើញសេចក្ដីល្មោភ និងការប្រទូសរាយទើបឆ្ងាយពីព្រះនិព្វាន ។

ន សោ រជ្ជតិ រូបេសុ      រូបំ ទិស្វា បដិស្សតោ
វិរត្តចិត្តោ វេទេតិ      តញ្ច នាជ្ឈោស តិដ្ឋតិ ។
យថាស្ស បស្សតោ រូបំ      សេវតោ ចាបិ វេទនំ
ខីយតិ នោបចិយតិ      ឯវំ សោ ចរតិស្សតោ
ឯវំ អបចិនតោ ទុក្ខំ      សន្តិកេ និព្វាន វុច្ចតិ[២៤] ។

"បុគ្គលនោះឃើញរូបហើយ មានសតិមិនពេញចិត្តក្នុងរូបទាំងឡាយ មានចិត្តធូរស្រាលកំណត់ដឹងវេទនា តែមិនជាប់ចិត្តក្នុងអារម្មណ៍នោះ ទាំងមិនមានការជាប់ចិត្តក្នុងអារម្មណ៍នោះ កាលគេកំពុងឃើញរូបនិងកំពុងសោយវេទនា ទុក្ខរមែងអស់ទៅ មិនសន្សំទុក្ខទៀតយ៉ាងណា គេជាអ្នកមានសតិត្រាច់ទៅយ៉ាងនោះ កាលមិនសន្សំទុក្ខយ៉ាងនេះ បណ្ឌិតពោលថា នៅជិតព្រះនិព្វាន" ។

តអំពីនោះ ព្រះមាលុក្យបុត្រ បានក្រាបទូលដល់ការនៅជិតនិងឆ្ងាយនិព្វានក្នុងខណៈស្តាប់សម្លេងជាដើមទៀតផង កាលលោកក្រាបទូលដូច្នេះហើយ ព្រះអង្គត្រាស់អនុមោទនាសាធុការ ហើយត្រាស់ថា ការចំរើនវិបស្សនាដោយសង្ខេប ដែលតថាគតណែនាំនេះ លោកបានអធិប្បាយទុកល្អហើយ ចូរទ្រទ្រង់ចាំទុកយ៉ាងនេះ តមកព្រះមាលុក្យបុត្រ បានបដិបត្តិតាមវិបស្សនានយ័ ដែលព្រះអង្គត្រាស់ទុក ហើយសម្រេចធម៌ជាព្រះអរហន្តមួយរូបក្នុងព្រះសាសនា រឿងនេះប្រាកដក្នុងមាលុក្យបុត្តសូត្រ[២៩] ។

អ្នកដែលផ្តើមចំរើនវិបស្សនាភាវនា កាលវិបស្សនាញាណមាន

កម្លាំងខ្សោយ អាចកើតកិលេសកាលកំណត់ថា "ឃើញហ្ន៎"បានខ្លះ ចូរកុំមានចិត្តរញ៉េរញ៉ៃ គួរកំណត់កិលេស ដែលកើតឡើងនោះថា "ចូលចិត្តហ្ន៎ៗ" ឬ"ក្រោធហ្ន៎ៗ" តាមសភាវៈនោះៗ ហើយលះសេចក្តីចូលចិត្ត ឬសេចក្តីក្រោធ ដោយការតាមដឹងសភាវធម៌ក្នុងបច្ចុប្បន្នខណៈ ការចម្រើនវិបស្សនាលះកិលេសនេះ ត្រូវសន្សំម្តងៗ សន្សំទុកម្តងបន្តិចៗ ដូចការសន្សំពិន្ទុទៅរឿយៗ ឬដូចការបោកខោអាវ ដែលត្រូវដុសញីច្រើនគ្រាទើបស្អាត មិនមែនញីត្រឹមមួយគ្រា ការបដិបត្តិធម៌ក៏ដូចគ្នា ក្នុងការបោកខោអាវ អាចដឹងបានថាសំពត់ស្អាតឡើងច្រើនត្រឹមណា ដោយការញីម្តងមួយគ្រា តែការលះកិលេសដោយវិបស្សនា មិនអាចដឹងថា ខ្លួនលះកិលេសបានច្រើនតិចត្រឹមណា បន្ទាប់ពីសម្រេចមគ្គផលហើយ ទើបនឹងជ្រាបថា ខ្លួនលះកិលេស បានច្រើនតិចប៉ុណ្ណោះ ។

ព្រះបរមសាស្តាត្រាស់ឧបមារឿងនេះ ទុកក្នុងសំយុត្តនិកាយ ខន្ធវគ្គ[៣០]ថា ដូចកាំបិតរបស់ជាងឈើម្នាក់ ពេលគឺជាងប្រើកាំបិតម្នាក់ការងារសិល្បកម្មផ្សេងៗ ជាប្រចាំរាល់ថ្ងៃ គេមិនដឹងថា ដងកាំបិតសឹករិចរិលទៅច្រើនតិចត្រឹមណា បន្ទាប់ពីកន្លងទៅយូររាប់ខែរាប់ឆ្នាំ រហូត

ទាំងប្រាកដស្នាមដៃលើដងកាំបិត កាលនោះទើបបានដឹងថា កាំបិតសឹករិចរិល អ្នកបដិបត្តិ ក៏ប្រៀបដូចជាងថ្វាក់ដូច្នោះដូចគ្នា ។

ម្យ៉ាងទៀត សូម្បីនៅមិនទាន់សំរេចមគ្គផល ក្នុងខណៈខ្លះដែលវិបស្សនាញាណចាស់ក្លា មានកម្លាំងច្រើនក្នុងវិថីចិត្តដែលកើតឡើងយ៉ាងបន្តបន្ទាប់គ្នា ដែលមានទូវកុសលជវនចិត្ត ជាចំណែកធំ អកុសលជវនចិត្ត សឹងតែនឹងមិនកើតឡើង ឬកាលកើតឡើងក្នុងគ្រាខ្លះ អ្នកបដិបត្តិអាចនឹងតាមដឹងបានភ្លាម ក្នុងខណៈនោះកិលេស រមែងស្ងប់ទៅមិនរំខានចិត្តជាពេលយូរ ដូចសេចក្តីក្នុងអដ្ឋកថារបស់សំយុត្តនិកាយថា

ទន្ធា ភិក្ខវេ សតុប្បាទោតិ សតិយា ឧប្បាទោយេវ ទន្ធោ ។ ឧប្បន្នមត្តាយ បន តាយ កេចិ កិលេសា និគ្គហិតាវ ហោន្តិ, ន សណ្ឋាតុំ សក្កោន្តិ ។ ចក្ខុទ្វារស្មឹ ហិ រាគាទីសុ ឧប្បន្នេសុ ទុតិយជវនវារេ "កិលេសា មេ ឧប្បន្នា"តិ ញត្វា តតិយេ ជវនវារេ សំវរជវនំយេវ ជវតិ ។ អនច្ឆរិយញ្ចេតំ, យំ វិបស្សកោ តតិយជវនវារេ កិលេសេ និគ្គណ្ហេយ្យ ។ ចក្ខុទ្វារេ

បទ ឥដ្ឋារម្មណេ អាបាថគតេ ភវង្គំ អាវដ្ដេត្វា អាវជ្ជនាទីសុ ឧប្បន្នេសុ វោដ្ឋព្វនានន្តរំ សម្បត្តកិលេសជវនភាវំ និវត្តេត្វា កុសលមេវ ឧប្បាទេតិ ។ អារទ្ធវិបស្សកានំ ហិ អយមានិសំសោ ភាវនាបដិសង្ខារេ បតិដ្ឋិតភាវស្ស[៣១] ។

“ព្រះតម្រាស់ជាដើមថា ម្នាលភិក្ខុទាំងឡាយ ការកើតសតិយឺតយូរ មានន័យថា ការកើតឡើងនៃសតិជាការយឺត តែកាលសតិកើតឡើងហើយ កិលេសខ្លះម្យ៉ាង រមែងត្រូវទប់បានដោយពិតមិនអាចតាំងនៅបាន ពោលគឺកាលរាគៈជាដើម កើតផ្លូវចក្ខុទ្វារ ហើយកាលបុគ្គលដឹងថា កិលេសកើតហើយដល់យើង ក្នុងជវនវារៈទី ២ ជវនវារៈដែលសង្រួម រមែងធ្វើចលនាទៅក្នុងជវនវារៈ ទី ៣ ម្យ៉ាងទៀត ការដែលអ្នកចម្រើនវិបស្សនាគប្បីទប់កិលេសក្នុងជវនវារៈទី ៣ ឬញ៉ាំងកុសលជវនៈឲ្យកើតឡើងដោយហាមអកុសលជវនវារៈ ដែលកើតតអំពីវោដ្ឋព្វនចិត្ត កាលអាវជ្ជនចិត្តជាដើមកើតឡើងកាត់ក្រសែភវង្គ ក្នុងខណៈដែលឥដ្ឋារម្មណ៍មកប្រាកដផ្លូវចក្ខុទ្វារនោះ មិនគួរអស្ចារ្យ ដោយពិតហើយ សេចក្ដីនេះជាអានិសង្សរបស់ការស្ថិតនៅក្នុងភាវនា ដែលតាក់តែងចិត្តរបស់

លោកអ្នកប្រាជ្ញវិបស្សនាទាំងឡាយ" ។

ទីងឃើញបានថា អ្នកដែលកើតវិបស្សនាញាណយ៉ាងកណ្ដាល តាំងអំពីញាណ ៤ គឺ ឧទយព្វយញាណជាដើមទៅ អាចហាមឃាត់ អកុសលជវនៈ ដែលកើតផ្លូវចក្ខុទ្វារជាដើម ហើយញុំាងឲ្យកើត កុសលជវនៈក្នុងវិថីចិត្តទី៣ ជាដើមទៅ និងកាលវិបស្សនាញាណ មានកម្លាំងចាស់ក្លាឡើងហើយ អ្នកបដិបត្តិអាចញុំាងឲ្យកើតកុសល ជវនចិត្តយ៉ាងបន្តបន្ទាប់ ដោយមិនមានអកុសលជវនចិត្តកើតរាំង ក្នុងខណៈខ្លះ អាចកើតវោដ្ឋព្វនចិត្តប៉ុណ្ណោះ ក្នុងខណៈទទួលដឹង សភាវៈឃើញជាដើម ដូចសេចក្ដីថា

ពលវវិបស្សកស្ស សចេបិ ចក្ខុទ្វារាទីសុ អារម្មណេ អាបា-ថគតេ អយោនិសោ អាវជ្ជនំ ឧប្បជ្ជតិ ។ វោដ្ឋព្វនំ បត្វា ឯកំ ទ្វេ វារេ អាសេវនំ លភិត្វា ចិត្តំ ភវង្គមេវ ឱតរតិ, ន រាគាទិវសេន ឧប្បជ្ជតិ ។ អយំ កោដិប្បត្តោ តិក្ខវិបស្សកោ ។ អបរស្ស រាគា-ទិវសេន ឯកំ វារំ ជវនំ ជវតិ ។ ជវនបរិយោសានេ បន "រាគាទិវសេន ឯវំ មេ ជវនំ ជវិតន្តិ អាវជ្ជតោ អារម្មណំ

បរិគ្គហិតមេវ ហោតិ ។ បុន វារំ តថា ន ជវតិ។ អបរស្ស ឯកវារំ ឯវំ អាវជ្ជតោបិ បុន ទុតិយវារំ រាគាទិវសេន ជវនំ ជវតិយេវ ។ ទុតិយវារាវសានេ បន "ឯវំ មេ ជវនំ ជវិតន្តិ អាវជ្ជតោ អារម្មណំ បរិគ្គហិតមេវ ហោតិ ។ តតិយវារេ តថា ន ឧប្បជ្ជតិ[៣២] ។

"ពោលដោយពិស្តារ សូម្បីកាលអារម្មណ៍ ប្រាកដផ្លូវចក្ខុទ្វារជាដើមដល់អ្នកចម្រើនវិបស្សនាលំដាប់ចាស់ក្លា [អ្នកសម្រេចនូវញាណ ៤ ជាដើមទៅ] អាវជ្ជនចិត្ត រមែងកើតឡើងដោយមិនសមរម្យ ចិត្តដល់សេចក្តីជាវោដ្ឋព្វនៈហើយ បានទទួលការទម្លាប់សេពមួយ ឬពីរគ្រាហើយចុះកាន់ភវង្គ រមែងមិនកើត [កិលេស] ដោយអំណាចរបស់រាគៈជាដើម បុគ្គលនេះ ជាអ្នកចម្រើនវិបស្សនាយ៉ាងចាស់ក្លាដល់ទីបំផុត តែបុគ្គលដទៃពីនេះ [អ្នកចម្រើនវិបស្សនាលំដាប់កណ្តាល] ជវនចិត្ត រមែងធ្វើចលនាទៅមួយគ្រា ដោយអំណាចរាគៈជាដើម តែក្នុងទីបំផុតរបស់ជវនចិត្ត កាលរិះគិតថា ជវនៈរបស់យើង ប្រព្រឹត្តទៅហើយយ៉ាងនេះ ដោយអំណាចរាគៈជាដើម រមែងជាការកំណត់ដឹងអារម្មណ៍បានដោយពិត ជវនៈ

រមែងមិនប្រព្រឹត្តទៅយ៉ាងនោះទៀត ក្នុងវារៈតមកនិងក្នុងបុគ្គលដទៃ [ អ្នកចម្រើនវិបស្សនាលំដាប់ទាប ] កាលវិះគិតយ៉ាងនេះមួយគ្រា ជវនៈរមែងប្រព្រឹត្តទៅ ដោយអំណាចរាគៈជាដើម ក្នុងគ្រាទី ២ ទៀត តែក្នុងទីបំផុតរបស់គ្រាទី ២ កាលវិះគិតថា ជវនៈរបស់យើងប្រព្រឹត្តទៅហើយយ៉ាងនេះ រមែងជាការកំណត់ដឹងអារម្មណ៍បានតែម្តង ជវនៈរមែងមិនប្រព្រឹត្តទៅយ៉ាងនោះទៀតក្នុងវារៈទី ៣" ។

បុគ្គលដែលពោលដល់នេះ មាន ៣ ជំពូកគឺ បុគ្គលអ្នកចម្រើនវិបស្សនាលំដាប់ចាស់ក្លា ( **ពលវវិបស្សកៈ** ) បុគ្គលអ្នកចម្រើនវិបស្សនាលំដាប់កណ្តាល ( **មជ្ឈិមវិបស្សកៈ** ) និងបុគ្គលអ្នកចម្រើនវិបស្សនាលំដាប់ទាប ( **មន្ទវិបស្សកៈ** ) ន័យម្យ៉ាងទៀត បុគ្គលប្រភេទដំបូង ជាអ្នកចំរើនវិបស្សនាលំដាប់ចាស់ក្លាថ្នាក់ខ្ពស់ បុគ្គលប្រភេទទី ២ ជាអ្នកចំរើនវិបស្សនាលំដាប់ចាស់ក្លាថ្នាក់កណ្តាល បុគ្គលប្រភេទទី ៣ ជាអ្នកចំរើនវិបស្សនាលំដាប់ចាស់ក្លាថ្នាក់ទាប ។

បុគ្គលប្រភេទទី ៣ សូម្បីនឹងកំណត់កិលេសដែលកើតផ្លូវចក្ខុទ្វារជាដើមមួយគ្រា ក៏នៅកើតកិលេសក្នុងជវនចិត្តទៀត តមកកាល

កំណោត់ដឹងមួយគ្រាទៀត ទឹងអាចលះកិលេសបាន ធ្វើឲ្យកើតកុស-
លជវនៈ ឬ វិបស្សនាជវនៈ ក្នុងវិថីចិត្តនោះ បុគ្គលប្រភេទទី ២
បានពោលទុកហើយ ចំណែកបុគ្គលប្រភេទដំបូងកាលជួបជាមួយ
អារម្មណ៍ដែលនាំឲ្យស្រឡាញ់ ឬស្អប់ក៏កើតអាវជ្ជនចិត្ត ដែលប្រកប
ដោយអយោនិសោមនសិការ តែអាវជ្ជនចិត្តនោះ មានកម្លាំងតិច
ដោយអានុភាពរបស់វិបស្សនា ដែលចម្រើនមកក្នុងវិថីចិត្តមុន ៗ
ដូច្នោះ បញ្ចវិញ្ញាណចិត្ត សម្បដិច្ឆន្នចិត្ត និងសន្តីរណចិត្ត ទើប
ទទួលយកអារម្មណ៍នោះ បានមិនជាក់ច្បាស់ តមកវោដ្ឋព្វនចិត្ត
ទើបកើតឡើង ២ ឬ ៣ គ្រា ដោយការពិចារណាមិនកាត់ចិត្ត
សម្រេចថា ជាអារម្មណ៍ដែលគួរស្រឡាញ់ឬគួរស្អប់ ព្រះអដ្ឋកថា-
ចារ្យ ទើបពោលទុកក្នុងគម្ពីរអដ្ឋកថាខាងដើមថា បានទទួលការ
ទម្លាប់សេព ( **អាសេវនំ លភិត្វា** ) ដោយសំដៅដល់លំដាប់ចិត្ត
ដែលកើតឡើងក្នុងពេល ខាងក្រោយយ៉ាងនេះ តែមិនបានសំដៅ
ដល់អាសេវនបច្ច័យ និង អាសេវនបច្ចយុប្បន្នៈ បន្ទាប់អំពីនោះ
ភវង្គចិត្តរមែងកើតឡើង ដោយមិនកើតជវនចិត្ត ព្រោះមិនមាន
សភាពកាត់ចិត្តសម្រេចអារម្មណ៍ថា គួរស្រឡាញ់ឬគួរស្អប់ សូម្បី

ក្នុងមនោទ្វារវិថី ក៏កើតរៀងតួនចិត្តប្រភេទនេះដែរ ។

ម្យ៉ាងទៀត ក្នុងខណៈកើតវិថីចិត្តដូចពោល អ្នកបដិបត្តិនឹងដឹងត្រឹមថា អារម្មណ៍ដែលទទួលដឹងមិនប្រាកដច្បាស់ ត្រឹមប្រាកដថា ត្រឹមតែឃើញ បានឮ ឬនឹកគិតប៉ុណ្ណោះ ចាត់ថាជាមនោទ្វារវិបស្សនាដែលកំណត់ដឹងសភាវៈឃើញជាដើម ដោយមិនប្រចក្សទាំងកុសលជវនៈ និងអកុសលជវនៈ ក៏មិនកើតឡើងតាមបញ្ចទ្វារមានត្រឹមវិបស្សនាជវនៈកើតផ្លូវមនោទ្វារ ការមិនកើតជវនចិត្តក្នុងវិថីដំបូង ព្រោះមានអារម្មណ៍មិនជាក់ច្បាស់ ការកើតវិបស្សនាជវនៈដែលប្រកបដោយតត្រមជ្ឈត្តតា ដែលញ៉ាំងឥន្ទ្រីយ៍ឲ្យស្មើគ្នាក្នុងមនោទ្វារវិថីទី ២ នេះ រមែងប្រាកដក្នុងខណៈដែលវិបស្សនាញាណទី ១១ គឺ សង្ខារុបេក្ខាញាណចាស់ក្លាដល់អ្នកបដិបត្តិ អ្នកដែលសម្រេចដល់ញាណលំដាប់នេះ រមែងជួបហេតុការណ៍យ៉ាងនេះក្នុងខណៈនោះ សូម្បីជាបុថុជ្ជន ក៏ជាអ្នកដល់ព្រមដោយឆឡង្គុបេក្ខា គឺ ឧបេក្ខាមានអង្គ ៦ ដូចសេចក្ដីក្នុងអង្គុត្តរនិកាយថា

*សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បដិកូលញ្ច អប្បដិកូលញ្ច*

តត្រាយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យ សតោ សម្បជានោ[៣៣] ។

“ភិក្ខុគប្បីវៀរវត្ថុទាំងពីរគឺ វត្ថុបដិកូលនិងវត្ថុមិនបដិកូលហើយ ជាអ្នកមានការព្រងើយ មានសតិសម្បជញ្ញៈនៅក្នុងគ្រាខ្លះ ការនៅយ៉ាងនោះជាការល្អ” ។

[ឆឡង្គុបេក្ខា គឺ ឧបេក្ខាមានអង្គ ៦ សំដៅសេចក្ដីថា ការព្រងើយមិនត្រេកអរ មិនរីករាយ ក្នុងអារម្មណ៍ ៦ ដែលមកប្រាកដផ្លូវទ្វារទាំង ៦ អង្គធម៌បានដល់ តត្រមជ្ឈត្តតាចេតសិក] ។

គម្ពីរអដ្ឋកថារបស់អង្គុត្តរនិកាយអធិប្បាយថា

ឆឡង្គុបេក្ខាវសេន បញ្ចមោ ។ ឆឡង្គុបេក្ខា បេសា ខីណាសវស្ស ឧបេក្ខាសទិសា ។ ន បន ខីណាសវុបេក្ខា ។ប។ ឥមស្មឹ សុត្តេ បញ្ចសុ ឋានេសុ វិបស្សនាវ កថិតា ។ តំ អារទ្ធវិបស្សកោ កាតុំ សក្កោតិ[៣៤] ។

“ភាវៈទី៥ ត្រាស់ទុកដោយឆឡង្គុបេក្ខា ម្យ៉ាងទៀត ឆឡង្គុបេក្ខានេះ ស្រដៀងជាមួយឧបេក្ខារបស់ព្រះខីណាស្រព.. តែមិនមែនឧបេក្ខារបស់ព្រះខីណាស្រព ព្រះបរមសាស្ដាត្រាស់វិបស្សនាក្នុងឋានៈទាំង

៥ ទុកក្នុងព្រះសូត្រនេះដោយពិត អ្នកដែលប្រារព្ធវិបស្សនា [តាំង អំពីញាណ ៤ ជាដើមទៅ] រមែងចំរើនវិបស្សនានោះបាន" ។

[ពាក្យថា អារទ្ធវិបស្សកៈ ( អ្នកដែលប្រារព្ធវិបស្សនា ) ដែល ប្រើក្នុងអដ្ឋកថានិងដីកា សំដៅដល់អ្នកដែលសំរេចវិបស្សនាញាណ ថ្នាក់ទី ៤ ជាដើមទៅ ដូចសាធកៈក្នុងអដ្ឋកថានិងដីកាថា

ឯត្ថ ហិ សម្មុញ្ចតិ អារទ្ធវិបស្សកតោ

បដ្ឋាយ យោគាវចរោតិ សាម្នោធិ[៣៥] ។

"ព្រះយោគាវចរ រមែងដឹងតាំងពីផ្តើមប្រារព្ធវិបស្សនា ទើបឈ្មោះ ជា សាម្នោធិ" ។

ឧទយព្វយញាណុប្បត្តិតោ បដ្ឋាយ សាម្នោធិបដិបទាយំ ឋិតោ នាម ហោតីតិ អាហ អារទ្ធវិបស្សកតោ បដ្ឋាយ យោគាវចរោតិ សាម្នោធីតិ[៣៦] ។

"ព្រះយោគាវចរឈ្មោះថា ស្ថិតនៅក្នុងបដិបទាដឹងតាំងពីការឧប្បត្តិ នៃបញ្ញាដែលយល់ឃើញការកើតឡើង និងរលត់ទៅ ដូច្នោះ ព្រះអដ្ឋក-ថាចារ្យ ទើបពោលថា អារទ្ធវិបស្សកតោ បដ្ឋាយ យោគាវចរោតិ សាម្នោធិ ( ព្រះយោគាវចររមែងដឹងតាំងពីផ្តើម ប្រារព្ធវិបស្សនា ទើប

ឈ្មោះថា សម្ពោធិ )"] ។

សូម្បីអដ្ឋថា របស់មជ្ឈិមនិកាយ ក៏អធិប្បាយទុកថា

ឧបេក្ខា កុសលនិស្សិតា សណ្ឋាតីតិ ឥធ ឆឡង្គុបេក្ខា ។ សា បនេសា កិញ្ចាបិ ខីណាសវស្ស ឥដ្ឋានិដ្ឋេសុ អារម្មណេសុ អរជ្ជនាទិវសេន បវត្តតិ ។ អយំ បន ភិក្ខុ វីរិយពលេន ភាវនា-សិទ្ធិយា អត្តនោ វិបស្សនំ ខីណាសវស្ស ឆឡង្គុបេក្ខាឋានេ ឋបេតីតិ វិបស្សនាវ ឆឡង្គុបេក្ខា នាម ជាតា[៣២] ។

"ឧបេក្ខាក្នុងព្រះតម្រាស់នេះថា ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ ( ឧបេក្ខដែលអាស្រ័យកុសលរមែងតាំងនៅ ) សំដៅដល់ឆឡង្គុបេក្ខា ម្យ៉ាងទៀត ឧបេក្ខានោះ សូម្បីកើតឡើងដល់ព្រះខីណាស្រព ដោយប្រាសចាកសេចក្ដីត្រេកអរពេញចិត្ត ក្នុងអារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា តែភិក្ខុនេះ រមែងតាំងវិបស្សនារបស់ខ្លួន ទុកក្នុងឋានៈឆឡង្គុបេក្ខារបស់ព្រះខីណាស្រព ព្រោះភាវនាសម្រេចហើយដោយកម្លាំងនៃវីរិយៈ ដូចនោះ វិបស្សនាទើបបានឈ្មោះថា ឆឡង្គុបេក្ខា" ។

## រឿងព្រះពោដ្ឋិលៈ

ការតាមដឹងសភាវៈបច្ចុប្បន្ន ដោយមិនឲ្យកើតជវនៈផ្លូវបញ្ចទ្វារនេះ ប្រៀបដូចសត្វទន្សង ដែលសាមណេរតូចមួយរូប ពោលបង្រៀនដល់ព្រះពោដ្ឋិលៈទុក ដូចមានរឿងរ៉ាវថា

សម័យពុទ្ធកាល មានព្រះថេរៈមួយរូបឈ្មោះថា **ព្រះពោដ្ឋិលៈ** ធ្លាប់បានបួសរៀន ទ្រទ្រង់ចាំព្រះត្រៃបិដក និងបង្រៀនបរិយត្តិធម៌ ក្នុងសម័យព្រះសម្មាសម្ពុទ្ធ ៦ ព្រះអង្គ មានព្រះវិបស្សីជាដើម សូម្បីក្នុងជាតិនេះ លោកក៏បួសរៀនទ្រទ្រង់ចាំព្រះត្រៃបិដកដូចគ្នា តែនៅមិនបានសម្រេចគុណធម៌វិសេសជាព្រះអរិយបុគ្គល ថ្ងៃមួយព្រះសម្មាសម្ពុទ្ធត្រាស់ហៅលោកថា **តុច្ឆពោដ្ឋិលៈ** ( ភិក្ខុគម្ពីរទទេ ) ទើបកើតការស្លុតចិត្តត្រិះរិះថា សូម្បីលោកបានបង្រៀនព្រះត្រៃបិដកដល់ភិក្ខុទាំងឡាយ ៥០០ រូបជាប់ជានិច្ច តែនៅមិនបានសម្រេចឈាន ឬមគ្គផល ព្រះសម្មាសម្ពុទ្ធត្រាស់ហៅដូច្នោះ លោកទើបសម្រេចចិត្តចេញដើរផ្លូវទៅអំពីវត្តជេតពន្ធចម្ងាយប្រវែង ១២០ យោជន៍ ( ប្រមាណ ១,៩២០ គីឡូម៉ែត្រ ) ដើម្បីបដិបត្តិធម៌ លុះដល់វត្តព្រៃមួយកន្លែងដែលមានព្រះអរហន្ត ៣០ រូប លោកបាន

សូមកម្មដ្ឋានទឹងព្រះមហាថេរៈ តែដើម្បីឲ្យលោកបន្ថយចុះមានៈក្នុងការដឹងដែលមាន ព្រះមហាថេរៈ ទើបឲ្យលោកទៅសូមកម្មដ្ឋានទឹងព្រះថេរៈរូបទី ២ ព្រះថេរៈនោះ ក៏ឲ្យទៅសូមទឹងព្រះថេរៈមួយរូបទៀត ដែលបានណែនាំឲ្យទៅសូមកម្មដ្ឋានអំពីព្រះថេរៈរូបដទៃៗ ទៀតរហូតដល់សាមណេរតូចអាយុ ៧ ឆ្នាំ លោកក៏ប្រណម្យដៃសូមកម្មដ្ឋានអំពីសាមណេរតូច ។

សាមណេរតូចបានឆ្លើយថា ខ្ញុំព្រះករុណាអាយុនៅតិច ការសិក្សាក៏តិច នៅត្រូវយល់ដឹងអំពីលោកម្ចាស់ច្រើនទៀត ទើបបង្រៀនលោកមិនបាន តែព្រះបោដ្ឋិលៈ បញ្ជាក់ច្បាស់ថា ទឹងសូមកម្មដ្ឋានអំពីសាមណេរតូច និងនិយាយថា ទឹងបដិបត្តិតាមដែលបង្រៀនគ្រប់យ៉ាង សាមណេរទើបសាកល្បងដោយប្រាប់ឲ្យដើរចុះទៅក្នុងទឹក លុះមចុងចីវររបស់លោកទទឹក ក៏ឲ្យលោកឡើងអំពីទឹក ហើយឲ្យកម្មដ្ឋានថា

"លោកម្ចាស់ ដំបូកកណ្តៀរមួយកន្លែងមានរន្ធ ៦ កន្លែង បើលំពាកទឹងចាប់សត្វទន្សងក្នុងដំបូកកណ្តៀរឲ្យបិទរន្ធ ៥ កន្លែង

ហើយរងចាំចាប់ក្នុងរន្ធមួយដ៏សេស ការបដិបត្តិធម៌ក៏ដូចគ្នា កាល អារម្មណ៍ ៦ មកប្រាកដផ្លូវទ្វារ ៦ បុគ្គលគប្បីបិទទ្វារ ៥ ហើយ បើកទ្វារចិត្តត្រឹមតែមួយកន្លែង" ។

ពាក្យថា "បិទទ្វារ ៥" សំដៅដល់ការមិនឲ្យកើតជវនចិត្ត ក្នុងទ្វារទាំងនោះ មិនបានសំដៅដល់ ការមិនមើល ឬមិនស្តាប់ ព្រោះ មិនអាចហាមការមើល ឬការស្តាប់ផ្លូវទ្វារបាន សូម្បីនឹងបិទភ្នែក ឬបិទត្រចៀកមិនឲ្យឃើញ និងបានឮក៏រកប្រយោជន៍មិនបាន ដូច សេចក្តីក្នុងឥន្ទ្រិយភាវនាសូត្រថា

**ឯវំ សន្តេ ខោ ឧត្តរ អន្ធោ ភាវិតិន្ទ្រិយោ ភវិស្សតិ ។ ពធិរោ ភាវិតិន្ទ្រិយោ ភវិស្សតិ ។ យថា បារាសិរិយស្ស ព្រាហ្មណស្ស វចនំ ។ អន្ធោ ហិ ឧត្តរ ចក្ខុនា រូបំ ន បស្សតិ ។ ពធិរោ សោតេន សទ្ទំ ន សុណាតិ[៣៨] ។**

"ម្នាលឧត្តរៈ បើការមិនមើល មិនស្តាប់ ជាវិធីអប់រំឥន្ទ្រីយ៍ យ៉ាងនោះ មនុស្សភ្នែកខ្វាក់ក៏នឹងអប់រំឥន្ទ្រីយ៍បាន មនុស្សត្រចៀក ថ្លង់ ក៏នឹងអប់រំឥន្ទ្រីយ៍បានតាមពាក្យរបស់ព្រាហ្មណ៍ បារាសិរិយៈ

ព្រោះមនុស្សភ្នែកខ្វាក់ឃើញរូបដោយភ្នែកមិនបាន មនុស្សត្រចៀកថ្លង់ ឮសម្លេងដោយត្រចៀកមិនបាន" ។

ក្រៅអំពីនេះ ក្នុងឥន្ទ្រិយភាវនាសូត្រ[៣៩] និងក្នុងព្រះសូត្រដទៃទៀត[៤០] ព្រះសម្មាសម្ពុទ្ធត្រាស់ដល់ការសង្រួមទ្វារកាលទទួលដឹងអារម្មណ៍ ៦ ដោយព្រះតម្រាស់ថា **ចក្ខុនា រូបំ ទិស្វា** ( ឃើញរូបដោយចក្ខុហើយ ), **សោតេន សទ្ទំ សុត្វា** ( ស្តាប់សម្លេងដោយត្រចៀកហើយ ) ជាដើម មិនបានត្រាស់ដល់ការសង្រួមដោយនៅមិនទទួលអារម្មណ៍ ៦ ដូចនោះ ការសង្រួមដូចពោល ទើបសំដៅដល់ការមិនកើតជវនចិត្តក្នុងបញ្ចទ្វារ ។

ពាក្យថា "បើកទ្វារចិត្ត" សំដៅដល់ ការឲ្យកើតវិបស្សនាជវនចិត្តផ្លូវមនោទ្វារនោះឯង ។

កាលព្រះបោដ្ឋិលៈបានស្តាប់ពាក្យបង្រៀននេះ ក៏កើតការយល់យ៉ាងជាក់ច្បាស់ ដូចជួបដួងប្រទីបក្នុងភាពងងឹត ក្នុងខណៈនោះព្រះបរមសាស្តាទ្រង់ប្រថាប់នៅចម្ងាយ ១២០ យោជន៍ បានសម្តែង

ព្រះអង្គឃើញច្បាស់ដូចប្រថាប់នៅចំពោះមុខ ហើយត្រាស់ព្រះគាថា ក្នុងគម្ពីរធម្មបទថា

យោគា វេ ជាយតេ ភូរិ អយោគា ភូរិសង្ខយោ
ឯតំ ទ្វេធា បថំ ញត្វា ភវាយ វិភវាយ ច
តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ[៤១] ។

"ប្រាជ្ញា រមែងកើតពីការប្រកប សេចក្តីវិនាសប្រាជ្ញា រមែងកើតពីការមិនប្រកប អ្នកមានប្រាជ្ញា ដឹងការប្រកប នឹងការមិនប្រកប ទាំងពីរនេះថា ជាគន្លងនៃសេចក្តីចម្រើននឹងសេចក្តីវិនាស ហើយប្រាជ្ញាចម្រើនឡើង ដោយប្រការណា គួរដំកល់ខ្លួនទុក ដោយប្រការនោះ" ។

ព្រះបោដ្ឋិលៈ បានសម្រេចអរហត្តផល កាលស្តាប់ព្រះធម៌ទេសនានេះចប់ សេចក្តីនេះពោលទុកក្នុងអដ្ឋកថានៃគម្ពីរធម្មបទ[៤២]។

[កន្លែងខ្លះអាងរឿងព្រះបោដ្ឋិលៈ ហើយសរុបថា ការសិក្សាបរិយត្តិធម៌ មិនសំខាន់ស្មើការបដិបត្តិធម៌ ពិតហើយ ការសិក្សាបរិយត្តិធម៌ដូចការអានផែនទីដើរផ្លូវ បើមិនមានផែនទីក៏អាចដើរខុសផ្លូវបាន សូម្បីនឹងព្រមទទួលថា សតិប្បដ្ឋានជាផ្លូវមួយត្រោះទៅកាន់ការរួចផុតបាកទុក្ខ តែ

បើមិនយល់វិធីចំរើនសតិប្បដ្ឋានយ៉ាងត្រឹមត្រូវហើយ ទីងបដិបត្តិធម៌បាន យ៉ាងណា ក្រៅពីនេះ ការដែលព្រះបុដ្ឋិលៈទ្រទ្រង់ចាំ និងបង្រៀនព្រះត្រៃបិដកអស់កាលយូរ សម្តែងថា លោកក៏ឧស្សាហ៍ព្យាយាមបដិបត្តិធម៌ ដើម្បីការសំរេចធម៌ពិតប្រាកដ កាលដល់ពេលដែលបារមីចាស់ក្លា ព្រះអង្គទើបហៅយ៉ាងនោះ ដើម្បីឲ្យលោកសង្វេគចិត្ត ដំកល់ទុកបរិយត្តិធម៌ ហើយប្រាថ្នាចំពោះការបដិបត្តិយ៉ាងពិតប្រាកដ មិនបានជាការសម្តែងថា ការសិក្សាបរិយត្តិធម៌មិនសំខាន់] ។

### ការប្រាកដរបស់រូបនិងនាម

ក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា

**ឯវំ សុវិសុទ្ធរូបបរិគ្គហស្ស បនស្ស អរូបធម្មា តីហិ អាកា-រេហិ ឧបដ្ឋហន្តិ ផស្សវសេន វា វេទនាវសេន វា វិញ្ញាណវសេន វា**[៤៣] ។

“ម្យ៉ាងទៀត កាលអ្នកបដិបត្តិនោះ កំណត់ដឹងរូបយ៉ាងជាក់ច្បាស់ដូច្នេះ នាមធម៌រមែងប្រាកដដោយអាការៈ ៣ ប្រការដោយសេចក្តីជា ផស្សៈ វេទនា ឬ វិញ្ញាណ” ។

អ្នកបដិបត្តិដែលតាមដឹងរូបធម៌យ៉ាងជាក់ច្បាស់ ទាំងឃើញលក្ខណៈរបស់រូបធម៌ ហើយនាមធម៌ដែលកើតផ្លូវចក្ខុទ្វារជាដើម រមែងប្រាកដច្បាស់ដល់គេ ដោយផស្សៈខ្លះ វេទនាខ្លះ វិញ្ញាណចិត្តខ្លះ ដូចកាលអ្នកបដិបត្តិបានទទួលដឹងសភាវធម៌ រឹងឬទន់របស់បឋវីធាតុហើយ ក្នុងខណៈខ្លះអាចទទួលដឹងផស្សៈ គឺ ការប៉ះខ្ទប់ជាមួយនឹងភាព រឹងឬទន់ ខណៈខ្លះអាចទទួលដឹងវេទនា គឺការដឹងត្រឹមសុខឬទុក្ខ ខណៈខ្លះអាចដឹងវិញ្ញាណចិត្ត ដែលទទួលដឹងភាពរឹងឬទន់ យ៉ាងណាក៏ដោយ កាលទទួលដឹងផស្សៈក៏រាប់ថា ទទួលដឹងនាមធម៌ដទៃ គឺវេទនា សញ្ញា សង្ខារ និងវិញ្ញាណទៀតផង ព្រោះនាមធម៌ទាំងនេះកើតព្រមគ្នាដូចមានខ្សែ ៥ សសៃចងជាប់គ្នា មួយសសៃងើបឡើងលើទឹក ៤សសៃទៀតលិចនៅក្នុងទឹក កាលទាញខ្សែដែលនៅលើទឹកមក ខ្សែសសៃដទៃក៏ជាប់តាមមកផង យ៉ាងណា ផស្សៈដូចខ្សែដែលនៅលើទឹក វេទនាជាដើមដូចខ្សែដែលនៅក្នុងទឹក ការទាញខ្សែដែលប្រាកដហើយ មានខ្សែដែលមិនប្រាកដជាប់មកផង ដូចការកំណត់ផស្សៈដែលប្រាកដច្បាស់ហើយរាប់ថា បានតាមដឹងវេទនាជាដើមដោយអម ដូចសាធកៈពោលថា

តេនស្ស ផុសនាការេន សុបាកដភាវេន ឧបដ្ឋានំ ទស្សេតិ ។ ផស្សេ បន ឧបដ្ឋិតេ យស្មឹ អារម្មណេ សោ ផស្សោ, តស្ស អនុភវនលក្ខណា វេទនា, សញ្ជាននលក្ខណា សញ្ញា, អាយូហ-នលក្ខណា ចេតនា, វិជាននលក្ខណំ វិញ្ញាណន្តិ ឥមេបិ បាកដា ហោតិ[៤៤] ។

“ព្រះអដ្ឋកថាចារ្យ សម្តែងសេចក្តីឃើញច្បាស់ដោយការប្រាកដច្បាស់ដោយអាការៈប៉ះខ្ទប់របស់ផស្សៈ ដោយពាក្យដែលសម្តែងថា ផស្សៈប្រាកដយ៉ាងណាក៏ដោយ កាលផស្សៈប្រាកដច្បាស់ ផស្សៈនោះមាននៅក្នុងអារម្មណ៍ណា វេទនាដែលមានលក្ខណៈសោយអារម្មណ៍នោះ សញ្ញាដែលមានលក្ខណៈសម្គាល់ដឹង ចេតនាដែលមានលក្ខណៈតាំងចិត្ត និងវិញ្ញាណចិត្តដែលមានលក្ខណៈទទួលដឹងនាមធម៌ទាំងនេះ រមែងប្រាកដ” ។

យស្ស ផស្សោ បាកដោ ហោតិ, សោបិ “ន កេវលំ ផស្សោវ ឧបជ្ជតិ, តេន សទ្ធឹ តទេវារម្មណំ អនុភវមានា វេទនាបិ ឧបជ្ជតិ, សញ្ជាននមានា សញ្ញាបិ ចេតយមានា ចេតនាបិ វិជាននមានំ

វិញ្ញាណម្បិ ឧប្បជ្ជតី"តិ ផស្សប្បញ្ចមកេយេវ បរិគ្គណ្ហាតិ[៤៥] ។

"ផស្សៈប្រាកដច្បាស់ដល់បុគ្គលណា បុគ្គលនោះរមែងកំណត់ដឹងធម៌ដទៃដែលមានផស្សៈជាលំដាប់ទី ៥ ( វេទនា សញ្ញា ចេតនា វិញ្ញាណ និងផស្សៈ )ថា សូម្បីវេទនាដែលសោយអារម្មណ៍នោះ សញ្ញាដែលសំគាល់ដឹង ចេតនាដែលតាំងចិត្ត និងវិញ្ញាណដែលទទួលដឹង រមែងកើតឡើងព្រមជាមួយផស្សៈ" ។

ឥធ បន ចក្ខុវិញ្ញាណសម្បយុត្តា តយោ ខន្ធា ។ តេ ហិ ចក្ខុវិញ្ញាណេន សហ វិញ្ញាតព្វត្តា ចក្ខុវិញ្ញាណវិញ្ញាតព្វាតិ វុត្តា[៤៦] ។

"ក្នុងព្រះសូត្រនេះ សំដៅយកខន្ធ៣ ដែលកើតរួមជាមួយចក្ខុវិញ្ញាណ ព្រោះខន្ធទាំងនោះហៅថា ធម៌ដែលគប្បីទទួលដឹងដោយចក្ខុវិញ្ញាណ ពីព្រោះជាធម៌ដែលទទួលដឹងបានព្រមជាមួយចក្ខុវិញ្ញាណ" ។

តសោ វេទនាតិ ផស្សាហារេ តីហិ បរិញ្ញាហិ បរិញ្ញាតេ តិស្សោ វេទនា បរិញ្ញាតាវ ហោន្តិ តម្មូលកត្តា តំសម្បយុត្តត្តា ច[៤៧]។

“ព្រះតម្រាស់ថា **តិស្សោ វេទនា** ( វេទនា ៣ ) មានសេចក្ដីថា កាលបុគ្គលកំណត់ដឹងផស្សាហារដោយបរិញ្ញា ៣ ក៏ជាការកំណត់ដឹងវេទនា ៣ ព្រោះវេទនាមានផស្សៈនោះជាហេតុកើត និងកើតព្រមជាមួយផស្សៈនោះ” ។

[បរិញ្ញា ៣ ដែលពោលដល់ក្នុងទីនេះ គឺ

១. **ញាតបរិញ្ញា** ការឃើញដោយការកំណត់ដឹងសភាវលក្ខណៈជាលក្ខណៈពិសេសរបស់រូបនាម សំដៅដល់ នាមរូបបរិច្ឆេទញាណ និង បច្ចយបរិគ្គហញាណ ។

២. **តីរណបរិញ្ញា** ការឃើញដោយការពិចារណាសាមញ្ញលក្ខណៈ គឺលក្ខណៈទូទៅ ដែលជាភាពមិនទៀង ជាទុក្ខ មិនមែនតួខ្លួន សំដៅដល់ សម្មសនញាណ និងឧទយព្វយញាណ ។

៣. **បហានបរិញ្ញា** ការឃើញដោយការលះនិច្ចសញ្ញាជាដើម សំដៅដល់វិបស្សនាញាណ តាំងអំពីភង្គញាណជាដើមទៅ] ។

**វិញ្ញាណស្មឹ ហិ បរិញ្ញាតេ តំ បរិញ្ញាតមេវ ហោតិ តម្មូលកត្តា សហុប្បន្នត្តា ច**[៤៨] ។

"កាលបុគ្គលកំណត់ដឹងវិញ្ញាណហើយ រូបនាមនោះក៏ជាការកំណត់ដឹងដោយពិត ព្រោះរូបនាមមានវិញ្ញាណនោះជាមូលហេតុនឹងកើតព្រមគ្នា" ។

ឆយិមា អានន្ទ ធាតុយោ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ ។ ឥមា ខោ អានន្ទ ឆ ធាតុយោ យតោ ជានាតិ បស្សតិ, ឯត្តាវតាបិ ខោ អានន្ទ ធាតុកុសលោ ភិក្ខូតិ អលំ វចនាយ[៩] ។

"ម្នាលអានន្ទ ធាតុមាន ៦ ប្រភេទទាំងនេះគឺ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ និងវិញ្ញាណធាតុ បុគ្គលរមែងដឹងច្បាស់ធាតុទាំង ៦ ប្រភេទនេះដោយវិបស្សនាញាណ និងមគ្គញាណណា គេគួរពោលថា ជាភិក្ខុអ្នកឆ្លាតក្នុងធាតុដោយការយល់ឃើញត្រឹមប៉ុណ្ណោះ" ។

គម្ពីរអដ្ឋកថានៃព្រះសូត្រនេះបានអធិប្បាយថា

ជានាតិ បស្សតីតិ សហ វិបស្សនាយ មគ្គោ វុត្តោ ។

បឋវីធាតុ អាទយោ សវិញ្ញាណកកាយំ សុញ្ញតោ និស្សត្តតោ ទស្សេតុំ វុត្តា ។ តាបិ ពុរិមាហិ អដ្ឋារសហិ ធាតូហិ បូរេតព្វា ។ បូរេន្តេន វិញ្ញាណធាតុតោ នីហរិត្វា បូរេតព្វា ។ វិញ្ញាណធាតុ ហេសា ចក្ខុវិញ្ញាណាទិវសេន ឆព្វិធា ហោតិ ។ តត្ថ ចក្ខុវិញ្ញាណធាតុយា បរិគ្គហិតាយ តស្សា វត្ថុ ចក្ខុធាតុ អារម្មណំ រូបធាតូតិ ទ្វេ ធាតុយោ បរិគ្គហិតាវ ហោន្តិ ។ ឯស នយោ សព្វត្ថ ។ មនោវិញ្ញាណធាតុយា បន បរិគ្គហិតាយ តស្សា បុរិមបច្ឆិមវសេន មនោធាតុអារម្មណវសេន ធម្មធាតូតិ ទ្វេ ធាតុយោ បរិគ្គហិតាវ ហោន្តិ[៥០] ។

"ព្រះបរមសាស្តា ត្រាស់មគ្គព្រមដោយវិបស្សនាដោយព្រះតម្រាស់ថា **ជានាតិបស្សតិ** ( រមែងដឹងច្បាស់ដោយការឃើញ ) ចំណែកបឋវីធាតុជាដើម ត្រាស់ទុកដើម្បីសម្តែងរាងកាយ ដែលមានចិត្តគ្រប់គ្រងថា សោះសូន្យ មិនមែនសត្វបុគ្គល ធាតុទាំង ៦ ប្រភេទនោះ គប្បីបំពេញឲ្យគ្រប់ដោយធាតុ ១៨ ប្រភេទដែលពោលមកហើយ កាលនឹងបំពេញឲ្យគ្រប់ គប្បីបំពេញដោយនាំមកអំពីវិញ្ញាណធាតុ ពិតហើយ វិញ្ញាណធាតុពួកនេះមាន ៦ ប្រភេទ

ដោយចែកជាចក្ខុវិញ្ញាណធាតុជាដើម ។

ក្នុងបណ្តាធាតុទាំងនោះ កាលបុគ្គលកំណត់ដឹងចក្ខុវិញ្ញាណ ក៏ជាការកំណត់ដឹងធាតុទាំង២ គឺចក្ខុធាតុ ( ចក្ខុបសាទ ) ដែលជាទីតាំង ( ទីអាស្រ័យកើត ) នៃចក្ខុវិញ្ញាណនោះ និងរូបធាតុ ( រូបារម្មណ៍ ) ដែលជាអារម្មណ៍គប្បីជ្រាបន័យនេះក្នុងវិញ្ញាណធាតុទាំងពួង ម្យ៉ាងទៀត កាលបុគ្គលកំណត់ដឹងមនោវិញ្ញាណធាតុហើយ ក៏ជាការកំណត់ដឹងធាតុទាំង ២ គឺ មនោធាតុ ដោយភាវៈជាសម្បដិច្ឆន្នចិត្តដែលកើតមុន និងបញ្ចទ្វារាវជ្ជនចិត្ត ដែលកើតខាងក្រោយ និងធម្មធាតុដោយភាពជាអារម្មណ៍ " ។

ព្រះតម្រាស់ថា **ជានាតិ បស្សតិ** ( រមែងដឹងច្បាស់ដោយការឃើញ ) សំដៅដល់ការឃើញច្បាស់វិបស្សនាញាណ និងមគ្គញាណ មិនមែនការទទួលដឹងដោយការស្តាប់ ឬជញ្ជឹងរិះគិត ដែលមិនបានដឹងច្បាស់អំពីបទពិសោធន៍របស់ខ្លួន ។

[សម្បដិច្ឆន្នចិត្ត ជាចិត្តដែលកើតមុនក្នុងលំដាប់វិថីចិត្ត គឺសម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋព្វនចិត្ត ជវនចិត្ត តទារម្មណចិត្ត និង

កវត្តចិត្ត ចំណែកបញ្ចទ្វារាវជ្ជនចិត្ត កើតតអំពីនោះ ក្នុងវិថីចិត្តតមក លោកទើបពោលថា សម្បដិច្ឆន្នចិត្តកើតមុនមនោវិញ្ញាណធាតុដទៃ ចំណែកបញ្ចទ្វារាវជ្ជនចិត្តកើតខាងក្រោយ] ។

ព្រះសូត្រខាងដើមពោលដល់អ្នកដឹងធាតុ ៦ ដោយវិបស្សនាញាណនិងមគ្គញាណថា ជាព្រះអរហន្តអ្នកខ្ចាតក្នុងធាតុ បុគ្គលដូចពោលត្រឹមទទួលដឹងផោដ្ឋព្វធាតុ និងវិញ្ញាណធាតុយ៉ាងបរិបូណ៌ប៉ុណ្ណោះ ដោយទទួលដឹងអាបោធាតុ និងអាកាសធាតុក្នុងធម្មធាតុ មិនបានទទួលដឹងធម្មធាតុយ៉ាងដទៃ ព្រមដោយធាតុពួកនេះ គឺ ចក្ខុធាតុ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ និងរសធាតុ តែបុគ្គលដូច្នេះ ចាត់ថាជាអ្នកទទួលដឹងធាតុ ១៨ បានដោយបំពេញឲ្យគ្រប់ធាតុ ១៨ ពោលគឺ វិញ្ញាណធាតុចែកចេញជា ៦ យ៉ាង បានដល់ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ និងមនោវិញ្ញាណធាតុ មានសេចក្តីពិស្តារថា

-ការទទួលដឹងសភាវៈឃើញ ដែលជាចក្ខុវិញ្ញាណធាតុ ចាត់

ជាការទទួលដឹងភាពថ្លានៃចក្ខុ គឺ ចក្ខុធាតុ និងពណ៌ គឺរូបធាតុ ។

- ការទទួលដឹងសភាវៈបានឮ ដែលជាសោតវិញ្ញាណធាតុ ចាត់ជាការទទួលដឹងភាពថ្លានៃត្រចៀក គឺ សោតធាតុ និងសម្លេង គឺ សទ្ទធាតុ ។

- ការទទួលដឹងសភាវៈដឹងក្លិន ដែលជាឃានវិញ្ញាណធាតុ ចាត់ជាការទទួលដឹងភាពថ្លានៃច្រមុះ គឺឃានធាតុ និងក្លិន គឺគន្ធធាតុ ។

- ការទទួលដឹងសភាវៈភ្លក្សរស ដែលជាជិវ្ហាវិញ្ញាណធាតុ ចាត់ជាការទទួលដឹងភាពថ្លានៃអណ្តាត គឺជិវ្ហាធាតុ និងរស គឺរសធាតុ ។

-ការទទួលដឹងសភាវៈសម្ផស្ស ដែលជាកាយវិញ្ញាណធាតុចាត់ជាការទទួលដឹងភាពថ្លានៃរាងកាយ គឺ កាយធាតុ និងសម្ផស្ស គឺ ផោដ្ឋព្វធាតុ ។

- ការទទួលដឹងសភាវៈនឹកគិត ដែលជាមនោវិញ្ញាណធាតុ ចាត់ជាការទទួលដឹងមនោធាតុ គឺសម្បដិច្ឆន្នចិត្ត ដែលកើតមុននិងបញ្ចទ្វារាវជ្ជនចិត្តដែលកើតខាងក្រោយ និងធម្មធាតុ គឺ មនោសម្ផស្ស ។

ដោយប្រការដូចនេះ ការដឹងច្បាស់ធាតុ ៦ រមែងបញ្ជូនផល ឲ្យទទួលដឹងធាតុដទៃក្នុងធាតុ ១៨ យ៉ាងទៀតផង ដូច្នោះ ការឃើញច្បាស់វិញ្ញាណធាតុយ៉ាងណានិមួយ ឬរូបនាមយ៉ាងណានិមួយ ក៏ធ្វើឲ្យទទួលដឹងនូវវិញ្ញាណធាតុទាំងអស់ និងរូបនាមទាំងអស់តែមួយដូចគ្នា ។

ដោយហេតុនេះ អ្នកបដិបត្តិទើបគួរកំណត់ថា "ឃើញហ្ន៎" ក្នុងខណៈឃើញ "បានឮហ្ន៎" ក្នុងខណៈបានឮ "ដឹងហ្ន៎" ក្នុងខណៈដឹងក្លិន "ភ្លក្សហ្ន៎" ក្នុងខណៈភ្លក្សរស "ប៉ះហ្ន៎" ក្នុងខណៈប៉ះខ្លួន ដោយទទួលដឹងសភាវៈ ត្រជាក់-ក្តៅ ទន់-រឹង ឬធូរ-តឹង ដែលកើតឡើងក្នុងខណៈនោះ បើភាពត្រជាក់ក្តៅជាដើមមិនប្រាកដ ក៏គួរកំណត់ថា "ប៉ះហ្ន៎" បើសភាវៈត្រជាក់ក្តៅ ឬវេទនាយ៉ាងណានិមួយប្រាកដ គួរកំណត់ដឹងតាមអាការនោះៗ ថា "ត្រជាក់ហ្ន៎" "ក្តៅហ្ន៎" "ទន់ហ្ន៎" "រឹងហ្ន៎" "សុខហ្ន៎" "នឿយហ្ន៎" "ឈឺហ្ន៎" "ចុកហ្ន៎" "រមាស់ហ្ន៎" "ស្ពឹកហ្ន៎" ។

ពិតមែនហើយ ការទទួលដឹងសភាវៈរឹងឬទន់ ជាការដឹងច្បាស់

បឋវីធាតុ ចំណែកការទទួលដឹងផស្សៈ ដែលល្អឬមិនល្អជាការដឹងជាប់ទាក់ទងជាមួយធាតុទាំង ៣ គឺ បឋវីធាតុ តេជោធាតុ និង វាយោធាតុ ដូចសាធកៈក្នុងគម្ពីរអដ្ឋសាលិនីថា

ឯត្ថ ច កក្ខឡំ មុទុកំ សណ្ហំ ផរុសំ គរុកំ លហុកន្តិ បទេហិ បឋវីធាតុឯវ ភាជិតា ។ សុខសម្ផស្សំ ទុក្ខសម្ផស្សន្តិ បទទ្វយេន បន តីណិ មហាភូតានិ ភាជិតានិ[៤១] ។

"ម្យ៉ាងទៀត ក្នុងរឿងនេះ ព្រះបរមសាស្តាទ្រង់ចែកបឋវីធាតុដោយបទ ៦ បទពួកនេះ គឺ រឹង ទន់ ល្អិត គ្រោតគ្រាត ធ្ងន់ ស្រាល និងទ្រង់ចែកមហាភូតរូប ៣ [ដ៏សេស] ដោយបទ ២ បទ គឺ សម្ផស្សជាសុខ សម្ផស្សជាទុក្ខ" ។

**វិធីតាមដឹងខ្យល់ដង្ហើមចូលចេញ**

ក្នុងមហាសតិប្បដ្ឋានសូត្រមានព្រះពុទ្ធវចនថា

**សោ សតោវ អស្សសតិ សតោវ បស្សសតិ[៤២] ។**

"លោកមានសតិដកដង្ហើមចូល មានសតិដកដង្ហើមចេញ" ។

ការទទួលដឹងសភាវៈប៉ះខ្ទប់ គឺ ផោដ្ឋព្វារម្មណ៍របស់វាយោធាតុ ដែលប៉ះខ្ទប់ត្រង់ចុងច្រមុះ ប៉ះបបូរមាត់ខាងលើ ព្រមជាមួយការទទួលដឹងកាយវិញ្ញាណចិត្ត ជាការចំរើនអានាបានៈបែបវិបស្សនា ដូចដែលបានពោលហើយក្នុងបរិច្ឆេទទី ៣ ថា ការចំរើនអានាបានៈបានទាំងសមថៈ និងវិបស្សនា ដោយស្របតាមអារម្មណ៍ដែលកំណត់ថា ជាបញ្ញត្តិឬបរមត្ថ មានលក្ខណៈជាដើម ដូច្នេះ គឺ

- សភាវៈតឹង-ធូរ ដែលប្រាកដដូចវត្ថុ ដែលត្រូវទាញចូលចេញជាលក្ខណៈពិសេសរបស់វាយោធាតុ ( **វិត្ថម្ភនលក្ខណា** ) ។

- ការធ្វើឲ្យចលនាអំពីរយៈពេលមួយទៅរយៈពេលមួយទៀតជានាទី ( **សមុទីរណរសា** ) ។

- ការរុញច្រាន ជាអាការប្រាកដ ( **អភិនីហារបច្ចុប្បដ្ឋានា** ) ។

ការកើតរលត់នៃខ្យល់ដង្ហើមចូលចេញ រមែងប្រចក្សដល់អ្នកដែលរលឹកដឹងខ្យល់ដង្ហើមតាមវិបស្សនានយដូចពោលនេះ គេរមែងដឹងច្បាស់ថា មានត្រឹមតែកងខ្យល់ដែលចលនា មិនមានបុគ្គលខ្លួនយើង របស់យើង គេមិនជំពាក់ដោយតណ្ហាទិដ្ឋិ និងមិន

ប្រកាន់មាំវត្ថុណានិមួយក្នុងលោក ដូចសេចក្តីក្នុងមហាសតិប្ប-
ដ្ឋានសូត្រ អានាបាបព្វៈថា

*សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ។ ន ច កិញ្ចិ លោកេ ឧបាទិយតិ*[៤៣] ។

"ភិក្ខុពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើងក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើងក្នុងកាយ ទាំងធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះផ្ចង់ឡើងចំពោះថា កាយមានមែន ( មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្ត

មិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង" ។

## ការតាមដឹងធាតុ ៤

ក្នុងខណៈឈរ ដើរ អង្គុយ ដេក កាលអ្នកបដិបត្តិប៉ះខ្ទប់ជាមួយរូប ៤២ ប្រការក្នុងរាងកាយដែលហៅថា អាការៈ ៤២ គឺ សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ជាដើម គប្បីកំណត់ថា "ប៉ះហ្ន៎" ចាត់ជាការទទួលដឹងសភាវធម៌ដូចតទៅនេះគឺ ៖

-ការទទួលដឹងសភាវៈ រឹងឬទន់ ជាលក្ខណៈពិសេសរបស់បឋវីធាតុ ( **កក្ខឡត្តលក្ខណា** ) ។

-ការទទួលដឹងសភាវៈត្រជាក់ឬក្តៅ ជាលក្ខណៈពិសេសរបស់តេជោធាតុ ( **ឧណ្ហត្តលក្ខណា** ) ។

-ការទទួលដឹងសភាវៈធូរឬតឹង ជាលក្ខណៈពិសេសរបស់វាយោធាតុ ( **វិត្ថម្ភនលក្ខណា** ) ។

- ការធ្វើចលនាអំពីរយៈពេលមួយទៅកាន់រយៈពេលមួយទៀត

ជានាទីរបស់វាយោធាតុ ( **សមុទីរណរសា** ) ។

- ការរុញច្រានជាអាការប្រាកដ របស់វាយោធាតុ ( **អភិនី-ហារបច្ចុបដ្ឋានា** ) ។

- ការទទួលដឹងសភាវៈហូរក្នុងខណៈដែលញើស ទឹកមាត់ ទឹកភ្នែកហូរចេញ ស្តោះស្លេស្ម៍ ស្តោះទឹកមាត់ និងខណៈបស្សាវៈជាដើមជាលក្ខណៈពិសេសរបស់អាបោធាតុ ( **បគ្ឃរណលក្ខណា** )។

- ការរួមខ្លួនជារូបរាង ជាអាការៈប្រាកដរបស់អាបោធាតុ ( **សង្គហបច្ចុបដ្ឋានា** ) ។

[ធាតុ៤ ក្នុងរាងកាយចែកចេញជាអាការ ៣២ គឺ សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត, ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ខួរក្នុងក្បាល, ប្រមាត់ ស្លេស្ម៍ ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត ។

អាការៈ ៤២ គឺជាអាការៈ ៣២ ដែលចែកជា

១. ធាតុដី មានអាការៈ ២០ គឺ សក់ រោម ក្រចក ធ្មេញ ស្បែក,

២. សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ, បេះដូង ថ្លើម វាវ ក្រពះ សួត, ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ខួរក្នុងក្បាល ។

២. ធាតុទឹក មានអាការៈ ១២ គឺ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត ។

៣. ធាតុភ្លើង មានអាការៈ ៤គឺ ភ្លើងដែលញុំាងកាយឲ្យក្តៅ ភ្លើងដែលញុំាងកាយឲ្យទ្រុឌទ្រោម ភ្លើងដែលញុំាងកាយឲ្យក្រហល់ក្រហាយ និងភ្លើងដែលដុតអាហារឲ្យរលួយ ។

៤. ធាតុខ្យល់ មានអាការៈ ៦ គឺ ខ្យល់បក់ឡើងលើ ខ្យល់បក់ចុះក្រោម ខ្យល់បក់ក្នុងពោះ ( ខ្យល់ក្នុងប្រហោងពោះក្រៅពីពោះវៀនធំ ) ខ្យល់បក់ក្នុងពោះវៀនធំ ខ្យល់បក់ទៅតាមអវយវៈតូចធំ ខ្យល់ដកដង្ហើមចេញចូល] ។

អាបោធាតុនេះ មិនមែនជាផ្ដព្វារម្មណ៍ដែលប៉ះខ្ទប់សម្ផស្សផ្លូវកាយបាន តែជាវត្ថុដែលទទួលដឹងបានផ្លូវចិត្តនោះ កាលប៉ះខ្ទប់ជាមួយបឋវីធាតុ តេជោធាតុ និងវាយោធាតុមុនហើយ តមកអ្នក

បដិបត្តិ ទើបអាចទទួលដឹងអាបោធាតុ ដោយការតាមដឹងសភាវៈប៉ះខ្ទប់ សេចក្ដីពិត ទឹកដែលប៉ះខ្ទប់បាននោះ ជាបឋវីធាតុដែលមានលក្ខណៈ រឹង-ទន់ ប្រកបដោយសភាវៈត្រជាក់ ឬក្ដៅរបស់តេជោ-ធាតុ និងសភាវៈធូររបស់វាយោធាតុ ចំណែកសភាវៈហូរឬកកជុំរបស់ធាតុទឹក ជាវត្ថុដែលទទួលដឹងផ្លូវចិត្តប៉ុណ្ណោះ ។

អ្នកដែលចម្រើនសតិរលឹកដឹងទាន់ធាតុទាំង ៤ តាមន័យដែលពោលមកនេះ រមែងដឹងជាក់ច្បាស់ថា មានត្រឹមសភាវៈ រឹង-ទន់ ហូរ-កកជុំ ត្រជាក់-ក្ដៅ ឬធូរ-តឹង មិនមានបុគ្គល យើង របស់យើង បុរស ស្ត្រី សមពិតដូចព្រះពុទ្ធវចនថា

*បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាប-ណិហិតំ ធាតុសោ បច្ចវេក្ខតិ “អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូ”តិ*[៥៤] ។

“ម្នាលភិក្ខុទាំងឡាយ ឧបដិបត្តិម្យ៉ាងទៀត គឺភិក្ខុរមែងពិចារណាឃើញកាយនេះ តាមដែលតាំងនៅ ស្ថិតនៅដោយភាពជាធាតុថាធាតុដី ធាតុទឹក ធាតុភ្លើង និងធាតុខ្យល់មាននៅក្នុងកាយនេះ” ។

## ខ/ វិនិច្ឆ័យការបដិបត្តិបែបប៉ោងស្រក

កន្លែងខ្លះពោលថា ការតាមដឹងសភាវៈប៉ោងស្រកមិនស្របជាមួយពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងទីនេះសូមបញ្ជាក់ថា ការតាមដឹងសភាវៈប៉ោងស្រកនេះ ចាត់ជាធាតុកម្មដ្ឋានតាមព្រះបាលីខាងដើមដោយសភាវៈប៉ោងស្រក ជាខ្យល់ក្នុងពោះដែលរុញច្រានឲ្យប៉ោងចេញ និងរួមស្រកចុះ កាលដកដង្ហើមចូលចេញ ការកំណត់សភាវៈប៉ោងស្រកថា "ប៉ោងហ្ន៎" "ស្រកហ្ន៎" ឬ "តឹងហ្ន៎" "ធូរហ្ន៎" ចាត់ថាបានទទួលដឹងលក្ខណៈជាដើមដូច្នេះគឺ

- សភាវៈតឹងធូររបស់ធាតុខ្យល់ ដែលជាផោដ្ឋព្វារម្មណ៍ ជាលក្ខណពិសេសរបស់វាយោធាតុ ( **វិត្ថម្ភនលក្ខណា** ) ។

-ការធ្វើចលនាអំពីរយៈពេលមួយទៅកាន់រយៈពេលមួយទៀត ជានាទីរបស់វាយោធាតុ ( **សមុទីរណារសា** ) ។

- ការរុញច្រានជាអាការប្រាកដរបស់វាយោធាតុ ( **អភិនីហារបច្ចុបដ្ឋានា** ) ។

ម្យ៉ាងទៀត វាយោធាតុ ដែលពោលទុកក្នុងកាយានុបស្សនា ( ការតាមដឹងកងរូប )នោះ នៅចាត់ជារូបខន្ធ ផោដ្ឋព្វាយតនៈ ផោដ្ឋព្វធាតុ និងទុក្ខសច្ចក្នុងធម្មានុបស្សនា ( ការតាមដឹងសភាវធម៌ ) ទៀតផង ទាំងជាសភាវៈផ្លូវកាយដែលស្របជាមួយឥរិយាបថបព្វៈ ក្នុងកាយានុបស្សនាថា

**យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ, តថា តថា នំ បជានាតិ[៥៤] ។**

"ឬលោកតាំងកាយទុកដោយកិរិយាឥរិយាបថយ៉ាងណាៗ ក៏ដឹងច្បាស់កិរិយាឥរិយាបថយ៉ាងនោះៗ" ។

ដោយហេតុនោះ ការចំរើនសតិដឹងទាន់សភាវៈប៉ុណ្ណេះ ទើបមានសេចក្តីស្របជាមួយព្រះបាលី ដូចដែលពោលមកហើយនេះ ។

[មនុស្សភាគច្រើនយល់ថា កាលដកដង្ហើមចូល ខ្យល់ដង្ហើមនិងធ្លងកាត់ចុងច្រមុះចូលទៅក្នុងសួតហើយ ធ្វើចលនាចុះទៅក្នុងពោះបណ្តាលឲ្យពោះប៉ោង តែការពិតមិនមែនដូច្នោះ ការដកដង្ហើម ជាវិធីការដែលកើតអំពីការធ្វើការងាររបស់សាច់ដុំបាំងខ្យល់ដើមទ្រូង និងឆ្អឹង

គ្រោងឆ្អឹងបាំងខ្យល់ទប់រាំងរវាងប្រហោងដើមទ្រូង និងប្រហោងពោះវៀន ដោយនៅប៉ែកកណ្ដាលរបស់សួតតាមប្រក្រតី កាលយើងដកដង្ហើមចូល បាំងខ្យល់រួញខូនសង្កត់អវយវៈក្នុងប្រហោងពោះ បណ្ដាលឲ្យខ្យល់ក្នុងពោះប៉ោងចេញមក និងកាលដកដង្ហើមចេញ ញ៉ាំងខ្យល់ទីងយឺតឡើង បណ្ដាលឲ្យខ្យល់ក្នុងពោះស្រុតចុះ ព្រមជាមួយរុញប្រាទចេញអំពីសួត។

ការចម្រើនសតិតាមបែបប៉ោងស្រុតនេះ បញ្ជាក់ការកំណត់ដឹងធាតុទាំង ៤ ដោយមានធាតុខ្យល់ជាគោល ចាត់ជាសតិប្បដ្ឋាន ប្រភេទកាយានុបស្សនា សភាវៈការប៉ោងស្រុតនោះ ជាខ្យល់ដែល កើតខាងក្នុងពោះហៅថា កុច្ឆិសយវាយោ ( ខ្យល់ក្នុងពោះ ) ដែលជាខ្យល់មួយយ៉ាងក្នុងចំណោមខ្យល់ ៦ ប្រភេទ គឺខ្យល់បក់ឡើងលើ ខ្យល់បក់ចុះក្រោម ខ្យល់ក្នុងពោះ ខ្យល់ក្នុងពោះវៀន ខ្យល់ដង្ហើម និងខ្យល់បក់តាមអវយវៈតូចធំ សមពិតដូចព្រះពុទ្ធវចនថា

កតមា ច រាហុល វាយោធាតុ ។ វាយោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច រាហុល អជ្ឈត្តិកា វាយោធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ វាយោ វាយោគតំ ឧបាទិន្នំ ។ សេយ្យថិទំ ។ ឧទ្ធង្គមា វាតា, អធោគមា វាតា, កុច្ឆិសយា វាតា កោដ្ឋាសយា វាតា, អង្គមង្គានុសារិនោ វាតា, អស្សាសោ បស្សាសោ, ឥតិ យំ វា

បទញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ វាយោ វាយោគតំ ឧបាទិន្នំ ។ អយំ វុច្ចតិ រាហុល អជ្ឈត្តិកា វាយោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា វាយោធាតុ យា ច ពាហិរា វាយោធាតុ, វាយោធាតុរេវេសា ។ តំ នេតំ មម, នេសោហមស្មិ, ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា វាយោធាតុយា និព្វិន្ទតិ ។ វាយោធាតុយា ចិត្តំ វិរាជេតិ[៥៦] ។

“ម្នាលរាហុល វាយោធាតុជាយ៉ាងណា វាយោធាតុជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ក៏វាយោធាតុជាខាងក្នុងជាយ៉ាងណា វត្ថុណាជាខាងក្នុងអាស្រ័យខ្លួន ជាវាយោធាតុ មានលក្ខណៈបក់ទៅមក ដែលកម្មនិងកិលេសចូលទៅប្រកាន់មាំ គឺខ្យល់បក់ឡើងលើ ខ្យល់បក់ចុះក្រោម ខ្យល់ក្នុងពោះ ខ្យល់ក្នុងពោះវៀន ខ្យល់បក់តាមអវយវៈតូចធំ និងខ្យល់ដកដង្ហើមចេញចូល ឬវត្ថុណានិមួយយ៉ាងដទៃ ជាខាងក្នុងអាស្រ័យខ្លួនជាវាយោបក់ទៅមក ដែលកម្មនិងកិលេសចូលទៅប្រកាន់មាំ នេះតថាគតហៅវាយោធាតុជាខាងក្នុង ក៏វាយោធាតុជាខាងក្នុងក្តី ជាខាងក្រៅក្តី យ៉ាងណា វាយោធាតុនោះជាវាយោធាតុដូចគ្នា លោកគប្បីដឹងច្បាស់វាយោធាតុនោះ ដោយបញ្ញាដែលប្រពៃតាមពិតយ៉ាងនេះថា វា-យោធាតុនោះមិនមែនជារបស់យើង យើងមិនមែនជាវាយោធាតុនោះ

វាយោធាតុនោះមិនមែនជាខ្លួនរបស់យើង ព្រោះបុគ្គលឃើញច្បាស់វាយោធាតុនោះដោយបញ្ញា ដែលពេញចិត្តតាមពិតយ៉ាងនេះហើយ រមែងនឿយណាយក្នុងវាយោធាតុ ចិត្តរមែងធុញទ្រាន់ក្នុងវាយោធាតុ"] ។

## កាយានុបស្សនា ( ការតាមដឹងកងរូប )

### ពួកឥរិយាបថបព្វៈ

ក្នុងខណៈដើរ អ្នកបដិបត្តិគប្បីចម្រើនសតិដឹងទាន់សភាវៈចលនាគ្រប់ៗជំហានដោយការកំណត់ថា "ដើរហ្ន៎ៗ" ឬ "ឈានហ្ន៎ៗ" ឬ"លើកហ្ន៎ ឈានហ្ន៎ ជាន់ហ្ន៎ " កាលសមាធិចាស់ក្លាច្រើនឡើងហើយ អ្នកបដិបត្តិអាចនឹងដឹងចិត្ត ដែលត្រូវការដើរបានទៀតផង ដោយដឹងថា ចិត្តដែលត្រូវការដើរនឹងកើតឡើងមុន ហើយនឹងកើតអាការចលនាបន្តមក មានសាធកៈក្នុងរឿងនេះថា

បុន ចបរំ ភិក្ខវេ ភិក្ខុ គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ[៤៧] ។

"ម្នាលភិក្ខុទាំងឡាយ ឧបដិបត្តិមួយទៀត គឺភិក្ខុកាលកំពុងដើរ រមែងដឹងច្បាស់ថា កំពុងដើរ" ។

ឯស ឯវំ បជានាតិ "គច្ឆាមី"តិ ចិត្តំ ឧប្បជ្ជតិ ។ តំ វាយំ

ជនេតិ ។ កាយោ វិញ្ញត្តឹ ជនេតិ ។ ចិត្តកិរិយកាយោជាតុវិប្ផារេន សកលកាយស្ស បុរតោ អភិនីហារោ គមនន្តិ វុច្ចតិ[៥៨] ។

“លោករមែងដឹងច្បាស់យ៉ាងនេះថា ចិត្តដែលទឹកគិតថានឹងដើររមែងកើតឡើង ចិត្តនោះរមែងញ៉ាំងធាតុខ្យល់ឲ្យកើតឡើង ធាតុខ្យល់រមែងញ៉ាំងវិញ្ញត្តិរូបឲ្យកើតឡើង ការចលនាខាងមុខនៃរាងកាយទាំងអស់ដោយការបណ្តេញចេញនៃធាតុខ្យល់ត្រង់ចិត្ត ការធ្វើឡើងហៅថា ការដើរ”។

សេចក្តីពិត មនុស្សទូទៅដែលមិនបានចម្រើនសតិប្បដ្ឋានក៏ដឹងថា ខ្លួនដើរ តែចិត្តរមែងគិតដល់រឿងអតីត ឬអនាគតដោយមិនបានទទួលដឹងសភាវៈដើរយ៉ាងពិតប្រាកដ ក្នុងខណៈខ្លះសូម្បីនឹងដល់ការដើរ ក៏មានការសម្គាល់ថា ជាអត្តាតួខ្លួន ជាយើង ដែលកំពុងដើរ ការដើរមានភាពទៀង មិនប្រែប្រួល ព្រោះកិរិយាដើរស្ថិតនៅដូចដើម មិនបានប្រាកដសភាវៈ កើតរលត់ ការយល់ដឹងរបស់មនុស្សទូទៅទើបមានអត្តសញ្ញា គឺការសំគាល់ថាជាតួខ្លួន មិនមែនសតិប្បដ្ឋាន ឬវិបស្សនាភាវនា ។

អ្នកបដិបត្តិតាមដឹងសភាវៈដើរក្នុងបច្ចុប្បន្នខណៈ រមែងនឹងមានសតិនិងបញ្ញាបែកផ្សេងគ្នាអំពីការទទួលដឹងរបស់មនុស្សទូទៅពោលគឺគេរមែងទទួលដឹងចិត្ត ដែលត្រូវការនឹងដើរមុន ដោយកំណត់ថា "ចង់ដើរហ្ន៎" ហើយអាចតាមដឹងសភាវៈចលនាយ៉ាងបន្តបន្ទាប់តាំងអំពីខាងដើមរហូតដល់ទីបំផុត គេដឹងថាសភាវៈចលនាកើតឡើងអំពីចិត្តដែលញ៉ាំងឲ្យចលនា និងសភាវៈចលនានោះក៏មានសភាពផុតចន្លោះក្នុងរយៈពេលដែល លើក ឈាន និងជាន់មិនលាយឡំគ្នា ក្រោយអំពីនោះ ក៏អាចឃើញការកើតរលត់យ៉ាងឆាប់រហ័សរបស់សភាវៈចលនាដោយល្អិតសុខុម អ្នកបដិបត្តិអ្នកកើតសភាវធម៌យ៉ាងនេះ រមែងនឹងយល់ថា មិនមែនខ្លួនយើង របស់យើងដែលជាអ្នកដើរ មានត្រឹមតែចិត្តដែលធ្វើការងារ និងក្រុមរូបដែលចលនាអំពីរយៈពេលមួយទៅកាន់រយៈពេលមួយទៀតមានសភាពមិនទៀង ព្រោះកើតឡើងហើយរលត់ទៅ ជាទុក្ខព្រោះត្រូវប្រចាប់ ដោយការកើតរលត់ និងមិនមែនតួខ្លួន ដែលអ្នកណា ៗ មិនអាចបង្គាប់បញ្ជាបាន គេរមែងដកចេញនូវ ការឃើញខុសថា មានបុគ្គលតួខ្លួន ជាយើង របស់យើង និងលះការ

ប្រកាន់មាំក្នុងតួខ្លួន ដូចសាធកៈថា

ឥមស្ស បន ភិក្ខុនោ ជាននំ សត្តូបលទ្ធិ បជហតិ។ អត្តសញ្ញំ សមុគ្ឃាដេតិ ។ កម្មដ្ឋានញ្ច សតិបដ្ឋានភាវនា ច ហោតិ[៥៩] ។

"ការយល់របស់ភិក្ខុនេះ រមែងលះសភាវៈឃើញថាជាបុគ្គល រមែងដកចេញនូវការសម្គាល់ថា ជាតួខ្លួន ចាត់ជាកម្មដ្ឋាន និងការចម្រើនសតិបដ្ឋាន" ។

បញ្ញាដែលឃើញក្នុងលក្ខណៈ ដូចពោលនេះ ឈ្មោះថា អសម្មោហសម្បជញ្ញៈ គឺការឃើញដោយមិនធ្លាក់ក្នុងការយល់ខុស ចំណែកការចម្រើនសតិ ដែលកំណត់ថា "ព្រាថ្នានឹងដើរហ្ន៎" ឬ "ដើរហ្ន៎"ជាដើម ឈ្មោះថា គោចរសម្បជញ្ញៈ គឺការឃើញអារម្មណ៍របស់សតិ សមាធិនិងបញ្ញា ម្យ៉ាងទៀត គោចរសម្បជញ្ញៈ ជាហេតុ អសម្មោហសម្បជញ្ញៈជាផល អ្នកបដិបត្តិទើបគួរចំរើន គោចរសម្បជញ្ញៈ យ៉ាងបន្តបន្ទាប់ជានិច្ចកាល គោចរសម្បជញ្ញៈ មានកម្លាំងចាស់ក្លាហើយ អសម្មោហសម្បជញ្ញៈ ក៏នឹងកើតឡើង ហើយនឹងចម្រើនរឿយ ៗ ទៅតាមលំដាប់ ដូចសាធកៈក្នុងគម្ពីរ

អដ្ឋកថាថា

អភិក្កមាទីសុ បន អសម្មុយ្ហនំ អសម្មោហសម្បជញ្ញំ ។ តំ ឯវំ វេទិតព្វំ ។ ឥធ ភិក្ខុ អភិក្កមន្តោ វា បដិក្កមន្តោ វា យថា អន្ធបុថុជ្ជនា អភិក្កមាទីសុ អត្តា អភិក្កមតិ, អត្តនា អភិក្កមោ និព្វត្តិតោតិ វា អហំ អភិក្កមាមិ, មយា អភិក្កមោ និព្វត្តិតោតិ វា សម្មុយ្ហន្តិ, តថា អសម្មុយ្ហន្តោ អភិក្កមាមីតិ ចិត្តេ ឧប្បជ្ជមានេ តេនេវ ចិត្តេន សទ្ធិំ ចិត្តសមុដ្ឋានា វាយោធាតុ វិញ្ញត្តិំ ជនយមានា ឧប្បជ្ជតិ ។ ឥតិ ចិត្តកិរិយាវាយោធាតុវិប្ផារវសេន អយំ កាយសម្មតោ អដ្ឋិសង្ឃាតោ អភិក្កមតិ ។ តស្សេវំ អភិក្កមតោ ឯកេកបាទុទ្ធរណេ បឋវីធាតុ អាបោធាតូតិ ទ្វេ ធាតុយោ ឱមត្តា ហោន្តិ មន្ទា ។ ឥតរា ទ្វេ អធិមត្តា ហោន្តិ ពលវតិយោ ។ តថា អតិហរណវីតិហរណេសុ ។ វោស្សជ្ជនេ តេជោវាយោធាតុយោ ឱមត្តា ហោន្តិ មន្ទា។ ឥតរា ទ្វេ អធិមត្តា ហោន្តិ ពលវតិយោ ។ តថា សន្និក្ខេបនសន្និរុម្ភនេសុ ។ តត្ថ ឧទ្ធរណេ បវត្តា រូបារូបធម្មា អតិហរណំ ន បាបុណន្តិ ។ តថា អតិហរណេ បវត្តា វីតិហរណំ ។ វីតិហរណេ បវត្តា

វោសជ្ជនំ ។ វោសជ្ជនេ បវត្តា សន្និក្ខេបនំ ។ សន្និក្ខេបនេ បវត្តា សន្និរុម្ភនំ ន បាបុណាន្តិ ។ តត្ថ តត្ថេវ បតុំ បតុំ សន្ធិ សន្ធិ ឪធិ ឪធិ ហុត្វា តត្តកបាលេ បក្ខិត្តតិលានិ វិយ បដបដាយន្តា ភិជ្ជន្តិ ។ តត្ថ កោ ឯកោ អភិក្កមតិ, តស្ស វា ឯកស្ស អភិក្កមនំ ។ បរមត្ថតោ ធាតូនំយេវ គមនំ ធាតូនំ ឋានំ ធាតូនំ និសជ្ជា ធាតូនំ សយនំ ។ តស្មឹ តស្មិញ្ហិ កោដ្ឋាសេ សទ្ធឹ រូបេន អញ្ញំ ឧប្បជ្ជតេ ចិត្តំ អញ្ញំ ចិត្តំ និរុជ្ឈតិ អវិចិមនុសម្ពន្ធោ នទីសោតោវ វត្តតិ ។ ឯវំ អភិក្កមាទីសុ អសម្មុយ្ហនំ អសម្មោហសម្បជញ្ញំ នាម[៦០] ។

"ការឃើញមិនមានសេចក្តីសង្ស័យក្នុងការឈានជាដើម ឈ្មោះថា អសម្មោហសម្បជញ្ញៈ គប្បីជ្រាបនូវអសម្មោហសម្បជញ្ញៈយ៉ាងនេះ ភិក្ខុក្នុងព្រះសាសនានេះ ឈាន កំពុងឈានទៅមុខឬថយក្រោយ រមែងប្រាសចាកសភាពធ្លាក់ចុះក្នុងការយល់ខុសដូចបុថុជ្ជនមនុស្សខ្វាក់ដែលធ្លាក់ចុះក្នុងការយល់ខុសថា ក្នុងការឈានជាដើម អត្តារមែងឈាន ការឈានត្រូវអត្តាធ្វើឲ្យកើតឡើង

ឬយល់ខុសថា យើងកំពុងឈាន ការឈានត្រូវយើងធ្វើឲ្យកើតឡើង កាលចិត្តដែលគិតថានឹងឈានកើតឡើង ត្រង់វាយោធាតុដែលមានចិត្តជាសមុដ្ឋាន ញ៉ាំងវិញ្ញត្តិរូបឲ្យកើតឡើង រមែងកើតរួមជាមួយចិត្តនោះឯង គំនរឆ្អឹងដែលសន្មតិថា រាងកាយនេះ រមែងឈានដោយការពង្រីកទៅនៃវាយោធាតុដែលចិត្តធ្វើឡើង ។

កាលគេកំពុងឈាន ក្នុងខណៈលើកជើងម្ខាង ធាតុ២ យ៉ាង គឺបឋវីធាតុ និងអាបោធាតុមានកម្លាំងតិច ចំណែកធាតុ ២ យ៉ាងដទៃ [គឺតេជោធាតុ និងវាយោធាតុ] មានកម្លាំងច្រើន សូម្បីក្នុងខណៈឈាន និង ឈានទៅខាងមុខក៏ដូចគ្នាតែម្យ៉ាង តែក្នុងខណៈដាក់ តេជោធាតុ និងវាយោធាតុ មានកម្លាំងតិច ចំណែកធាតុទាំង ២ ដ៏សេស [គឺបឋវីធាតុ និងអាបោធាតុ] មានកម្លាំងច្រើនក្នុងខណៈដាក់ និងសង្កត់ក៏ដូចគ្នានេះ ។

បណ្ដាខណៈពួកនោះ រូបនាមដែលប្រព្រឹត្តទៅក្នុងខណៈលើករមែងមិនទៅដល់ខណៈឈានដូចគ្នាយ៉ាងនេះ រូបនាមដែលប្រព្រឹត្តទៅក្នុងខណៈឈាន ក៏ទៅមិនដល់ខណៈឈានទៅខាងមុខ ដែល

ប្រព្រឹត្តទៅក្នុងខណៈរុញទៅខាងមុខ ក៏ទៅមិនដល់ខណៈជាន់ ដែលប្រព្រឹត្តទៅក្នុងខណៈជាន់ ក៏ទៅមិនដល់ក្នុងខណៈដាក់ ដែលប្រព្រឹត្តទៅក្នុងខណៈដាក់ ក៏មិនដល់ខណៈសង្កត់ រូបនាមទាំងនោះកើតរលត់ជាក្រុម ៗ មួយផ្នែក ៗ រមែងរលត់ទៅក្នុងខណៈនោះ ៗ ខ្ទេចខ្ទីដូចគ្រាប់ល្ង ដែលដាក់ក្នុងខ្ទះក្តៅកំពុងបញ្ចេញសំឡេងក្នុងរូបនាមដែលកំពុងកើតរលត់នោះ នណាម្នាក់កំពុងឈានឬ ឬជាការឈានរបស់នណាម្នាក់ ឬ ជាការពិតត្រឹមតែជាការដើរ ឈរ អង្គុយ និងដេក របស់ធាតុទាំងឡាយដោយសភាវធម៌ ។

"ដោយពិតហើយ ក្នុងខណៈដើរនិងគិតជាដើម ចិត្ត១ដួងចាស់រមែងរលត់ទៅព្រមជាមួយរូប ចិត្តមួយដួងថ្មី រមែងកើតឡើងបន្តគ្នាទៅក្រសែចិត្តត្រាច់ទៅមិនដាច់ដួរវារៈដូចក្រសែទឹក" ។

ការឃើញមិនធ្លាក់ចុះក្នុងការយល់ខុសក្នុងការឈានជាដើមយ៉ាងនេះ ឈ្មោះថា អសម្មោហសម្បជញ្ញៈ" ។

ព្រះអដ្ឋកថាចារ្យ ពោលដល់លក្ខណៈរបស់ធាតុ ក្នុងខណៈលើកជើងជាដើមថា

- ការលើក (ឧទ្ធរណ) កើតអំពីធាតុភ្លើង និងធាតុខ្យល់

- ការឈាន ( អតិហរណ ) កើតអំពីធាតុភ្លើង និងធាតុខ្យល់

- ការឈានទៅខាងមុខ ( វីតិហរណ ) កើតអំពីធាតុភ្លើងនិងធាតុខ្យល់

- ការជាន់ ( វោស្សជ្ជន ) កើតអំពីធាតុដី និងធាតុទឹក

- ការដាក់ ( និស្សិក្ខេបន ) កើតអំពីធាតុដី និងធាតុទឹក

- ការសង្កត់ ( សន្និរុម្ភន ) កើតអំពីធាតុដី និងធាតុទឹក ។

យ៉ាងណាក៏ដោយ គម្ពីរដីកាបានបញ្ជាក់បន្ថែមខាងដើមថា ធាតុភ្លើងស្រាលជាងធាតុខ្យល់ និងធាតុទឹកធ្ងន់ជាងធាតុដី ទើបសរុបសភាវៈរបស់ធាតុក្នុងខណៈដែលដើរថា

- ការលើក ( ឧទ្ធរណ ) កើតអំពីធាតុភ្លើងជាគោល ធាតុខ្យល់ស្របតាម ព្រោះធាតុភ្លើងមានសភាពស្រាលជាងធាតុខ្យល់ តាមអាការប្រាកដ ( បច្ចុបដ្ឋាន ) របស់ធាតុភ្លើងថា មទ្ទវានុប្បាទនបច្ចុបដ្ឋានា ( មានការឲ្យដល់ការទន់នៃការស្ទុះឡើងខ្ពស់ ជាគ្រឿង

ប្រាកដ ) ។

- ការឈាន ( **អតិហរណា** ) កើតអំពីធាតុខ្យល់ ជាគោល ធាតុភ្លើងស្របតាម ព្រោះធាតុភ្លើងមានសភាពរុញច្រានតាមអាការប្រាកដរបស់ធាតុខ្យល់ថា **អភិនីហារបច្ចុបដ្ឋាន** ( មានការរុញច្រានជាគ្រឿងប្រាកដ ) ។

- ការឈានទៅខាងមុខ ( **វីតិហរណា** ) កើតអំពីធាតុខ្យល់ ជាគោល ធាតុភ្លើងស្របតាម ព្រោះមានសភាពរុញច្រាន ។

- ការជាន់ ( **វោស្សជ្ជន** ) កើតអំពីធាតុទឹកជាគោល ធាតុដីស្របតាម ព្រោះធាតុទឹកមានសភាពធ្ងន់ជាងធាតុដី តាមលក្ខណៈរបស់ធាតុទឹកថា **បគ្ឃរណលក្ខណា** ( មានលក្ខណៈហូរ ឬកកជុំ ) ជាប់ទាក់ទងនឹងធាតុទឹកមានលក្ខណៈហូរទៅកាន់ទីទាប ទើបធ្ងន់ជាងធាតុដី ។

- ការដាក់ ( **សន្និក្ខេបន** ) កើតអំពីធាតុដីជាគោល ធាតុទឹកស្របតាម ព្រោះមានសភាពប៉ះខ្ទប់ការរឹង ឬទន់តាមលក្ខណៈរបស់ធាតុដីថា **កក្ខឡត្តលក្ខណា** ( មានលក្ខណៈរឹង ឬទន់ )

និងតាមនាទីរបស់ធាតុដីថា បតិដ្ឋានរសា ( មាននាទីតាំងទុក ) ។

- ការសង្កត់ ( សន្និរម្ភន ) កើតអំពីធាតុដីជាគោល ធាតុទឹកស្របតាម មានការជាប់ទាក់ទងជាមួយរឿងនេះ ក្នុងគម្ពីរដីកាថា

វាយោធាតុយា អនុគតា តេជោធាតុ ឧទ្ធរណស្ស

បច្ចយោ ។ ឧទ្ធរណគតិកា ហិ តេជោធាតូតិ[៦១] ។

"ធាតុភ្លើងដែលមានធាតុខ្យល់តាមទៅ រមែងជាបច្ច័យដល់ការលើក ព្រោះធាតុភ្លើងមានសភាពស្ទុះឡើងខ្ពស់" ។

តេជោធាតុយា អនុគតា វាយោធាតុ អតិហរណវីតិហរណានំ បច្ចយោ ។ តិរិយគតិកាយ ហិ វាយោធាតុយា អតិហរណវីតិហរណេសុ សាតិសយោ ព្យាបារោតិ[៦២] ។

"ធាតុខ្យល់ដែលមានធាតុភ្លើងតាមទៅ រមែងជាបច្ច័យដល់ការឈាន និងការឈានទៅខាងមុខ ព្រោះការខ្វល់ខ្វាយដ៏ក្រៃលែងក្នុងការឈានជើង និងរុញជើង រមែងមានដល់ធាតុខ្យល់ដែលមានសភាវៈទៅផ្លូវខាងស្តាំ" ។

**បឋវីធាតុយា អនុគតា អាបោធាតុ កោសស្ស ជូនស្ស បច្ចយោ ។ គរុតរសភាវា ហិ អាបោធាតូតិ**[៦៣] ។

"ធាតុទឹកដែលមានធាតុដីតាមទៅ រមែងជាបច្ច័យដល់ការជាន់ ព្រោះធាតុទឹកមានសភាវៈធ្ងន់ជាង[ធាតុដី]" ។

[គម្ពីរវិសុទ្ធិមគ្គពោលថា **អតិហរណ** ប្រែថា "ការឈាន" ចំណែក **វីតិហរណ** ប្រែថា "ការប្តូរ" សំដៅដល់ ការប្តូរជើងក្នុងខណៈឈាន ដើម្បីគេចចេញពីបន្លា ឬដង្កត់ឈើជាដើមដូចសេចក្តីថា

**អតិហរណំ នាម បុរតោ ហរណំ ។ វីតិហរណំ នាម ខាណុកណ្ដកទីឃជាតិអាទីសុ កិញ្ចិទេវ ទិស្វា ឥតោ ចិតោ ច បាទសញ្ចារណំ**[៦៤] ។

"ការឈានទៅខាងមុខ ឈ្មោះថា **អតិហរណៈ** ( ការឈាន ) ការប្តូរជើងអំទីនោះទីនេះ កាលជួបដង្កត់ឈើ បន្លា ឬពស់ ជាដើមយ៉ាងណានិមួយ ឈ្មោះថា **វីតិហរណៈ** ( ការប្តូរ )" ។

យ៉ាងណាក៏ដោយ គម្ពីរមូលដីកានិងដីការបស់ទីឃនិកាយ

បានសម្ដែងសេចក្ដីរបស់វីតិហរណ ន័យម្យ៉ាងទៀតថា “ការឈាន ទៅខាងមុខ” ពោលគឺ អតិហរណ ជាការឈានទៅចូលដល់ជើង ដែលកំពុងឈរនៅ ចំណែក វីតិហរណ ជាការឈានទៅខាងមុខ បន្ទាប់អំពីនោះ ដូចមានសាធកៈក្នុងរឿងនេះថា

ខាណុអាទិបរិហរណត្ថំ, បតិដ្ឋិតបាទបរិហរណត្ថំ វា បស្សេន ហរណំ វីតិហរណន្តិ វទន្តិ ។ យាវ បតិដ្ឋិតបាទោ, តាវ អាហរណំ អតិហរណំ ។ តតោ បរំ ហរណំ វីតិហរណន្តិ អយំ វា ឯតេសំ វិសេសោ[៦៤] ។

“អាចារ្យទាំងឡាយពោលថា ការឈានទៅខាង ដើម្បីគេចចេញ ពីដង្គត់ឈើជាដើម ឬដើម្បីគេចចេញពីជើងដែលកំពុងឈរ ឈ្មោះ ថា វីតិហរណៈ ន័យម្យ៉ាងទៀត សេចក្ដីផ្សេងគ្នានៃ អតិហរណ និង វីតិហរណ ពួកនោះមានដូច្នេះ គឺការឈានទៅដល់ជើងដែលកំពុង ឈរ ឈ្មោះថា អតិហរណៈ ចំណែកការឈានទៅបន្ទាប់អំពី នោះ ឈ្មោះថា វីតិហរណ” ។

បិត្តដ្ឋានំ អតិក្កមិត្វា បុរតោ ហរណំ អតិហរណំ ។ ខាណុ-

អាទិបរិហរណត្ថំ បទិដ្ឋិតបាទឃដ្ដនបរិហរណត្ថំ វា បស្សេន ហរណំ វីតិហរណំ ។ យាវ បទិដ្ឋិតបាទោ, តាវ អាហរណំ អតិហរណំ, តតោ បរំ ហរណំ វីតិហរណន្តិ អយំ វា ឯតេសំ វិសេសោ[៦៦] ។

“ការឈានទៅខាងមុខ ផុតទៅអំពីទីកន្លែងដែលកំពុងឈរ ឈ្មោះថា **អតិហរណ** ការឈានទៅដើម្បីគេចចេញអំពីជង្គត់ឈើជាដើម ឬដើម្បីគេចចេញពីការប៉ះខ្ទប់ជាមួយជើង ដែលកំពុងឈរ ឈ្មោះថា **វីតិហរណ** ន័យម្យ៉ាងទៀត សេចក្ដីផ្សេងគ្នានៃ **អតិហរណ** និង **វីតិហរណ** ពួកនោះមាន ដូចនេះ គឺ ការឈានទៅដល់ជើងដែលកំពុងឈរ ឈ្មោះថា **អតិហរណ** ចំណែកការឈានទៅបន្តអំពីនោះ ឈ្មោះថា **វីតិហរណ**” ។

ដោយហេតុដែលការប្ដូរជើងតាមដែលពោលទុកក្នុងវិសុទ្ធិមគ្គ ជាវត្ថុដែលប្រាកដក្នុងខណៈខ្លះ កាលកំពុងដើរចង្ក្រមក្នុងព្រៃនិងការឈានជើងទៅខាងមុខកន្លងជើងដែលពោលទុកក្នុងមូលដីកា និងដីការបស់ទីឃនិកាយក៏ចាត់ថា ជាការឈានជើងដូចគ្នា បោរាណាចារ្យ

ទើបពោលដល់ការដើរចង្ក្រម ៦ គ្រា ដោយបន្ថែមការលើកកែង ស្បែកជើងថា ៖

- ឡើងហ្ន៎
- លើកហ្ន៎
- ឈានហ្ន៎
- ជាន់ហ្ន៎ ឬដាក់ហ្ន៎
- ប៉ះខ្ទប់ហ្ន៎
- សង្កត់ហ្ន៎

ការកំណត់ថា "ប៉ះខ្ទប់" ក៏គឺការដាក់ជើងជាមួយផ្ទៃ ដែលហៅថា **សន្និក្ខេបន** នោះឯង ដូចគម្ពីរវិសុទ្ធិមគ្គពោលថា

**សន្និក្ខេបនំ នាម បឋវីតលេ ឋបនំ**[៦៧] ។

"ការដាក់ទុកលើផ្ទៃដី ឈ្មោះថា **សន្និក្ខេបន**"]។

**២ការតាមដឹងឥរិយាបថក្នុងខណៈឈរជាដើម**

ក្នុងខណៈឈរ អង្គុយ និងដេក អ្នកបដិបត្តិគប្បីកំណត់ថា

"ឈរហ្ន៎" "អង្គុយហ្ន៎" "ដេកហ្ន៎" កាលសតិ សមាធិ និងបញ្ញាចាស់ក្លាច្រើនឡើងអ្នកបដិបត្តិនឹងទទួលដឹងចិត្តដែលត្រូវការនឹងឈរ និងសភាវៈឈរ ជាធាតុខ្យល់ដែលមានលក្ខណៈតឹងចិត្តដែលត្រូវការទើងអង្គុយ និងសភាវៈអង្គុយជាធាតុខ្យល់ ដែលមានលក្ខណៈតឹង ព្រមទាំងចិត្តដែលត្រូវការទើងដេក និងសភាវៈដេកជាធាតុខ្យល់ដែលមានលក្ខណៈធូរ-តឹង និងធាតុដីដែលមានលក្ខណៈរឹង-ទន់ ការយល់សភាវធម៌នៃអ្នកបដិបត្តិនេះ បែកផ្សេងអំពីការយល់របស់បុគ្គលទូទៅ ដូចមានសាធកៈថា

ឯកោ ហិ ភិក្ខុ គច្ឆន្តោ អញ្ញំ ចិន្តេន្តោ អញ្ញំ វិតក្កេន្តោ គច្ឆតិ ។ ឯកោ កម្មដ្ឋានំ អវិស្សជ្ជេត្វា គច្ឆតិ ។ តថា ឯកោ ទិដ្ឋន្តោ និសីទន្តោ សយន្តោ អញ្ញំ ចិន្តេន្តោ អញ្ញំ វិតក្កេន្តោ សយតិ ។ ឯកោ កម្មដ្ឋានំ អវិស្សជ្ជេត្វា សយតិ[៦៨] ។

"សេចក្តីដោយពិស្តារថា ភិក្ខុមួយរូបកាលដើរទៅ រមែងគិតត្រិះរិះរឿងដទៃទៅ ភិក្ខុមួយរូបដើរទៅមិនលះកម្មដ្ឋាន ដូចគ្នាយ៉ាងនេះ ភិក្ខុមួយរូបដទៃទៀត អង្គុយ ដេក រមែងត្រិះរិះរឿងដទៃកាលកំពុង

ដេក ភិក្ខុមួយរូបដេកមិនលះកម្មដ្ឋាន” ។

ពួកសម្បជញ្ញៈ

ព្រះពុទ្ធអង្គទ្រង់ត្រាស់វិធីចម្រើនសតិក្នុងពួកសម្បជញ្ញៈថា

**បុន ចបរំ ភិក្ខវេ ភិក្ខុ អភិក្កន្តេ**

**បដិក្កន្តេ សម្បជានការី ហោតិ[៦៩] ។**

“ម្នាលភិក្ខុទាំងឡាយ ឧបដិបត្តិម្យ៉ាងទៀតគឺ ភិក្ខុរមែងធ្វើការដឹងខ្លួនក្នុងការឈានទៅមុខ ក្នុងការឈានថយក្រោយ” ។

ក្នុងខណៈឈានឬថយ គប្បីតាមដឹងសភាវៈឈាន ឬថយ បរិកម្មថា “ឈានហ្ន៎” “ដើរហ្ន៎” ឬ “ថយហ្ន៎” កាលវិបស្សនាញាណមានកម្លាំងច្រើនឡើង នឹងទទួលដឹងចិត្តដែលត្រូវការនឹងឈានឬថយ ព្រមទាំងសភាវៈឈាន ឬថយ ដែលជាសភាវៈចលនាកម្រើកយ៉ាងជាក់ច្បាស់ ប្រាសចាកតួខ្លួន យើង របស់យើង ។ មានព្រះពុទ្ធតម្រាស់តទៅក្នុងពួកនេះថា

**អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ[៧០] ។**

"កិច្ចរមែងធ្វើសេចក្តីដឹងខ្លួន ក្នុងការក្រឡេក ក្នុងការងាក" ។

សូម្បីក្នុងខណៈក្រឡេក និងងាក ក៏គប្បីកំណត់ថា "មើលហ្ន៎" "ឃើញហ្ន៎" តាមសមគួរ ការបដិបត្តិដូចនេះ ចាត់ជាគោចរសម្បជញ្ញៈ ដែលចម្រើនសតិជានិច្ចមិនលះកម្មដ្ឋាន ដូចមានសាធកៈថា

**កម្មដ្ឋានស្ស បន អវិជ្ជហានមេវ គោចរសម្បជញ្ញំ ។ តស្មា ខន្ធធាតុ អាយតនកម្មដ្ឋានិកេហិ អត្តនោ កម្មដ្ឋានវសេនេវ, កសិណាទិកម្មដ្ឋានិកេហិ វា បន អត្តនោ កម្មដ្ឋាសីសេនេវ អាលោកនវិលោកនំ កាតព្វំ[៣១] ។**

"ការមិនលះបង់កម្មដ្ឋាន [ដែលជាសមថៈ ឬវិបស្សនា] ជាគោចរសម្បជញ្ញៈ ដូចនោះ អ្នកដែលចម្រើនកម្មដ្ឋាន ដែលជាខន្ធ អាយតនៈនិងធាតុ គប្បីធ្វើការក្រឡេកមើល និងងាកមើលតាមកម្មដ្ឋានរបស់ខ្លួន ឬអ្នកដែលចម្រើនកម្មដ្ឋានដែលជាកសិណជាដើម ក៏គប្បីធ្វើការក្រឡេកមើល និងងាកមើលដោយមានកម្មដ្ឋានរបស់ខ្លួនជាគោល" ។

អ្នកដែលចំរើនសមថភាវនា គប្បីរឭកដឹងកម្មដ្ឋានរបស់ខ្លួន

មានកសិណនិមិត្តជាដើមជានិច្ច សូម្បីកាលត្រូវការនឹងមើលវត្ថុណានិមួយ ក៏ត្រូវធ្វើទុកក្នុងចិត្តចំពោះកសិណនិមិត្តជាដើមនោះ ដូចជាមេគោ ក្រឡេកមើលកូនគោតូចកំពុងស៊ីស្មៅ ចំណែកអ្នកដែលចម្រើនវិបស្សនាភាវនា គប្បីអប់រំដឹងសភាវធម៌បច្ចុប្បន្នដែលប្រាកដក្នុងបច្ចុប្បន្នខណៈ ការតាមដឹងក្នុងខណៈក្រឡេកមើល និងងាកមើលនេះ មានច្រើនយ៉ាង តាមសមគួរគឺ

- កាលទទួលដឹងចិត្តដែលត្រូវការនឹងមើល គប្បីកំណត់ចិត្តនោះថា "ចង់មើលហ្ន៎" ។

- ការទទួលដឹងការបើកភ្នែក គប្បីកំណត់ថា "បើកហ្ន៎" ។

- កាលក្រឡិបក្រឡាប់ភ្នែក គប្បីកំណត់ថា "កម្រើកហ្ន៎" ។

- កាលចលនាមុខឬក គប្បីកំណត់ថា "កម្រើកហ្ន៎" ។

- កាលឃើញ គប្បីកំណត់ថា "ឃើញហ្ន៎" ។

- កាលគិតពិចារណាកើតឡើងអំពីការឃើញ គប្បីកំណត់ថា "គិតហ្ន៎" ។

- មានព្រះពុទ្ធតម្រាស់តទៅក្នុងពួកនេះថា

*សមិញ្ជិតេ បសារិតេ សម្បជានការី ហោតិ*[៧២] ។

"ភិក្ខុរមែងធ្វើសេចក្តីដឹងខ្លួន ក្នុងការបត់ចូល ក្នុងការលាតចេញ" ។

ក្នុងខណៈបត់ចូល លាតចេញ គប្បីកំណត់តាមអាកប្បកិរិយានោះ ៗ ថា "បត់ហ្ន៎" "លាតហ្ន៎" "រុញហ្ន៎" "ទាញហ្ន៎" "កម្រើកហ្ន៎" "ញ័រហ្ន៎" កាលវិបស្សនាញាណចាស់ក្លាហើយ អ្នកបដិបត្តិ នឹងអាចទទួលដឹងដល់ចិត្តដែលត្រូវការនឹងបត់ និងលាតបានទៀតផង ។

ក្នុងគម្ពីរអដ្ឋកថាពោលដល់រឿងការបត់ចូល និងលាតចេញរបស់ព្រះថេរៈមួយរូបទុកថា ព្រះថេរៈមួយអង្គកំពុងសន្ទនាជាមួយសិស្ស បានបត់ដៃចូលយ៉ាងលឿនដោយភ្លេចសតិ លោកទើបបត់ដៃចេញហើយបត់ដៃចូលមួយដងទៀតយឺតៗ សិស្សរបស់លោកសង្ស័យទើបសួរថា ហេតុអ្វីធ្វើយ៉ាងនេះ លោកឆ្លើយថា យើងមិនធ្លាប់ភ្លេចសតិបត់ដៃចូលតាំងពីពេលបដិបត្តិធម៌ជាដើមមក តែ

ក្នុងពេលកំពុងសន្ទនានេះ បានបត់ដៃចូលដោយប្រាសចាកសតិ កំណត់ដឹងទើបធ្វើដដែលៗ ដើម្បីដាស់តឿនសតិក្នុងឱកាសតទៅ ពេលនោះសិស្សរបស់លោកទើបពោលសាធុការ ។

រឿងនេះ សម្ដែងដល់ការបត់ចូល និងលាតចេញដោយមានសតិកំពុងដឹកនាំរហូតកាលនិងបង្រៀនឲ្យធ្វើយ៉ាងយឺតៗ ការទទួលដឹងសភាវៈបត់លាត ព្រមទាំងចិត្តដែលត្រូវការនឹងធ្វើអាកប្បកិរិយាពួកនេះ ឈ្មោះថា **គោចរសម្បជញ្ញៈ** បន្តកាលវិបស្សនាចាស់ក្លាឡើង អ្នកបដិបត្តិនឹងដឹងច្បាស់ថា មិនមានតួខ្លួន អ្នកធ្វើការចលនាកម្រើកមានត្រឹមតែសភាវៈចលនា អំពីរយៈពេលមួយទៅកាន់រយៈពេលមួយទៀត ដោយកើតអំពីចិត្តដែលត្រូវការធ្វើ ដែលកើតឡើងមុនខាងមុខហើយរលត់ទៅ គេរមែងនឹងកើតបញ្ញាឃើញច្បាស់ថា ចលនាក្នុងការបត់ចូល និងលាតចេញនោះកើតឡើងហើយ និងរលត់ទៅមួយខណៈៗ ក្នុងសភាវៈបត់មិនមានសភាវៈលាត ក្នុងសភាវៈលាតមិនមានសភាវៈបត់ បញ្ញាដូចពោល រមែងជាក់ច្បាស់ក្នុងត្រៃលក្ខណ៍ គឺសភាពមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ឈ្មោះថា

អសម្មោហសម្បជញ្ញៈ ។

ការបរិកម្មថា "បត់ហ្ន៎" "លាតហ្ន៎" ជួយឲ្យអ្នកបដិបត្តិដឹងខ្លួនថា កំពុងតាមដឹងបច្ចុប្បន្នក្នុងខណៈនោះ ចិត្តរបស់អ្នកបដិបត្តិនឹងទទួលដឹងពាក្យបញ្ញត្តិស្តាប់គ្នា ទៅជាមួយសភាវៈចលនាកម្រើក តែកាលវិបស្សនាញាណចាស់ក្លាហើយ អ្នកបដិបត្តិនឹងទទួលដឹងដល់ចិត្តដែលត្រូវការនឹងចលនា និងទទួលដឹងសភាវៈចលនា ដែលកើតរលត់យ៉ាងលឿនរហ័ស ក្នុងខណៈនោះ អ្នកបដិបត្តិនឹងទទួលដឹងសភាវធម៌បានដោយមិនចាំបាច់បរិកម្ម ។

មានព្រះពុទ្ធតម្រាស់តទៅក្នុងពូកនេះថា

សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ[៧៣] ។

"ភិក្ខុរមែងធ្វើការដឹងខ្លួនក្នុងការស្លាយសំពត់សង្ឃាដិ ទ្របាត្រ និងដណ្តប់ចីវរ" ។

ក្នុងវេលាស្លៀកដណ្តប់ចីវរ ទ្រទ្រង់សំពត់សង្ឃាដី គប្បីកំណត់តាមសភាវៈនោះៗ ថា "ស្លៀកហ្ន៎" "ដណ្តប់ហ្ន៎" ជាដើម ក្នុងពេលកាន់ភាជនៈ ដូចជាបាត្រ កែវ ចាន ស្លាបព្រា គប្បីកំណត់

ថា "ចាប់ហ្ន៎" "កាន់ហ្ន៎" "ដាក់ហ្ន៎" "ត្រូវហ្ន៎" កាលវិបស្សនាញាណចាស់ក្លាឡើង អ្នកបដិបត្តិនឹងទទួលដឹងចិត្ត ដែលត្រូវការនឹងធ្វើអាកប្បកិរិយានោះៗ ព្រមទាំងអាកប្បកិរិយាកម្រើក និងសភាវៈប៉ះខ្ទប់ផ្លូវកាយ ។

មានព្រះពុទ្ធតម្រាស់តទៅក្នុងពួកនេះថា

**អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ**[៧៤] ។

"ភិក្ខុរមែងធ្វើសេចក្ដីដឹងខ្លួនក្នុងការឆាន់ ការផឹក ការទំពារ និងការភ្លក្ស" ។

ក្នុងពេលឆាន់ គប្បីកំណត់ថា "ឆាន់ហ្ន៎" "ផឹកហ្ន៎" "ទំពារហ្ន៎" "ភ្លក្សហ្ន៎" "លេបហ្ន៎" កាលវិបស្សនាញាណចាស់ក្លាឡើង អ្នកបដិបត្តិនឹងទទួលដឹងចិត្ត ដែលត្រូវការធ្វើអាកប្បកិរិយានោះៗ ព្រមទាំងសភាវៈកម្រើក និងការទទួលដឹងដោយជិវ្ហាវិញ្ញាណ ។

ម្យ៉ាងទៀតក្នុងគម្ពីរព្រះអដ្ឋកថាចារ្យ[៧៥] បានពោលដល់អសម្មោហសម្បជញ្ញៈទុកក្នុងរឿងពិចារណាអាហារថាជាវត្ថុបដិកូល ( អាហារេបដិកូលសញ្ញា ) ដោយពោលថា អាហារជារបស់

បដិកូលដោយអាការៈ ១០ យ៉ាង មានការទៅ ការស្វែងរក ការបរិភោគ កន្លែងដែលថែរក្សា និងការផ្ទាប់ជាដើម សេចក្ដីដូចដែលពោលមកនេះ ជាអសម្មោហសម្បជញ្ញៈ ដែលជាប់ទាក់ទងជាមួយសមថភាវនា មិនមែនវិបស្សនាភាវនា ។

ន័យម្យ៉ាងទៀត កាលគោចរសម្បជញ្ញៈចាស់ក្លាឡើងដោយការកំណត់ថា "ឆាន់ហ្ន៎" "ផឹកហ្ន៎" "ទំពារហ្ន៎"ជាដើម អ្នកបដិបត្តិអាចកើតការដឹងខ្ពើមឆ្អើមថា ជាវត្ថុបដិកូល និងឃើញថា ជាការៈក្នុងការទំពារស៊ី អ្នកខ្លះទទួលទានអាហារបានមិនឆ្អែត ព្រោះដឹងត្រឹមថាគួរខ្ពើមសំគាល់ថា អាហារជាវត្ថុបដិកូលនេះ កើតឡើងកាលគោចរសម្បជញ្ញៈ មានកម្លាំងចាស់ក្លាហើយ ដូច្នោះ ព្រះអដ្ឋកថាចារ្យទើបពោលដល់រឿងនេះទុក ក្នុងអសម្មោហសម្បជញ្ញៈ។

មានព្រះពុទ្ធតម្រាស់តទៅក្នុងពួកនេះថា

**ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ**[៧៦] ។

"ភិក្ខុរមែងធ្វើសេចក្ដីដឹងខ្លួន ក្នុងការបន្ទោរបង់នូវឧច្ចារៈ និងបស្សាវៈ" ។

ក្នុងខណៈ បន្ទោរបង់ឧច្ចារៈ និងបស្សាវៈ គប្បីកំណត់ថា "បន្ទោរបង់ហ្ន៎" ជាដើម ពិតហើយ ការចម្រើនវិបស្សនា ជាការទទួលដឹងរូបនាមតាមសភាវៈពិត មិនមានការរៀរអារម្មណ៍ ដែលល្អលើស ឬអាក្រក់ ព្រោះអារម្មណ៍គ្រប់យ៉ាងដូចសំពត់ស ដែលមកប្រាកដក្នុងចិត្ត បើយើងទទួលដឹងអារម្មណ៍ដោយសតិ និងបញ្ញា ក៏ដូចជាការចាប់សំពត់ដោយដៃដែលស្អាត បើទទួលដឹងអារម្មណ៍ដោយសេចក្ដីលោភជាដើម ក៏ដូចជាការចាប់ដោយដៃដែលកខ្វក់ កាលវិបស្សនាញាណចាស់ក្លាឡើង អ្នកបដិបត្តិនឹងទទួលដឹងចិត្តដែលត្រូវការនឹងបន្ទោរបង់ និងសភាវៈចលនារបស់រូបធម៌ ព្រមដោយទុក្ខវេទនាដែលកើតឡើងក្នុងខណៈនោះជាដើម ។

មានព្រះតម្រាស់តទៅក្នុងពួកនេះថា

**គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ**[៧៧] ។

"ភិក្ខុរមែងធ្វើសេចក្ដីដឹងខ្លួនក្នុងការដើរ ការឈរ ការអង្គុយ ការដេកលក់ ការភ្ញាក់ឡើង ការនិយាយ និងការនៅស្ងៀម" ។

ការកំណត់ដឹងក្នុងខណៈដើរ ឈរ និងអង្គុយ ដូចជាមួយពួកឥរិយាបថដែលពោលមកហើយក្នុងខណៈអង្គុយដេក គប្បីកំណត់ថា "អង្គុយដេកហ្ន៎" "ដេកមួយស្របក់ហ្ន៎" "ងក់ហ្ន៎" "ជួន់ហ្ន៎" កាលអង្គុយដេកខ្លាំង គប្បីលាតកាយដេកហើយកំណត់ថា "ដេកហ្ន៎ៗ" ជាដើម ដោយទទួលដឹងរូបនាម ដែលប្រាកដច្បាស់ក្នុងមួយខណៈៗ ។

ក្នុងខណៈភ្ញាក់ឡើង គប្បីកំណត់ចិត្តភ្ញាក់នោះថា "ភ្ញាក់ហ្ន៎" ចិត្តដូចពោលមិនប្រាកដច្បាស់ ក្នុងពេលចាប់ផ្តើមបដិបត្តិ ចំណែកខាងក្រោយ កាលសមាធិមានកម្លាំងហើយ អ្នកបដិបត្តិទើបអាចកំណត់បាន យ៉ាងណាក៏ដោយ កាលភ្ញាក់ឡើងដឹងខ្លួន ក៏គួរកំណត់ថា "ភ្ញាក់ហ្ន៎"អ្នកបដិបត្តិរមែងកើតបញ្ញាឃើញច្បាស់ថា រូបនាមដែលកើតឡើងមុន និងលក់បាន រលត់ទៅមុនជាប់តគ្នាដល់ខណៈលក់ ការលក់គឺការកើតឡើងរបស់ចិត្តដែលមិនអាចធ្វើការគិត កំណត់ឃើញ បានឮ ឬប៉ះខ្លួបជាដើម រូបនាមក្នុង ខណៈលក់ ក៏រលត់ទៅមុនដែលនឹងដល់ខណៈភ្ញាក់ ការភ្ញាក់គឺ ការកើតឡើងរបស់

ចិត្តដែលធ្វើការគិតជាដើមបាន មិនមានតួខ្លួនអ្នកដេក ឬ អ្នកភ្ញាក់យ៉ាងពិតប្រាកដ និងមិនមានសភាវៈដែលទៀង ជាសុខ បន្ទាប់បញ្ញាបាន ការឃើញយ៉ាងនេះឈ្មោះថា អសម្មោហសម្បជញ្ញៈ ។

ក្នុងខណៈនិយាយគប្បីកំណត់ថា "ចង់និយាយហ្ន៎" "និយាយហ្ន៎" តែការនិយាយធ្វើឲ្យភ្លេចសតិនិងបណ្ដាលឲ្យគិតរវើរវាយរឿងរ៉ាវដែលនិយាយខាងក្រោយ អ្នកបដិបត្តិ ទើបមិនគួរនិយាយគ្នាក្នុងវាងការបដិបត្តិធម៌ លើកលែងតែមានហេតុសំខាន់ពិតៗ កាលវិបស្សនាញាណចាស់ក្លាហើយ រមែងទទួលដឹងចិត្ត ដែលលំបាកនឹងនិយាយ និងរូបដែលចលនាប៉ះខ្ទប់គ្នា កាលនិយាយហើយឈប់និយាយក៏គប្បីកំណត់រូបនាមដែលប្រេចក្សក្នុងខណៈនោះថា "ចង់ឈប់ហ្ន៎" "ឈប់ថាហ្ន៎" "ស្ងៀមហ្ន៎" កាលវិបស្សនាញាណមានកម្លាំងខ្លាំងឡើងនឹងដឹងច្បាស់ថា រូបនាមដែលកើតឡើងក្នុងខណៈនិយាយបានរលត់ទៅមុន មិនជាប់តគ្នាដល់ខណៈនៅស្ងៀមសូម្បីចិត្តដែលត្រូវការនឹងស្ងៀម និងរូបស្ងៀមក៏កើតឡើងហើយរលត់ទៅមួយរំពេចក្នុងខណៈនោះ ការឃើញយ៉ាងនេះ ក៏ចាត់ជា

អសម្មោហសម្បជញ្ញៈ ។

កាលអ្នកបដិបត្តិតាមដឹងកងរូបខាងក្នុងរាងកាយប្រវែងមួយព្យាម កម្រាស់ប្រវែង ១ ចំអាម ទទឹងមួយហត្ថយ៉ាងនេះហើយកើតបញ្ញាឃើញនូវព្រះត្រៃលក្ខណ៍ថា រូបនាមដែលតាមដឹងក្នុងបច្ចុប្បន្នខណៈនោះ មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ក៏ចាត់ថាបានអនុមានដឹងកងរូបនាមខាងក្នុងរាងកាយថា មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ក្នុងខណៈខ្លះកាលតាមដឹងកងរូបខាងក្នុងថា "ចង់ដើរហ្ន៎" "ដើរហ្ន៎" អាចកើតការយល់ថា សូម្បីសភាវៈដើររបស់មនុស្សដទៃក៏ដូចជាមួយសភាវៈដើររបស់ខ្លួន ក្នុងខណៈនោះចាត់ថា បានតាមដឹងទាំងកងរូបខាងក្នុងនិងកងរូបខាងក្រៅបញ្ច្រាស់គ្នាទៅ ដូចសាធកៈក្នុងពួកសម្បជញ្ញៈនេះថា

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ ។ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ[៧៨] ។**

"ដូចពណ៌នានេះ ភិក្ខុរមែងតាមដឹងក្នុងកងរូបខាងក្នុងថា ជាកង

រូបខ្លះ តាមដឹងកងរូបខាងក្រៅថា ជាកងរូបខ្លះ តាមដឹងកងរូបទាំងខាងក្នុងទាំងខាងក្រៅថា ជាកងរូបខ្លះ" ។

តអំពីនោះព្រះពុទ្ធអង្គបានត្រាស់ថា

សមុទយធម្មានុបស្សី វា កាយស្មិំ វិហរតិ ។ វយធម្មានុបស្សី វា កាយស្មិំ វិហរតិ ។ សមុទយវយធម្មានុបស្សី វា កាយស្មិំ វិហរតិ[៧៨] ។

"ភិក្ខុតាមដឹងសភាវៈ គឺការកើតឡើងក្នុងកងរូបខ្លះ តាមដឹងសភាវៈគឺការរលត់ក្នុងកងរូបខ្លះ តាមដឹងសភាវៈ គឺទាំងការកើតឡើងទាំងការរលត់ទៅក្នុងកងរូបខ្លះ" ។

ពាក្យថា "សភាវៈ គឺការកើតឡើង" សំដៅដល់ ការកើតឡើងរបស់ចិត្តដែលត្រូវការទីងដើរ និងរូបដែលកំពុងចលនាជាដើម ។

ពាក្យថា "សភាវៈ គឺការរលត់" សំដៅដល់ការរលត់នៃចិត្ត និងកងរូបពួកនោះ ។

អ្នកបដិបត្តិដែលទទួលដឹងសភាវៈ គឺការកើតឡើង និងការ

វលត់នោះ អាចយល់ហេតុដែលធ្វើឲ្យកងរូបកើតឡើងនិងរលត់ទៀតផង ពោលគឺ កងរូបកើតអំពីហេតុ គឺចិត្តដែលត្រូវការនឹងធ្វើអាកប្ប-កិរិយាផ្សេងៗ បើមិនមានចិត្តដូចពោល រូបក៏កើតឡើងមិនបាន ក្រៅអំពីនេះ រូបនៅកើតអំពីហេតុដទៃដែលបានដល់អវិជ្ជា ( ការមិនដឹងការកើតក្នុងភពមុន ) តណ្ហា ( សេចក្តីភ្លើតភ្លើនក្នុងកាមគុណដែលកើតក្នុងភពមុន ) កម្ម ( ការធ្វើក្នុងភពមុន ) និងអាហារ ( វត្ថុដែលផឹកស៊ីក្នុងភពនេះ ) ទៀតផង បើមិនមានសភាវៈពួកនោះ ក៏មិនមានរូប ការយល់ចូលចិត្តហេតុកើត និងហេតុរលត់របស់កងរូបអាចកើតឡើងក្នុងខណៈខ្វះយ៉ាងនេះ សមពិតដូចសាធកៈថា

តស្ស វិត្ថារោ "អវិជ្ជាសមុទយា រូបសមុទយោ, តណ្ហា-សមុទយា រូបសមុទយោ, កម្មសមុទយា រូបសមុទយោ, អាហារសមុទយា រូបសមុទយោ"តិ ។ អត្ថង្គមេបិ អវិជ្ជានិរោធា រូបនិរោធោ ។បេ។[៤០]

"គប្បីជ្រាបសេចក្តីពិស្តារនៃហេតុកើតនោះថា រូបកើតឡើងព្រោះអវិជ្ជា តណ្ហា កម្មនិងអាហារកើតឡើង សូម្បីក្នុងហេតុរលត់

ក៏មានសេចក្តីពិស្តារថា រូបរលត់ព្រោះអវិជ្ជារលត់" ។

ព្រះពុទ្ធអង្គទ្រង់សម្តែងផលការបដិបត្តិតទៅទៀតថា

**អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ។ ន ច កិញ្ចិ លោកេ ឧបាទិយតិ[៩១] ។**

"មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង" ។

អ្នកបដិបត្តិចម្រើនសតិរឭកដឹងថា "ចង់ដើរហ្នឹ" "ដើរហ្នឹ" ជាដើម រមែងយល់ថា មានត្រឹមចិត្តដែលត្រូវការនឹងចលនា និងកងរូបដែលកំពុង ចលនា វត្ថុដែលមនុស្សក្នុងលោកសន្មតិថា ជាបុគ្គល យើង របស់យើង មិនមានទៅពិត កាលវិបស្សនាញាណចាស់ក្លា ហើយអ្នកបដិបត្តិអាចដឹង ត្រឹមថា អវយវៈចំណែកខ្លះក្នុងរាងកាយ

ឬ រាងកាយទាំងអស់វិនាសទៅ ការចម្រើនសតិរបស់លោករមែង ប្រព្រឹត្តទៅដើម្បីចម្រើនបញ្ញាឃើញសភាវធម៌យ៉ាងពិតប្រាកដ លោកមិនត្រូវតណ្ហាអាស្រ័យលើដោយការកើតកើនក្នុងរូបនាម ដែលកំពុងកំណត់ដឹងនិងមិនត្រូវទិដ្ឋិអាស្រ័យលើដោយការឃើញខុសក្នុងតួខ្លួន រមែងប្រាសចាកនូវសេចក្តីប្រកាន់មាំក្នុងលោក គឺ ឧបាទានក្ខន្ធ ៥ ។

ចប់ កាយានុបស្សនា

## វេទនានុបស្សនា

ព្រះអង្គត្រាស់ការចំរើនវេទនានុបស្សនាក្នុងមហាសតិប្បដ្ឋាន-សូត្រថា

**ឥធ ភិក្ខវេ ភិក្ខុ សុខំ វា វេទនំ វេទយមានោ សុខំ វេទនំ វេទយាមីតិ បជានាតិ ។ ទុក្ខំ វា វេទនំ វេទយមានោ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ ។ អទុក្ខមសុខំ វា វេទនំ វេទយមានោ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ[១២] ។**

“ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេ-

ទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា ។ កាលទទួលទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា ។ កាលទទួលអទុក្ខមសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា" ។

ក្នុងពេលសោយវេទនា គឺ មានសេចក្តីដឹងខ្លួនយ៉ាងណានិមួយដែលជាសុខទុក្ខ ឬព្រងើយ គប្បីតាមដឹងសភាវៈនោះដោយកំណត់ថា "សុខហ្ន៎" "ទុក្ខហ្ន៎" "ព្រងើយហ្ន៎" ។

សុខវេទនា គឺ ការដឹងខ្លួនជាសុខផ្លូវកាយ បានដល់ស្រស់ស្រាយសប្បាយ ឬការដឹងខ្លួនថា ជាសុខផ្លូវចិត្ត បានដល់ការសប្បាយចិត្ត រីករាយសោមនស្សត្រេកអរក្នុងសភាពពិត ក្មេងដែលនៅមិនទាន់បណ្តាច់ដោះ ឬមនុស្សទូទៅក៏ដឹងបានថាជាសុខ តែជាការដឹងដោយសភាពមានតួខ្លួនថា យើងជាសុខ និងសេចក្តីសុខនេះក៏ជារបស់ទៀងមិនប្រែប្រួល នឹងជាការមិនដឹងថាសុខវេទនាត្រឹមតែជាសភាវធម៌ដែលកើតឡើងតាមហេតុបច្ច័យទើបមិនអាចនឹងលះបង់អត្តសញ្ញា គឺ ការសម្គាល់ថា មានតួខ្លួន ។

អ្នកបដិបត្តិដែលតាមដឹងវេទនា តាមសេចក្ដីពិត រមែងដឹងច្បាស់ថា មានត្រឹមតែសភាវធម៌ដែលកើតឡើងអំពីរយៈពេលមួយទៅកាន់រយៈពេលមួយទៀត កាលកើតឡើងហើយក៏រលត់ទៅ មិនទៀង ជាទុក្ខ មិនមែនតួខ្លួន មិនមានយើង របស់យើង អ្នកកំពុងសោយវេទនានោះៗ ដូចសាធកៈក្នុងគម្ពីរអដ្ឋកថាថា

***វត្ថុំ អារម្មណំ កត្វា វេទនាវ វេទយតីតិ សល្លក្ខេន្តោ ឯស សុខំ វេទនំ វេទយាមីតិ បជានាតីតិ វេទិតព្វោ*[៩៣] ។**

"គប្បីជ្រាបថា ភិក្ខុអ្នកកំពុងកំណត់វេទនាថា វេទនាប៉ុណ្ណោះរមែងសោយអារម្មណ៍ ដោយទទួលយកអារម្មណ៍ដែលជាហេតុនៃសេចក្ដីសុខ រមែងដឹងច្បាស់ថា កំពុងសោយសុខវេទនា" ។

ពាក្យពោលថា "វេទនាប៉ុណ្ណោះរមែងសោយអារម្មណ៍" សំដៅដល់ការទទួលដឹងលក្ខណៈវិសេសរបស់វេទនា ។

ពាក្យពោលថា "ដោយយកអារម្មណ៍ដែលជាហេតុនៃសេចក្ដីសុខ" សំដៅដល់ការទទួលយកហេតុជិតរបស់វេទនា គឺអារម្មណ៍ដែលគួរពេញចិត្ត ។

ទុក្ខវេទនា គឺ ការដឹងខ្លួនជាទុក្ខផ្លូវកាយ បានដល់ការឈឺ ចុកចាប់ អស់កម្លាំង ស្ពឹក រមាស់ ក្តៅ ត្រជាក់ ចុកសៀត ទៀយហត់ ឬការដឹងខ្លួន ជាទុក្ខផ្លូវចិត្តបានដល់ការសោយសោក ខូចចិត្ត ខ្លាច មិនសប្បាយចិត្ត ក្តៅក្រហាយចិត្ត ខ្វល់ខ្វាយ អ្នកបដិបត្តិគប្បីតាមដឹងទុក្ខវេទនាតាមអាការនោះៗ ថា "ឈឺហ្ន៎" "ចុកហ្ន៎" "អស់កម្លាំងហ្ន៎" "ស្ពឹកហ្ន៎" "រមាស់ហ្ន៎" "ក្តៅហ្ន៎" "ត្រជាក់ហ្ន៎" "ចុកសៀតហ្ន៎" "ទៀយហត់ហ្ន៎" ឬ "សោយសោកហ្ន៎" "ខូចចិត្តហ្ន៎" "ខ្លាចហ្ន៎" "មិនសប្បាយចិត្តហ្ន៎" "ក្តៅក្រហាយចិត្តហ្ន៎" "កង្វល់ហ្ន៎" ។

កន្លែងខ្លះពោលថា ការចម្រើនវិបស្សនា គឺ ការស្វាធ្យាយពាក្យបញ្ញត្តិថា រូបនាម ធាតុដី ធាតុទឹក ផស្សៈ វេទនា សុខ ទុក្ខ ការឃើញដូចពោលមិនត្រឹមត្រូវ ព្រោះការទទួលដឹងសភាវធម៌របស់រូបនាមជាគោលសំខាន់ក្នុងការបដិបត្តិធម៌ មិនមែនការទទួលដឹងពាក្យបញ្ញត្តិ អ្នកដែលអត់ធន់តាមដឹងទុក្ខវេទនាថា "ចុកហ្ន៎" រមែងអាចទទួលដឹងលក្ខណៈវិសេស គឺ ការអត់ធន់បានលំបាករបស់ទុក្ខវេទនា និងលក្ខណៈទូទៅ គឺ ត្រៃលក្ខណ៍បាន សូម្បី

នឹងមិនដឹងថា វត្ថុនេះហៅថាទុក្ខវេទនា ក៏រាប់ថា បានទទួលដឹងសភាវៈដែលពិតនៃទុក្ខវេទនាហើយ ។

ឧបេក្ខាវេទនា គឺ ការដឹងខ្លួនជាកណ្តាល មិនសុខមិនទុក្ខវេទនាប្រភេទនេះ មិនប្រចក្សច្បាស់ដូចសុខវេទនានិងទុក្ខវេទនា ក្នុងអដ្ឋកថា ដែលអធិប្បាយចូលវេទល្លសូត្រ[៩៤] សង្គីតិសូត្រ[៩៥] និងពហុធាតុកសូត្រ[៩៦] ពោលថា ឧបេក្ខាវេទនាជាវត្ថុដែលដឹងបានលំបាក ដូចអវិជ្ជាដែលកើតព្រមជាមួយលោភៈ និងទោសៈ មានន័យថា ក្នុងកាលកើតលោភៈ និងទោសៈនោះ មានអវិជ្ជាកើតរួមដោយធ្វើនាទីបិតបាំងទោសរបស់សេចក្តីលោភ និងសេចក្តីក្រោធ ធ្វើឲ្យបុគ្គលពេញចិត្តនឹងលោភនិងក្រោធ ឧបេក្ខាក៏ដូចគ្នា មិនមែនប្រចក្សបានក្នុងពេលប្រក្រតី តែនឹងប្រាកដឡើងក្រោយអំពីសុខ-វេទនា ឬទុក្ខវេទនាបាត់ទៅហើយ កាលអ្នកបដិបត្តិបន្ទុះវិបស្សនាញាណជាន់ទី ៤ ជាដើមហើយ ឧបេក្ខាវេទនាអាចប្រាកដច្បាស់ក្នុងគ្រាខ្លះ អ្នកបដិបត្តិគប្បីតាមដឹងឧបេក្ខាវេទនាថា "ព្រងើយហ្ន៎" ដូចមានសាធកៈថា

**អទុក្ខមសុខា បន ទុទ្ទីបនា ។ អន្ធការា អវិភូតា ។ សា សុខទុក្ខានំ អបគមេ សាតាសាតប្បដិក្ខេបវសេន មជ្ឈត្តាការភូតា អទុក្ខមសុខា វេទនាតិ នយតោ គណ្ហន្តស្ស បាកដា ហោតិ**[៩៧] ។

“ចំណែកឧបេក្ខាវេទនា ជាវេទនាដែលដឹងបានលំបាក មិនប្រាកដច្បាស់ដូចភាពងងឹត ឧបេក្ខាវេទនានោះប្រាកដដល់អ្នកយល់ចូលចិត្តតាមន័យថា ឧបេក្ខាវេទនា មានការព្រងើយជាកណ្ដាលដោយការបដិសេធសេចក្ដីពេញចិត្ត ឬមិនពេញចិត្តក្នុងពេលដែលសុខវេទនា ឬទុក្ខវេទនាបាត់ទៅ” ។

**ទុទ្ទីបនាតិ ញាណេន ទីបេតុំ អសក្កុណេយ្យា ។ ទុព្វិញ្ញេយ្យាតិ អត្ថោ ។ តេនាហ អន្ធការា អវិភូតាតិ**[៩៨] ។

“ពាក្យថា **ទុទ្ទីបនា** ( ដឹងបានលំបាក ) មានន័យថា មិនអាចដឹងដោយបញ្ញាបាន ពោលគឺ យល់ចូលចិត្តបានលំបាក ដូច្នោះព្រះអដ្ឋកថាចារ្យ ទើបពោលថា **អន្ធការា អវិភូតា** ( មិនប្រាកដច្បាស់ដូចភាពងងឹត )” ។

តមកព្រះពុទ្ធអង្គទ្រង់ចែកសុខវេទនាចេញជាសុខអាស្រ័យ

កាមគុណជាដើម ដូចព្រះពុទ្ធវចនៈថា

*សាមិសំ វា សុខំ វេទនំ វេទយមានោ សាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ ។ និរាមិសំ វា សុខំ វេទនំ វេទយមានោ និរាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ*[៥៩] ។

“ភិក្ខុកាលទទួលសុខវេទនាប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនាប្រកបដោយអាមិសៈ ។ កាលទទួលសុខវេទនាដែលឥតអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនាដែលឥតអាមិសៈ” ។

សុខអាស្រ័យអាមិសៈ ( **សាមិសសុខ** ) សំដៅដល់ការពេញចិត្តជាប់ទាក់ទងជាមួយកាមគុណ ៥ គឺ រូប សម្លេង ក្លិន រស និងសម្ផស្ស បានដល់វត្ថុដែលខ្លួនស្រឡាញ់ពេញចិត្តដែលស្ថិតនៅខាងក្នុង និងខាងក្រៅរាងកាយ ក្នុងកន្លែងខ្លះ ហៅថា **គេហសិតសោមនស្ស** គឺ សោមនស្សអាស្រ័យផ្ទះសោមនស្សប្រភេទនេះ មានសេចក្តីក្លើតក្លើនចំពោះរូបដែលប្រទះឃើញក្នុងពេលទទួលយករូបដែលស្រស់ស្អាតជាអារម្មណ៍ឬពេញចិត្តសម្លេង

ក្នុងពេលទទួលយកសម្លេងដែលពិរោះជាអារម្មណ៍ អ្នកបដិបត្តិគប្បីតាមដឹងសេចក្តីពេញចិត្តនោះដោយកំណត់ថា "ស្រឡាញ់ហ្ន៎" ។

អ្នកដែលចម្រើនវិបស្សនាតាមដឹងសភាវធម៌ ដែលមកប្រាកដផ្លូវទ្វារទាំង ៦ រមែងឃើញច្បាស់ការកើតរលត់របស់អារម្មណ៍បច្ចុប្បន្នពួកនោះ រាប់ថា បានដឹងច្បាស់ការមិនទៀង គឺ អនិច្ចំ គេរមែងអនុមានដឹងថា សូម្បីអារម្មណ៍ ៦ ដែលជាអតីត និងបច្ចុប្បន្នទាំងអស់ក៏មានសភាពមិនទៀងដូចគ្នា បុគ្គលដូចដែលពោល រមែងកើតបីតិសោមនស្ស នេះ ឈ្មោះថា សុខមិនអាស្រ័យអាមិសៈ ( និរាមិសសុខ ) ក្នុងកន្លែងខ្លះហៅថា នេក្ខមសិតសោមនស្ស គឺសោមនស្សអាស្រ័យវិបស្សនា ដូចសេចក្តីក្នុងគម្ពីរឧបរិបណ្ណាសកៈថា

រូបានំ ត្វេ អនិច្ចំ វិទិត្វា វិបរិណាមំ វិរាគំ និរោធំ បុព្វេ ចេវ រូបា ឯតរហិ ច ។ សព្វេ តេ រូបា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ឧប្បជ្ជតិ សោមនស្សំ ។ យំ ឯវរូបំ សោមនស្សំ, វុច្ចតិ នេក្ខម្មស្សិតំ

សោមនស្ស[៩០] ។

"បុគ្គលកាលជ្រាបសភាវៈមិនទៀង សភាវៈប្រែប្រួល ប្រាសចាកតម្រេក និងការរលត់នៃរូបទាំងឡាយ ហើយឃើញដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា រូបក្នុងកាលមុននិងកាលឥឡូវនេះទាំងអស់នោះ មិនទៀង ជាទុក្ខ មានសភាវៈប្រែប្រួលជាធម្មតា រមែងកើតសោមនស្សឡើង សោមនស្សដូច្នេះ ហៅថា សោមនស្សអាស្រ័យវិបស្សនា" ។

បីតិសោមនស្សនេះ រមែងប្រាកដច្បាស់កាលបន្ទុះវិបស្សនាញាណទី ៤ ឈ្មោះថា **ឧទយព្វយញ្ញាណ** គឺ បញ្ញាដឹងច្បាស់ការកើតរលត់ អ្នកបដិបត្តិគប្បីតាមដឹងបីតិសោមនស្សដោយកំណត់ថា "ពេញចិត្តហ្ន៎" ឬ "សុខហ្ន៎" ។

តពីនោះ ព្រះអង្គទ្រង់ចែកទុក្ខវេទនាចេញជាទុក្ខអាស្រ័យអាមិសៈជាដើម ដូចព្រះពុទ្ធវចនថា

*សាមិសំ វា ទុក្ខំ វេទនំ វេទយមានោ សាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ ។ និរាមិសំ វា ទុក្ខំ វេទនំ វេទយមានោ*

និរាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ[១] ។

“ក៏កាលទទួលទុក្ខវេទនាប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនាប្រកបដោយអាមិសៈ កាលទទួលទុក្ខវេទនាដែលឥតអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនាដែលឥតអាមិសៈ” ។

អ្នកដែលជួបជាមួយសេចក្តីទុក្ខផ្លូវកាយឬទុក្ខផ្លូវចិត្ត កាលមិនប្រាថ្នាកាមគុណខាងក្នុងឬខាងក្រៅ ឬត្រឡប់គិតដល់ទុក្ខដែលធ្លាប់ជួបប្រទះមកមុន រមែងកើតទុក្ខដែលហៅថា ទុក្ខអាស្រ័យអាមិសៈ (សាមិសទុក្ខ) អ្នកបដិបត្តិគប្បីកំណត់ថា “ទុក្ខហ្ន៎” ឬ “ខូចចិត្តហ្ន៎” ។

អ្នកបដិបត្តិបន្ទុះឧទយព្វយញ្ញាណជាដើមទៅ រមែងសង្ឃឹមក្នុងការសម្រេចមគ្គផល ដែលព្រះអរិយៈទាំងឡាយឃើញច្បាស់ហើយ អ្នកខ្លះបដិបត្តិធម៌អស់កាលយូរ ក៏មិនអាចសម្រេចមគ្គផលបាន ឬអ្នកខ្លះ ក៏មិនជួបប្រទះសេចក្តីចម្រើនក្នុងការបដិបត្តិធម៌តាមសេចក្តីប្រាថ្នា ទើបកើតការខូចចិត្តដែលជាប់ទាក់ទងជាមួយវិបស្សនា ការខូចចិត្តប្រភេទនេះហៅថា ទុក្ខមិនអាស្រ័យអាមិសៈ

( និរាមិសទុក្ខ ) ក្នុងកន្ទែងខ្លះហៅថា ទេក្ខម្មសិតទោមនស្ស គឺទោមនស្សអាស្រ័យវិបស្សនា ក្នុងខណៈនោះ គប្បីកំណត់ថា "ខូចចិត្តហ្ន៎" គម្ពីរអដ្ឋកថា ពោលដល់រឿងរបស់ព្រះមហាសិវៈជាឧទាហរណ៍ក្នុងរឿងនេះ[៩២] ។

ព្រះមហាសិវត្ថេរជាអ្នកជំនាញបរិយត្តិធម៌ បង្រៀនភិក្ខុ ១៨ គណៈ សិស្សរបស់លោកបដិបត្តិតាមពាក្យណែនាំហើយ សម្រេចជាព្រះអរហន្ត ៣ ម៉ឺនអង្គ ថ្ងៃមួយមានសិស្សមួយរូបបានពិចារណាគុណធម៌ដែលខ្លួនបានសម្រេចហើយត្រិះរិះថា អាចារ្យរបស់យើងមានគុណូបការដល់យើងច្រើន កាលពិចារណាតទៅក៏ដឹងច្បាស់ថាអាចារ្យកំពុងនៅជាបុថុជ្ជន ទើបត្រិះរិះថា លោកជាទីពឹងដល់មហាជន តែមិនជាទីពឹងដល់ខ្លួនឯង កុំដូច្នោះឡើយ យើងនឹងដាស់តឿនសតិលោក កាលគិតដូច្នោះហើយ ព្រះអរហន្តរូបនោះក៏ហោះទៅរកអាចារ្យ ល្មមជិតដល់កុដិរបស់អាចារ្យហើយ ក៏ដើរចូលទៅរកព្រះមហាថេរៈសួរថា មកដោយមានធុរៈអ្វី ព្រះអរហន្តឆ្លើយថា ចង់សុំរៀនធម៌សម្រាប់អនុមោទនាបង្រៀនគ្រហស្ថ លោកឆ្លើយថា យើងមិនមានពេលទេ ព្រះអរហន្តក៏សួរដល់ពេលដែល

ល្មមនឹងសួរបញ្ហាបាន តាំងអំពីភ្ញាក់ពីដេករហូតលក់ស៊ប់ ព្រះមហាថេរៈឆ្លើយថា មានមនុស្សកំពុងផងចាំសួរបញ្ហារហូតកាលព្រះអរហន្តទើបពោលថា ពេលរបស់អាចារ្យពេញរវល់ពិត ៗ ទាំងពេលស្ងាប់ក៏មិនមាន លោកប្រព្រឹត្តខ្លួនដូចបង្អែកជាទីពឹងដល់អ្នកដទៃ មិនមែនបង្អែកជាទីពឹងដល់ខ្លួនឯង ខ្ញុំករុណាមិនត្រូវការសិក្សាអំពីលោកឡើយ គ្រាពោលហើយ ព្រះអរហន្តក៏ហោះចេញទៅ ពេលនោះព្រះថេរៈទើបមានសតិដឹងថា ភិក្ខុរូបនេះ មកដើម្បីដាស់តឿនសតិ មិនមែនត្រូវការសិក្សាធម៌ទេ ក្នុងថ្ងៃព្រឹកឡើងលោកក៏រៀបចំបាត្រនិងចីវរ ហើយចេញអំពីវត្តទៅបដិបត្តិធម៌ដោយស្ងាត់នៅកន្លែងជើងភ្នំជិតភូមិ ។

ក្នុងខាងដើមលោកសំគាល់ថា ខ្លួនអាចសម្រេចអរហត្តផលបានក្នុងរវាងពីរបីថ្ងៃ ទើបមិនបានពោលលាសិស្ស តមកកាលមិនអាចសម្រេចធម៌បាន មនោបណិធានក៏គិតថា គង់នឹងសម្រេចបានក្នុងរវាង ៣ ខែ លុះគ្រប់ ៣ ខែ លោកក៏មិនបានសម្រេចធម៌ទើបគិតថា សព្រហ្មចារីខ្លះសង្ឃឹមថា លោកអាចសម្រេចធម៌ជាព្រះអរហន្តក្នុងរវាងវស្សា ហើយបវារណារួមគ្នាក្នុងថ្ងៃពេញ

បូណ៌មី តែក៏នៅមិនអាចសម្រេចបាន ទើបខូចចិត្តស្រែកយំ និងគិតថា ខូនអស់ពេលទៅព្រោះការដេក ទើបសម្រេចធម៌មិនបាន ក៏ក្រោកឡើងរៀបចំទីដេក ហើយបដិបត្តិធម៌តាមឥរិយាបថ ៣ គឺ ការឈរ ការដើរ នឹងការអង្គុយ ។

លោកព្យាយាមបដិបត្តិធម៌រឿយៗ មកដល់ ២៩ ឆ្នាំក៏នៅមិនសម្រេចធម៌ គម្រប់ឆ្នាំដែលវិលមកដល់ថ្ងៃបវារណាពេលណា ក៏ខូចចិត្តស្រែកយំ រហូតដល់ឆ្នាំទី ៣០ កាលដល់ថ្ងៃបវារណា ទើបត្រិះរិះថា លោកបដិបត្តិធម៌គ្រប់ ៣០ ឆ្នាំហើយក៏នៅតែមិនបានសម្រេចតាមសេចក្តីប្រាថ្នា ជាតិនេះគង់នឹងសម្រេចធម៌ដូចអ្នកដទៃមិនបាន លោកខូចចិត្តខ្លាំងរហូតដល់ស្រែកយំខ្សឹកខ្សួល ក្នុងពេលនោះ ទេពធីតាម្នាក់ត្រូវការនឹងដាស់តឿនសតិលោក ទើបក្លែងជាស្ត្រីមកឈរស្រែកយំជិតៗ លោកបានឮសម្លេងក៏សួរថា នរណាមកស្រែកយំទីនេះ ទេពធីតាឆ្លើយថា ខ្ញុំករុណាជាទេពធីតានៅក្នុងកន្លែងក្នុំនេះ ឃើញលោកស្រែកយំ ក៏គិតថា បើយំហើយនឹងបានសម្រេចមគ្គផលទើបខ្ញុំយំតាមលោក ព្រះថេរៈបានស្តាប់ហើយក៏មានសតិគិតថា មើលចុះសូម្បីទេពធីតាក៏មកចំអកឲ្យយើង

ព្រោះយើងធ្វើក្នុងវត្ថុដែលមិនគួរធ្វើ គិតដូច្នោះហើយ ក៏ផ្តងចិត្តចម្រើនវិបស្សនា ក្នុងទីបំផុតបានសម្រេចអរហត្តផលក្នុងខណៈនោះ ។

ការដែលព្រះថេរៈប្រើពេលបដិបត្តិធម៌យូររហូតដល់ ៣០ឆ្នាំ ក៏ព្រោះថា លោកចម្រើនវិបស្សនាយ៉ាងពិស្តារតាមដែលបានសិក្សាមក ដូចព្រះសារីបុត្រប្រើពេលបដិបត្តិធម៌យូរជាងព្រះមហាមោគ្គល្លានសេចក្តីពិត អ្នកដែលចាំព្រះត្រៃបិដករាប់ថា ជាអ្នកមានបារមីពេញបរិបូណ៌ក្នុងការសម្រេចមគ្គផលដោយការចម្រើនវិបស្សនាដោយសង្ខេប ដូចព្រះពោធិសត្វកាលសោយព្រះជាតិជាសុមេធតាបស ក៏មានសាវកបារមីញាណពេញបរិបូណ៌ហើយ តែព្រះថេរៈចម្រើនវិបស្សនាដោយពិស្តារទើបប្រើពេលយូរជាងបុគ្គលដទៃ ដូចសាធកៈក្នុងគម្ពីរដីកាថា

អនុច្ឆវិកំ នុ ខោ តេ ឯតន្តិ សំវេគជាតោ វីរិយំ សមុត្តេជេន្តោ អរហត្តំ អគ្គហេសិ ឯត្តកំ កាលំ វិបស្សនាយ សុចិណ្ណការតោ ញាណស្ស បរិបាកគតត្តា[៩៣] ។

"ព្រះថេរៈកើតសេចក្តីស្លុតចិត្តថា ការយំនេះ សមគួរដល់យើង ឬ ហើយញ៉ាំងសេចក្តីព្យាយាមឲ្យខ្លាំងក្លា បានសម្រេចអរហត្តផល ព្រោះញាណចាស់ក្លាហើយ បន្ទាប់អំពីអប់រំវិបស្សនាជាយ៉ាងល្អ រហូតកាលត្រឹមណោះ" ។

តមកព្រះអង្គទ្រង់ចែកឧបេក្ខាវេទនាចេញជាឧបេក្ខាអាស្រ័យ អាមិសៈជាដើម ដូចព្រះពុទ្ធវចនៈថា

*សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ សាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ ។ និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ និរាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ*[៩៤] ។

"ភិក្ខុកាលទទួលឧបេក្ខាវេទនាប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលឧបេក្ខាវេទនាប្រកបដោយអាមិសៈ ។ កាលទទួលឧបេក្ខាវេទនាដែលឥតអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលឧបេក្ខាវេទនាដែលឥតអាមិសៈ" ។

ដោយទូទៅ មនុស្សដែលមិនបានអប់រំចិត្តដោយការចម្រើនវិបស្សនា ក្នុងខណៈខ្លះអាចកើតការដឹងព្រងើយចំពោះកាមគុណខាងក្នុងឬខាងក្រៅ តែបណ្តោយទុកអារម្មណ៍នោះមិនបាន ព្រោះមានការប្រកាន់ជាប់ជំពាក់ដោយការលោភ ឧបេក្ខាប្រភេទនេះហៅថា ឧបេក្ខាអាស្រ័យអាមិស (សាមិសឧបេក្ខា) កន្លែងខ្លះហៅថា គេហសិតឧបេក្ខា គឺ ឧបេក្ខាអាស្រ័យផ្ទះ ឬអញ្ញាណុបេក្ខា គឺឧបេក្ខាដែលកើតព្រមជាមួយមោហៈ ក្នុងពេលដែលឧបេក្ខានេះប្រាកដច្បាស់ អ្នកបដិបត្តិគប្បីកំណត់ថា "ព្រងើយហ្ន៎" ។

កាលអ្នកបដិបត្តិសម្រេចឧទយព្វយញ្ញាណហើយ កន្លងផុតវិបស្សនូបកិលេសបាន ការព្រងើយកន្តើយក្នុងខណៈតាមដឹងអារម្មណ៍ផ្លូវទ្វារទាំង ៦ រមែងកើតឡើង ការព្រងើយកន្តើយហៅថា ឧបេក្ខាមិនស្រ័យអាមិសៈ ( និរាមិសឧបេក្ខា ) រមែងប្រាកដច្បាស់ក្នុងកន្តញាណ និងប្រាកដច្បាស់ដ៏ក្រៃលែងឡើងទៅក្នុងសង្ខារុបេក្ខាញាណក្នុងកន្លែងខ្លះហៅថា នេក្ខម្មសិតឧបេក្ខា ឬឧបេក្ខាអាស្រ័យវិបស្សនា អ្នកបដិបត្តិគប្បីកំណត់ថា "ព្រងើយហ្ន៎" ។

## អានិសង្សនៃការតាមដឹងវេទនា

ការតាមដឹងវេទនាធ្វើឲ្យអ្នកបដិបត្តិឃើញច្បាស់ការកើតរលត់របស់វេទនា ក្នុងខណៈខ្លះអ្នកបដិបត្តិអាចទទួលដឹងហេតុកើតឡើងនិងហេតុរលត់ទៅរបស់វេទនាតាមដែលបានស្ដាប់មកទៀតផងពោលគឺ សុខវេទនាកើតអំពីការជួបប្រទះជាមួយអារម្មណ៍ដែលគួរជាទីប្រាថ្នា ទុក្ខវេទនាកើតអំពីការជួបជាមួយអារម្មណ៍ដែលមិនជាទីប្រាថ្នា ឧបេក្ខាវេទនា កើតអំពីការជួបជាមួយអារម្មណ៍ជាកណ្ដាល ក្រៅអំពីនេះ វេទនានៅមានហេតុកើត គឺ កម្មក្នុងអតីត អវិជ្ជានិងតណ្ហា ។

អ្នកដែលឃើញការកើតរលត់របស់វេទនាយ៉ាងនេះ នឹងកើតសតិរលឹកដឹងថា មានត្រឹមតែការដឹងខ្លួនជាសុខ ទុក្ខ ឬព្រងើយមិនមានបុគ្គល យើង របស់យើង បុរស ស្ត្រី គេរមែងប្រាសចាកការប្រកាន់មាំវត្ថុណាទិមួយក្នុងលោក គឺ ឧបាទានក្ខន្ធ សមពិតដូចព្រះពុទ្ធវចនថា

សមុទយធម្មានុបស្សី វា វេទនាសុ វិហរតិ ។ វយធម្មានុបស្សី

វា វេទនាសុ វិហរតិ ។ សមុទយវយធម្មានុបស្សី វា វេទនាសុ វិហរតិ ។ អត្ថិ វេទនាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ។ ន ច កិញ្ចិ លោកេ ឧបាទិយតិ[៩៥] ។

“ភិក្ខុពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំកើតឡើងក្នុងវេទនាទាំងឡាយគ្រប់ឥរិយាបថទាំង ៤ ផង ។ ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ៤ ផង ។ ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយគ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី ( ជាគ្រឿងកំណត់នូវវេទនា ) របស់ភិក្ខុនោះផុងឡើងចំពោះថា វេទនាទាំងឡាយមានមែន ( មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផងមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង” ។

ចប់ វេទនានុបស្សនា ។

## ចិត្តានុបស្សនា

ចិត្តដែលប្រាថ្នានូវវត្ថុណាទិមួយ ឈ្មោះថា ចិត្តមានរាគៈ ( **សរាគចិត្ត** ) អ្នកបដិបត្តិគប្បីតាមដឹងទាន់សភាវៈចិត្តដូចពោល ដោយកំណត់ថា "ស្រឡាញ់ហ្ន៎" "លោភហ្ន៎" ឬ "ចំណង់ហ្ន៎" ក្នុងខណៈខ្លះកាលកំណត់ត្រឹមតែមួយគ្រា ចិត្តដូចដែលពោលអាចស្ងប់ទៅបាន តែបើនៅមិនស្ងប់ទៅដោយការតាមដឹងមួយគ្រា ក៏គប្បីតាមដឹងរហូតទាល់តែស្ងប់ទៅទាំងអស់ កាលចិត្តនោះស្ងប់ហើយ ក៏គប្បីតាមដឹងចិត្តដែលផ្ទុយផង់ប្រាសចាករាគៈ ដោយកំណត់ថា "ដឹងហ្ន៎" ចិត្តដូចដែលពោល ឈ្មោះថា ចិត្តប្រាសចាករាគៈ ( **វីតរាគចិត្ត** ) សមពិតដូចព្រះពុទ្ធវចនក្នុងមហាសតិប្បដ្ឋានសូត្រ

ចិត្តានុបស្សនាថា

*ឥធ ភិក្ខវេ ភិក្ខុ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ ។ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ*[៩៦] ។

"ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ទោះចិត្តប្រកបដោយ

រាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ។ ទោះចិត្តប្រាស់ចាក រាគៈក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ" ។

ចិត្តដែលកើតទុក្ខមិនពេញចិត្ត ក្រោធ ស្អប់ អាឃាតឬព្យាបាទ ប្រទូសរាយ ឈ្មោះថា ចិត្តមានទោសៈ អ្នកបដិបត្តិគប្បីតាមដឹងចិត្ត ដូចដែលពោលរហូតទាល់តែស្ងប់ទៅដោយកំណត់ថា "ក្រោធហ្ន៎" ជាដើម កាលចិត្តនោះស្ងប់ហើយ ក៏គប្បីតាមដឹងចិត្តដែលធូរផង់ ប្រាសចាកទោសៈ ដោយកំណត់ថា "ដឹងហ្ន៎" ចិត្តដូចពោល ឈ្មោះថា ចិត្តប្រាសចាកទោសៈ ( វីតទោសចិត្ត ) សមពិតដូច ព្រះពុទ្ធវចនក្នុងមហាសតិប្បដ្ឋានសូត្រថា

***សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ ។ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ***[១៧] ។

"ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយ ទោសៈ ។ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាស ចាកទោសៈ" ។

ចិត្តដែលប្រកបដោយសេចក្ដីសង្ស័យនិងចិត្តដែលប្រកបដោយ

សេចក្តីរវើរវាយ ឈ្មោះថា ចិត្តដែលមានមោហៈ ( សមោហចិត្ត ) នៅមានចិត្តដែលមានមោហៈមួយប្រភេទទៀតគឺ

-លោភមូលសមោហចិត្ត ចិត្តដែលមានមោហៈប្រកបដោយលោភ ដែលមិនឃោរឃៅ រមែងប្រាកដក្នុងពេលដែលគិតដល់វត្ថុដែលគួរប្រាថ្នា ត្រូវការទទឹងអួតខ្លួន ឬសំគាល់ថា មានតួខ្លួន ។

-ទោសមូលសមោហចិត្ត ចិត្តដែលមានមោហៈ ដែលប្រកបដោយសេចក្តីក្រោធដែលមិនឃោរឃៅ រមែងប្រាកដក្នុងពេលខ្វាចសោយសោក ស្អប់ កំណាញ់ ឥស្សា ក្តៅក្រហាយចិត្ត ។

ពិតហើយក្នុងគម្ពីរអដ្ឋកថា[៩៨] ពោលដល់លោភមូលចិត្ត ៨ ដូចថា ជាសរាគចិត្ត, ទោសមូលចិត្ត ២ ដូចថា ជាសទោសចិត្ត និងអកុសលចិត្ត ១២ ដូចទាំងអស់ថា ជាសមោហចិត្ត ក្នុងទីនេះចែកតាមសភាវៈ ដើម្បីឲ្យយល់បានងាយ ។

អ្នកបដិបត្តិគប្បីតាមដឹងចិត្តដែលសង្ស័យថា "សង្ស័យហ្ន៎" និងតាមដឹងចិត្តដែលរវើរវាយរាយមាយ "គិតហ្ន៎" ឬ "រាយមាយហ្ន៎" កាលចិត្តនោះស្ងប់ហើយ ក៏គប្បីតាមដឹងចិត្តដែលផូរផង់ប្រាសចាក

សេចក្ដីសង្ស័យ ឬសេចក្ដីរវើរវាយដោយកំណត់ថា "ដឹងហ្ន៎" ចិត្តដូចដែលពោលឈ្មោះថា ចិត្តប្រាសចាកមោហៈ ( **វីតមោហចិត្ត** ) សមពិតដូចព្រះពុទ្ធវចនក្នុងមហាសតិប្បដ្ឋានសូត្រថា

**សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ ។ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ**[៩៧] ។

"ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ។ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ" ។

ក្រៅអំពីនេះ ចិត្តដែលរួញរា ឈ្មោះថា **សង្ខិត្តចិត្ត**, ចិត្តដែលរាយមាយ ឈ្មោះថា **វិក្ខិត្តចិត្ត**, ចិត្តដែលតាំងមាំ ឈ្មោះថា **សមាធិចិត្ត**, ចិត្តដែលមិនតាំងមាំ ឈ្មោះថា **អសមាធិចិត្ត**, ចិត្តដែលរួចផុតអំពីកិលេស ឈ្មោះថា **វិមុត្តចិត្ត**, ចិត្តដែលត្រូវសេចក្ដីរាយមាយគ្របសង្កត់មិនរួចផុតអំពីកិលេស ឈ្មោះថា **អវិមុត្តចិត្ត** ចិត្តដូចដែលពោលនេះ ក៏ជាអារម្មណ៍នៃការចម្រើនវិបស្សនាតាមសមគួរ ដោយអ្នកបដិបត្តិគប្បីកំណត់ដឹងថា "ផង់យហ្ន៎" ជាដើម ។

អ្នកដែលសម្រេចឈានហើយ គប្បីតាមដឹងចិត្តដែលកើតមុន ឬកើតក្រោយឈានចិត្តថា មិនមែនមហគ្គតចិត្ត ( **អមហគ្គតចិត្ត** ) និងមានចិត្តដទៃប្រសើរជាង ( **សឧត្តរចិត្ត** ) និងកាលចេញអំពីឈានហើយ គប្បីតាមដឹងឈានចិត្តទាន់ពេលថា ជាចិត្តដែលប្រសើរ ( **មហគ្គតចិត្ត** ) និងមិនមានចិត្តដទៃប្រសើរជាង ( **អនុត្តរចិត្ត** ) ។ ម្យ៉ាងទៀត កាលចេញអំពីរូបឈានហើយសម្រេចអរូបឈាន ក៏គប្បីតាមដឹងឈានថា មិនមែនមហគ្គតចិត្ត មិនមានចិត្តដទៃប្រសើរជាង ចំណែកអរូបឈានជាចិត្តដ៏ប្រសើរ និងមិនមានចិត្តដទៃប្រសើរជាង កាលតាមដឹងមហគ្គតចិត្ត និងអមហគ្គតចិត្ត ព្រមទាំងសឧត្តរចិត្ត និងអនុត្តរចិត្ត ទើបជាវិស័យរបស់លោកអ្នកសម្រេចឈានប៉ុណ្ណោះ ដូចមានព្រះពុទ្ធវចនៈជាប់ទាក់ទងរឿងនេះថា

*សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ ។ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ ។ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ ។ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ ។ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ ។ អនុត្តរំ វា ចិត្តំ*

អនុត្តរំ ចិត្តន្តិ បជានាតិ ។ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ ។ អសមាហិតំ វា ចិតំ អសមាហិតំ ចិត្តន្តិ បជានាតិ ។ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ ។ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ[100] ។

“(ភិក្ខុ) ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា ។ ទោះចិត្តរាយមាយក៏ដឹងច្បាស់ថា ចិត្តរាយមាយ ។ ទោះចិត្តដល់នូវភាវៈជាធំ ( គឺរូបាវចរនិងអរូបាវចរ ) ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាវៈជាធំ ។ ទោះចិត្ត មិនដល់នូវភាវៈជាធំ ( គឺកាមាវចរ ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈជាធំ ។ ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង ( គឺនៅជាកាមាវចរ ) ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង ។ ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង ( គឺរូបាវចរចិត្តនិងអរូបាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ។ ទោះចិត្តតាំងនៅមាំ ( ជាអប្បនាសមាធិនិងឧបចារសមាធិ ) ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ ។ ទោះចិត្តមិនតាំងនៅមាំ ( ប្រាសចាកសមាធិទាំងពីរ ) ក៏ដឹងច្បាស់ថា ចិត្តមិនតាំងនៅមាំ ។ ទោះចិត្តរួចស្រឡះ ( តទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ) ក៏ដឹងច្បាស់ថា ចិត្តរួច

ស្រឡះ ។ ទោះចិត្តមិនរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនរួចស្រឡះ" ។

ការតាមដឹងចិត្តតាមន័យរបស់ចិត្តានុបស្សនា មានសភាវធម៌ដូចនេះគឺ

- ការទទួលដឹងអារម្មណ៍ដោយការឃើញ បានឮ ដឹងក្លិន ភ្លក្សរស ដឹងសម្ផស្សនិងនឹកគិត ជាលក្ខណៈវិសេសរបស់ចិត្ត ( វិជាននលក្ខណំ ) ។

- ភាពជាធំក្នុងការទទួលដឹងអារម្មណ៍ជានាទី ( បុព្វង្គមរសំ )។

- ការកើតឡើងជាប់តគ្នាមិនដាច់ ជាអាការប្រាកដ ( សន្ទហនបច្ចុបដ្ឋានំ ) ។

- រូបដែលជាទីអាស្រ័យរបស់ចិត្ត និងនាមដែលប៉ះខ្ទប់ ឬ សោយអារម្មណ៍ ជាហេតុជិត ( វត្ថារម្មណបទដ្ឋានំ ) ។

ការតាមដឹងចិត្ត ដូចដែលពោលមកនេះ ញុំាងផលឲ្យអ្នកបដិបត្តិឃើញការកើតរលត់របស់ចិត្តបាន ក្នុងខណៈខ្លះ អ្នកបដិបត្តិ

អាចទទួលដឹងហេតុកើតឡើង និងហេតុរលត់ទៅរបស់ចិត្តតាមដែលបានស្ដាប់មកទៀតផង ពោលគឺចិត្តកើតអំពីរូបដែលជាទីអាស្រ័យកើតនិងនាម ( ចេតសិក ) ដែលប្រកបរួមគ្នា បើមិនមានរូបនាម ចិត្តក៏កើតឡើងមិនបាន ក្រៅអំពីនេះ ចិត្តនៅកើតអំពីកម្មក្នុងអតីត អវិជ្ជា និងតណ្ហាទៀតផង ។

អ្នកដែលឃើញការកើតរលត់របស់ចិត្តយ៉ាងនេះ រមែងកើតសតិរលឹកដឹងថា មានត្រឹមតែចិត្តដែលទទួលដឹងអារម្មណ៍ មិនមានបុគ្គល យើង របស់យើង បុរស ស្ត្រី គេរមែងប្រាសចាកការប្រកាន់មាំវត្ថុណាទីមួយក្នុងលោក គឺ ឧបាទានក្ខន្ធ សមពិតដូចព្រះពុទ្ធវចនថា

សមុទយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ ។ វយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ ។ សមុទយវយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ ។ អត្ថិ ចិត្តន្តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ។ ន ច កិញ្ចិ លោកេ ឧបាទិយតិ[១០១] ។

"ភិក្ខុពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំកើតឡើងក្នុងចិត្ត គ្រប់ឥរិយាបថទាំង ៤ ផង ។ ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងចិត្ត គ្រប់ឥរិយាបថទាំង ៤ ផង ។ ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតក្នុងចិត្ត ទាំងធម៌ដែលសូន្យទៅក្នុងចិត្ត គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយវិញទៀត ស្មារតី ( ជាគ្រឿងកំណត់ដឹងនូវចិត្ត ) របស់ភិក្ខុនោះផ្ចង់ឡើងចំពោះថា ចិត្តមានមែន ( មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ( ភិក្ខុមានចិត្តមិនអាស្រ័យដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង" ។

ចប់ ចិត្តានុបស្សនា ។

៤.ធម្មានុបស្សនា

ពួកនីវរណៈ

នីវរណៈមាន ៥ ប្រការគឺ

១.**កាមច្ឆន្ទៈ** សេចក្ដីត្រេកអរពេញចិត្តក្នុងកាម គឺ វត្ថុដែលជាទីប្រាថ្នា បានដល់រូបស្អាត សម្លេងពីរោះ ក្លិនក្រអូប រសឆ្ងាញ់ និងសម្ផស្សទន់ សូម្បីសេចក្ដីត្រូវការនឹងសម្រេចឈាន វិបស្សនា មគ្គ ផលនិងនិព្វាន ក៏ចាត់ជាកាមច្ឆន្ទៈដូចគ្នា អ្នកបដិបត្តិគប្បីតាមដឹងសភាវធម៌នេះថា "ប្រាថ្នាហ្ន៎" ។

២. **ព្យាបាទៈ** សេចក្ដីកើតទុក្ខ មិនពេញចិត្ត ក្រោធ ស្អប់ ប្រទូសរាយ អ្នកបដិបត្តិគប្បីតាមដឹងសភាវធម៌នេះថា "ក្រោធហ្ន៎" ។

៣. **ថីនមិទ្ធៈ** សេចក្ដីរួញរា អ្នកបដិបត្តិគប្បីតាមដឹងសភាវធម៌នេះថា "ងងុយហ្ន៎" ។

៤. **ឧទ្ធច្ចកុក្កុច្ច** សេចក្ដីរវើរវាយក្ដៅក្រហាយចិត្ត អ្នកបដិបត្តិគប្បីតាមដឹងសភាវធម៌នេះថា "គិតហ្ន៎" "រវើរវាយហ្ន៎" ឬ "ក្ដៅក្រហាយចិត្តហ្ន៎" ។

៥. **វិចិកិច្ឆា** សេចក្ដីសង្ស័យក្នុងព្រះពុទ្ធទ្រង់ត្រាស់ដឹងច្បាស់ធម៌ទាំងពួង សង្ស័យក្នុងព្រះធម៌គឺ មគ្គ ផល និងនិព្វាន សង្ស័យក្នុងព្រះអរិយសង្ឃ អ្នកបាក់ដុះធម៌ សង្ស័យក្នុងរូបនាមដែលកើត

អំពីហេតុគឺ អវិជ្ជា សង្ស័យក្នុងគន្លងផ្លូវនៃការបដិបត្តិ ឬសង្ស័យក្នុងការណែនាំរបស់វិបស្សនាចារ្យជាដើម អ្នកបដិបត្តិគប្បីតាមដឹងសភាវធម៌នេះថា "សង្ស័យហ្ន៎" ។

កាលអ្នកបដិបត្តិតាមដឹងកាមច្ឆន្ទៈជាដើម រហូតដល់ស្ងប់ទៅដោយកំណត់ដឹងមួយគ្រា ឬច្រើនគ្រាតាមសមគួរហើយ គប្បីតាមដឹងចិត្តដែលផូរផង់ប្រាសចាកកាមច្ឆន្ទៈដោយកំណត់ថា "ដឹងហ្ន៎" សូម្បីព្យាបាទជាដើម ក៏មានន័យដូចគ្នា ។

មានព្រះពុទ្ធវចនក្នុងមហាសតិប្បដ្ឋានសូត្រ ពួកនីវរណៈថា

ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ ។ អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ ។

សន្តំ វា អជ្ឈត្តំ ព្យាបាទំ អត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ ។ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ នត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ ។

សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ ។

អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ ។

សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ អត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ ។ អសន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ នត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ ។

សន្តំ វា អជ្ឈត្តំ វិចិកិច្ឆា អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ ។ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ[១០២] ។

“ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈនៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះកាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។

ទោះព្យាបាទមាននៅក្នុងសន្តានចិត្តនៃខ្លួនក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។

ទោះថីនមិទ្ធៈមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។

ទោះឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះឧទ្ធច្ច-កុក្កុច្ចៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។

ទោះវិចិកិច្ឆាមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ទោះវិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ” ។

ម្យ៉ាងទៀត ហេតុកើតរបស់នីវរណៈទាំង ៥ គឺ អយោនិសោ-មនសិការ សំដៅដល់ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវទំនង ចំណែកហេតុដែលធ្វើឲ្យនីវរណៈរលត់បាត់ទៅ គឺ យោនិសោមនសិការ

សំដៅដល់ការធ្វើទុកក្នុងចិត្តដោយត្រូវទំនងដែលជាការកំណត់ដឹង សភាវធម៌បច្ចុប្បន្ន ដូចកាលអ្នកបដិបត្តិគ្រេកអរភ្លើតភ្លើនក្នុងរូបដែលស្រស់ស្អាតជាដើម កាមច្ឆន្ទៈរមែងកើតឡើង តែការមានសតិកំណត់ដឹងទាន់បច្ចុប្បន្នហើយ កាមច្ឆន្ទៈក៏រលត់ទៅ ក្នុងខណៈខ្លះថីនមិទ្ធៈរមែងកើតឡើង បើអ្នកបដិបត្តិកំណត់ដឹងថីនមិទ្ធៈដោយសតិដែលមានកម្លាំងហើយ ថីនមិទ្ធៈរមែងរលត់ទៅ ក្នុងខណៈនោះ អ្នកបដិបត្តិ នឹងមានចិត្តរឹងប៉ឹងប្រាសចាកភាពងងុយងងក់អស់កាលយូរ ។

ពិតហើយ យោនិសោមនសិការ ជាការធ្វើទុកក្នុងចិត្តយ៉ាងត្រឹមត្រូវដើម្បីឲ្យកើតកុសលគ្រប់យ៉ាង ដោយចំពោះយោនិសោ-មនសិការក្នុងរឿងវិបស្សនា ជាការឃើញសភាវលក្ខណៈរបស់រូបនាម ដែលកំពុងកើតឡើងក្នុងបច្ចុប្បន្ន ព្រមដោយសភាវៈកើតឡើង តាំងនៅ រលត់ទៅ ជាទុក្ខ មិនមែនតួខ្លួន បុគ្គល ខ្លួនយើងរបស់យើង ដែលហៅថា ត្រៃលក្ខណ៍ កាលវិបស្សនាញាណមានកម្លាំងខ្លាំងឡើង សូម្បីរូបនាមដែលមិនបានដឹងច្បាស់ដោយប្រចក្ស

ក៏ជាការអនុមានដឹងបានដោយបរិយាយ ការឃើញដោយអមយ៉ាង
នេះ ជាយោនិសោមនសិការដូចគ្នា សរុបសេចក្តីថា យោនិសោ-
មនសិការ ជាការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនងដើម្បីឲ្យកើត
វិបស្សនាញាណជាន់ខ្ពស់ និងមគ្គផលនិព្វាន អង្គធម៌គឺវិបស្សនា-
ជវនចិត្តផ្លូវមនោទ្វារ ដែលប្រចក្សច្បាស់រូបនាមត្រៃលក្ខណ៍យ៉ាង
ពិតប្រាកដ ដូចសាធកៈក្នុងគម្ពីរផ្លូវព្រះសាសនាថា

**យោនិសោ មនសិការោ នាម ឧបាយមនសិការោ បថមន-
សិការោ ។ អនិច្ចេ អនិច្ចន្តិ វា ទុក្ខេ ទុក្ខន្តិ វា អនត្តនិ អនត្តាតិ
វា អសុភេ អសុភន្តិ វា មនសិការោ**[១០៣] ។

“ការធ្វើទុកក្នុងចិត្តដោយត្រូវទំនងវិធី និងគន្លងផ្លូវដែលត្រឹម
ត្រូវ ឈ្មោះថា យោនិសោមនសិការ ( ការធ្វើទុកក្នុចិត្តដោយ
ត្រូវទំនង ) គឺ ការធ្វើទុកក្នុចិត្តថា មិនទៀងក្នុងកម្មដែលមិនទៀង
ការធ្វើទុកក្នុចិត្តថា ជាទុក្ខក្នុងកម្មដែលជាទុក្ខ ការធ្វើទុកក្នុចិត្តថា
មិនមែនតួខ្លួនក្នុងកម្មដែលមិនមែនតួខ្លួន”។

**យោនិសោ មនសិការោ នាម កុសលាទីនំ តំតំសភាវរស-**

លក្ខណាទិស្ស យោថាវតោ អវពុជ្ឈនវសេន ឧប្បន្នោ ញាណសម្បយុត្តចិត្តុប្បាទោ ។ សោ ហិ អវិបរីតមនសិការតាយ យោនិសោ មនសិការោតិ វុត្តោ ។ តទាភោគតាយ អាវជ្ជនាបិ តគ្គតិកា ឯវ[១០៤] ។

"ចិត្តដែលប្រកបជាមួយបញ្ញាដែលកើតឡើងដោយការឃើញសភាវៈ នាទីនិងត្រៃលក្ខណ៍ជាដើមនោះៗ របស់កុសលចិត្តជាដើម ឈ្មោះថា យោនិសោមនសិការ ដោយពិតហើយ ចិត្តដូចពោលហៅថា យោនិសោមនសិការ ព្រោះសេចក្ដីថាចិត្តយ៉ាងត្រឹមត្រូវ សូម្បីអាវជ្ជនចិត្ត ក៏មានការប្រព្រឹត្តទៅជាមួយនឹងជវនចិត្តនោះ ព្រោះកើតភាវៈតែមួយជាមួយជវនចិត្ត" ។

តាមពាក្យអធិប្បាយខាងដើម យោនិសោមនសិការ គឺហេតុកើតរបស់កុសលទាំងអស់ ដែលបានដល់អាវជ្ជនចិត្ត និងវិបស្សនាជវនចិត្ត ដែលកើតក្នុងវិថីចិត្តមុនៗ ដែលធ្វើឲ្យកើតកុសលក្នុងវិថីចិត្តតៗ មក យ៉ាងណាក៏ដោយ ក្នុងអដ្ឋកថា និងដីកាកន្លែងខ្លះ ពោលដល់អាវជ្ជនចិត្ត ដែលជាហេតុកើតរបស់កុសលថា

យោនិសោមនសិការ ឬអាវជ្ជចិត្តដែល ហេតុកើតរបស់កុសលថា អយោនិសោមនសិការ តាមសមគួរដល់សេចក្តីក្នុងព្រះសូត្រនោះៗ ។

ម្យ៉ាងទៀត យោនិសោមនសិការ មានធម៌ដែលត្រង់ចន្លោះគ្នាគឺ អយោនិសោមនសិការ លោកអធិប្បាយទុកក្នុងគម្ពីរអដ្ឋកថាថា

**អយោនិសោ មនសិការោ នាម អនុបាយមនសិការោ ឧប្បថមនសិការោ ។ អនិច្ចេ និច្ចន្តិ វា ទុក្ខេ សុខន្តិ វា អនត្តនិ អត្តាតិ វា អសុភេ សុភន្តិ វា មនសិការោ[១០៤] ។**

“ការធ្វើទុកក្នុងចិត្ត គឺ ផ្លូវដែលមិនត្រឹមត្រូវ ឈ្មោះថា អយោនិសោមនសិការ ( ការធ្វើទុកក្នុងចិត្តដោយមិនត្រូវទំនង ) គឺការធ្វើទុកក្នុងចិត្តថាទៀង ក្នុងធម៌ដែលមិនទៀង ធ្វើទុកក្នុងចិត្តថាជាសុខក្នុងធម៌ដែលជាទុក្ខ ធ្វើទុកក្នុងចិត្តថាជាតួខ្លួន ក្នុងធម៌ដែលមិនមែនតួខ្លួន” ។

អយោនិសោមនសិការ គឺ ការធ្វើទុកក្នុងនាមរូបដែលប្រាកដផ្លូវទ្វារទាំង ៦ ថាទៀង ជាសុខ បន្ទាប់បញ្ជាបាន និងជារបស់

ស្អាតល្អ សូម្បីការធ្វើទុកក្នុងចិត្តថាទៀង ជាតួខនោះ និងមិនប្រាកដ យ៉ាងជាក់ច្បាស់ តែបើបុគ្គលមិនបានចំរើនសតិរលឹកដឹងនាមរូប បច្ចុប្បន្ន ក៏ចាត់ជាអយោនិសោមនសិការដូចគ្នា ព្រោះកាលត្រឡប់ រលឹកដឹងអារម្មណ៍ទាំងឡាយនោះ ក៏នឹងយល់ថា ជារបស់ទៀង ជាសុខ បន្ទាប់បញ្ជាបាន ហើយក៏ជារបស់ស្អាតល្អ បើមិនចំរើន សតិរលឹកដឹងសភាវៈឃើញក្នុងខណៈឃើញ ក៏នឹងធ្វើទុកក្នុងចិត្ត ដល់រូបរាងសណ្ឋានថាឃើញនណា កាលមុនឃើញគេមក ក្នុង ខណៈនោះ គេក៏នៅដូចដើម សូម្បីកាលឃើញហើយ ក៏អាច ត្រឡប់រលឹកថា គេទៅទីណា ឥឡូវនេះនៅទីណា យើងកំពុងនឹក ដល់គេដូច្នេះជាដើម ដោយធ្វើទុកក្នុងចិត្តថា អ្នកដែលឃើញជា សភាពទៀង មានសេចក្តីសុខ បន្ទាប់បញ្ជាបាន ឬស្អាតល្អ ធ្វើ ទុកក្នុងចិត្តដូចពោល ធ្វើឲ្យមិនអាចទទួលដឹងសភាវធម៌របស់នាមរូប ដែលមិនទៀង ជាទុក្ខ មិនមែនតួខន និងមិនមែនរបស់ស្អាតល្អ ។

អយោនិសោមនសិការនេះ ជាហេតុកើតរបស់អកុសលធម៌ ទាំងអស់ អន្តធម៌ គឺអាវជ្ជនចិត្ត និងអកុសលជវនចិត្តដែលកើត

ក្នុងវិថីចិត្តមុន ៗ ដែលធ្វើឲ្យកើតអកុសលក្នុងវិថីចិត្តត ៗ មក ពិត ហើយ ហេតុកើតរបស់អកុសលក្នុងវិថីចិត្តដូចគ្នា គឺ អាវជ្ជនចិត្ត ដែលពិចារណាដោយមិនត្រូវទំនង ពោលគឺ តាមប្រក្រតីបុថុជ្ជន កាលជួបអារម្មណ៍ ៦ ក៏រមែងពិចារណាដោយ អាវជ្ជនចិត្តថា គួរស្រឡាញ់ ឬគួរស្អប់ដូចជាមួយមនុស្សខ្មាចខ្មោច ពេលដែលបាន ឮសម្លេងខ្លាំង ក៏យល់ថា ខ្មោចដើរមក ឬដូចមនុស្សដែលលំបាក ជួបមិត្ត កាលឃើញមនុស្សដទៃ ដើរមកក៏គិតថា ជាមិត្តរបស់ខ្លួន ដូចនោះ កាលអាវជ្ជនចិត្តកើតឡើងផ្លូវបញ្ចទ្វារ ហើយកើតវិថីចិត្ត ក្នុងលំដាប់តមក គឺ សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត និងវោដ្ឋព្វនចិត្ត ដែលកាត់ចិត្តសំរេចថា អារម្មណ៍ដែលខ្លួនជួបនោះ គួរស្រឡាញ់ ឬគួរស្អប់ ក្រោយអំពីនោះទើបកើតសេចក្តីលោភ ក្នុងអារម្មណ៍ ដែលគួរស្រឡាញ់ និងសេចក្តីក្រោធក្នុងអារម្មណ៍ដែលគួរស្អប់ ដែលមានការរង្វេងប្រកបរួមជាមួយសេចក្តីលោភ និងសេចក្តី ក្រោធ ក្រៅអំពីនេះ សូម្បីក្នុងមនោទ្វារវិថីក៏កើតជវនចិត្ត ដែល កុសលឬអកុសល ដោយស្របតាមអាវជ្ជនចិត្តដែលពិចារណាថា គួរជ្រះថ្លា គួរស្រឡាញ់ ឬគួរស្អប់ជាដើម ។

សរុបសេចក្តីថា ការកំណត់ដឹងទាន់សភាវធម៌បច្ចុប្បន្ន ជាយោនិសោមនសិការក្នុងវិបស្សនាភាវនា សូម្បីការធ្វើទុកក្នុងចិត្តដែលគាំទ្រដល់ការកំណត់ដឹង ក៏ចាត់ជាយោនិសោមនសិការដូចគ្នា ចំណែកការមិនកំណត់ដឹងទាន់បច្ចុប្បន្ន និងការធ្វើទុកក្នុងចិត្តដែលមិនគាំទ្រដល់ការកំណត់ដឹង ចាត់ជាអយោនិសោមនសិការទាំងអស់ ដូច្នោះ ក្នុងពួកនីវរណៈ ទើបពោលដល់ការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនងដែលធ្វើឲ្យកើតនីវរណៈ និងការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនងដោយការកំណត់នីវរណៈ ដែលកើតឡើងហើយ ដែលធ្វើឲ្យនីវរណៈរលត់ទៅថា

យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ ។ តញ្ច បជានាតិ ។ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ ។ តញ្ច បជានាតិ[១០៦] ។

“ម្យ៉ាងទៀត សេចក្តីត្រេកអរពេញចិត្តក្នុងកាម ដែលនៅមិនទាន់កើត នឹងកើតឡើងដោយប្រការណា រមែងដឹងច្បាស់ប្រការនោះ សេចក្តីត្រេកអរពេញចិត្តក្នុងកាមដែលកើតឡើងហើយ នឹង

លះចេញបានដោយប្រការណា រមែងដឹងច្បាស់ប្រការនោះ" ។

ក្រៅអំពីនេះ ព្រះអង្គបានត្រាស់តទៅថា

**យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ**

**អនុប្បាទោ ហោតិ, តញ្ច បជានាតិ**[107] ។

"សេចក្ដីត្រេកអរពេញចិត្តក្នុងកាម ដែលលះបានហើយ នឹងមិនកើតតទៅដោយប្រការណា រមែងដឹងច្បាស់ដោយប្រការនោះ" ។

សេចក្ដីនេះ មានន័យថា នីវរណៈរមែងត្រូវលះដោយមិនមានសេសសល់ដោយមគ្គនោះៗ តាមសមគួរពោលគឺ វិចិកិច្ឆារមែងត្រូវលះដោយសោតាបត្តិមគ្គ សេចក្ដីពេញចិត្តក្នុងកាម ព្យាបាទ និងការក្ដៅក្រហាយចិត្ត ត្រូវលះដោយអនាគាមិមគ្គ ថីនមិទ្ធៈ និងឧទ្ធច្ចៈត្រូវលះដោយអរហត្តមគ្គ កាលអ្នកបដិបត្តិបានសម្រេចមគ្គហើយ នឹងកើតបច្ចវេក្ខណញាណ ដែលពិចារណាមគ្គ ផល និព្វាន កិលេសដែលលះហើយ និងកិលេសដែលនៅសេសសល់ ក្នុងខណៈនោះ ទើបនឹងដឹងខ្លួនថា បានលះកិលេសយ៉ាងណា ដោយមិនមានសេសសល់ ក្រៅអំពីនេះ អ្នកបដិបត្តិអ្នកយល់បរិយត្តិ

ល្មមសមគួរ រមែងដឹងថា មគ្គជាគ្រឿងលះកិលេសយ៉ាងដាច់ខាត កាលនីវរណៈកើតឡើង ក៏ដឹងថា សភាវធម៌នោះកើតឡើង ព្រោះខ្វះនៅមិនបានសម្រេចមគ្គ ហើយរមែងខ្វល់ខ្វាយដើម្បីការសំរេចមគ្គនោះៗ ក្នុងឱកាសតទៅ ។

## ២...ពួកឧបាទានក្ខន្ធ

ការតាមដឹងខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ជាដើម មានន័យដូចដែលបានពោលទុកមកហើយ ដោយការកំណត់ថា "ឃើញហ្ន៎" "បានឮហ្ន៎" ជាដើម ផ្សេងគ្នាត្រឹមតែឈ្មោះ តាមសភាវៈនោះៗ ថាការតាមដឹងខន្ធ អាយតនៈ ធាតុ ។ល។

អ្នកបដិបត្តិអ្នកតាមដឹងសភាវៈឃើញថា "ឃើញហ្ន៎" ជាអ្នកតាមដឹងខន្ធ ៥ តាមសមគួរដូច្នេះ គឺ ៖

- **រូបខន្ធ** រមែងប្រាកដក្នុងខណៈយល់ឃើញភាពថា ក្នុងពេលឃើញរូប ឬរូបារម្មណ៍ ។

- **វេទនាខន្ធ** រមែងប្រាកដក្នុងខណៈដឹងត្រឹមតែសប្បាយចិត្តខូចចិត្ត ឬព្រងើយៗ ក្នុងពេលឃើញ ។

- **សញ្ញាខន្ធ** រមែងប្រាកដក្នុងខណៈសំគាល់ដឹងវត្ថុដែលបានឃើញ ។

- **សង្ខារខន្ធ** រមែងប្រាកដក្នុងខណៈផ្សេងៗ ដូចជា

  - ផស្សៈ រមែងប្រាកដក្នុងខណៈប៉ះខ្ទប់នឹងពណ៌ ។

  - ចេតនា រមែងប្រាកដក្នុងខណៈតាំងចិត្ត ។

  - លោភៈ រមែងប្រាកដក្នុងខណៈត្រេកអរពេញចិត្ត ។

  - ទោសៈ រមែងប្រាកដក្នុងខណៈមិនពេញចិត្ត ។

  - សទ្ធា រមែងប្រាកដក្នុងខណៈជ្រះថ្លា ។

- **វិញ្ញាណក្ខន្ធ** រមែងប្រាកដក្នុងខណៈដែលឃើញជាប្រធាន ។

អ្នកបដិបត្តិទទួលដឹងយ៉ាងនេះ រមែងសម្គាល់ថា មានត្រឹមតែរូប វេទនាជាដើម ដែលជាសភាវធម៌បច្ចុប្បន្ន ដែលកើតឡើងតាំងនៅ រលត់ទៅ ជាទុក្ខ មិនមែនតួខ្លួន មិនស្រស់ស្អាត សមពិតដូចព្រះពុទ្ធវចនថា

ឥធ ភិក្ខវេ ភិក្ខុ ឥតិ រូបំ, ឥតិ រូបស្ស សមុទយោ, ឥតិ រូបស្ស

អត្ថង្គមោ ។ ឥតិ វេទនា, ឥតិ វេទនាយ សមុទយោ, ឥតិ វេទនាយ អត្ថង្គមោ ។ ឥតិ សញ្ញា, ឥតិ សញ្ញាយ សមុទយោ, ឥតិ សញ្ញាយ អត្ថង្គមោ ។ ឥតិ សង្ខារា, ឥតិ សង្ខារានំ សមុទយោ, ឥតិ សង្ខារានំ អត្ថង្គមោ ។ ឥតិ វិញ្ញាណំ, ឥតិ វិញ្ញាណស្ស សមុទយោ, ឥតិ វិញ្ញាណស្ស អត្ថង្គមោ[១០៨] ។

"ភិក្ខុក្នុងព្រះសាសនានេះ រមែងដឹងច្បាស់ថា នេះគឺរូប ការកើតឡើងរបស់រូប រមែងមានយ៉ាងនេះ ការរលត់ទៅរបស់រូប រមែងមានយ៉ាងនេះ ។ នេះគឺវេទនា ការកើតរបស់វេទនា រមែងមានយ៉ាងនេះ ការរលត់ទៅរបស់វេទនា រមែងមានយ៉ាងនេះ ។ នេះគឺសញ្ញា ការកើតឡើងរបស់សញ្ញា រមែងមានយ៉ាងនេះ ការរលត់ទៅរបស់សញ្ញា រមែងមានយ៉ាងនេះ ។ នេះគឺសង្ខារ ការកើតឡើងរបស់សង្ខារ រមែងមានយ៉ាងនេះ ការរលត់ទៅរបស់សង្ខារ រមែងមានយ៉ាងនេះ ។ នេះគឺវិញ្ញាណ ការកើតឡើងរបស់វិញ្ញាណ រមែងមានយ៉ាងនេះ ការរលត់ទៅរបស់វិញ្ញាណ រមែងមានយ៉ាងនេះ" ។

ការដឹងច្បាស់ថា នេះគឺរូប សំដៅដល់ការឃើញថា សភាវៈ

ប៉ោងផតជាដើម ជារូបដែលប្រែប្រួល ការឃើញវេទនាថា ជាការដឹងខ្លួន សញ្ញាជាសេចក្ដីចងចាំបានដឹង សង្ខារជាការតាក់តែងចិត្តឲ្យមានសភាវៈស្រឡាញ់ ឬស្អប់ ។ល។ និងវិញ្ញាណជាការទទួលដឹងអារម្មណ៍ប៉ុណ្ណោះ ។ សមពិត ដូចពាក្យអធិប្បាយក្នុងគម្ពីរអដ្ឋកថាថា

**ឥតិ រូបន្តិ ឥទំ រូបំ ឯត្តកំ រូបំ, ន ឥតោ បរំ រូបំ អត្ថីតិ សភាវតោ រូបំ បជានាតិ ។ វេទនាទីសុបិ ឯសេវ នយោ[១០៩] ។**

"ព្រះតម្រាស់ថា ឥតិ រូបំ ( នេះគឺរូប ) មានន័យថា រមែងដឹងច្បាស់រូបតាមលក្ខណៈរបស់ខ្លួនថា សភាវៈនេះ គឺរូបដែលប្រែប្រួល និងរូបក៏មានត្រឹមតែប៉ុណ្ណោះ មិនមានរូបដទៃក្រៅលែងទៅជាងនេះ សូម្បីវេទនាជាដើម ក៏ន័យនេះដូចគ្នា" ។

អ្នកបដិបត្តិដែលប្រចក្សច្បាស់លក្ខណៈរបស់រូបជាដើមយ៉ាងជាក់ច្បាស់ហើយ រមែងនឹងកើតបញ្ញាឃើញច្បាស់នូវការកើតរលត់របស់រូបជាដើមទៀតផង ពោលគឺ រូបដែលចលនាដោយការលាតនិងការបត់ មានសភាពកើតឡើង និងអស់ទៅក្នុងតែមួយអាការ

ដែលលាភ និងបត់ តមកអ្នកបដិបត្តិនឹងទទួលដឹងការកើតឡើង និងការរលត់ទៅយ៉ាងលឿនរហ័ស របស់សភាវៈលាភ និងបត់ជាដើម ។

ក្រៅពីនេះ អ្នកបដិបត្តិដូចដែលពោលនេះ អាចយល់ហេតុដែលធ្វើឲ្យរូបកើតឡើងនិងរលត់ទៅទៀតផង ពោលគឺ ៖

- រូបកើតពីអវិជ្ជា ( ការមិនដឹងដែនកើតក្នុងភពមុន ) តណ្ហា ( ការភ្ញើតភ្ញើនក្នុងកាមគុណដែលកើតក្នុងភពមុន ) កម្ម ( ការធ្វើក្នុងភពមុន ) និងអាហារ ( វត្ថុដែលបរិភោគក្នុងភពនេះ ) ។

- វេទនាកើតពីអវិជ្ជា តណ្ហា កម្ម និងផស្សៈ ( ការដែលចិត្តប៉ះខ្ទប់ជាមួយអារម្មណ៍ ) ។

- សញ្ញាកើតពីអវិជ្ជា តណ្ហា កម្ម និងផស្សៈ ។

- សង្ខារកើតពីអវិជ្ជា តណ្ហា កម្ម និងផស្សៈ ។

- វិញ្ញាណកើតពីអវិជ្ជា តណ្ហា កម្ម និងរូបនាម ។

ចំណែកហេតុនៃការរលត់ទៅរបស់រូបជាដើម មានលក្ខណៈ

ផុយគ្នាពេលគឺ រូបរលត់ព្រោះអវិជ្ជាដូច្នេះជាដើម ។

## ពួកអាយតនៈ និងពួកធាតុ

ក្នុងខណៈឃើញរូប ចក្ខុបសាទ ឈ្មោះថា ចក្ខាយតនៈ ឬចក្ខុធាតុ រូបារម្មណ៍ឈ្មោះថា រូបាយតនៈ ឬរូបធាតុ ចិត្តទាំងអស់ដែលកើតឡើង ក្នុងខណៈឃើញឈ្មោះថា មនាយតនៈ កាលចែកចិត្តដោយធាតុបានដូច្នេះ គឺ ៖

-ចិត្តធ្វើនាទីឃើញរូប ឈ្មោះថា ចក្ខុវិញ្ញាណធាតុ ( ចិត្តដែលធ្វើនាទីបានឮសម្លេង ឈ្មោះថា សោតវិញ្ញាណធាតុជាដើម ) ។

-អាវជ្ជនចិត្តដែលកើតមុនចក្ខុវិញ្ញាណ ដែលធ្វើនាទីពិចារណាវត្ថុដែលឃើញ និងសម្បដិច្ឆន្នចិត្តដែលកើតបន្ទាប់អំពីចក្ខុវិញ្ញាណធ្វើនាទីទទួលយករូបារម្មណ៍ទុក ឈ្មោះថា មនោធាតុ ។

- ចិត្តដែលកើតក្នុងលំដាប់តមក គឺសន្តីរណចិត្ត ធ្វើនាទីពិចារណាអារម្មណ៍ វោដ្ឋព្វនចិត្តធ្វើនាទីកាត់ក្តីអារម្មណ៍ថា ល្អ ឬមិនល្អ ជវនចិត្ត ដូចជាមួយការស្ទុះចូលទៅរករូបារម្មណ៍ និងតទារម្មណចិត្ត ដែលកើតបន្ទាប់អំពីជវនចិត្ត ធ្វើនាទីទទួលយកនូវ

អារម្មណ៍របស់ជវនចិត្ត ចិត្តទាំងអស់នេះឈ្មោះថា មនោវិញ្ញាណ-ធាតុ ។

- ចេតសិកធ្វើនាទីតាក់តែងចិត្ត ដូចជាការប៉ះខ្ទប់អារម្មណ៍ ( ផស្សៈ ) ការសោយអារម្មណ៍ ( វេទនា ) ការចងចាំ ( សញ្ញា ) ការតាំងចិត្ត ( ចេតនា ) ការត្រេកអរពេញចិត្ត ( លោភៈ ) ការមិនពេញចិត្ត ( ទោសៈ ) និងសេចក្ដីជ្រះថ្លា ( សទ្ធា )ជាដើម ឈ្មោះថា ធម្មាយតនៈ ឬធម្មធាតុ ។

ចិត្តនិងចេតសិកទាំងអស់ មានសភាពបង្អោនទៅក្នុងអារម្មណ៍ ទើបឈ្មោះថានាម ចំណែកចក្ខុបសាទ និងរូបារម្មណ៍ ឈ្មោះថារូប ព្រោះមិនបង្អោនទៅក្នុងអារម្មណ៍ និងប្រែប្រួលកាលជួបជាមួយវត្ថុដែលបដិបក្ខគ្នា មានការក្ដៅ ការត្រជាក់ជាដើម សរុបសេចក្ដីមក អ្នកដែលចម្រើនសតិ តាមដឹងសភាវៈការឃើញ កាលកំណត់ថា "ឃើញហ្ន៎" ចាត់ថា ជាអ្នកដែលទទួលដឹងរូបនាម ២ យ៉ាង អាយតនៈ ៤ យ៉ាង និងធាតុ ៦ យ៉ាងតាមសមគួរ ។

ក្នុងខណៈបានឮកាលកំណត់ថា "បានឮហ្ន៎" តែកបានដូច្នេះ

គឺ ៖

- សោតបសាទ ជារូបខន្ធ សោតាយតនៈ សោតធាតុ ។

- សម្លេងជារូបខន្ធ សទ្ទាយតនៈ សទ្ទធាតុ ។

- ការបានឮ ជានាមខន្ធ មនាយតនៈ សោតវិញ្ញាណធាតុ មនោធាតុ មនោវិញ្ញាណធាតុ ធម្មាយតនៈ ធម្មធាតុ ( សោតវិញ្ញាណចិត្ត ជាមនាយតនៈ សោតវិញ្ញាណធាតុ វិថីចិត្តដែលសល់ជាមនោធាតុ មនោវិញ្ញាណធាតុ ចំណែកចេតសិកដែលប្រកបជាធម្មាយតនៈ ធម្មធាតុ ) ។

ក្នុងខណៈដឹងក្លិន កាលកំណត់ថា “ដឹងហ្ន៎” ចែកបានដូច្នេះ គឺ ៖

- ឃានបសាទ ជារូបខន្ធ ឃានាយតនៈ ឃានធាតុ ។

- ក្លិន ជារូបខន្ធ គន្ធាយតនៈ គន្ធធាតុ ។

- ការដឹងក្លិន ជានាមខន្ធ មនាយតនៈ ឃានវិញ្ញាណធាតុ មនោធាតុ មនោវិញ្ញាណធាតុ ធម្មាយតនៈ ធម្មធាតុ ។

ក្នុងខណៈភ្លក់រស កាលកំណត់ថា “ដឹងហ្ន៎” ឬ “ភ្លក់ហ្ន៎” ចែកបានដូច្នេះ គឺ ៖

- ជិវ្ហាបសាទ ជារូបខន្ធ ជិវ្ហាយតនៈ ជិវ្ហាធាតុ ។

- រស ជារូបខន្ធ រសាយតនៈ រសធាតុ ។

- ការភ្លក់រស ជានាមខន្ធ មនាយតនៈ ជិវ្ហាវិញ្ញាណធាតុ មនោធាតុ មនោវិញ្ញាណធាតុ ធម្មាយតនៈ ធម្មធាតុ ។

ក្នុងខណៈប៉ះខ្ទប់ កាលកំណត់ថា “ប៉ះខ្ទប់ហ្ន៎” ចែកបានដូច្នេះ គឺ ៖

- កាយបសាទ ជារូបខន្ធ កាយាយតនៈ កាយធាតុ ។

- សម្ផស្ស ជារូបខន្ធ ផោដ្ឋព្វាយតនៈ ផោដ្ឋព្វធាតុ ។

- ការដឹងសម្ផស្ស ជានាមខន្ធ មនាយតនៈ កាយវិញ្ញាណធាតុ មនោធាតុ មនោវិញ្ញាណធាតុ ធម្មាយតនៈ ធម្មធាតុ ។

ក្នុងខណៈនឹកគិត កាលកំណត់ថា “គិតហ្ន៎” ចែកបានដូច្នេះ គឺ ៖

- ចិត្តជាសភាវៈដែលទទួលដឹងអារម្មណ៍ ជានាមខន្ធ មនាយតនៈ មនោវិញ្ញាណធាតុ ។

- ចេតសិកដែលតាក់តែងចិត្ត ដូចជាការប៉ះខ្ទប់អារម្មណ៍ ( ផស្សៈ ) ការសោយអារម្មណ៍ ( វេទនា )ជាដើម ជានាមខន្ធ ធម្មាយតនៈ ធម្មធាតុ ។

សុខុមរូបក៏ចាត់ថាជាធម្មាយតនៈ ធម្មធាតុ ពោលគឺ ៖

- ហទយវត្ថុ ជាទីអាស្រ័យកើតរបស់ចិត្តដែលនឹកគិត ។

- ឥត្ថីភាវរូប ជាហេតុនៃភាពជាស្ត្រី ។

- បុរិសភាវរូប ជាហេតុនៃភាពជាបុរស ។

ដោយហេតុនេះ អ្នកដែលតាមដឹងចិត្តដែលគិតរវើរវាយថា "គិតហ្ន៎" "រវើរវាយហ្ន៎" ឬតាមដឹងចិត្តដែលគិតចង់នឹងធ្វើឥរិយាបថយ៉ាងណាទិមួយថា "ចង់លាតហ្ន៎" "ចង់បត់ហ្ន៎"ជាដើម ចាត់ជាអ្នកទទួលដឹងរូបនាម ២ យ៉ាង អាយតនៈ ២ យ៉ាង និងធាតុ ២ យ៉ាងតាមសមគួរ ម្យ៉ាងទៀត អារម្មណ៍ដែលប្រាកដក្នុងខណៈដែល

ទទួលដឹងធម្មារម្មណ៍អាចជាបញ្ញត្តិ ឬបរមត្ថបាន ទាំង ២យ៉ាង ។

៦ពួកសំយោជនៈ

ក្នុងពួកនេះ ព្រះអង្គត្រាស់ដល់ការតាមដឹងសំយោជនៈដែលកើតឡើងក្នុងខណៈឃើញជាដើមទៀតផង សំយោជនៈ គឺសភាពដែលចងពួកសត្វទុកក្នុងវដ្តសង្សារ ដោយធ្វើឲ្យវិលកើត វិលស្លាប់អំពីភពចាស់ទៅកាន់ភពថ្មី មាន ១០ យ៉ាងគឺ ៖

១. **កាមរាគៈ** ការត្រេកអរក្នុងកាមគុណទាំងខាងក្នុង និងខាងក្រៅរាងកាយរបស់ខ្លួន ។

២. **បដិឃៈ** ការប្រទូសរាយក្នុងអារម្មណ៍ បានដល់ការកើតទុក្ខមិនពេញចិត្ត ក្រោធ ស្អប់ ប្រទូសរាយ ។

៣. **មានៈ** ការប្រកាន់ខ្លួន ។

៤. **ទិដ្ឋិ** ការយល់ខុសថាមានអត្តា ឬវិញ្ញាណ ដែលមិនសូន្យ និងជាប់តាមខ្លួនទៅគ្រប់ៗ ជាតិ ។

៥. **វិចិកិច្ឆា** ការសង្ស័យ មិនស្ងប់ចិត្តគឺ វិភាគវិចារណ៍ក្នុង

គុណរបស់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កម្មនិងផលកម្ម ។

៦. **សីលព្វតបរាមាស** ការប្រកាន់មាំក្នុងសីល និងវត្តក្រៅសាសនា ដែលប្រព្រឹត្តខ្លួនដូចសុនក គោ ។ល។ ថាជាផ្លូវរួចផុតចាកទុក្ខ ។

៧. **ភវរាគៈ** ការពេញចិត្តក្នុងរូបភព អរូបភព ឬរូបឈាន អរូបឈាន ដែលខ្លួនសម្គាល់ថាល្អប្រសើរ ។

៨. **ឥស្សា** ការច្រណែនមិនពេញចិត្តក្នុងសម្បត្តិ ឬគុណសេចក្ដីល្អរបស់អ្នកដទៃ ។

៩. **មច្ឆរិយៈ** ការហួងហែងទ្រព្យសម្បត្តិ ឬគុណសេចក្ដីល្អរបស់ខ្លួនដោយត្រូវការឲ្យកើតដល់ខ្លួនប៉ុណ្ណោះ មិនត្រូវការឲ្យអ្នកដទៃបានទទួល ។

១០. **អវិជ្ជា** ការមិនដឹងសេចក្ដីពិតក្នុងសភាវៈរបស់រូបនាម ការបិទបាំងសភាពពិតទុក គឺការវង្វេង ។

សំយោជនៈ ១០ ទាំងនេះ រមែងកើតឡើងតាមសមគួរដល់

បុគ្គល ដែលមិនបានចម្រើនសតិទទួលដឹងរូបនាមបច្ចុប្បន្នជាអារម្មណ៍ អ្នកបដិបត្តិគប្បីតាមដឹងតាមសភាវៈនោះៗ ថា "ប្រាថ្នាហ្ន៎" ជាដើម ការតាមដឹងយ៉ាងនេះចាត់ថា ជាការទទួលដឹងការធ្វើទុកក្នុងចិត្តដោយមិនត្រូវទំនង ( អយោនិសោមនសិការ )ដែលធ្វើឲ្យកើតសំយោជនៈ និងការធ្វើទុកក្នុងចិត្តដោយត្រូវទំនង ដោយការកំណត់ដឹងសំយោជនៈដែលកើតឡើងហើយ និងធ្វើឲ្យសំយោជនៈរលត់ទៅថា

យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ, តញ្ច បជានាតិ ។ យថា ច អនុប្បន្នស្ស សំយោជនស្ស ឧប្បាទោ ហោតិ, តញ្ច បជានាតិ ។ យថា ច ឧប្បន្នស្ស សំយោជនស្ស បហានំ ហោតិ, តញ្ច បជានាតិ[១១០] ។

"ម្យ៉ាងទៀត សំយោជនៈដែលនៅមិនទាន់កើតនឹងកើតឡើងដោយប្រការណា រមែងដឹងច្បាស់ប្រការនោះ សំយោជនៈដែលកើតឡើងហើយនឹងលះចេញបានដោយប្រការណា រមែងដឹងច្បាស់ប្រការនោះ" ។

ក្រៅពីនេះព្រះអង្គបានត្រាស់ដូច្នេះថា

យថា ច បហីនស្ស សំយោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ[១១] ។

"សំយោជនៈដែលលះបានហើយនឹងមិនកើតឡើងតទៅដោយប្រការណា រមែងដឹងច្បាស់ប្រការនោះ" ។

សេចក្ដីនេះមានន័យថា មគ្គជាធម៌ដែលលះសំយោជនៈបានដោយមិនមានសេសសល់ កាលអ្នកបដិបត្តិសម្រេចមគ្គហើយកើតបច្ចវេក្ខណញ្ញាណទើបនឹងដឹងថា ខ្លួនលះសំយោជនៈកិលេសយ៉ាងណាបានខ្លះ ពោលគឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឥស្សា និងមច្ឆរិយៈ ត្រូវលះដោយសោតាបត្តិមគ្គ កាមរាគៈនិងបដិឃៈយ៉ាងគ្រោតគ្រាត ត្រូវលះដោយសកទាគាមិមគ្គ កាមរាគៈនិងបដិឃៈយ៉ាងល្អិតត្រូវលះដោយអនាគាមិមគ្គ មានៈ ភវរាគៈ និងអវិជ្ជាត្រូវលះដោយអរហត្តមគ្គ ។

សូម្បីព្រះសោតាបន្ន លះបង់សេចក្ដីកំណាញ់ដោយមិនមានសេសសល់ តែលោកមិនបានបរិច្ចាគគ្រប់វត្ថុ ដល់អ្នកដែលមក

សូម មិនដូច្នោះហើយ លោកក៏គង់ទីងអស់ភាពបរិសុទ្ធយ៉ាងពិត ប្រាកដ លោករមែងបរិច្ចាគ ដល់អ្នកទទួលយ៉ាងពេញចិត្ត ជាមួយ ទីងអត្តភាពរបស់ខ្លួន ដូចរឿងរបស់នាងឧប្បលវណ្ណាថេរី ដែលមិន បានថ្វាយសំពត់ស្បង់ដល់ព្រះឧទាយី អ្នកមកសូមទទួលបរិច្ចាគ ដោយពោលថា

**មយំ ខោ ភន្តេ មាតុគាមា នាម កិច្ឆលាភា ។ ឥទញ្ច មេ អន្តិមំ បញ្ចមំ ចីវរំ ។ នាហំ ទស្សាមិ[១១២] ។**

"បពិត្រលោកម្ចាស់ដ៏ចំរើន ធម្មតាថា ពួកយើងទាំងឡាយជា មាតុគ្រាមជាអ្នកមានលាភតិចរកបានលំបាក និងចីវរនេះក៏ជាផ្នែក ទី ៥ ជាំងបំផុត នាងខ្ញុំទីងមិនថ្វាយទេ" ។

នាងឧប្បលវណ្ណាថេរី ជាព្រះអរហន្តអ្នកលះកិលេសទាំងអស់ បានហើយ តែមិនបានថ្វាយសំពត់ស្បង់ដល់ព្រះឧទាយី ព្រោះមិន គួរថ្វាយដល់អ្នកដទៃក្នុងខណៈនោះ ។

៦ ពួកពោជ្ឈង្គៈ

កាលឧទយព្វយញ្ញាណ ដែលឃើញការកើតរលត់ បានកើតឡើងហើយ សតិដែលឃុំគ្រងក៏អាចរលឹកដឹងទាន់សភាវធម៌បច្ចុប្បន្ន ដូចស្រមោលជាប់តាមខ្លួនរមែងកើតឡើង សតិដូចដែលពោលអាចញ៉ាំងឲ្យចិត្តនៃបរិត្យចូលលិចចុះក្នុងអារម្មណ៍បច្ចុប្បន្ន ដូចគម្ពីរអដ្ឋកថា[១១៣]ពោលថា **សតិអបិលាបនលក្ខណា** ( សតិមានលក្ខណៈធ្វើឲ្យចិត្តមិនអណ្តែតអណ្តូង ) សតិយ៉ាងនេះ ឈ្មោះថា សតិសម្ពោជ្ឈង្គៈ ព្រោះញ៉ាំងផលឲ្យកើតមគ្គញាណបាន ។

ក្នុងខណៈនោះ អ្នកបដិបត្តិនឹងកើតបញ្ញាដឹងច្បាស់លក្ខណៈវិសេស ( **សភាវលក្ខណៈ** ) របស់រូបនាមយ៉ាងជាក់ច្បាស់រហូតពេលដែលតាមដឹងបច្ចុប្បន្ន និងអាចឃើញត្រៃលក្ខណ៍ គឺការមិនទៀងដែលជាការកើតរលត់យ៉ាងលឿនរហ័ស ( **អនិច្ចំ** ) សេចក្តីទុក្ខដែលជាការលំបាកចិត្តមិនគួរប្រាថ្នា ( **ទុក្ខំ** ) និងសេចក្តីមិនមែនតួខ្លួនដែលមិនមាននរណាបង្គាប់បញ្ជាបាន ( **អនត្តា** ) បញ្ញាឃើញដូច្នេះឈ្មោះថា ធម្មវិចយសម្ពោជ្ឈង្គៈ ។

ក្នុងខណៈពោល ការព្យាយាមយ៉ាងកណ្តាល មិនធូរមិនតឹង

រមែងកើតឡើងគ្រប់ខណៈដែលកំពុងចំរើនសតិ ការព្យាយាមនេះមិនតឹងរហូតញ៉ាំងផលឲ្យកើតសេចក្ដីរវើរវាយ និងមិនធូររហូតឲ្យញ៉ាំងផលឲ្យកើតការរាយមាយទើបឈ្មោះថាវីរិយសម្ពោជ្ឈង្គៈ ។

សេចក្ដីឆ្អែតចិត្ត គឺបីតិ ៥ ប្រការ ដែលកើតឡើងក្នុងខណៈបដិបត្តិធម៌ឈ្មោះថា បីតិសម្ពោជ្ឈង្គៈ ។

សេចក្ដីស្ងប់កាយស្ងប់ចិត្ត ដែលកើតឡើងក្នុងខណៈនោះឈ្មោះថា បស្សទ្ធិសម្ពោជ្ឈង្គៈ ។

សេចក្ដីឆ្អែតចិត្ត ( **បីតិ** ) និងសេចក្ដីស្ងប់កាយស្ងប់ចិត្ត ( **បស្សទ្ធិ** ) ពួកនេះ រមែងកើតឡើង ក្នុងខណៈចាប់ផ្ដើមសម្រេចឧទយព្វយញ្ញាណ និងប្រាកដច្បាស់ក្នុងគ្រាខ្លះ កាលបន្ទុះភង្គញាណជាដើមទៅ តែកាលបន្ទុះសង្ខារុបេក្ខាញាណ ដែលជាញាណទី ១១ គឺជាញាណខ្ពស់បំផុតរបស់បុថុជ្ជន ខណៈខ្លះអាចកើតជាប់បន្តគ្នាអស់កាលយូរ កាលនោះអ្នកបដិបត្តិរមែងបានទទួលសេចក្ដីសុខដែលមិនធ្លាប់ជួបប្រទះមកមុនយ៉ាងសន្ធឹកសន្ធាប់គ្រប់ៗ ខណៈក្នុងពេលដែលឈរ ដើរ អង្គុយ ដេក ខណៈខ្លះអាចដឹងខ្លួនថា

មានសេចក្ដីត្រជាក់សប្បាយបែកសាយតាមរាងកាយ ដោយកម្លាំងរបស់ការផ្ចង់ចិត្ត ខណៈខ្លះក៏រលឹកដឹងដល់សេចក្ដីស្ងប់ចិត្តដោយប្រាសចាកការក្រហល់ក្រហាយ អ្នកបដិបត្តិគ្រប់គ្នា ដែលកើតសភាវធម៌ដូច្នេះ នឹងកើតសេចក្ដីត្រេកអរសប្បាយក្នុងធម៌ដែលមានសេចក្ដីសុខជាងសេចក្ដីសុខអាស្រ័យកាមគុណ ដូចមានព្រះពុទ្ធវចន[១១៤]ថា **សព្វរតី ធម្មរតិ ជិនាតិ** ( សេចក្ដីត្រេកអរក្នុងធម៌ឈ្នះអស់សេចក្ដីត្រេកអរទាំងពួង ) ។

សមាធិមួយខណៈ ( **ខណិកសមាធិ** ) ដែលនៃបនិត្យនៅក្នុងសភាវធម៌បច្ចុប្បន្ន ដោយប្រាសចាកនីវរណៈរំខានចិត្ត ដែលជាហេតុឲ្យកើតបញ្ញា ឃើញច្បាស់សភាវធម៌តាមសេចក្ដីពិត ឈ្មោះថាសមាធិសម្ពោជ្ឈង្គៈ ។

សេចក្ដីព្រងើយកន្តើយ ក្នុងការដឹងទាន់ដោយវីរិយៈជាមួយសមាធិមានសេចក្ដីស្មើគ្នា ឈ្មោះថា ឧបេក្ខាសម្ពោជ្ឈង្គៈ អង្គធម៌គឺតត្រមជ្ឈត្តតាចេតសិក ឧបេក្ខាប្រភេទនេះ ប្រាកដឡើង លំបាកនឹងអធិប្បាយឲ្យអ្នកដទៃយល់ចូលចិត្តបានដោយលំបាក តែអ្នក

បដិបត្តិដែលបន្ទុះខុទយព្វយញ្ញាណជាដើមទៅហើយ នឹងអាចទទួល ដឹងឧបេក្ខានេះ ដែលកើតឡើងយ៉ាងជាក់ច្បាស់បាន ។

គ្រាជំបូងនៃការបដិបត្តិធម៌នោះ ឥន្ទ្រិយ៍ ៥ គឺសទ្ធា វិរិយៈ សតិ សមាធិ និងបញ្ញា មានកម្លាំងតិច និងសទ្ធាមិនស្មើគ្នាជាមួយ បញ្ញា វិរិយៈ មិនស្មើគ្នាជាមួយសមាធិ ញុាំងផលមិនឲ្យជួបការ ឈានទៅមុខតាមដែលគួរ លក្ខណៈនៃការមិនស្មើគ្នា គឺក្នុងខណៈ ខ្លះ សទ្ធាមានកម្លាំងច្រើនជាងបញ្ញា ដោយចំពោះកាលផ្ដើមដឹង លក្ខណៈវិសេសរបស់រូបនាមយ៉ាងជាក់ច្បាស់ និងការកើតរលត់ របស់រូបនាម អ្នកខ្លះកើតសទ្ធាចាស់ក្លារហួតមិនបានចំរើនសតិយ៉ាង បន្តបន្ទាប់ តែទៅត្រិះរិះដោយសេចក្ដីជ្រះថ្លាថា មានត្រឹមតែរូបនាម ប៉ុណ្ណោះ មិនមានបុគ្គល យើង របស់យើង និងធម៌ដែលតាំងនៅ យូរជាងមួយប្រព្រិចភ្នែក រមែងមិនមានឡើយ ធម៌ទាំងពួងមាន សភាពមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ព្រះអង្គជាអ្នកដឹងធម៌យ៉ាង ពិតប្រាកដ ព្រះធម៌ជាពាក្យប្រៀនប្រដៅដ៏ត្រឹមត្រូវ ពាក្យបង្រៀន របស់វិបស្សនាចារ្យ ក៏ស្របតាមព្រះពុទ្ធវចនជាដើម ។

ក្នុងខណៈខ្លះ បញ្ញាមានកម្លាំងខ្លាំងជាងសទ្ធា ញ៉ាំងផលមិនឲ្យបានចំរើនសតិយ៉ាងបន្តបន្ទាប់ តែទៅគិតពិចារណាថា វត្ថុដែលទទួលដឹងជារូប ឬនាម ជាផស្សៈ ឬវេទនាជាលក្ខណៈ នាទី អាការប្រាកដ ឬហេតុជិតជាដើម ។

ក្នុងខណៈខ្លះ វិរិយៈមានកម្លាំងច្រើនជាងសមាធិ ញ៉ាំងផលឲ្យប្របូកប្របល់ក្នុងចិត្តជាមួយការបដិបត្តិ និងមានសេចក្តីរវើរវាយរំខានចិត្តជានិច្ច មិនអាចចំរើនសតិយ៉ាងជាប់តគ្នាបាន ។

ក្នុងខណៈខ្លះ សមាធិមានកម្លាំងច្រើនជាងវិរិយៈ ញ៉ាំងផលឲ្យងងុយជិនណាយគ្របសង្កត់ចិត្ត មិនអាចចំរើនសតិយ៉ាងជាប់តគ្នា ។

ឧបេក្ខាដែលហៅថា តត្រមជ្ឈត្តតានេះ ជាគ្រឿងកែតម្រូវសទ្ធាជាមួយបញ្ញា និងវិរិយៈជាមួយសមាធិឲ្យស្មើគ្នា ញ៉ាំងផលឲ្យមិនគិតជ្រះថ្លា ឬគិតពិចារណាព្រមទាំងមិនមានការរវើរវាយ និងងងុយជិនណាយក្នុងខណៈនោះ អ្នកបដិបត្តិនឹងអាចតាមដឹងសភាវធម៌បច្ចុប្បន្នបានជាក់ច្បាស់យ៉ាងក្រៃលែង មិនភ្លេចសតិរលឹកដឹងតាម

ទាន់សភាវពិត ព្រះអង្គត្រាស់ការចម្រើនសតិសម្ពោជ្ឈង្គៈទុកក្នុងមហាសតិប្បដ្ឋានសូត្រថា

៩៨ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ បជានាតិ ។ អសន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ[១១៤] ។

"ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោះសតិសម្ពោជ្ឈង្គៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ។ ពោះសតិសម្ពោជ្ឈង្គៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ" ។

ក្រៅពីនេះ អ្នកបដិបត្តិធម៌រមែងដឹងច្បាស់ថា សតិសម្ពោជ្ឈង្គៈកើតអំពីយោនិសោមនសិការ គឺការចំរើនសតិយ៉ាងជាប់តគ្នា រហូតជាហេតុឲ្យកើតសតិសម្ពោជ្ឈង្គៈ សេចក្ដីតាំងចិត្តថា នឹងអប់រំចិត្តឲ្យកើតសតិសម្ពោជ្ឈង្គៈ និងការធ្វើទុកក្នុងចិត្តនៅអារម្មណ៍ដែលគួរជ្រះថ្លាមានព្រះពុទ្ធគុណជាដើម ។ម្យ៉ាងទៀត ក្នុងខណៈដែល

សម្រេចធម៌ជាព្រះអរហន្ត ហើយពិចារណាដោយបច្ចវេក្ខណញាណ រមែងដឹងច្បាស់ថា បានចម្រើនសតិសម្ពោជ្ឈង្គៈយ៉ាងបរិបូណ៌ហើយ សមពិតដូចព្រះពុទ្ធវចនថា

យថា ច អនុប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ, តញ្ច បជានាតិ ។ យថា ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ, តញ្ច បជានាតិ[១១៦] ។

"ម្យ៉ាងទៀត សតិសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើត នឹងកើតឡើងដោយហេតុណា រមែងដឹងច្បាស់ដោយហេតុនោះ សតិសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយ និងចំរើនបរិបូណ៌ដោយហេតុណា រមែងដឹងច្បាស់ដោយហេតុនោះ" ។

សូម្បីធម្មវិចយសម្ពោជ្ឈង្គៈជាដើម ក៏មានន័យដូចគ្នាយ៉ាងនេះ ។

## ពួកអរិយសច្ច

អរិយសច្ច គឺសេចក្ដីពិតដ៏ប្រសើរមាន ៤ យ៉ាង គឺ ៖

១. ទុក្ខសច្ច សភាវៈពិត គឺទុក្ខ ។

២. **ទុក្ខសមុទយសច្ច** សភាវៈពិត គឺហេតុនៃទុក្ខ ។

៣. **និរោធសច្ច** សភាវៈពិត គឺការរលត់ទុក្ខ ។

៤. **មគ្គសច្ច** សភាវៈពិត គឺផ្លូវរំលត់ទុក្ខ ។

**ទុក្ខសច្ច** គឺសេចក្ដីទុក្ខ ដែលមិនគួរប្រាថ្នា មិនគួរពេញចិត្ត បែងចេញជា ៣ ប្រភេទ គឺ ៖

- **ជាតិទុក្ខ** ទុក្ខ គឺការកើត ដែលជាការឧបត្តិរបស់រូបនាមក្នុងភពមួយៗ ។

- **ជរាទុក្ខ** ទុក្ខ គឺការចាស់នៃរូបនាម ដែលកើតឡើងយ៉ាងបន្តបន្ទាប់ ។

- **មរណទុក្ខ** ទុក្ខ គឺសេចក្ដីស្លាប់ ជាការរលត់សូន្យរបស់រូបនាម ដោយមិនកើតឡើងទៀតក្នុងភពនោះ ៗ ។

ក្រៅពីនេះ ទុក្ខនៅមាន ៧ ប្រភេទទៀត គឺ ៖

- **ទុក្ខទុក្ខ** ទុក្ខពិតដែលអត់ទ្រាំបានលំបាក គឺសេចក្ដីទុក្ខ ផ្លូវកាយ ដែលបានដល់ការឈឺចុកចាប់ ឬសេចក្ដីទុក្ខផ្លូវចិត្ត ដែល

បានដល់ការមិនសប្បាយចិត្ត សេចក្ដីសោកសង្រេងចិត្ត ។

- *វិបរិណាមទុក្ខ* ទុក្ខប្រែប្រួល គឺសេចក្ដីទុក្ខផ្លូវកាយនិងចិត្ត ដែលមិនបានគង់វង់នៅរហូតទៅ កាលប្រែប្រួលទៅ ក៏ធ្វើឲ្យអ្នកដែលបានទទួលសេចក្ដីសុខកើតសេចក្ដីទុក្ខវិញ ។

- *សង្ខារទុក្ខ* ទុក្ខប្រចាំសង្ខារ គឺរូបនាមទាំងអស់ដែលជាលោកិយធម៌ព្រមទាំងឧបេក្ខាវេទនា វៀរលែងតណ្ហាចេញ សង្ខារទុក្ខនេះ គ្របដណ្ដប់សេចក្ដីទុក្ខក្នុងទុក្ខសច្ចទាំងអស់ សុខ្បីសុខ-វេទនា និងទុក្ខវេទនា ក៏រាប់ចូលក្នុងសង្ខារទុក្ខដូចគ្នា ដូចសេចក្ដីក្នុងសឡាយតនវគ្គ វេទនាសំយុត្ត ថា

**តំ ខោ បនេតំ ភិក្ខុ មយា សង្ខារនំ អនិច្ចតំ សន្ធាយ ភាសិតំ យំ កិញ្ចិ វេទយិតំ, តំ ទុក្ខស្មិន្តិ**[១១៧] ។

"ម្នាលភិក្ខុ ពាក្យថា វេទនាយ៉ាងណានិមួយមាននៅ វេទនានោះជាទុក្ខ តថាគតពោលដល់ការមិនទៀងរបស់សង្ខារទាំងឡាយ" ។

សុខ្បីសុខវេទនា និងទុក្ខវេទនានឹងរាប់ថា ជាសង្ខារទុក្ខដូចគ្នា តែសុខវេទនា ជាហេតុឲ្យកើតទុក្ខ កាលប្រែប្រួលអំពីដើមទើបមាន

ឈ្មោះថា វិបរិណាមទុក្ខ និងទុក្ខវេទនា ក៏ជាទុក្ខដែលអត់ទ្រាំបានដោយលំបាកយ៉ាងពិតប្រាកដ ទើបមានឈ្មោះថា ទុក្ខទុក្ខ ។

- **បដិច្ឆន្នទុក្ខ** ទុក្ខបិទបាំង គឺទុក្ខដែលអ្នកដទៃ ទទួលដឹងមិនបានដូចជា ឈឺក្បាល ឈឺធ្មេញ ក្ដៅខ្លួន សេចក្ដីលំបាកកាយ លំបាកចិត្ត សេចក្ដីទោមនស្សតូចចិត្ត ( ក្នុងកន្លែងខ្លះហៅថា **អបាកដទុក្ខ** គឺទុក្ខមិនប្រាកដច្បាស់ ) ។

-**អបដិច្ឆន្នទុក្ខ** ទុក្ខមិនបិទបាំង ដូចជាសេចក្ដីទុក្ខផ្លូវកាយដែលកើតអំពីកាំបិតមុត លំពែងមុត បន្លាមុត បួស ( ក្នុងកន្លែងខ្លះហៅថា **បាកដទុក្ខ** គឺទុក្ខប្រាកដច្បាស់ ) ។

- **និប្បរិយាយទុក្ខ** ទុក្ខដោយត្រង់ គឺទុក្ខវេទនា ។

- **បរិយាយទុក្ខ** ទុកដោយអម គឺជាតិទុក្ខជាដើម ក្រៅអំពីទុក្ខវេទនា សូម្បីទុក្ខទាំងនេះនឹងមិនមែនសភាពដែលអត់ធន់ដោយលំបាក ក៏ជាហេតុកើតរបស់សេចក្ដីទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្តក្នុងឱកាសតទៅ ។

ជាតិទុក្ខ ជរាទុក្ខ និងមរណទុក្ខ ចាត់ជាទុក្ខសច្ច ព្រោះជាទុក្ខដោយអម សូម្បីសេចក្ដីសោយសោក សេចក្ដីទួញយំ សេចក្ដីទុក្ខកាយ សេចក្ដីទុក្ខចិត្ត និងសេចក្ដីចង្អៀតចង្អល់ក្នុងចិត្ត ក៏ចាត់ជាទុក្ខសច្ចដូចគ្នា ព្រោះជាទុក្ខដោយត្រង់ ពិតហើយ ជាតិជាដើមកើតអំពីឧបាទានក្ខន្ធ ៥ គឺ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ បើមិនមានឧបាទានក្ខន្ធហើយ ការកើតជាដើមក៏មានមិនបាន ដូចនោះពោលដោយសង្ខេប ឧបាទានក្ខន្ធ ៥ ដែលប្រាកដក្នុងខណៈឃើញបានឮជាដើម ទើបឈ្មោះថា ទុក្ខ ព្រោះជាទុក្ខប្រចាំសង្ខារ ដែលប្រែប្រួល និងជាទីតាំងនៃជាតិទុក្ខជាដើម សមពិតដូចព្រះពុទ្ធវចនថា

កតមញ្ច ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។ ជាតិបិ ទុក្ខា ។ ជរាបិ ទុក្ខា ។ មរណម្បិ ទុក្ខំ ។ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា ។ អប្បិយេហិ សម្បយោគោ ទុក្ខោ ។ បិយេហិ វិប្បយោគោ ទុក្ខោ ។ យម្បិច្ឆំ ន លភតិ ។ តម្បិ ទុក្ខំ ។ សង្ខិត្តេន បញ្ចុបា-ទានក្ខន្ធា ទុក្ខា[១១៨] ។

"ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខអរិយសច្ចតើដូចម្ដេច ។ ជាតិគឺកំណើតដែលកើតជាដំបូងក៏ជាទុក្ខ ។ ជរាគឺចាស់គ្រាំគ្រា ក៏ជាទុក្ខ ។ មរណៈ គឺសេចក្ដីស្លាប់ ក៏ជាទុក្ខ ។ សោកៈ គឺសេចក្ដីស្ដាយស្រណោះ បរិទេវៈ គឺសេចក្ដីខ្សឹកខ្សួល ទុក្ខ គឺសេចក្ដីលំបាកកាយ ទោមនស្ស គឺសេចក្ដីអាក់អន់តូចចិត្ត ឧបាយាសៈ គឺសេចក្ដីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ ។ អប្បិយេហិសម្បយោគ គឺដំណើរជួបប្រសប់ដោយសត្វនឹងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ក៏ជាទុក្ខ ។ បិយេហិវិប្បយោគ គឺសេចក្ដីព្រាត់ប្រាសចាកសត្វនឹងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ក៏ជាទុក្ខ ។ យម្បិច្ឆំ នលភតិ តម្បិ គឺបុគ្គលកាលចង់បាននូវរបស់ណា មិនបាន ឯការមិនបានរបស់នោះ ក៏ជាទុក្ខ ។ បើដោយសេចក្ដីបំព្រួញ ឧបាទានក្ខន្ធទាំង ៥ មានរូបក្ខន្ធជាដើម ក៏ជាទុក្ខ" ។

សមុទយសច្ច គឺតណ្ហាដែលភ្លើតភ្លើនត្រេកអរ ឧបាទានក្ខន្ធ ៥ ថា ជាវត្ថុដែលល្អស្អាត ជាទីពេញចិត្ត អ្នកដែលមានតណ្ហារមែងធ្វើកម្មល្អ ឬកម្មអាក្រក់ដោយសេចក្ដីត្រូវការ នឹងឲ្យខ្លួនជា

សុខក្នុងបច្ចុប្បន្ន ឬអនាគត កម្មដែលបុគ្គលធ្វើទុកក្នុងមួយភពៗ ទើបមានច្រើនសន្ធឹកសន្ធាប់រាប់មិនអស់គ្រប់យ៉ាង កម្មដែលនឹងឲ្យផលបដិសន្ធិនោះ ជាកម្មយ៉ាងណានិមួយ ដែលមានកម្លាំង ដែលធ្វើពេលជិតស្លាប់ ឬសន្សំទុកជានិច្ច រមែងមកប្រាកដឲ្យជាអារម្មណ៍ក្នុងពេលជិតស្លាប់ ឬអារម្មណ៍ដែលជាឧបករណ៍របស់កម្មនោះៗ ដូចជាផ្កាឈើបូជាព្រះ ឬអារម្មណ៍ដែលជាទីតាំងរបស់ភពថ្មី ដូចជាវិមាន រមែងមកប្រាកដដូចសុបិនឃើញអ្នកដែលតោងយកអារម្មណ៍ទាំង ៣ គឺ កម្ម កម្មនិមិត្ត ឬគតិនិមិត្ត យ៉ាងណានិមួយទុកហើយ រមែងទៅកើតក្នុងភពនោះៗ ក្រោយអំពីអស់ជីវិតហើយ ដោយមានឧបាទានក្ខន្ធ ៥ ឧប្បត្តិឡើងក្នុងភពថ្មី ។

ការកើតឡើងជាខាងដើមនៃឧបាទានក្ខន្ធ ចាត់ជាជាតិទុក្ខ សភាពចាស់របស់ខន្ធជាជរាទុក្ខ សេចក្ដីរលត់របស់ខន្ធក្នុងភពនោះៗ ជាមរណៈទុក្ខ សេចក្ដីសោកនិងការទួញយំជាដើម ដែលកើតតាមហេតុបច្ច័យក្នុងភពនោះ ក៏ជាទុក្ខដូចគ្នា ដូច្នោះ ឧបាទានក្ខន្ធដែលប្រាកដយ៉ាងបន្តបន្ទាប់ក្នុងខណៈឃើញបានឮ ។ល។ ទើបជាទុក្ខសច្ច

ទុក្ខសច្ចកើតអំពីកម្ម ចំណែកកម្មកើតអំពីតណ្ហា អ្នកដែលលះតណ្ហាបានហើយ រមែងមិនធ្វើកម្មថ្មី សូម្បីកម្មចាស់របស់លោកក៏មិនឲ្យផលជាបដិសន្ធិក្នុងភពថ្មី ព្រោះឫសគល់ គឺ តណ្ហាបានកាត់ផ្តាច់ហើយ នឹងឃើញបានថា មូលហេតុនៃឧបាទានក្ខន្ធ ក៏គឺតណ្ហានោះឯង សមពិតដូចព្រះពុទ្ធវចនថា

**កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា បោនោភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី ។ សេយ្យថីទំ ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា**[១១៩] ។

"ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខអរិយសច្ច ។ តណ្ហាណា ជាធម្មជាតិនាំសត្វកើតទៀត ប្រកបដោយតម្រេករីករាយ ជាធម្មជាតិនាំសត្វឲ្យត្រេកត្រអាលក្នុងភពនោះ ៗ ឬក្នុងអារម្មណ៍នោះ ៗ តណ្ហានោះ គឺអ្វីខ្លះ គឺ **កាមតណ្ហា** ( សេចក្តីប្រាថ្នាក្នុងកាម ) ១ **ភវតណ្ហា** ( សេចក្តីប្រាថ្នាក្នុងរូបភពនិងអរូបភព ) ១ **វិភវតណ្ហា** ( សេចក្តីប្រាថ្នាក្នុងភពសូន្យ ) ១" ។

[ ព្រះត្រៃបិដកច្បាប់ថៃនិងខ្មែរមានរូបថា បោនោព្ភវិកា តែច្បាប់

សន្ធិឬ: និងច្បាប់ឆ្លងសន្ធិតិមានរូបជា បោនោភរិកា កាលប្រៀបធៀបជាមួយភាសាសំស្ក្រឹត ក៏បានសេចក្តីថា ស័ព្ទថា បុទ្រ ក្នុងសំស្ក្រឹតជា រ ការន្ត ចំណែកភាសាបាលីជា បុទ កាលផ្សំ បុទ ជាមួយ ករ សមាស ក៏មានរូបដែលតម្រូតព្យញ្ជនសំយោគថា បុទក្ករ ព្រោះសំស្ក្រឹតមានរូបសំយោគថា បុទ្រ តែកាលផ្លាស់ អរ ក្នុង បុទ្រ ជា ឱ បានរូបថា បុនោ, បោនោ ក៏មិនគួរមានរូបសំយោគ ជា បោនោករ, បោនោក្ករិកា ក្នុងទីនេះប្រើជា បោនោភរិកា តាមច្បាប់សន្ធិឬ: និងច្បាប់ឆ្លងសន្ធិតិ] ។

និរោធសច្ច គឺ សេចក្តីរលត់របស់ទុក្ខសច្ចដែលជារូបនាមទាំងអស់ កាលអ្នកបដិបត្តិសម្រេចមគ្គញាណទទួលយកព្រះនិព្វានជាអារម្មណ៍ហើយ រមែងឃើញច្បាស់ថា រូបនាមទាំងអស់ជាទុក្ខ និងប្រាសចាកតណ្ហាដែលភ្លឺតភ្លើនត្រេកអរក្នុងរូបនាម ដោយហេតុនេះ ឧបាទានក្ខន្ធ ៥ ដែលគួរនឹងកើតឡើង រមែងរលត់ទៅមិនកើតទៀត ចាត់ជាការរលត់ដែលមិនមានសេសសល់ ដែលហៅថា អនុបាទិសេសនិព្វាន ឬ អនុប្បាទនិរោធ គឺ ការរលត់មិនកើតទៀត ដូច្នោះ ព្រះនិព្វានដែលជាអារម្មណ៍របស់មគ្គញាណ ទើបឈ្មោះថា និរោធសច្ច សមពិតដូចព្រះពុទ្ធវចនថា

កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ[១២០] ។

“ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា ទុក្ខនិរោធអរិយសច្ច។ ការអស់ទៅទីងការរលត់ទៅដោយមិនមានសេសសល់ ការលះបង់ ការរលាស់ចោល ការជម្រះចោល ការមិនមានអាល័យចំពោះតណ្ហានោះឯង (ហៅថា ទុក្ខនិរោធអរិយសច្ច)” ។

ច្បាប់ថៃមានរូបថា ទុក្ខសមុទយោ អរិយសច្ចំ និង ទុក្ខនិរោធោ អរិយសច្ចំ តែច្បាប់ឆដ្ឋសង្គីតិមានរូបថា ទុក្ខសមុទយំ អរិយសច្ចំ និង ទុក្ខនិរោធំ អរិយសច្ចំ ដោយ ទុក្ខសមុទយំ និង ទុក្ខនិរោធំ មានរូបជានបុំសកលិង្គ យោងទៅតាម អរិយសច្ចំ បាឋៈដែលជានបុំសកលិង្គនេះ ស្របជាមួយអដ្ឋកថារបស់បដិសម្ភិទាមគ្គថា

ឥទំ ទុក្ខំ អរិយសច្ចន្តិអាទីសុ ទុក្ខសមុទយោ ទុក្ខនិរោធោតិ វត្តព្វេ ទុក្ខសមុទយំ ទុក្ខនិរោធន្តិ សង្គីរំបហរសោ កតោ[១២១] ។

“ក្នុងពាក្យថា ឥទំ ទុក្ខំ អរិយសច្ចំ ជាដើម គួរពោលថា ទុក្ខសមុទយោ ទុក្ខនិរោធោ តែបានផ្លាស់លិង្គថា ទុក្ខសមុទយំ ទុក្ខនិរោធំ” ។

សេចក្ដីខាងដើមសម្ដែងថា ពាក្យថា ទុក្ខសមុទយំ ទុក្ខនិរោធំ ជាលិង្គវិបល្លាសដែលពោលជារូបនបុំសកលិង្គ ដូចគួរពោលជារូបបុំលិង្គថា ទុក្ខសមុទយោ ទុក្ខនិរោធោ យ៉ាងណាក៏ដោយ គម្ពីរវិសុទ្ធិមគ្គមហាដីកាពោលដល់រូបថា ទុក្ខសមុទយោ និង ទុក្ខនិរោធោ ដោយឃើញថា សូម្បីលិង្គទីងផ្សេងគ្នាក៏មិនខុសគោលភាសា ដូចពាក្យថា ឧប្បាទោ ភយំ ( ការកើតឡើងនៃសង្ខារគួរខ្លាច ) ដូចសាធកៈក្នុងគម្ពីរនោះថា

សតិបិ ទ្វិន្នំ បទានំ សមានាធិករណភាវេ លិង្គភេទោ គហិតោ ។ យថា ទុក្ខសមុទយោ អរិយសច្ចន្តិ[១២២] ។

"កាលមានសេចក្ដីស្មើគ្នានៃបទទាំងពីរ លិង្គរមែងផ្សេងគ្នាបាន ដូចជា ទុក្ខសមុទយោ អរិយសច្ចំ " ។

ដោយហេតុដូចដែលពោល ក្នុងទីនេះទើបប្រើតាមច្បាប់ថៃ រូបនេះនៅស្របជាមួយពាក្យថា ទុក្ខនិរោធគាមិនី បដិបទា ដែលជាឥត្ថីលិង្គទៀតផង] ។

មគ្គសច្ច គឺ អរិយមគ្គមានអង្គ ៨ ដែលមានសម្មាទិដ្ឋិជាដើម ដែលឃើញព្រះនិព្វានដោយប្រចក្ស សមពិតដូចព្រះពុទ្ធវចនថា

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថិទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវា-យាមោ សម្មាសតិ សម្មាសមាធិ[១២៣] ។

"ម្នាលភិក្ខុទាំងឡាយ **អរិសច្ច** គឺ មគ្គដែលជាផ្លូវលត់ទុក្ខបានដល់ អរិយមគ្គមានអង្គ ៨ ប្រការនោះឯង ពោលគឺ សេចក្តីយល់ឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ ការនិយាយពាក្យត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ សេចក្តីនឹករលឹកត្រូវ ១ និងការតម្កល់ចិត្តឲ្យនឹងត្រូវ ១" ។

បុថុជ្ជនទូទៅគួរតាមដឹងអរិយសច្ច ២យ៉ាងគឺ **ទុក្ខសច្ច** ដែលជារូបនាម ដែលកើតរលត់ជានិច្ច និង **ទុក្ខសមុទយសច្ច** ដែលជាតណ្ហាដែលភ្ញើតភ្ញើនក្នុងអារម្មណ៍ ដែលមកប្រាកដផ្លូវទ្វារទាំង ៦ ចំណែក **និរោធសច្ច** និង **មគ្គសច្ច** មិនមែនអារម្មណ៍កម្មដ្ឋានយ៉ាងពិតប្រាកដ អ្នកបដិបត្តិដែលបង្អោនចិត្តទៅក្នុងសច្ចៈទាំង ២នេះ ថាជាសច្ចៈដែលល្អលើស មិនមែនអារម្មណ៍របស់កិលេស ក៏បាត់ថាជាការតាមដឹងដោយបរិយាយ ដូចគម្ពីរអដ្ឋកថាពោលថា

តត្ថ បរិមានិ ទ្វេ សច្ចានិ វដ្តំ បច្ឆិមានិ វិវដ្តំ ។ តេសុ ភិក្ខុនោ វដ្តេ កម្មដ្ឋានាភិនិវេសោ ហោតិ ។ វិវដ្តេ នត្ថិ អភិនិវេសោ ។ បុរិមានិ ទ្វេ សច្ចានិ "បញ្ចក្ខន្ធា ទុក្ខំ, តណ្ហា សមុទយោតិ ឯវំ សង្ខេបេន ច កតមេ បញ្ចក្ខន្ធា ។ រូបក្ខន្ធោតិអាទិនា នយេន វិត្ថារេន ច អាចរិយស្ស សន្តិកេ ឧគ្គណ្ហិត្វា វាចាយ បុនប្បុនំ បរិវត្តេន្តោ យោគាវចរោ កម្មំ ករោតិ ។ ឥតរេសុ បន ទ្វីសុ សច្ចេសុ "និរោធសច្ចំ ឥដ្ឋំ កន្តំ មនាបំ, មគ្គសច្ចំ ឥដ្ឋំ កន្តំ មនាបន្តិ ឯវំ សវនេនេវ កម្មំ ករោតិ ។ សោ ឯវំ ករោន្តោ ចត្តារិ សច្ចានិ ឯកប្បដិវេធេនេវ បដិវិជ្ឈតិ ។ ឯកាភិសមយេន អភិសមេតិ ។ ទុក្ខំ បរិញ្ញាបដិវេធេនេវ បដិវិជ្ឈតិ សមុទយំ បហានប្បដិវេធេនេវ បដិវិជ្ឈតិ ។ និរោធំ សច្ឆិកិរិយាបដិវេធេនេវ បដិវិជ្ឈតិ ។ មគ្គំ ភាវនាបដិវេធេនេវ បដិវិជ្ឈតិ ។ ទុក្ខំ បរិញ្ញាភិសមយេន អភិសមេតិ ។ សមុទយំ បហានាភិសមយេន ។ និរោធំ សច្ឆិកិរិយាភិសមយេន ។ មគ្គំ ភាវនាភិសមយេន អភិសមេតិ ។ ឯវមស្ស បុព្វភាគេ ទ្វីសុ សច្ចេសុ ឧគ្គហបរិបុច្ឆា-

សវនធារណសម្មសនប្បដិវេធោ ហោតិ ។ ទ្វីសុ បន សវនប្បដិ-វេធោយេវ ។ អបរកោគេ តីសុ កិច្ចតោ បដិវេធោ ហោតិ ។ និរោធេ អារម្មណប្បដិវេធោ[១២៤] ។

“ក្នុងបណ្តាសច្ចៈពួកនោះ សច្ចៈ២យ៉ាងដំបូងឈ្មោះថា វដ្តសច្ច ( សច្ចៈដែលនៅក្នុងវដ្តៈ ) សច្ចៈ ២ យ៉ាងខាងក្រោយ ឈ្មោះថា វិវដ្តសច្ច ( ប្រែថា សច្ចៈដែលផុតអំពីវដ្តៈ ) ក្នុងសច្ចៈ ២ យ៉ាង នោះ ការចំរើនកម្មដ្ឋាន រមែងមានដល់ភិក្ខុក្នុងវដ្តសច្ច មិនមាន ការចំរើនកម្មដ្ឋាន ក្នុងវិវដ្តសច្ច អ្នកបដិបត្តិបានដឹងសច្ចៈ ២ យ៉ាង ដំបូងដោយសង្ខេបថា ខន្ធ៥ ជាទុក្ខសច្ច តណ្ហាជាសមុទយសច្ច ឬ ដោយពិស្តារមានន័យថា ខន្ធ ៥គឺអ្វី គឺរូបក្ខន្ធជាដើម ការស្វាធ្យាយ ដោយវាចារឿយៗ រមែងជាការបំពេញកម្មដ្ឋាន ចំណែកក្នុងសច្ចៈ ទាំង ២ដ៏សេស រមែងបំពេញកម្មដ្ឋានដោយការស្តាប់យ៉ាងនេះថា និរោធសច្ច ជាសច្ចៈដែលល្អលើសគួរប្រាថ្នាពេញចិត្ត មគ្គសច្ច ជា សច្ចៈដែលល្អលើសគួរប្រាថ្នាពេញចិត្ត ។

អ្នកចំរើនកម្មដ្ឋានយ៉ាងនោះ រមែងបន្ទុះសច្ចៈ ៤ ដោយការ

ចាក់ធ្លុះ រហូតគ្រប់ពេលដូចគ្នា រមែងឃើញច្បាស់ដោយការដឹងមួយគ្រាដូចគ្នាពោលគឺ រមែងបន្ទុះទុក្ខសច្ចដោយការចាក់ធ្លុះរហូត គឺការកំណត់ដឹង រមែងបន្ទុះ សមុទយសច្ច ដោយការចាក់ធ្លុះរហូត គឺការលះបង់ រមែងបន្ទុះ និរោធសច្ច ដោយការចាក់ធ្លុះរហូត គឺការធ្វើឲ្យជាក់ច្បាស់ រមែងបន្ទុះមគ្គដោយការចាក់ធ្លុះរហូត គឺការចំរើន រមែងឃើញ ទុក្ខសច្ច ដោយការដឹងច្បាស់ គឺការកំណត់ដឹង រមែងឃើញ សមុទយសច្ច ដោយការដឹងច្បាស់ គឺ ការលះបង់ រមែងឃើញនិរោធសច្ច ដោយការដឹងច្បាស់ គឺការធ្វើឲ្យជាក់ច្បាស់ រមែងឃើញ មគ្គសច្ច ដោយការដឹងច្បាស់ គឺការចំរើន ។

ដោយប្រការដូច្នេះ ក្នុងគ្រាដំបូងការចាក់ធ្លុះរហូត គឺការរៀនសាកសួរ ស្តាប់ ចាំទុក និងកំណត់ដឹង រមែងមានដល់លោកក្នុងសច្ចៈ ២ យ៉ាង [ដំបូង] ចំណែកការចាក់ធ្លុះរហូត គឺការស្តាប់ រមែងមានក្នុងសច្ចៈ ២ យ៉ាងខាងក្រោយ តមកការចាក់ធ្លុះដោយកិច្ចរមែងមានក្នុងសច្ចៈ ៣ យ៉ាង ចំណែកការចាក់ធ្លុះរហូតអារម្មណ៍ រមែងមិនមានក្នុង និរោធសច្ច" ។

ពិតហើយ មគ្គញាណជាសភាវៈទទួលដឹង និរោធសច្ច ជាអារម្មណ៍ ចំណែកសច្ចៈ ៣យ៉ាងដ៏សេស អ្នកបដិបត្តិ រមែងទទួលដឹង ដោយកិច្ច គឺ ការកំណត់ដឹង ការលះ និងការធ្វើឲ្យជាក់ច្បាស់ ក្រៅពីនេះ ការរៀន សាកសួរ ស្តាប់និងចងចាំទុក ចាត់ជាការយល់ ក្នុងលំដាប់បរិយត្តិប៉ុណ្ណោះ ការយល់ក្នុងលំដាប់វិបស្សនាដែល ត្រឹមត្រូវ ជាការកំណត់ដឹងប៉ុណ្ណោះ នៅក្នុងទីនេះ សំដៅដល់ វិបស្សនាញាណទាំងអស់ ។

ម្យ៉ាងទៀត បុថុជ្ជនមិនអាចទទួលយកលោកុត្តរធម៌ គឺមគ្គផល និងនិព្វានមកជាអារម្មណ៍ដោយប្រចក្សបានទេ ព្រោះខ្លួននៅមិនទាន់ បានបន្ទុះ បុថុជ្ជនទើបកំណត់ដឹង និរោធសច្ច និង មគ្គសច្ចមិនបាន ចំណែកព្រះអរិយបុគ្គល សូម្បីបន្ទុះលោកុត្តរធម៌ហើយ ក៏មិន កំណត់ដឹងនិរោធសច្ច និងមគ្គសច្ច ព្រោះមិនមានប្រយោជន៍ក្នុងការ លះកិលេសដោយការកំណត់ដឹងយ៉ាងនោះ ។

ការបង្អោនចិត្តទៅក្នុងនិរោធសច្ច និងមគ្គសច្ចថា ជាសច្ចៈ ដែលល្អលើសគឺ ការតាំងចិត្តក្នុងការបន្ទុះនិរោធសច្ច និងមគ្គសច្ច

នោះ ដោយការបដិបត្តិធម៌ សមដូចសេចក្ដីប្រាថ្នាថា អទ្ធា ឥមាយ បដិបទាយ ជរាមរណម្ហា បរិមុច្ចិស្សាមិ ( ខ្ញុំរមែងរួចផុតអំពីការចាស់និងការស្លាប់ដោយបដិបទានេះពិតប្រាកដ ) មិនមែនការពេញចិត្តហើយអប់រំរឿយ ៗ ដោយអាស្រ័យតណ្ហានិងទិដ្ឋិ ដូចគម្ពីរដីកាអធិប្បាយថា

វដ្ដេ កម្មដ្ឋានាភិនិវេសោ សរូបតោ បរិគ្គហសព្ភាវតោ ។ វិវដ្ដេ នត្ថិ អវិសយត្តា ។ វិសយត្តេបិ ច បយោជនាភាវតោ ។បេ។ ឥដ្ឋំ កន្តន្តិ និរោធមគ្គេសុ និន្នភាវំ ទស្សេតិ ។ ន អភិនន្ទនំ ។ តន្និន្នភាវោយេវ ច តត្ថ កម្មករណំ ទដ្ឋព្វំ[១២៥] ។

"ការចំរើនកម្មដ្ឋាន រមែងមិនមានក្នុងសច្ចៈ ព្រោះអាចកំណត់ដឹងបានដោយសភាវៈ មិនមានការចំរើនកម្មដ្ឋានក្នុងវិវដ្ដសច្ច ព្រោះមិនមែនជាអារម្មណ៍របស់បុថុជ្ជន និងសូម្បីជាអារម្មណ៍របស់ព្រះអរិយបុគ្គល ក៏មិនមានប្រយោជន៍ក្នុងការកំណត់ដឹង ។បេ។ ពាក្យថា ឥដ្ឋំ កន្តំ ( សច្ចៈដែលល្អលើសគួរប្រាថ្នាទីពេញចិត្ត ) សម្ដែងការបង្អោនចិត្តទៅក្នុងនិរោធសច្ច និងមគ្គសច្ច មិនបានសម្ដែង

សេចក្តីពេញចិត្តទេ គប្បីជ្រាបថា ការបង្អោនសច្ចៈទាំងនោះ ក៏គឺការចំរើនកម្មដ្ឋានក្នុងសច្ចៈដូចដែលពោល" ។

អ្នកបដិបត្តិដែលតាមដឹងរូបនាមបច្ចុប្បន្នតាមសភាវពិត រមែងដឹងច្បាស់លក្ខណៈ កិច្ច ផល និងអាការប្រាកដរបស់រូបនាមនោះៗ ព្រមទាំងសភាវៈប្រែប្រួលរបស់រូបនាម សភាវៈបង្អោនទៅក្នុងអារម្មណ៍របស់នាមធម៌ និងសភាវៈជាទុក្ខដែលត្រូវបៀតបៀនដោយការកើតរលត់ កាលបន្ទុះវិបស្សនាញាណជាន់ខ្ពស់ រមែងឃើញច្បាស់សភាវធម៌បច្ចុប្បន្ន ដែលកំណត់ដឹងទាំងអស់នោះ មានសភាពកើតរលត់រឿយ ៗ មិនមានអារម្មណ៍ ដែលល្អស្អាត គួរជាទីពេញចិត្ត តែយ៉ាងណា ការដឹងច្បាស់យ៉ាងនេះ គឺការទទួលដឹងទុក្ខសច្ចតាមគោលសច្ចៈទេសនា ដូចសេចក្តីថា

**ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ**[១២៦] ។

"ភិក្ខុក្នុងសាសនានេះ រមែងដឹងច្បាស់តាមសេចក្តីពិតថា ឧបាទានក្ខន្ធ ៥ នេះជាទុក្ខ" ។

**បវេត្តា តណ្ហំ តេភូមកធម្មេ ឥទំ ទុក្ខន្តិ យថាសភាវតោ បជានាតិ**[១២៧] ។

"ភិក្ខុរមែងដឹងច្បាស់ធម៌ដែលមាននៅក្នុងភូមិ ៣ វៀរលែងតណ្ហាចេញតាមសមគួរដល់សភាវៈថា ឧបាទានក្ខន្ធ៥នេះ ជាទុក្ខ" ។

**យថាសភាវតោតិ អវិបរីតសភាវតោ ពាធនលក្ខណតោ ។ យោ យោ វា សភាវោ យថាសភាវោ ។ តតោ រូបនាទិកក្ខឡត្តាទិសភាវតោ**[១២៨] ។

"ពាក្យថា **យថាសភាវតោ** ( តាមសមគួរដល់សភាវៈ ) មានន័យថា តាមសភាវៈដែលមិនប្រែប្រួល គឺ តាមលក្ខណៈបៀតបៀន ។ ន័យម្យ៉ាងទៀត សភាវៈដែលកើតឡើងគ្រប់ៗយ៉ាងឈ្មោះថា **យថាសភាវៈ** ភិក្ខុរមែងដឹងច្បាស់តាមសភាវៈគ្រប់ ៗ យ៉ាងដែលមានការប្រែប្រួល និងការស្ថិរស្ថេជាដើម" ។

[តាមន័យដំបូងពាក្យថា **យថាសភាវៈ** មានរូបវិគ្គហៈថា **សភាវស អនុរូបំ = យថាសភាវំ** ( យថាសភាវៈ គឺសមគួរ ដល់សភាវៈ ) ន័យក្រោយមានរូបវិគ្គហថា **យោ យោ សភាវោ = យថាសភាវំ**

( យថាសភាវៈ គឺ សភាវៈគ្រប់ៗ យ៉ាង )] ។

ធម៌ដែលមានក្នុងភូមិ ៣ ដែលហៅថា តេភូមិកធម៌ គឺ ធម៌ដែលជាកាមាវចរ រូបាវចរនិងអរូបាវចរដែលកើតខាងក្នុងពួកសត្វ ចំណែកធម៌ខាងក្រៅ ( **អនិន្ទ្រិយពទ្ធរូប** ) បានដល់អាហារ ខោអាវ ជាដើមមិនចាត់ថា ជា**ទុក្ខសច្ច** ព្រោះមិនបានកើតអំពីតណ្ហាដែលជា **សមុទយសច្ច** និងមិនអាចរម្ងាប់ដោយមគ្គសច្ច ពិតហើយ ក្នុងខណៈខ្លះ អ្នកបដិបត្តិអាចតាមដឹង អារម្មណ៍ខាងក្រៅដែលមកប្រាកដឯងបានខ្លះ កាលទទួលដឹងអារម្មណ៍ខាងក្នុងយ៉ាងជាក់ច្បាស់ហើយ រឿងនេះ ចាត់ជាខលើកលែងវិសេសប៉ុណ្ណោះ អារម្មណ៍ខាងក្រៅទាំងអស់ទើបមិនមែន **ទុក្ខសច្ច** ដែលគួរកំណត់ដឹង ។

[អនិន្ទ្រិយពទ្ធរូប គឺរូបដែលមិនមានចិត្តគ្រប់គ្រងចាត់ជា **សច្ចវិមុត្តិ** ( រួចផុតអំពីសច្ចៈទាំង ៤ )] ។

អរិយសច្ច ៤ ដែលជាសេចក្តីពិតរបស់ជីវិតនេះ ប្រាកដនៅក្នុងកាយដែលប្រវែងមួយព្យាម កម្រាស់មួយចំអាម ទទឹងមួយហត្ថ ព្រោះ**ទុក្ខសច្ច** ដែលកើតអំពីតណ្ហា បានកើតឡើងខាងក្នុងរាង

កាយនេះ សមុទយសច្ច ដែលជាសេចក្ដីរលត់ទុក្ខ និងមគ្គសច្ច ដែលជាផ្លូវរលត់ទុក្ខ ក៏កើតខាងក្នុងរាងកាយនេះដូចគ្នា ដូច្នោះ ការតាមដឹងអរិយសច្ចខាងក្នុងរាងកាយ ទើបជាគោលសំខាន់ ទើង ឃើញបានថា ព្រះបរមសាស្ដាត្រាស់ការតាមដឹងកងរូបខាងក្នុង ទុកមុនកងរូបខាងក្រៅ ក្នុងមហាសតិប្បដ្ឋានសូត្រ[១២៩] ដើម្បីសម្ដែង សេចក្ដីសំខាន់របស់កងរូបខាងក្នុង និងវេទនាខាងក្នុងជាដើម ក្រៅ អំពីនេះ នៅមានសាធកៈដទៃថា

យត្ថ ខោ អាវុសោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន ចវតិ ន ឧប្បជ្ជតិ ។ នាហំ តំ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ ។ ន ខោ បនាហំ អាវុសោ អប្បត្វា លោកស្ស អន្តំ ទុក្ខស្ស អន្តកិរិយំ វទាមិ ។ អបិច ខ្វាហំ អាវុសោ ឥមស្មិំយេវ ព្យាមមត្តេ កឡេវរេ សសញ្ញិម្ហិ សមនកេ លោកញ្ច បញ្ញបេមិ លោកសមុទយញ្ច លោកនិរោធញ្ច លោកនិរោធគាមិនិញ្ច បដិបទំ[១៣០] ។

“ម្នាលអាវុសោ សត្វរមែងមិនកើត រមែងមិនចាស់ រមែង

មិនស្លាប់ រមែងមិនច្យុត រមែងមិនឧប្បត្តិក្នុងទីណា យើងពោល ទីនោះថា ទីបំផុតនៃលោកដែលគួរដឹង គួរឃើញ គួរដល់ដោយ ការទៅ និងយើងរមែងមិនពោលការធ្វើនូវទីបំផុតនៃទុក្ខ ព្រោះទៅ មិនដល់ទីបំផុតនៃលោក តែយើងរមែងបញ្ញត្តិលោក ហេតុកើត របស់លោក សេចក្ដីរលត់របស់លោក និងបដិបទាឲ្យដល់ការ រលត់នៃលោក ក្នុងអត្តភាពដែលមានប្រមាណមួយព្យាម មាន សញ្ញា និងមានចិត្តនេះប៉ុណ្ណោះ" ។

លោកន្តិ ទុក្ខសច្ចំ ។ លោកសមុទយន្តិ សមុទយសច្ចំ ។ លោកនិរោធន្តិ និរោធសច្ចំ ។ បដិបទន្តិ មគ្គសច្ចំ ។ ឥតិ នាហំ អាវុសោ ឥមានិ ចត្តារិ សច្ចានិ តិណកដ្ឋាទិសុ បញ្ញបេមិ ។ ឥមស្មឹ បន ចាតុមហាភូមិកេ កាយស្មឹយេវ បញ្ញបេមីតិ ទស្សេតិ[១៣១] ។

"ពាក្យថា លោកំ ( លោក ) គឺ ទុក្ខសច្ច ។

ពាក្យថា លោកសមុទយំ ( ហេតុកើតនៃលោក ) គឺ សមុទយសច្ច ។

ពាក្យថា លោកនិរោធំ ( ការរលត់នៃលោក )គឺ និរោធសច្ច ។

ពាក្យថា **បដិបទំ** ( បដិបទា ) គឺ មគ្គសច្ច ។

ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់សម្ដែងថា តថាគត មិនបានបញ្ញត្តិសច្ចៈ ៤ ពួកនេះទុកក្នុងអារម្មណ៍ខាងក្រៅមានស្មៅ ឬអុសជាដើមទេ តែតថាគតបញ្ញត្តិទុកក្នុងអត្តភាពដែលកើតឡើង ដោយអាស្រ័យមហាភូតរូប ៤ នេះប៉ុណ្ណោះ ។

សសន្តតិបរិយាបន្នានំ ទុក្ខសមុទយានំ អប្បវត្តិភាវេន បរិគ្គយ្ហមានោ និរោធោបិ សសន្តតិបរិយាបន្នោ វិយ ហោតីតិ កត្វា វុត្តំ អត្តនោ វា ចត្តារិ សច្ចានីតិ ។ បរស្ស វាតិ ឯត្ថាបិ ឯសេវ នយោ[១៣២] ។

"សូម្បីនិរោធសច្ច ដែលបុគ្គលកំណត់ដឹងដោយការមិនកើតឡើងនៃទុក្ខសច្ច និងសមុទយសច្ចដែលប្រាកដនៅក្នុងក្រសែចិត្តរបស់ខ្លួន ក៏ដូចប្រាកដនៅក្នុងក្រសែចិត្តរបស់ខ្លួន ដូច្នោះ លោកទើបពោលទុកក្នុងគម្ពីរអដ្ឋកថា] ថា អត្តនោ វា ចត្តារិ សច្ចានិ ( សច្ចៈ ៤ របស់ខ្លួន ) សូម្បីពាក្យថា បរស្ស វា ( សច្ចៈ ៤ របស់អ្នកដទៃ ) ក៏មានន័យដូចគ្នានេះ" ។

សេចក្តីពិត **និរោធសច្ច** សូម្បីជាធម៌ខាងក្រៅតាមដែលពោលទុកក្នុងព្រះអភិធម្មថា ជា**ពហិទ្ធធម៌** ( ធម៌ខាងក្រៅ )[១៣៣] ក៏ចាត់ថាជាធម៌ខាងក្នុងតាមបរិយាយ ដែលពោលមកនេះ ព្រោះដូចជាការប្រាកដនៅក្នុងក្រសែចិត្តរបស់ខ្លួន ។

សរុបសេចក្តីថា អរិយសច្ច ៤ ជាធម្មជាតិដែលប្រាកដខាងក្នុងក្រសែចិត្តរបស់ខ្លួន ដោយការកំណត់ដឹងទុក្ខសច្ច សមុទយសច្ច ការធ្វើនិរោធសច្ចឲ្យជាក់ច្បាស់ និងចំរើនមគ្គធ្វើឲ្យកើតឡើងខាងក្នុងអត្តភាពដែលប្រវែងមួយព្យាម កម្រាស់មួយចំអាម ទទឹងមួយហត្ថនេះ មិនប្រាកដក្នុងក្រសែចិត្តរបស់បុគ្គលដទៃ ។

អ្នកដែលចំរើនសតិតាមដឹងរូបនាមបច្ចុប្បន្ន កាលកើតការភ្លើតភ្លើនត្រេកអរក្នុងវត្ថុដែលជួបប្រសប់ រមែងកំណត់ដឹងទាន់បាន ការទទួលដឹងយ៉ាងនេះ ជាការដឹងប្រចក្សសមុទយសច្ចក្នុងបច្ចុប្បន្នភព តែសមុទយសច្ចដូចដែលពោលនេះ ជាហេតុឲ្យកើតរូបនាមដែលជាទុក្ខសច្ចក្នុងភពតទៅ ។ មិនមែនជាសមុទយសច្ច ដែលជាហេតុកើតរបស់ភពនេះ សមុទយសច្ច ដែលជាហេតុកើតរបស់ភពនេះ

នោះ ជាវត្ថុដែលពួកសត្វបានធ្វើទុកក្នុងភពមុន ពោលគឺ បុគ្គលត្រូវការនឹងបានទទួលអត្តភាពដែលស្រស់ស្អាត ព្រមដោយសេចក្តីសុខ ទើបបំពេញកុសលទុក គេរមែងទៅកើតក្នុងភពនោះ ដោយផលបុណ្យដែលធ្វើទុក ដែលមានតណ្ហាជាមូលហេតុ តែបុគ្គលមិនអាចដឹងច្បាស់តណ្ហា ដែលរលត់ទៅបានទេ យ៉ាងណាក៏ដោយ តណ្ហាក្នុងអតីតមានសភាពដូចជាមួយតណ្ហាក្នុងបច្ចុប្បន្ន និងកើតឡើងក្នុងក្រសែចិត្តរបស់ខ្លួនដូចគ្នា ទើបពោលបានថា ដូចគ្នាដោយឯកត្តនយ័ គឺ នយ័ដែលមានសភាពតែម្យ៉ាង ដូចការឃើញមហាសមុទ្រឬភ្នំ ចំណែកខ្លះ ក៏អាចពោលថា ឃើញមហាសមុទ្រឬភ្នំដូច្នោះ ការតាមដឹងតណ្ហាក្នុងបច្ចុប្បន្ន ទើបចាត់ថា ជាការតាមដឹងសមុទយសច្ច ។

អ្នកបដិបត្តិដែលឃើញច្បាស់វិបស្សនាញាណតាំងអំពីនាមរូបបរិច្ឆេទញាណជាដើមទៅ អាចអនុមានដឹង តណ្ហាក្នុងអតីតបានទៀតផង គួយ៉ាងដូចជា កាលគេបានឃើញសភាវលក្ខណៈរបស់រូបនាមយ៉ាងជាក់ច្បាស់ហើយ រមែងទទួលដឹងហេតុផលរបស់រូបនាមតពី

នោះពោលគឺ ៖

- ភាវៈការលោភ កើតឡើងអំពីចិត្តដែលគិតចង់ទីនលាភ ។

- រូបដែលមានលក្ខណៈត្រជាក់ កើតឡើងអំពីធាតុភ្លើងដែលមានលក្ខណៈត្រជាក់ ។

- សភាវៈឃើញ កើតឡើងអំពីចក្ខុបសាទ និងរូបារម្មណ៍ ។

- ការកំណត់ដឹងឬការគិតរវើរវាយ កើតឡើងអំពីការមានអារម្មណ៍យ៉ាងណាមួយឲ្យចិត្តទទួលដឹងបាន ។

- ចិត្តដែលកើតឡើងក្នុងពេលខាងក្រោយអំពីចិត្តដែលកើតឡើងមុន ។

អ្នកបដិបត្តិដែលឃើញការជាប់តគ្នា នៃហេតុផលយ៉ាងនេះហើយ រមែងអនុមានដឹងថា រូបនាមក្នុងភពនេះតាំងពីបដិសន្ធិជាដើមមកគួរមានហេតុជាប់តគ្នា ដូចរូបនាមដែលកំណត់ដឹងក្នុងបច្ចុប្បន្នខណៈ គេរមែងអនុមានដឹងដោយសម្មាទិដ្ឋិ ដែលយល់កម្មនិងផលនៃកម្មថា រូបនាមដូចពោលនេះ កើតអំពីកុសលកម្មដែលធ្វើទុក

ក្នុងអតីតនិងអនុមានដឹងតទៅថា កុសលកម្មកើតអំពីតណ្ហាដែលត្រូវការទៅកើតក្នុងភពដែលល្អមានសេចក្តីសុខ ពិតហើយ អ្នកដែលអនុមានដឹងយ៉ាងនេះ មិនបានជញ្ជឹងគិតអស់កាលយូរ គេត្រឹមតែកើតការយល់ដោយអនុមានដឹង ហើយតាមកំណត់ដឹងសភាវធម៌បច្ចុប្បន្នតទៅគ្រប់ពេល មានការជាប់ទាក់ទងជាមួយរឿងនេះ ក្នុងគម្ពីរព្រះអដ្ឋកថាថា

*តស្សេវ ខោ បន ទុក្ខស្ស ជនិកំ សមុដ្ឋាបិកំ បរិមតណ្ហំ អយំ ទុក្ខសមុទយោតិ*[១៣៤] ។

"លោករមែងដឹងច្បាស់តណ្ហា ដែលញ៉ាំងទុក្ខនោះឲ្យកើតមានឡើងតាមសភាវៈថា តណ្ហានេះ ជាហេតុកើតនៃទុក្ខ" ។

ម្យ៉ាងទៀត *ទុក្ខសច្ចៈ* និង *ទុក្ខសមុទយសច្ចៈ* ទាំង ២ នេះ ជាសភាវៈ ដែលកំពុងប្រចក្សដល់ពួកសត្វហើយ តែការទឹងយល់សភាវៈនិងកិច្ចរបស់សច្ចៈទាំងនោះ ដោយបរមត្ថសុទ្ធៗ មិនមានបញ្ញត្តិលាយឡំជាមួយវត្ថុដែលធ្វើបានដោយលំបាក អ្នកដែលចំរើនវិបស្សនាតាមដឹងសច្ចៈទាំងនោះតាមសភាវៈពិត រមែងទឹងយល់ចូល

ចិត្តសភាវៈ និងកិច្ចបានតាមសមគួរ រហូតកាលបន្ទះមគ្គញាណ ហើយទើបយល់បានយ៉ាងពិតប្រាកដ ដោយមិនញាប់ញ័រ ដូចមានសាធកៈថា

ទុក្ខសច្ចម្ហិ ឧប្បត្តិតោ បាកដំ ។ ខាណុកណ្ដកប្បហារាទិសុ អហោ ទុក្ខន្តិ វត្តព្វតម្បិ អាបជ្ជតិ ។ សមុទយម្បិ ខាទិតុកាមតា កុញ្ចិតុកាមតាទិវសេន ឧប្បត្តិតោ បាកដំ ។ លក្ខណប្បដិវេធតោ បន ឧភយម្បិ តំ គម្ភីរំ ។ ឥតិ តានិ ទុទ្ទសត្តា គម្ភីរានិ[១៣៤] ។

“ដោយពិតហើយ ទុក្ខសច្ច ជាសភាវៈប្រាកដដោយការកើតឡើង សត្វលោករមែងពោលក្នុងខណៈប៉ះខូប់ដង្កត់ឈើ បន្ទាជាដើម ( ឱហ្ន៎ជាទុក្ខ ) សូម្បីសមុទយសច្ច ក៏ប្រាកដដោយការកើតឡើងដោយសេចក្ដីត្រូវការទំពារឬបរិភោគជាដើម ទាំង ២ យ៉ាងនេះជ្រាលជ្រៅដោយការចាក់ធ្លុះសភាវៈសច្ចៈទាំងនោះ ជ្រាលជ្រៅព្រោះដឹងច្បាស់បានលំបាកយ៉ាងនេះ” ។

ទុទ្ទសត្តាតិ អត្តនោ បវត្តិក្ខណវសេន បាកដានិបិ បកតិញា-

ញាណេន សភាវសរតោ ទុជ្ជំ អសក្កុណេយ្យត្តា គម្ភីរេនេវ ច ភាវនាញាណេន តត្តាបិ មគ្គកប្បត្តេន អរិយមគ្គញាណេនេវ យាថាវតោ បស្សិតព្វត្តា គម្ភីរានិ[១៣៦] ។

“ពាក្យថា ទុទ្ទសត្តា ( ព្រោះដឹងច្បាស់បានលំបាក ) មានន័យថា សច្ចៈពួកនោះ សូម្បីប្រាកដដោយខណៈដែលកើតឡើងក៏ជ្រាលជ្រៅ ព្រោះមិនអាចដឹងច្បាស់សភាវៈនិងកិច្ច ដោយបញ្ញាប្រក្រតីទេ តែគួរដឹងច្បាស់តាមសភាវៈពិតដោយភាវនាបញ្ញាដែលជ្រាលជ្រៅ ព្រមដោយមគ្គញាណដ៏ប្រសើរដែលចាស់ក្លាហើយ” ។

សច្ចៈ ២យ៉ាងក្រោយនោះ មិនបានកើតឡើងដល់បុថុជ្ជន ទើបជាសភាពដ៏ជ្រាលជ្រៅ ដែលបុថុជ្ជនមិនអាចទទួលដឹងបានដោយប្រចក្ស អ្នកដែលចាប់ផ្តើមចំរើនវិបស្សនា ទើបបានបង្អោនចិត្តទៅក្នុងសច្ចៈទាំងនោះ តមកកាលបដិបត្តិតាមលំដាប់វិបស្សនាញាណ រហូតដល់ញាណទី ៤ ដែលហៅថា ឧទយព្វយញ្ញាណ គឺ ញាណដែលឃើញការកើតរលត់ ក្នុងខណៈខ្វះអាចអនុមានដឹងហេតុផលដែលជាប់តគ្នាថា ខន្ធ ៥ មានហេតុមកអំពីអវិជ្ជា តណ្ហា កម្ម

អាហារ ផស្សៈនិងរូបនាម បើមិនមានអវិជ្ជាជាដើមទេ ខន្ធ ៥ ក៏កើតឡើងមិនបានដែរ ការបន្ទុះភយញាណ គឺ ញាណឃើញសង្ខារថា ជារបស់គួរខ្លាចជាដើមទៅ ហើយក៏អាចអនុមានដឹងថា គ្រប់ខណៈដែលមានការឃើញ បានឮ ។ល។ ក៏នៅមានការក្តៅក្រហាយចិត្តដោយទុក្ខក្នុងវដ្ដៈ សេចក្តីស្ងប់យ៉ាងពិតប្រាកដ រមែងមិនកើតឡើង តមកកាលសភាវធម៌ទាំងនោះអស់ទៅ សេចក្តីស្ងប់ទើបកើតឡើងបាន សមពិតដូចសេចក្តីក្នុងគម្ពីរបដិសម្ភិទាមគ្គថា

ឧប្បាទោ ភយំ ។ អនុប្បាទោ ខេមន្តិ អភិញ្ញេយ្យំ[១៣៧] ។

“គប្បីដឹងច្បាស់ថា ការកើតជាភ័យ ការមិនកើតជាសេចក្តីក្សេម” ។

ក្រៅពីនេះ កាលសម្រេចញាណទី ៩ ដែលហៅថា មុច្ចតុកម្យតាញាណ គឺញាណដឹងច្បាស់ដែលត្រូវការទីងរួចផុតអំពីសង្ខារ អ្នកបដិបត្តិកន្លែងខ្លះ អាចមិនត្រូវការទីងតាមដឹងបច្ចុប្បន្ន ព្រោះដឹងខ្លួនថា សភាវធម៌គ្រប់យ៉ាងមិនមែនវត្ថុដែលល្អស្អាតគួរស្រឡាញ់ទេ សូម្បីគេទីងបានកំណត់ដឹងរូបនាម ក៏អាចទទួលដឹងរូបនាមបានឯង

ដោយកម្លាំងវិបស្សនា ដែលសន្សំមករហូតដល់លំដាប់នេះ តមក គេនឹងអនុមានដឹងព្រះនិព្វានថា រូបនាមមិនបានរលត់ទៅដោយការ មិនធ្វើទុកក្នុងចិត្តតាមដឹង តែរលត់ទៅមិនមានសេសសល់ដោយ ការដឹងព្រះនិព្វានជាអារម្មណ៍ ហើយគេនឹងព្យាយាមបដិបត្តិដើម្បី ការចាក់ធ្លុះព្រះនិព្វានតទៅ អ្នកបដិបត្តិរមែងទទួលដឹងសច្ចៈទាំង ៤ ដោយប្រការដូច្នេះ ។

ដោយហេតុដែលទុក្ខសច្ចនោះ គឺជាធម៌ដែលគួរកំណត់ដឹង ( **បរិញ្ញេយ្យៈ** ) សមុទយសច្ច ជាធម៌ដែលគួរលះបង់ ( **បហាតព្វៈ** ) និរោធសច្ច ជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ( **សច្ឆិកាតព្វៈ** ) និង មគ្គសច្ច ជាធម៌ដែលគួរធ្វើឲ្យចំរើនឡើងក្នុងក្រសែចិត្តរបស់ខ្លួន ( **ភាវេតព្វៈ** ) កាលអ្នកបដិបត្តិចំរើនសតិរលឹកដឹងនាមរូប បច្ចុប្បន្នរហូតឃើញការកើតរលត់ហើយ រមែងបានឈ្មោះថា ជា អ្នកចំរើនអរិយសច្ចទាំង ៤ ពោលគឺ

- ការកំណត់ដឹងរូបនាម ជាបរិញ្ញាកិច្ច គឺ ការកំណត់ដឹង

ទុក្ខសច្ច ។

- ការលះបង់សេចក្តីភ្លើតភ្លើនត្រេកអរក្នុងរូបនាម ដែលទទួលដឹងដោយសតិ បហានកិច្ច គឺ ការលះបង់សមុទយសច្ច ។

- ការមិនកើតឡើងនៃតណ្ហា ឧបាទាន កម្ម និងរូបនាមដែលជាផលកម្ម ដោយការកំណត់ដឹងបច្ចុប្បន្ន ជាសច្ឆិកិរិយាកិច្ច គឺការធ្វើនិរោធសច្ច ឲ្យជាក់ច្បាស់ ការរលត់តណ្ហាជាដើមដូចដែលពោល ចាត់ជាការរលត់មួយខណៈដោយវិបស្សនា ដែលហៅថាតទង្គនិរោធ កាលបន្ទុះអរិយមគ្គយ៉ាងពិតប្រាកដ ទើបទើងទទួលដឹងការរលត់របស់រូបនាមទាំងពួងដោយប្រចក្សបាន ។

- ការឃើញលក្ខណៈពិសេសរបស់រូបនាម តែម្យ៉ាង និងលក្ខណៈទូទៅគឺ ត្រៃលក្ខណ៍ ចាត់ជាសម្មាទិដ្ឋិ, សេចក្តីត្រិះរិះត្រូវជាសម្មាសង្កប្បៈ,ការព្យាយាមត្រូវ ជាសម្មាវាយាមៈ, ការអប់រំត្រូវជាសម្មាសតិ, ការតម្កល់ចិត្តដោយប្រពៃ ជាសម្មាសមាធិ, ការមិនកន្លងល្មើសផ្លូវវាចាមានការនិយាយកុហកជាដើម ក្នុងខណៈបដិបត្តិធម៌ ជាសម្មាវាចា ការមិនកន្លងល្មើសផ្លូវកាយមានសម្លាប់សត្វ

ជាដើម ជាសម្មាកម្មន្តៈ, ការមិនកន្លងល្មើសផ្លូវកាយនិងវាចា ដែលជាប់ទាក់ទងជាមួយការចិញ្ចឹមជីវិត ជាសម្មាអាជីវៈ, ការចំរើនសតិរលឹកដឹងបច្ចុប្បន្ន ដែលប្រកបដោយអរិយមគ្គប្រកបដោយអង្គ ៨ នេះ ចាត់ជាភាវនាកិច្ច គឺ ការចំរើនមគ្គសច្ច ។

ម្យ៉ាងទៀត មគ្គសច្ចដែលជាលោកិយ រមែងប្រាកដដល់អ្នកបដិបត្តិដែលបន្ទុះឧទយព្វយញ្ញាណជាដើមហើយ ចំណែកមគ្គសច្ចដែលជាលោកុត្តរ រមែងប្រាកដដល់អ្នកដែលបន្ទុះមគ្គញាណ ដោយហេតុដូចដែលពោលមកនេះ អ្នកបដិបត្តិដែលចំរើនសតិប្បដ្ឋានរមែងបានឈ្មោះថា ជាអ្នកចំរើនអរិយសច្ច ៤ គ្រប់ ១ ខណៈដែលតាមដឹងទាន់រូបនាមបច្ចុប្បន្ន សមពិតដូចសាធកៈថា

**យញ្ចស្ស ឧទយព្វយទស្សនំ, មគ្គោវាយំ លោកិកោតិ មគ្គសច្ចំ បាកដំ ហោតិ[១៣៨] ។**

"ម្យ៉ាងទៀត កាលឃើញសភាវៈកើតរលត់របស់បុគ្គលនោះ ជាមគ្គផ្នែកលោកិយនោះឯង ដូច្នោះ មគ្គសច្ចទើបប្រាកដបាន" ។

**ញាយោ វុច្ចតិ អរិយោ អដ្ឋង្គិកោ មគ្គោ ។ តស្ស អធិគមាយ**

បត្តិយាតិ វុត្តំ ហោតិ, អយញ្ហិ បុព្វភាគោ លោកិយោ សតិបដ្ឋា-នមគ្គោ ភាវិតោ លោកុត្តរមគ្គស្ស អធិគមាយ សំវត្តតិ[១៣៩] ។

“អរិយមគ្គមានអង្គ ៨ ឈ្មោះថា ញាយៈ សេចក្ដីនេះ ក៏គឺ ដើម្បីបន្ទុះអរិយមគ្គនោះ ពិតហើយ ផ្លូវនៃការចំរើនសតិប្បដ្ឋាន ដែលជាលោកិយៈ ក្នុងខាងដើមកាលបុគ្គលបំពេញហើយ រមែង ប្រព្រឹត្តទៅដើម្បីការបន្ទុះមគ្គដែលជាលោកុត្តរ” ។

ក្នុងខណៈកើតមគ្គញាណដែលទទួលដឹងព្រះនិព្វាន ដែលជា សភាពរលត់រូបនាមទាំងអស់នោះ អ្នកបដិបត្តិនឹងឃើញការកើត រលត់របស់រូបនាមទាំងអស់ សូម្បីថា គេនឹងមិនបានទទួលយក រូបនាម ដែលជាទុក្ខសច្ចជាអារម្មណ៍ ក៏ចាត់ថា បានកំណត់ដឹង ទុក្ខសច្ចដូចគ្នា ប្រៀបដូចបុរសម្នាក់មកអំពីទីក្ដៅខ្លាំង គេមកកាន់ ទីដែលមានក្ដៅតិចជាង រមែងសម្គាល់ថា ជាទីត្រជាក់ កាលទៅ កាន់ទីត្រជាក់ជាង ក៏នឹងសម្គាល់ថា ទីថ្មីត្រជាក់ជាងខាងដើម តមក កាលទៅកាន់ទីត្រជាក់បំផុត ក៏នឹងសម្គាល់ទីថ្មីថា ត្រជាក់ជាង ខាងដើមទាំង ២ កន្លែង អ្នកដែលមិនបានចំរើនវិបស្សនា រមែង

សំគាល់ខុសក្នុងរូបនាមទាំងអស់ ស៊ើរទុក្ខវេទនាថា ល្អស្អាតមាន ខ្លឹមសារ ចំណែកអ្នកដែលចម្រើនវិបស្សនា រមែងសម្គាល់ថា រូបនាម មិនល្អស្អាត វិបស្សនាទើបជាខ្លឹមសាររបស់អ្នកបដិបត្តិ តមកកាលគេ សម្រេចមគ្គញាណទទួលយកព្រះនិព្វានជាអារម្មណ៍ ទើបយល់ថា ព្រះនិព្វាន មានសភាពសុខស្ងប់ក្រៃលែង និងជាខ្លឹមសារដ៏ខ្ពស់ បំផុតក្នុងព្រះសាសនានេះ ។

បុថុជ្ជនទូទៅសូម្បីនឹងពិចារណាថា រូបនាមមិនទៀង ជាទុក្ខ មិនមែនតួខ្លួនតាមដែលធ្លាប់សិក្សាមកពីមុន ក៏រមែងសង្ស័យស៊ុក ស៊ើរចិត្ត តែព្រះសោតាបន្នអ្នកលះសក្កាយទិដ្ឋិ គឺការឃើញខុសក្នុង តួខ្លួនហើយ រមែងមិនប្រកាន់មាំរូបនាមថា ទៀង ជាសុខ មាន តួខ្លួន សូម្បីលោកនឹងខ្វល់ខ្វាយ ដើម្បីឲ្យបានទទួលសេចក្ដីសុខ ក៏នឹងមិនធ្វើបាបដែលជាហេតុឲ្យធ្លាក់អបាយ ការលះតណ្ហារបស់ ព្រះអរិយបុគ្គលតែក្នុងមួយលំដាប់ មានការបែកផ្សេងគ្នាដូចតទៅ នេះ

-ព្រះសោតាបន្នលះតណ្ហា ដែលជាហេតុឲ្យកើតកម្មអាក្រក់

-ញ៉ាំងផលឲ្យកើតក្នុងអបាយ

និងតណ្ហាដែលកើតកើនក្នុងភពច្រើន

ជាង ៧ ជាតិក្នុងកាមភូមិ ។

- ព្រះសកទាគាមី លះបង់កាមតណ្ហាយ៉ាងគ្រោតគ្រាត និង

តណ្ហា ដែលកើតកើនក្នុងភពច្រើនជាង ២ ជាតិ ។

- ព្រះអនាគាមី លះបង់កាមតណ្ហាយ៉ាងល្អិត ។

- ព្រះអរហន្ត លះបង់តណ្ហាដែលត្រេកអរក្នុងរូបឈាន និង

អរូបឈាន ព្រមទាំងរូបភពនិងអរូបភព លោកដូចជាមនុស្សកំសត់

ដែលមានទ្រព្យជាសេដ្ឋី និងបានទទួលរាជាភិសេក តមកទើបមិន

ត្រេកអរក្នុងកិលេស ដែលដូចជាមួយមនុស្សកំសត់ ។

និរោធសច្ច គឺ ព្រះនិព្វានដែលប្រចក្សដល់អ្នកបដិបត្តិនោះ

មានសភាពស្ងប់រលត់រូបនាម សង្ខារទាំងអស់ រមែងប្រាកដដោយ

សេចក្តីជាសភាពដែលមិនប្រែប្រួល និងប្រាសចាកនិមិត្តសណ្ឋាន

ដូចសេចក្តីដែលពោលដល់ព្រះនិព្វាន[១៤០]ថា

- មានលក្ខណៈស្ងប់ពីរូបនាម ខន្ធ ៥ ( *សន្តិលក្ខណំ* ) ។

- មានកិច្ចមិនច្យុតិ ( *អច្ចុតរសំ* ) ។

- មិនមាននិមិត្តជាគ្រឿងប្រាកដ ( *អនិមិត្តបច្ចុបដ្ឋានំ* ) ។

អ្នកបដិបត្តិដែលប្រាថ្នានឹងឃើញអរិយសច្ច ៤ សម្រេចធម៌ជាព្រះអរិយបុគ្គល គប្បីចំរើនវិបស្សនា ដែលប្រកបដោយសម្មាទិដ្ឋិជាដើម ដែលជាលោកិយមុនសិន តមកទើបនឹងបន្ទុះមគ្គសច្ចដែលជាលោកុត្តរក្នុងកាលជាខាងក្រោយ ព្រោះវិបស្សនាតាំងអំពីញាណដំបូងរហូតដល់អនុលោមញាណ ជាឧបនិស្សយបច្ច័យញ៉ាំងឲ្យកើតមគ្គសច្ច ដែលជាលោកុត្តរបន្ទាប់អំពីអរិយមគ្គមានអង្គ ៨ ដែលប្រាកដក្នុងមគ្គចិត្ត មិនអាចកើតឡើងដោយប្រាសចាកវិបស្សនា មគ្គដែលជាលោកិយៈ ទើបជាផ្លូវលេត់ទុក្ខដូចគ្នា ដូចគម្ពីរវិសុទ្ធិមគ្គពោលថា

*តត្ថ បឋមមគ្គញាណំ តាវ សម្បាទេតុកាមេន អញ្ញំ កិញ្ចិ កាតព្វំ នាម នត្ថិ ។ យញ្ហិ អនេន កាតព្វំ, តំ អនុលោមាវសានំ វិបស្សនំ ឧប្បាទេន្តេន កតមេវ*[១៤១] ។

"ក្នុងបណ្តាមគ្គញាណពួកនោះ អ្នកដែលប្រាថ្នានឹងឲ្យសម្រេចមគ្គញាណដំបូង មិនគប្បីធ្វើយ៉ាងដទៃអំពីការចំរើនវិបស្សនា ព្រោះវត្ថុដែលគួរធ្វើនោះ ឈ្មោះថា បានធ្វើហើយដោយការចំរើនវិបស្សនាដែលមានអនុលោមញាណជាទីបំផុត" ។

ឯស លោកុត្តរោ អរិយោ អដ្ឋង្គិកោមគ្គោ, យោ សហ លោកិយេន មគ្គេន ទុក្ខនិរោធគាមិនីបដិបទាតិ សង្ខំ គតោ[១៤២] ។

"មគ្គនេះ គឺអរិយមគ្គមានអង្គ ៨ ដែលជាលោកុត្តរៈ និងមគ្គដែលជាលោកិយៈ រាប់ថាជាផ្លូវនៃសេចក្តីរលត់ទុក្ខ" ។

ក្នុងសំយុត្តនិកាយ សគាថវគ្គ មានសេចក្តីដែលពោលដល់ការចំរើនអរិយមគ្គមានអង្គ ៨ ដើម្បីលះកិលេសទុកថា

ឥធានន្ទ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ សម្មាសង្កប្បំ ភាវេតិ ។បេ។ សម្មាវាចំ ។បេ។ សម្មាកម្មន្តំ ។បេ។ សម្មាអាជីវំ ។បេ។ សម្មាវាយាមំ ។បេ។ សម្មាសតឹ ។បេ។ សម្មាសមាធឹ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។

ឯវំ ខោ អានន្ទ ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ ។ អរិយំ អដ្ឋង្គិកំ មគ្គំ ពហុលីករោតិ[១៤៣] ។

“ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ រមែងចំរើនសម្មាទិដ្ឋិដែល អាស្រ័យសេចក្តីស្ងាត់ចាកកិលេស អាស្រ័យការប្រាសចាកកិលេស អាស្រ័យការរលត់កិលេស បង្អោនទៅដើម្បីការលះបង់កិលេស ។ រមែងចំរើនសម្មាសង្កប្បៈ ។បេ។ រមែងចំរើនសម្មាវាចា ។បេ។ រមែងចំរើនសម្មាកម្មន្តៈ ។បេ។ រមែងចំរើនសម្មាអាជីវៈ ។បេ។ រមែងចំរើនសម្មាវាយាមៈ ។បេ។ រមែងចំរើនសម្មាសតិ ។បេ។ រមែងចំរើនសម្មាសមាធិ ដែលអាស្រ័យសេចក្តីស្ងាត់ចាកកិលេស អាស្រ័យការប្រាសចាកកិលេស អាស្រ័យសេចក្តីរលត់កិលេស បង្អោនទៅដើម្បីការលះបង់កិលេស ។

ម្នាលអានន្ទ ភិក្ខុមានមិត្តល្អ សំឡាញ់ល្អ មានចិត្តបង្អោនទៅក្នុងមនុស្សដែលល្អ រមែងចំរើនអរិយមគ្គមានអង្គ ៨ រមែងធ្វើនូវអរិយមគ្គមានអង្គ ៨ ឲ្យច្រើនបានយ៉ាងនេះ” ។

ក្នុងព្រះបាលីខាងដើមនេះ សម្មាទិដ្ឋិ គឺវិបស្សនាញាណ និង មគ្គញាណ សម្មាសង្កប្បៈ គឺ ការត្រិះរិះដែលកើតព្រមជាមួយ វិបស្សនាចិត្ត និងមគ្គចិត្ត សម្មាវាចា គឺ សភាវៈលះបង់មិច្ឆាវាចា ដែលជា**អនុស័យកិលេស** ( កិលេសដែលដេកសម្ងំ ) **បរិយុដ្ឋា-នកិលេស** ( កិលេសដែលរួបរឹតចិត្ត ) និង **វីតិក្កមកិលេស** ( កិលេសដែលកន្លងល្មើសផ្លូវកាយឬវាចា ) មិនមែនសំដៅដល់ការពោលវាចាក្នុងខណៈចំរើនវិបស្សនានិងមគ្គ សូម្បីសម្មាកម្មន្តៈ និងសម្មាអាជីវៈ ក៏មានន័យដូចគ្នា ។

សម្មាសតិ គឺ ការចំរើនសតិប្បដ្ឋាន ៤ ដែលទទួលដឹងសភាវធម៌បច្ចុប្បន្ន ដែលបានដល់កាយ វេទនា ចិត្តនិងសភាវធម៌។

សម្មាសមាធិ គឺ ខណិកសមាធិ ដែលមានកម្លាំងប្រៀបដូចឧបចារៈសមាធិក្នុងលំដាប់វិបស្សនាញាណ តាំងអំពីញាណដំបូងរហូតដល់អនុលោមញាណ និងមានកម្លាំងប្រៀបដូចបឋមឈានក្នុងលំដាប់មគ្គញាណ ។ ក្នុងគម្ពីរអដ្ឋកថា បានអធិប្បាយសេចក្ដីខាងដើមថា

វិវេកនិស្សិតន្តិ តទង្គវិវេកនិស្សិតំ សមុច្ឆេទវិវេកនិស្សិតំ និស្សរណវិវេកនិស្សិតញ្ច សម្មាទិដ្ឋឹ ភាវេតីតិ អយមត្ថោ វេទិតព្វោ ។ តថា ហិ អយំ អរិយមគ្គភាវនានុយុត្តោ យោគី វិបស្សនាក្ខណេ កិច្ចតោ តទង្គវិវេកនិស្សិតំ អជ្ឈាសយតោ និសរណវិវេកនិស្សិតំ, មគ្គកាលេ បន កិច្ចតោ សមុច្ឆេទវិវេកនិស្សិតំ អារម្មណតោ និស្សរណវិវេកនិស្សិតំ សម្មាទិដ្ឋឹ ភាវេតិ ។ ឯស នយោ វិរាគនិស្សិតាទីសុ ។ វិវេកត្ថា ឯវ ហិ វិរាគាទយោ[១៤៤]។

“គប្បីជ្រាបសេចក្តីនេះថា ភិក្ខុរមែងចំរើនសម្មាទិដ្ឋិ [វិបស្សនាញាណ និងមគ្គញាណ] ដែលអាស្រ័យសេចក្តីស្ងាត់ចាកកិលេសមួយខណៈ [ដោយវិបស្សនា] អាស្រ័យសេចក្តីស្ងាត់ចាកកិលេសដោយគ្មានសេសសល់ [ដោយមគ្គញាណ] និងអាស្រ័យសេចក្តីស្ងាត់ចាកកិលេស ដោយការរួចផុត [គឺព្រះនិព្វាន] នៅអធិប្បាយបានថា អ្នកបដិបត្តិដែលព្យាយាមចំរើនអរិយមគ្គនេះ រមែងចំរើនសម្មាទិដ្ឋិ ដែលអាស្រ័យការស្ងាត់អំពីកិលេសមួយខណៈ ដោយកិច្ច និងអាស្រ័យការស្ងាត់ចាកកិលេសដោយការរួចផុត ដោយ

អធ្យាស្រ័យក្នុងខណៈចំរើនវិបស្សនា តែក្នុងខណៈកើតមគ្គញាណ លោករមែងចំរើនសម្មាទិដ្ឋិ ដែលអាស្រ័យការស្ងាត់ចាកកិលេស ដោយមិនមានសេសសល់ ដោយកិច្ចនិងអាស្រ័យការស្ងាត់កិលេស ដោយការរួចផុតដោយសភាពជាអារម្មណ៍ គប្បីជ្រាបន័យនេះ ក្នុងសម្មាទិដ្ឋិ ដែលអាស្រ័យការប្រាសចាកកិលេសជាដើម ព្រោះការប្រាសចាកកិលេសជាដើម ក៏មានសេចក្តីដូចគ្នាជាមួយការស្ងាត់" ។

សេចក្តីស្ងាត់អំពីកិលេស ដែលហៅថា **វិវេក** មាន ៥ យ៉ាងគឺ ៖

១. **តទង្គវិវេក** សេចក្តីស្ងាត់ដោយហេតុនោះៗ ដែលកែតម្រូវគ្នា ដូចជាកាលអ្នកបដិបត្តិបន្ទុះវិបស្សនាញាណ តាំងអំពីកង្ខញាណ ដែលឃើញការកើតរលត់របស់រូបនាមជាដើមទៅ រមែងមិនកើតអនុស័យកិលេស ដែលដេកសម្ងំនៅក្នុងអារម្មណ៍ ( **អារម្មណានុស័យ** ) ដែលជួបឃើញក្នុងខណៈនោះ និងមិនកើតកិលេសលេចឡើងក្នុងចិត្ត ( **បរិយុដ្ឋានកិលេស** ) ព្រមទាំងកិលេសដែលកន្ទងល្មើសផ្លូវកាយនិងវាចា ( **វីតិក្កមកិលេស** ) ។

២. **វិក្ខម្ភនវិវេក** សេចក្តីស្ងាត់ចាកនីវរណៈ ដោយការគ្រប

សង្កត់ទុក ដោយកម្លាំងរបស់ឧបចារសមាធិ និងអប្បនាសមាធិ ។

៣. **សមុច្ឆេទវិវេក** សេចក្ដីស្ងាត់ចាកកិលេសដែលមិនមានសេសសល់ដោយលោកុត្តរមគ្គ ។

៤. **បដិបស្សទ្ធិវិវេក** សេចក្ដីស្ងាត់ចាកកិលេសដែលស្ងប់រម្ងាប់ដោយលោកុត្តរផល ។

៥. **និស្សរណវិវេក** សេចក្ដីស្ងាត់ចាកកិលេស ដែលរលាស់ចេញអំពីសង្ខារគឺព្រះនិព្វាន ។

ក្នុងខណៈសម្រេចមគ្គញាណ ដែលទទួលយកព្រះនិព្វានជាអារម្មណ៍នោះ វិរតិចេតសិក ៣ ដួង គឺ សម្មាវាចា សម្មាកម្មន្ត: និងសម្មាអាជីវៈ រមែងកើតឡើងព្រមគ្នាដោយលះបង់ទុច្ចរិតផ្លូវកាយនិងវាចាទាំងអស់ យ៉ាងណាក៏ដោយ ក្នុងខណៈបន្ទុះវិបស្សនាញាណវិរតិចេតសិក ក៏កើតឡើងបានដូចគ្នា តែមិនកើតព្រមគ្នា ដូចក្នុងខណៈបន្ទុះមគ្គ ដូចសេចក្ដីក្នុងគម្ពីរអដ្ឋកថាថា

សម្មាវាចាទយោ តយោ វិរតិយោ ហោន្តិ

ចេតនាទយោបិ ។ មគ្គក្ខណេ បន វិរតិយោ[១៤៤] ។

"[ក្នុងលោកិយៈ] មគ្គមានសម្មាវាចាជាដើម ៣ យ៉ាង ជាវិរតិចេតសិក [ដែលប្រកបបានមិនទៀងទាត់ និងប្រកបព្រមគ្នាមិនបាន] ឬជា ចេតនាចេតសិកជាដើមក៏បាន តែក្នុងខណៈបន្ទុះមគ្គជាវិរតិចេតសិកប៉ុណ្ណោះ ចេតសិកដែលប្រកបបានពិតប្រាកដ និងប្រកបព្រមគ្នាបានជានិច្ច]" ។

សេចក្តីនេះ មានន័យថា កាលបុគ្គលត្រូវការរក្សាសីល ក្នុងខណៈ វៀរចាកកាយទុច្ចរិត និងវចីទុច្ចរិត សម្មាវាចាជាដើមនោះចាត់ជាវិរតិចេតសិក សូម្បីក្នុងខណៈដែលបុគ្គលធ្វើសេចក្តីល្អផ្លូវកាយ វាចានិងចិត្ត សម្មាវាចាជាដើម ក៏ជាចេតនាចេតសិក ឬចិត្តដែលកើតព្រមជាមួយចេតនានោះ តែក្នុងខណៈបន្ទុះមគ្គ សម្មាវាចាជាដើម ចាត់ជាវិរតិចេតសិកដោយពិត ដោយហេតុនោះ សម្មាវាចាជាដើម ក្នុងខណៈចំរើនវិបស្សនា ទើបជាកុសលចិត ដែលប្រកបដោយចេតនាក្នុងការធ្វើសេចក្តីល្អ ដូចពាក្យអធិប្បាយនៅក្នុងគម្ពីរដីកាចារ្យថា

សិក្ខាបទវិភង្គេ វិរតិ ចេតនា សព្វេ សម្បយុត្តធម្មា ច

**សិក្ខាបទានីតិ វុត្តាតិ តត្ថ បធានានំ វិរតិចេតនានំ វសេន “វិរតិយោបិ ហោន្តិ ចេតនាយោបីតិ អាហ ។ មុសាវាទាទីហិ វិរមណកាលេ វា វិរតិយោ សុរាសិតាទិវាចាភាសនាទិកាលេ ច ចេតនាយោ យោចេតព្វា**[១៨៦] ។

“ព្រះសម្មាសម្ពុទ្ធត្រាស់ទុកក្នុងសិក្ខាបទវិភង្គ ( ពាក្យអធិប្បាយសិក្ខាបទ ) ថា សិក្ខាបទ គឺវិរតិចេតសិក ចេតនា និង សម្បយុត្តធម៌ទាំងពួង ដូច្នោះ ព្រះអដ្ឋកថាចារ្យទើបពោលថា **វិរតិយោបិ ហោន្តិ ចេតនាយោបិ** ( ជាវិរតិ ឬចេតនាចេតសិកជាដើម ) ដែលជាប់ទាក់ទងដោយវិរតិ និងចេតនា ដែលជាប្រធានក្នុងរឿងនោះ ។ ន័យម៉្យាងទៀត គប្បីប្រកបវិរតិចេតសិកក្នុងពេលវៀរចាក ការនិយាយកុហកជាដើម និងគប្បីប្រកបចេតនាចេតសិកក្នុងពេលនិយាយពាក្យសំដីដែលពិរោះជាដើម” ។

**ចតុសច្ចកម្មដ្ឋាន**

សរុបសេចក្តីថា អ្នកបដិបត្តិគប្បីតាមដឹងទុក្ខសច្ច និងសមុទយសច្ច ព្រមទាំងបំពេញនិរោធសច្ច និងមគ្គសច្ច ដោយការ

បង្អោនចិត្តទៅក្នុងធម៌ ដូចដែលពោលការបដិបត្តិធម៌ក្នុងលក្ខណៈនេះឈ្មោះថា ចតុសច្ចកម្មដ្ឋាន គឺកម្មដ្ឋានដែលធ្វើឲ្យចាក់ធ្លុះរហូតសច្ចៈ ៤ ជាកម្មដ្ឋានដែលញ៉ាំងប្រយោជន៍ឲ្យអ្នកបដិបត្តិសម្រេចមគ្គផលបាន ដូចសេចក្ដីថា

ចតុសច្ចប្បដិវេធាវហំ កម្មដ្ឋានំ ចតុសច្ចកម្មដ្ឋានំ ។ ចតុសច្ចំ វា ឧទ្ទិស បវត្តំ ភាវនាកម្មំ យោគិនោ សុខវិសេសានំ ឋានភូតន្តិ ចតុសច្ចកម្មដ្ឋានំ[១៤៧] ។

"ចតុសច្ចកម្មដ្ឋាន គឺ កម្មដ្ឋានដែលនាំការចាក់ធ្លុះរហូតសច្ចៈ ៤ មកឲ្យ ឬការនាដែលប្រព្រឹត្តទៅដែលជាប់តគ្នាដោយសច្ចៈ ៤ និងជាហេតុឲ្យបានទទួលនូវសេចក្ដីសុខដ៏វិសេស ទើបឈ្មោះថា ចតុសច្ចកម្មដ្ឋាន" ។

ពាក្យថា ចតុសច្ចកម្មដ្ឋាន មានសេចក្ដីតាមស័ព្ទ ២ ប្រការគឺ

១. កម្មដ្ឋានដែលនាំការចាក់ធ្លុះរហូតសច្ចៈ ៤ មកឲ្យ = ចតុសច្ចប្បដិវេធាវហំ កម្មដ្ឋានំ ចតុសច្ចកម្មដ្ឋានំ វិសេសនបុព្វបទ កម្មធារយសមាស ។

២. កម្មដ្ឋានដែលប្រព្រឹត្តទៅជាប់បន្ទាដោយសច្ចៈ៤ ចតុសច្ចំ វា ឧទ្ទិស្ស បវត្តំ កម្មដ្ឋានំ ចតុសច្ចកម្មដ្ឋានំ មជ្ឈលោបីទុតិយាតប្បុរិស-សមាស] ។

តត្ថ អស្សាសបស្សាសបរិគ្គាហិកា សតិ ទុក្ខសច្ចំ ។ តស្សា សមុដ្ឋាបិកា បុរិមតណ្ហា សមុទយសច្ចំ ។ ឧភិន្នំ អប្បវត្តិ និរោធសច្ចំ ទុក្ខបរិជាននោ សមុទយប្បជហនោ និរោធារម្មណោ អរិយមគ្គោ មគ្គសច្ចំ ។ ឯវំ ចតុសច្ចវសេន ឧស្សក្កិត្វា និព្វុតិំ បាបុណាតីតិ ឥទមេកស្ស អស្សាសបស្សាសវសេន អភិនិវិដ្ឋស្ស ភិក្ខុនោ យាវ អរហត្តា និយ្យានមុខំ[១៤៨] ។

“ក្នុងរឿងនោះ សតិដែលកំណត់ដឹងខ្យល់ដង្ហើមចូលចេញជា ទុក្ខសច្ច តណ្ហាក្នុងកាលមុនដែលបង្កឲ្យកើតសតិនោះជាសមុទយសច្ច សេចក្ដីរលត់របស់ទុក្ខសច្ច និងសមុទយសច្ចទាំងពីរ ជានិរោធសច្ច អរិយមគ្គកំណត់ដឹងទុក្ខ លះបង់សមុទយៈ និងមាននិរោធជា អារម្មណ៍ ជាមគ្គសច្ច ភិក្ខុខិតខំព្យាយាមដោយចតុសច្ចកម្មដ្ឋាន យ៉ាងនេះហើយ រមែងបន្លុះព្រះនិព្វាន ដូច្នោះ ខ្យល់ដង្ហើមចូលចេញ នេះ ទើបជាផ្លូវរួចផុតចាកទុក្ខ រហូតអរហត្តមគ្គរបស់ភិក្ខុមួយរូប

អ្នកកំណត់ដឹងខ្យល់ដង្ហើមចូលចេញ" ។

ភិក្ខុអ្នកចំរើនសតិតាមដឹងខ្យល់ដង្ហើមចូលចេញ ក្នុងអានាបានៈ គប្បីទទួលដឹងសភាវៈប៉ះខ្ទប់របស់ធាតុខ្យល់ត្រង់ចុងច្រមុះ ឬបបូរមាត់ខាងលើដោយកំណត់ថា "ចូលហ្ន៎" "ចេញហ្ន៎" សតិដូចពោលជាសតិក្នុងវិបស្សនា ដែលកើតឡើងមុននឹងសម្រេចមគ្គញាណទើបចាត់ជាមគ្គសច្ចដោយបរិយាយ តែជាទុក្ខសច្ចដោយត្រង់ ព្រោះតាមចតុសច្ចៈទេសនានេះ លោកសំដៅយកវិបស្សនា ដែលបង្កើតក្នុងខណៈសម្រេចមគ្គញាណប៉ុណ្ណោះ ដូចនោះ ទុក្ខសច្ចតាមន័យនោះ ទើបគ្របសង្កត់សតិ សម្បយុត្តធម៌ ( ចិត្តនិងចេតសិក ) ដែលកើតព្រមជាមួយសតិ រូបដែលជាទីអាស្រ័យកើតរបស់សតិនិងខ្យល់ដង្ហើមចូលចេញដែលជាអារម្មណ៍របស់សតិ ដោយពោលសតិទុកជាគោលសំខាន់ ។

សូម្បីសេចក្តីក្នុងមហាសតិប្បដ្ឋានសូត្រ និងអដ្ឋកថា ពោលដល់ការសម្រេចមគ្គផលបាន ដោយការចំរើនសតិប្បដ្ឋាន ៤ យ៉ាងណាមួយ៉ាង អ្នកបដិបត្តិអាចចំរើនសតិប្បដ្ឋានច្រើនយ៉ាងបានតាមសមគួរដល់អារម្មណ៍ដែលប្រាកដកច្បាស់ក្នុងខណៈតែមួយ ដូច

ព្រះពុទ្ធតម្រាស់ ដែលត្រាស់ដល់ព្រះឧត្តិយៈដូច្នេះថា "គប្បីចំរើនសតិប្បដ្ឋាន ៤ ក្រៅពីនេះ អ្នកបដិបត្តិគប្បីចម្រើនកម្មដ្ឋានយ៉ាងណាមួយ៉ាងជាគោល ដែលហៅថា មូលកម្មដ្ឋាន និងអាចចម្រើនកម្មដ្ឋានដទៃបានតាមសមគួរ ម្យ៉ាងទៀត សូម្បីនឹងមិនមានសេចក្តីបញ្ជាក់ទុកយ៉ាងជាក់ច្បាស់ថា បុគ្គលណា គួរចំរើសតិប្បដ្ឋានប្រភេទណា តែអ្នកបដិបត្តិគួរចំរើនកាយានុបស្សនាជាគោល ព្រោះការតាមដឹងរូបធម៌ ងាយជាងការតាមដឹងនាមធម៌" ។

[ រូបធម៌មានសភាពប្រែប្រួល និងជាក់ច្បាស់ដល់បុគ្គលទូទៅ. អ្នកបដិបត្តិទើបគួរតាមដឹងរូបធម៌ជាគោល កាលសមាធិតាំងមាំហើយ នាមធម៌ក៏នឹងច្បាស់ឯង ដូចស្រមោលកញ្ចក់ដែលបានខាត់ពណ៌ល្អហើយ រមែងនឹងឃើញស្រមោលបានច្បាស់ ដូចសេចក្តីក្នុងគម្ពីរវិសុទ្ធិមគ្គថា

សចេ បនស្ស តេន តេន មុខេន រូបំ បរិគ្គហេត្វា អរូបំ បរិគ្គណ្ហតោ សុខុមត្តា អរូបំ ន ឧបដ្ឋាតិ, តេន ធុរនិក្ខេបំ អកត្វា រូបមេវ បុនប្បុនំ សម្មសិតព្វំ មនសិកាតព្វំ បរិគ្គហេតព្វំ វវត្ថបេតព្វំ ។ យថា យថា ហិស្ស រូបំ សុវិក្ខាលិតំ ហោតិ និជ្ជដំ សុបរិសុទ្ធំ, តថា តថា តទារម្មណា អរូបធម្មា សយមេវ បាកដា ហោន្តិ[១៥០] ។

"ម្យ៉ាងទៀត បើអ្នកបដិបត្តិនោះ កំណត់រូបតាមន័យនោះៗ ហើយកំពុងកំណត់នាម នាមរមែងមិនប្រាកដ ព្រោះជាសភាពសុខុម យើងមិនគប្បីចាក់ធុះ តែគួរកំណត់ធ្វើទុកក្នុងចិត្តតាមដឹង សំគាល់ដឹងរូបរឿយ ៗ ព្រោះនាមដែលមានរូបនោះជាអារម្មណ៍ រមែងប្រាកដឯង កាលរូបបានប្រចក្សច្បាស់ស្អាតបរិសុទ្ធល្អដល់យើងហើយ"]·ឃ

## ២ អានិសង្សនៃការចំរើនសតិប្បដ្ឋាន

អ្នកដែលចំរើនសតិប្បដ្ឋាន តាមសតិប្បដ្ឋានទេសនានេះ រមែងសម្រេចមគ្គផលនិងនិព្វាន ជាព្រះអរហន្ត ជាអ្នកលះកិលេសបានដោយមិនមានសេសសល់ អាចរម្ងាប់ការសោយសោកនិងការរួញរាលត់ទុក្ខផ្លូវកាយនិងទោមនស្សផ្លូវចិត្តក្នុងភពនេះ ដើម្បីបាននិព្វានហើយក៏មិនវិលស្លាប់វិលកើតក្នុងភពថ្មី បានទទួលទុក្ខនិងទោមនស្សទៀត លោកជាអ្នកសម្រេចមគ្គញាណ ៤ គឺសោតាបត្តិមគ្គញាណ សកទាគាមិមគ្គញាណ អនាគាមិមគ្គញាណ និងអរហត្តមគ្គញាណ ព្រមទាំងដឹងច្បាស់ព្រះនិព្វាន ដែលជាសភាពរលត់ទុក្ខទាំងពួងសមពិតដូចព្រះពុទ្ធវចនក្នុងមហាសតិប្បដ្ឋានសូត្រថា

*ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ, យទិទំ ចត្តារោ សតិប្បដ្ឋានា*[១៤១] ។

"ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវតែមួយដែលនឹងធ្វើឲ្យពួកសត្វបរិសុទ្ធបាន កន្លងផុតសេចក្ដីសោក និងសេចក្ដីយំសោករៀបរាប់បាន រលត់ទុក្ខនិងទោមនស្សបាន សម្រេចអរិយមគ្គ និងឃើញច្បាស់ព្រះនិព្វានបាន ផ្លូវនេះ គឺសតិប្បដ្ឋាន ៤ ប្រការ" ។

ការចំរើនសតិប្បដ្ឋាននេះ ជាផ្លូវមួយ ដើម្បីជម្រះកិលេសដឹងច្បាស់ព្រះនិព្វាន ដូចនោះ អ្នកដែលចំរើនសតិប្បដ្ឋានដោយការកំណត់ដឹងកងរូប វេទនា ចិត្តនិងសភាវធម៌ដែលជាបរមត្ថសុទ្ធ ៗ ទើបអាចសម្រេចចំណុចប្រាថ្នាក្នុងការបដិបត្តិធម៌គឺ ការរួចផុតអំពីវដ្តសង្សារបាន ម្យ៉ាងទៀត ការចំរើនសតិប្បដ្ឋាន អាចហៅថា **វិបស្សនាភាវនា** ( ការចំរើនវិបស្សនា ) **ចតុសច្ចកម្មដ្ឋាន** ( កម្មដ្ឋានដែលធ្វើឲ្យបាក់ធ្លុះសច្ចៈ៤ ) និង **បុព្វភាគមគ្គ** ( ផ្លូវខាងដើមក្នុងការសម្រេចលោកុត្តរធម៌ ) ក្រៅពីនេះ ការចម្រើនភាវនាដទៃដើម្បី

សម្រេចព្រះនិព្វាន ដែលប្រាកដក្នុងព្រះសូត្រផ្សេងៗ ដូចការចំរើនសម្មប្បធាន ការចំរើនឥន្ទ្រិយ៍ ការចំរើនពោជ្ឈង្គៈ និងការចំរើនអដ្ឋមគ្គជាដើម ក៏រាប់ចូលក្នុងការចំរើនសតិប្បដ្ឋាន ព្រោះសតិជាគោលសំខាន់ ប្រសិនប្រាសចាកសតិហើយ អ្នកបដិបត្តិមិនអាចចម្រើនធម៌យ៉ាងដទៃបាន ដូចពាក្យអធិប្បាយក្នុងគម្ពីរដីកា និងអដ្ឋកថាថា

ឯកាយនោ អយំ ភិក្ខវេ មគ្គោតិ ឯត្ថ ឯកមគ្គោ អយំ ភិក្ខវេ មគ្គោ ។ ន ទ្វិធា បថភូតោតិ ឯវមត្ថោ ទដ្ឋព្វោ[១៥២] ។

"ក្នុងព្រះតម្រាស់ថា ឯកាយនោ អយំ ភិក្ខវេ មគ្គោ ( ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវតែមួយ ) នេះមានន័យថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋាននេះជាផ្លូវតែមួយ មិនមែនផ្លូវបែកជា ២" ។

ឯកមគ្គោតិ ឯកោ ឯវ មគ្គោ, ន ហិ និព្វានគាមិមគ្គោ អញ្ញោ អត្ថីតិ ។ ននុ សតិប្បដ្ឋានំ ឥធ មគ្គោតិ អធិប្បេតំ ។ តទញ្ញោ ច ពហូ មគ្គធម្មា អត្ថីតិ ។ សច្ចំ អត្ថិ ។ តេ បន សតិប្បដ្ឋានគ្គហណេនេវ គហិតា តទវិនាភាវតោ ។ តថា ហិ ញាណវីរិយាទយោទ និទ្ទេសេ គហិតា ។ ឧទ្ទេសេ បន សតិយា

ឯវ គហណំ វេនេយ្យជ្ឈាសយវសេនាតិ ទដ្ឋព្វំ ។ ន ទ្វិធា បថភូតោតិ ឥមិនា ឥមស្ស មគ្គស្ស អនេកមគ្គភាវការំ វិយ អនិព្វានគាមិភាវការញ្ច ទស្សេតិ[១៤៣] ។

"ពាក្យថា ឯកមគ្គោ ប្រែថា ផ្លូវមួយប៉ុណ្ណោះ ព្រោះមិនមានផ្លូវដទៃ ដែលនឹងធ្វើឲ្យសម្រេចព្រះនិព្វានបាន ។

សួរថា : ព្រះអង្គប្រាថ្នាយកសតិប្បដ្ឋានជាផ្លូវតែ ១ ក្នុងទីនេះ តែធម៌ដែលជាផ្លូវដទៃក្រៅពីនោះ នៅមានច្រើនមិនមែនឬ ?

ឆ្លើយថា : នៅមានពិត តែធម៌ទាំងនោះពោលទុក [ដោយបរិយាយ] ដោយពាក្យថា សតិប្បដ្ឋាន ព្រោះកើតព្រមជាមួយសតិនោះ ដូចនោះ ក្នុងនិទ្ទេស ទើបត្រាស់ដល់បញ្ញានិងវីរិយៈជាដើម តែក្នុងឧទ្ទេស បានត្រាស់សតិទុកតែម្យ៉ាងតាមអធ្យាស្រ័យរបស់វេនេយ្យជន ។

ពាក្យថា ន ទ្វិធា បថភូតោ ( មិនមែនផ្លូវបែកជា ២ )នេះ សម្តែងថា ផ្លូវដូចពោលមិនមានច្រើនផ្លូវ និងជាផ្លូវដែលនឹងធ្វើឲ្យសម្រេចនិព្វានយ៉ាងពិតប្រាកដ" ។

ដូច្នេះ ព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអរហន្តសាវ័ក

ទាំងអស់ សុទ្ធតែចំរើនសតិប្បដ្ឋាន ហើយកើតបញ្ញាដឹងច្បាស់ជាអ្នកអស់កិលេសដោយមិនមានសេសសល់ អ្នកខ្លះស្តាប់គាថា ១ បទហើយសម្រេចធម៌ជាព្រះអរិយបុគ្គល ដោយការចំរើនសតិរឭកដឹងសភាវធម៌ក្នុងខណៈស្តាប់ធម៌នោះឯង សតិប្បដ្ឋានទេសនា ទើបជាផ្លូវដែលព្រះសម្មាសម្ពុទ្ធជាដើមទ្រង់យាងទៅហើយ ។

បុគ្គលអ្នកមានបញ្ញាថ្នាក់កណ្តាលចំរើនសតិប្បដ្ឋានយ៉ាងណាម្យ៉ាង ក្នុង ២១ ពួកហើយ រមែងអាចសម្រេចធម៌ជាព្រះអរហន្តឬព្រះអនាគាមី បានខាងក្នុង ៧ ឆ្នាំ រហូតដល់ ៧ ថ្ងៃ ដូចពាក្យបដិញ្ញាដែលព្រះបរមសាស្តាត្រាស់ទុកថា

**យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ សត្តវស្សានិ, តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា**[១៨៤] ។

“ម្នាលភិក្ខុទាំងឡាយ អ្នកណាម្នាក់គប្បីចំរើនសតិប្បដ្ឋានទាំង ៤ នេះ យ៉ាងនេះរហូត ៧ ឆ្នាំ គេគប្បីសង្ឃឹមផល ២ ប្រការយ៉ាងណាម្យ៉ាងគឺ សម្រេចអរហត្តផលក្នុងបច្ចុប្បន្ន ឬអនាគាមិផលកាលនៅមានខន្ធ” ។

ម្យ៉ាងទៀត ក្នុងពោធិរាជកុមារសូត្រ ព្រះបរមសាស្តាត្រាស់ដល់ការសម្រេចធម៌ខាងក្នុងមួយថ្ងៃ ឬមួយយប់របស់វេនេយ្យជនអ្នកមានបញ្ញាចាស់ក្លាថា

**ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតោ ភិក្ខុ តថាគតំ នាយកំ លភមានោ សាយមនុសិដ្ឋោ បាតោ វិសេសំ អធិគមិស្សតិ ។ បាតោ អនុសិដ្ឋោ សាយំ វិសេសំ អធិគមិស្សតិ[១៥៥]។**

"ភិក្ខុអ្នកព្យាយាមព្រមដោយអង្គគុណ ដែលព្យាយាមបដិបត្តិធម៌ ៥ប្រការនេះ កាលបានទទួលអ្នកណែនាំជាព្រះតថាគតប្រៀនប្រដៅក្នុងពេលព្រលប់ នឹងសម្រេចគុណធម៌វិសេសក្នុងពេលព្រឹក កាលប្រៀនប្រដៅក្នុងពេលព្រឹក នឹងសម្រេចគុណធម៌វិសេសក្នុងពេលព្រលប់" ។

អង្គគុណដែលព្យាយាមបដិធម៌ហៅថា **បធានិយង្គៈ** មាន ៥ ប្រការគឺ

១. មានការជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ វិបស្សនាចារ្យ និងផ្លូវក្នុងការបដិបត្តិ ។

២. មានសុខភាពល្អ មានភ្លើងធាតុរំលាយអាហារបានងាយ ។

៣. មិនបិតបាំងទោសរបស់ខ្លួនដល់គ្រូអាចារ្យនិងសព្រហ្មចារី ។

៤. មានការព្យាយាមដែលមានអង្គ ៤ គឺ ការព្រមឲ្យរាងកាយនៅសល់ត្រឹមស្បែក សរសៃ ឆ្អឹង និងការព្រមឲ្យឈាមស្បែកក្នុងរាងកាយហួតហែងទៅ ។

៥. កើតបញ្ញាឃើញការកើតរលត់របស់រូបនាម ។

ពាក្យទទួលរងក្នុងការសម្រេចធម៌ខាងដើម ជាព្រះតម្រាស់របស់ព្រះពុទ្ធអង្គ អ្នកត្រាស់ដឹងធម៌ទាំងពួងដោយព្រះអង្គឯង និងជាអ្នកត្រាស់ល្អតាមព្រះនាមថា ព្រះសុគត ទើបមិនខុសអំពីសេចក្ដីពិត ដូចសេចក្ដីក្នុងគម្ពីរពុទ្ធវង្សថា

អទ្វេជ្ឈវចនា ពុទ្ធា អមោឃវចនា ជិនា[១៩៦] ។

"ព្រះពុទ្ធទាំងឡាយមានព្រះវាចាពិតប្រាកដ ព្រះជិនស្រីទាំងឡាយមិនមានព្រះវាចាឥតខ្លឹមសារ" ។

ដោយហេតុនេះ អ្នកបដិបត្តិទើបគួរជឿមាំព្រះពុទ្ធតម្រាស់នោះ ហើយព្យាមយាមចំរើនសតិប្បដ្ឋាន ដើម្បីសម្រេចធម៌ដែលជាទីពឹងរបស់យើងទាំងឡាយចុះ ។

**"ចប់ បរិច្ឆេទទី ៤"**

ចប់វិសុទ្ធិមគ្គ ភាគទី ២

បរិច្ឆេទ សូមអនុមោទនា !!! ៗ

៨ កើត ខែមាឃ ឆ្នាំកុរ នព្វស័ក

ពុទ្ធសករាជ ២៥៥១

## លេខយោងអត្ថ

### លេខយោងបរិច្ឆេទទី ១

(១) វិសុទ្ធិ. ២. ២៥០

(២) ទី. សី. ៩. ១៩៣. ៦៣

(៣) វិសុទ្ធិ. ១. ៣១

(៤) វិសុទ្ធិ. ១. ៤៥

(៥) វិសុទ្ធិ. ដី. ១. ៨៥

(៦) វិសុទ្ធិ. ដី. ១. ៨៧

(៧) ខុ. ធ. ២៥. ២៤០.៥៩ ឬបិដកខ្មែរ ៥២.៧២

(៨) អំ. អ. ១. ៦០

(៩) វិ.មហាវិ. ២.៥០. ២៣៦

(១០) វិ. មហាវិ. ២. ២៥០. ២៣៦

(១១) វិសុទ្ធិ. ដី. ១. ៣៥

(១២) សំ. អ. ៣. ៣០៤

(១៣) វិសុទ្ធិ. ១. ៤៤

(១៤) ម. ម. ១៣.១២. ៩

(១៥) វិសុទ្ធិ. ១. ២១

(១៦) វិសុទ្ធិ. ដី. ១. ៥៧

(១៧) ខុ. ឧ. ២៥. ១០. ១០១

(១៨) វិសុទ្ធិ. ១. ២១

(១៩) វិសុទ្ធិ. ១. ២២

(២០) វិសុទ្ធិ. ១. ៧

(២១) មូលដី. ១. ២២៦

(២២) វិសុទ្ធិ. ដី. ១. ៥៨

(២៣) វិសុទ្ធិ. ១. ៧

(២៤) ម. ម. ១៣. ១២. ៩

(២៥) វិសុទ្ធិ. ១.៧- ៨

(២៦) វិសុទ្ធិ. ១. ៨

(២៧) ខុ. ចូឡ. ៣០. ៤. ៣២

(២៨) វិសុទ្ធិ. ១. ៨

(២៩) វិសុទ្ធិ. ១. ៨

(៣០) ទី. មហា. ១០. ៤០២. ២៣០

(៣១) វិសុទ្ធិ. ១. ៨

(៣២) អភិ. អ. ១. ១២២

(៣៣) អភិ. អ. ២. ២៩៤

(៣៤) ខុ. ចូឡ. ៣០. ១៨. ៦៨

(៣៥) សុត្តនិ. អ. ២. ៣២២

(៣៦) វិសុទ្ធិ. ១. ២២

(៣៧) ម. អ. ២. ៩

(៣៨) ខុ. សុ. ២៥. ១១០៦. ៥៤៥ ឬបិដកខ្មែរ ៥៤. ៣១៦

(៣៩) ទី. អ. ២. ៣៦២

(៤០) សំ. មហា. ១៩. ៣៨២. ១៤៤

(៤១) អភិ. អ. ២.៣៥៥- ៥៦

(៤២) កង្ខា. នវដី. ១៣៥

(៤៣) ខុ. ធ. ២៥. ២៧០. ៦៣ ឬបិដកខ្មែរ ៥២. ៧៧

(៤៤) ធម្ម. អ. ៧. ៥៥

(៤៥) ខុ. ធ. ២៥.៦៣. ២៨ ឬបិដកខ្មែរ ៥២. ៣៤

(៤៦) សំ. មហា. ១៩. ១០២០. ៣២៥

(៤៧) . សំ. មហា. ១៩.១០២១.៣២៧

(៤៨) សំ. មហា. ១៩.១០២១.៣២៧

(៤៩) សំ.មហា.១៩.១០២១.៣២៧

(៥០) អភិ. បុ.៣៦. ១៥០. ១៥២

(៥១) នេត្តិ. អ. ២១៣

(៥២) ម. អ. ១. ៣១៨

(៥៣) ធម្ម. អ. ៤. ៩០

(៥៤) ធម្ម. អ. ៤. ៩១

(៥៥) ខុ. ធ. ២៥. ១០០. ៣៥ ឬបិដកខ្មែរ ៥២. ៤៣

(៥៦) ម. អ. ២. ៨

(៥៧) ម. ម. ១៣. ៦. ៥

(៥៨) ខុ. បដិ. ៣១. ៤១. ៤៧

(៥៩) វិសុទ្ធិ. ១.៨

(៦០) វិសុទ្ធិ. ១. ៥៣

(៦១) អំ. ឯក. ២០. ៥៣. ៩

(៦២) អំ. ឯក. ២០. ៣៩០- ៩៣. ៤១

(៦៣) អំ. អ. ១. ៦១

(៦៤) អំ. អ. ១. ៦២- ៦៣

(៦៥) វិសុទ្ធិ. ដី. ១. ១៥

(៦៦) សំ. ស. ១៥. ២៣. ១៦

## លេខយោងបរិច្ឆេទទី ២

(១) វិសុទ្ធិ. ១. ១៣៧

(២) វិសុទ្ធិ. ២. ២៥០

(៣) ម. ដី. ១. ២៥៧

(៤) វិសុទ្ធិ. ២. ២៥០

(៥) ទី. អ. ២. ៣៨៨

(៦) វិសុទ្ធិ. ដី. ២. ៣៨៦-៨៧

(៧) វិសុទ្ធិ. ដី. ១. ១៧

(៨) សំ. ស. ១៥.២៣,១៩២.១៦,១៩៨

(៩) វិសុទ្ធិ. ១.៣

(១០) ម. អ. ១.១១៧

(១១) ម. ដី. ១.២៥៦

(១២) ខុ. បដិ. ៣១.១.២

(១៣) ម. អ. ១.១១៨

(១៤) ម. ដី. ១.២៥៧

(១៥) អំ. អ. ២. ៣៩១

(១៦) ខុ. បដិ. ៣១.១៥៨.១៧៩

(១៧) វិសុទ្ធិ. ២.៣១៧

(១៨) វិសុទ្ធិ. ២.៣០៤

(១៩) ម. ម. ១៣.៣៣៤.៣២៨

(២០) ខុ. បដិ. ៣១.៥១.៤៨

(២១) អភិ. អ. ១.៤១០, ម. អ. ១.២៤. សំ. អ. ២. ២៧៨

(២២) វិសុទ្ធិ. ដី. ១.៤០៩

(២៣) វិសុទ្ធិ. ១. ៣១៤

(២៤) ខុ. បដិ. ៣១.៤.៣១១

(២៥) ខុ. បដិ. ៣១.៥.៣១១, ខុ. បដិ. ៣១.៦.៣១៥

(២៦) ខុ. បដិ. ៣១.១៥.១៧៤

(២៧) ឥតិវុត្ត. អ. ៣៩៤.

(២៨) ម. ខ. ១៤.៣០៧.២៨៥

(២៩) ម. ដី. ៣.៤៥៧

(៣០) ម. ដី. ២.៣៣០

(៣១) ខុ. បដិ. ៣១.

(៣២) ខុ. បដិ. ៣១.១៥៣.១៧៤

(៣៣) ខុ. បដិ. ៣១.១៥៣.១៧៤

(៣៤) ខុ. បដិ. ៣១.១៥៣.១៧៤

(៣៥) ខុ. បដិ. ៣១.១៥៣.១៧៤

(៣៦) នេត្តិ. អ. ៩៨

(៣៧) ម. មូ. ១២.២៥១២១៣

(៣៨) ខុ. បដិ. ៣១.១៥៣.១៧៤

(៣៩) វិសុទ្ធិ. ដី. ២.២៤

(៤០) អភិ. អ. ១.៣០៦

(៤១) ខុ. បដិ. ៣១.១៥៣.១៧៤

(៤២) វិសុទ្ធិ. ដី. ២.១៨

(៤៣) វិ. ប. ៨. ៣៦៦.៣៤៤

(៤៤) ខុ. ធ. ២៥.៣៧៤.៨២

(៤៥) ខុ. ធ. ២៥.១៧៤.៤៧ ឬបិដកខ្មែរ ៥២. ៥៨

(៤៦) ធម្ម. អ. ៦.៤៣

(៤៧) ខុ. បដិ. ៣១.១៥៣.១៧៤

(៤៨) ខុ. ធ. ២៥.៤៣.២៤ ឬបិដកខ្មែរ ៥២. ៣០

(៤៩) អំ. ឯក. ២០.៤២.៧

(៥០) ធម្ម. អ. ៦.២៦

(៥១) ខុ. ធ. ២៥.១៦៦.៤៦ ឬបិដកខ្មែរ ៥២. ៥៧

(៥២) ធម្ម. អ. ៦.២៦

(៥៣) ទី. មហា. ១០.១៩៩.១២១ ឬបិដកខ្មែរ ១៦. ២៩០

(៥៤) ទី. អ. ២.១៨៣

(៥៥) ម. មូ. ១២.២៩.១៧ ឬបិដកខ្មែរ ៥២. ៧៨

(៥៦) ខុ. ធ.២៥.២៧១.៦៣ ខុ. ខុ. ធម្មដ្ឋវគ្គ ទំ. ៧៨

(៥៧) ម. មូ. ១២.២១៦.១៨៣

(៥៨) វិសុទ្ធិ. ១.១០២

(៥៩) ម. មូ. ១២.២១៨.១៨៤

(៦០) ម. អ. ១.៤១៨

(៦១) ម. មូ. ១២.២២០.១៨៥

(៦២) សំ. អ. ៣.២៧៩-៨០

(៦៣) ទី. អ. ២.៤០១

(៦៤) ខុ. បដិ. ៣១.១៥៨.១៧៨

(៦៥) ខុ. បដិ. ៣១.១៥៨.១៧៩

(៦៦) ខុ. បដិ. ៣១.១៥៨.១៧៨

(៦៧) ខុ. ធ. ២៥.៣៧១.៨១ ឬបិដកខ្មែរ ៥២. ១០០

(៦៨) ម. មូ. ១២.៦៥.៤៣

(៦៩) វិសុទ្ធិ. ១.៣៩

(៧០) អំ. អ. ១.៣១

(៧១) សំ. និ. ១៦.២២.២៩

(៧២) ខុ. បដិ. ៣១.១៥៨.១៧៨

(៧៣) ខុ. បដិ. ៣១.១៥៨.១៧៨

(៧៤) ខុ. បដិ. ៣១.១៥៨.១៧៨

(៧៥) ខុ. បដិ. ៣១.១៥៨.១៧៩

លេខយោងបរិច្ឆេទទី ៣

(១) សង្គហ. ដី. ៦៦

(២) អភិ. អ. ៣.១២៩, មូលដី. ៣. ៥៥

(៣) អភិ. អ. ៣.១២៩

(៤) អភិ. អ. ៣.១៣០

(៥) មូលដី. ១.៨៩

(៦) មូលដី. ៣.៥៥

(៧) អនុដី. ៣.៦៨

(៨) វិសុទ្ធិ. ២.២៥២

(៩) ទី. ដី. ២.៤៣០

(១០) វិសុទ្ធិ. ២.៣៨៩

(១១) វិសុទ្ធិ. ២.២៧៦

(១២) វិសុទ្ធិ. ដី. ២.៣៨៩

(១៣) អភិ. អ. ១.២១១

(១៤) សង្គហ. ដី. ទំព័រ ១១១

(១៥) ឥតិវុត្ត. អ. ២៣៨

(១៦) អភិ. ប. ៤០.៤០៦.១២៤

(១៧) ទី. មហា. ១០.៣៧៤.២៦០

(១៨) ម. ដី. ៣.៣២៦

(១៩) ម. ដី. ៣.៣២៦

(២០) វិសុទ្ធិ. ដី. ២.៤០៦

(២១) ម. ឧ. ១៤.២៧២.២៤១ ប្អូបិដកខ្មែរលេខ ២៨. ៧

(២២) វិសុទ្ធិ. ២.៧០

(២៣) នេត្តិ. អ. ២៥៩

(២៤) វិសុទ្ធិ. ២.៧០

(២៥) វិសុទ្ធិ. ដី. ២.៧៣

(២៦) ទី. មហា. ១០.៣៧៥.២៧០

(២៧) ទី. មហា. ១០.៣៨០.២៦៥

(២៨) ទី. មហា. ១០.៣៨២.២៦៦-៦៧

(២៩) ទី. មហា. ១០.៣៨១.២៦៦

(៣០) ទី. អ. ២.៣៩១

(៣១) ទុ. បដិ. ៣១.៤៨.៥៤

(៣២) អភិ. អ. ៣.២៨៥

(៣៣) អភិ. អ. ៣.២៨៥

(៣៤) អំ. នវក. ២៣.៣៦.៣៤៧

(៣៥) វិសុទ្ធិ. ២.២៥០

(៣៦) ម. ដី. ៣.២៦៩

(៣៧) វិសុទ្ធិ. ដី. ២.៥១៩

(៣៨) ទី. ដី. ២.៣៧៦

(៣៩) វិសុទ្ធិ. ដី. ២.៥១៩

(៤០) ទី. ដី. ២.៣៧៦

(៤១) វិសុទ្ធិ. ១.៣១៣

(៤២) ទី. អ. ២.៣៩៧

(៤៣) ម. ឧ. ១៤.១៤៩.១៣៤

(៤៤) ម. ឧ. ៤.១០០

(៤៥) អភិ. ធ. ៣៤.៥៩៥.១៨១

(៤៦) ម. អ. ២.១៦៨-៦៩

(៤៧) អំ. អ. ៣.៣៩២-៩៣

(៤៨) វិសុទ្ធិ. ១.៣០០

(៤៩) វិសុទ្ធិ. ដី. ២.៤៤១

(៥០) ម. ដី. ៣.៣២៦

(៥១) ទី. ដី. ២.៣៧៦

(៥២) ម. អ. ១.៥៧

(៥៣) សំ. សឡា. ១៨.២៤៥.១៨០

(៥៤) សំ. សឡា. ១៨.២៤៥.១៨០

(៥៥) សំ. សឡា. ១៨.២៤៥.១៨០

(៥៦) សំ. សឡា. ១៨.២៤៥.១៨០

(៥៧) សំ. សឡា. ១៨.២៤៥.១៨១

(៥៨) សំ. សឡា. ១៨.២៤៥.១៨២

(៥៩) ម. ឧ. ១៤. ៩៣. ៧៧

(៦០) ម. អ. ៤.៥៨

(៦១) ខុ. បដិ. ៣១.៥១.៥៨

(៦២) វិសុទ្ធិ. ២.២៩៦

(៦៣) ម. អ. ៤.៥៨-៩

(៦៤) ម. អ. ៣.២៥៩

(៦៥) ម. អ. ៤.៦០

(៦៦) ម. ដី. ៣.៣៣០

(៦៧) ម. ឧ. ១៤.៩៥.៨០

(៦៨) ម. អ. ៤.៦១-២

(៦៩) ម. មូ. ១២.៨៣.៥៨

# លេខយោងបរិច្ឆេទទី ៤

(១) វិសុទ្ធិ. ដី. ១.៣១៦

(២) វិសុទ្ធិ. ដី. ១.៥៣៧

(៣) សង្គហ. ៦១

(៤) វិសុទ្ធិ. ១.៤៣៣

(៥) ទី. មហា. ១០.៣៨៤.២៦៩

(៦) ទី. អ. ២.៣៩៩

(៧) សំ. សឡា. ១៨.៤៦.២៦

(៨) មូលដី. ២.១៣៣, វិសុទ្ធិ. ដី. ២.៣៦០

(៩) សំ. អ. ៣-៥

(១០) វិសុទ្ធិ. ២-២៩៣

(១១) វិសុទ្ធិ. ដី. ២.៤៥៣

(១២) សំ. សឡា. ១៨.៤៦.២៦

(១៣) សំ. សឡា. ១៨.៤.២៦

(១៤) វិសុទ្ធិ. ដី. ២.៤២៧

(១៥) វិសុទ្ធិ. ដី. ២-៥៦១

(១៦) ខុ. បដិ. ៣១.៥១.៥៩

(១៧) ខុ. ឧ. ២៥.១០.១០១

(១៨) ឧទាន. អ. ៩៤

(១៩) ឧទាន. អ. ៩៥

(២០) សំ. សឡា. ១៨.៩៥.៧០

(២១) សំ. សឡា. ១៨.៩៥.៧០

(២២) សំ. សឡា. ១៨.៩៥.៧០-១

(២៣) សំ. សឡា. ១៨.៩៥.៧១

(២៤) សំ. ខ. ១៧.៤៣.៣៦

(២៥) ឧទាន. អ. ៩៥

(២៦) ឧទាន. អ. ៩៨

(២៧) សំ. សឡា. ១៨.៩៥.៧១

(២៨) សំ. សឡា. ១៨.៩៥.៧១

(២៩) សំ. សឡា. ១៨.៩៥.៧០

(៣០) សំ. ខ. ១៧.១០១.១២១

(៣១) សំ. អ. ៣.១១៤

(៣២) ម. អ. ២.១៣៣

(៣៣) អំ. បញ្ចក. ២២.១៤៤.១៥៩

(៣៤) អំ. អ. ៣.៥៦

(៣៥) ទី. អ. ២.៤០១, ម. អ. ១.៣០៦

(៣៦) ទី. ដី. ២.៤០៦, ម. ដី. ១. ៤៥

(៣៧) ម. អ. ២.១៣៤

(៣៨) ម. ឧ. ១៤.៤៥៣.៣៨៩

(៣៩) ម. ឧ. ១៩.៤៥៣.៣៨៩

(៤០) ម. មូ. ១២. ២៩៥.២៦១

(៤១) ខុ. ធ. ២៥.២៨២.៦៥ ឬបិដកខ្មែរ ៥២. ៨០

(៤២) ធម្ម. អ. ៧.៧៣

(៤៣) វិសុទ្ធិ. ២-២៥៥

(៤៤) វិសុទ្ធិ. ដី. ២.៣៩៣

(៤៥) ទី. អ. ២.៣៣៧

(៤៦) សំ. អ. ៣. ៧

(៤៧) សំ. អ. ២. ១២៧

(៤៨) សំ. អ. ២.១២៩

(៤៩) ម. ឧ. ១៤.២២៥.១១២

(៥០) ម. អ. ៤.៧២

(៥១) អកិ. អ. ១.៣៩១

(៥២) ទី. មហា. ១០.៣៤.២៥៩

(៥៣) ទី. មហា. ១០.៣៤.២៦០

(៥៤) ទី. មហា. ១០.៣៤.២៦២

(៥៥) ទី. មហា. ១០.៣៤.២៦០-១

(៥៦) ម. ម. ១៣.១៧៧.៩៣

(៥៧) ទី. មហា. ១០.៣៤.២៦០

(៥៨) ទី. អ. ២.៣៨១

(៥៩) ទី. អ. ២.៣៨១

(៦០) ទី. អ. ១.១៧៤

(៦១) ទី. ដី. ១.៣០១, ម. ដី.១.៤៤៦

(៦២) ទី. ដី. ១.៣០១-២, ម. ដី. ១.៤៤៦

(៦៣) ទី. ដី. ១.៣០២, ម. ដី. ១. ៤៤៦

(៦៤) វិសុទ្ធិ. ២.២៩០

(៦៥) មូលដី. ៣. ១៩៨

(៦៦) ទី. ដី. ១.៣០២

(៦៧) វិសុទ្ធិ. ២.២៩០

(៦៨) អភិ. អ. ២.៣៨៩

(៦៩) ទី. មហា. ១០.៣៦.២៦១

(៧០) ទី. មហា. ១០.៣៦.២៦១

(៧១) ទី. អ. ១.១៧៥

(៧២) ទី. មហា. ១០.៣៦.២៦១

(៧៣) ទី. មហា. ១០.៣៦.២៦១

(៧៤) ទី. មហា. ១០.៣៦.២៦១

(៧៥) ទី. អ. ១.១៨១

(៧៦) ទី. មហា. ១០.៣៦.២៦១

(៧៧) ទី. មហា. ១០.៣៦.២៦១

(៧៨) ទី. មហា. ១០.៣៦.២៦១

(៧៩) ទី. មហា. ១០.៣៦.២៦១

(៨០) ទី. អ. ២.៥៨

(៨១) ទី. មហា. ១០.៣៦.២៦១

(៨២) ទី. មហា. ១០.៣៨០.២៦៥

(៨៣) ទី. អ. ២.៣៨៨

(៨៤) ម. អ. ២.២៧៧

(៨៥) ទី. អ. ៣.១៨៧

(៨៦) ម. អ. ៣.៧២

(៨៧) ទី. អ. ២.៣៣៩, ម. អ. ១.២៩៤

(៨៨) ទី. ដី. ២.៣២៦

(៨៩) ទី. មហា. ១០.៣៨០.២៦៥

(៩០) ម. ឧ. ១៤.៣០៦.២៨៤-៨៥

(៩១) ទី. មហា. ១០.៣៨០.២៦៥

(៩២) ទី. អ. ២.៣៤៣

(៩៣) ទី. ដី. ២.៣៣៣

(៩៤) ទី. មហា. ១០.៣៨០.២៦៥

(៩៥) ទី. មហា. ១០.៣៨០.២៦៥

(៩៦) ទី. មហា. ១០.៣៨១.២៦៦

(៩៧) ទី. មហា. ១០.៣៨១.២៦៦

(៩៨) ទី. អ. ២.៣៩១

(៩៩) ទី. មហា. ១០.៣៨១.២៦៦

(១០០) ទី. មហា. ១០.៣៨១.២៦៦

(១០១) ទី. មហា. ១០.៣៨១.២៦៦

(១០២) ទី. មហា. ១០.៣៨២.២៦៦-៦៧

(១០៣) ទី. អ. ២.២៥៤

(១០៤) ទី. ដី. ២.៤០៧

(១០៥) ទី. អ. ២.៣៩២

(១០៦) ទី. មហា. ១០.៣៨២.២៦៧

(១០៧) ទី. មហា. ១០.៣៨២.២៦៧

(១០៨) ទី. មហា. ១០.៣៨៣.២៦៨

(១០៩) ទី. អ. ២.៣៩៨

(១១០) ទី. មហា. ១០.៣៨៤.២៦៩

(១១១) ទី. មហា. ១០.៣៨៤.២៦៩

(១១២) វិ. មហាវិ. ២.៥០៨.១៩

(១១៣) អភិ. អ. ១.១៧១, ម. អ.១.៩១

(១១៤) ខុ. ធ. ២៥. ៣៥៤.៧៨

(១១៥) ទី. មហា. ១០.៣៨៥.២៧១

(១១៦) ទី. មហា. ១០.៣៨៥.២៧១, ទី. មហា. ១០.៤០២.២៧៩

(១១៧) សំ. សឡា. ១៨.២៥៩.២០២, ទី. អ. ២.៤១៧

(១១៨) ទី. មហា. ១០.៣៨៧.២៧៣, ទី. ដី. ២.៤៣០

(១១៩) ទី. មហា. ១០.៤០០.២៧៥

(១២០) ទី. មហា. ១០.៤០១.២៧៧

(១២១) ទី. មហា. ១០.៣៨១.២៦៦, បដិសំ. អ: ១.៦៨

(១២២) ទី. មហា. ១០.៣៨១.២៦៦, វិសុទ្ធិ. ដី. ២. ៤៩៥

(១២៣) វិ. មហា. ៤.១៤.១៤

(១២៤) ទី. អ. ២.៤១៧

(១២៥) ទី. ដី. ២.៤២១

(១២៦) ទី. មហា. ១០.៣៨៦.២៧៣

(១២៧) ទី. អ. ២.៤១២

(១២៨) ទី. ដី. ២.៤២១

(១២៩) ទី. មហា. ១០.៣៧៤.២៦០

(១៣០) សំ. ស. ១៥.១០៧.៧៤, អំ. ចតុក្ក.២១.៤៥.៥៣

(១៣១) សំ. អ. ១.១១២, អំ. អ. ២.៣៤៥

(១៣២) ទី. ដី. ២.៤៣៧

(១៣៣) អភិ. ធ. ៣៤.២០.៤

(១៣៤) ទី. អ. ២.៤១២

(១៣៥) ទី. អ. ២.៤១៨

(១៣៦) ទី. ដី. ២.៤៣២

(១៣៧) ខុ. បដិ. ៣១.១០.១៥

(១៣៨) វិសុទ្ធិ. ២.៣០៣

(១៣៩) ទី. អ. ២.៣៦៥

(១៤០) អភិ. អ. ២. ៩១

(១៤១) វិសុទ្ធិ. ២.៣៥៣

(១៤២) អភិ. អ. ២.១៣០

(១៤៣) សំ. ស. ១៥.១២៩.១០៥

(១៤៤) សំ. អ. ១.១៥១

(១៤៥) សំ. អ. ១.១៥០

(១៤៦) មូលដី. ២.៨០

(១៤៧) ទី. ដី. ២.៤៣០

(១៤៨) ទី. អ. ២.៤៣០

(១៤៩) សំ. មហា. ១៩.៣៨២.១៤៤

(១៥០) វិសុទ្ធិ. ២.២៥៤

(១៥១) ទី. មហា. ១០.៤០៥.២៨២

(១៥២) ទី. អ. ២.៣៥៩

(១៥៣) ទី. ដី. ២.៣៤៩

(១៥៤) ទី. មហា. ១០.៤០៤.២៨១

(១៥៥) ម. ម. ១៣.៣៥៤.៣២៩

(១៥៦) ខុ. ពុទ្ធ. ៣៣.១០៩.៤៥៨

═══ : ═══ : ═══ : ═══

## ឈ្មោះអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ

១ ភិក្ខុអមរាកិលេស ថោង សីលា

២ ភិក្ខុសិក្ខានន្ទ លី សាភឌី

៣ ភិក្ខុសច្ចធរ រី សារ៉េន

៤ ភិក្ខុធម្មចេតិយ ពៅ ថេន

៥ ភិក្ខុជោតិតេ ស៊ុំ ជោតិ

៦ ភិក្ខុជោតិសម្បន្ន ណុប ណេង

៧ ភិក្ខុសាន់ រ៉ាត

៨ សាមណេរ យឿន ឃីម

៩ លោកគ្រូធម្មាចារ្យ រស់ សុផាត

១០ លោកគ្រូធម្មាចារ្យ ប៊ុន គឿន

១១ ឧបាសក ជីម ជំនិត

# ព្រះពុទ្ធជាមុនិ

**តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជ្ជិ មុនិ**
**អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវន្តិ ។**

ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វានដែលជាគុណជាតិថ្លឹងមិនបានផងនូវភពផង ទ្រង់លះបង់នូវសង្ខារដែលនាំសត្វទៅកាន់ភព ទ្រង់ត្រេកអរនូវអារម្មណ៍ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងមាំហើយ (ដោយអំណាចសមថៈ) ទ្រង់បានរំលាយនូវបណ្ដាញគឺកិលេស ដែលកើតមានទៅក្នុងខ្លួន ដូចជាក្រោះ ។

"បិដកលេខ១៦ មហាបរិនិព្វានសូត្រ"

សម្រាប់ចែកជាធម្មទាន...